១

# កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS ET COUTUMES

ទស្សនាវដ្ដី ផ្សាយខាងសាសនានិង អក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ៤៤ ខែ មករា

ព.ស. ២៥១៥ គ.ស. ១៩៧២

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : អ៊ុក - សាម៉ន

និពន្ធនាយក - អ្នករៀបចំ លី ធាម តេង

គណៈកម្មការនិពន្ធ:

ព្រះពោធិវង្ស ហួត-តាត

លោក ផល-ទិត អ្នកស្រី ពេជ-សល់

# បញ្ជីរឿង

អត្ថបទ　　　　　　　　　　　　　　　　　　　ទំព័រ

## ១– ផ្នែកសាសនា :


១- អបរិហានីយធម៌ ៧ យ៉ាង រៀបរៀងដោយ ព្រះពោធិវង្ស សូរ-ហាយ . . ១

២- ចតុរារិយសច្ច (ត) រៀបរៀងដោយព្រះភិក្ខុ ប៉ាង-ខាត់ . . . . ៧


## ២– ផ្នែកអក្សរសាស្ត្រ :


៣- រឿងសាមកុក . . . . . . . . . . . . . ១៥

៤- កុំស្ដាប់ឆ្លូចពស់របស់ដូចកង្កែប ( កំណាព្យ ) . . . . . . ២៧


## ៣- ផ្នែកកំណត់ប្រវត្តិការណ៍ :


៥- អនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃ លើកទី ២៨ ប្រចាំឆ្នាំ ១៩៧២

- សេចក្ដីរាយការរបស់លោក លី ធាម តេង . . . . . . . . ៣៦

៦- ឯកសារៈ ការស្រាវជ្រាវពីល្ខោនខ្មែរ . . . . . . . . . ៤០


---

## . តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ។

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

# អបរិហានិយធម៌ ៧ យ៉ាង

រៀបរៀងដោយ ព្រះពោធិវង្ស សួរ-ហាយ

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## អបរិហានិយធម៌ ៧ យ៉ាង គឺ

១– ឧស្សាហ៍ប្រជុំគ្នារឿយៗ ដើម្បីជជែកប្តូរយោបល់គ្នា,

២– ត្រូវព្រមព្រៀងគ្នាប្រជុំតាមកាលកំណត់ ដោយទៀងទាត់,

៣– មិនបញ្ញត្តឲ្យហួសព្រំដែនអំពីបទបញ្ញារបស់លក្ខន្តិកៈជាធរមាន,

៤– អ្នកណាជាមេ ឬជាប្រធាន ត្រូវគោរពជឿស្តាប់អ្នកនោះ,

៥– មិនលុះអំណាចនៃមហិច្ឆតា ដោយនាំឲ្យស្រវឹងពុលគំនិត,

៦– ត្រេកអរចំពោះប្រយោជន៍ជាសាធារណៈរបស់ជាតិ,

៧– ត្រូវតាំងចិត្តថា អ្នកណាជាអ្នកមានចិត្តត្រង់ចំពោះប្រយោជន៍ជាតិ និងជាអ្នកមានសីលធម៌ - សុជីវធម៌, ត្រូវសេពគប់កប់រក លើកតម្កើងអ្នកនោះ ឲ្យជាអ្នកដឹកនាំកិច្ចការតទៅ ។

## អធិប្បាយពង្រីកសេចក្តី

ពាក្យថា «អបរិហានិយធម៌» ប្រែថា «ធម៌មិនជាទីតាំងនៃសេចក្តី

វិនាស » គឺមានតែនាំឲ្យមានសេចក្តីចម្រើន ៗ ធម៌នេះ កាលបើបុគ្គល-បានអនុវត្តត្រឹមត្រូវហើយ រមែងនាំមកនូវសេចក្តីសុខ ចម្រើនដោយពិតពុំខាន ព្រោះអបរិហានិយធម៌ទាំង ៧ ប្រការ សុទ្ធតែជាមូលដ្ឋានដ៏ប្រ-សើរមួយដែលនាំឲ្យមានសាមគ្គីរវាងគ្នានឹងគ្នា ដោយរាប់ថាជាចំណងនៃសាមគ្គីធម៌មួយឲ្យរស់នៅជាប្រាកដ, កាលបើយើងមានសាមគ្គីគ្រប់គ្រាន់ដរាបណា សេចក្តីចម្រើននិងសេចក្តីសុខក៏អាចកើតមានដរាបនោះដែរ ៗ

ពាក្យថា « សាមគ្គី » ដែលយើងធ្លាប់ប្រែមកហើយថា « សេចក្តី-ព្រមព្រៀង » បានន័យថា «ការប្រស្រ័យទាក់ទង, ការយល់ឃើញស្របគ្នា, ការធ្វើ ការនិយាយ ក៏ត្រូវគ្នា, គោលគំនិតក៏ត្រូវគ្នា » ទាំងនេះហៅថា សាមគ្គី ៗ សាមគ្គី កាលបើមានបរិបូណ៌ក្នុងសង្គមណា ឬ ក្នុងក្រុមណា សេចក្តីចម្រើន និងសេចក្តីសុខ រមែងមានក្នុងសង្គមនោះ ឬ ក្រុមនោះ ដោយពិត ៗ

អបរិហានិយធម៌ ៧ ប្រការ ដែលត្រូវអធិប្បាយតទៅនេះ សុទ្ធតែជាធម៌អាចបណ្តុះបណ្តាលឲ្យកើតសាមគ្គីរវាងគ្នានិងគ្នាជាប្រាកដ ដែលអាចរាប់បញ្ចូលក្នុងអង្គការនៃកំណែនទូទៅ ៗ សាមគ្គីធម៌របស់សង្គមមនុស្សនាំឲ្យមានសេចក្តីចម្រើន-សេចក្តីសុខ យ៉ាងណា សូម្បីសាមគ្គីធម៌របស់ពួកសត្វតិរច្ឆាន ក៏នាំឲ្យមានសេចក្តីចម្រើន-សេចក្តីសុខរបស់វា ក៏យ៉ាងនោះដែរ ៗ

ព្រះសម្មាសម្ពុទ្ធទ្រង់សព្វព្រះទ័យសម្ដែងអំពីសាមគ្គីធម៌នេះជាញឹកញយណាស់ ហើយទ្រង់សរសើរថា « សាមគ្គី ជាកម្លាំងមួយដ៏រឹងប៉ឹងមាំមួនជាទីបំផុត អាចប្រព្រឹត្តទៅដើម្បីសេចក្ដីសុខ ចម្រើនរបស់ពួកក្រុមឃើញជាក់ច្បាស់ក្នុងបច្ចុប្បន្ននេះ ។ »

អបរិហានិយធម៌ ក៏ចាត់ជាផ្លូវបែរឈមត្រង់ទៅរកសេចក្ដីចម្រើន ដែលផ្ទុយគ្នានឹងសេចក្ដីវិនាស ដូចមានអធិប្បាយ ចំពោះធម៌ទាំង ៧ ប្រការនេះ ដោយមាតិកាធម៌មួយមួយ ៗ តរៀងទៅ :

ធម៌ទី ១- ឧស្សាហ៍ប្រជុំគ្នារឿយ ៗ ដើម្បីជជែកដេញដោលឈ្វេចឈ្វៀអំពីករណីយកិច្ចណាមួយ ដែលជាអង្គការរបស់រដ្ឋ ឬ របស់សាសនា ដើម្បីផ្ដូរយោបល់របស់គ្នាទៅវិញទៅមក ។ ការប្រជុំគ្នារឿយ ៗ ជាមូលហេតុមួយដែលនាំឲ្យបានទទួលដំណឹងជាមួយគ្នា, ឲ្យមានយោបល់ស្របគ្នា, មានគោលគំនិតត្រូវគ្នា ដោយហេតុតែបានឃើញគ្នា, ស្ដាប់សម្ដីគ្នាទៅវិញទៅមក ។ ជាពិសេស គឺ ការប្រជុំរឿយ ៗ នេះ ជាផលានិសង្សមួយ នាំឲ្យយើងជាសមាជិកនៃទីប្រជុំបានឃើញមុខគ្នា, ស្គាល់គ្នា, គោរពគ្នា ទៅវិញទៅមក និងបានជាមិត្តភាពជាប់ទាក់ទងរវាងគ្នានឹងគ្នាជាដរាបទៅ ។

ធម៌ទី ២- ប្រជុំគ្នា ត្រូវព្រមព្រៀងគ្នាប្រជុំ តាមកាលកំណត់ដ៏ទៀងទាត់ តាមគម្រោងរបស់គណៈកម្មការដែលបានចេញលិខិតនិមន្ត ឬ

អញ្ជើញ ចំពោះកាលបរិច្ឆេទដែលកំណត់ពេលវេលានោះហើយ ។ លុះប្រជុំជជែកដោះស្រាយបញ្ហាតាមរបៀបវារៈចប់ហើយ លើកលែងប្រជុំក៏ត្រូវព្រមព្រៀងគ្នា ចេញពីទីប្រជុំទាំងអស់គ្នា ។

ធម៌ទី ៣- មិនត្រូវបញ្ញត្តច្បាប់តែម្នាក់ ៗ ឯងឲ្យហួសព្រំដែនរបស់បទបញ្ញា ។ ពាក្យថា «ច្បាប់» ឬ «បញ្ញត្ត» ត្រូវបង្កើតឡើងដោយគណៈកម្មការ តាមមហាសន្និបាតជាដរាប គឺដោយសមាជិកភាគច្រើនយល់ព្រមផង មិនត្រូវលបលាក់បញ្ញត្តច្បាប់ ឬ ប្រកាន់យកតាមអស្មិមានះរបស់បុគ្គលម្នាក់ៗ នោះឡើយ ។

ធម៌ទី ៤- អ្នកណាជាមេ ឬជាប្រធាន ដោយសមាជិកភាគច្រើនយល់ព្រមហើយ, សមាជិកទីប្រជុំទាំងអស់ត្រូវតែគោរពជឿស្តាប់ចំពោះមេ ឬប្រធាននោះជាដរាប ។ សមាជិកនៃទីប្រជុំទាំងអស់ ត្រូវស្តាប់សេចក្តីថ្លែងការណ៍ ឬ សេចក្តីប្រកាស ដោយគោរពយកចិត្តទុកដាក់, មិនត្រូវជជែកគ្នាឲ្យឮឡូឡា ឬសើចក្អាកក្អាយ ដែលនាំឲ្យខាតដល់ទីប្រជុំនោះឡើយ គឺថា សមាជិកទីប្រជុំ ត្រូវរៀបចំទុកខ្លួនឲ្យនៅក្នុងវង្វង់នៃរបៀបវារៈរបស់ទីប្រជុំ មិនត្រូវធ្វេសប្រហែសភ្លេចស្មារតីឲ្យថ្វស់ព្លោយធ្លាក់ខ្លួនធ្លាយទៅក្រៅរបៀបវារៈនោះទេ ។

ធម៌ទី ៥- ក្នុងពេលប្រជុំ មិនត្រូវលុះអំណាចនៃមហិច្ឆតា គឺសេចក្តីប្រាថ្នាលោភលន់ហួសហេតុនោះទេ, ព្រោះថាសេចក្តីប្រាថ្នាប្រកបដោយ

លោភតណ្ហា របស់យើងជាបុថុជ្ជន តែងតែមានគ្រប់គ្នាមែនពិតហើយ ប៉ុន្តែ កាលបើចូលទៅកាន់ទីប្រជុំណាមួយ ត្រូវតែយកប្រាជ្ញាមកលាតត្រដាងពិចារណាក្នុងខ្លួនយើងគ្រប់ៗគ្នា ឲ្យឃើញច្បាស់ថា "ចិត្តរបស់អាត្មាអញដែលកំពុងប្រជុំនេះ តើមានលោភតណ្ហាក្នុងចិត្តក្រៀវក្លាយ៉ាងណា? ត្រូវយកប្រាជ្ញាទៅញាំញី គ្របសង្កត់ចិត្តនោះ កុំឲ្យលោភតណ្ហាជះជាន់បាន" ។ សមាជិកទីប្រជុំ កាលបើបណ្ដោយចិត្តឲ្យលុះលង់ខ្លាំង ទៅក្នុងលោភតណ្ហា ទោសៈ មោហៈ ពុះពោរឡើង បណ្ដាលឲ្យកាយវាចាកម្រើកញាប់ញ័រឲ្យអ្នកផងឃើញដឹងច្បាស់ជាប្រាកដពុំខាន ។ មនុស្សបែបនេះ បើកំពុងនិយាយ ក៏មិនមានសុជីវធម៌ល្អបានឡើយ ជាហេតុនាំឲ្យឃ្លាងចាកផ្លូវត្រូវ នឹងអាចរអិលធ្លាក់ទៅរកផ្លូវខុសពុំខាន ។

ធម៌ទី ៦- ត្រូវត្រេកអរ ត្រូវសប្បាយចិត្ត ចំពោះប្រយោជន៍របស់ជាតិ របស់សាសនា ។ ជាតិមនុស្សទាំងអស់ ក្នុងសកលលោក តែងត្រូវការសេចក្ដីសុខ-សេចក្ដីចម្រើនទាំងអស់ ដែលយើងហៅដោយខ្លីថា " សុភមង្គល " ។ ពាក្យនេះធំទូលាយណាស់ គឺសេចក្ដីសុខសន្តិភាព, សេចក្ដីចម្រើន, សេចក្ដីចុះចើនរុងរឿង នៃប្រទេសជាតិនិងសាសនារបស់ខ្លួនទាំងនេះ ជាទីចាប់អារម្មណ៍របស់ជាតិមនុស្សពន់ពេកណាស់ ដោយហេតុតែមនុស្សបុថុជ្ជន ក្នុងលោក តែងមានទីដៅចំពោះសុភមង្គលនេះគ្រប់ៗគ្នា ។ ករណីយកិច្ចរបស់សត្ថមនុស្ស សុទ្ធតែបែរមុខឆ្ពោះទៅរក

សុភមង្គលគ្រប់ៗគ្នាទាំងអស់ ព្រោះហេតុនោះ យើងទាំងអស់គ្នា ត្រូវមានឆន្ទៈខ្ពស់ជៅចំពោះមធ្យោបាយ ដើម្បីស្វែងរកប្រយោជន៍ក្នុងផ្លូវលោក ឬផ្លូវធម៌ ដោយបរិសុទ្ធ កុំឲ្យប៉ះពាល់ កុំឲ្យគ្របសង្កត់ជិះជាន់លើអ្នកដទៃ ដោយអំពើវៀចវេរលាក់កំណួចលួចគំនិតរបស់អ្នកដទៃ ។

**ធម៌ទី ៧-** ត្រូវតាំងចិត្តថា "លោកណា ជាអ្នកមានសីលធម៌-សុជីវធម៌ ស្មោះត្រង់ចំពោះជាតិសាសនា ត្រូវតែព្រមព្រៀងព្រួតគ្នាយកលោកនេះឲ្យជាអ្នកដឹកនាំប្រទេសជាតិនិងសាសនា ហើយត្រូវសេពគប់រាប់រក ទទួលស្គាល់ ស្មោះត្រង់ លើកតម្កើងលោកនោះ ហើយជួយឈឺឆ្អាលបំពេញកិច្ចការរបស់លោកនោះតរៀងទៅ" ដើម្បីឆ្ពោះទៅរកទីដៅរបស់យើង គឺការគ្រប់គ្រងថែទាំប្រទេសជាតិ ឲ្យគង់វង្សចម្រើនរុងរឿងជាស្ថាពរ កុំឲ្យធ្លាក់ចុះថោកទាប តាំងអំពីបច្ចុប្បន្នរហូតដល់អនាគត ។

លោកអ្នកដែលមានសមត្ថភាព មានចំណេះវិជ្ជាគ្រប់គ្រាន់ អាចដឹកនាំប្រទេសជាតិនិងសាសនាបាន ត្រូវធ្វើតាមគន្លងធម៌ដ៏បរិសុទ្ធ ដែលប្រជាជនបានលើកឡើងតាមផ្លូវការហើយ ត្រូវតែបំពេញបេសកកម្មរបស់ខ្លួន ឲ្យប្រកបដោយយុត្តិធម៌ ឲ្យឃើញជាក់ស្តែង មិនត្រូវឲ្យធ្លាក់ខ្លួនទៅក្នុងផ្លូវអយុត្តិធម៌ ឬ អគតិធម៌នោះឡើយ ។

អបរិហានីយធម៌ ចប់ ។

# ចតុរារិយសច្ច

(តមកពីឆ្នាំ ១៩៧១)

ភិក្ខុ ប៉ាង-ខាត់ រៀបរៀង

ង- ការប្រជុំធាតុគឺគ្រឿងដឹង "វិញ្ញាណក្ខន្ធ" (Agrégat de la Conscience) វិញ្ញាណគឺអ្វី? វិញ្ញាណ(១) ជាប្រតិកម្ម ឬជាចម្លើយមួយនៃឥន្ទ្រិយទាំង ៦ ប្រការ: ចក្ខុ សោត: ឃាន: ជិវ្ហា កាយ និងមន: ឬចិត្ត គឺជាធម្មជាតតែមួយ ដែលធ្វើឲ្យប្រាកដ ឬដែលជាធាតុកម្មខាងក្រៅ បានដល់អារម្មណ៍ខាងក្រៅ (Phénomènes extérieurs) ពោលគឺ រូប សទ្ទ គន្ធ រស កាយ និងធម្មារម្មណ៍ (មនោគតិ ឬគំនិត) ដូចជាចក្ខុវិញ្ញាណ (Conscience Visuelle) មានចិត្តជាអាយតនៈ មានរូបជាអារម្មណ៍,. . . មនោវិញ្ញាណ (Conscience mentale) មានចិត្តជាអាយតនៈ មានអារម្មណ៍របស់ចិត្ត គឺ មនោគតិ ឬ គំនិត (Idée ou Pensée) ដែលជាគូ "ធម្ម" ជាអារម្មណ៍ ដែលលោកហៅថា ធម្មារម្មណ៍ ។ ដូច្នេះ វិញ្ញាណនេះ ត្រូវអាស្រ័យនឹងឥន្ទ្រិយដទៃទៀតផង ទើបបានសម្រេចប្រយោជន៍ ដូចជាវេទនា និងសញ្ញា ឬ ចេតនាដែរ, វិញ្ញាណ(២) នេះក៏

---

១ – ទស្សនវិជ្ជាមហាយាន មានសេចក្ដីថា វិញ្ញាណនេះ មាន ៣ ប្រការគឺ ចិត្តឬមនះ, វិជ្ញាន និងអាលយ-វិជ្ញាន ជាធម៌មាននៅក្នុងវិញ្ញាណក្ខន្ធនេះ ។ អាលយ-វិជ្ញាននេះ គេច្រើនតែប្រែជាភាសាអង់គ្លេសថា "Store-consciounses" ឬ ជាបារាំងថា " Conscience-tréfonds" ។

២ – សំយុត្តនិកាយ ខន្ធវារវគ្គ សៀវភៅទី ៣៣ ទំព័រ ១៤០ ។

មាន ៦ ប្រការ ក្នុងការទាក់ទងជាមួយអាយតនៈខាងក្នុង ៦ ប្រការ និងអារម្មណ៍ខាងក្រៅ ៦ ប្រការ ។

សេចក្ដីនេះ យើងគប្បីយល់ថា វិញ្ញាណនេះ មិនចេះស្គាល់អារម្មណ៍ទេ គ្រាន់តែជាធម្មជាតជាគ្រឿងដឹងប៉ុណ្ណោះ (Acte d'attention, Awsreness) គឺគ្រឿងដឹងនូវធម្មារម្មណ៍ ក្នុងបច្ចុប្បន្ន ឧបមាថា កាលណាចក្ខុប៉ះពាល់ពណ៌ដូចជាពណ៌ខៀវ ខណៈនោះចក្ខុវិញ្ញាណកើតឡើង ហើយគ្រាន់តែបានដឹងថាពណ៌ក្នុងបច្ចុប្បន្នកាលប៉ុណ្ណោះទេ ប៉ុន្តែវិញ្ញាណមិនចេះស្គាល់ថា "ពណ៌នេះ" ជា "ខៀវ" ដូច្នេះឡើយ គឺវិញ្ញាណមិនមែនជានាទីត្រូវ "ស្គាល់" ឬ "ចាំ" ពណ៌ថា "ខៀវ" ទេ, ឯនាទីស្គាល់ថា ពណ៌ជា "ខៀវ" ជានាទីរបស់សញ្ញាទេតើ ដែលត្រូវស្គាល់ថានេះជាពណ៌ "ខៀវ" ។ ពាក្យថា "ចក្ខុវិញ្ញាណ" ជាពាក្យដែលលោកប្រើក្នុងទស្សនវិជ្ជាពុទ្ធសាសនា សម្រាប់គត់ចំណាំអ្វីមួយ ដូចជាពាក្យថា "ឃើញ" ។ ពាក្យថា "ឃើញ" នេះមិនមែនបានសេចក្ដីថា "ចាំ" ឬ "ស្គាល់" ទេ, នេះគឺគ្រាន់តែជាត្រូវ "វិញ្ញាណ" (ដឹងដោយឡែក) ប៉ុណ្ណោះទេ ។ ឯវិញ្ញាណដទៃទៀត ក៏មានន័យដូចគ្នាដែរ ។

មួយទៀត សេចក្ដីត្រង់នេះ គួរយើងបន្ថែមសេចក្ដីថា ទស្សនវិជ្ជាពុទ្ធសាសនានិយាយថា មិនមានអ្វីជាធម៌ទៀងទាត់ ជាធម៌មិនផ្លាស់ប្ដូរ ដែលគួរយើងនឹងយល់បានថា នេះជា "ឯង, អញ" ឬ "អាត្មា" ឬក៏អហង្ការ

(Ego) ដែលជាធម្មជាតិផ្សេងពីធាតុ គឺ Matter, Matière នោះទេ ហើយវិញ្ញាណនេះ ក៏យើងមិនគួរនឹងទុកថាជា Spirit ឬ Esprit ដែលជាធម្មជាតិផ្សេងពីធាតុ Matter ឬ Matière នោះដែរ, តែចំណុចត្រង់នេះសំ-ខាន់ណាស់ យើងត្រូវសង្កត់ពាក្យនេះឲ្យធ្ងន់ដោយពិសេសបន្តិច ព្រោះគេកត់សម្គាល់ខុសថា «វិញ្ញាណ» នេះ គឺគួ «អញ, ឯង» ឬ «អាត្មា» ជាតែមានសារៈទៀងទាត់ រៀងរហូតទៅ ហើយឋិតថេរចិរកាល តាំងពីបឋម-កាល មកដល់ក្នុងបច្ចុប្បន្នកាលនេះឯង ។

ក្នុងសម័យពុទ្ធកាល(១) សម័យមួយ កាលអង្គព្រះសម្ពុទ្ធទ្រង់សម្រេចសម្រាន្តព្រះឥរិយាបថ នៅក្នុងវត្តជេតពន ជាអារាមអនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី, កាលនោះ មានភិក្ខុ ១ រូប មានឈ្មោះប្រាកដថា សាតិកេវដ្ដបុត្ត ។ ភិក្ខុសាតិកេវដ្ដបុត្តនេះ មានសេចក្តីយល់ថា «វិញ្ញាណ ស្ទុះទៅ អន្ទោលទៅ មិនក្លាយទៅជាអ្វីដទៃឡើយ» បានសេចក្តីថា ភិក្ខុសាតិនេះយល់ថា រូប វេទនា សញ្ញា សង្ខារ រលត់អស់ទៅនៅក្នុងភពនេះ តែវិញ្ញាណមិនរលត់ទេ ស្ទុះទៅ អន្ទោលទៅ ពីលោកនេះ ទៅកាន់បរលោក ហើយវិលមកកាន់លោកនេះវិញ ដដែល ៗ សេចក្តីនេះ ជ្រាបដល់ព្រះកាណ៌អង្គព្រះសម្ពុទ្ធ ហើយទ្រង់ត្រាស់ឲ្យហៅភិក្ខុសាតិនេះមកសាកសួរ ៗ ទ្រង់ត្រាស់សួរថា «នែសាតិ! អ្នកយល់ថា វិញ្ញាណនេះ តើដូចម្ដេច ?

---

១ មជ្ឈិមនិកាយ មូលបណ្ណាសក មហាតណ្ហាសង្ខយសូត្រ សៀវភៅទី ២២ ទំព័រ ១៧២ ។

— សូមទ្រង់ព្រះមេត្តាប្រោស! សភាវៈណា និយាយបាន ទទួលអារម្មណ៍បាន បុគ្គលរមែងសោយវិបាកនៃកម្មល្អអាក្រក់បាន ដោយអាស្រ័យសភាវៈនោះ សភាវៈនោះ ហៅថា «វិញ្ញាណ» ។ ធម៌នេះព្រះមានព្រះភាគកាត់ទ្រង់បានសម្តែងហើយ ។

— នែមោឃៈ! អ្នកចេះធម៌នេះពីអ្នកណាមក? ម្តេចក៏អ្នកបង្អាប់តថាគតថាសម្តែងដូច្នេះវិញ, តថាគត តែងសម្តែងធម៌នេះ ដោយអនេកបរិយាយថា «វិញ្ញាណកើតឡើង ព្រោះអាស្រ័យបច្ច័យ, បើវៀរចាកបច្ច័យហើយ វិញ្ញាណមិនកើតឡើងទេ» ហេតុដូចម្តេច ក៏អ្នកពោលបង្អាប់តថាគតដោយទិដ្ឋិយល់ខុសរបស់ខ្លួនដូច្នេះ ?

តទៅ ព្រះសម្ពុទ្ធទ្រង់សម្តែងចំពោះភិក្ខុទាំងឡាយថា:

ភិក្ខុទាំងឡាយ! វិញ្ញាណកើតឡើងដោយអាស្រ័យបច្ច័យណា ក៏គួរនឹងរាប់ទៅតាមបច្ច័យនោះ ឧបមាថា វិញ្ញាណកើតឡើងដោយអាស្រ័យភ្នែកនិងរូប ក៏គួរហៅថា ចក្ខុវិញ្ញាណ, វិញ្ញាណកើតឡើងដោយសារត្រចៀកនិងសំឡេង ក៏គួរហៅថា សោតវិញ្ញាណ, វិញ្ញាណកើតឡើងដោយសារច្រមុះនិងក្លិន ក៏គួរហៅថា ឃានវិញ្ញាណ, វិញ្ញាណកើតឡើងដោយអាស្រ័យអណ្តាតនិងរស ក៏គួរហៅថា ជិវ្ហាវិញ្ញាណ, វិញ្ញាណកើតឡើងដោយអាស្រ័យកាយនិងវត្ថុដែលប៉ះពាល់ដោយកាយ ក៏គួរហៅថា កាយវិញ្ញាណ,

វិញ្ញាណកើតឡើងដោយអាស្រ័យចិត្តនិងធម្មារម្មណ៍ គឺគួរហៅថា មនោវិញ្ញាណ ។

— ភិក្ខុទាំងឡាយ! ដូចជាភ្លើងនេះ អាស្រ័យនឹងវត្ថុណា គឺគួរនឹងរាប់ទៅតាមវត្ថុនោះ ឧបមាថា ភ្លើងឆេះដោយអាស្រ័យឧស គឺគួរហៅថា ភ្លើងឧស, ភ្លើងឆេះដោយអាស្រ័យប្រឆេះ ឬ ប៉ុយ គឺគួរហៅថា ភ្លើងប៉ុយ, ភ្លើងឆេះដោយអាស្រ័យស្មៅ គឺគួរហៅថា ភ្លើងស្មៅ, ភ្លើងឆេះដោយអាស្រ័យអាចម៍គោ គឺគួរហៅថា ភ្លើងអាចម៍គោ, ភ្លើងឆេះដោយអាស្រ័យអង្កាម គឺគួរហៅថា ភ្លើងអង្កាម, ភ្លើងឆេះដោយអាស្រ័យសម្រាម គឺគួរហៅថា ភ្លើងសម្រាម ។

— ភិក្ខុទាំងឡាយ! អ្នកទាំងឡាយឃើញខន្ធបញ្ចកៈកើតឡើងឬទេ?

សូមទ្រង់ព្រះមេត្តាប្រោស! ឃើញ ។

— ភិក្ខុទាំងឡាយ! អ្នកទាំងឡាយឃើញថាខន្ធបញ្ចកៈនេះកើតឡើងហើយរលត់ទៅវិញ ព្រោះរលត់អាហារឬទេ?

សូមទ្រង់ព្រះមេត្តាប្រោស! ឃើញ ។

— ភិក្ខុទាំងឡាយ! វិចិកិច្ឆាកើតឡើង ដោយសង្ស័យថា ខន្ធបញ្ចកៈនេះកើតឬមិនកើតដែរឬទេ ?

សូមទ្រង់ព្រះមេត្តាប្រោស! កើតឡើង ។

-ភិក្ខុទាំងឡាយ! វិចិកិច្ឆាកើតឡើង ដោយសង្ស័យថា ខន្ធបញ្ចកៈនេះកើតឡើងដោយអាហារនោះឬមិនមែនទេ ?

សូមទ្រង់ព្រះមេត្តាប្រោស! មែន ។

-ភិក្ខុទាំងឡាយ! វិចិកិច្ឆាកើតឡើង ដោយសង្ស័យថា ខន្ធបញ្ចកៈកើតឡើងហើយរលត់ទៅវិញ ព្រោះរលត់អាហារនោះ ឬមិនមែនដូច្នោះទេ ?

សូមទ្រង់ព្រះមេត្តាប្រោស! ដូច្នោះមែន ។

-ភិក្ខុទាំងឡាយ! កាលបុគ្គលឃើញច្បាស់ ដោយបញ្ញាដ៏ប្រពៃតាមពិតថា ខន្ធបញ្ចកៈកើតដូច្នេះ បុគ្គលនោះ ឈ្មោះថាលះបង់វិចិកិច្ឆាបានឬទេ ?

សូមទ្រង់ព្រះមេត្តាប្រោស! បាន ។

-ភិក្ខុទាំងឡាយ! កាលបុគ្គលឃើញច្បាស់ ដោយបញ្ញាដ៏ប្រពៃតាមពិតថា ខន្ធបញ្ចកៈកើតឡើងព្រោះអាហារនោះដូច្នេះ បុគ្គលនោះឈ្មោះថាលះបង់វិចិកិច្ឆាបានឬទេ ?

សូមទ្រង់ព្រះមេត្តាប្រោស! បាន ។

-ភិក្ខុទាំងឡាយ! កាលបុគ្គលឃើញច្បាស់ ដោយបញ្ញាដ៏ប្រពៃតាមពិតថា ខន្ធបញ្ចកៈកើតហើយរលត់ទៅវិញ ព្រោះរលត់អាហារនោះដូច្នេះ បុគ្គលនោះ ឈ្មោះថាលះបង់វិចិកិច្ឆាបានឬទេ ?

សូមទ្រង់ព្រះមេត្តាប្រោស! បាន ។

—ភិក្ខុទាំងឡាយ! អាហារ (១) ដែលសម្រាប់អនុគ្រោះសត្វដែលកើតហើយឲ្យតាំងនៅ អនុគ្រោះសត្វដែលជាសម្ភវេសីឲ្យប្រព្រឹត្តទៅ មាន ៤ ប្រការ គឺកវឡិង្ការាហារ (អាហារគ្រោតគ្រាតឬល្អិត) ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១, អាហារទាំង ៤ នេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ អាហារនេះ មានតណ្ហាជាហេតុ មានតណ្ហានាំឲ្យកើត មានតណ្ហាជាកំណើត មានតណ្ហាជាដែនកើត(២) ។ល។

ក្នុងចំណុចវិញ្ញាណនេះ ព្រះពុទ្ធឃោសាចារ្យបន្ថែមសេចក្ដីបន្តិចថា «ភ្លើងនេះដោយអាស្រ័យទស បើទឹងនេះនៅក៏ត្រូវមានឧសតទៅទៀត, បើភ្លើងនេះឧសអស់ហើយ ភ្លើងនឹងរលត់ទៅវិញក្នុងទីនោះ បើឧសអស់

១ — កវឡិង្ការាហារទី ១ ដែលលោកចាត់ជា ២ យ៉ាងនោះ ដោយការប្រៀបធៀបដូចក្រពើលេបថ្ម ក្ងោកស៊ីពស់និងស្កា, អាហារក្រពើជាអាហារគ្រោតគ្រាត«ឱឡារិក», ឯអាហារក្ងោកជាអាហារល្អិត «សុខុម» ប្រៀបធៀបគ្នាមើលរហូតទៅដល់អាហារទេវតា ។ អាហារទេវតាជាន់បរនិម្មិតវសវត្តី ជាអាហារសុខុម, ឯអាហារទេវតាជាន់និម្មានរតី ជាឱឡារិក ។ អាហារសុខុមមានរសជាតិជាងអាហារឱឡារិក ។ កវឡិង្ការាហារនេះ មានឧជារស ៨ ប្រការ គឺ បឋវី អាបោ តេជោ វាយោ វណ្ណោ គន្ធោ រសោ ឱជា ។ ផស្សាហារទី ២ បានដល់វេទនា ៣ ដែលកើតពីការប៉ះពាល់សម្ផស្ស ៦ ប្រការ ។ មនោសញ្ចេតនាហារទី ៣ លោកសំដៅយកចេតនាកម្ម ៣ ប្រការ ដែលប្រមូលមកនូវបដិសន្ធិក្នុងត្រៃភព ។ វិញ្ញាណាហារទី ៤ បានដល់ចិត្តណាមួយដែលនាំមកនូវរូបក្នុងខណៈបដិសន្ធិក្នុងត្រៃភពនោះ ។ អាហារទាំង ៤ នេះ សេចក្ដីពិស្ដារមាននៅក្នុងបបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ មូលបណ្ណាសក ត្រង់សម្មាទិដ្ឋិវណ្ណនា ។

២ សេចក្ដីតទៅ ប្រាប់លម្អិតបដិច្ចសមុប្បាទ ។

ហើយភ្លើងមិនអាចនឹងឋិតនៅបានទេ ព្រោះមានលក្ខណៈប្រែប្រួលហើយ ហើយភ្លើងមិនអាចនឹងលោត ឆ្លងទៅចាប់កាច់ឧសនៅឆ្ងាយមួយទៀតបានទេ, ឯវិញ្ញាណក៏ដូច្នោះឯង, វិញ្ញាណកើតឡើងដោយអាស្រ័យចក្ខុនិងរូប កើតឡើងក្នុងចក្ខុទ្វារ កាលបើមានលក្ខណៈគ្រប់បរិបូណ៌ ដូចជាភ្នែក រូប ពន្លឺ មនសិការ ហើយរលត់ទៅវិញក្នុងទីនោះ ជាធម្មតា បើមានលក្ខណៈមិនគ្រប់បរិបូណ៌ទេ, បើមានលក្ខណៈប្រែប្រួលដូច្នេះហើយវិញ្ញាណមិនអាចនឹងលោតឆ្លងទៅកាន់ត្រចៀក ហើយកើតទៅជាសោត·វិញ្ញាណទៀតបានឡើយ ។ល។

ព្រះសម្ពុទ្ធទ្រង់ត្រាស់ដោយពុទ្ធដីកាដែលមិនគួរមានក្តីសង្ស័យទេថា វិញ្ញាណអាស្រ័យដោយរូប វេទនា សញ្ញា សង្ខារ ហើយកើតឡើង, វិញ្ញាណនេះមិនអាចនឹងតាំងនៅដោយឡែកពីធម៌ទាំងនេះបានទេ ។ ទ្រង់ត្រាស់ច្បាស់លាស់ថា (១) ភិក្ខុទាំងឡាយ !

វិញ្ញាណ មានរូបជាគ្រឿងក្តួចកាន់ (រូបុបាយំ) កាលឋិតនៅ គប្បីឋិតនៅបាន មានរូបជាអារម្មណ៍ (រូបារម្មណំ) មានរូបជាទីតាំង (រូបបតិដ្ឋំ)

វិញ្ញាណ មានវេទនាជាគ្រឿងក្តួចកាន់ (វេទនូបាយំ) កាលឋិតនៅ គប្បីឋិតនៅបាន, មានវេទនាជាអារម្មណ៍ (វេទនារម្មណំ) មានវេទនាជាទីតាំង (វេទនាបតិដ្ឋំ)

---

១— សំយុត្តនិកាយ ខន្ធវគ្គ សៀវភៅ ទី ៣៣ ទំព័រ ១២២ ។

(នៅមានត)

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ - កន

### ប្រែ ~ រៀបរៀង

### (ក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកភិងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

យូ-អ៊ុន

តេងអ៊ុនជានាម៉ឺនធំម្នាក់ មានចិត្តឈឺក្តៅនឹងដូកាត់គេកតាំងពីដើមរៀងមកលុះដឹងថាធ្វើរលោភដូច្នោះតេងអ៊ុនក៏ទៅរកស៊ុនជុនហើយនិយាយថា ដូកាត់គេកបានធ្វើធំហើយរលោភកំហែងនាម៉ឺនទាំងពួងណាស់ធ្វើការសព្វថ្ងៃនេះ ខ្ញុំពិគ្រោះមើលឃើញដូចជាវាប្រុងនឹងក្បត់ផែនដីលោកជាពូជព្រះរាជវង្ស ហេតុម្តេចមកនៅស្ងៀមមិនរិះគិតនឹងកំចាត់សត្រូវរាជសម្បត្តិចេញ ៗ ស៊ុនជុនថា ការនេះខ្ញុំបានគិតយូរមកហើយ តែថាវាទាល់ប្រកល្អក់សោះមិនមានទីប្រឹក្សា បើបានលោកមកជាគៀនគិតត្រូវនឹងគំនិតគ្នាហើយ មុខជានឹងសម្រេចការ ខ្ញុំគិតថានឹងនាំលោកចូលទៅទូលព្រះចៅស៊ុនសៀងសូមទ្រង់ជ្រាបតាមការដែលខ្ញុំគិតគ្រប់ប្រការនោះរួចហើយនឹងគិតចាប់ខ្លួនដូកាត់គេក តើលោកនឹងយល់ឃើញប្រការម្តេច ? តេងអ៊ុនយល់ឃើញត្រូវ ក៏នាំគ្នាចូលទៅគាល់ហើយទូលប្រាប់កិច្ចការទាំងពួង ៗ

ព្រះចៅស៊ិនលៀងត្រាស់ថា ការនេះយើងបានគិតឃើញយូរមក ហើយតែថាពាល់គំនិតណាស់ មិនដឹងនឹងធ្វើម្ដេចបាន, ឥឡូវអ្នកទាំង ២ ស្វាមីភក្ដិដល់យើង ឃើញដល់ការផែនដីដូច្នេះហើយ មិនត្រូវបង្អង់ឲ្យយូរទៀយត្រូវតែស្រូតរះគិតកំចាត់សត្រូវផែនដីនេះចេញឲ្យបាន, គេងម៉ុនទើបទូលថ្កានថា: សូមព្រះអង្គឲ្យទាហានដែលមានថ្វីដៃខ្លាំងពូកែកាន់អាវុធបង្កប់នៅក្នុងផាកហើយទ្រង់ណាត់ថា បើឮសូរពេលតែងស្រាវេលាណា ឲ្យទាហានព្រមគ្នាចេញមកសម្លាប់ដូកាត់កេកវេលានោះ, លុះត្រៀមការព្រមស្រេចហើយ ព្រះចៅស៊ិនលៀងក៏ឲ្យទៅអញ្ជើញដូកាត់កេកមកបរិភោគអាហារលៀងគ្នា ៗ ឯដូកាត់កេកដេកឈឺនៅក្នុងផ្ទះ ឲ្យចេះតែក្ដៅក្នុងប្រាណរំខានចិត្តណាស់ក៏ចេញមកនិយាយរពជការ ក្រឡេកទៅឃើញមនុស្សម្នាក់ស្លៀកសពាក់សដើរចូលមកចំពីមុខក៏ខឹងណាស់, បង្គាប់ទា- ហានឲ្យចាប់មនុស្សនោះយកទៅវាយសួរពិចារណា មនុស្សក៏ឆ្លើយឲ្យការថា បិតាខ្ញុំបាទស្លាប់នឹងទៅនិមន្ត លួងដីមកធ្វើបុណ្យ ខ្ញុំបាទមិនដឹងមិនស្គាល់បានជាដើរមកប្រទះលើលោកម្ចាស់ ដោយស្មានថាទីនេះជាទីវត្តខ្ញុំបាទខុសណាស់ហើយ ស្រេចតែលោកម្ចាស់នឹងមេត្តាប្រោស; ដូកាត់កេកខឹងណាស់ ឲ្យហៅទាហានរក្សាទ្វារមកសួរថា: ហេតុម្ដេចបានជាឯងបណ្ដោយឲ្យតាមនុស្សនេះចូលមកក្នុងភូមិអញ អ្នករក្សាទ្វារប្រហែល ៤០ នាក់ឲ្យការថា ខ្ញុំបាទកាន់អាវុធគ្រប់ដៃរក្សាហាត់ទ្វារព្រម [illegible]

កំមិនបានឃើញនរណាដើរចូលមកទេ, ជូកាត់កេកកំបង្គាប់ឲ្យយកពួកទា-
ហានគេក្រទ្វារចាំផងអស់នោះ ហើយនឹងមនុស្សដែលចូលទៅនោះ ទៅ
សម្លាប់ចាំផងអស់, លុះវេលាកណ្ដាលយប់កំឲ្យខានកន្លងចិត្តណាស់ ដេក
កំមិនលក់ ស្រាប់តែឮសូរដូចន្ទះបាញ់ លុះស្ទុះចេញមកក្រឡេកឃើញ
នោះដាច់ចេញជា ២ កំណាត់កំរិតតែកក័យណាស់ ត្រឡប់
ចូលទៅដេកវិញកំមិនលក់, មានបិសាចចូលទៅរងបន្ទាចធ្វើជាខ្យល់បក់
ទៅត្រវខ្លួនជូកាត់កេក ៗ ក្រឡេកឃើញពួកមនុស្សដែលយកទៅសម្លាប់
នោះគ្មានក្បាលចាំផងអស់, ឃើញដៃកយួរក្បាលម្នាក់ ១ ដើរចូលទៅតាម
គ្នា ហើយស្រែកថា លោកយកជីវិតមកឲ្យយើងវិញ ៗ

ជូកាត់កេកឃើញដូច្នោះកំរិតតែខ្លាញ់ណាស់ កំស្ទុះប្រឡេតទាល់
តែភ្លាក់ពីលើគ្រែបាត់មាត់ ១ ស្រេក អ្នកគេក្រជម្ងឺកៅខដឹងឡើងវិញ, លុះ
វេលាព្រឹកជូកាត់កេកចេញទៅលប់មុខ ប៉ុន្តែធ្លាចទឹកកន្លងកាជនៈដែលលថ
មុខនោះបដូចឈាមស្រស់ ៗ កំខឹងខ្លាំងណាស់, ទើបឲ្យមនុស្សបំរើទៅដង
ទឹកថ្មីយកមកឲ្យជាច្រើនគ្រា កំនៅឆ្អាងជាក្ងនលោហិតដដែល រឹតតែ
សង្ស័យណាស់ ទទួលមានពជបំរើត្រាស់ឲ្យហៅជូកាត់ កក សេចក្ដីថា
ព្រះចៅស៊ុនលៀនឲ្យអញ្ជើញលោកទៅពិសាភុលៀងអាហារ, ជូកាត់
កេកកំរៀបខ្លួនឡើងសេះ មានទាហានហែមុខក្រោយរួលទៅតាប់, មាន
ផ្ទៃលៀង ១ ដែលជូកាត់កេកចិញ្ចឹមទុកក្នុងផ្ទះនោះ កស្ទុះទៅទាំជាយគាវជូ

គាត់កេកទាញទុកហើយរាំស្រែកល្បីដូចដាស់ឡើងស្រែកយំ. ដូកាត់កេកទឹកប្លែកក្នុងចិត្តណាស់ ប្រឹងស្រែកគំហកដេញផ្គរនោះឲ្យចេញទៅបន្តិច ស្រាប់តែក្រឡេកទៅឃើញផ្សែងភ្លើងផុសឡើងពីផែនដី ជាប្រផ្នូលប្លែកដូចកាលទៅទ័ព ក៏រឹតតែប្លែកចិត្តទៀត ទៀរអៀតទាហានស្និទ្ធម្នាក់ឃើញដូច្នោះក៏រំលឹកថាដែលមានព្រះតម្រាស់ឲ្យព្រះតេជព្រះគុណអញ្ជើញទៅពិសាលៀងគ្រានេះ, ដូចជាមិនដឹងច្បាស់ការធូនស្រាលអ្វីឡើយ, ហេតុនេះហើយសូមឲ្យព្រះតេជព្រះគុណត្រិះរិះគិតឲ្យល្អិតល្អមែនទែន កុំស្រាល ដូកាត់កេកបានឮដូច្នោះក៏ឲ្យត្រឡប់បរទេះទៅផ្ទះវិញ; តេងអ៊ុនទង់ស៊ុនដុនដឹងថា: ដូកាត់កេកត្រឡប់ទៅវិញ ក៏បរសេះស្រូតទៅទាន់រទេះហើយថា ព្រះចៅស៊ុនលៀងរឭកដល់លោកមហាឧបកដណាស់ ទើបឲ្យតាមអញ្ជើញទៅពិសាលៀងកុំខាន, ហេតុម្តេចបានជាលោកអញ្ជើញទៅវិញ, ដូកាត់កេកថា: ខ្ញុំមកដល់ទីនេះហើយ តែមិនស្រួលក្នុងព្រោះឃើញថាទីងត្រាំទៅគាល់មិនបាន បានជាត្រឡប់ទៅវិញ ។

តេងអ៊ុនថា គាំងពីមហាឧបកដអញ្ជើញទៅទ័ព ទាល់តែត្រឡប់មកវិញនៅមិនទាន់បានចូលគាល់សោះ, ព្រះចៅស៊ុនលៀងយកព្រះទ័យទុកដាក់ទឹកព្រួកគ្រាស់សួរតែរឿយៗប្រាប់ថា លោកធូរស្រាលអាការជម្ងឺហើយ បានជាឲ្យតាមអញ្ជើញទៅពិសាលៀង ហើយទីងបាងប្រឹក្សាពីការពាក់ការផែនដីផង លោកអញ្ជើញមកហើយត្រូវតែខំកាត់ចិត្ត

ចូលទៅគាល់ម្ដងចុះ, ដើម្បីបំពេញព្រះទ័យព្រះចៅស៊ុនលៀនដែលទ្រង់ស្មោះសរពេកអាន; ជូកាត់កេកបានឮដូច្នោះក៏មិនមានសេចក្ដីសង្ស័យអ្វីសោះ ក៏ត្រឡប់ចូលទៅគាល់ ទៀវអៀតទាហានជំនិតក៏តាមទៅផង ៗ

ព្រះចៅស៊ុនលៀន ទ្រង់ធ្វើបដិសណ្ឋារៈគួរសមនឹងជូកាត់កេក ហើយអញ្ជើញឲ្យអង្គុយកៅអី ហើយអញ្ជើញឲ្យសេពសុរា, ជូកាត់កេករាំងខ្លួនណាស់ទូលថា ទូលព្រះអង្គថាខ្ញុំនៅឈឺនឹងទទួលព្រះរាជទានសុរាពុំបាន, ស៊ុនជុនថាៈ ខ្ញុំបាទឃើញមហាឧបរាជពិសាស្រាថ្នាំលាយសុរានៅជាដរាប កុំឲ្យទទឹងព្រះអធ្យាស្រ័យឡើយ, គួរប្រើមនុស្សឲ្យទៅយកស្រាថ្នាំមកពិសាឲ្យល្មមតាមព្រះរាជហឫទ័យ, ជូកាត់កេកក៏ប្រើបំរើឲ្យទៅយកស្រាថ្នាំមកផឹក, ព្រះចៅស៊ុនលៀនឃើញជូកាត់កេកផឹកស្រាថ្នាំស្រវឹងក្នុងខ្លួនហើយ ទើបត្រឡប់យកសេចក្ដីដែលព្រះបិតាបានផ្ដាំផ្ញើស្រុកទេសនឹងខ្លួនរបស់ព្រះអង្គនោះមកប្រោរព្ធឲ្យជូកាត់កេកទុកចិត្ត ស៊ុនជុនក៏ចូលទៅក្នុងផាកដោះអាវចេញ ហើយតែងខ្លួនជាមាំមួនបែបយ៉ាងចូលធ្វើសង្គ្រាម ហើយកាន់គ្របចេញទៅហើយស្រែកថា មានព្រះតម្រាស់ឲ្យយើងសម្លាប់មារសត្រូវរាជសម្បត្តិ គឺរូបអាជូកាត់កេកនេះឲ្យអស់ជីវិត ជូកាត់កេកភ័យណាស់, ដៃចាប់គ្របអាក់ខ្លួនទើងក្រោកឡើង, ស្រាប់តែស៊ុនជុនស្ទុះទៅកាប់ជូកាត់កេកដាច់ក្បាលធ្លាក់ចុះ, ទៀវអៀតក៏ពារចូលទៅចាក់ត្រូវស៊ុនជុន [illegible] ហានដែលកាន់

អាវុធត្រៀមក្នុងទូក ក៏ស្ទុះស្រែចេញមកព័ទ្ធជុំវិញខ្លួនទៀវអៀត ហើយចាក់ទៀវអៀតដួលស្លាប់, ស៊ុនជុនក៏បង្គាប់ទាហានឲ្យទៅចាប់ភរិយាបុត្រដូកាត់កេកនិងទៀវអៀត ហើយឲ្យយករបស់ទ្រព្យសម្បត្តិដាក់ជាព្រះរាជទ្រព្យហ្លួងទាំងអស់ លុះបង្គាប់ហើយក៏ឲ្យយកអារុំសពដូកាត់កេកនិងទៀវអៀតទៅចោលក្រៅកំពែងក្រុងខាងទិសឯត្បូង ។

ឯភរិយាបុត្រដូកាត់កេក វេលានោះបណ្តាលជាទុក្ខក្តៅក្រហាយក្នុងទ្រូងខ្លាំងណាស់, ក្រឡេកទៅឃើញស្រីម្នាក់ដែលជាមនុស្សបំរើក្នុងផ្ទះនោះ បិសាចដូកាត់កេកទៅចូលវា ។ ក៏មានក្លិននោះផ្អាបឈាមណាស់ ហើយវាដើរចូលទៅក្នុងផ្ទះ, ភរិយាក៏សួរថា: ខ្លួនឯងត្រូវទឹងអ្វីបានជាធុំក្លិនផ្អាបឈាមណាស់ម្ល៉េះ ស្រីនោះខមក្អែក លៀនអណ្តាត ហើយលោតឡើងទៅលើដំបូលផ្ទះ ហើយចុះមកអង្គុយលើហ៊ុងស្រែកថា: អញនេះគឺដូកាត់កេក, ទទួលទាហានទៅដល់ចោមព័ទ្ធផ្ទះទុក ហើយដេញចាប់ភរិយាបុត្រដូកាត់កេក និងមនុស្សក្នុងផ្ទះបានទាំងអស់ ហើយរឹបយករបស់ទ្រព្យមាសប្រាក់ ហើយនាំយកមនុស្សទាំងអស់នោះទៅប្រហារជីវិតកណ្តាលផ្សារ ឯរបស់ទ្រព្យក៏នាំទៅដាក់ជាព្រះរាជទ្រព្យហ្លួងទាំងអស់ គ្រានោះជាខែកត្តិក ក្នុងរាជព្រះចៅស៊ុនលៀងសោយរាជ្យបាន ២ ឆ្នាំ (ព.ស ៧៩៦) កាលស៊ុនជុនសម្លាប់កាត់កេកវេលានោះ ព្រះចៅស៊ុនលៀងក៏តាំងស៊ុនជុនជាមហាឧបរាជនិយាយរាជការទូទាំងផែនដី ។

ឯកៀងអ៊ុយមេទ័ពស្រុកសៃឈួន លុះដឹងតាមសំបុត្រជូកាត់កេក ឲ្យទៅដល់គំពេញអំណរណាស់ ទើបនាំសេចក្តីនោះទៅទូលព្រះចៅឡៅសៀន ហើយទូលលានឹងលើកកងទ័ពទៅវាយស្រុកវ៉ុយកុក ព្រះចៅឡៅសៀនក៏យល់ព្រមផង កៀងអ៊ុយកេណ្ឌទាហានបាន ២០ ម៉ឺន ឲ្យលៀវហ៊្វាជាមេកងជើង ទៀវអេជាមេកងស្តាំ ឲ្យលើកទៅមុន ឲ្យហែហ៊ូប៉ាជាទីប្រឹក្សាក្នុងកងទ័ពលួង ឲ្យទៀវងីជាកងទ័ពក្រោយប្រចាំជួន លុះរៀបស្រេចក៏ឲ្យលើកកងទ័ពចេញទៅតាមផ្លូវហៃបេងគួន លើកទ័ពទៅគ្រានោះ ព្រះចៅឡៅសៀនសោយរាជ្យបាន ១៦ ឆ្នាំ (ព.ស.៧៩៦) កៀងអ៊ុយប្រឹក្សានឹងហៃហ៊ូប៉ាថា: យើងលើកកងទ័ពទៅគ្រាមុនថ្ងៃការទីងសត្រូវ គ្រានេះទាហានយើងក៏ច្រើន គ្រឿងសស្ត្រាវុធក៏ច្រើនគ្រប់សព្វ យើងត្រូវតែរិះគិតធ្វើការម៉ែតចត់ តើអ្នកគិតយល់ឃើញប្រការម្តេច? ទើបនឹងមានជ័យជំនះសត្រូវខាងឲ្យបាន ៗ

ហៃហ៊ូប៉ាថា: អាណាខែត្រឡើងវ៉ុយកុកមែកខាងជើង: ឃើញតែស្រុកអាខណាំនោះមានស្រូវអង្ករស្បៀងអាហារបរិបូណ៌ បើយើងវាយយកបានទឹងបានជាកំឡាំងចិញ្ចឹមអាហារដោយស្រួល កាលយើងលើកទៅគ្រាមុនថ្ងៃការទីងពួកសត្រូវ ព្រោះកងទ័ពស្រុកកៀងមិនក្នុងមកដល់ព្រម គឺមកមិនទាន់វេលា គ្រានេះសុំឲ្យអ្នកមានសំបុត្របង្គាប់ទៅឲ្យ [illegible] កកងទ័ពមកតាមផ្លូវសេកកេង ឲ្យបែកបន្ទុលគ្នានឹងទ័ពយើងទៅ [illegible] កេង

ព្រមគ្នា ហើយយើងនឹងលើកទៅវាយស្រុកអាន់ណាំ ។

គៀងអ៊ុយបានឮដូច្នោះក៏មានសេចក្ដីត្រេកអរណាស់ ទើបឲ្យចាត់ចែងនាំយកពេជ្រ និងប្រាក់មាសព្រៃសាច់ហ៊ានល្អជាគ្រឿងរាជបណ្ណាការទៅដល់ប៊ិតង ចៅហ្វាយស្រុកគៀងឲ្យលើកកងទ័ពមកជួយ ប៊ិតងចៅហ្វាយស្រុកគៀងខែត្រក្រៅ បានបណ្ណាការក៏ពេញអំណរណាស់ ទើបកេណ្ឌពលបាន ៥០.០០០ ចាត់ងោហោនិងសៀវកួ ទាំង២នាក់នេះជាមេទ័ពមុខ ខ្លួនប៊ិតងជាមេទ័ពល្វងលើកទៅស្រុកគងតេង ។

ឯឃួយហ៊្វួយចៅហ្វាយស្រុកអេងជីវ ដឹងថា គៀងអ៊ុយលើកទ័ពមក ក៏ឲ្យបំរើសេះកាន់សំបុត្រចូលទៅប្ដឹង តាមខាកជការ ដល់ស្រុកឡូកអៀង សុម៉ាស៊ូទើបប្រឹក្សានឹងនាម៉ឺនទាំងពួងថា: កងទ័ពគៀងអ៊ុយលើកមកគ្រានេះ នរណានឹងអាសាចេញទៅតទល់បាន ឈីដិតនាម៉ឺនធំម្នាក់ក៏និយាយថា: ខ្ញុំបាទនឹងសុំអាសាចេញទៅ សុម៉ាស៊ូដឹងមកពីដើមថា: ឈីដិតនោះជាមនុស្សមានសតិបញ្ញា ទាំងកំឡាំងក៏ច្រើន ហើយទាហានហានក្លាក្នុងការសង្គ្រាម លុះបានឮឈីដិតទទួលអាសាដូច្នោះក៏ពេញចិត្តណាស់ទើបឲ្យឈីដិតជាមេទ័ពមុខ សុម៉ាចៀវជាមេទ័ពល្វង នាំទាហានលើកទៅដល់ដំបន់តេង ឈីដិតកាន់ពូថៅជិះសេះនាំទាហានចេញទៅ គៀងអ៊ុយចាត់ច្រើលៀងហ៊្វួនាំទាហានចេញច្បាំង លៀវហ៊្វួកាន់លំពែងជិះសេះនាំទាហានចេញទៅតទល់គ្នានឹងឈីដិតបាន ៣ ក្បួន

លំពែងក្ដាត់ធ្លាក់ពីដៃដោយចាញ់ប្រៀបក៏ទាញសេះរត់ទៅ កៀងអ៊ុយប្រើឲ្យទៀវអេកចេញទៅជួយ, ទៀវអេកកាន់លំពែងជិះសេះចេញច្បាំងនិងឈើជិតបានប្រមាណ ៤ ក្បួន លើសកំឡាំងក៏ថយរត់ចេញ, ឈើជិតបានចំណាប់ក៏នាំទាហានដេញទន្ទ្រានធានការសម្លាប់ទាហានកៀងអ៊ុយស្លាប់ជាច្រើន, កៀងអ៊ុយឃើញទាហានសាប់សោយណាស់ ទើងតទល់មិនបានក៏សោយទ័ពថយទៅប្រមាណ ៣០០ សិន (១២គ) ក៏តាំងបន្ទាយភ្ជាប់នៅទីនោះ ឯស៊ុម៉ាឃៀវកោមមិនឲ្យទាហានដេញតាម ក៏បង្គាប់ទាហានឲ្យតាំងបន្ទាយនៅប្រចគ្នា ។

កៀងអ៊ុយក៏ប្រឹក្សានឹងហែហូម៉ាថា: ឈើជិតនោះជាមនុស្សមានកំឡាំងថ្មីដៃខ្លាំងណាស់, យើងត្រូវគិតប្រការម្ដេចទើបនឹងសម្លាប់ចេញបាន, ហែហ៊ូបាថា ចាំព្រឹកស្អែកយើងនឹងឲ្យបង្កប់ទាហានទុកសងខាងផ្លូវ ហើយឲ្យខ្ទុះចេញទៅច្បាំងតដៃនឹងឈើជិត ហើយឲ្យធ្វើជាចាញ់ថយរត់មក បើឈើជិតដេញតាម យើងត្រូវឲ្យទាហានដែលពួនបង្កប់នោះចេញវាយស្ទាក់ពីសងខាង គង់នឹងព្រួតចាប់ឈើជិតបានជាប្រាកដ ។

កៀងអ៊ុយថា: ស៊ុម៉ាឃៀវនោះជាបុត្រស៊ុម៉ាអ៊ីគេក៏ចំណានក្នុងកលសឹកណាស់ដែលនឹងជះញ្ញាតថ្វះបោះក្រងមិនសម្រេចដូចគំនិតគិត ព្រោះទីផ្លូវស្ពានបម្លាំងនោះទំនងស្រួលណាស់ មុខជាគេនឹងមិនដេញតាមទេដឹង ពិគ្រោះមើលៈមើលថា គង់ស្រុកយ៉ាគុក មកធ្វើការជំនួសយើង ពីមុនមក

រមែងប្រើកងទាហានទៅចាំស្កាត់ផ្លូវប្រចាំជួន ដែលយើងនឹងចាំសម្លាប់ឈើជិតក្នុងទីចម្បាំងដូច្នេះដូចជាមិនបាន ព្រោះកំឡាំងពលទាហានគេក៏ច្រើន ត្រូវតែយើងតាំងទ័ពនៅក្នុងបន្ទាយឲ្យមាំមួនចុះ មុខជាស៊ុម៉ាចៀវនឹងប្រើឈើជិតឲ្យចាំវាយកាត់ទ័ពប្រចាំជួន យើងត្រូវគិតបញ្ឆោតឈើជិតឲ្យបាញ់គលយើង នៅវេលាដែលវាវាយកាត់ទ័ពប្រចាំជួននោះឲ្យបាន ព្រោះទីនោះជាច្រកចង្អៀត ហែហ៊្វូបា៉ក៏យល់ឃើញត្រូវ ។

គៀងអ៊ុយក៏ឲ្យហៅលៀងហ៊្វូនិងទៀវអេកមកពន្យល់ឲ្យធ្វើកលឧបាយដែលខ្លួនធ្លាប់ធ្វើការជាមួយនឹងខុងបេង អ្នកទាំង ២ នាក់ក៏ទៅធ្វើដូចគំនិតគិតទុក តាមគៀងអ៊ុយបង្គាប់ពន្យល់នោះ, ឯគៀងអ៊ុយនៅក្នុងបន្ទាយឲ្យទាហានធ្វើកន្ទ្រាក្របដាប់ដៃកាយពេញក្នុងបន្ទាយ ហើយឲ្យកាត់ឈើធ្វើចំរូងដោតពាសជុំក្នុងបន្ទាយក្រៅបន្ទាយជាច្រើន, ឯឈើជិតនាំទាហានចេញទៅមុខបន្ទាយគៀងអ៊ុយ ហើយស្រែកចំអកឲ្យគេបញ្ឈឺចិត្តរាល់ថ្ងៃឲ្យគៀងអ៊ុយ ចេញច្បាំង, គៀងអ៊ុយក៏មិនចេញច្បាំងសោះ លុះនឹងចូលហែកកំលាយបន្ទាយក៏ពុំបាន ។

កងល្បាតទើបប្រើបរិវារសេះឲ្យទៅប្រាប់ស៊ុម៉ាចៀវថា ទាហានគៀងអ៊ុយនាំពួកប្រចាំជួនមកដល់ក្រោយភ្នំចៀតឡុងសានហើយ, ស៊ុម៉ាចៀវទើបព្រឹក្សានឹងឈើជិតថា: គៀងអ៊ុយមិនបានចេញច្បាំងនឹងយើង តាំងខ្ជាប់ខ្ជួនមួនមាំក្នុងបន្ទាយ ទាំងទាហានជាចាំទ័ពជួនហើយ: បើដូច្នោះ

ត្រូវយើងឲ្យទៅកាត់ពួកប្រចាំជួនឲ្យបាន បើកៀងអ៊ុយខុះផុតពួកប្រចាំជួនកាលណា មុខជាទីងវត់ចាញ់យើងជាប្រាកដ, អ្នកចូរនាំទាហានចេញទៅធ្វើការនេះឲ្យបានសម្រេចចុះ, ឈីជិតនាំទាហាន ៥០០០ លើកចេញទៅពីពេលព្រលប់ ទៅដល់ភ្នំថៀតឡុងសានហើយ ពួកកងល្បាតមកប្រាប់ថា: ទាហានកៀងអ៊ុយប្រហែល ២០០ ប្លាយ នាំប្រចាំជួនបន្ទុកគោយន្តប្រមាណ ១០០ ប្លាយមកហើយ នោះឈីជិតក៏ឲ្យទាហានទៅបង្កប់នៅសងខាងផ្លូវ ឯខ្លួនឈីជិតក៏ទៅតាំងស្កាត់នៅដើមផ្លូវ, នោះពួកកងល្បាតខាងកៀងអ៊ុយក៏ចាត់បំរើសេះឲ្យទៅប្រាប់កៀងអ៊ុយថា ឈីជិតលើកទ័ពតម្រង់ទៅចាំកាន់ពួកប្រចាំជួនហើយ, នោះកៀងអ៊ុយក៏លើកទ័ពទៅ លុះកងប្រចាំជួនទៅដល់ហើយ ឈីជិតក៏ឲ្យទាហានស្រែកហោរ៉ាយប្រសព្វចូលទៅ, នោះពួកទាហានប្រចាំជួនឃើញហើយ ក៏នាំគ្នារត់ទៅតាមផ្លូវត្រង់លើលៀងហ្វូទិងទៀវអេកធ្វើគលនោះ, ឈីជិតក៏ឲ្យទាហាន ២.៥០០ នាំរបស់ប្រចាំជួនយកទៅ, ឯខ្លួនក៏នាំទាហាន ២ ៥០០ ដេញតាមទៅ លុះដេញទៅបានប្រហែល ១០០ សិន (៤ គ) ដល់ផ្លូវប្រហាច ក៏ទទួលប្រទះនឹងរទេះគល់ជាច្រើនដែលលៀងហ្វូទិងទៀវអេកធ្វើជាគល់ទុកតាមផ្លូវនោះ, ឈីជិតក៏ឲ្យទាហានចុះពីលើសេះជួយគ្នារុញរទេះនោះឲ្យបែរទៅខាងផ្លូវ, ទាហានក៏ចូលទៅព័ទ្ធរុំជុំគ្នារុញរទេះនោះ ឯទាហានដែលតាមទៅនោះក៏ប្រជ្រៀតប្រៀតគ្នាជា

ច្រើនណាស់ រទេះនោះក៏លឿនគ្រៀនតាកទី ស្រាប់តែឆេះឡើងជា
ភ្លើងគ្រប់រទេះ អណ្ដាតសន្ធោសន្ធៅ នុះទៅត្រូវទាហានពួក.នោះរបួស
ពិការស្លាប់ជាច្រើនណាស់, ឈីដិតគិតថា គេធ្វើកលទទឹងពីមុខទុក
ហើយ លុះនឹងត្រឡប់ទៅតាមផ្លូវដែលមកក្រែងគេបង្កប់ទាហានស្ទាក់
កាត់ទុក ទើបនាំទាហានរត់ទៅមុខតាមផ្លូវតូចក្បែរជើងភ្នំមួយ លុះទៅដល់
ជិតមាត់ផ្លូវក៏ប្រទះនឹងរទេះកលអែបនៅសងខាងផ្លូវជាច្រើន រឹតតែភ័យ
ណាស់ ក៏បង្ខំទាហានស្រែកទៅឲ្យផុតរទេះនោះក៏ឆេះឡើងជាភ្លើង បក
អណ្ដាតប្រសព្វគ្នាពីសងខាងផ្លូវ ត្រូវលើកពួកទាហាននោះ របួសពិការ
ស្លាប់ជាច្រើនណាស់, ឈីដិតក៏នាំទាហានដែលសល់ពីស្លាប់រត់ផុតទៅ
ហើយបានឮស្នូរផាវសញ្ញា ក្រឡេកទៅឃើញលៀវហ៊្វួចេញមកពីខាង
ជើង, ទៀវអេកចេញមកពីខាងស្ដាំ នាំទាហានស្រែកហោព័ទ្ធចូលមក
ទាំងសងខាង សម្លាប់ពួកទាហានឈីដិតស្លាប់ទាំងអស់, ឯឈីដិតបំផាយ
សេះរត់ទៅ ប្រទះនឹងកៀងអ៊ុយចេញមកស្ទាក់ពីមុខ ឈីដិតភ័យណាស់
នឹងត្រឡប់ការពុំចូលតស៊ូមិនទាន់, កៀងអ៊ុយចាក់ត្រូវឈីដិតធ្លាក់ពីលើ
សេះ អស់ពួកទាហានក៏ស្លុះចូលទៅព័ទ្ធរុំជុំវិញ ព្រួតគ្នាចាក់កាប់ឈី
ដិតទាល់តែជាប់ខ្យល់ស្លាប់ ។

(នៅមានត)

# កុំស្លាប់ដូចពស់រស់ដូចកង្កែប

រៀបរៀងដោយ ផល - និត ក្រុមជំនុំព្រះត្រៃបិដក

គតិកាសិតព្រឹទ្ធទិដាទ
ថាកាលនោះមានតាបសី
មួយអង្គគង់សាងបារមី
បាលី ហៅថា "មេត្តាធម៌" ៗ

អប់រំព្រះទ័យនិស្ស័យចិត្ត
ករុណាអាណិតសត្វទិករ
សព្វកាលតែងកាន់ក្រឹត្យបវរ
គឺបរបង្ក្រើមផ្សំវិវេក ៗ

ថ្ងៃមួយ កំពុងស្ងំអារម្មណ៍
បរប្រប់បង្ក្រើមអារម្មណ៍ឯក
ស្រាប់តែឮស្នូរស័ព្ទ.មម្រែក
កង្កែបមួយស្រែកគួរអាណិត ៗ

ហាក់ដូចដង្ហោយហៅគេជួយ
ឲ្យជួយស្រោចស្រង់ជន្មជីវិត
តាមសព្ទភ្លាមភាមអង្កិត
ពិនិត្យមើលការណ៍តើជាអ្វី? ៗ

លោកឃើញពស់មួយចាប់កង្កែប
កំពុងប្រឹងលេបជាចំណី
តាបសទាល់ប្រាជ្ញពុំអាចក្រើ
ពុំដឹងកាត់ក្តីរបៀបណា? ៗ

បើជួយកង្កែបឲ្យរួចរស់
នោះពស់អត់ឆីក្ស័យជន្មា
បើទឹងបណ្តោយតាមចិត្តព៌
កង្កែបពិតជាស្លាប់ពុំខាន ៗ

ជួយមួយឲ្យរស់ មួយត្រូវស្លាប់
លៃម្តេចឲ្យគាប់ទាំងពីរប្រាណ
ទើបប្រើវិចារណញ្ញាណ
រំឭកខ្លួនទកង្កែបថា =

"នែ! ហៅកង្កែប! ចូរអែបស្តាប់
អាត្មានឹងប្រាប់ដោយមេត្តា
ទៅឯងប្រឹងហើយនៅទេណា
[illegible]

កង្កែបយល់ស្របតបភ្លាមថា　　«កូណា! កូណា! ខ្ញុំប្រុងហើយ»
ឥសីសួរឲ្យកង្កែបឆ្លើយ　　រួចហើយក៏ពោលទៅរកពស់ :
«ហៃចៅពស់វែកដ៏មានឫទ្ធិ　　រូបចោរវិចិត្រប្រណិតស្រស់
ដីតាកាន់ផ្នួសជាតាបស　　ចង់ឲ្យចៅរស់ដោយសុខសាន្ត ៗ
ឥឡូវចៅចាប់បានកង្កែប　　ចូលទៅប្រឹងលេបពីឲ្យបាន
ឮទេ? ពាក្យតាទាំងប៉ុន្មាន　　ប្រឹងប្រាណមែនទែនណាចៅណា៎» ៗ
ពស់ឮសម្ដីឥសីប្រាប់　　សម្ងំចាំស្ដាប់ពេញចិន្ដា
ក៏ចៀតហាមាត់ឆ្លើយឆ្លងថា　　«កូណា! កូណា ប្រឹងលេបហើយ» ៗ
គ្រាន់តែពស់វែកហើបមាត់ថា　　«កូណា...» ប៉ុណ្ណឹងប្រឹងហាឆ្លើយ
កង្កែបស្ទុះផ្លោតលោតទៅត្រើយ　　ផុតហើយមុជផ្លុបចូលត្រឹបបាត់ ៗ
ពស់វែកវឹកហាក់ក្ដឹកក្ដាំង　　ក្ដួចខ្លួនមួយកាំងតាំងហាមាត់
ក្ដីក្ដើមកក្ដួយឲ្យខ្លួនភ្លាត់　　កង្កែបរត់បាត់ពីមាត់ទៅ ៗ
ក៏ស្ទុះដេញភ្លាមតាមប្រកិត　　តែត្រូវខកចិត្តឡិតទឹកជ្រៅ
មិនយល់ទិសណាកង្កែបទៅ　　មួម៉ៅក្ដៅចិត្តឥតចេញស្ដី ៗ
　　បើអត់អាហារធម្មតាលោក　　មុខជាកើតរោគឃ្លានចំណី
ហើយទីបំផុតសត្វលោកិយ　　តែគ្មានចំណីត្រូវតែស្លាប់ ៗ
　　នេះគឺនិទានជានិទស្សន៍　　ប្រាជ្ញប្រាយរឿងពស់ដែលត្រូវអាប់
ហើយនិងកង្កែបដែលផុតស្លាប់　　មានជាប់ជាក្បួនជូនលោកិយ ៗ

សត្វពស់ក៏រស់ដោយអាហារ ត្រូវការគេថ្កើបជាចំណី
ចាប់ជាប់ទឹងមាត់គិតទឹងធី ចាញ់ស្នៀតឥសីព្រោះក្តីល្ងង់ ។
ចំណីក្នុងមាត់ក៏អត់ក៏ញូ រគ្រាមិនជាប់ឲ្យបាត់បង់
នេះប្រៀបប្រដូចនឹងមនុស្សល្ងង់ លិចលង់លំនឹងពឹងកសនា ។
មិនចេះរិះគិតស្រិតយោបល់ គំនិតដូចគល់គ្មានប្រាជ្ញា
ជឿតាមតែពាក្យគេឃោសនា ខុសត្រូវម្តេចម្តាមិនរវល់ ។
ចេះធ្វើការដែរ តែកម្សត់ បានត្រឹមនឿយហត់ទុកអំពល់
លុះដល់ពេលដែលត្រូវបានផល របូតជាផ្តល់ទៅគេផ្សេង ។
គោតផលកណ្តាខ្លួនចំនួនគ្រប់ បែរជាអភ័ព្វដេកផ្សងព្រេង
បណ្តោយឲ្យគេជ្រៀតជ្រែង ព្រមថាខ្លួនឯងគ្មានកសនា ។
បើមានសម្បត្តិធនធានផង មិនចេះស្ងួនគ្រងថែរក្សា
ជាមនុស្សចុះផ្លូវត្រូវតែគ្រា ថា « ចាំកសនាលើកបញ្ចុក » ។
ពូកែខាងធ្វើគ្លើភ្លើចផល មិនយល់នាទីជាបន្ទុក
មួយដូចពេលខ្មាំងចូលភូមិស្រុក ឈ្លានពានសន្តិសុខប្រទេសជាតិ ។
វាបោកគំនិតស្បិតបើដឹង ពិតតែពីប្រឹងទំទីឃាត
អួតថាធ្វើការដើម្បីជាតិ ផលខាតបំណេញវិញមិនយល់ ។
ខ្មាំងមកពីនាយស្ពាយអាវុធ ប្រើល្បិចលាក់ពុតឥទ្ធិពល
ខ្លួបដូចខ្លាស្លាមចូលចំគល យើងគិតមិនដល់យល់ថាស្លូត ។

ប្រឹងស្ទួនចំណីលៃចំណុក　　ដាក់ទុកពួកវាថា «ទេវទូត»
សមទឹងបរិតយើងស្ទួតបួត　　ជឿវាហួតស្ដាប់គំនិត ។
ខំប្រឹងធ្វើការទាំងយប់ថ្ងៃ　　ជួយៈពេញដៃដោយស្មោះចិត្ត
ដឹកស្បៀងដឹកគ្រាប់យប់ងងឹត　　ជួយចិទចំប៉ាំងរាំងយាមល្បាត ។
ជួយជុតសាលា ជួយជុតស្ពាន　　ជីកលេណដ្ឋាន ជីកថ្នល់ជាតិ
ជួយហូតពន្ធដារ ជួយបង់កាត　　ជួយចាប់ពិឃាតជនប្រឆាំង ។
ជួយចាប់លោកសង្ឃសណ្ឋានទឹក　　ជួយចាប់លោកផ្សឹកឲ្យទៅច្បាំង
ជួយឃោសនាថា «ខ្មែរ ជាខ្មាំង»　　ជួយច្បាំងទាហានគ្មានសំចៃ ។
គិតចុះប្រុសប្រាជ្ញគួរខ្លាចខ្មាស　　រឿងនេះជាក់ច្បាស់គ្មានបំភ្លៃ
បើយើងខំប្រឹងមិនដឹងន័យ　　តើបានជោគជ័យទៅអ្នកណា? ។
ថាមកប៉ុណ្ណេះប៉ុណ្ណឹង　　ល្មមឲ្យយើងដឹងយល់បានថា
កម្លាំងដែលយើងប្រឹងជួយវា　　ពិតជាឲ្យយល់ផលគួរស្ដាយ ។
គឺបានលទ្ធផលអស់ស្រូវខ្មែរ　　ខ្ទេចវត្តម៉ត់កេរ្តិ៍ខ្មែរទាំងឡាយ
ថ្នល់ខ្មែរស្ពានខ្មែរដាច់អន្តរាយ　　អគារធេតធាយក្លាយជាដី ។
ភូមិខ្មែរប្រែជាវាលស្រឡះ　　ផ្ទះផ្ទះសាលាខ្ទេចផ្ការគ្រើ
គេបុកណាដ៏ល្បាញល្បី　　សមិទ្ធិហិនហោចដែរ ។
មិនត្រឹមតែម្រញ ស្ពានទាំងមនុស្ស　　ក្មេងចាស់ស្រីប្រុសស្ទួនតែខ្មែរ
[illegible]　　ខ្ទួចស្លាប់ទាំងខ្មែរ គួរខ្លាចផង ។

ខ្មែរច្រើនធ្វើការប្រាថ្នាផល    ធ្វើថ្នល់ផ្លូវពេទ្យធ្វើសាលា
ធ្វើកសិកម្មផងនានា    ទឹកជាស៊ីមុកទុកប្រើប្រាស់ ។
ដល់ទម៌ខ្យល់ចូលមកបកប្រែប្រាប់    ជឿស៊ុនលង់ស្លាប់ចិត្តផ្តេសផ្តាស
បំផ្លាញទ្រព្យខ្លួនឲ្យវិនាស    ត្រូវណាស់ ដូច«ពស់ងង់ចំណី» ។
ដល់អ៊ីកឹកត់ខ្សត់ទាំងអស់    តើរស់ម្តេចបានក្នុងលោកិយ
គង់ស្លាប់ដោយសារការឥតធី    ស្លាប់ដោយសម្តីគេបង្អាប់ ។
គង់ស្លាប់ដោយគេខ្ចីដៃខ្មែរ    ឲ្យសម្លាប់ខ្មែរជាឈាមសាច់
ស្លាប់ដោយអស់ខ្យល់លំប្រកាច់    ស្លាប់ដាច់ទាំងជាតិពូជពង្សខ្មែរ ។
ស្លាប់បែបនេះឯងវេនអាប់យស    ហៅ «ស្លាប់ដូចពស់» ព្រោះឃ្លង់ព្រម
ទម្រាំដឹងខ្លួនសុខចិត្តញ៉ម    កំដល់ស្លាប់លុម អស់ផ្លូវកែ ។
រឯកន្ទុបនៅតែបំព្រែក    សម្ងំធ្មេចភ្នែកដេកធ្វេសធ្វេ
ភ្លេចខ្លួនជួនក្លាត់ចូលមាត់គេ    ទើបលៀនភ្នែកភ្លេះហៅគេជួយ ។
អស់ឫទ្ធឥតកលពាល់ផ្លូវស្រាយ    គ្មានមធ្យោបាយអ្វីណាមួយ
សង្ឃឹមសំណាំសុំជំនួយ    ឥសីលៃជួយទើបបានរស់ ។
ន័យនេះប្រៀបដូចជនឥតខ្ជឹម    ជួញចិត្តសង្ឃឹមគេទាំងអស់
មិនបេះសាងខ្លួនឲ្យខ្លាំងខ្ពស់    មានរូបនៅរស់តែះសារះបុទ្ធិ ។
គ្មានមធ្យោបាយស្រាយបញ្ហា    ផ្សងកាយៈសនាព្រេងអតីត
ពេញព្រះ-មេរគា-ព្រហ្មលិខិត    ផ្ទេរទុក្ខពីតែខឹងជំនួយ ។

គំនិតខ្លួនឯងវង្វេងស៊ុង គ្មានចិត្តគិតប្រុងបារម្ភព្រួយ
មានទុក្ខទើបទួញយំអួយ ស្រែកល្ហូរកឈ្នួយជួយអាសា ។
ពោះបើគេជួយឲ្យរស់កន តែប្រាជ្ញបុរាណលោកប្រាប់ថា
រស់នេះចូលផ្លូវត្រូវតម្រា ចែងថា«រស់ដូចក្អែប»ពិត ។
រស់នៅបែបនេះមិនទឹងទួន រស់នៅតែខ្លួនគ្មានជីវិត
រស់នៅដោយសារគេអាណិត ដល់គេប្រែចិត្តពិតជាស្លាប់ ។

មួយសោតដូចពេលបច្ចុប្បន្ន ស្រុកមានអាសន្នប្រែក្រឡាប់
ជាតិខ្មែរត្រូវខ្មោចយៀកមិញចាប់ មើលឃើញក្ដីស្លាប់យ៉ាងជាក់ស្ដែង ។
ពីដើមពូជខមជាចមពល ធ្លាប់ច្បាំងកំហឹងដល់ឥតចេះក្រែង
ល្បីខាងលំទឹងពឹងខ្លួនឯង គេកោតស្ញប់ស្ញែងទាំងសកល ។
ក្រោយមកចិត្តខ្មែរប្រែជាទន់ ចុះអន់ទន់អាប់ឥទ្ធិពល
ព្រោះដេកផ្អែកលើតែបុគ្គល ងងឹតងងល់ពុំយល់ផ្លូវ ។
អង្គុយតែស្មានថាគេខ្លាច ពូកែព្រោកប្រាជ្ញ ខ្លាចអស់ឪ
ដល់ទល់គំនិតជិតម្រឹតត្រូវ អាងផ្លាស់រស់ផ្លូវទៅពឹងគេ ។
ត្រង់គោលលំនឹងពឹងខ្លួនឯង ពុំខ្វល់ចាត់ចែងបង្កើតទេ
មានអីដល់ចេះតែពឹងគេ គំនិតខ្លាចខ្លកាន់តែខ្លាំង ។
ដល់ពេលអាសន្នគេជាន់ក ទើបមាត់ចំហត្រដរច្បាំង
តើធ្វើម្ដេចទៅផ្លូវគេតាំង បើគ្មានកម្លាំងខឹងទប់ទល់ ។

ដូច្នេះដើម្បីឲ្យបានរស់ រួចពីមាត់ពស់អសិរពិស
ត្រូវតែពឹងរកឥទ្ធិពល សុំគេឲ្យផ្តល់ផលជំនួយ ។
ទើបអាចបានរស់ហួសពីស្លាប់ ដោយសារតែកំព្រាមានគេជួយ
តែរស់បែបនេះរេរៃងព្រួយ រស់ដោយគេជួយដូច «កន្ទើប» ។

ហេតុនេះ យើងត្រូវមានវិចារ មនសិការ កុំគប់សេព្ត

ត្រូវតែបារម្ភរឿងពស់លេប ក្រែងអាចទេពជួយមិនទាន់ ។
ខ្វះបានរូបរស់មកប៉ុណ្ណោះ ទុកដូចជាបេះតែគ្រប់គ្រាន់
តែបើមិនគិតទៀតឲ្យទាន់ ក្រែងជាន់ទូកលិចមុនដល់ត្រើយ ។
ជំនួយគេជួយជាចំណួល ត្រូវតែប្រមូលគិតចឹងហើយ
តែគួរកុំភ្លេចខ្លួនសោះឡើយ កុំអាលលោតសើយសើចសប្បាយ ។
ត្រូវបេះជួយខ្លួនដោយខ្លួនឯង គិតការបែងចែកចាត់ចាយ
រឿងណាសម្រាប់តែសប្បាយ មិនត្រូវចំណាយជាដាច់ខាត ។
ត្រូវកាត់ចំណង់ដែលចង់បាន ដែលពាន់ប៉ះពារប្រយោជន៍ជាតិ
ធ្វើអ្វីលៃត្បិតតែឲ្យស្អាត ត្រូវយករឿងជាតិជាគោលគម្ពុ ។
ជំនួយជាភាគ រ៉ាជាផល គ្មានឫសគ្មានគល់ដូចដំណាំ
តែត្រូវឲ្យបេះបណ្តុះដាំ សាកផ្សាំដាំផ្សាយពូជជាថ្មី ។
ដូចជាស៊ីក្រូចគ្រាអភ័ព្យ ត្រូវលៃទុកគ្រាប់គាយកប់ដី
ស្រោចទឹកដាក់ដីថែឃ្មាតខ្មី គង់បានផ្លែឈើប់ស៊ុះ ។

ការយកជំនួយមួយមកប្រើ | បើយើងចេះធ្វើឲ្យផលទ្វេ
បណ្ដុះប្ញសគល់ទុកជាមេ | ទើបគេពេញចិត្តតែជួយ ។
កាលណាយើងសាងមូលដ្ឋាន | ជាគ្រឹះមាំបាន ក៏លែងព្រួយ
យើងអាចរស់នៅជាជាតិមួយ | មិនបាច់គេជួយដូចកន្ទែប ។

## យោបល់បន្ថែម

កាសិតភាសាពីព្រេងនាយ | មានន័យបរិយាយតាមបទបែប
ខ្មែរយើងធ្លាប់ពោលពាក្យសង្ខេប | ថា "ពស់ចំលេប កន្ទែបចំរើ" ។
ជាពាក្យរបស់ពួកកវី | លើកតួឥសីជាអ្នកប្រើ
ខ្ញុំអធិប្បាយដោយអទ្វើ | តាំងធ្វើជាអង្គប្រធានស្រាយ ។
ឃើញពិតហើយថា ពស់ដែលស្លាប់ | ព្រោះប្រាជ្ញាអាប់មិនយល់ឆ្ងាយ
ចំណីក្នងមាត់ក៏អន្តរាយ | តើរស់វែងឆ្ងាយទៅប៉ុន្មាន ។
បើចាប់បានហើយចេះតែបង់ | មិនអាចឲ្យគង់គ្រប់គ្រាបាន
ប្រាកដជាត្រូវអន្តរធាន | ក្សិណក្ស័យបែកហានពុំខានឡើយ ។
រីឯកន្ទែបឯបអបរស់ | រួចពីមាត់ពស់ពិតមែនហើយ
តែរស់សោះបុទ្ធិឥតស្រួលឡើយ | ព្រោះទៅបង្កើយខឹងក្ដស្លាប់ ។
ពេលនេះឥសីមកជួយទាន់ | ចុះបើអាសន្នក្រោយអភ័ព្យ
គ្មានគេមកជួយឲ្យដូចធ្លាប់ | គង់តែត្រូវងាប់ធាប់ទិងយូរ ។

តម្លៃជីវិតទាំងពីរហ្នឹង    បើថ្លឹងទឹងគ្នាផ្លាស់ប្តូរ
គឺស្លាប់អាប់យសមិនថ្លៃថ្នូរ    រស់ក៏មិនយូរព្រោះគ្មានឫទ្ធិ ៗ
ហៅ“ស្លាប់ក៏ចាញ់ រស់ក៏ចាញ់„    ចូលក្នុងសំណាញ់„ចាញ់គេ„ពិត
ដូចគ្នាប្រាកដអត់រខិត    ជនជាតិបណ្ឌិតពិតជាយល់ ៗ
ព្រោះហេតុហ្នឹងឯងទើបព្រេងព្រឹទ្ធ    ពោលពាក្យភាសិតទុកទប់ទល់
រំឭកទូន្មានឲ្យនយោបល់    ជាសព្វសាកលដូច្នេះថា= ៗ
“កុំស្លាប់ដូចពស់រស់ដូចកង្កែប    គួរប្រឹងគប់សេពសិល្បវិជ្ជា
កុំបណ្ដោយតាមកម្មយថា    កុំចាំអសនាលើកបាយបញ្ចុក» ៗ

× × ×

# កំណត់-ប្រវត្តិការណ៍

## អនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃ

លើកទី ២៨ ប្រចាំឆ្នាំ ១៩៧២

( ថ្ងៃ ១៧-១-៧២ )

ថ្វីត្បិតតែពេលនេះ ប្រទេសជាតិយើងកំពុងតែមានសង្គ្រាមឈ្លានពានពីសំណាក់ពួកទមិឡអតសាសនា យ៉ាងណាក្តី ព្រះសង្ឃពុទ្ធសាសនិក នៅតែប្រឹងប្រែងបំពេញភារកិច្ចបានទៀងទាត់ដូចកាលពីដើមដែរ ។ នៅថ្ងៃទី ១៦ មករា ១៩៧២ ព្រះសង្ឃដែលមានតំណាងមកពីគ្រប់អាណាខេត្ត លើកលែងតែតំបន់អសន្តិសុខខ្លាំងមកមិនរួច, បាននិមន្តមកជួបជុំនៅរដ្ឋធានីភ្នំពេញ ដើម្បីធ្វើមហាសន្និបាតពិភាក្សាគ្នាពីបញ្ហាផ្សេង ៗ ដែលទាក់ទងនឹងព្រះពុទ្ធសាសនា គឺគណៈមហានិកាយជួបជុំនៅវត្តឧណ្ណាលោម ឯគណៈធម្មយុត្តិនៅវិហារវត្តបទុមវតី ។ វេលាម៉ោង ១៥ កន្លះ ការជួបជុំមហាសន្និបាតនេះបានប្រព្រឹត្តទៅរៀងខ្លួនទាំងពីរគណៈ នៅចំពោះមុខលោករដ្ឋមន្ត្រីក្រសួងធម្មការ ឧត្តមសេនីយ៍ទោ ថាប្បាណាងិន្ទ និង អនុរដ្ឋលេខាធិការ ប៊ុណ្ណ ចន្ទម៉ុល ដំមានមន្ត្រីអគ្គមុខអ្នកការនៅក្រសួងធម្មការជូនដំណើរផង គឺមានលោក ហ៊ីង-សាខុន, នួន-សាមិន, តែ-ម៉េង-ហាប់, ថាច-សីវណ្ណ, អ៊ុក-សាម៉ុន, លី-ឆាមគេង, គង់ គាត, វង្ស-ម៉េង, សរ-បេងគុត, ហង្ស-បេក, ប៊ុក-វ៉ា, ស្តើង-ធូរ, និង កង-ថូ ។

លុះដល់ថ្ងៃចន្ទទី ១៧ មករា ១៩៧២ វេលាម៉ោង ១៥ មានពិធីជាផ្លូវការមួយទៀត បានប្រព្រឹត្តទៅឡើងនៅសាលសន្និសីទចតុមុខ ដែលគេសង្កេតឃើញមានសភាពគួរអធិកអធម ក្រៃលែងចាប់ពីម៉ោង ១៥ ទៅមានការជួបជុំមន្ត្រីសង្ឃទាំងពីរគណៈ ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ ។ ម៉ោង ១៦ គត់លោកប្រមុខរដ្ឋ ចេង ហេង អញ្ជើញមកដល់ ដោយមានលោកប្រធានសភាធម្មនុញ្ញ អ៊ិន តាំ និងលោកនាយករដ្ឋមន្ត្រីប្រតិភូ សិរិមតៈ គមផង មួយអន្ទើនឹងសមាជិកសមាជិកាសភាធម្មនុញ្ញ និងសមាជិកទាំងអស់នៃរដ្ឋាភិបាល ព្រមទាំងទីប្រឹក្សាប្រមុខរដ្ឋ ទីប្រឹក្សានាយករដ្ឋមន្ត្រី នាម៉ឺនសព្វមុខមន្ត្រីជាច្រើនទៀត ។

ភ្លេងជាតិបានបន្លឺឡើង មុននឹងលោកប្រមុខរដ្ឋចូលកាន់ទីអាសនៈកិត្តិយស, រួចហើយមានការសូត្រស្វាធ្យាយនាទីដើម្បីគោរពវិញ្ញាណក្ខន្ធព្រះសង្ឃនិងយុទ្ធជន ព្រមទាំងពុទ្ធបរិស័ទទាំងអស់ដែលធ្វើកាលកិរិយាទៅដោយសារសង្គ្រាម ។ កណ្តាលស្នូរភ្លេងដ៏ស្រងូតស្រងាត់ ទឹកព្រះភក្ត្រទឹកមុខនៃសមាជិកមហាសន្និបាតទាំងអស់ ស្ងួតស្ងៀមស្រពាប់ស្រពោនក្រៃលែង ហាក់អណ្តែតត្រសែតទៅរលឹកឃើញដល់មិត្តភក្តិញាតិមិត្តផ្សេងៗខ្លួនដែលទទួលគ្រោះតាមសមរភូមិនានា ។

តមកលោករដ្ឋមន្ត្រីក្រសួងធម្មការ ចាប់ថ្លែងសុន្ទរកថាមួយក្នុង[illegible] សភាពដ៏ស្ងប់ស្ងាត់នេះ ដែលបន្ទាប់មកព្រះវ៉ែត ប៊ុណ្យ សុផាត [illegible]

ខេត្តបាត់ដំបងគណៈមហានិកាយ ថ្លែងក្នុងនាមព្រះសង្ឃទាំងអស់ នូវសុន្ទរកថាតបវិញជាទីរំជួលចិត្តណាស់ដែរ ។ ដើម្បីទុកជាការពិចារណារបស់លោកអ្នកអាន យើងសូមចុះផ្សាយសុន្ទរកថាទាំងពីរនេះនៅទំព័របន្ទាប់ទៅទៀត ។

ម៉ោង ១៧ បន្ទាប់ពីស្វាធ្យាយជយន្តោប្រសិទ្ធិពរជ័យ ពួកគឹកកងមកលោកប្រមុខរដ្ឋ លោកប្រធានសភាជម្មនុញ្ញ និងលោកនាយករដ្ឋមន្ត្រីប្រតិភូបានអញ្ជើញឡើងទៅក្រាបបង្គំគាល់សុំលាសម្តេចព្រះសង្ឃរាជ ដែលវេលានោះសម្តេចបានជូនញត្តិរបស់ព្រះសង្ឃទាំងពីរគណៈ ទៅលោកប្រមុខរដ្ឋដើម្បីថ្លែងចំពោះមតិសកលលោក និងអ្នកកាន់សាសនាទាំងអស់ឲ្យជួយធ្វើអន្តរាគមន៍ឃាត់ឃាំងមារសត្រូវ កុំឲ្យរំលោភបន្តសកម្មភាព ធ្វើទុក្ខធ្វើបាបព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរតទៅទៀត ។

បន្ទាប់ពីលោកប្រមុខរដ្ឋនិងវរជនទាំងអស់អញ្ជើញចេញហើយ ក៏មានការប្រគេនកេសដ្ឋៈចំពោះព្រះសង្ឃ ហើយតមកមានបញ្ចាំងខ្សែភាពយន្តប្រគេនព្រះសង្ឃទតអំពីរឿងទសន្ទនកិច្ច នៃគណៈប្រតិភូពុទ្ធសាសនាខ្មែរទៅប្រទេសថៃ, អំពីការខូចខាតព្រោះសង្គ្រាមនៅតាមតំបន់ខ្លះនៃប្រទេសយើង និងអំពីសកម្មភាពអង្គការផ្តល់ជំនួយដល់អ្នករងគ្រោះទាំងអស់នោះផង ។

វេលាម៉ោង ២០ ទើបចប់សព្វគ្រប់ ។ ឯការប្រជុំនៃមន្ត្រីសង្ឃនៅតែប្រព្រឹត្តទៅតាមវគ្គទាំងពីរ បន្តទៅអស់រយៈ ២ ថ្ងៃទៀត ។

# សុន្ទរកថា

លោករដ្ឋមន្ត្រី ក្រសួងធម្មការ ថ្លែងក្នុងឱកាស

អនុសំវច្ឆរៈមន្ត្រីសង្ឃលើកទី ២៨

សូមនមស្ការ សម្តេចជាអម្ចាស់

សូមពិតពុទ្ធដីកា ព្រះតេជគុណគ្រប់ព្រះអង្គ

សូមគោរពលោកប្រមុខរដ្ឋ

– លោកប្រធានសភាធម្មនុញ្ញ

– លោកនាយករដ្ឋមន្ត្រី ព្រមទាំងសមាជិករដ្ឋាភិបាល

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងក្នុងនាមក្រសួងធម្មការ នូវអំណរព្រះគុណដ៏លើសលុប ចំពោះវត្តមាននៃសម្តេចជាអម្ចាស់ មន្ត្រីសង្ឃ និងលោកអ្នក ជាពុទ្ធបរិស័ទ ដែលបាននិមន្តនិងអញ្ជើញជាអធិបតីក្នុងពិធីបើកមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ២៨ ក្នុងវេលានេះ ។ ព្រះវត្តមាននៃសម្តេច និងព្រះករុណាគ្រប់ព្រះអង្គ និងវត្តមាននៃអស់លោក បញ្ជាក់យ៉ាងច្បាស់នូវសាមគ្គីធម៌របស់ខ្មែរ ក្នុងក្របខណ្ឌព្រះពុទ្ធសាសនា ដ៏ជាទីគោរពបូជាពិសិដ្ឋថ្លៃថ្នារបស់យើង ។

អនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃនេះ បានប្រព្រឹត្តទៅជារៀងរាល់ឆ្នាំ ដើម្បីពិភាក្សាដោះស្រាយបញ្ហាជាច្រើនក្នុងវិស័យកិច្ចប្រតិបត្តិព្រះពុទ្ធសាសនានៅក្នុងប្រទេសយើង ហើយលទ្ធផលក៏តែងបានទទួលយ៉ាង

គ្រប់គ្រងជាទីពេញចិត្ត ។ ប៉ុន្តែនៅឆ្នាំនេះយើងប្រជុំគ្នាដោយភាពកក្តុក ក្តួលពន់ពេកណាស់ ព្រោះព្រះសង្ឃយើងមួយភាគធំ ពុំបានសុខសាន្ត ត្រាណដូចប្រក្រតីទេ ដោយសារតែមានខ្មាំងសត្រូវនឹងសាសនា វាកំពុង តែញាំញីរុករានចូលក្នុងវត្តអារាម ធ្វើបាបពុទ្ធបរិស័ទដោយសេចក្តីឈ្នានិស មិនឲ្យប្រតិបត្តិពុទ្ធសាសនា ។ ដោយសារគំនិតគិតព្យាបាទរបស់ពួកខមិឡ វាចាប់ព្រះសង្ឃធ្វើទារុណកម្មយ៉ាងឃោរឃៅបំផុត ដូចជាយកទៅវាយ សំពង ដាក់ទឹងជើង ខ្វេះព្រះនេត្រ ចងសណ្តូនថ្មទំលាក់ទឹកជាដើម ។ ម្លោះហើយសកម្មភាពផ្សេងៗ ខាងសាសនាយើងដែលធ្លាប់តែប្រព្រឹត្តទៅ ហូរហែក្នុងទីវត្តដែលយើងមានវត្តដល់ទៅបីពាន់ពីរយប្លាយនោះ ពុំអាច ធ្វើទៅបានដូចធម្មតាទេ ។ អគារសិក្សាពុទ្ធសាសនានៅតាមខេត្តនានា ត្រូវបិទទ្វារ អាចារ្យនិងសិស្សត្រូវរត់ខ្ចាត់ខ្ចាយ ខ្លះភៀសខ្លួនទៅជ្រកទី ដទៃ ឬមកក្រុងភ្នំពេញក៏មាន ។ ព្រះវិហារ កុដិ សាលា ក៏ត្រូវធ្វើឲ្យ វិនាសខូចខាតតាមល្បិចអប្រិយរបស់វា ។ ក្បួនខ្នាតគម្ពីរដីកាទាំងប៉ុន្មាន ដែលមាននៅក្នុងវត្ត ក៏ត្រូវពួកអាខមិឡតរដុតបំផ្លាញឲ្យអន្តរាយហិនហោច អស់ ។ ទាំងនេះហើយជាសេចក្តីសោកសៅ ដែលយើងខ្ញុំព្រះករុណា ខ្ញុំ បាទថា ពិធីយើងក្នុងវេលានេះ ប្រកបដោយចិត្តកក្តុកក្តួលក្រៃលែង ។

អាស្រ័យដោយការយល់ច្បាស់នូវទុក្ខសោកព្រះសង្ឃនិងបងប្អូនខ្មែរ ជាពុទ្ធបរិស័ទនៅតាមខេត្តនានានោះ ក្រសួងធម្មការក្នុងនាមរដ្ឋាភិបាល

ធ្វើជាញឹកញយនូវពិធីបុណ្យសាមគ្គី ប្រមូលសប្បុរសធម៌នៃអ្នកមានសទ្ធា ដើម្បីជួយផ្តល់ជាទេយ្យវត្ថុទានជាទំនួយសង្គ្រោះចំពោះព្រះសង្ឃយើង ចំពោះពុទ្ធបរិស័ទយើង ដែលនាំគ្នារត់មកពាក្យាបាលក្នុងមន្ទីរពេទ្យ ឬមកជ្រកនៅសុំសេចក្តីសុខមួយគ្រានៅវត្តណានី ឬនៅទីប្រជុំជនណាមួយ ។

ជាមួយគ្នានេះទៀត ក្រសួងបានចាត់ការអំពាវនាវចំពោះអង្គការសប្បុរសធម៌និងអង្គការសាសនាទាំងអស់ក្នុងសកលលោក ឲ្យគេដឹងឮច្បាស់ពីឧក្រិដ្ឋកម្មដែលពួកសត្រូវអនេត្រិយ ធ្វើមកលើពុទ្ធបរិស័ទយើងនេះផង និងសូមឲ្យអង្គការទាំងនោះជួយប្រើគ្រប់មធ្យោបាយដើម្បីហាមឃាត់អំពើអមនុស្សធម៌នេះផង ។ ដោយសារសេចក្តីអំពាវនាវនេះ យើងក៏បានទទួលជំនួយជាវត្ថុខ្លះ ដែលសម្រាប់ជួយសម្រាលទុក្ខរបស់ពុទ្ធបរិស័ទរួមជាតិយើង ។ ឯអង្គការសាសនាទាំងនោះក៏បានជួយស្រែកបន្តសម្លេងឲ្យយើងបន្ថែមតិអន្តរជាតិដែរ ដូចជាសន្និសីទពុទ្ធសាសនានៅក្រុងសេអ៊ូល នៅក្រុងតាយប៉ិ ហើយថ្មីៗនេះនៅក្រុងបាងកកជាដើម ។ ចំណែកកិច្ចការសង្គ្រោះនៅខាងក្នុងនេះវិញ រដ្ឋាភិបាលតែងគិតគូរជានិច្ច ចំពោះព្រះសង្ឃដែលភៀសព្រះអង្គមកគង់នៅទីនវត្តនានាក្នុងទីក្រុង ឬគង់ពាក្យាបាលពេកក្នុងមន្ទីរពេទ្យដោយផ្តល់នូវបច្ច័យបួន តាមមធ្យោបាយដែលអាចធ្វើបាន ។ ឯនៅទីណាដែលអាចរៀនសូត្រកើត ក៏បានបើកថ្នាក់រៀនបាត់ឲ្យមានអាចារ្យទៅបង្រៀនប្រចាំការ ដើម្បីឲ្យសេចក្តីការសិក្សានៅ

ក្រុងភ្នំពេញ និងនៅខេត្តបាត់ដំបងដែលជាទីមានសុខសាន្តនៅឡើយ ។ គឺថាមុនពេលសង្គ្រាម យើងមានសាលាពុទ្ធិកបឋមសិក្សាចំនួន ៩៣ ប៉ុន្តែពេលកាលថ្ងៃនេះបើករៀនចំនួនតែ ៥០ ទេ ហើយកខ្វែងខ្វះរៀនដោយភិតភ័យផង ។ ឯពុទ្ធិកវិទ្យាល័យមានពីរ នៅភ្នំពេញមួយ នៅបាត់ដំបងមួយ ក៏កំពុងតែមានដំណើរល្អជាធម្មតា សម្រាប់សម្រិតសម្រាំងសិស្សបន្តឧត្តមសិក្សា គឺបូលពុទ្ធិកសាកលវិទ្យាល័យទៀត ។

ដូច្នេះ អនុសំវេរ របស់មន្ត្រីសង្ឃបន្ទាប់បន្តទៅនេះ ពិតជាមានពិភាក្សាច្រើន ទាក់ទងនឹងផលវិបាកនៃសង្គ្រាមនេះឯង ។

ជាអវសានខ្ញុំព្រះករុណា ខ្ញុំបាទ សូមលំឱនកាយថ្វាយអំណរព្រះគុណសម្តេចជាអម្ចាស់ និងព្រះថេរានុត្ថេរៈ ព្រមទាំងអស់លោកពុទ្ធបរិស័ទជាចម្បងទៀត ដែលបាននិមន្ត និងអញ្ជើញមកចូលរួមក្នុងពិធីនេះ ឲ្យកាន់តែមានសុភាពអធិកអធមឡើង ទោះបីជាស្រុកទេសកំពុងតែមានភយន្តរាយក៏ដោយ ។

# សុន្ទរកថា

តំណាងមន្ត្រីសង្ឃ

ថ្លែងតបចំពោះសុន្ទរកថា លោករដ្ឋមន្ត្រីក្រសួងធម្មការ

ក្នុងឱកាសអនុសំវច្ឆរមហាសន្និបាតទី ២៨

សូមចម្រើនពរចំពោះលោកប្រមុខរដ្ឋ

- លោកប្រធានសភាធម្មនុញ្ញ
- លោកនាយករដ្ឋមន្ត្រី
- សមាជិករាជ្យាភិបាល
- សមាជិកសភាធម្មនុញ្ញ
- អស់លោកមន្ត្រីរដ្ឋការ

និង ឧបាសក ឧបាសិកាពុទ្ធបរិស័ទ

តាមព្រះរាជបញ្ជា នៃសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ ខ្ញុំព្រះករុណាអាត្មាភាព សូមថ្លែងជាតំណាងនៃមន្ត្រីសង្ឃ ដែលបានមកកាន់មហាសន្និបាត ក្នុងឱកាសនេះ ដើម្បីតបចំពោះ សុន្ទរកថានៃលោករដ្ឋមន្ត្រីក្រសួងធម្មការ ។

លោករដ្ឋមន្ត្រី

អម្បាញមិញ លោកមានប្រសាសន៍ថា នៅឆ្នាំនេះ យើងប្រជុំគ្នា

ដោយការក្តុកក្តួលពន់ពេកណាស់ ព្រោះព្រះសង្ឃយើងមួយភាគធំ ពុំបានសុខសាន្តត្រាណដូចប្រក្រតីទេ ។

ប្រសាសន៍របស់លោករដ្ឋមន្ត្រីនេះ ជាពាក្យពិតក្រៃលែងពិត ។ យើងក្តុកក្តួលរំជួលចិត្តក្រៃលែង ។

សម្តេចព្រះសង្ឃរាជជាអម្ចាស់ បានបញ្ចេញព្រះឧទានវាចាប្រាប់ខ្ញុំព្រះករុណាអាត្មាភាពថាៈ "៨០ ឆ្នាំហើយ ខ្ញុំព្រះករុណាពិបាកចិត្តពេលណា ក៏មិនដល់ មិនដូចពេលនេះដែរ . . .

បើធ្លាប់បានជួបប្រទះនឹងសង្គ្រាមពីមុនមកដែរ ដូចសង្គ្រាមជប៉ុននិងសម្ពន្ធមិត្តបារាំង សង្គ្រាមទាមទារឯករាជពីអាណាព្យាបាលបារាំងជាដើម ប៉ុន្តែពេលនោះ ព្រះសង្ឃហាក់ដូចជាមិនសូវមានទុក្ខព្រួយខ្លាំងដូចនៅពេលនេះទេ សង្គ្រាមបច្ចុប្បន្ននេះ ពិតជាសង្គ្រាមសាសនា ។ ពុទ្ធសាសនា កំពុងទទួលរងមុខរបួស ជួបប្រទះនឹងវិនាសកម្មច្រើនប្រការ ។ល។

មន្ត្រីសង្ឃ ខេត្តក្រៅ និងក្នុងក្រុង បានជួបជុំគ្នា ជាមហាសន្និបាតមួយឆ្នាំម្តង គួរណាស់តែមានសេចក្តីរីករាយ មិនដូច្នោះ កាលពីឆ្នាំមុនក៏ដូចជានៅពេលនេះ យើងមានទឹកមុខក្រៀមក្រំ ដំណាលអំពីសេចក្តីទុក្ខលំបាក សេចក្តីវិនាសខូចខាត នៃព្រះពុទ្ធសាសនា ប្រាប់គ្នាទៅវិញទៅមក ។ល។ ប៉ុន្តែយើងនៅមានសង្ឃឹមថា មិនយូរប៉ុន្មាន សេចក្តីទុក្ខលំ

បាក់ និងវិនាសកម្មដ៏ខ្លោចផ្សាទាំងនេះ នឹងដល់ទៅទីបំផុតចុងចប់មិនខាន ៗ

មន្ត្រីសង្ឃទាំងអស់សង្ឃឹមថា រដ្ឋាភិបាលនឹងរៃលក ជួយដោះស្រាយយ៉ាងណាឲ្យព្រះពុទ្ធសាសនា បានប្រកបដោយសុខសន្តិភាព និងឲ្យមានសេចក្តីចម្រើន លូតលាស់ដូចដើមវិញពុំខាន ៗ រដ្ឋាភិបាលនិងជួយអំពាវនាវ ចំពោះរដ្ឋាភិបាលប្រទេសនានា ក្នុងពិភពលោក ឲ្យជួយរកមធ្យោបាយរំលត់ភ្លើងសង្គ្រាម ជាពិសេសជួយការពារព្រះពុទ្ធសាសនាទប់ទល់នឹងវិនាសកម្ម នៃអាយុជីវិតពុទ្ធបរិស័ទ និងសម្បត្តិវប្បធម៌ក្នុងអនាគតដ៏ខ្លីនេះពុំខាន ៗ

លោករដ្ឋមន្ត្រី

សេចក្តីទុក្ខដូចអាត្មាភាព បានរៀបរាប់យ៉ាងសង្ខេបដូចខាងលើនេះ នៅមិនទាន់ផុតរលត់អំពីចិត្តគំនិតនៅឡើយផង ស្រាប់តែនៅពេលបានមកជួបជុំគ្នានេះ មន្ត្រីសង្ឃគ្រប់រូប សម្តែងសេចក្តីព្រួយបារម្ភមួយថ្មីទៀត ខ្លាចក្រែងព្រះពុទ្ធសាសនាខ្មែរយើង រអិលធ្លាក់ទៅក្នុងហាយនភាព ដោយហេតុមានព្រះសង្ឃផុងខ្លួនចូលទៅក្នុងនយោបាយ ជាមួយគណៈផ្សេង ៗ ក្នុងការឃោសនាប្រណាំងប្រជែង ដណ្តើមចំនួនសន្លឹកឆ្នោតដើម្បីខ្លួនឬដើម្បីបក្សពួករបស់ខ្លួន ៗ

ព្រះសង្ឃក្នុងប្រទេសកាន់ព្រះពុទ្ធសាសនាខ្លះ បានលង់ខ្លួនក្នុងផ្លូវនយោបាយដឹកនាំរដ្ឋ ហើយបានទទួលកេរ្តិ៍ឈ្មោះអាក្រក់ ពេញពិភពលោក

ជាហូរហែមកហើយ ។ ចំណែកខាងព្រះសង្ឃខ្មែរយើងតែងមានកេរ្តិ៍ឈ្មោះល្អ ។ គេតែងសរសើរថា យើងបេះបាត់ការត្រឹមត្រូវ គួរគេយកតម្រាប់តាម ។

ដោយហេតុនេះមន្ត្រីសង្ឃគ្រប់រូប ក្រោមព្រះឱវាទនៃសម្តេចព្រះសង្ឃរាជជាអម្ចាស់ សូមសង្ឃឹមលើលោកប្រមុខរដ្ឋ និងរដ្ឋាភិបាលដែលបានបង្ហាញកស្តុតាងយ៉ាងជាក់ស្តែង ក្នុងកាលៈទេសៈដ៏លំបាកនេះចំពោះការរក្សាទំនៀមទម្លាប់ប្រពៃណី និងការឧបត្ថម្ភព្រះពុទ្ធសាសនា ជាប្រាកដជានឹងមិនបណ្តែតបណ្តោយឲ្យព្រះសង្ឃខូចបង់កិត្តិយស ចូលប្រឡូកប្រឡល់ ក្នុងបក្សពួកនយោបាយដែលជាកិច្ចការរដ្ឋការសុទ្ធសាធ ខុសប្រពៃណី ខូចកេរ្តិ៍ឈ្មោះដូចប្រទេសខ្លះនោះឡើយ ។

ដោយមានសេចក្តីសង្ឃឹមថា ប្រពៃណីល្អរបស់ពុទ្ធសាសនាខ្មែរ នឹងស្ថិតស្ថេរចិរកាលក្នុងនាមមន្ត្រីសង្ឃ ក្នុងមហាសន្និបាតនេះ អាត្មាភាពសូមជូនពរសព្វសាធុការពរ ចំពោះលោកមន្ត្រីរដ្ឋការគ្រប់ក្រសួង គ្រប់ក្រុមទាំងទាហាន ទាំងស៊ីវិល មានលោកប្រមុខរដ្ឋ លោកប្រធានសភាធម្មនុញ លោកសេនាប្រមុខ, និងលោកនាយករដ្ឋមន្ត្រីប្រតិភូជាអាទិ, សូមបានប្រកបដោយព្រះពុទ្ធពរ អាយុ, វណ្ណៈ, សុខៈ, ពលៈ គឺរៀងទៅកុំបីឃ្លាត ។

សូមចម្រើនពរ

## កំណត់ការិយាល័យនិពន្ធ:

សមាគមអ្នកនិពន្ធខ្មែរ បានចេញផ្សាយ ជាពុម្ពរ៉ៃវៃ នូវអត្ថបទមួយ របស់គណៈកម្មការស្រាវជ្រាវស្ដីអំពីប្រវត្តិហូរហែនៃល្ខោនខ្មែរ ។

យើងយល់ថាអត្ថបទនេះអាចទុកជាឯកសារមួយយ៉ាងសំខាន់សម្រាប់អ្នកស្រាវជ្រាវតទៅថ្ងៃមុខទៀត ដូច្នេះយើងសូមចុះផ្សាយទាំងស្រុងនូវអត្ថបទនេះ ទុកជាហិតប្រយោជន៍អ្នកស្រាវជ្រាវតទៅ:

# ការស្រាវជ្រាវអំពីល្ខោនខ្មែរ

*ប្រទេសជាតិនីមួយ ៗ តែងតែ ទិង ពង្រីកវប្បធម៌ជាតិខ្លួន ពុំដែលលស់ខាន ។ ខ្មែរយើង ក៏បានពង្រីកវប្បធម៌ជាតិគ្រប់ផ្នែកគ្រប់វិស័យដែលធ្លាប់មានមកហើយស្រាប់ក្ដី ឬ ទើបតាក់តែងឲ្យមានឡើងថ្មីក្ដី ។ ហេតុបានជាខិតខំក្នុងវិស័យនេះ ព្រោះជនជាតិយើង ក៏ដូចជនជាតិនានាដែរ យល់ច្បាស់ថា វប្បធម៌ជាគ្រឿងបណ្ដុះនិស្ស័យមនុស្ស ពង្រីកស្មារតីមនុស្ស ឲ្យមានប្រាជ្ញាវាងវៃ ចេះមើលចេះគិតកិច្ចការអ្វីមួយបានវែងឆ្ងាយ ។ មិនតែប៉ុណ្ណោះ មនុស្សម្នាក់ ៗ តែងមានមនោសញ្ចេតនាប្រចាំរាងកាយ ហើយមនោសញ្ចេតនានោះឯង ចេះត្រូវការឲ្យមានចំណីអាហារជានិច្ចជាកាលដែរ គឺថា បើចរិតកោតចំណីចាស់ផ្អែតផ្អល់ហើយ គេរាងតែត្រូវការឲ្យបានទទួលរសជាតិចំណីថ្មី ៗ ទៀត ។ និយាយឲ្យច្បាស់ថា បើយើងធ្លាប់ក្រេបរសជាតិបរិប្បូរៈចាស់ផ្អែតផ្អល់យូរបន្តិចហើយ ក៏ត្រូវការតាក់តែងឲ្យបានជាបរិប្បូរថ្មីទុកជំនួស ឬមក*

បន្ថែមទៀត ទើបមានការចូលចិត្តទៅទៀត ។ អាស្រ័យហេតុនេះ ហើយ បានជាអ្នកតុបតែងសិល្បៈចេះតែផ្លាស់ប្ដូរទៅតាមរបៀបថ្មី ៗ ជាធម្មតា ពិសេស គឺសិល្បៈដែលចេញជារូប ជាកាយវិការ ជាទស្សនីយ-ភាព យ៉ាងច្បាស់លាស់ដូចជា "ល្ខោន" នេះឯង ។

ល្ខោនខ្មែរយើង ក៏មានប្រវត្តិវែងឆ្ងាយ ដូចជាល្ខោននៅប្រទេសនានាដែរ ។ បុព្វបុរសយើង ចេះបង្កើតវប្បធម៌ ក៏បង្កើតល្ខោននេះឯងទុកមកឲ្យយើងដែរ ។

ពាក្យថា **ល្ខោន** តាមវចនានុក្រម ពន្យល់ថា ក្លាយមកពីភាសាសៀមថា ឡ្ៈខន[១] ដែលបានន័យថា មហោស្រពមួយប្រភេទលេងមានជារឿងវែងឬខ្លី ។ ដូច្នេះ បើគិតតែពាក្យឈ្មោះនេះ នាំឲ្យអ្នកខ្លះច្រឡំថា ខ្មែរទើបតែមានល្ខោននៅសម័យដែលខ្មែរទទួលវប្បធម៌មកពីសៀមមកវិញ គឺរវាងសតវត្សទី ១៧,១៨ និង ១៩ ។

ក៏ប៉ុន្តែតាមពិតមិនដូចនោះទេ កាលមុននឹងមានពាក្យថា ល្ខោន, កាលនោះ យើងមានឈ្មោះផ្សេងហៅថាអ្វីទៅទៀត ដូចកំណត់ហេតុរបស់ជីវតាក្វាន់ ដែលសរសេរពីស្រុកយើង សម័យ គ.ស. ១២៩៧ ៩៨ ថា: គេលេងរបាំមហោស្រពមួយយ៉ាងហៅថា អៃឡា ទំនងជាក្លាយពីពាក្យ

១ — តាមការស្រាវជ្រាវរបស់លោក សឺដេស (Bulletin S.E.I. 1963) ថា ឡ្ៈ ខន មកពី លខាំខោន ឬ រាំខោល ។ ខោល ជាប្រភេទស្វាមួយបែប ; រាំខោល = របាំស្វា ។

ខ្មែរយើងថា "រេក" គឺគេលេងរបាំដំណាលជារឿង នៅក្នុងពេលចូលឆ្នាំ (១) ។ តាមសិលាចារឹកភិមានអាកាសរបស់ក្សត្រីឈ្មោះ ឥន្ទ្រទេវី ថា ក្សត្រីនេះខ្លួនឯង បានប្រមូលផ្តុំពួកកូនស្រីៗនៅក្នុងវាំងធ្វើជាក្រុមរបាំហើយ ក្សត្រីនេះទៀត បានតាំងសរសេររឿងដកស្រង់ពីជាតកនានា សម្រាប់ឲ្យក្រុមនេះ លេងល្ខោនឲ្យអ្នកស្រុកមើលផង ។ ខទាំងនេះ បញ្ជាក់ថា ខ្មែរសម័យសតវត្សទី ១២-១៣ ឯនោះ មានក្រុមរបាំសម្តែងរឿងច្បាស់ណាស់ទៅហើយ គ្រាន់តែពុំទាន់បញ្ញាឈ្មោះថា "ល្ខោន" នៅឡើយប៉ុណ្ណោះ ។

ឥឡូវនេះ យើងសូមអធិប្បាយតែប្រវត្តិ ល្ខោន ចាប់ពីមានពាក្យហៅថា "ល្ខោន" នេះមក ហើយសូមយកតែតាមការ ដែលយើងស្រាវជ្រាវឃើញហើយ ចំណែកភាគតិចមានដែលពុំទាន់ច្បាស់កំពុងតែស្រាវជ្រាវនៅឡើយតទៅមុខទៀតនោះ យើងសូមទុកមួយអន្លើសិន នឹងមានអធិប្បាយបន្ថែមនៅពេលក្រោយទៀត ។

ពាក្យ ល្ខោន ទើបតែបញ្ចេញ ឥទ្ធិពលខ្លាំងនៅពេលសតវត្សទី ២០ យើងនេះ គឺសំខាន់កើតពីពួកមជ្ឈដ្ឋានអ្នកធំអ្នកខ្ពស់ មានស្តេច ឬ មន្ត្រីធំនេះឯងជាដំបូង ។ ចំណែកអ្នកស្រុកសាមញ្ញ គេ ជាមានទំនៀមការ

---

១-សូមអានសៀវភៅ កំណត់ហេតុ របស់ជីវតាក្វាន់ អំពីប្រពៃណីអ្នកស្រុកចេនឡា ជាត់ចែងប្រែផ្តាច់ពីភាសាចិន ដោយ លី ធាមតេង ។

សម្ដែងសិល្បៈជាទស្សនិយភាពរបៀបគ្នានេះ កំគេហៅឈ្មោះថាអ្វីផ្សេងៗ ទៅទៀត ដូចជា យីកេ, អាយ៉ៃ, ណាំង, ខោល (របាំពាក់មុខស្វា) ដូច្នេះជាដើម ។ ប៉ុន្តែ របៀបបែបទាំងនេះ ចេះតែខ្សោយឥទ្ធិពល បន្តិចម្ដងៗ មកពីឥទ្ធិពលល្ខោនចេះតែផ្សាយខ្លាំងឡើងៗ បញ្ចូលល្បិចសិល្បៈថ្មីៗ មកពីប្រទេសក្រៅ ច្រើនឡើងៗ ជ្រួតជ្រាបទៅគ្រប់ស្រុកភូមិកាន់តែសុសសាយឡើងដែរ ។ ទទួលអ្នកស្រុកបានជួបប្រទះនៃភ្នែកនឹងសិល្បៈថ្មីៗ ទៅ រឹងរឹតតែចូលចិត្ត តាមបែបបទដែលហៅថាល្ខោននោះកាន់តែខ្លាំងសព្វភូមិស្រុក ។

ក្រុមល្ខោន ដែលឧបត្ថកពាក្យនេះជាឈ្មោះនោះ គឺក្រុមល្ខោននៅក្នុងវាំង ដែលហ្លួននរោត្តម បានចាត់ចែងឲ្យមានឡើង ហើយឧបត្ថម្ភពេញបន្ទុក ដោយឲ្យប្រាក់ផ្គាន់ពួកកូនរាំ នឹងរើសយកគ្រូមកពីស្រុកសៀម ដែលចេះក្បាច់រាំចេះតាក់តែងកាយ ចេះដឹករឿង ចេះបង្ហាត់កូនរាំៗ ពួកគ្រូរបាំទាំងនេះ ច្រើនមានរាសនាបានជាឃុន ឬ ជាម៉ឺន (ប្រពន្ធហ្លួន) ផង ។ ហើយឃុន-ម៉ឺនទាំងនោះចង់ឲ្យគាប់ព្រះទ័យហ្លួន ក៏រក្សាស្និតស្នាងក្រុមល្ខោនខ្លួន ឲ្យប៉ិនថេរនៅសម្រាប់លេងថ្វាយស្ដេច ទតក្រសាលនៅពេលបុណ្យទានផ្សេងៗ ភោះបើក្រុមខ្លួនល្អក៏ មិនសូវល្អក៏ គឺទំរកល្បិចឲ្យបានថ្មីៗ គ្នា ដូចមានពាក្យទំនុកទំនើរចាស់ៗ នៅក្រុងភ្នំពេញ ដែលធ្លាប់ចេញចូលក្នុងវាំងពីដើម ធ្លាប់ដំណាលសូត្រលេងថា:

លោនយុនថាន់ដូចផ្កាត្រកៀត

លោនយុនព្រះញាតិដូចផ្កាត្រកួន

លោនម៉មសួនដូចយួនហាក់បោយ ។

តាមប្រសាសន៍លោកតា ជុំ ហួន ដែលជាអ្នកចូលចិត្តលោនថាន់ថាស់ថាន់ថ្មី ហើយលោកនិយាយប្រាប់យើងថា បានជាថាដូច្នេះ ព្រោះ :

១ យុនថាន់ ជាទីសំណព្វព្រះទ័យហ្លួង គឺមានមធ្យោបាយច្រើនរចនាលោនបានល្អ ទើបប្រដូចទៅនឹងផ្កាត្រកៀត ។

២ យុនព្រះញាតិក៏ជាទីសំណព្វព្រះទ័យដែរ តែរៀបចំក្រោយម៉ោះហើយ លោនគាត់អន់ជាងយុនថាន់បន្តិច ។

៣. ចំណែក ម៉មសួន ជាម៉មថ្នាក់តូចជាងគេ ហើយមិនសូវមានមធ្យោបាយគ្រប់គ្រាន់ ក៏រើសរកកូនចិនកូនយួនឲ្យតែស្ម័គ្រចូលមកកំ ។

ប៉ុណ្ណេះ យើងដឹងថា មានលោនប៉ុន្នេះហើយនៅក្នុងវាំងនៅពេលជំណាលគ្នានេះ ។ តែបើតាមយើងយល់ ក្រុមរបាំ និងក្បាច់ក្បួនរបាំនេះជាកេរ្តិ៍របស់ខ្មែរដែលធ្លាប់មានស្រាប់ពីដើមមក គ្រាន់តែត្រូវលោកទាំងនេះយល់ល្បិចពត់ហាត់ពីស្រុកសៀមមកបញ្ចូលបន្ថែម ហើយកាឡៃបទពោលទៅតាមសៀម ពាក្យហៅតួហើយនិងគ្រឿងប្រដាប់ទៅតាមសម្ដីសៀមតែប៉ុណ្ណោះ ដូចជាតួឯកស្រីហៅនាងឯក (ណាងអេក) ឯតួឯកប្រុសហៅនាយរោង (ណាយរ៉ុង) ។ល។ លោនទាំងនេះតួក៏សុទ្ធតែស្រី

ហើយតួមិនមានចម្រៀងឬចេញពាក្យទេឡើយនៅពេលដែលចាក់ក្បាច់ គឺមាន
អ្នកបើកក្រាំងអានពាក្យតាមក្រាំងរាយជារឿង ប្រាប់ជាក្បាច់រាំ ហៅថា
"អ្នកពោល" ដោយឡែក ៗ ដូច្នេះ តួរាំត្រូវធ្វើកាយវិការឲ្យបានស្រប
តាមពាក្យពោល និងតាមចង្វាក់ភ្លេងប៉ុណ្ណោះឯង ។

លោកតាជុំ ហួន (សព្វថ្ងៃអាយុ ៨០ ឆ្នាំ) និយាយទៀតថា: នៅ
ឆ្នាំ ១៩២០ មានមន្ត្រីខ្លះ បង្កើតក្រុមល្ខោននៅក្រៅវាំងដែរ ដូចជា
ឧញ៉ា យោធានរិន្ទ ហ៊ន លោកមានក្រុមល្ខោនមួយ របៀបជាក្រុមយីកេ ប៉ុន្តែ
បញ្ចូលក្បាច់រាំ ពាក្យពោលរបៀបល្ខោនរាំងឬល្ខោនហ្លួង ។ មានមន្ត្រី
ខាងសេរីជនម្នាក់ទៀត នាមចិន៉ុ មានក្រុមល្ខោនមួយធំដែរលេងតាមបែប
ល្ខោនហ្លួងសុទ្ធ ប៉ុន្តែបញ្ចូលឲ្យតួច្រៀងខ្លួនឯងផង ពិសេសគឺពេលចាប់
រឿងថ្ងៃនិងទុកថ្ងៃលេងចក្ដីសប្បាយ ។ ក្រៅពីគ្នានេះទៀត មានក្រុម
យីកេមួយទៀតដែរ ដែលប្រែបែបទៅតាមរបៀបល្ខោនហ្លួងនេះដែរ គឺ
ក្រុមរបស់លោកចៅក្រមអៀមដែលមានគ្រូបង្ហាត់ជាតិសៀមម្នាក់ ឈ្មោះ
ចៅស្រីដកឡយ ។ ក្រុមនេះលេងជារបៀបយីកេសុទ្ធ ប៉ុន្តែមានតែង
គ្រឿងផ្ទុំនិងភ្លេងពិណពាទ្យដូចល្ខោន ។

មកដល់ពេលមួយ គឺ គ.ស. ១៩២៨ ដែលធ្វើបុណ្យអភិសេក
ហ្លួងមុនីវង្សឡើងសោយរាជ្យ, ពេលនោះ ក្រុមល្ខោនពាក់វង់ដែលមាន
ស្រាប់នៅក្នុងប្រទេសយើង គឺល្ខោនខាងវាំង ហើយនៅកំពង់ចាម គ្រាន់ផ្សារ

ស៊ីញែក និងក្រុមល្ខោននាយអួន ដែលជាជាតិសៀមមកពីឈៀងម៉ៃ ហើយមករស់នៅធ្វើល្ខោនក្នុងស្រុកយើងយូរឆ្នាំហើយ ។ ក្រុមល្ខោនទាំងពីរនេះ គេរៀបចំទៅតាមរបៀបដែលខ្មែរនិយម គឺលេងរបៀបយីកេ ប៉ុន្តែបួលតួច្រៀងខ្លះ និង កាឡៃសម្លៀកបំពាក់ទៅតាមល្ខោនហ្វង ព្រមទាំងប្រកបទីងភ្លេងពិណពាទ្យលាយឲ្យមានតួប្រុសផង ។

ដើម្បីប្រកបពេលបុណ្យរាជាភិសេកគ្រានេះ ឲ្យបានអធិកអធមមាន ក្រុមល្ខោន «ប្រមោជ័យ»(១) មួយក្រុមទៀត បង្កើតឡើងដោយមានមេដឹកនាំសុទ្ធតែជាស្រីសៀមដែលបានមករស់នៅក្នុងក្រុមល្ខោនខ្មែរយូរឆ្នាំហើយ ។ មេទាំងនោះ មាននាមដូចតទៅ: យុនកេត, ម៉ែម៉ែន, ម៉ែចាម៉យ និងម៉ែ សាងៀម ។ ពាក្យហៅថា ម៉ែៗនេះ គឺសម្គាល់ពួកស្រីគ្រូល្ខោន ។ ល្ខោនប្រមោជ័យឬបារមោជ័យនេះ លេងក្បាច់ជារបៀបល្ខោននិយាយ (Théâtre parlé) មកពីស្រុកសៀមវិញ ។ មានគ្រឿងតុបតែងឆាក, សម្លៀកបំពាក់តាមបែបធម្មតាដូចអ្នកស្រុកអ្នកភូមិមែនទែន ប៉ុន្តែមានច្រៀងលាយខ្លះ ហើយមានភ្លេងគ្រឿងផ្លុំប្រកបផង ដំណាន់នោះគេហៅភ្លេងមុយហ្សិក (Musique) ។ ល្ខោនបារមោជ័យ លេងជារបៀបចែកជាឈុតជាឆាក ហើយតួមានប្រុសមានស្រី ។ ល្ខោនបារមោជ័យ ៤ ក្រុមនេះ

---

១— បើចង់ជ្រាបច្បាស់ ពីល្ខោនប្រមោជ័យសូមអានអត្ថបទការស្រាវជ្រាវមួយ របស់ លី ធាម តេង ចុះផ្សាយក្នុងកម្ពុជសុរិយា ឆ្នាំ ១៩៦៤ និងប្រក្រតិទិនឆ្នាំ ១៩៧២ ។

បានជាគជ័យណាស់ ព្រោះដំណើបភ្នែកអ្នកស្រុកខ្មែរ ទទួលពេលបុណ្យធំនោះមានបណ្តាជនខេត្តក្រៅ មកកកកុញទីក្រុងភ្នំពេញផង ក៏នាំឲ្យសិល្បៈនេះឯងល្បីល្បាញទៅតាមខេត្តនានា ។ មិនយូរប៉ុន្មាន ក្រុមល្ខោននេះ ក៏បានទៅលេងដល់ខេត្តធំៗផង ដូចជាបាត់ដំបង កំពង់ចាមជាដើម ។

សម័យនេះហើយ ជាសម័យរីកសាយខាងសិល្បៈល្ខោនព្រោងព្រាតឡើង នៅទីក្រុងនិងនៅខេត្តធំៗ ។

នៅភ្នំពេញ មានក្រុមល្ខោនបីវង់ ដែលលេងជាប់លាប់យូរក្រែលមកហើយ ហើយបេះតែចំត្រដរប្រណាំងប្រជែងជាមួយការផ្លាស់ប្តូរវិវត្តឡើងនៃពួកអ្នកបំណូលថ្មីៗ ក្រុមទាំងបីនោះ គឺ:

១. ក្រុមល្ខោនអ្នកប្រែង លេងជាបែបល្ខោនហ្វូងសុខសាធលាយ តែត្រង់ឲ្យតួរាំមានច្រៀងផង ប្រកបទំនងក្នុងពិណពាទ្យ ។

២ ល្ខោនក្រឡាបញ្ចីហ៊ុំ លេងរបៀបចម្រុះ នាំឲ្យមានពាក្យកំប្លែង ហៅថាល្ខោនចាប់ឆាយ គឺរាំក្បាច់ខ្លះ ច្រៀងបុរាណខ្លះ ច្រៀងបែបថ្មីខ្លះ ស្លៀកពាក់គ្រឿងបុរាណផង គ្រឿងទំនើបផង មានភ្លេងពិណពាទ្យ ភ្លេងខ្មែរ ភ្លេងស្គរលេងលាយលុកគ្នា ។

៣. ល្ខោនម៉មសយសង្វាន លេងជាបែបល្ខោនក្បាច់(ល្ខោនហ្វូង) ដែរ ប៉ុន្តែសម័យឥទ្ធិពលបារាំងចូលមកខ្លាំងពេក ក៏ក្លាយទៅជាបែបបារាំងខ្លះ ដល់ក្រោយមក មានឥទ្ធិពលល្ខោននិយាយ (Théâtre)

បែបគីរុប ក៏ក្លាយទៅទៀតដែរ ។

នៅឯខេត្តបាត់ដំបងឯនោះ មានល្ខោនមួយវង់ប្រចាំស្រុកយូរមកហើយ អ្នកម្ចាស់ល្ខោនចេះតែបែកមតិគេ តមកកូនចៅតៗគ្នារហូតដល់សម័យប្រឡូកជាមួយគេនេះឯង គេស្គាល់ឈ្មោះល្ខោននេះថា ល្ខោនបៃរៀម ។ ល្ខោននេះដំបូងឡើងលេងជាល្ខោនក្បាច់ខ្មែរ តែក្រោយមកក៏កាឡៃបែបជាបាមោច័យ ឬបែបល្ខោនសម័យថ្មីខ្លះ ហើយទីបំផុត ក៏ក្លាយរូបជាល្ខោនបាសាក់ដែរ ។ គឺមិនមែនតែល្ខោនបៃរៀមទេ ដែលក្លាយខ្លួនទៅជាច្រើនសានោះ ល្ខោននៅក្រុងភ្នំពេញទាំងបីវង់ដែលយើងរាប់មកខាងលើក៏ចេះតែក្លាយប្រែប្រួលដូច្នេះដែរ ព្រោះហេតុ ក្រោយពីល្ខោនបាមោ-ច័យអស់ឥទ្ធិពលទៅ មានឥទ្ធិពលពីរកើតឡើងទៀត គឺ:

**១- ល្ខោនបាសាក់** ល្ខោនបាសាក់នេះ កើតមកពីអ្នកស្រុកកម្ពុជាក្រោមដែល យើងនិយមហៅថាស្រុកបាសាក់ ទោះបីនៅភូមិភាគដទៃក្រៅពីភូមិបាសាក់ក៏ដោយ ឲ្យតែមកពីស្រុកក្រោម ។ តាមពត៌មានពីលោកតាធាគ្រន់ ជាអ្នកបង្កើតនិងនាំយកល្ខោន នេះ មកស្រុកខ្មែរពីដំបូងក្នុងរវាងឆ្នាំ ១៩៣០ លោកនិយាយថា ដំបូងនៅស្រុកក្រោម ក៏មានក្រុមយីកេលេងតាមស្រុកភូមិ ដូចនៅកម្ពុជាកណ្ដាលយើងនេះដែរ ។ ប៉ុន្តែដល់មើលដដែលៗយូរពេក អ្នកស្រុកឯនោះក៏ធុញទ្រាន់ មានអ្នកខ្លះ ចូលចិត្តទៅមើលហាត់ហុយយូន (ល្ខោនចៀង) ទៅវិញ ។ ជួនកាលហាក់

ដោយនោះ មានតុបតែងឆាក លំអរគ្រឿងតាមបែបកៃលឿង (ល្ខោន សម័យថ្មី) ផងក៏មាន នាំឲ្យរឹតតែប្លែកក្លែកណាស់ទៅទៀត ៗ ម្ល៉ោះហើយ លោកតា ធាត្រន់ មានយោបល់មួយ គិតប្រមូលបក្ខអ្នកស្រុក ក៏យកយីកេ យើងនេះ កាឡៃទៅជាបែបបាក់ដោយ ជាល្ខោនច្រៀងមិនមែនជារបាំ រាំ ៗ គេលេងមានច្រៀងពប់រៀបខ្លួនឯងតាមដំណើររឿងឥតមានអ្នក ពោល ហើយធ្វើកាយវិការទៅតាមសភាវគតិ គឺលោតរត់ដួលដើរប្រ កាប់គ្នាប្រដេញគ្នា លួងលោមបេចគ្នា ទៅតាមសាច់រឿង ៗ វេលានោះ មានមនុស្សនិយមច្រើនអ្នកស្រុកក្រោម បាស់ៗស្រុកនោះហៅល្ខោននេះ ថា យីកេ ៗ ព្រោះមានដើមកំណើតមកពីយីកេ ។ ល្ខោននេះបានចូល ទៅលេងដល់ទីក្រុងព្រៃនគរ រឹតតែល្បីទៀត មានចិនយួន ៗ មើលកក កុញកល់យប់ផង រហូតដល់មានអ្នកកំពង់ទៅឃើញ ក៏បបួលដឹកនាំមក លេងស្រុកខ្មែរ ៗ លុះមកដល់ ក៏បានជាគង់យ៉ាងខ្លាំង ព្រោះល្ខោន នេះមានកាយវិការហ៊ឺៗហាក់ហើសហួស មើលមិនធុញ ។ លេងនៅ កំពញរួចដឹកនាំទៅលេងខេត្តទៀត គេទៅតែខេត្តនៅតាមមាត់ទឹកដូចជា កំពង់ចាម ក្រចេះ កំពង់ឆ្នាំង ព្រោះក្រុមល្ខោននេះគេនៅនឹងទូកប៉ុកបាយធំ បើលើកទៅណាទៅតាមទូក មានកន្ទេលដេកយោយោហូទឹកនឹងប្រដាប់ប្រដា សម្រាប់ធ្វើ [illegible] ពាក់ [illegible] ទាំងអស់ក្នុងទូក [illegible] ។ ទីណា ក៏បានតែមាន [illegible] ។ [illegible] ស្ទួតែក្រុម ក៏ទៅ [illegible]

ប្រាកដ មានរូបស្អាតៗ មានចាស់ៗ ជាគ្រូ លេងជាតួស្ដេចឪពុក ជាតួព្រះឥន្ទ្រ ឬ តួឥសី ។ល។

ដោយសារតែល្បីល្បាញល្ខោនបាសាក់ ដែលអ្នកស្រុកយើងដាក់ឈ្មោះឲ្យនេះឯង បានជាល្ខោនបែបឯទៀតៗ កាឡៃខ្លួនទៅតាមបែបល្ខោនបាសាក់នេះអស់ ព្រោះបើមិនកាឡៃដូច្នោះទេ នឹងពុំមានមនុស្សមើលឡើយ សូម្បីល្ខោនបែបរៀមនៅឯបាត់ដំបងនោះ ក៏គេនឹងតែក្លាយបែបទៅតាមគេដែរ ។ ពត៌មាននេះ លោក កួយ យក់ហួ ដែលជាមិត្តអ្នកនិពន្ធរបស់ខ្ញុំ និងជាតួឯកប្រុសរបស់បែបរៀមនេះឯងតែម្ដង បានបញ្ជាក់ប្រាប់ខ្ញុំ ។

**២- ល្ខោនសម័យថ្មី** របាំល្ខោនសម័យថ្មីនេះ ជាសិល្បៈមកពីបស្ចិមប្រទេស ដោយសារកាលនោះ ប្រទេសខ្មែរយើងនៅក្នុងអាណាព្យាបាលបារាំង គេក៏ព្យាយាមផ្សាយវប្បធម៌គេដែរ ។ មិនតែប៉ុណ្ណោះ បារាំងបានអនុញ្ញាតឲ្យក្រុមល្ខោនសម័យថ្មី គឺល្ខោននិយាយ (Théâtre parlé) របស់ប្រទេសនានាចូលមកលេងស្រុកខ្មែរ ដើម្បីផ្សាយវប្បធម៌បស្ចិមប្រទេសផងដែរ ។ កាលនោះមានល្ខោនមកពីសៀម មកពីឥណ្ឌូណេស៊ី និងមកពីភូមាផង ។ ល្ខោនទាំងនេះ ច្រើនតែជាក្រុមដែល [illegible] ដើម្បីរកប្រាក់ [illegible] ផងការរីកព្រោះយក

បង្កើតឡើង ហើយធ្វើដំណើរទេសចរណ៍ទៅកាន់ប្រទេសនានា ជាដំណើរសិក្សារបស់គេ ។

លុះឃើញល្ខោនសម័យថ្មីនេះញឹកញាប់ទៅ អ្នកស្រុកយើងពិសេសក្នុងមជ្ឈដ្ឋានអ្នកចេះដឹង គឺពួកមន្ត្រីរាជការខាងមន្ត្រីរដ្ឋបាលខ្មែរក្តី ខាងមន្ត្រីអាណាព្យាបាល (Protectorat) ក្តី ក៏នាំគ្នាទទួលស្គាល់ថាសិល្បៈគេជាសិល្បៈថ្មីប្លែក គួរបង្កើតឲ្យមានក្នុងស្រុកយើងឡើង ហើយនាំគ្នាហៅរត់មាត់របាំនេះថា ល្ខោនតេអាត្រ (Théâtre) ជាប់រហូតមក ។ គ្រានោះ មានខ្មែរមួយក្រុមនាំគ្នាប្រឹងបង្កើតក្រុមល្ខោនសម័យថ្មីនេះឡើង ប៉ុន្តែ មិនមែនយកតាមបែបគេសុទ្ធសាធទេ គឺរចនាទៅតាមការនិយមរបស់ខ្មែរ ដោយលេងជាឆាក ជាឈុត និយាយឆ្លើយឆ្លង និងស្លៀកពាក់តាមសម័យថ្មីហើយ តែមានផ្សំជាមួយភ្លេង មានច្រៀងដោយអះទ្ធិ ៗ និងលាយរបាំអ្នកខ្លះផង ហើយរបាំនេះ ច្រើនរាំមុនពេលចេញជារឿង ។ ដូនកាលគឺរាំរបាំខ្មែរដែលកាត់ឡែក្បាច់រាំពីក្បាច់ ល្ខោនបុរាណខ្លះ ឬរាំតាមបែបក្បាច់យីកេក៏មាន ក្រៅពីនេះ មានយកលំនាំតាមបែបបាល្លេពួកបស្ចិមប្រទេស ។ បែបនេះមនុស្សប្លែកភ្នែកក៏ចូលចិត្តមើលច្រើនដែរ ដូច្នេះបានជាជាប់ទំលាប់ក្នុងវង់ល្ខោនៗមកមុននឹងជូនរឿងគេជូនរបាំសិន ( ខ្លះហៅថា លោតម៉ាជាំ ) ។ ក្រុមល្ខោនវង់ថ្មីនេះ ពុំមែនកើតឡើងដោយនរណាម្នាក់ ៗ ឡើយ គឺមានសមាគមមួយរួមប្រមូល

ដើមទុនមកកសាង ច្រើនតែជាមន្ត្រីរាជការខ្លះ និងមន្ត្រីក្នុងវាំងខ្លះ មាន ទាំងឃុនព្រះម្នាងយិនគាត ជាអ្នកឧបត្ថម្ភផង ។ លោកជុំ ហួន ទទួល ជាអ្នកកាន់កាប់ និងចាត់ចែងការផ្សាយក្នុងក្រុមល្ខោននេះ ។ លោកជុំម៉ៅ ក៏ប៉ុនប៉ងខាងតែងរឿង រៀបចំពាក្យពេចន៍ បង្ហាត់និយាយឲ្យត្រឹមត្រូវ មាន មួង ៗ លោកប្រែរឿងបារាំងមកឲ្យសម្ដែងដែរ ។ ក្រុមនេះបាននាំគ្នាទៅសុំ ឈ្មោះពីព្រះសពសម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលកាលនោះនៅជា ព្រះពុទ្ធឃោសាចារ្យ ។ សម្ដេចក៏ប្រតិស្ឋនាមឲ្យថា «ក្រុមល្ខោនវឌ្ឍនាភិរម្យ» ។ ពេលចេញសម្ដែងដំបូង ជានុកាសសម្ពោធអឹកធឹកណាស់ មានហួង មានរេស៊ីដង់ស៊ុប៉េរីយ៉េ (Résident supérieur) និងមន្ត្រីបារាំង ខ្មែរ អ្នកមុខអ្នកការទាំងអស់មកជួយអបអរសាទរ ។ ល្ខោននេះ លេង បានយូរក្រែលដែរ ប្រកបដោយការល្បីល្បាញនាំឲ្យវង់តូច ៗ ដទៃទៀត នាំគ្នាប្រឹងយកបែបបទពីល្ខោននេះ ទៅលេងតាមជាច្រើនដែរ ។ ប៉ុន្តែ ដោយលំបាកខាងសម្ភារៈ និងខាងបច្ចេកទេស ក្រុមនេះក៏ផ្អាកដំណើរខ្លួន ទៅវិញទៅ ។

បន្ទាប់ពីនោះ រាជការអាណាព្យាបាលគេបានចាត់អ្នកលេងល្ខោន ម្នាក់មកពីស្រុកបារាំង ឈ្មោះ Gui Porée មកបង្ហាត់ល្ខោននិយាយនេះឲ្យ បានម៉ត់ចត់ មានឈ្មោះថា ក្រុមតេអាត្រនូវ៉ូ (Théâtre nouveau) ដែល បង្ហាត់ទៅសាលមហោស្រពហៅថា ហ្វីឡាម៉ូនិច (Phyllamonique) (នៅ ជិតក្រសួងឃោសនាសព្វថ្ងៃនេះ) ។ ក្រុមនេះមានមន្ត្រីខ្លះចូលហាត់រៀន

ច្រើននាក់ដែរ ច្រើនតែពួកគ្រូ និងមានសិល្បការច្រើនទៀត ។ គេបង្ហាត់
បានចេញសម្ដែងច្រើនលើកណាស់ នៅទីក្រុងនិងនៅខេត្តក្រៅ គឺលេង
តាមរបៀបល្ខោននិយាយសុទ្ធសាធតាមក្បួនខាត ។

ដោយសារតន្ត្រីពលនៃបែបល្ខោន ទាំងពីរសណ្ឋាន គឺបែបល្ខោន
បាសាក់ជាល្ខោនច្រៀង និងល្ខោនតេអាត្រ ជាល្ខោននិយាយនេះហើយ
បានជាស្រុកយើង នៅសល់កេរ្តិ៍ទាំងពីរបែបនេះដែរដល់មកសព្វថ្ងៃ ។
ព្រោះថា ល្ខោនបាសាក់ នេះតែងតែមានវង់មួយទៅវង់មួយ ពីវង់ធំទៅជាវង់
តូច ៗ នៅតាមស្រុកខេត្តនានា ពិសេសគឺស្រុកខេត្តនៅតាមដងទន្លេធំ
មានច្រើនជាងគេ រហូតដល់លេងដូរជាផលានុផលក៏បានមិនបាច់ចាញ់សំ
បុត្រនឹងលុយទេ ព្រោះអ្នកស្រុកមិនទាន់លក់ផលានុផលបាន ។ បន្ទាប់
ពីក្រុមល្ខោនរបស់លោកភាធាក្រុងនៅ មានវង់បន្តបន្ទាប់មកទៀតគេហៅ
វង់ទី ២ ទី ៣ ខ្ញុំសុំអនុញ្ញាតចាប់ឈ្មោះខ្លះទុកជាប្រវត្តិ គឺក្រុមល្ខោន
បាសាក់សំខាន់ ៗ នៅភ្នំពេញ មានក្រុមល្ខោនអ្នកម្ចាស់ឡា, ល្ខោនបាឡាត់
អួន, ល្ខោនក្រឡាបញ្ជីស្ពាន ហើយក្រោយមកមានល្ខោន ឃុនព្រះ
ម្ចាស់ យិនគាត ល្ខោនចៅកែ បាកស្រេង ល្ខោនកេងទួលទពូង ។ល។

ចំណែកល្ខោននិយាយជាថ្មីសម័យថ្មី ទោះបីជាផុតពីក្រុមវិជ្ជានា
ការម្យ ក្រុមតអាត្រទូរ៉ូ នេះអស់ទៅ ក៏នៅបន្តបែបនេះពួកសិស្សដែលគេ
លេងថ្មីៗ ១ គង់តែលបុណ្យដូចជាគេលែករង្វាន់ប្ដូរ បុណ្យកឋិនរបស់

សាលានោះហើយបានជាមានពាក្យហៅមួយទៀតថា "ល្ខោនកូនសិស្ស" ក្រៅពីសិស្ស មានសមាគមខ្លះខាងវប្បធម៌ ដូចជាសមាគមមិត្រសិស្សចាស់, សមាគមអ្នកនិពន្ធខ្មែរ, សមាគមបុគ្គលិកសិក្សា ។ល។ បានធ្វើជាក្រុមល្ខោនបែបនេះ លេងម្តងៗដែរ ជាការផ្សាយវប្បធម៌ផងនិងជាការរៃអង្គាសបច្ច័យជួយឧបត្ថម្ភសមាគមផង ។ លុះមកដល់ឆ្នាំ ១៩៥៥ ៥៦ ទើបកជការបង្កបង្កើតជាក្រុមល្ខោនរបស់រដ្ឋឡើង ដោយប្រមូលផ្តុំអ្នកដែលបានរៀនល្ខោនពិតប្រាកដ មានលោក ហង្ស ធុនហាក់ មកពីប្រទេសបារាំង និងអស់លោកដែលធ្លាប់រៀននៅសាលាតេអាត្រទូរ៉ូប ធ្លាប់ហាត់លេងជាច្រើនផងទៀត ដូចជា លោក ឌុប ស៊ីឌិម លោកអ៊ុំ ឈិន លោកពៅយូឡេង លោកគង់ លឹម ជាដើម ហើយតមកក៏បង្ហាត់បានអ្នកចូលចិត្តសិល្បៈនេះ បានជាច្រើននាក់ទៀត មាន លោកឆេង ផុន, លី គិមអួង, នួនគន, ប៉ុល សំអឿន, មាស គក, ហ៊ីន ប៊ុនថុន, ហង្ស ដួន, ជឹក សំផេន, ស្រីឡូច, សៅវណ្ណគុណ ។ល។ និងអ្នកគ្រូជាច្រើននាក់ទៀត ដែលខ្ញុំសុំអភ័យទោសមិនបានចុះនាម ។ ក្រុមល្ខោន ដែលរៀបចំមានច្បាប់ទម្លាប់ មានការរៀនសូត្រពិតប្រាកដនេះ ក៏មានឈ្មោះថា "ល្ខោនជាតិ,, ជាប់តមក ល្ខោនសព្វថ្ងៃនេះ នៅក្រោមអំណាចសកលវិទ្យាល័យវិចិត្រសិល្បៈហើយ ក៏នៅតែហៅ ល្ខោនជាតិ ៗ ដែរ ។

សេចក្ដីអធិប្បាយមកនេះ បញ្ជាក់ថា ខ្មែរជាអ្នកនិយមល្ខោនតាំងពីសម័យបុរាណរៀងមក តាំងពីមិនទាន់មានពាក្យហៅថា "ល្ខោន"នោះទៅទៀត ។ រហូតមកដល់ពេលកើតពាក្យហៅថាល្ខោនហើយ ក៏នៅតែដុះដាលសាយភាយយ៉ាងខ្លាំង ហើយមានអ្នកតពូជពង្សប្រុលចិត្តសិប់សួនកុងសិល្បៈល្ខោននេះក៏ច្រើនគ្នាណាស់ ដើម្បីរក្សាពូជវប្បធម៌ខ្មែរខាងល្ខោននេះ មិនឱ្យសាបរលាបទៅបាន ។

លោក លី ធាម តេង
ប្រធានគណៈកម្មការស្រាវជ្រាវ នៃសមាគមអ្នកនិពន្ធខ្មែរ
រៀបរៀងក្នុងឆ្នាំ ១៩៧១

២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤៤ ខែ កុម្ភៈ

ព.ស. ២៥១៦ គ.ស. ១៩៧២

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : អ៊ិត - សាម៉ន

និពន្ធនាយក - អ្នករៀបចំ លី ធាម តេង

គណៈកម្មការនិពន្ធ:

ព្រះពោធិវង្ស ស្វូរ-ហាយ

លោក ផល-ទិត អ្នកស្រី ពេជ-សល់

# បញ្ជីរឿង

| អត្ថបទ | ទំព័រ |
|---|---|


## ១– ផ្នែកសាសនា :

១. លោកបាលធម៌ ២ យ៉ាង រៀបរៀងដោយ ព្រះពាន់វិរៈ សួរ-ហាយ . . . ៦៣

២ ចតុរារិយសច្ច (ត) រៀបរៀងដោយ ព្រះភិក្ខុ ប៉ាង-ខាត់ . . . . . ៧៥

## ២– ផ្នែកអក្សរសាស្ត្រ :

៣- រឿងសាមកុក . . . . . . . . . . . . . ៨០

៤- សាស្ត្រាថ្ងៃសុក្រ ឬ ល្បើកថ្ងៃសុក្រ ( កំណាព្យ ) . . . . . . ៩៥

## ៣- ផ្នែកកំណត់ប្រវត្តិការណ៍ :

៥- លោក ហង់រី គីស្សីង្គ័រ ជាអ្នកណា -. . . . . . . . . ១០៦


---

## តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ៛

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

## ផ្នែកសាសនា

# លោកបាលធម៌ ២ យ៉ាង

រៀបរៀងដោយ ព្រះពោធិវង្ស សួរ-ហាយ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

លោកបាលធម៌ ២ យ៉ាង គឺ

១- ហិរិ *ការអៀនខ្មាសចំពោះអំពើអាក្រក់ ,*

២- ឱត្តប្បៈ *ការក្តៅក្រហាយចំពោះអំពើអាក្រក់ ។*

## អធិប្បាយពន្យល់សេចក្តី

លោកបាលធម៌ *ប្រែថា « ធម៌សម្រាប់រក្សាលោក » ។ ពាក្យថា « លោក » បានដល់ប្រជាជនគឺមនុស្សក្នុងសកលលោក ។ លោកបាលធម៌ ជាទ្រឹស្តីមួយក្នុងព្រះពុទ្ធសាសនា ទុកថាជាច្បាប់សម្រាប់ប្រៀនប្រដៅមនុស្សដោយល្អ គឺ ឲ្យមនុស្សក្នុងសង្គម មានសីលធម៌, សុជីវធម៌, ឲ្យមានអធិបតេយ្យ, ឲ្យមានរបៀបរៀបរយល្អ មិនឲ្យធ្លាក់ទៅជាអនាធិបតេយ្យ ។*

*១- ពាក្យថា « អំពើអាក្រក់ » នោះ សំដៅយកការប្រព្រឹត្តទុច-ចរិតដោយកាយវាចាចិត្ត គឺអំពើអាក្រក់ ដែលគេធ្វើដោយកាយ មានការ*

សម្លាប់, លួចលាក់, បោកប្រាសជាដើម ហៅថា **កាយទុច្ចរិត** ។ អំពើអាក្រក់ដែលគេធ្វើដោយវាចា មាននិយាយកុហក, ញុះញង់ជាដើម ហៅថា **វចីទុច្ចរិត** ។ អំពើអាក្រក់ដែលគេគិតដោយផ្លូវចិត្ត មានការយល់ខុស យល់ឆ្គងជាដើម ហៅថា **មនោទុច្ចរិត** ។

ពាក្យថា "អៀនខ្មាស" សំដៅយកចិត្តដែលរួញថយ មិនត្រូវការចង់ជួបប្រទះ, មិនត្រូវការចង់ធ្វើ, ប្រៀបដូចជាអវយវៈរបស់មនុស្សប្រុសស្រី ដែលនៅក្នុងទីកំបាំង គេខំប្រយ័ត្នបិទបាំងមិនត្រូវការឲ្យអ្នកណាមួយឃើញឡើយ ដែលយើងហៅថា "បិទបាំងកេរខ្មាស" ដោយប្រយ័ត្នជាទីបំផុត ។ មួយវិញទៀត ចិត្តដែលខ្វះរួញថយ ចាកអំពើទុច្ចរិត ឬអំពើអាសអាភាសណាមួយ ដែលមិនហ៊ានបញ្ចេញ មិនហ៊ានបង្ហាញឲ្យខ្លួនឯងឬអ្នកដទៃឃើញ ទាំងនេះហៅថា "អៀនខ្មាស" ។ អំពើទុច្ចរិតទាំងបីយ៉ាង មានកាយទុច្ចរិតជាដើម លោកចាប់ថា ជាអំពើអាក្រក់ អំពើបាប អំពើគួរអៀនខ្មាស, មិនត្រូវបណ្តោយឲ្យកាយវាចាចិត្តហ៊ានប្រព្រឹត្តហ៊ានធ្វើដោយឥតអៀនខ្មាសនោះឡើយ ។ ពាក្យថា "អៀនខ្មាស" នេះ បានដល់សេចក្តីខ្មាសក្នុងចិត្តរបស់ខ្លួនឯងផង ខ្មាសអ្នកដទៃផង ។

សេចក្តីអៀនខ្មាសក្នុងផ្លូវធម៌នេះ បើមានកម្លាំងបរិបូណ៌ហើយ ជាហេតុឲ្យចិត្តខ្វះរួញថយ ចាកអំពើអាក្រក់គ្រប់យ៉ាង អាចទុកដាក់អំពើអាក្រក់នោះថា ជារបស់ស្អុយ គួរស្អប់ខ្ពើម, គួរធុញទ្រាន់, គួរវៀរឲ្យ

ស្រឡះចេញ, ពុំគួរបណ្តោយឲ្យកាយវាចាចិត្តប្រឡាក់ប្រឡូសដោយអំពើអាក្រក់នោះឡើយ ។ អំពើអាក្រក់នេះ លោកប្រៀបដូចជារបស់សម្អុយ ឬគ្រឿងប្រឡាក់ដ៏អាក្រក់ ដែលយើងជាមនុស្សពុំត្រូវការចង់ឲ្យប៉ះពាល់ទេ ។ អ្នកត្រូវការសេចក្តីស្អាតបរិសុទ្ធកាយវាចាចិត្ត មិនត្រូវការនឹងវត្ថុសម្អុយ មិនត្រូវការនឹងគ្រឿងប្រឡាក់ដ៏អាក្រក់នោះទេ ប្រៀបដូចស្ត្រីក្រមុំនិងកំលោះជាអ្នកកំពុងស្រឡាញ់ខ្លួន មិនត្រូវការវត្ថុសម្អុយនិងគ្រឿងប្រឡាក់ប្រឡូសដ៏អាក្រក់ មកប៉ះពាល់ប្រឡាក់ដល់រាងកាយរបស់ខ្លួនទេ, គេតែងឧស្សាហ៍ងូតទឹកលាងជម្រះកាយឲ្យរឿយ ៗ, គេតែងប្រយ័ត្នគ្រឿងស្មោកគ្រោកគ្រប់យ៉ាង មិនឲ្យប្រឡាក់ខ្លួនប្រាណ ឬ សំពត់អាវ របស់គេឡើយ ។

**ហិរិ** គឺសេចក្តីអៀនខ្មាស ដែលបានអធិប្បាយដោយសង្ខេបមកនេះ រាប់ថា ជាលក្ខណធម៌មួយ សម្រាប់បង្ក្រៀកចិត្ត មិនបណ្តោយចិត្តឲ្យក្លាហានក្នុងការប្រព្រឹត្តអាក្រក់ អាចធ្វើចិត្តឲ្យអៀនខ្មាស ឲ្យរួញថយឲ្យនឿយណាយ ធុញទ្រាន់ ខ្ពើមរអើម នឹងអំពើអាក្រក់គ្រប់យ៉ាង ។

**ហិរិ** ជាធម៌សម្រាប់រក្សាចិត្តឲ្យតាំងនៅល្អជាដរាប តាំងអំពីបច្ចុប្បន្នតទៅអនាគត ។ **ហិរិ** ធម៌នេះ ជាមូលដ្ឋានមួយដ៏ប្រសើរ អាចគ្រប់គ្រងរក្សាលោក គឺប្រែជាជនគ្រប់ជាតិ ឲ្យប្រព្រឹត្តល្អ គឺ ឲ្យមានអធ្យាស្រ័យល្អ ប្រកបដោយសីលធម៌និងសុជីវធម៌ ដើម្បីជាកិត្តិយសរបស់សង្គមមនុស្ស ជាមូលហេតុនាំឲ្យមនុស្ស ស្ថិតនៅក្នុងឋានៈជាមនុស្សមាន

មនុស្សធម៌ គ្រប់ជាតិគ្រប់ត្រកូលឡើង ដើម្បីជាអលង្ការ ជាគ្រឿងលម្អរបស់មនុស្សទៅ ។

មួយទៀត **ហិរិធម៌** នេះ គួរមនុស្សគ្រប់ជាន់ថ្នាក់ពិចារណា ឲ្យញឹកញយ ហើយយកប្រាជ្ញាស្មារតីមកត្រួតពិនិត្យចំពោះចិត្ត ឲ្យញឹកញាប់រៀងរាល់ថ្ងៃ ដើម្បីទូន្មានសង្កត់សង្កិនចិត្ត បង្រៀនចិត្តឲ្យចេះអៀនខ្មាសចំពោះអំពើអាក្រក់ អំពើអយុត្តិធម៌ អំពើថោកទាប របស់ជាតិសាសនាសម្រាប់ប្រទេសរបស់យើង មិនត្រូវបណ្ដោយឲ្យចិត្តនៅទំនេរ ដោយគ្មានច្បាប់ណាមួយសម្រាប់អប់រំនោះឡើយ, ត្រូវតែយកប្រាជ្ញាស្មារតីឬសតិ·សម្បជញ្ញៈមកធ្វើគ្រូបង្រៀនរបស់ចិត្តជានិច្ចកាលតទៅ ។ កាលបើបុគ្គលមានសតិសម្បជញ្ញៈបរិបូណ៌ហើយ អាចទូន្មានប្រៀនប្រដៅចិត្ត ឲ្យទៅជាចិត្តល្អ ឲ្យទៅជាចិត្តបានបទ ឲ្យទៅជាចិត្តស្គាល់ហេតុផល ស្គាល់គុណទោស ស្គាល់ទាបខ្ពស់ ស្គាល់ថោកទាប ស្គាល់ហេតុការណ៍គ្រប់យ៉ាងបានជាប្រាកដ ។ ផ្ទុយពីនេះទៅវិញ បើចិត្តរបស់យើង មិនមានធម៌ណាមួយសម្រាប់ធ្វើជាគ្រូបង្រៀនអប់រំប្រៀនប្រដៅផងទេ ជាហេតុនាំឲ្យវង្វេងនាំឲ្យល្ងើយ ខុសចាកកាលសម័យនិយមពុំខាន ត្រឡប់ជាហេតុនាំឲ្យលង់ខ្លៅ នាំឲ្យធ្លាក់ខ្លួនទៅជាថោកទាប នាំឲ្យមានកេរ្តិ៍ឈ្មោះអាក្រក់ នាំឲ្យខ្មាសគេអ្នកប្រទេសដទៃ ក្នុងប្រវត្តិសាស្ត្រតទៅ ពុំខាន ។

ហិរិ ធម៌ កប់ថា ជាច្បាប់មួយដ៏ប្រសើរ សម្រាប់ឲ្យចិត្តប្រព្រឹត្ត អនុវត្ត ដើម្បីប្រុស់ព្រំ លាបស្រឡាប អប់ឲ្យមានក្លិនក្រអូបក្តៅឈ្មោះប្រទេសជាតិនាំឲ្យចិត្តចេះអៀនចេះខ្មាស មិនចំពោះតែអំពើអាក្រក់ក្នុងផ្លូវព្រះពុទ្ធសាសនាប៉ុណ្ណោះទេ គឺ អាចនឹងនាំចិត្តយើងដែលអប់រំល្អហើយនោះ ឲ្យចេះខ្មាសប្រទេសជាតិគេ ឲ្យចេះខ្មាសខ្លួនឯង ចំពោះវ័យរបស់ខ្លួន ចំពោះការចេះដឹងរបស់ខ្លួន ដោយប្រៀបធៀបប្រទេសជាតិខ្លួនទៅនឹងប្រទេសជាតិគេដែលចម្រើនរុងរឿងហើយ ។

ធម្មតាចិត្តរបស់មនុស្សក្នុងលោក កាលបើគ្មានធម៌សម្រាប់ទូន្មានអប់រំទេ តែងទៅជាចិត្តអាក្រក់គ្រប់យ៉ាងបាន, កាលបើចិត្តអាក្រក់ នាំកាយឲ្យប្រព្រឹត្ត ក៏អាក្រក់តាមចិត្តដឹកនាំ, នាំវាចាពាក្យសម្តីឲ្យប្រព្រឹត្ត ក៏អាក្រក់តាមចិត្តថែមទៀត ។ ក្នុងករណីដូចបានអធិប្បាយមកនេះ ឃើញថា ចិត្តរបស់យើង ពុំគួរទុកឲ្យនៅទំនេរ ក្រៅអំពីច្បាប់ទម្លាប់ណាមួយទេ ត្រូវតែរកមធ្យោបាយ ទុកដាក់ចិត្តរបស់យើង ឲ្យនៅក្នុងកម្រងច្បាប់ផ្លូវធម៌ផ្លូវលោក កុំខាន ។ តួយ៉ាង ក្នុងកាលៈទេសៈរបស់ប្រទេសជាតិយើងសព្វថ្ងៃនេះ យើងបានរៀបចំអង្គការផ្សេងៗ ជាច្រើនយ៉ាង មានផែនការកំណែនទូទៅជាដើម សម្រាប់អប់រំប្រជាពលរដ្ឋ ដើម្បីជាពន្លឺរបស់ចិត្តឲ្យភ្លឺថ្លា ដើម្បីឲ្យយល់ឃើញស្របគ្នាត្រូវគ្នា ឲ្យមានសាមគ្គីជាប់ទាក់ទងគ្នាទៅវិញទៅមក អនុវត្ត ឲ្យឃើញរូបរាងអង្គការនោះ ។

ប្រាកដប្រជាឡើង ៗ ដូចសម័យនេះ រដ្ឋាភិបាលបានបង្កើតផែនការកំ· ណែនទូទៅ សម្រាប់ប្រជាពលរដ្ឋ ទាំងទីក្រុងទាំងស្រុកក្រៅ បានរៀបចំឲ្យមានលក្ខណត្រឹមត្រូវ ដើម្បីអប់រំប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ ឲ្យចេះដឹង ឲ្យយល់ករណីយកិច្ចរបស់យើង ក្នុងការដោះស្រាយបញ្ហាប្រទេសជាតិដែលកំពុងមានទុក្ខធុរៈ គ្របសង្កត់មកលើយើង រៀងរាល់ថ្ងៃ ដូចយើងកំពុងជួបប្រទះនេះ ៗ ផែនការកំណែនទូទៅនេះ កាលបើយើងបាននាំគ្នាអនុវត្តត្រឹមត្រូវ យើងអាចទាយបានថា ជាកម្លាំងសាមគ្គីមួយដ៏ប្រសើរបំផុត ៗ ផែនការនេះ ទុកថា ជាច្បាប់មួយក្នុងផ្លូវចិត្តសាស្ត្រតម្រូវចំពោះប្រជាពលរដ្ឋទូទៅ ដើម្បីឲ្យសមហេតុផលរបស់ប្រទេសជាតិដែលសត្រូវកំពុងឈ្លានពាន រុករានមកលើជាតិសាសនារបស់យើងសព្វថ្ងៃនេះ ៗ

**២ ឱត្តប្បៈ** ការក្តៅក្រហាយ ចំពោះអំពើអាក្រក់ ៗ ពាក្យថា "អំពើអាក្រក់" នេះ បានអធិប្បាយរួចមកហើយក្នុងធម៌ទីមួយខាងដើម ៗ

**ឱត្តប្បៈ** នេះ មានសេចក្តីប្រែច្រើនយ៉ាង គឺប្រែថា "សេចក្តីក្តៅក្រហាយ" ថា "សេចក្តីខ្លាច" ថា "សេចក្តីតក់ស្លុត" ថា "ការញាប់ញ័រចំពោះអំពើអាក្រក់មានកាយទុច្ចរិតជាដើម" ៗ

**ឱត្តប្បៈ** ដែលប្រែថា "សេចក្តីក្តៅក្រហាយ" បានដល់អាការក្តៅក្រហាយក្នុងផ្លូវចិត្តដោយគិតថា អំពើអាក្រក់ទាំងអស់ ជាអំពើឲ្យក្តៅរោលរាល ៗ

ឱត្តប្បៈ ដែលប្រែថា «សេចក្ដីខ្លាច» នោះគឺខ្លាចក្នុងចិត្តរបស់ខ្លួនចំពោះអំពើអាក្រក់ ហើយមិនហ៊ានធ្វើ មិនហ៊ានប៉ះពាល់ ចំពោះអំពើអាក្រក់ ។ ឱត្តប្បៈ ដែលប្រែថា «សេចក្ដីតក់ស្លុត» បានសេចក្ដីថា ការរន្ធត់ចិត្តចំពោះអំពើអាក្រក់ ដោយឃើញគេកំពុងប្រព្រឹត្តអាក្រក់មានការសម្លាប់ជាដើម ។ ឱត្តប្បៈ ដែលប្រែថា «ការញាប់ញ័រ ចំពោះអំពើអាក្រក់» នោះបានន័យថា ចិត្តគិតភ័យតក់ស្លុតចំពោះខ្លួនឯងឬអ្នកដទៃដែលកំពុងធ្វើអំពើអាក្រក់ផ្សេងៗ ។ «សេចក្ដីក្ដៅក្រហាយ, សេចក្ដីខ្លាច»នេះ សំដៅយកការឃើញច្បាស់ នូវផលវិបាករបស់អំពើអាក្រក់ដែលត្រូវត្រឡប់ឲ្យផលមកដល់ខ្លួនអ្នកធ្វើវិញ ក្នុងកាលបច្ចុប្បន្ន ឬ ក្នុងកាលអនាគត ពុំមែនភ័យខ្លាចដូចជា កូនខ្លាចមាតាបិតា សិស្សខ្លាចគ្រូអាចារ្យ អ្នកតូចខ្លាចអ្នកធំ នោះទេ ។

ពាក្យថា «ភ័យខ្លាច»ឬ«ញាប់ញ័រ»នោះ សំដៅយកគំនិតរបស់បុគ្គលដែលគិតឃើញថា អកុសលកម្មឬបាបកម្មក្ដី កុសលកម្មឬបុញ្ញកម្មក្ដី លោកកប់ថា ជាប្រភពមួយដែលនាំឲ្យកើតផល ហើយអាចផ្ដល់មកលើបុគ្គលអ្នកប្រព្រឹត្តវិញ ពុំខាន ។ ព្រោះថា កម្មគឺអំពើ របស់សត្វលោកទោះបីអំពើអាក្រក់ក្ដី អំពើល្អក្ដី តែងប្រគល់នូវផលដល់សត្វលោកវិញជាប្រាកដ ដូចពុទ្ធភាសិតថា «សត្វទាំងអស់ មានកម្មជារបស់ខ្លួន, មានកម្មជាអ្នកឲ្យកំណើត, មានកម្មជាប់ទាក់ទងដូចផៅពង្ស, មានកម្មជាទីពឹង

ពាក់អាស្រ័យនៅ, បើបុគ្គលធ្វើកម្មអាក្រក់ក្តី កម្មល្អក្តី កម្មនោះ អាចឲ្យផលសងមកវិញ តាមស្នាមគំនូសរបស់កម្ម ។ **កម្ម** គឺអំពើរបស់កាយវាចាចិត្តនេះ រមែងមានផលជាប់តាមបុគ្គលអ្នកធ្វើនោះ ដូចស្រមោលតែងអន្ទោលជាប់តាមប្រាណនោះដែរ ។

កាលបុគ្គលពិចារណាឃើញកម្មជាបាបអកុសលដូច្នេះហើយ ក៏មានសេចក្តីគិតភ័យខ្លាចចំពោះកម្មអាក្រក់ សូម្បីមានប្រមាណតិច ក៏មិនហ៊ានធ្វើ ប្រៀបដូចជាមនុស្សស្រឡាញ់ជីវិត ខ្លាចពស់អាសិរពិស សូម្បីខ្លួនវាតូច ក៏យើងមិនហ៊ានចាប់ពាល់ ។

**ហិរិ និង ឱត្តប្បៈ** មានលក្ខណៈផ្សេងគ្នា ដោយភាពនៃចិត្តរបស់មនុស្ស គឺ **ហិរិ** ដែលប្រែថា « សេចក្តីអៀនខ្មាសចំពោះអំពើអាក្រក់ » នោះ ដោយហេតុថា ចិត្តរបស់មនុស្សដែលធ្លាប់តែធ្វើអំពើល្អ ហើយទុកដាក់អំពើអាក្រក់នោះ ថាដូចជាវត្ថុស្មុយមានលាមកជាដើម រួចក៏អៀនខ្មាស ចំពោះវត្ថុស្មុយទាំងនោះ ពុំហ៊ានចាប់កាន់ ឬ ប៉ះពាល់ឡើយ ។ **ឱត្តប្បៈ** ដែលប្រែថា « សេចក្តីក្តៅក្រហាយ » ឬ « ភ័យខ្លាច » នោះ ដោយហេតុនៃចិត្តរបស់បុគ្គលអ្នកធ្លាប់ធ្វើល្អ គេទុកដាក់អំពើអាក្រក់នោះ ថាដូចជាដុំដែកដែលភ្លើងកំពុងឆេះក្រហមរងាល ហើយគេមិនហ៊ានចាប់ពាល់ដែកនោះទេ ។ លក្ខណៈរបស់ **ហិរិ និង ឱត្តប្បៈ** ដែលមានសេចក្តីផ្សេងគ្នាដូច្នេះ ដោយហេតុមកអំពីដំណើរចិត្ត របស់មនុស្សដូចសេចក្តីអធិប្បាយសង្ខេបប៉ុណ្ណោះ ។

**ហិរិ** មាននាទីខាងអៀនខ្មាស, **ឱត្តប្បៈ** មាននាទីខាងក្តៅក្រហាយភ័យខ្លាច ។ ការជួបទាក់ទងរវាងមនុស្សនិងមនុស្សក្តី ទាក់ទងរវាងមនុស្សនិងតិរច្ឆានក្តី ទាក់ទងរវាងមនុស្សនិងអំពើអាក្រក់ល្អក្តី ដែលអាចជួបប្រទះកប់ប្រសព្វទាក់ទងនឹងគ្នាទៅបាន ក៏ព្រោះអាស្រ័យគ្មានការអៀនខ្មាស គ្មានការក្តៅក្រហាយភ័យខ្លាចនេះឯង ។ ព្រោះហេតុនោះ កាលបើបុគ្គលប្រកបដោយ **ហិរិ** និង **ឱត្តប្បៈ** បរិបូណ៌ហើយ មិនអាចនឹងជួបប្រទះប៉ះពាល់ក្នុងការធ្វើអំពើអាក្រក់គ្រប់យ៉ាងបានឡើយ ។

**ហិរិ** និង **ឱត្តប្បៈ** ជាមូលដ្ឋានដ៏ខ្ពង់ខ្ពស់សម្រាប់គាំទ្រលោក គឺប្រជាជន ឲ្យប្រកបដោយសេចក្តីសុខចម្រើនក្នុងបច្ចុប្បន្ននិងអនាគតដោយពិត, ជាធម៌ជួយឧបត្ថម្ភជ្រោមជ្រែងថែទាំរក្សាលោក ទុកឲ្យនៅជាប់ជាស្ថាពរតទៅវែងឆ្ងាយ សមដូចពុទ្ធភាសិតថា **ហិរិឱត្តប្បយញ្ញេវ លោកំ ធារេតិ សាធុកំ** ប្រែថា **ហិរិ ឱត្តប្បៈ** ហ្នឹងឯង តែងរក្សានូវលោកទុកឲ្យល្អ ។ ពាក្យថា "រក្សា" បានន័យថា ឧបត្ថម្ភគាំទ្រគ្រប់គ្រងលោក គឺប្រជាជន ឲ្យឋិតនៅដោយល្អ មិនឲ្យមានការបៀតបៀន ជិះជាន់សង្កត់សង្កិនគ្នាទៅវិញទៅមក ។ **ហិរិ និង ឱត្តប្បៈ** នេះឈ្មោះថា ជាទ្រព្យមួយដ៏ប្រសើរ អាចនាំសត្វលោកឲ្យរួចចាកភយន្តរាយគ្រប់យ៉ាង គឺថា ធម៌ទាំងពីរនេះ អាចដឹកនាំសត្វលោក ឲ្យមានសិរីសួស្តីជាប់យូរអង្វែងកប់កប្បតទៅ, ឈ្មោះថា ជាធម៌ញុំាងសត្វលោកឲ្យមានសេរីភាព- វឌ្ឍនភាព

និងអធិបតេយ្យ ទៅជាយូរអង្វែង ។

ធម៌ទាំងពីរយ៉ាងនេះ ឈ្មោះថា ជាគ្រឿងប្រដាប់ដ៏ល្អបំផុតសម្រាប់មនុស្សជាតិគ្រប់ជាន់ថ្នាក់ ។ មនុស្សដែលមានត្រកូលខ្ពស់ក្តី ត្រកូលកណ្តាលក្តី ថោកទាបក្តី តែងតែមានគ្រឿងអលង្ការ គឺសំពត់អាវជាដើម សម្រាប់ស្លៀកពាក់ប្រើប្រាស់ តាមសមគួរដល់ឋានៈរបស់ខ្លួន យ៉ាងណាមិញ, ហិរិ និង ឱត្តប្បៈ ក៏លោកលើកថា ជាគ្រឿងអលង្ការដ៏ប្រសើរបំផុតរបស់មនុស្សជាតិ ក៏យ៉ាងនោះដែរ គឺថា មនុស្សក្នុងត្រកូលគ្រប់ទាំងអស់ត្រូវកាន់យក ហិរិ និង ឱត្តប្បៈ ថាជាគ្រឿងអលង្ការ យកទៅអនុវត្តប្រតិបត្តិឲ្យបានគ្រប់គ្រាន់ ទើបប្រព្រឹត្តទៅដើម្បីសេចក្តីសុខចម្រើនសមគួរដល់ឧបនិស្ស័យអាស្រ័យរបស់ខ្លួនផង សមគួរដល់កិត្តិយសរបស់មនុស្សជាតិផង ។

មនុស្សក្នុងត្រកូលយ៉ាងណាក៏ដោយ តែងនិយមគ្រឿងអលង្ការមានសំពត់អាវជាដើម សម្រាប់ស្លៀកពាក់បិទបាំងរាងកាយ បិទបាំងកេរខ្មាសផង សម្រាប់ជាលម្អរបស់រាងកាយផង ដោយពិត, ប៉ុន្តែ បើមនុស្សក្នុងត្រកូលណាមួយ ដែលកើតមករួមរស់នៅក្នុងភូមិស្រុកសង្កាត់ជាមួយនឹងគេដែរ ហើយគ្មានសំពត់អាវស្លៀកពាក់បិទបាំងរាងកាយ បិទបាំងកេរខ្មាសប្រាកដប្រជា គេហៅថា "មនុស្សអាក្រាត" ឬគេហៅថា "មនុស្សវិកលចរិត"ពុំខាន ។ ហិរិ និង ឱត្តប្បៈ នេះ លោកប្រៀបថា ដូចជា

គ្រឿងអលង្ការមួយប្រសើរណាស់ គួរយកមកស្លៀកពាក់បិទបាំង ដើម្បីជាលម្អរបស់មនុស្សជាតិ ឲ្យសមគួរដល់កិត្តិយសរបស់សត្វដែលកើតមកបានជាមនុស្ស ប៉ុន្តែ បើយើងកើតមកជាមនុស្សហើយ មិនត្រូវការប្តូរស្អប់ទ្រើម ចំពោះ **ហិរិ** និង **ឱត្តប្បៈ** ក៏គួរបានទទួលឈ្មោះថា «ជាមនុស្សអាក្រាត» ដូច្នោះដែរ ។

ប្រជាជនក្នុងសកលលោក ឬ ក្នុងប្រទេសណាមួយ ដែលមានសុខសន្តិភាពរៀបរយចម្រើនរុងរឿង មានសេរីភាព-វឌ្ឍនភាពនិងអធិបតេយ្យរស់នៅ ដោយជីវភាពខ្ពង់ខ្ពស់ ក៏ព្រោះហេតុតែអានិសង្ស នៃ **ហិរិ** និង **ឱត្តប្បៈ** នេះឯង ។ ប្រជាជនដែលប្រាសចាក **ហិរិ** និង **ឱត្តប្បៈ** ហើយ ជាហេតុនាំឲ្យមានការបៀតបៀន សង្កត់សង្កិន លោភលន់ប្រើអំណាចគ្រប់សង្កត់ជិះជាន់គ្នា នាំឲ្យសង្គមមនុស្សបាក់បែកប្រេះឆា សាមគ្គីរវាងគ្នានិងគ្នា ពុំអាចរស់នៅជាសុខស្រួលបានឡើយ ទាំងជាហេតុនាំឲ្យលោកអ្នកគ្រប់គ្រងប្រទេស លំបាកគ្រប់គ្រងក្រៃជាទីបំផុត ទោះបីប្រើអំណាចអាជ្ញាដោយគ្រឿងសស្ត្រាវុធសម្រាប់ការពារគ្រប់គ្រង ក៏ធ្វើបានដោយលំបាកណាស់ ។ អាស្រ័យហេតុដូចអធិប្បាយមកនេះ អាចបញ្ជាក់ឲ្យឃើញថា **ហិរិ** និង **ឱត្តប្បៈ** ធម៌នេះ ជាមធ្យោបាយមួយរបស់ព្រះពុទ្ធ-សាសនា ដែលគួរយកមកអនុវត្តឲ្យឃើញមានជាទ្រង់ទ្រាយរូបរាងឡើងសម្រាប់ជាជំនួយក្នុងការគ្រប់គ្រងប្រទេសជាតិ ដើម្បីសុខសន្តិភាពរៀប

ហើយក្នុងរដ្ឋនីមួយៗ ។ **ហិរិ** និង **ឱត្តប្បៈ** រាប់ថា ជាច្បាប់មួយសម្រាប់អប់រំក្នុងផ្លូវចិត្តសាស្ត្រឲ្យមានសណ្ដាប់ធ្នាប់ល្អ តាមរបៀបសីលធម៌សុជីវ-ធម៌នៃពុទ្ធសាសនា ។

ច្បាប់អាជ្ញារបស់រដ្ឋ សម្រាប់គ្រប់គ្រងមនុស្ស អាចប្រើប្រាស់ខ្លួនបានចំពោះតែខាងកាយ ពុំបានទូទៅដល់ផ្លូវចិត្តផងឡើយ, ចំណែក **ហិរិ** និង **ឱត្តប្បៈ** ធម៌នេះ ទើបអាចអប់រំបានទាំងខាងផ្លូវកាយទាំងខាងផ្លូវចិត្ត ដូចសេចក្ដីពណ៌នាមកនេះឯង ។

**ធីរំ បសំសន្តិ ន ហិ តត្ថ សូរំ**

ក្នុងការប្រព្រឹត្តផ្លូវទុច្ចរិត
នោះ ពួកបណ្ឌិតគ្រប់ទីឋាន
មិនដែលសរសើរអ្នកក្លាហាន
លោកបានសរសើរតែអ្នកខ្លាច

ស-សំ

ផល - និត

# ចតុរារិយសច្ច

(តមកពីលេខមុន)

ភិក្ខុ ម៉ាខ-ខាត់ រៀបរៀង

-វិញ្ញាណមានសញ្ញាជាគ្រឿងគួបកាន់=សញ្ញុបាយំ កាលឋិតនៅ គប្បីឋិតនៅបាន មានសញ្ញាជាអារម្មណ៍= សញ្ញារម្មណំ មានសញ្ញាជាទីតាំង=សញ្ញាបតិដ្ឋំ

-វិញ្ញាណមានសង្ខារជាគ្រឿងគួបកាន់-សំខារូបាយំ កាលឋិតនៅ គប្បីឋិតនៅបាន មានសង្ខារជាអារម្មណ៍=សង្ខារម្មណំ មានសង្ខារជាទីតាំង-សង្ខារបតិដ្ឋំ

ហើយសេពនៅក្តីកកាយចំរើនឡើង លូតលាស់ដុះដាលឡើង ធំពេញលេញឡើង ៗ

ភិក្ខុទាំងឡាយ អ្នកណាគប្បីពោលថា: ខ្ញុំនឹងបញ្ញត្ត នូវអ្វីមក-ទៅ-ចុតិ-កើត-ចំរើនឡើង-លូតលាស់ដុះដាលឡើង ធំពេញលេញឡើងនៃវិញ្ញាណក្រៅពីរូប វេទនា សញ្ញា សង្ខារទាំងឡាយ យ៉ាងនេះ ឬនឹងប្រែថា : ខ្ញុំនឹងចង្អុលប្រាប់អ្នក នូវវិញ្ញាណ មក-ទៅ-ចុតិ-កើត-ចំរើនឡើង-លូតលាស់ដុះដាលឡើង-ធំពេញលេញឡើង ក្រៅពីរូប វេទនា សញ្ញា សង្ខារទាំងឡាយ យ៉ាងនេះ នេះមិនមែនជាឋានៈទេ= យោ ភិក្ខវេ ឯវំ វទេយ្យ: (អហំ អញ្ញត្រ រូបា អញ្ញត្រ វេទនាយ

អញ្ញត្រ សញ្ញាយ អញ្ញត្រ សង្ខារេហិ វិញ្ញាណស្ស អាគតឹ វា ចុតឹ វា ឧបបត្តឹ វា វុឌ្ឍឹ វា វិរុឡ្ហឹ វា វេបុល្លំ វា បញ្ញបេស្សាមីតិ) នេតំ ឋានំ វិជ្ជតិ ។

ពុទ្ធភាសិត ជាសេចក្ដីពន្យល់បន្តិចនេះ ជាចំណុចមានសារៈសំ-ខាន់បំផុត បានសេចក្ដីច្បាស់ថា អង្គព្រះសម្ពុទ្ធមិនសំដែងថា វិញ្ញាណនេះជាតួ បុគ្គល ។ (សត្វ)ឬ(អញ-ខ្ញុំ) ដូច្នេះទេ ។ បើអ្នកណាមួយបាននិយាយ មានតែអ្នកនោះចង់និយាយពីអ្វី ដែលមិនមាន គឺនិយាយពីអ្វីទទេ បង្កើតតែពាក្យទទេ គ្រាន់តែឲ្យមានពាក្យនិយាយ ពាក្យនេះហើយយូរៗទៅ កើតទៅជាគំនិតនៅក្នុងមនោគតិថាមានពិត ហើយបានកើតទៅជាទ្រឹស្ដី ។ អាត្មន ដែលមេលទ្ធិព្រាហ្មណ៍ទុកជាទ្រឹស្ដីវិសេសនៅក្នុងទស្សនវិជ្ជារបស់ខ្លួន អាថ៌កំបាំងនេះ មើលទៅឃើញហាក់ដូចជាវាក់ៗតែជ្រៅណាស់ ជ្រៅទាល់តែយើងគ្រប់គ្នាកន្ត្រច្រឡំ ទៅជាយល់ថានេះជាតួ សត្វ បុគ្គល ឬ អញ ខ្ញុំ ឬក៏ អាត្មន ព្រលឹង ហើយប្រកាន់ជាប់ស្អិតនៅក្នុងចិត្តថា ជា «ធម៌ពិត» ជជែកគ្នាបែកជាអូរហូរជាស្ទឹងមិនចេះចប់ ។ ប្រាជ្ញគួរត្រិះរិះ ពុទ្ធភាសិតខាងលើនេះឲ្យម៉ត់ចត់ ។

នេះជាខន្ធបញ្ចកៈ ដោយសង្ខេប ។ នេះហើយដែលយើងហៅ សត្វ បុគ្គល អញ ឯង គឺយើងហៅជានាម ឬ យីហោ ដែលជាតួផ្សេង

ខន្ធបញ្ចកៈ ៗ ធម៌ទាំងអស់នេះ ជាធម៌អនិច្ចំ តែងប្រែប្រួលទៅជានិច្ច របស់ណាដែលមិនទៀង របស់នេះជាទុក្ខំ=យទនិច្ចំ តំ ទុក្ខំ ៗ នេះហើយជាអរិយសច្ចៈ ក្នុងពុទ្ធវចនៈ ដែលទ្រង់ត្រាស់ទុកថា សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ៗ ខន្ធបញ្ចកៈ នេះមិនដូចគ្នាគ្រប់ខណៈចិត្តទៅទេ ៗ

ដូច្នេះវិញ្ញាណនេះប្រែប្រួលទៅជានិច្ច ដូចអក្សរ ក នេះមិនមែនជាអក្សរ ក គទៅខាងមុខទេ ព្រោះធម្មជាតិនេះតែងហូរទៅជានិច្ចគ្រប់ខណៈ គឺក្នុងខណៈដែលកើតឡើង និងខណៈដែលរលត់ទៅវិញ ៗ បើលះបង់រាគៈ នៅក្នុងខន្ធបញ្ចកៈបានហើយ វិញ្ញាណនឹងរលត់ទៅវិញដោយពិត ដូចពុទ្ធភាសិតដែលទ្រង់ត្រាស់ទុក(១)ថា :

ភិក្ខុទាំងឡាយ បើលះបង់រាគៈ ក្នុងរូបធាតុ វេទនាធាតុ សញ្ញាធាតុ សង្ខារធាតុ វិញ្ញាណធាតុ អស់ហើយ អារម្មណ៍នឹងដាច់ស្រឡះចេញ, វិញ្ញាណមិនមានអ្វីជាទីតាំងនៅទៀតទេ បើមិនមានទីតាំងហើយ វិញ្ញាណនោះមិនលូតលាស់ទៀតទេ មិនតាក់តែងបដិសន្ធិតទៀតទេ រួចស្រឡះអស់ហើយឋិតនៅតែកាយមិនតក់ស្លុត ហើយបរិនិព្វានប្រាកដ ៗ ពេលនោះអ្នកនឹងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បានបំពេញបរិបូណ៌ហើយ សោឡសកិច្ចបានធ្វើរួចស្រេចហើយ មិនមានមគ្គភាវនាកិច្ចដទៃទៀតទេ ៗ

---

១-សំយុត្ត. យ ឧបាយវគ្គ សៀវភៅទី ៣៣ ទំព័រ ១២៣ ៗ

មួយទៀតវិញ្ញាណនេះប្រៀបដូចពូជ ដូចពុទ្ធភាសិតថា (១)

ភិក្ខុទាំងឡាយ ពូជមាន ៥ ប្រការគឺ ពូជមើម ពូជដើម ពូជថ្នាំង ពូជត្រួយ ពូជគ្រាប់ ។ ពូជទាំង ៥ នេះបើមិនពុក មិនស្អុយ មិនវិនាសដោយខ្យល់និងថ្ងៃ គួរនឹងមានខ្លឹមនៅល្អទៅ តែបើមិនមានដី មិនមានទឹក ពូជទាំងនេះមិនដុះលូតលាស់ឡើងទេ ។

ភិក្ខុទាំងឡាយ ពូជ ៥ ប្រការនេះ អាស្រ័យដោយអាហារយ៉ាងណា វិញ្ញាណក៏អាស្រ័យដោយអាហារយ៉ាងនោះដែរ ។

ភិក្ខុទាំងឡាយ វិញ្ញាណនេះមានរូបធាតុ វេទនាធាតុ សញ្ញាធាតុ សង្ខារធាតុ សម្រាប់ក្តោបកាន់ កាលឋិតនៅ គប្បីឋិតនៅបាន មានរូបធាតុ វេទនាធាតុ សញ្ញាធាតុ សង្ខារធាតុជាអារម្មណ៍ មានរូបធាតុ វេទនាធាតុ សញ្ញាធាតុ សង្ខារធាតុជាទីតាំង ហើយសេពនូវក្តីត្រេកអរ ក៏ចំរើនឡើង លូតលាស់ដុះដាលឡើង ធំពេញលេញឡើង ។

ភិក្ខុទាំងឡាយ! បើលះបង់ពន្ធៈក្នុងរូបធាតុ វេទនាធាតុ សញ្ញាធាតុ សង្ខារធាតុ អស់ហើយ អារម្មណ៍នឹងដាច់ច្រឡះចេញ វិញ្ញាណមិនមានអ្វីជាទីតាំងនៅទៀតទេ លែងតែងបដិសន្ធិទៅទៀតទេ រួចស្រឡះអស់ហើយ ឋិតនៅរីករាយមិនតក់ស្លុត ហើយបរិនិព្វានប្រាកដ ។ ពេលនោះអ្នកនឹងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បានបំពេញរួចហើយ សោឡសកិច្ចបានធ្វើរួចស្រេចហើយ មិនមានមគ្គភាវនាកិច្ចដទៃទៀតទេ ។

១- សំយុត្តនិកាយ ខន្ធវគ្គ សៀវភៅទី ៣៣ ទំព័រ១២៨ តទៅ ។

ឯជីវិតតិចណាស់ខ្លីណាស់ហើយតែងតែប្រព្រឹត្តទៅជានិច្ចដកបតទៅ ប្រៀបដូចជាទឹកស្ទឹងដែលហូរខ្វលខ្វាញ់ចុះពីលើកំពូលភ្នំ ។ សេចក្តីនេះ ព្រះសម្ពុទ្ធទ្រង់បានត្រាស់ចំពោះព្រាហ្មណ៍ម្នាក់ឈ្មោះ អរកៈ (១) ថា:

ព្រាហ្មណ៍ ប្រៀបដូចទឹកស្ទឹងដែលចុះពីកំពូលភ្នំទៅកាន់ទីឆ្ងាយមានខ្សែទឹកហើសនាំយកអ្វីដែលនៅក្នុងពោះស្ទឹង ទៅជាមួយផង ឥតឈប់សម្រាកមួយខណៈ ឬមួយវេលាណាឡើយ ចេះតែហូរទៅ ចេះតែលូនទៅចេះតែស្ទុះទៅយ៉ាងនេះដកប ។

ព្រាហ្មណ៍! ជីវិតនេះតិចណាស់ ខ្លីណាស់ប្រៀបដូចទឹកស្ទឹងដែលហូរចុះពីកំពូលភ្នំដូច្នោះឯង ។

សេចក្តីនេះ ត្រូវនឹងស្រៀបដល់ពាក្យ លោក ហេរ៉ាក្លីត ទស្សនវិទូក្រិក ដែលលោកនិយាយ (២) ថា អ្វីៗទាំងអស់សុទ្ធតែប្រែប្រួលជានិច្ច លោកនិយាយតទៅថា អ្នកមិនគប្បីឈប់ពីរដងនៅក្នុងទឹកស្ទឹងដដែល ដើម្បីមុជទឹកត្រជាក់ដែលកំពុងហូរខ្វលខ្វាញ់នោះទេ ។

---

១-អង្គុត្តរនិកាយ សត្តកនិបាត សៀវភៅទី ៤៧ ទំព័រ ២៤៨

២- Héraclite ( ou Héraclitus ) ទស្សនវិទូក្រិក ( 576 480Av.J.C. )
លោកនិយាយថា Everything is in a state of flux. His famous Statement is : You cannot step twice into the same rever ; for fresh waters are ever flowing in upon you

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ - កន

ប្រែ ~ រៀបរៀង

## (ក)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នកវាងវៃឆ្លាសបើបានអាន |
| នឹងចេះឧបាយកលចំណាន | ទាំងមានសន្តានស្នេហាជាតិ |

យូ-អ៊ុន

ឯទាហានឈើជិតពាក់កណ្ដាលដែលនាំរបស់ប្រចាំជូនទៅនោះ ទៅប្រទះនឹងហែហ៊្វិប៉ា ៗ ក៏ឲ្យទាហានឡោមព័ទ្ធឃាត់ឃុំទុក ពួកទាហានឈើជិតទប់ពុំឈ្នះក៏ព្រមស្ម័គ្រចូលទៅជាពួកហែហ៊្វិប៉ាទាំងអស់, ហើយនាំគ្នាកាន់ទង់ជ័យឈើជិតជាមុខ នាំកងព័ទ្ធនឹងស្បៀងត្រង់ទៅបន្ទាយស៊ុម៉ាចៀវ ៗ ឃើញជាពួកទាហានឈើជិតវ៉ាយយកស្បៀងប្រចាំជូនបានមក. ក៏បើកទ្វារទទួលឲ្យចូលទៅ, ហែហ៊្វិប៉ាក៏នាំទាហានចូលទៅក្នុងបន្ទាយស៊ុម៉ាចៀវ ហើយក៏ដេញកាប់សម្លាប់ទាហានស៊ុម៉ាចៀវ, ឯស៊ុម៉ាចៀវក៏នាំទាហានតែចំណាយចេញទៅបាន លៀវហ៊្វិនឹងទៀវអេកក៏បង្ហំស្រួតទៅប្រទះនឹងស៊ុម៉ាចៀវហើយព្រួតគ្នាវាយប្រសព្វ, ស៊ុម៉ាចៀវទ្រាំមិនបានក៏ប្រះរត់ទៅតាមផ្លូវ ១, ប្រទះគ្នានឹងកងព័ទ្ធកៀងអ៊ុយ ៗ ក៏បរពេលចូលទៅមកវាយស៊ុម៉ាចៀវ ៗ ទាល់ប្រកគេបរសោះ, ក៏[illegible]រត់ឡើងទៅបើក្ដី

ទៀតឡើងសាន់, ភ្នំនោះមានផ្លូវចំពោះឡើងទៅតែ ១, មានអន្លង់ទឹកតូច ១ ល្មមទឹកបានចំនួនមនុស្ស ១០០ នាក់, ពាហានដែលឡើងទៅជាមួយនឹងសុម៉ាចៀវនោះ ប្រមាណ ៦០០០ នាំគ្នាផឹកទឹកនោះរីងអស់, គៀងអ៊ុយនឹងតាមឡើងទៅពុំបាន ក៏ឲ្យពាហានព័ទ្ធភ្នំនោះទុក, សុម៉ាចៀវឃើញសេះនឹងពាហានឃ្លានស្រេកទឹកណាស់ ក៏ងើបមុខឡើងមើលអាកាសហើយតទ្រំដើងស្រែកថា: ឃើ! ទេពតាមិនអាណិតយើងទេ ឬ ៗ នឹងឲ្យអត់ទឹកស្លាប់ទាំងអស់គ្នាហើយ ៗ

អងហ៊ៅ សមុហបញ្ចើ្លយថា: ពីគ្រាមុនឈ្មោះក្រេងក:យុងម្នាក់ លើកកងទ័ពទៅច្បាំងនឹងសត្រូវហើយដាច់ទឹកផឹកសោះ បានប្រទះអន្លង់ ១ ចូលទៅរកទឹកគ្មានក៏ក្រាបចុះបន់ស្រន់ទេពតាទើបបានទឹកផឹកបរិបូណ៌, លោកដាច់ទឹកវេលានេះ សុំឲ្យបន់ស្រន់ទេពតាទៅមើលចុះ, សុម៉ាចៀវយល់ឃើញត្រូវ ក៏ដើរឡើងទៅដល់អន្លង់ទឹកនោះ ហើយក៏ក្រាបចុះ ៣ ដងបន់ស្រន់ថា ខ្ញុំម្ចាស់ឈ្មោះ សុម៉ាចៀវ បានយកអាសាម្ចាស់ផែនដីចេញមកប្រាបប្រាមខ្មាំងសត្រូវ បើខ្ញុំម្ចាស់នឹងអស់ជីវិតហើយ សុំកុំឲ្យមានទឹកមកឡើយ ខ្ញុំម្ចាស់នឹងបានការគេឲ្យស្លាប់ ពាហានទាំងពួងនឹងនាំគ្នាចូលទៅចំណុះសត្រូវតែម្តង, បើខ្ញុំម្ចាស់នៅមានជីវិតធ្វើកផការ ជួយ ម្ចាស់ផែនដីតទៅ, សូមឲ្យទេពតាបណ្តាលឲ្យមានទឹកមកពេញអន្លង់នេះចុះ លុះបន់ស្រន់ល្មមតែផុតពាក្យសច្ចាធិដ្ឋាន ក៏

មានទឹកហូរចេញមកពេញអន្ទង់នោះ អស់រេហ៍ពលទាំងសេះ ក៏បានបរិភោគឆ្អែតស្កប់ស្កល់កល់គ្នា មិនមានស្រុតស្រេកឡើយ ។

គៀងអ៊ុយក៏និយាយនឹងទាហានទាំងពួងថា: មហាឧបពជព័ទ្ធស៊ុម៉ាអ៊ីទុកបានមុន តែចាប់ខ្លួនមិនបាន យើងក៏មានសេចក្ដីខឹងក្ដៅណាស់ គ្រានេះយើងឃើញថា ស៊ុម៉ាចៀវមុខជាមិនផុតពីដៃយើងទេ, យើងមុខជាចាប់បានខ្លួនជាប្រាកដហើយ ។

ឯគួយហ៊្វួយនៅស្រុកអេងជីវបានដឹងថា: គៀងអ៊ុយព័ទ្ធស៊ុម៉ាចៀវទុកលើភ្នំថៀតឡុងសាន់ហើយ ទើបប្រឹក្សានឹងតាន់ថាយថា: នឹងលើកកងទ័ពទៅជួយ ឬ? តាន់ថាយឆ្លើយថា: ដែលនឹងលើកទៅជួយនោះ ខ្ញុំនៅមានបារម្ភណាស់ ព្រោះគៀងអ៊ុយលើកព័ទ្ធមកគ្រានេះ មានកងទ័ពស្រុកគៀងលើកមកផង, លើកមកដល់ដែនស្រុកតាន់ណាំហើយ បើដឹងថាលោកលើកទៅជួយស៊ុម៉ាចៀវវេលាណា គង់គៀងអ៊ុយនឹងលើកត្រឡប់ទៅវាយយកស្រុកអេងជីវវិញ យើងនឹងមិនថុសការទេ ឬ? ខ្ញុំបាទគិតថានឹងទំលាយទ័ពស្រុកគៀងចេញមុន និងឲ្យដឹកល្បុងធំវែងស្អាក់ពីមុខស្រុក ទុកហើយខ្ញុំបាទនឹងទៅបញ្ឆោតបីតង់ឲ្យហ្វាយស្រុកគៀងឲ្យលើកមកវាយស្រុកយើង ហើយយើងនឹងកំចាត់បីតង់ចេញ បើបានហើយសឹមលើកទៅជួយស៊ុម៉ាចៀវ និងមិនបាច់វាំងក្រោយឡើយ ។

គួយហ៊្វួយយល់ឃើញត្រូវផង ក៏ប្រើតាន់ថាយនាំទាហាន ៥.០០០

ទៅបញ្ចោតបីតង, តាន់ថាយក៏លើកចេញទៅ លុះដល់ទៅជិតស្រុក
កៀនហើយ ទើបប្រើទាហានឲ្យចងគ្រឿងសស្ត្រាវុធរែកចូលទៅឲ្យបី
តង តាន់ថាយទៅដល់បីតងហើយក៏ក្រាបចុះ ហើយយំៗហើយថា: ខ្ញុំ
បាទធ្វើជការនិងគួយហ៊្វយមានសេចក្ដីគាប់ប្រសើរណាស់ គួយហ៊្វយ
មិនបានលើកសេចក្ដីគាប់ប្រសើរនោះ ឲ្យខ្ញុំបាទពេញចិត្តសោះឡើយ
តាំងខ្លួនជាធំហើយ គិតកំចាត់ខ្ញុំបាទចេញទៀត ខ្ញុំបាទមានសេចក្ដីតូច
ចិត្តណាស់ បាទជាស្ម័គ្រចិត្តចូលមកនៅជាមួយលោក, ព្រោះខ្ញុំបាទ
ដឹងពីដើមថា: លោកមានសតិបញ្ញាចេះចិញ្ចឹមរក្សាមនុស្សល្អៗ បាន
ជាខ្ញុំបាទចូលមកនៅនឹងលោក, ឯដែលនឹងវាយយកស្រុកកេងជីវនោះ
ជាភារកិច្ចលើខ្ញុំបាទម្នាក់ឯងចុះ សុំកុំឲ្យលំបាកឡើយ, សុំឲ្យលោក
លើកកងទ័ពទៅក្នុងពេលយប់នេះចុះ ខ្ញុំបាទនឹងសុំទៅសងសឹកវិញឲ្យ
បាន, បីតងក៏ជឿស្ដាប់ចិត្ត ទើបបង្គាប់ឲ្យង៉ោហោ និងសៀវគួលើក
ទ័ពទៅជាមួយនឹងតាន់ថាយ ។

ឯង៉ោហោនិងសៀវគួក៏ឲ្យទាហានតាន់ថាយនៅពីក្រោយ យកតែ
ខ្លួនតាន់ថាយទៅមុនមួយផង, លុះដល់ពេលយាម ២ យប់ ក៏លើក
ទៅដល់ស្រុកកេងជីវ ក្រះឡូកទៅ ឃើញទ្វារកំផែងបើកចំហ, តាន់
ថាយក៏ចំផាយសេះទៅប្រាជ់គួយហ៊្វយ ដែលត្រៀមកងទ័ពទុកនោះនាំ
គ្នាចេញមកវាយត្រឡប់ពីក្រោយ, ទាហានតាន់ថាយដែលតាមមកពី

នាយនោះ កំដេញកាប់សម្លាប់ពីក្រោយចូលទៅ ពាហានអ៊ោហោ និងសៀវគួក៏ធ្លាក់ចុះក្នុងរំលុងទាំងសេះនិងមនុស្សជាន់សង្កត់លើគ្នា របួសពិការស្លាប់ជាច្រើនណាស់, ពាហានដែលសល់ពីស្លាប់នោះ កំសុំចំណុះចុះចូលទៅនឹងតាន់ថាយ ។

ឯអ៊ោហោនិងសៀវគួ កំយកជាវការកស្លាប់ទាំង ២ នាក់, លុះព្រឹកឡើងគួយហាយ និងតាន់ថាយកំលើកចូលទៅក៏យបឹតងហៅហ្វាយស្រុកកៀង ដែលតាំងនៅដែនស្រុកគាន់ណាំនោះ, បឹតងឃើញកងទ័ពតាន់ថាយនិងគួយហួយក៏មានសេចក្តីខឹងក្តៅណាស់ ឡើងសេះនាំពាហានចេញមកក្រៅបន្ទាយ; ឯពាហានគួយហួយ និងតាន់ថាយឃើញទាហានបឹតងនៅតិចណាស់ កំចូលឃុំព័ទ្ធចាប់ខ្លួនបឹតងបានចងយកទៅឲ្យគួយហួយ ។ គ្រាឡើកឃើញ ធ្វើជាភ័យភ្ញាក់ចុះពីលើសេះប្រញាប់ប្រញាល់ទៅស្រាយចំណងពីខ្លួនបឹតងចេញអស់ហើយនិយាយថាព្រះចៅចូហងទ្រង់ព្រះមេត្តាលោកណាស់ថា លោកជាមនុស្សទៀងត្រង់តាំងព្រះទ័យប្រុងនៃតនឹងទំនុកបំរុងលោក, ហេតុម្តេចក៏លោកប្រែចិត្តទៅចូលខាងអៀនស៊ុយដែលជាមនុស្សអាក្រក់នោះវិញ, បឹតងក៏អង្វរការសុំអាយុជីវិតហើយថា ខ្ញុំបាទសុំធ្វើជាខ្ញុំព្រះចៅចូហងៈទៅ, គួយហួយថាៈ បើដូច្នោះលោកចូរធ្វើជាមេទ័ពមុខ លើកទៅក៏យអៀនស៊ុយដែលព័ទ្ធសុមាំទៀវទុក.នោះ បើសម្រេចពជការហើយ យើងនឹងពិត

ទូលលើកយកសេចក្ដីគាប់ប្រសើរឲ្យ ប៉ីតងក៏ទទួលការសា, លុះពេលា ព្រលប់ក៏នាំពលលើកចេញទៅដល់ទ័ពមុខ, លុះពេលយាម ៣ ទៅដល់ ជិតបន្ទាយគៀនអ៊ុយហើយប្រើទាហានឲ្យចូលទៅ ប្រាប់គៀនអ៊ុយថា ទ័ពប៉ីតងលើកមកដល់ហើយ, គៀនអ៊ុយមានអំណរណាស់ ក៏បង្គាប់ថា ឲ្យអញ្ជើញប៉ីតងចូលមកចុះ, ប៉ីតងនាំទាហានរបស់ខ្លួន និងទាហាន របស់គួយហួយចូលទៅជាមួយផងជាច្រើន, គៀនអ៊ុយឃើញប្លែកណាស់ ទើបឃាត់ថា: ឲ្យទាហានតាំងបន្ទាយនៅខាងក្រៅសិនចុះ, ត្រូវអញ្ជើញ តែខ្លួនអ្នកនិងទាហានដែលតាមខាងក្រោយឲ្យចូលមកចុះ, ប៉ីតងក៏នាំទា ហានគួយហួយនិងទាហានរបស់ខ្លួន ដែលមានថ្វីដៃប្រហែល ១០០នាក់ ចូលទៅក្នុងបន្ទាយ, គៀនអ៊ុយនិងហៃហ៊ួចា៎ ចេញមកទទួលនាំចូលទៅ ក្នុងបន្ទាយ, ប៉ីតងនៅមិនទាន់បង្គាប់ឲ្យធ្វើការអ្វី ស្រាប់តែពួកទាហាន តាំងនោះឃើញបានចំណាប់ហើយ ក៏លើកគ្នាដេញកាប់សម្លាប់ពួកទា ហានក្នុងបន្ទាយជាច្រួលច្របល់ឡើង , ទាហានខាងក្រៅក៏តាវទំលាយ ចូលទៅក្នុងបន្ទាយបានព្រួតជួយគ្នា ។

គៀនអ៊ុយភ័យតក់ស្លុតស្មារតីណាស់ មិនទាន់ទឹងក្រោកចាប់យក អាវុធ ក៏លោតឡើងលើសេះបររត់ទៅ ទាហានទាំងពួងក៏នាំគ្នារត់ចេញ ពីក្នុងបន្ទាយខ្ចាត់ខ្ចាយចេញទៅ គៀនអ៊ុយមិនមានអាវុធកាន់សោះ ប្រវា ចាប់បានតែដងធ្នូទទេនៅជាប់ក្នុងបង្កេះ គ្មានព្រួញសោះធ្លាក់អស់ពីដៃ

គួយហួយឃើញកៀនអ៊ុយក៏បំផាយសេះដេញ, កៀនអ៊ុយក៏ឃឹតធ្នូបាញ់តែបន្ទោះទទេ, គួយហួយបានឮតែសំឡេងខ្សែបន្ទោះធ្នូមិនមានព្រួញសោះ, គួយហួយក៏យកស្រោមដាវធ្វើជាព្រួញបាញ់ទៅ, កៀនអ៊ុយស្ទាក់ចាប់បានក៏បង្អង់នៅឲ្យគួយហួយស្ទុះចូលទៅជិត គេប្រមាណបានចំណាប់ហើយ ក៏បាញ់ត្រូវគួយហួយ ធ្លាក់ពីលើសេះ, កៀនអ៊ុយក៏ត្រឡប់ទៅដណ្ដើមបានលំពែងសម្រាប់ដៃ គួយហួយលើកឡើងនឹងចាក់ទទួលទាហានគួយហួយ ក៏ស្ទុះចូលទៅដល់ទាន់, កៀនអ៊ុយក៏រត់ទៅទាហានក៏នាំគួយហួយវិលទៅចន្ទាយ តែលុះមកទ្រាក់ដកយកស្រោមដាវដែលមុតនោះបាន លោហិតក៏ហូរចេញមកច្រើនណាស់ គួយហួយក៏ដាច់ខ្យល់ស្លាប់, ស៊ុម៉ាចៀវក៏នាំទាហានចុះពីលើភ្នំទៅជួយគ្នាដេញសត្រូវទៅ ។

ឯហៃហ៊្វូប៉ាំរត់ទៅប្រទះគ្នានឹងកៀនអ៊ុយ ក៏នាំគ្នាត្រឡប់ទៅស្រុកហាន់តុង ទើបប្រឹក្សាគ្នាថា: យើងទៅទ័ពគ្រានេះ ខូចខាតទាហានច្រើនណាស់ តែជាបានប្រៀបដោយបានរំលាងនាយទាហានឯកដែលមានថ្វីដៃបាន ៦ នាក់, កូនទាហានក៏បានច្រើនដែលស្លាប់វិនាសនោះសេចក្ដីខុសយើងក៏មាន សេចក្ដីចាប់យើងក៏បាន ទោះទឹងចូលទៅគាល់ក៏មិនទាន់ស៊ូរ ថាហើយក៏នាំគ្នាចូលទៅគាល់ ព្រះចៅឡៅសៀនឯក្រុងសែលទូន ។

និយាយពីស៊ុម៉ាចៀវ ក៏ ឲ្យ[illegible]ចាប់ផ្ទាំងដល់តែងតាំងទាហាន

ទាំងពួងតាមសមគួរ ហើយទើបបង្គាប់ថា អ្នកចូរត្រឡប់វិលទៅស្រុកវិញចុះ ខ្ញុំចូលទៅគាល់ទឹងទូលសេចក្ដីគាប់ឲ្យ ប៉ិតងក៏លា ទាហានត្រឡប់ទៅស្រុក គៀងស៊ីម៉ាចៀវក៏លើកទ័ពត្រឡប់ចូលទៅក្រុងឡុងអៀង ។

នោះស៊ីម៉ាស៊ូ នឹង ស៊ីម៉ាចៀវ បាននិយាយពជការក្នុងស្រុកវ៉ៃកុក បណ្ដានាម៉ឺនមុខមន្ត្រីធំតូចក៏សឹងនៅក្រោមបង្គាប់បញ្ញា ទាំងអស់ បើនឹងខុសនឹងត្រូវប្រការម្ដេចក៏រកនរណាទទឹងទាស់គ្មាន ។

※ ※ ※

តាំងពីស៊ុម៉ាស៊ូឡើងអំណាច ព្រះចៅចោហាងនឹងមន្ត្រីធំ ៣ នាក់គិតការស្ងាត់នឹងកំចាត់ស៊ុម៉ាស៊ូ ដឹងសម្លាប់មន្ត្រី ៣ នាក់នឹងព្រះអគ្គមហេសីស្តេច ដករាជសម្បត្តិចោហាង តាំងចោម៉ឲ្យឡើងសោយរាជសម្បត្តិ ស៊ុម៉ាស៊ូឡើងជាមហាឧបរាជ ។ ស៊ុម៉ាស៊ូស្លាប់ ស៊ុម៉ាចៀវឡើងជាមហាឧបរាជជំនួសបង, កៀងអ៊ុយលើកទ័ពទៅច្បាំងនឹងស្រុកវុយកុក ។

ឯព្រះចៅចោហាងចេញនិយាយរាជការវេលាណា បើបានឃើញមុខស៊ុម៉ាស៊ូចូលគាល់ក៏ឲ្យមានសេចក្តីខ្លាចក្រែងពេកណាស់ ថ្ងៃមួយនោះឃើញស៊ុម៉ាស៊ូកាន់ក្រប៊ីដើរចូលទៅក្នុងទីគាល់ ស្តេចក៏ស្ទុះព្រះទ័យលឿនព្រះអង្គរលឹកចុះពីព្រះទីនាំងកៅអី ស្តេចចេញទៅទទួលគំនាប់ស៊ុម៉ាស៊ូៗអស់សំណើចហើយថា: មានទំនៀមពីណាទីឲ្យអម្ចាស់ចេញទៅទទួលខ្ញុំឯនោះ, អញ្ជើញឡើងទៅគង់លើព្រះទីនាំងវិញចុះទើបនឹងសមគួរ ។

ឯអស់នាម៉ឺនមុខមន្ត្រីកំពុងតែប្រឹក្សាការរាជការ លុះឃើញស៊ុម៉ាស៊ូចូលទៅហើយក៏ស្ងៀមទាំងអស់គ្នា ព្រះចៅចោហាងក៏ទ្រង់ស្ងៀមមួយស្របក់ហើយក៏ត្រឡប់យាងចូលទៅក្នុង, ស៊ុម៉ាស៊ូក៏ចេញចាកទីគាល់មិនមានសេចក្តីគោរពក្រែងរអែងខ្លាចព្រះចៅចោហាងសោះ ឡើងជិះលើរទេះមានទាហានប្រហែល ១០០០ នាក់ ដែលកាន់សាស្ត្រាវុធហែហមអមព្រះអង្គចេញមកពីក្នុងវាំងត្រឡប់ទៅផ្ទះ, ព្រះចៅចោហាងក្រឡេកទតខ្មេង ស្តាំ

ឃើញមន្ត្រីធំជាទីប្រឹក្សានៅគាល់នៅទីនោះ៣នាក់ ឈ្មោះហៃហោហៀន ១, លីហង១, ទៀវអ៊ុមជាបិតានាងទៀវហងមហេសីស្តេច១, ព្រះចៅចោហងទ្រង់បណ្តេញមនុស្សទាំងពួងឲ្យចេញអស់ហើយ ទើបទ្រង់ហៅមន្ត្រីទាំង៣នាក់ឲ្យចូលមកជិតព្រះអង្គ ៗ ចាប់ដៃទៀនអ៊ុមហើយក៏ទ្រង់ព្រះកន្សែងសោកហើយត្រាស់ថា: សព្វថ្ងៃនេះសុម៉ាស៊ូមើលងាយយើងដូចកូនក្មេង, មើលងាយនាម៉ឺនមុខមន្ត្រីទាំងពួងស្មៅដើនក្រាស, យើងមើលទៅឃើញមិនយូរទេរាជសម្បត្តិនេះក៏នឹងជារបស់សុម៉ាស៊ូ ។

លីហងក្រាបថា: ទូលព្រះបង្គំជាខ្ញុំនេះ មិនមានសតិបញ្ញាដែលនឹងជួយព្រះអង្គបាន តែទូលព្រះបង្គំជាខ្ញុំគិតថា នឹងសុំត្រាព្រះជម្រាស់របស់ព្រះអង្គចេញទៅបញ្ចុះបញ្ចូលអាណាខែត្រទាំងពួង នឹងបានរកមនុស្សល្អមានសតិបញ្ញា មានថ្វីដៃខ្លាំងពូកែ នឹងទាហានទាំងពួងបានច្រើនហើយនឹងចូលមកកំចាត់អាសត្រូវផែនដីចេញឲ្យបាន ហៃហោហៀនក្រាបទូលថា ហេហ៊ូប៉ាជាបងទូលព្រះបង្គំជាខ្ញុំ រត់ចូលទៅនៅនឹងព្រះចៅឡៅសៀន ព្រោះពួកសុម៉ាស៊ូប្រុងនឹងធ្វើអន្តរាយ បើបងព្រះបង្គំជាខ្ញុំដឹងថាព្រះអង្គនឹងកំចាត់សុម៉ាស៊ូ ក៏នឹងត្រឡប់មកជួយ ទូលព្រះបង្គំជាខ្ញុំក៏ជាពូជព្រះរាជវង្ស កើតហេតុដូច្នេះហើយនឹងស្ងៀមនៅបានឬ នឹងសុំទៅបញ្ចុះបញ្ចូលជាមួយនឹងលីហង ។

ព្រះចៅចោហងទ្រង់ត្រាស់ថា យើងញញើតណាស់ ក្រែងធ្វើទៅ

មិនសម្រេច មន្ត្រីទាំង ៣ នាក់យំហើយទូលថា ទូលព្រះបង្គំជាខ្ញុំទាំងសត្យស្បថស្បាទព្រមចិត្តគ្នា ទឹងរិះគិតកំចាត់កាសត្រូវផែនដីឲ្យបានព្រះចៅចោហងទើបផ្ទាស់ស្នងព្រះអង្គពិតាង ជាន់កូនមកកាត់ជាប្រហោងហើយកាត់ម្រាមព្រះហស្តយកព្រះលោហិតសរសេរថា ព្រះជម្រាស់ដាក់ក្នុងព្រះស្រទាប់ធ្ងន់ព្រះអង្គនោះ ហើយប្រគល់ឲ្យទៀវអ៊ុបរួចត្រាស់ថាៈ កាលគ្រាព្រះចៅចោនោ ជាព្រះអយ្យកោទួតនៃយើងសម្លាប់ពួកតាំងស៊ុនចេញអស់នោះព្រោះធ្វើការមិនជិត ឥឡូវអ្នកទាំង ៣ នាក់ទឹងធ្វើគ្រានេះបើនាំឲ្យបែកធ្លាយ ហើយក៏មិនជាការល្អ, លីហងទូលថា នៅមិនទាន់បានជាការអ្វី ព្រះអង្គមកមានព្រះវាចាជាប្រផ្លូលផ្ដេះមិនគួរទេ, ទូលព្រះបង្គំជាខ្ញុំមិនមែនល្ងង់ក្លើដូចតាំងស៊ុននោះទេ, សុម៉ាស៊ូវទឹងស្រួយយ៉ាងណាទៅ វាមិនមែនដូចព្រះចៅចោនោទេ ព្រះអង្គកុំទ្រង់ព្រួយព្រះទ័យឡើយ ទូលហើយក៏ថ្វាយបង្គំចេញមក ។

ខណៈនោះមានមនុស្សនាំយករឿងក្ដីកំបាំងនោះទៅប្រាប់សុម៉ាស៊ូវៗទឹងណាស់កាន់គ្រឿងនាំទាហាន ៥០០ សុទ្ធតែកាន់អាវុធគ្រប់ដៃចូលទៅដល់ទ្វារព្រះរាជវាំង; ទទួលជួបប្រទះទឹងហៃហៅហៀន, លីហង ទឹងទៀវអ៊ុប ១ ខ្ទាចក៏ចៀសទៅបំបាំងទឹងទ្វារព្រះរាជវាំង; សុម៉ាស៊ូសួរដណ្ដឹងថា អស់នាម៉ឺនម៉ុខមន្ត្រីទាំងពួងគេចេញពីទីគាល់ព្រមគ្នាហើយ, អ្នកឯងទាំង ៣ នាក់នៅយូរទើបចេញក្រោយគេ នោះតើទូវមានគិតការ

អ្វី ទាំង ៣ នាក់ឆ្លើយថា ដ្បិតទ្រង់ចង់សណ្ដាប់ព្រះរាជពង្សាវតារឲ្យខ្ញុំបាទមើលថ្វាយ, សុម៉ាស៊ូសួរថា ឲ្យមើលរឿងអ្វី លីហានថា មើលរឿងអ៊ុអ៊ិន គឺដីវថង់ជាមហាឧបរាជ លុះមើលដល់ឈ្មោះនេះ ទ្រង់សួរថា អ៊ុអ៊ិននឹងដីវថង់បានបំរុងផែនដីដល់ ២ រាជនោះតើគិតធ្វើយ៉ាងម្ដេច ? ខ្ញុំបាទទាំង ៣ នាក់ទូលថា បំរុងដូចព្រះតេជគុណរក្សាផែនដីដូចសព្វថ្ងៃនេះ, សុម៉ាស៊ូក្រែងធ្វើជាអស់សំណើចហើយថា អ្នកឯងទាំង ៣ នាក់ស្ទួយលើកយើងយកទៅប្រៀបនឹងរូបអ៊ុអ៊ិន ហើយនឹងដីវថង់ម្ដងឬ ? យើងអាចដឹងដល់ទឹកចិត្តអ្នកឯងទាំងអស់ហើយ គឺ អ្នកឯងយកយើងទៅប្រៀបដូចជាគង់មាំងនឹងតាំងគុះ ដែលជាសត្រូវនឹងរាជសម្បត្តិនោះទេតើ ទាំង ៣ នាក់ឆ្លើយថា យើងខ្ញុំក៏ជាខ្ញុំព្រះតេជ គុណប្រាកដ ដែលនឹងគិតថាទៅដូច្នោះនោះមិនគួរទេ ។

សុម៉ាស៊ូខឹងណាស់ថា អា៣នាក់ អាឯងញុះញង់ទូលសេចក្ដីស្ងាត់កំបាំងហើយយំដោយហេតុអ្វី ? ទាំង៣នាក់ក៏បដិសេធថាមិនមែនទេ , សុម៉ាស៊ូក៏ស្រែកគំហកហើយថា ឯងយំនៅក្នុងមិនទាន់បាត់ក្រហមទេតើ គួរឬមកបដិសេធដូច្នេះវិញ, វ៉ៃហៅហឿនឃើញថាការដែលធ្វើនោះបែកធ្លាយហើយក៏ឆ្លើយថា អញយំនោះ ព្រោះអាឯងរិះគិតជាក្បត់នឹងដណ្ដើមយករាជសម្បត្តិ, សុម៉ាស៊ូក៏បង្គាប់ឲ្យទាហានព្រួតចាប់ខ្លួនអ្នកទាំង៣នាក់ វ៉ៃហៅហឿនតែម្ដងទេ ក៏តាំងយ៉ុងផែចូលទៅដាល់គប់

សុម៉ាស៊ូ នោះទាហានក៏ស្ទុះឈូទៅព្រួតចាប់ខ្លួនបាន, សុម៉ាស៊ូក៏ឲ្យស្រាវជ្រាវរើកខ្លួន ក៏ឃើញអាវឡាយព្រះហស្ដដែលស្ដេចលិខិតត្រាស់បង្គាប់លាក់ក្នុងស្រទាប់អាវទៀអ៊ុប ហើយយកមកមើលឃើញសេចក្ដីថា សុម៉ាស៊ូនឹងស៊ូគ្រប់គ្រួពួកវារះគិតជាក្បត់នឹងដណ្ដើមយករាជសម្បត្តិ, បើមុខមន្ត្រីណាមានចិត្តស្វាមីភក្ដិដល់យើង ចូរស្រួតរិះគិតគ្នាជាប្រញាប់ ដើម្បីនឹងកំចាត់សត្រូវផែនដីនេះឲ្យបាន, យើងនឹងឲ្យលឿនទីយសស័ក្តិ នឹងបំណាច់រង្វាន់ឲ្យជួនដល់ចិត្ត, សុម៉ាស៊ូឃើញដូច្នោះក៏ខឹងខ្លាំងណាស់ថា យើពួកអស់នេះ វាគិតធ្វើអន្តរាយអញទេតើ ទោសវាជាទម្ងន់ណាស់ នឹងលើកលែងក៏មិនបាន ទើបបង្គាប់ឲ្យយកនាម៉ុទាំង៣នាក់ទៅ ប្រហារជីវិតកណ្ដាលផ្លាផ្សារ អស់ទាំងគោត្រ, ទាំង៣នាក់នោះក៏ស្រែកជេរ សុម៉ាស៊ូដោយពាក្យទ្រគោះតាមអំពើក្ដៅ ពួកទាហានក៏យកកាំបិតចូលថ្គាយមាត់បំបាក់ធ្មេញទាំង៣នាក់អស់, អ្នកទាំង៣នាក់នោះក៏មិនឈប់ស្ងៀម រឹតតែគំរាមស្រែកជេរទាល់ស្លាប់ សុ-ម៉ាស៊ូក៏ចូលទៅក្នុងវាំង ។

ខណៈនោះ ព្រះចៅហោហានកំពុងប្រឹក្សាការជាមួយនឹងនាងទៀវ. ហានហៅ ក៏ទូលថា ក្នុងវាំងនេះមានមនុស្សច្រើនណាស់ បើសេចក្ដីនេះបែកផ្សាយទៅខ្ញុំម្ចាស់ក៏នឹងក្ស័យស្លាប់អសារ និយាយមិនទាន់ផុតមាត់ស្រាប់តែក្រឡេកទៅឃើញសុម៉ាស៊ូកាន់គ្រប់ដើរចូលទៅ លុះចូលទៅ

ដល់ហើយ សុម៉ាស៊ូនិយាយថា បិតាទូលព្រះបង្គំជាខ្ញុំបានលើកដម្កើងព្រះអង្គឲ្យបានសោយរាជសម្បត្តិ ទោះបីជាវង្សមហាឧបរាជពីបូរាណដែលមានអំណាចណាស់ ក៏យកមកផ្ទឹមប៉ះនឹងបិតាទូលព្រះបង្គំជាខ្ញុំពុំបាន ទូលព្រះបង្គំជាខ្ញុំបានទំនុកបំរុងព្រះអង្គជាប់មក ទោះបីអ៊ុំអ៊ុនពីដើមដែលជាមហាឧបរាជនោះ ក៏មិនមានធ្វើឲ្យដូចទូលព្រះបង្គំជាខ្ញុំទេ គុណដែលមានមកពីដើមទាំងប៉ុន្មានក៏សូន្យទៅអស់ហើយ ព្រោះព្រះអង្គមកស្ដាប់ពាក្យញុះញង់ ហើយទ្រង់ត្រឡប់គិតប្រទូសរ៉ាយទូលព្រះបង្គំជាខ្ញុំវិញ ព្រះចៅហោហាងឆ្លើយតបថា យើងមិនមែនគិតធ្វើដូច្នោះទេ ។

សុម៉ាស៊ូក៏ហូតយកការទ្ធងព្រះអង្គ.បាលបំពោះមុខព្រះភ័ក្ត្រ លើក-ដៃបង្អួលហើយថា នេះរបស់នរណា ៗ ធ្វើនេះ ព្រះចៅហោហាងភ្ញាក់ស្លុតព្រះទ័យមិនមានព្រះស្មារតីសោះ មានព្រះអង្គញ័ររំប្រប់ តែប្រឹងទប់ឆ្លើយថា យើងធ្វើការដូច្នេះ ពីព្រោះមានគេបង្គាប់ឲ្យធ្វើ ខ្លួនយើងមិនបានគិតធ្វើលោកទេ, សុម៉ាស៊ូថាធ្វើខ្លួនឯងត្រឡប់ឆ្លើយដាក់គេដៃទៃវិញ ទោសព្រះអង្គខុសធ្ងន់យ៉ាងនេះហើយតើនឹងរិះគិតដូចម្ដេចទៅវិញ, ព្រះ-ចៅហោហាងស្លុតព្រះទ័យណាស់ ក៏ក្រោកលុតជង្គង់ជាក់ព្រះអង្គចុះហើយថា ទោសខ្ញុំខុសណាស់ហើយ សុំឲ្យលោកអត់ទោសខ្ញុំចុះ, សុម៉ាស៊ូថាព្រះអង្គជាបង្គោផែនដី, ទូលព្រះបង្គំមិនធ្វើអន្តរាយដល់ព្រះអង្គទេអញ្ជើញស្ដេចឡើងគង់លើព្រះទីនាំងតាមសមគួរចុះ ថាហើយក៏បង្អួលមុខ

នាងទៀវហាងហៅនឹងគ្រប៉ីថា នាងនេះជាបុត្រទៀវអ៊ុចត្រូវតែប្រហារជីវិតឲ្យស្លាប់តាមបិតា ព្រះចៅចោហាងក៏ទ្រង់ព្រះករឲ្យងអង្វរសុំជីវិតនាងទៀវហាងហៅ សុម៉ាស៊ូក៏មិនស្តាប់ បង្គាប់ទាហានឲ្យចាប់ដឹកកន្ទ្រាក់យកខ្លួនទៅ ពួកទាហាននាំនាងទៅដល់មាត់ទ្វារទិសខាងកើត ក៏ឲ្យនាងយកព្រែរុំក ទាហានក៏ចាប់ទាញព្រែម្ខាងម្នាក់រឹតទាល់តែបែកបំពង់កស្លាប់ ។

លុះពេលព្រឹកឡើង សុម៉ាស៊ូឲ្យហៅអស់នាម៉ឺនមន្ត្រីធំតូចទាំងអស់មកប្រជុំព្រមគ្នានៅទីសាលាជំនុំរាជការ ទើបប្រឹក្សាគ្នាថា ព្រះចៅចោហាងមិនយកព្រះទ័យទុកដាក់ក្នុងរាជកិច្ចទាំងពួងក្នុងព្រះនគរ ប្រព្រឹត្តតែការលេងសប្បាយដោយមនុស្សអន្ធពាល ហើយនឹងសតិបញ្ញាក៏រកគ្មាន រមែងជឿស្តាប់តាមពាក្យមនុស្សអាក្រក់រាំញុះញង់នឹងឲ្យស្រុកទេស ជាចលាចល ឥឡូវខ្ញុំគិតយល់ថានឹងឲ្យស្តេចនេះនៅក្នុងរាជសម្បត្តិពុំបាន ត្រូវតែលើកយកចេញឲ្យផុត ហើយយើងនឹងរើសរកព្រះរាជបុត្រនគោឯណាដែលមានសតិបញ្ញាឆ្លៀវឆ្លាត គួរនឹងទទួលរាជសម្បត្តិបាន ។ ឧបាតត្រួតត្រាផែនដីតទៅ តើអស់អ្នកទាំងឡាយនឹងយល់ឃើញប្រការម្តេច ។

( នៅមានត )

# សាស្ត្រាថ្ងៃសុក្រ

# ឬ

# ល្បើក ថ្ងៃសុក្រ

**ពាក្យនាំ :**

គឺជាសាស្ត្រាថ្ងៃសុក្រនេះហើយ ដែលសំបូរដោយពាក្យកាព្យជាសម្ដោកហោទជាអាថ៌ប្រស្នា អ្នកស្រុកធ្លាប់តែនាំគ្នាចាំមាត់ ហើយលើកយកមកប្រដូចប្រដៅជាទំនាយស្រុកទេស ដូចឃ្លាថា :

" កំពីសឡើងពងលើកំពូលភ្នំ កុកសសម្ងំកូនគុម្ពត្រែង ... ក្របីណាក់ខ្លួនសម្រួចស្នែង,... តើស្ត្រីខានកុកប្ដីខានខ្លា អ្នកមានប្រាជ្ញាទើបថាត្រូវ,... ។ល។

នៅពេលដែលស្រុកទេសយើងកើតវឹកវរដោយសង្គ្រាម មានអ្នកចាំមាត់ខ្លះមកជជីកសួរយើងរកមើលសាស្ត្រានេះឡើងវិញ ព្រោះធ្លាប់តែឮគេថាតៗគ្នា ។ ដូច្នេះ យើងសូមចម្លងអត្ថបទនេះទាំងស្រុងមកចុះផ្សាយ ដើម្បីឆ្លើយតបទីងសេចក្ដីត្រូវការនេះ ។ បើទោះបីជាប្រស្នាទាំងនេះត្រូវឬមិនត្រូវក្ដី គ្រាន់តែបានជាគតិឲ្យមនុស្សរេះគិតពិចារណាទៅដែរ ។ ម្យ៉ាងទៀត បើគិតខាងផ្នែកអក្សរសិល្បវិញ អត្ថបទនេះជាពាក្យកាព្យខាងបែបរះគន់ ប្រកបដោយពាក្យដួន ពាក្យណ្ដំ មានន័យទូលាយណាស់ ។ អ្នកនិពន្ធម្ចាស់អត្ថបទ ជាមនុស្សព្រេងនៃ ខាងរាប់ពាក្យប្រាស់ សិទ្ធនូវកាព្យ ពេចន៍គួរសរសើរ សម្ពន្ធពាក្យក៏កេះណែនណាស់ក្នុងតែម ។

# ប្រវត្តិសាស្ត្រថ្ងៃសុក្រ

(ស្រង់ពីច្បាប់ដើម)

តាមដែលខ្ញុំបានឮគេនិយាយតៗមកថា ទំនាយនេះ មានអ្នកស្រុកពោធិចិនតុងម្នាក់ ដើរទៅវាលស្រែស្រុកនេះ ស្រាប់តែបានឃើញរបស់ទាំងនេះ គឺ ច័ត្រ ប្រត់ និង យាម ១ អ្នកនោះបានរើយករបស់ទាំងនេះ ចេញពីយ.មមក ឃើញមាន អកកំបោរ ប្រណាក ស្វាម្បត្បាល់បុក ហើយឃើញទាំងទំនាយប្រស្នានេះផង នៅជាមួយគ្នា យកមកមើល ឃើញជាទំនាយដូច្នេះ ក៏នឹករអែងខ្លួនទឹងកដការ ហើយយកវត្ថុទាំងនេះ ទៅជូនសាលាស្រុក ជួនជាពេលនោះលោកសក្តិ ៤ អ៊ុំទៅលេងនឹងចៅហ្វាយស្រុក ។ និយាយរឿងរ៉ាវជម្រាបលោកហើយយកទំនាយនោះ មកជូនមើលផងលោកស័ក្តិ ៤ បានមើលហើយហូតទំនាយនេះទុក ឲ្យបញ្ជូនតែវត្ថុឯទៀត ទៅក្រសួងលោក.យកទំនាយនេះជាប់មកទឹងខ្លួនលោក អ្នកខ្លះក៏សុំចម្លងពីលោក និងចម្លងតៗ គ្នាមករហូតដល់មានស្ទើរសព្វតែខេត្ត ។ ដោយហេតុតែទំនាយប្រស្នានេះ ពុំមានឈ្មោះអ្នកទាយដាក់នៅជាប់ផងទើបពុំបានឲ្យឈ្មោះដូចពុទ្ធទំនាយ , ព្រះកេងទំនាយ , ឥន្ទទំនាយ , ... គេនាំគ្នាហៅថា « ទំនាយឥតឈ្មោះ » ។

ឯរឿងទំនាយនេះ បើថា ដោយខ្ញុំជាអ្នកសរសេរ (គ្មានឈ្មោះ) ស្មានប្រហែលជាកើតនៅឆ្នាំច ... ស័ក ព.ស. ២៤៥២ ។

លុះមកដល់ឆ្នាំច អដ្ឋស័ក ព.ស ២៤៨៩ លោកអ្នកឧកញ៉ាសុន្ទរពាជកិច្ច ខឹម ប៉ែន ជាអ្នកកាន់កាប់ការ ក្រសួងព្រះបរមរាជវាំង បានឲ្យបម្លងទុកឲ្យឈ្មោះថា សាស្ត្រាថ្ងៃសុក្រ" ព្រោះសាស្ត្រានេះ ចេញពាក្យថា ថ្ងៃសុក្រពេញបូណ៌មី ជាខាងដើម ។

(មិនបានឃើញឈ្មោះអ្នកកត់ប្រវត្តិនេះទេ ។ យើងបម្លង
ចេញពីក្បាប់សរសេរដៃ តម្កល់ នៅក្រុមជំនុំទំនៀម
ទម្លាប់លេខ ៥៤-០៤២ ជាក្បាប់បម្លងពីលោក កែម
(ប៉ាងកែម) ធ្វើការនៅមន្ទីរព្រះរាជពង្សាវតារក្នុងវាំង
ថ្ងៃ ២១-៦-៧២

# សារស្ត្រាថ្ងៃសុក្រ

ពាក្យ ៧

១ ថ្ងៃសុក្រពេញបូណ៌មីខែកត្ដិក    នៅក្នុងកំណត់ព្រះវស្សា
ឆ្នាំជូវត្រីស័កនក្សត្រា    សាសនាពីរពាន់ជួនរយហ្វាយ ៗ
ទឹងថ្ងៃនពីរដ្ឋភជបូរ    ក្នុងផែនផែនដីនគរអាយ
កកើតឥស្សារ្យផងទាំងឡាយ    ក្លែងក្លាយទាំងគ្រប់សព្វសេចក្ដី ៗ
តាំងតែអ្នកឆ្ងាយគេចូលមក    នៅក្នុងគោកធ្លកភជបូរ
កកើតជាហេតុកេទផែនដី    ទាំងមនុស្សប្រុសស្រីប្រែចិត្ដា ៗ
បែរបែកបោះបង់បែបបុរាណ    គ្រប់ប្រាណពុំមានតាមគម្រា
សឹងត្រេកដោយទ្រព្យគ្រប់រូបា    ពុំមានអ្នកណាតាមសណ្ដាប់ ៗ
ទាំងនេះហេតុតែកេទសេមា    ព្រះពុទ្ធសាសនាប្រែត្រឡប់
បណ្ដាលក្នុងចិត្តងឹតអ័ព្ទ    យកខុសជាគាប់ត្រឡប់ប្រែ ៗ
អ្នកប្រាជ្ញប្រាប់ទៅខ្ញាមិនតាម    មិនដោយទំនៀមទំនងខ្មែរ
ចរចេសចិត្តឯងអាងពូកែ    ត្បិតតែមានគេមកនៅថ្មី ៗ
ខ្លះអាងខ្លួនឯងមានមាសប្រាក់    មានបុណ្យមានសក្ដិជាមន្ត្រី
ហើយកើតធំចិត្តធំសម្ដី    ឥតបីឥតបើទឹងគណនា ៗ
តម្កើងខ្លួនឯងឲ្យគេខ្លាច    ពាក្យគោងប៉ោងកាចទាំងឫកពា
មិនកោតមិនខ្លាចចាស់ព្រឹទ្ធា    អាងមានទ្រព្យជាទីពឹង ៗ

ខ្ទះអាងខ្លួនឯងមានចំណេះ ប្រាជ្ញាវៃចេះជជែករឹង
ជជែកយកឈ្នះឈ្លោះទទឹង មិនមានរំពឹងគិតខុសត្រូវ ។
មានទ្រព្យគាប់ចិត្តស្អិតធ្វើបុណ្យ ក្អាំងក្អេនក្អេចគុណម៉ែគុណឪ
គិតតែធ្វើស្រែនិងលក់ស្រូវ ឯផ្លូវទៅសួគ៌មិននឹកសោះ ។
នេះហើយជាកម្មអកុសល មកផ្តល់ឲ្យគ្មានបុណ្យឡើងសោះ
បើខាងស៊ីផឹកនឹកទាំងអស់ នោះទើបស្រួលស្រស់គិតកល់ថ្ងៃ ។
ខ្ទះមានបុណ្យសក្តិមើលងាយសង្ឃ ព្រោះសាងជាអង្គឯងច្រើនក្រៃ
សំពះព្រះសង្ឃក្រែងថោកដៃ ឆ្ងើនឆ្ងៃវិស័យដូចក្រៅសាសន៍ ។
មានបុណ្យប៉ុនហ្នឹងប្រឹងក្រអឺត ចំកាងស្ងួយស្ញើតទើសអាកាស
បង់ជំនិតខ្លួនគ្មានគិតខ្មាស ពោលសង្ឃបង់សាសន៍ថ្ងៃឧត្តម ។
ដួនកាលត្រូវការដើរចូលវត្ត ពាក់មួកបាំងច័ត្រធ្វើរម្យទម
ចូលក្នុងអាពមគ្មានអារម្មណ៍ អាងខ្លួនជាធំប៉ុណ្ណោះឯង ។
អ្នកអើយនេះហើយហៅលោកោ ទោសោមោហោនាំវង្វេង
បង្វែរនាំចិត្តឥតគិតក្រែង នេះហៅវង្វេងក្នុងសាសនា ។
មនុស្សលោកឥឡូវក្រៅក្រមក្រិត្យ កើតមានទុស្តចិត្តបីប្រការ
ចិត្តមួយមិនខ្លាចគ្រូអាចារ្យ ចិត្តមួយសោតណាមិនខ្លាចចាស់ ។
ចិត្តមួយមិនខ្លាចម៉ែឪឯង ឥតកោតឥតក្រែងវេងក្រឡាស់
ក្រឡាប់ក្រឡប់គ្រប់សព្វសាសន៍ កល់រូបកល់ព្រលឹងវង្វេង ។

វិលវល់ក្នុងចិត្តគិតវៃរ　　ព្រោះគេខនគកើតហេតុព្រេង
ទើបមានអកុសលដូច្នេះឯង　　ក្លាយកូនវង្វេងវរចិន្តា ។
នេះហៅប្រែពក្យប្រែសកពជ　　សិស្សសោតមិនខ្លាចគ្រូអាចារ្យ
ឯកូនមិនខ្លាចអ្នកមេបា　　រីឯកិរិយាមិនខ្លាចប្ដី ។
កន្ទេបមិនបន់ខ្លាចពស់វែក　　សត្វក្អែកបន់ដល់ទីងដំរី
ដើមចេកប្រុងដល់ទីងក្របី　　រីត្រីបន់ដល់ទីងបព្វតា ។
ហេតុគេចទាំងនេះកើតមានមក　　នាំឲ្យជនយកជាកិរិយា
សឹងបោលសណ្ដាប់ច្បាប់មាត្រា　　ទើបលោកឧបមាដូច្នេះនៃ ។
គោស្រុកទៅចូលឯហ្វូងស្វា　　ឯឆ្មាបង់ផ្ទះទៅពឹងព្រៃ
មច្ឆាបោលបឹងទៅពឹងជ្រៃ　　ក្របីបោលត្រាញ់ស្រឡាញ់ត្រែង ។
យកជាពំនាក់នៃអាត្មា　　ក្ដីងនេះកាលណាទើបស្ងះស្វែង
ក្ដីងឆាបពេលពលដល់ខ្លួនឯង　　ទើបបោលបឹងត្រែងមករកត្រាញ់ ។
ពជហង្សហើយបន់បោលសំបុក　　ហើយទៅយកកុកជាសម្លាញ់
ដល់មានព្រានព្រៃមកបរបាញ់　　កុកសស្រោញ់ហើយបោលហង្ស ។
ម្ល៉ោះហើយសមទីងអសារសូន្យ　　អន្តរាយខ្លួនខ្លួនវិនាសបង់
ព្រោះព្រើលគំនិតចិត្តគិតបង់　　សប្បាយទើបបង់ពីសម្បុក ។
លង់លុះមានភ័យដូច្នេះឯង　　ទើបបានហើយស្វែងរកទីសុខ
គេទៅរកមកបានតែទុក្ខ　　ព្រោះបង់សំបុកបានអាត្មា ។

ហៃនែអស់ជនទាំងឡាយអើយ  អ្នកអើយនេះហើយហៅទុចមា
ទុបមេយ្យឲ្យដឹងហេតុគ្រប់គ្នា  ការរងវេទនាជាប្រាកដ ។
ព្រោះជនមានចិត្តជាវិបល្លាស  សាងអកុសលក្រាស់ដោយសន្ធត
លោកទីនវង្វេងជាបែបបទ  កំណត់ឥតក្រែងបានអាវិចី ។
គ្មានទីករលឹកទៅបាននាយ  គិតតែសប្បាយនៅលោកិយ
ចង់បានចង់មានហួសពេកខ្វី  មានអ្វីអ្នកហ្នឹងឥតគណនា ។
មានគោអ្នកគោពូកែគាប់  មានទ្រព្យអ្នកទ្រព្យប្រសើរជា
បេះគូរអ្នកគូរឥតគណនា  បេះបៀអ្នកបៀឥតបើស្តី ៕
មានកូនអ្នកកូនដោយដំណើរ  មានក្តីអ្នកក្តីដោយមេត្រី
មានសេះអ្នកសេះឲ្យបានល្បី  មានអ្វីអ្នកហ្នឹងឲ្យបានខ្ពស់ ។
អ្នកណាដូច្នោះនោះលោកថា  រីងស៊ិនមនុស្សព្រហ្មហាគោតហួស
សឹងលុះអំណាចខ្ញាំជ្រុលជ្រួស  ពីព្រោះមិនត្រូវគន្លងឡើយ ។
ហៃអ្នកទាំងឡាយចូរស្អាងចិត្ត  ស្អាងកាយប្រព្រឹត្តទៅអ្នកអើយ
ត្បិតព្រះសាសនាជិតដល់ហើយ  កុំធ្វើគោះតើយគួរឲ្យប្រឹង ។
ធ្វើបុណ្យធ្វើទានកុំរៀនខ្ចៅ  កុំកាចឃោឃៅឆោតឆាប់ខឹង
ធ្វើចិត្តឲ្យធ្ងន់ទន់ទើបទឹង  បានជាពំនឹងទៅបាននាយ ។
សេចក្តីនេះក្រែងអស់អ្នកផង  ពុំដឹងទំនងការសម្រាយ
នូវអស់កិច្ចការផងទាំងឡាយ  នៃនគរកាយកើតកូនខ្ចី ។

កូនមួយជាប្អូនមួយជាបង | ដើរត្រេចត្រសងសាងបារមី
ឯអស់មហាជនទាំងប្រុសស្រី | បានដឹងសេចក្ដីនៃសុខ ៗ
ផ្ទះលោនឯបូពិព្ធកណ្ដុក | អ្នកតាចាស់ស្រុកឱបផែយំ
កំពឹសទៀនពនកំពូលភ្នំ | ក្អែកសសម្ងំកងគុម្ពព្រៃង ៗ
ពោធិព្រឹក្សាបគល់ពុំចាក់ឫស | ពស់វែកត្រាំពិសផ្ដាំកន្ទង
ក្របីលាក់ខ្លួនសម្រួចស្នែង | ពពាហ៊នព្រហើរស្វែងកាច់សំបុក ៗ
ពពែបក្រោបពងក្រោមគន្ធា | ក្អែកពាំផ្លែល្ហាពយត្រប់ស្រុក
អ្នកផងឃើញហើយប្រឹងរើសទុក | បំណោរទៅមុខទើបដឹងខ្លួន ៗ
ស្វាក្រេះក្រញឹងប្រឹងហាត់គុន | លុះឃើញសេះលុនទើបតេពួន
កុកសកវែងឯងអួតខ្លួន | ថាដឹងចំនួនត្រីក្នុងទឹក ៗ
កុកសាប់កេស៊ីកណ្ដាលត្រាញ់ | សស្រាក់សស្រាញ់ពុំមានភ្លឹក
សីហនាទគគាគជាពន្លឹក | ចាប់ត្រីពល់ព្រឹកគ្មានមេត្តា ៗ
ខ្លាញីរកស៊ីកងសមសាន្ត | លាក់ប្រាណលំអានចាំសាសនា
លុះដល់ផ្ទះលានប្អូនទិសា | ទើបខ្លាយាត្រាពីកងព្រៃ ៗ
ឲ្យអស់មហាជនស្រាយចំណោទ | ដែលខ្ញុំចែងទោទអាថ៌សេចក្ដី
បើអ្នកឯណាប្រាជ្ញាវៃ | ទើបដឹងសេចក្ដីនៃបញ្ហា ៗ
រីឯគោស្រុកនិងកុកស | សព្វថ្ងៃឧបអស្រឡាញ់គ្នា
ធ្វើហាក់ដូចមិត្តចិត្តស្នេហា | តែថាគំនិតគិតទីទៃ ៗ

ឯកុកនិងខ្លានៅដោយខ្លួន មិនទាន់ជួបជួនគ្នាឡើយនៃ
តែជួបកាលណាអស្ចារ្យក្រៃ សត្វសាសន៍ទីទៃភ័យមិនខាន ៗ
ត្បិតអ្នកតាំងពីសឹងកាចក្តាត់ អួតអាងអាវុធតែកល់ប្រាណ
កានឫទ្ធិចេស្តាពន់ប្រមាណ សឹងកាចហាវហានឥតឧបមា ៗ
ឥឡូវខ្ញុំសួរអ្នកទាំងឡាយ ស័ត្រូចិត្តស័ត្រូកាយទៅខាងណា
ជាស័ត្រូខាងកុកឬខាងខ្លា អ្នកមានប្រាជ្ញាទើបថាត្រូវ ៗ
ឯមនុស្សវែងស៊ុំងអាក់សែ ឃើញតែគេខ្ពស់ដូច្នោះគួរ
ម៉្លោះហើយផ្ដេកខ្លួនចូលចិត្តទៅ អែបអបនិត្យនៅផ្ញើអាត្មា ៗ
នេះហើយសង្គ្រាមសកកជថ្មី អ្នកល្បីនិងល្បីល្បងចេស្តា
ឯត្រង់ឈ្មោះបាញ់មិនហ៊ានថា តែទឹងឧបមាដូច្នោះនៃ ៗ
កង្កែបខ្លួនតូចតាបទេតើ ដូចម្តេចឲ្យស្មើទឹងដំរី
កង្កែបនៅតែដោយរូងដី ដូចម្តេចកជសីហ៍មានគុហា ៗ
អំពិលអំពែកតូចមួយមិញ ម្តេចឡើយគិតផ្កាញ់ព្រះចន្ទ្រា
សត្វតាបខ្លួនតូចឥតគណនា ម្តេចឡើយពុះពារដល់ទឹងចាន់ ៗ
រីសោតកុកសាប់អាប់វង្វា ម្តេចមកប្រាជ្ញាថាហង្សសោភ័ណ
សំណស្វលាយកាឡៃស្ពាន់ ដូចម្តេចសុវណ្ណមាសចរណៃ ៗ
ដូច្នោះអ្នកអើយចូរអ្នកគិត រំពឹងក្នុងចិត្តកុំសង្ស័យ
ជម្ពូភាឯខ្លាញុចនៅក្នុងព្រៃ កន្ទុយវែងវៃបំពេនទុក ៗ

ឥឡូវខ្ញាដឹងដំណឹងជាក់ ជាគោមកស្ត្រតាក់ទឹងកុក
វិស័យឯខ្ញាទន្សាយស្រុក ដឹងហើយកើតទុក្ខឥតឧបមា ៗ
ផ្គរលាន់ឯជើងភ្លើងឆេះទឹក ឆេះដើមពោធិព្រឹក្សព្រៃបព្វតា
លុះដល់សៀលព្រះសុរិយា ទើបខ្ញាយាត្រាលត់ភ្លើងព្រៃ ៗ
ហៃអស់មហាជនទាំងឡាយអើយ អ្នកអើយដឹងហើយគួររំពៃ
រំពឹងរកបាទខ្លួនទីទៃ រវៀសរវៃឲ្យធាប់ក៏ ៗ
សេចក្តីនេះមានមែនពិតហើយ អ្នកអើយកុំតុញពាល់ប្រាជ្ញា
រឿងនេះអ្នកប្រាជ្ញលោកឧបមា ឲ្យអ្នកពាល់គ្នាគិតឲ្យយល់ ៗ
សាសនាពីរពាន់បួនរយឆ្ងាយ តាមដោយទំនាយព្រះទសពល
អ្នកបុណ្យបាត់ផ្ទៃក្នុងមណ្ឌល កើតកោលាហលខ្វល់ដំពាក់ ៗ
កើតកាប់លួចប្លន់ក្នុងនគរ សង្គ្រាមរឹករគ្មានទីកាក់
គ្មានទីអាស្រ័យជាពំនាក់ ពំនឹងពឹងពាក់អាត្មាឡើយ ៗ
អ្នកអើយត្រូវហើយគួរភាវនា ធ្វើបុណ្យគ្រប់គ្នាកុំកន្តើយ
សីលទានភាវនាធ្វើឲ្យហើយ ទើបអ្នកបានស្បើយពីទុក្ខភ័យ ៗ
ការនេះអ្នកប្រាជ្ញគាប់ប្រាយប្រាប់ ឲ្យអ្នកផងស្តាប់ហើយរវៃ
រវៀសរវាងមគ្គផលប្រពៃ ដើម្បីឲ្យបានព្រះសិអារ្យ ៗ
ហៃអស់មហាជនផងទាំងឡាយ កុំភ្លើតភ្លើនកាយភ្លេចមាតា
ភ្លេចភ្លាំងគុណគ្រូគុណអាចារ្យ ទាំងគុណបិតានិងគុណបង ៗ

តែក្មួយសឹងភ្ញាក់ក្តីប្រាថ្នា
ក្មេងនេះហៅមហាខុសពេកហោង
អ្នកណាធ្វើតាមដោយគន្លង
នេះហោងនឹងបានដូចប្រាថ្នា ។
ឥឡូវនេះនឹងបង្អង់ស្មេះ
បញ្ឈប់ប៉ុណ្ណោះពុំបរោ
សង្ខេបសេចក្តីនៃប្រាស្នា
សូរេចបការម៉េះឯងហោង ។

## សុភាសិត :

ទាហានច្រើនត្បិតសឹក
ធ្វើស្រែត្បិតទឹក
ត្រីកពលព្រោះបាយ
សិស្សប្រាជ្ញត្បិតគ្រូ
ជេរពោលដំវាយ
ពលច្រើនត្បិតនាយ
ហ្វឹកហ្វឺនខះខំ ។

ច្បាប់រាជនេតិ

# លោក ហង់រី គីស៊ីង្គ័រ ជាអ្នកណា ?

អំណាចរបស់ខ្ញុំ ស្ថិតនៅត្រង់ដែលលោកប្រធានាធិបតី "រីស្ហា និចសុន ទុកចិត្ត"

នេះជាសំដីរបស់លោក ហង់រី គីស៊ីង្គ័រ ទីប្រឹក្សាកិច្ចការបរទេស របស់លោក "រីស្ហា និចសុន"

នៅខែធ្នូកន្លងទៅនោះ ក្រោយអំពីកិច្ចចរចាយ៉ាងយូរពីរលើក នៅសណ្ឋាគារ ពីយែរ នាក្រុង "ញូវយ៉ក" មក លោក រីស្ហា និចសុន ដែលទើបនឹងជាប់ឆ្នោតជាប្រធានាធិបតីនៃសហរដ្ឋអាមេរិក (១) បានស្នើសុំលោក ហង់រី គីស៊ីង្គ័រ ដែលជាបញ្ញវន្តមួយរូប, ជាតិអាលឺម៉ង់, អាយុ ៤៦ ឆ្នាំ ដើម្បីធ្វើជាឧបការីក្នុងផ្នែកសន្តិសុខជាតិ ។ ការស្នើនេះធ្វើឲ្យមតិទូទៅភ្ញាក់ផ្អើលជាច្រើន ជាពិសេសគឺរូបលោក "ហង់រី គីស៊ីង្គ័រ" ខ្លួនឯងហ្នឹងតែម្តង ទើបលោកសុំពន្យារពេលគិតគូរមើលសិន ។

បន្ទាប់មក លោកបាននិយាយថា:

" ក្នុងការទទួលតំណែងនេះ ខ្ញុំយល់ថា ដរាបណាខ្ញុំមិនទាន់ស្គាល់ចិត្តថ្លើមលោកប្រធានាធិបតីជាក់លាក់ទេ ខ្ញុំនឹងមិនអាចទទួលតំណែងនេះបានឡើយ ព្រោះថា កន្លែងដែលជាទីទុកចិត្តនេះ សន្តានចិត្តជួបគ្នានៃយើងទាំងពីរនាក់ ជាកត្តាមួយធំជាបណ្តាច់ " ។

---

១ ជាប់ឆ្នោតនៅខែធ្នូ ឆ្នាំ ១៩៦៨ ។

ក្រោយមក លោកក៏បានព្រមទទួលមុខតំណែងនោះ ។ ឥឡូវនេះ លោកទៅជាទីប្រឹក្សាមួយរូប ដែលលោកប្រធានាធិបតីយកចិត្តទុកដាក់ស្តាប់ជានិច្ច ក្នុងកិច្ចការនយោបាយក្រៅប្រទេស ។ ដោយសារជឿពាក្យលោកនេះហើយ បានជាក្នុងវិស័យបរមាណូ លោក និចសុន សុខចិត្តបោះបង់នយោបាយប្រដែងយកឧត្តមភាព ដើម្បីទៅចាប់យកតែគោលការណ៍បម្រុងសញ្ញុង ឲ្យតែគ្រប់គ្រាន់ប៉ុណ្ណោះ ។ លោក គីស៊ីង្គ័រនេះ ជាបុគ្គលសំខាន់មួយរូប ដែលបានរៀបចំដំណើរប្រកបទៅដោយអត្ថប្រយោជន៍ របស់លោកប្រធានាធិបតីទៅកាន់ទ្វីបអឺរ៉ុប កាលពី ខែកុម្ភៈឆ្នាំ ១៩៦៩ និងទៅកាន់ទ្វីបអាស៊ី កាលពីខែ កក្កដា ។ លោកមានមុខងារយ៉ាងសំខាន់ ក្នុងការប្រឹងប្រែងរបស់រដ្ឋាភិបាលអាមេរិកាំង ដើម្បីដោះស្រាយបញ្ហាជម្លោះនៅវៀតណាម តាមការចរចាវិញ ។ ការចាត់ចែងរបស់លោក ក្នុងការកាត់តែងសេចក្តីសម្រេចចិត្តនៃសេតវិមាន ក្នុងវិធានការការពារ មីស៊ីល និងក្នុងរឿងយន្តហោះអាមេរិកាំងមួយគ្រឿង ដែលត្រូវពួកកូរេខាងជើងបាញ់ធ្លាក់ ។

លោក គីស៊ីង្គ័រ ដែលមានអំណាចបានប៉ុណ្ណោះ គឺដោយសារតែលោកប្រធានាធិបតីស្រឡាញ់រាប់អាន ហើយចេះឲ្យតម្លៃលោក ។ លោក ម.រ. ហាលដឹម៉ាន ដែលជានាយកបុគ្គលិកនៃសេតវិមាននោះ ពោលថា:

លោក [illegible] ចំណាយពេលមិនប៉ុន្មានសោះ ដើម្បីធ្វើខ្លួន

លោកទិនទៅហ្វាយលោក ឲ្យមានការទាក់ទងយ៉ាងស្និទ្ធស្នាលនឹងគ្នាជាទីបំផុត ៗ វេជ្ជទាំងពីររូបនេះ គិតគូរអ្វី ៗ រហ័ស ហើយថែមទាំងមានរបៀបបញ្ចេញមកស្រេចតែម្តង ៗ លោកប្រធានាធិបតីច្រើនតែផ្ដោះសេចក្ដីផ្ដើម ឈានទៅចាប់យកគោលដៅតែម្តង ប៉ុន្តែមុននឹងធ្វើសេចក្តីសម្រេចរឿងអ្វីមួយ ៗ លោកបើកសំនួរហួរ ដូចគេបើកក្អើងអនុញ្ញាតបកបរ ៗ រីឯលោកទីប្រឹក្សាវិញ ត្រៀមខ្លួនចាំតែឆ្លើយតបគ្រប់វិស័យឲ្យប៉ះ ៗ ត្រង់ ៗ ទៅ មិនបាច់លាក់លៀមអ្វីទេ ៗ មនុស្សដែលចាំកិច្ចការវេជ្ជ ដើម្បីសម្រួលកិច្ចការហ្វាយដូចរូបលោកគីស៊ីង្គ័រនេះ កម្រមានណាស់ ៗ

ក្រោយមក ឧបការី ដែលដើមឡើយ មិនសូវជាពេញចិត្តប៉ុន្មាននឹងទទួលតំណែងធ្វើការជាមួយនឹងលោកប្រធានាធិបតី ក៏ទៅជាមានការគោរពលោកណាស់ទៅវិញ ៗ ប៉ុន្តែ កាលណានៅចំពោះមុខហ្វាយលោក ហាន់រី មិនរវល់នឹងធ្វើបុករណបរណិបពេកទេ ព្រោះលោកមិនចូលចិត្តធ្វើបុក ដូចសហការីនៃអ្នកកម្រិតខ្លះ ដែលបញ្ចេញបុកពាយស្របគ្រប់មាត់ដែលហ្វាយហានោះសោះ ៗ លោកតែងនិយាយអំពីហ្វាយលោកថា: លោកប្រធានាធិបតីជាអ្នកស្គាល់ការ ទើបនិយាយអ្វីចាប់ស្តាប់គ្នាបាន ៗ លោកជាអ្នកមានបញ្ញាវៃ ហើយមុតផល់ជម្រៅការ កិច្ចការអ្វីដែលគេដាក់ជូនលោក លោកមើលចាំរស់ ហើយនៅពេលខាន

វិបត្តិម្ដង ៗ ខ្ញុំសង្កេតឃើញលោកមានស្មារតីមិនតក់ស្លុតមែន ត្រង់នេះឯងហើយ ដែលខ្ញុំកោតលោកណាស់ ៗ

គេតែងតែជជែកវែកគ្នាចង់ដឹងថា ក្នុងចំណោមវរជនជាន់ខ្ពស់ទាំងបីរូប ដូចមានរាយនាមតទៅនេះ គឺ លោក គីស៊ីង្គើរ លោក វីល្យ៉ា រដ្ឋមន្ត្រីការបរទេស និងលោក មែលវិន ឡៃរដ៍ រដ្ឋមន្ត្រីក្រសួងការពារជាតិ តើវរជនរូបណាមួយ ដែលមានទម្ងន់លើសគេ ក្នុងសេចក្ដីសម្រេចចិត្តរបស់រដ្ឋាភិបាលលើផ្នែកនយោបាយក្រៅប្រទេស ៗ ក្នុងសំនួរនេះ វរជនប្រជាធិបតេយ្យនិយមមួយរូបបានតបថា :

នៅក្នុងនគរដែលមានបណ្ដាជនសុទ្ធតែខ្វាក់ អ្នកមានភ្នែកម្ខាង គេទុកជាស្ដេចហើយ កុំបាច់ឆ្ងល់ ព្រោះថា ក្នុងវិស័យនយោបាយអន្តរជាតិ លោក រដ្ឋមន្ត្រីទាំងពីររូបខាងលើនេះ ជាមនុស្សថ្មីសុទ្ធ ដូចេះមុខតំណែងទាំងពីរត្រូវធ្លាក់ទៅលើវរជនទី ៣ ដែលត្រូវបំពេញយ៉ាងពេញសមត្ថភាព ហើយដែលខ្ញុំពេញចិត្តជាទីបំផុត ព្រោះលោកជាបុគ្គលមួយរូប ដែលមានគ្រឹះមាំក្នុងកិច្ចការ ហើយជាអ្នកល្អិតល្អន់ណាស់ថែមទៀត ៗ

អំពីភ្នែកនិងត្រចៀក

ឧបការី ដែលទទួលបន្ទុកខាងសន្តិសុខជាតិនេះ ត្រូវទទួលភារៈដល់ទៅពីរមុខ គឺភារៈជាទីប្រឹក្សាមួយ និងភារៈជានាយកកិច្ចការរដ្ឋបាលមួយ ៗ ក្នុងភារៈកិច្ចទី ២ នេះ លោកត្រូវរៀបចំសំណុំរឿង សម្រាប់ប្រ-

ជុំប្រចាំសប្តាហ៍នៃក្រុមប្រឹក្សាការពារសន្តិសុខជាតិ  ជាមួយនឹងសហការី ក្នុងការិយាល័យរបស់លោក  ហើយនិងពិនិត្យឲ្យដឹងច្បាស់ថា តើសេចក្តីប្រមើលចាំនូវអស់លើរឿងអ្វីមួយពិសេសនោះគេដាក់ជូនមកលោកប្រធានាធិបតីហើយឬនៅ  ហើយលោកត្រូវតាមមើលទៅទៀត  ដើម្បីឲ្យដឹងថា តើកិច្ចការដែលលោកប្រធានាធិបតីបានសម្រេចរួចហើយនោះ គេមានបាត់វិធានការតាមបញ្ជា  ហើយត្រូវតាមបំណងរបស់លោកឬទេ ? ក្រុមរបស់លោកដែលមានសហការីតែម្នាក់ប៉ុណ្ណោះ ត្រូវទុកដូចជាភ្នែកនិង.ត្រចៀករបស់នាយករដ្ឋាភិបាល  នៅក្នុងផ្ទៃដ៏ធំធេងនៃក្រុមអភិបាលខាងកិច្ចការបរទេស  តួការនេះបម្រើលោកប្រធានាធិបតីដោយមិនសូវយកចិត្តលោកប៉ុន្មានសោះ ។

លោក គីស្សីង្គ័រ បានពោលថា :

ខ្ញុំមានភារៈខាងលៃលកដូចម្តេច  ដើម្បីឲ្យលោកប្រធានាធិបតីបាត់ការទៅហើយ  ឲ្យគេយកទៅប្រតិបត្តិឲ្យត្រូវតាមបំណងរបស់លោក ។ បើសិនជាខ្ញុំមិនទទួលភារៈនេះទេ  លោកប្រធានាធិបតីនឹងត្រូវណាយចិត្តចំពោះកិច្ចការការិយាល័យ  ដែលលោកត្រូវចុះហត្ថលេខានរស្មើរកប់ខ្ទង់បាត់ ។ ម្ល៉ោះហើយគឺត្រូវតែមានមនុស្សម្នាក់ចាំជូនពត៌មានលោក  កុំឲ្យល្ងៀង ក្នុងនាទីនេះហើយដែលខ្ញុំយល់ថា  អំណាចរបស់ខ្ញុំគឺនៅត្រង់ដែលលោកប្រធានាធិបតីទុកចិត្តលើរូបខ្ញុំ អស់ពីដួងចិត្តរបស់លោកមែន ៗ

រាល់ព្រឹកពេលចាប់ធ្វើការភ្លាម លោក ហាន់រី គីស្ស៊ីង្គ័រ ត្រូវប្រជុំបុគ្គលិកសំខាន់ៗ ក្នុងសេតវិមាននៅម៉ោង ៧,៤៥ នាទី ឬនៅម៉ោង ៧,៥៤ នាទី ព្រោះលោកមានទម្លាប់បង្អែបង្អង់ ដើម្បីកំប្លែងលេងអស់ ៩ នាទីជាធម្មតាទៅហើយ ។ ការប្រជុំនោះត្រូវធ្វើរហូតដល់ម៉ោង ៨,១៥ លើកពេលប្រជុំភ្លាម សមាជិកអង្គប្រជុំទាំងប៉ុន្មាន ត្រូវចូលទៅជួបសន្ទនាជាមួយនឹងលោកប្រធានាធិបតី ពីម៉ោង ៨ កន្លះដល់ម៉ោង ៩ ទៀតវៀរលែងតែលោក ហាន់រីគីស៊ីង្គ័រ ដែលត្រូវចូលបន្ទាប់អំពីអស់លោកទាំងនោះមក ហើយម្តងនេះ លោកមិនហ៊ានបង្អែបង្អង់ជាដាច់ខាត សូម្បីតែមួយនាទីក៏មិនដែលឡើយ ។ ការសន្ទនានោះ ជួនកាលអស់រយៈពេល ១០ នាទី ជួនកាលអស់ពេលមួយម៉ោង តាមករណីដែលត្រូវពិគ្រោះគ្នា ។ កាលណាលោកចេញមកវិញ លោកតែងតែនាំយកនូវកម្មវិធី រឺងសេចក្តីរាយការណ៍សម្ងាត់ប្រចាំថ្ងៃមកផង ព្រោះលោកប្រធានាធិបតី ច្រើនរៀបតែរបៀបវារៈទុកជូនលោកតែប៉ុណ្ណោះៗក្រៅអំពីពេលនេះ វេនទាំងពីររូបនេះ ច្រើនជួបប្រាស្រ័យគ្នាជាច្រើនដងក្នុងមួយថ្ងៃ តាមទូរសព្ទ ។ ក្រៅពីនោះ លោកប្រធានាធិបតីនឹងលោក គីស៊ីង្គ័រ ត្រូវជួបជជែកគ្នាពីនេះបន្តិចពីនោះបន្តិចនៅពេលល្ងាច ពីរដងក្នុងមួយអាទិត្យ នៅក្នុងការិយាល័យរបស់លោកប្រធានាធិបតីតែម្តង ។ ការសន្ទនានេះមានសភាពស្ងប់ស្ងាត់ណាស់ ប៉ុន្តែសុទ្ធសឹងជាសាច់ការណ៍ទាំងស្រុង ។

អ្នកធ្វើការក្រោមបង្គាប់លោក និចសុន ពុំមានទម្លាប់ការគ្រប់សង្កត់ ធ្វើឲ្យមនុស្សតប់ប្រមល់មួរម៉ៅ ដូចជាអ្នកធ្វើការជាមួយនឹងលោក លិនដុន ជនសុន ឡើយ ។

តើគេរៀបចំគាត់តែងសេចក្តីសម្រេចចិត្តរបៀបដូចម្តេច ?

មុខការដែលលោក គីស្ស៊ីង្គ័រ បានបំពេញក្នុងរឿងយន្តហោះ បង្ហាញឲ្យឃើញជាក់ស្តែង នូវកិត្យានុភាពសំខាន់របស់លោក ក្នុងរឿងរៀបចំសេចក្តីសម្រេចចិត្តរបស់លោកប្រធានាធិបតី ។ ដំណឹងបាត់យន្តហោះនោះ បានមកដល់អគារបញ្ចកោណនៅថ្ងៃអង្គារ ១៥ មេសា ១៩៦៩ នៅសូន្យម៉ោង៥៥នាទី ដល់ម៉ោងដប់មួយនាទី សេនានុពន្ធផ្ទាល់របស់លោក បានដាស់លោកជូនដំណឹង ។ មួយរំពេចនោះ លោកឲ្យគេនិយាយរៀបរាប់អំពីបេសកកម្មរបស់យន្តហោះ ហើយនឹងកន្លែងដែលយន្តហោះអាចទៅដល់ហើយធ្លាក់ ។ ម៉ោង ពីរម្ភៃប្រាំនាទី ដោយបានដំណឹងថាពួកកូរេខាងជើងធ្វើយអះអាងថា បានបាញ់ធ្លាក់យន្តហោះនោះមែន លោកសួរទៅអាគារបញ្ចកោណភ្លាមថា តើខាងផ្នែកកងទ័ព មានបានចាត់វិធានការបម្រុងយ៉ាងណា សម្រាប់យថាហេតុបែបនេះឬទេ ។ ពេលម៉ោង ៤ ក្តី គេមកជម្រាបលោកបញ្ជាក់ថែមទៀតថា យន្តហោះនោះប្រាកដជាគេបាញ់ធ្លាក់មែន លោកចាប់ទូរសព្ទនិយាយទៅជម្រាបលោកប្រធានាធិបតីភ្លាម ។ ម៉ោង៧គត់ លោកនិយាយទូរសព្ទម្តងទៀត ទៅ

លោកប្រធានាធិបតីដើម្បីជូនសេចក្ដីរាយការណ៍ យ៉ាងសង្ខេប ដល់ម៉ោង ៨ លោកចូលទៅជួបទីងទៅហ្វាយតែម្ដង ។

ចេញអំពីនោះមកវិញ លោកត្រូវទៅប្រមូលសេចក្ដីរាយការណ៍មួយចប់ អំពីក្រសួងការបរទេស និងអំពីក្រសួងការពារប្រទេស ដើម្បីឲ្យដឹងថា តើសហរដ្ឋអាមេរិក នឹងអាចទទួលគេតបមកវិញដោយប្រការណាខ្លះ តាំងតាមរយៈទ័ព, តាំងតាមរយៈទូត សេចក្ដីរាយការណ៍ក៏ត្រូវបានគេផ្ដល់មកជាហូរហែ ក្នុងរសៀលថ្ងៃដដែលនោះ លោកកោះមន្ត្រីរដ្ឋការគ្រប់ក្រុមអភិបាល មកជួយរៀបចំសំណុំរឿងឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យទាន់ពេលក្រុមប្រឹក្សាសន្តិសុខជាតិចូលមកប្រជុំ ។ ក្រុមមន្ត្រីរដ្ឋការនោះ ធ្វើការចាប់តាំងពីម៉ោង១៨ហូតដល់ម៉ោង៣ភ្លឺ ដើម្បីឲ្យបានសេចក្ដីរាយការណ៍សព្វគ្រប់ អំពីដំណើររឿង ដែលអាចកើតឡើង ហើយដាក់ជូនលោកប្រធានាធិបតីស្រាប់នូវថ្ងៃពុធ គឺថ្ងៃបន្ទាប់មក ។

ព្រឹកថ្ងៃពុធក្រុមប្រឹក្សា បើកសម័យប្រជុំមួយភ្លាម ដើម្បីនឹងប្ដូរយោបល់គ្នា ។ ដល់ពេលរសៀល មានការប្រជុំយ៉ាងតូចម្ដងទៀត ដោយមានសមាជិកតែ ៣-៤ រូប មានៈ លោកប្រធានាធិបតី លោកគីស៊ីង្គ័រ លោករដ្ឋមន្ត្រី ឡែរ លោក រ៉ូស្ហែរ និងលោកឧត្ដមសេនីយ៍ អែរលឺ វីហ្លែរនៅសេនាធិការដ្ឋានអន្តរទ័ព ។ ការប្រជុំចប់ហើយ លោកប្រធានាធិបតីនៅតែមិនទាន់មានយោបល់ជាដូចម្ដេចទៀត ។ ក្រោយ

មក លោកបានសន្ទនាយ៉ាងយូរជាមួយនឹងទីប្រឹក្សារបស់លោក រួចទើបលោកសម្រេចឲ្យដាក់រឿងនោះ ឲ្យបុគ្គលិក ១ ក្រុមផ្សេងទៀតពិនិត្យសារជាថ្មី ។ ក្រុមនេះមានភ្នាក់ងារខាងការបរទេស ភ្នាក់ងារខាងការការពារជាតិ ខាងភ្នាក់ងារកណ្តាលសម្ងាត់ផ្តល់ពត៌មាន និងភ្នាក់ងារខាងសេនាធិការដ្ឋានអន្តរទ័ពសមាជិក ។ ក្នុងក្រុមពិនិត្យថ្មីនេះក៏នៅតែមានលោក គីស៊ីង្គ័រ មួយរូបជាសមាជិកផងដែរ ។

ក្នុងរយៈពេលពីរថ្ងៃបន្ទាប់មក គឺក្នុងថ្ងៃព្រហស្បតិ៍និងថ្ងៃសុក្រសមាជិកអង្គប្រជុំនោះ បានរៀបចំសេចក្តីរាយការណ៍ពីរបែបយ៉ាងពិស្តារ ស្តីអំពីផលប្រតិកម្មជាការសងសឹក ដែលអាចកើតឡើងតាមរយៈទ័ព ឬតាមរយៈទូត ។ សេចក្តីរាយការណ៍ទី ១ ស្តីអំពីការប្រមើល ដែលអាចប៉ះទង្គិចនឹងប្រទេសចិនឬសហភាពសូវៀត ឬប៉ះទង្គិចមហាអំណាចទាំងពីរនោះព្រមគ្នាតែម្តង ។

ថ្ងៃសុក្រពេលថ្ងៃត្រង់ លោកប្រធានាធិបតីបានធ្វើសន្ទកថាមួយតាមរយៈទូរទស្សន៍ ស្តីអំពីបឋមប្រតិកម្មនៃសហរដ្ឋអាមេរិក លោកបញ្ជាក់ថាការតក៏នឹងត្រូវខានធ្វើទៅទៀត ហើយអំណើសតទៅ សហរដ្ឋអាមេរិកនឹងចាត់វិធានការ ដើម្បីឲ្យមានការធានាក៏បរងរឿងគ្រោះថ្នាក់យន្តហោះបែបនេះ ។ នៅពេលរសៀលថ្ងៃដដែល លោកសុំឲ្យឧបការីរបស់លោក ដើរស្ទាបស្ទង់មតិផ្ទាល់របស់សមាជិកក្រុមប្រឹក្សាសន្តិសុខជាតិ

ម្នាក់ៗមើល ដើម្បីចង់ដឹងថា តើសេចក្តីដែលលោកបានប្រកាសជាផ្លូវការនោះ ចុះដល់ជម្រៅចិត្តអ្នកទាំងនោះឬទេ ។ ក្រោយអំពីនោះមក លុះសង្កេតឃើញថា មតិសមាជិកភាគច្រើនប្រឆាំងនឹងការធ្វើយតប ដោយទ័ព នឹងដោយពិចារណាឃើញថា បើនឹងបាត់ការតបតដោយទ័ពទៅ និងបង្កើតឲ្យមានបរិយាកាសអាប់អួរថែមទៀត ហើយថែមទាំងសង្កេតឃើញប្រតិកម្មគាំទ្រមតិ ដែលលោកបានថ្លែងក្នុងសុន្ទរកថារបស់លោកផងនោះ លោកប្រធានាធិបតីក៏សម្រេចចិត្ត នៅល្ងាចថ្ងៃ-សុក្រនោះភ្លាមថា នឹងមិនតបតដោយកម្លាំងទ័ពឡើយ ។

ក្នុងរឿងវៀតណាម

លោក គីស៊ីង្គ័រ បានចូលប្រឡូកយ៉ាងសកម្ម ក្នុងការខិតខំរបស់-រដ្ឋាភិបាល ដើម្បីជម្រះរឿងជម្លោះនៅវៀតណាម ។ លោកខំខ្នះខ្នែងយ៉ាងអស់សមត្ថភាព ដើម្បីជួយធ្វើការនោះឲ្យបានលទ្ធផលល្អ ព្រោះលោកជាអ្នកយល់ស្ថានការណ៍នៅវៀតណាមច្រើនជាងគេ ក្នុងបណ្តាសមាជិកក្រុមប្រឹក្សារបស់សេតវិមាន លើកលែងតែលោក ហង់រី កាបូឡូដស៍ចេញៗ កាលពីឆ្នាំ១៩៦៥ លោកគីស៊ីង្គ័រ បានត្រូវរដ្ឋការអាមេរិកាំងចាត់ឲ្យមកបំពេញបេសកម្មនៅវៀតណាមខាងត្បូង ដើម្បីយកព័ត៌មានតាមសេចក្តីទោះសុំរបស់លោក កាបូឡូដ ដែលជាឯកអគ្គរដ្ឋទូតអាមេរិ-កាំងប្រចាំប្រទេសនោះ ។ ដល់មកឆ្នាំ ១៩.៦ លោកគីស៊ីង្គ័របាន

អញ្ជើញមកប្រទេសនេះម្ដងទៀត ដើម្បីនឹងរៀបចំការឲ្យលោកប្រធានាធិបតី ហ្ស៊ុនសុន និងអ្នកដឹកនាំប្រទេសវៀតណាមខាងត្បូង ជួបសន្ទនាគ្នានៅក្រុង ម៉ានីល ។

ក្នុងសម័យលោក ហ្ស៊ុនសុន ពួកមិត្តភក្តិដែលធ្លាប់មកជជែកវែកនិងលោក អំពីរឿងដែលសហរដ្ឋអាមេរិកលូកដៃចូលក្នុងរឿងវៀតណាម តែងតែឃើញទឹកមុខលោកប្រែព្រួយជាប ។ ប៉ុន្តែពោះនៅក្នុងសម័យនោះ លោកមានគំនិតដូចម្ដេច ក៏លោកខំទ្រាំចាំទាល់តែលោក និចសុន ជាប់ឆ្នោតរួចសិន ទើបលោកហ៊ានធ្វើការរិះគន់ ហើយបញ្ចេញយោបល់របស់លោក ក្នុងការចរចាដែលនឹងអាចធ្វើទៅបាននៅថ្ងៃមុខ ។ ការរិះគន់និងយោបល់របស់លោក មានចុះផ្សាយក្នុងទស្សនាវដ្ដីឈ្មោះ ហ្វរិន អាហ្វែរ ពីខែមករា ១៩៦៩ ។

ការសំខាន់គឺ លោកធ្វើសេចក្ដីស្នើចេញជាពីរបែប បែបទី ១ គឺការចរចារវាងសហរដ្ឋអាមេរិកនិងហាណូយអំពីរឿងទ័ព បែបទី ២ គឺការចរចារវាងព្រៃនគរ និងអង្គការសេរីការជាតិ អំពីបញ្ហានយោបាយ ។ បន្ទាប់មក គេដឹងថារដ្ឋាភិបាលអាមេរិកាំង បានយកសេចក្ដីស្នើនេះទាំងស្រុង មកប្រតិបត្តិតាមក្នុងការចរចានាក្រុង ប៉ារីស ។

នៅក្នុងអត្ថបទដដែលនោះ លោក គីស្ស៊ីង្ហ័រ បានផ្សាយសេចក្ដីថ្លែងការណ៍ អំពីគោលដៅពីរនៃបន្ទាត់នយោបាយអាមេរិកាំងនៅវៀត

ណាម ដែលលោកបានពិចារណាឃើញ គោលដៅទី ១ គឺជៀសវាងដូច-ម្ដេច កុំឲ្យកងទ័ពវៀតណាមខាងជើង ទម្លាក់រដ្ឋាភិបាលព្រៃនគរបាន ។ គោលដៅទី ២ គឺថា បើសិនជាកម្លាត់ពួកទ័ព និងកម្លាំងសង្កត់សង្កិនរបស់ក្រុមហាណូយបានហើយ ក៏ត្រូវកុំឲ្យយល់ថានឹងអាចរក្សារដ្ឋាភិបាលឲ្យរឹងជំហរបាន ដោយកម្លាំងបង្ខិតបង្ខំឲ្យសោះ គឺត្រូវទុករឿងវៀតណាមព្រៃនគរនេះ ឲ្យគេដោះស្រាយខ្លួនគេទៅ ព្រោះជាគេលើកអ្នកណា ទម្លាក់អ្នកណាក៏ដោយ ។

អ្នកបញ្ញវន្តនិងជាអ្នករហ័សរហួនក្នុងកាយវិការ

ជីវភាព និង សកម្មភាពរបស់លោក គីស្ស៊ីង្ហ័រ ចេះតែមានការប្រទាំងប្រទើសគ្នា ដោយលោកជាមនុស្សដែលមានឈាមជាអឺរ៉ុបផង ជា-អាមេរិកាំងផងតាមដំណាស់គ្នាយ៉ាងប្រកិតជាប់ ។ លោកជាមនុស្សចិត្តដាច់ ប៉ុន្តែក្នុងរឿងនយោបាយ លោកប្រយ័ត្នប្រយែងណាស់ លោកមានបំណង ចង់រក្សាភាពរៀបរយ ប៉ុន្តែលោកបារម្ភខ្លាចតែមានឧបទ្ទពយតាមវិស័យបរមាណូ ។ កូនសិស្សដែលបានរៀននៅមហាវិទ្យាល័យជាមួយនឹងលោកពីក្មេង តែងទុកលោកជាបញ្ញវន្តប្រឡោងខាម ប៉ុន្តែដល់ពេលលោកចេញទៅបំពេញមុខងារបច្ចុប្បន្នរបស់លោក លោកចេះបំពេញការ-កិច្ចនោះដោយចិត្តសុភាពទៅវិញ ។ នេះឯងហើយដែលជាការសំខាន់ៗ លោកចូលចិត្តធ្វើការរិះគន់ថែបក់បួងសួង ហើយដោយ គ បញ្ញលោកប្រយ័ត្នប្រយែងក្នុងបញ្ហាបរមាណូពេកម្យ៉ាង ម្យ៉ាងទៀតដោយសារលោកនៅ

សំនៀងសំឡេងជាអាល្លឺម៉ង់បន្តិចផង គេនាំគ្នារិះគន់លោកវិញហើយដាក់ងារលោកថា "វេជ្ជបណ្ឌិតឆ្កួតស្នេហា" ប៉ុន្តែលោកសុខចិត្តទទួលដោយគ្មានអាក់អន់បន្តិចសោះ ។ ថ្ងៃមួយមានស្ត្រីម្នាក់ ធ្វើឫកម៉ឹកម៉ក់ដាក់លោក ហើយធ្វើជាសរសើរ ថា: ខ្ញុំពេញចិត្តនឹងមុខងាររបស់លោកណាស់ លោកពោលក្អកទៅលើនាឡិកាដៃរបស់លោក ហើយឆ្លើយតបយ៉ាងរ៉ាក់ហ៊ុទៅវិញ អ្នកនិយាយនេះបំដាត្រូវមែន នៅតែ ៣០ វិនាទីទៀតទេ យន្តហោះទម្លាក់គ្រាប់បែកយើង នឹងមកដល់លើផ្ទៃអាកាសហាណូយហើយ ៗ

នៅក្នុងរឿងដែលលោកសរសេរតាំងអំបាលម៉ាន លោកតែងតែមានអារម្មណ៍ជាប់ជានិច្ចក្នុងរឿងលោកវិនាស ដោយបរមាណូ ៗ

សតិសោកនាដកម្មបានចាក់ឫសជាប់ ក្នុងសតិអារម្មណ៍របស់លោក ព្រោះលោកធ្លាប់មានការពិសោធន៍ ក្នុងឆាកជីវិតរបស់លោកផ្ទាល់ ៗ លោកកើតនៅថ្ងៃ ២៧ ឧសភា ឆ្នាំ ១៩២៤ ក្នុងគ្រួសារមួយនៅទីក្រុង ហ្វ៊ឺត នាប្រទេសអាល្លឺម៉ង់ខាងលិច ៗ លោកបានរស់ក្នុងសម័យព្រឹត្តិការណ៍ជាតិសង្គមនិយមអាល្លឺម៉ង់ ហើយលោកបានទទួលរងការឈឺចាប់យ៉ាងខ្លាំងផង ៗ បងប្រុសរបស់លោកនិងរូបលោក បានត្រូវសិស្សរួមថ្នាក់ផងធ្វើទុក្ខបុកម្នេញ ដោយសារប្រមាថសែនទារុណ ៗ លុះមកដល់ឆ្នាំ ១៩៣៨ ឪពុកលោកដែលធ្វើជាគ្រូបង្រៀនមួយរូបក៏ត្រូវខូចការ គ្រួសារលោកក៏នាំគ្នាចេញចាកស្រុកកំណើត ដើម្បីទៅរស់នៅទីក្រុងញូវយ៉ក ៗ

នៅនាក្រុងនោះ លោក ហង់រី មានស័ក្តងការរៀនសូត្រផ្នែកមធ្យមសិក្សា ។ លោកត្រឡប់ទៅជាន់ដីអាល្លឺម៉ង់ម្តងវិញនៅឆ្នាំ ១៩៤៥ ក្នុងឋានៈជាពលបាលត្រី នៃកងទ័ពអាមេរិកាំង ហើយលោកបានឃើញស្រុកកំណើតរបស់លោកនោះខ្ទេចខ្ទាំអស់ ដោយចម្បាំង ។

នៅឆ្នាំ ១៩៤៧ លោកបានទទួលអាហារូបករណ៍ ដើម្បីចូលទៅរៀននៅមហាវិទ្យាល័យហាវើដនៅសហរដ្ឋអាមេរិក លោកឡើងជាប់ថ្នាក់បណ្ឌិត ហើយបានចេញមកធ្វើជាសាស្ត្រាចារ្យ ។ នៅក្នុងមហាវិទ្យាល័យនោះ លោកត្រូវបង្រៀនផ្នែកវិទ្យាសាស្ត្រខាងនយោបាយ ប៉ុន្តែលោករវល់តែសរសេរ លោកមិនដែលបានទៅបង្រៀនទាល់តែសោះ ហើយគេទុកលោកដូចជាឈប់សម្រាក ។ ក្នុង ១៥ ឆ្នាំ មុននេះ[1] សៀវភៅដែលលោកសរសេរ ក៏ចាប់មានតម្លៃជាអន្តរជាតិ ។ ក្រោយមក នៅពេលដែលលោកអ៊ីសិនហូវ័រឡើងកាន់តំណែងជាប្រធានាធិបតី លោកគីស៊ីង្ហ័រ ក៏ត្រូវបានតែងតាំងជាអ្នកជំនាញការក្នុងក្រុមប្រឹក្សាសន្តិសុខជាតិ ។

លោកមានតណ្ហាដ៏មុតមាំលើភាពរៀបរយក្នុងលោកសន្និវាស

លោក គីស៊ីង្ហ័រ មានអារម្មណ៍ពីរដែលជាប់នៅក្នុងដួងចិត្តលោកជានិច្ច គឺអារម្មណ៍ជាប់ទៅលើរឿងដែលកើតមហាភ័យអន្តរាយមួយ អារម្មណ៍មួយទៀត គឺលោកចង់ឲ្យលោកសន្និវាសមានភាពរៀបរយ ហើយ

១ គិតមកដល់ឆ្នាំ ១៩៦៩ ។

ជាពិសេសទៅទៀត គឺលោកចង់បន្ថយភាពតានតឹងរវាងគូប្រឆាំងទាំងពីរ ទាំងចង់ឲ្យមានតុល្យភាពថាមពល (Un équilibre des forces) ផង ចង់ឲ្យសហរដ្ឋអាមេរិកនិងសហភាពសូវៀតស្រុះស្រួលនឹងគ្នា ទាំងខាងផ្នែកទ័ព ទាំងខាងផ្នែកនិន្នាការនយោបាយដែលមានចំនួនច្រើនអនេកប្បការនោះ ។ លោក គីស៊ីង្គ័រ ប្រាថ្នាម៉្យាងទៀត ចង់ឲ្យសហរដ្ឋអាមេរិកបន្ថយចំណាន់តាំងខ្លួនជាអ្នកសម្បើមមួយក្នុងលោកនោះទៅ ព្រោះលោកយល់ថាសហរដ្ឋអាមេរិក មិនអាចទុកខ្លួនជាតម្រួតមើលការរៀបរយលើលោកនេះរហូតដល់អស់កប្បអស់កល្បបានឡើយ ។

ដើម្បីទាញចិត្ត ស្រុកថ្មី ៗ ឲ្យពេញចិត្តរើសយកលទ្ធិប្រជាធិបតេយ្យមកកាន់ លោកខំសុំឲ្យសហរដ្ឋអាមេរិកបង្កើនជំនួយហើយលោកថ្លែងថាដើម្បីឲ្យសហរដ្ឋអាមេរិកយើង មានឥទ្ធិពលទៅលើច្រើនប្រទេស ដែលស្ថិតនៅរួមជាមួយគ្នា លើទ្វីបនិមួយៗ មធ្យោបាយដ៏ប្រសើរជាងគេរបស់យើងគឺត្រូវជួយប្រទេសណាមួយ ក្នុងទ្វីបនោះ ឲ្យដុះដាលប្រាកដឡើង ដូចជាជួយឥណ្ឌានៅក្នុងទ្វីបអាស៊ី ជួយប្រទេសប្រេស៊ីលនៅទ្វីបអាមេរិកឡាទីន ជួយប្រទេសនីសេរីយ៉ា នៅទ្វីបអាហ្វ្រិក នេះឯងហើយ ដែលជាឧទាហរណ៍សម្រាប់ប្រទេសជិតខាងយកតម្រាប់តាម ។ ហើយបើសិនជាយល់ដូច្នេះ តើគប្បីធ្វើទាំងជម្រុលឲ្យដល់កម្រិត ដែលលោកម៉ាកស្ហាល បានគ្រោងទុកក្នុងផែនការរបស់លោក ឬយ៉ាងណា ?

តាមរឿងក៏ដែលមានមកហើយនេះ គេអាចយល់ថា លោកគីសុីន្ត្រ័រ នៅមិនទាន់បញ្ចេញស្នាដៃឲ្យអស់សមត្ថភាពនៅឡើយទេ ហើយលោកនឹងត្រូវទទួលបំពេញការកិច្ច ១ យ៉ាងល្បីល្បាញ នាអនាគត ៗ អ្នកបច្ចេកទេសជំនើមក្នុងកិច្ចការអន្តរជាតិនេះ នៅធ្វើការជូនលោកប្រធានាធិបតីមួយរូប ដែលចូលចិត្តត្រិះរិះអំពីរឿងនយោបាយពិភពលោក ហើយមានមនុស្សច្រើនរូបទៀត ដែលយល់ថា បើសិនជាលោកគីសុីន្ត្រ័រនេះបានឡើងឋានន្តរស័ក្តិដល់ទៅប្រធានាធិបតីនោះ មុខជានឹងមានទុកស្នាកស្នាមពិសេសណាមួយក្នុងប្រវត្តិសាស្ត្រមិនខានឡើយ ៗ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

៣

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៤៤ ខែ មីនា

ព.ស. ២៥១៦ គ.ស. ១៩៧២

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

នាយកការផ្សាយ ៖ អ៊ុក - សាម៉ន

និពន្ធនាយក - អ្នករៀបចំ លី ធាម តេង

គណៈកម្មការនិពន្ធៈ

ព្រះពោធិវង្ស ស្វូរ-ហាយ

លោក ផល-ទិត អ្នកស្រី ពេជ-សល់

# បញ្ជីរឿង

**អត្ថបទ** **ទំព័រ**

## ១— ផ្នែកសាសនា :

១- ធម្មរាជធិកថា រៀបរៀងដោយ ព្រះញាណវង្ស សួរ-ហាយ . . . . . ១២៣

២- ចតុរារិយសច្ច (ត) រៀបរៀងដោយ ព្រះភិក្ខុ ប៉ាង-ខាត់ . . . . . ១៣៦

## ២— ផ្នែកអក្សរសាស្ត្រ :

៣- រឿងសភមក្រុក . . . . . . . . . . . . . ១៤៤

៤- ករីទស្សនៈ ចំពោះស្នេហាបុរស និង ស្ត្រី (ពាក្យកាព្យ) លោក ផល-ទិត រៀបរៀង . . . . . ១៥៥

៥- ភាពិញ្ញាវិធារ សាស្ត្រាវិត្តពោកពាក លោក យួន-សែប ចម្លងចេញពីស្លឹករឹត . . . . . . ១៧១

---

## តម្លៃខាង :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០៛០០ ។

អាណត្តិសូមផាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

# ផ្នែកសាសនា

## ជរាព្យាធិកថា

រៀបរៀងដោយ ព្រះពោធិវង្ស សួរ - ហាយ

---

## ជរាព្យាធិកថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

(៣ ចប់)

**អប្បំ វត ជីវិតំ ឥទំ ឱរំ វស្សសតាបិ មិយ្យតិ**
**សចេបិ អតិច្ច ជីវតិ អថខោ សោ ជរសាបិ មិយតិ។**

នេះជាពុទ្ធភាសិត ដែលមានមកក្នុងជរាសូត្រនៃគម្ពីរអង្គុត្តរនិកាយ ផែកខាងសុត្តន្តបិដក ។ ក្នុងពុទ្ធភាសិតនេះ និយាយអំពី **ជរា ព្យាធិ** និង **មរណៈ** ជាសត្រូវនៃជីវិត ដែលមានសេចក្ដីពិស្ដារ ក្នុងអដ្ឋកថា មនោរថបូរណីខ្លះ ក្នុងអដ្ឋកថាបបញ្ចសូទនី នៃគម្ពីរមជ្ឈិមនិកាយខ្លះ ដូចសេចក្ដីប្រែផ្ដិត តាមពុទ្ធភាសិតខាងលើ ព្រមទាំងសេចក្ដីអធិប្បាយ តាមអដ្ឋកថា ដូចតទៅនេះ

### សេចក្ដីប្រែផ្ដិត

**ជីវិតនេះ** មានប្រមាណតិចណាស់ រមែងស្លាប់ក្នុងកាលខាងអាយុ អំពី ១០០ ឆ្នាំ ប៉ុន្ដែបើសត្វនោះរស់នៅក្នុងពីអាយុ ១០០ ឆ្នាំទៅ ក៏រមែងស្លាប់ក្នុងកាលនៃវ័យចាស់ ដោយពិតពុំខាន ៗ

ព្រះធម៌ទេសនា របស់ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់សម្ដែងទុកមក បាត់ជាព្រះវិន័យខ្លះ បាត់ជាព្រះធម៌ខ្លះ ។ ច្បាប់ ដែលព្រះអង្គសម្ដែង បញ្ញត្តទុកមក ដើម្បីទូន្មានប្រៀនប្រដៅ ចំពោះពុទ្ធបរិស័ទ ទាំងបព្វជិត ទាំងគ្រហស្ថ ដោយឧបាយសម្រាប់កំចាត់ការពារកាយនិងវាចា ច្បាប់នោះ ហៅថាព្រះវិន័យ ។ ច្បាប់ដែលព្រះអង្គសម្ដែងទុកមកដើម្បីប្រៀនប្រដៅ ចំពោះផ្លូវចិត្តនិងចេតសិក សម្រាប់កំចាត់ការពារកិលេសគ្រប់យ៉ាង មាន នីវរណៈ ៥ យ៉ាងជាដើម ដើម្បីមិនឲ្យពួកកិលេសណាមួយកើតឡើងក្នុង ចិត្ត ឬថា បើពួកកិលេសទាំងនោះកើតឡើងក្នុងចិត្តហើយ ក៏អាចយកធម៌ ទៅចម្រើនអប់រំបរិកម្ម ដើម្បីកម្ចាត់បង់ ដើម្បីរម្ងាប់នូវពួកកិលេសទាំងពួង ឲ្យស្ងប់រម្ងាប់ទៅបាន ។ ច្បាប់ ដែលជាឧបាយដ៏ប្រសើរ សម្រាប់ទូន្មាន សង្កត់សង្កិនចិត្ត ប្រៀនប្រដៅចិត្ត ជោសសម្អាតផ្លូវចិត្ត ដូច្នេះ ហៅថា ព្រះធម៌ ។

ជរាធម៌ ព្យាធិធម៌ និង មរណធម៌ ទាំងបីនេះ ជាធម៌ដែលយើងត្រូវ ពិចារណារឿយៗ ឲ្យឃើញច្បាស់ដោយបញ្ញាថា ធម៌ទាំងនេះ មានអ្វី ជាប្រភព ជាដែននាំឲ្យកើតមាន ?

ធម៌ទាំងនេះ មានរូបកាយរបស់សត្វលោក ជាប្រភព ជាដែន នាំឲ្យកើត ។ កាលបើរូបកាយរបស់សត្វលោក កើតមានមក ដរាបណា

ធម៌ទាំង ៣ យ៉ាង មានផលធម៌ជាដើម ក៏រមែងកើតមានមកជាមួយនឹងរូបកាយសត្វលោក ផងបនោះដែរ ។

ផល ព្យាធិ និង មរណៈ លោកចាត់ថាជា «នាមធម៌ឬអរូបធម៌» គឺ ជាធម៌គ្រាន់តែមានឈ្មោះ ពុំមានរូបរាងឃើញប្រាកដដោយចក្ខុទេ ។ ធម៌ទាំងនេះ គេពុំអាចមើលឃើញ ពុំអាចស្ទាបប៉ះពាល់ត្រូវបានឡើយ ។ ធម៌នេះ មានឈ្មោះថា អរូបធម៌ ពិតមែន ប៉ុន្តែ អាចកើតមានដុះលូតលាស់នៅក្នុងរូបធម៌របស់សត្វលោកដោយពិត ។ ផល ព្យាធិ និង មរណៈនេះ លោកចាត់ថាជា «អនិដ្ឋារម្មណ៍» គឺអារម្មណ៍មិនជាទីប្រាថ្នា មិនជាទីត្រូវការ មិនជាទីគាប់ចិត្តរបស់សត្វលោកទេ ប៉ុន្តែ ដើមដំបូង សត្វលោកដែលជាប់ជាក់ចងដោយតណ្ហាទាំង ៣ ប្រការ (មានកាមតណ្ហាជាដើម) ដែលជាកិលេសជាតិដឹកនាំចិត្តសត្វលោកឲ្យប្រាថ្នា ឲ្យស្រឡាញ់ ឲ្យអន្ទះសាទន្ទ្រាចង់កើតចង់មានក្នុងភពទាំង ៣ គឺ កាមភព១ រូបភព១ អរូបភព១ ។

សត្វលោកដែលចេះតែកើតមានមិនដេរដាស កុះករក្នុងភពទាំង ៣ នេះ ព្រោះហេតុមកអំពីតណ្ហា គឺមានតណ្ហាជាឈ្នួនដំបូងបង្អស់ ដែលនាំឲ្យសត្វលោកកើតឡើងមាននៅក្នុងភពមិនដាច់ ។ កាលបើរូបកាយសត្វលោកកើតមានមកហើយ ទើបឯផលព្យាធិនិងមរណា ក៏បានមកជាមួយជាផលប ។ ដំណើរនេះ ជាទិដ្ឋភាពមួយ នាំឲ្យយើងឃើញច្បាស់ថា សត្វលោក មានតណ្ហាជាស្នេហ៍មុខ មានតណ្ហាជាប្រធាន ជាដែននាំឲ្យ

កើត ៗ រូបកាយសត្វលោកដែលមានជរាព្យាធិនិងមរណៈនេះ ពុំមែនខាស់មកអំពីហេតុអ្វីដទៃក្រៅអំពីតណ្ហាឡើយ គឺថា សត្វលោក ដែលចេះតែកកើតឡើងមិនដេរដាសនៅក្នុងលោកនេះ ព្រោះហេតុតែតណ្ហា ដូចបាលីថា

**យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី តណ្ហាសិនេហា តណ្ហាជនិកា តណ្ហាជប្បនា តណ្ហាធិលេបនា តណ្ហាសប្បនា តណ្ហាអាសប្បនា តណ្ហា-ភប្បនា តណ្ហាអាភប្បនា អយំ វុច្ចតិ តណ្ហា ។**

ប្រែជាសេចក្ដីថា កិលេសជាតិណា ដែលឈ្មោះថា តណ្ហា តែងឈមទៅរកកំណើតថ្មី ប្រកបព្រមដោយនន្ទិរាគ ជាទីត្រេកត្រអាលនៅក្នុងភពនោះ ៗ ទុកដូចជាជរស្អិត ជាគ្រឿងញ៉ាំងសត្វឲ្យកើត ជាគ្រឿងជប់ ជាគ្រឿងលាប ជាគ្រឿងអន្ទះសា ជាគ្រឿងច្រូច ជាគ្រឿងខ្នះខ្នែង រឹតអាតគឺតណ្ហា កិលេសជាតិនេះ លោកហៅថា តណ្ហា ។

បាលីដែលមានមកនេះបញ្ជាក់ឲ្យឃើញថា សត្វលោក មានតណ្ហានេះហើយជាប្រភពនាំឲ្យកើតឡើង គឺថា កិលេសជាតិពោលគឺតណ្ហានេះឯង តែងដឹកនាំសត្វលោក ឲ្យប្រណាំងប្រជែងដេញដើងគ្នា ក្នុងការបង់កើតទៀត មិនចេះឈប់ មិនចេះស្រាក គឺថា អ្នកនោះក៏បង់កើតទៀត អ្នកនេះក៏បង់កើតទៀតដែរ ចេះតែនៅមានការបង់ ការប្រាថ្នា តទៅមុខទៀត ឥតមានទៀយណាយធុញទ្រាន់ក្នុងការកើតនោះទៀតឡើយ ។

ជរាព្យាធិនិងមរណៈ ក៏ជាជា ទោសឬសត្រូវ របស់ជីវិតសត្វលោកដោយពិត ព្រោះហេតុតែសត្វលោកកើតមក ទើបជាបច្ច័យនាំឲ្យមានជរាព្យាធិនិងមរណៈមកជាមួយ ៗ ដើមដំបូង កាលដែលសត្វលោកចង់កើតមានឡើងនោះ ដោយមានសេចក្តីប្រាថ្នាជ្រុលប្រាល់ អន្ទះសាលឿនរលេញ ផ្តោះទៅរកការកើតទៀត ហើយមានមោហកិលេសគ្របសង្កត់ នាំឲ្យវិលវល់ភ្លេចភ្លាំង មិនឲ្យឃើញទោស មិនឲ្យឃើញសឹកសត្រូវ របស់ជាតិនោះឡើយ ៗ ជរាព្យាធិនិងមរណៈនេះឯង ចាត់ទុកថា ជាទោស ជាសត្រូវនៃជីវិតសត្វលោក ដូចអធិប្បាយមកនេះឯង ៗ

## អធិប្បាយពាក្យសេចក្តី

**១- ជរា** ប្រែថា "ការចាស់, គ្រាំគ្រា, រង្គោះរង្គើ, ទ្រុឌទ្រោម, ទ្រេតទ្រោត, រេះរោះ, ទទិកទទក់" ៗ ជរានេះ វែកញែកដោយខ្លីមាន ២ យ៉ាងគឺ **បដិច្ឆន្នជរា** ជរាដែលមាន តែនៅកំបាំង ១, **អប្បដិច្ឆន្នជរា** ជរាដែលមិនកំបាំង ១ ៗ

ជរាដែលមានពិតប្រាកដ ក្នុងរូបកាយរបស់សត្វ ប៉ុន្តែ មិនទាន់ឃើញអាការៈដែលចេញមកខាងក្រៅប្រាកដច្បាស់នៅឡើយ ដូចយ៉ាងសក់មិនទាន់ស្កូវ ធ្មេញមិនទាន់បាក់ ភ្នែកមិនទាន់ងងឹត សាច់ឈាមពុំទាន់ជ្រួញជ្រីវ ខ្នងពុំទាន់កោងក្ងក់ ដៃពុំទាន់កាន់ឈើច្រត់ ៗ អាការៈរបស់រូបកាយ តែងមានជរាសឹកសៀតបង្កប់នៅដោយពិត ប៉ុន្តែ មិនទាន់

ឃើញចេញផ្ទៃផ្កាមកខាងក្រៅ ដូច្នេះ លោកហៅថា បដិច្ឆន្នជរា គឺជរា មានមកប្រាកដនៅក្នុងរូបកាយ ប៉ុន្តែ នៅកំបាំងនៅឡើយ ។

ជរាដែលមិនកំបាំង បានដល់អាការៈពង្សកាយចេញចម្លែកមកហើយ ដូចយ៉ាង សក់ធ្លាប់មានសម្បុរខ្មៅ ក៏ស្រាប់តែសក្បុសដូចសំឡី, មាត់ធ្លាប់មានធ្មេញ ក៏ស្រាប់តែមាត់គ្រហិបគ្រហុប, ភ្នែកធ្លាប់ភ្លឺ ទៅជាងងឹតងងល់, ត្រចៀកធ្លាប់ឮ ទៅជាថ្លង់, ខ្នងធ្លាប់ត្រង់ ទៅជាកោងកូក, ជើងធ្លាប់មានតែពីរ ត្រឡប់ទៅជាមានឈើច្រត់មួយទៀតទៅជាជើងបី, សម្បុរស្បែកសាច់ ក៏ទៅជាជ្រួញជ្រីវយុរយារ, ពុស្សូវថ្ងូរគ្ងួញតែអំពីកាពនៃខ្លួន ដែលទ្រុឌទ្រោមទ្រមអន់ជារឿយ ៗ ។

សេចក្តីចាស់ជរានៃអាការៈពង្សកាយ ដែលបញ្ចេញមកខាងក្រៅ ឲ្យឃើញប្រាកដប្រជា ដូចអធិប្បាយមកនេះ ហៅថា អប្បដិច្ឆន្នជរា ។

ក្នុងអភិណ្ហប្បច្ចវេក្ខណសូត្រ លោកឲ្យពិចារណាជរាធម៌រឿយ ៗថា អាត្មាអញមានជរាជាធម្មតា មិនកន្លងជរាធម៌បានឡើយ ។ ការពិចារណាជរាធម៌នេះ ដើម្បីឲ្យចាំជាក់ចំពោះរូបកាយរបស់ខ្លួន តាំងអំពីបឋមវ័យរហូតដល់មកមជ្ឈិមវ័យនិងបច្ឆិមវ័យ ដើម្បីលះបង់ ឬបន្ទាបពិស នៃសេចក្តីស្រវឹងមួយហៅថា „យោព្វនមទៈ" (សេចក្តីស្រវឹងថាខ្លួននៅក្មេង) ។ មួយទៀត ការពិចារណារឿយៗ ចំពោះជរាធម៌នេះ ដើម្បីឲ្យមានសេចក្តីសង្វេគ នឿយណាយ ធុញទ្រាន់ ចំពោះរូបកាយ ហើយតម្កល់សតិ

និងសម្បជញ្ញៈ មិនឲ្យមានបមាទធម៌ គ្របសង្កត់ប្រាជ្ញាស្មារតីបានឡើយ ហើយត្រូវត្រិះរិះពិចារណារករកថា តើធម៌ណាដែលគ្មានជរា ? ទីបំផុតក៏ឃើញច្បាស់ថា ធម៌ដែលគ្មានជរា មានតែមគ្គផលនិព្វាន ។ លំដាប់មកបុគ្គល គប្បីជម្រះកាយវាចាចិត្តឲ្យបរិសុទ្ធ ធ្វើសេចក្តីស្រឡាញ់ចាញ់ត្រង់ទៅរកមគ្គផលនិព្វានជារឿយ ៗ តទៅ ។

ពុទ្ធភាសិតខាងលើ ដូចបានអធិប្បាយមកនេះ សម្តែងអំពីជរាថាជាសឹកសត្រូវរបស់ជីវិត ឬថា ជាបច្ចាមិត្តនៃជីវិត ។ ពាក្យថា "ជីវិតមានប្រមាណតិចណាស់" នោះបានន័យថា ជីវិត ជាធម្មជាតមិនមានកម្លាំងរឹងប៉ឹងជាប់ស្ថិតថេរ ទោះបីជីវិតរបស់តិរច្ឆាន ដែលមានមាឌធំ ៗ ដូចជាដំរី ក្របី គោ ជាដើម ក៏ជីវិតរបស់វាមិនជាប់ស្ថិតជាងជីវិតរបស់មនុស្សប៉ុន្មានឡើយ ។ ជីវិត ជាធម្មជាតងាយនឹងផុតរលត់ ជាធម្មជាតផុយ ឆាប់ជាប់ឆាប់ពេកលោយដោយងាយណាស់ ។

សម្ភារៈក្នុងសំណុំកងកាយយើង មានច្រើនយ៉ាងណាស់ដែលជារបស់ចាំបាច់នៃជីវិត ។ ដូចយ៉ាង បេះដូង មានចលនាដើរយោល គាបបឺតយកឈាម អំពីកោសិកានៃថ្លើម ហើយផ្លុំឈាមឲ្យរត់ទៅតាមសរសៃក្នុងសរីរាង្គ ។ កាលបើបេះដូងមិនមានចលនា ដែលយើងហៅថា "បេះដូងគាំង" នោះ ជីវិតក៏រលត់ទៅភ្លាម ជំណាលគ្នានឹងបេះដូងគាំង ។ មួយទៀត ជីវិតនេះ មានសរសៃឈាមតាមកញ្ចឹងកមកលលាដ៍ក្បាល ជា

សម្ភារៈជាចាំបាច់មួយរបស់ជីវិតដែរ, កាលបើសរសៃឈាមនេះដាច់ ជីវិតក៏រមែងរលត់ទៅភ្លាមដែរ ។ មួយទៀត ធម៌ដែលជាសត្រូវចំពោះជីវិត មានច្រើនយ៉ាងណាស់ ដូចយ៉ាង ជរាធម៌ អាចធ្វើរូបកាយរបស់សត្វ ឲ្យចាស់គ្រាំគ្រាទ្រុឌទ្រោម ឲ្យខ្សោយកម្លាំងនេះ អាចធ្វើជីវិតឲ្យខ្សោយបន្តិចម្តងៗរៀងរាល់ថ្ងៃៗ ជីវិតក៏កាន់តែងាយនឹងរលត់រលាយដោយឆាប់រហ័ស ព្រោះហេតុនៃសម្ភារៈក្នុងកាយគ្រាំគ្រាទ្រុឌទ្រោម ។

ជីវិតរបស់មនុស្សសត្វទាំងអស់ ជាធម្មជាតមានតម្លៃខ្ពង់ខ្ពស់ជាទីបំផុត, វត្ថុទាំងអស់ក្នុងលោក ដែលគេបង្កើតឡើងសម្រាប់ប្រើប្រាស់ជុំវិញខ្លួន របស់ទាំងនោះជួនកាលឡើងថ្លៃ ជួនកាលក៏ចុះថ្លៃ ទើបឯជីវិតរបស់មនុស្សសត្វ ចេះតែឡើងថ្លៃជាប់ជាដរាប ពុំចេះចុះថ្លៃឡើយ ព្រោះថា មនុស្សគ្រប់រូប សុទ្ធតែប្រកាន់មាំក្នុងជីវិតថា ជីវិតរបស់អាត្មាអញ ជាទីស្រឡាញ់ ជាទីពេញចិត្ត ពុំមានវត្ថុស្មើជីវិតឡើយ ។ ជីវិតនេះ ជាធម្មជាតឥតរូបកាយទេ គឺជានាមធម៌ ដែលមិនអាចមើលឃើញស្ទាបពាល់ត្រូវ មិនអាចចាប់បានឡើយ ។

ជីវិត កាលបើជរាព្យាធិញាំញី រមែងអន់ថយខ្សោយទៅ អស់ទៅដោយលំដាប់ ។ ជរានិងព្យាធិនេះ បញ្ជាក់ឲ្យឃើញថា ជាបច្ចាមិត្រ ឬជាសត្រូវរបស់ជីវិត ដោយពិតប្រាកដ ព្រោះហេតុនោះ ទើបជីវិតឋិតនៅពុំបានទៀតទេ ច្រើនតែស្លាប់ក្នុងកាលខាងអាយនៃអាយុ

១០០ឆ្នាំ បើទុកជាហួសពី ១០០ ឆ្នាំ ក៏ហួសបន្តិចបន្តួច ក៏អាចស្លាប់ដោយផុតពីព្យាធិណាមួយពុំបានឡើយ ។

**២- ព្យាធិ** ប្រែថា "ការឈឺចាក់ឬដមឹតម្កាត់" ។ពាក្យថា "ព្យាធិ" នេះមានវេវចនស័ព្ទ គឺជាពាក្យសម្រាប់ហៅ សម្រាប់និយាយផ្លាស់ប្តូរមាន ៣យ៉ាងទៀតគឺ **រោគ** (ការចាក់ដោត, ការចាប់ពើត) **គិលាន** (ការពុកចាប់, រួយស្រយង់, ការញាំញីកាយចិត្តឲ្យរំខាន ឲ្យព្រួយបារម្ភ) **អាពាធ** ប្រែថា "ការបៀតបៀន ការរួបរឹត ការគាបសង្កត់ ការធ្វើកាយចិត្តឲ្យទទួលទុក្ខវេទនា មានការឈឺចាប់ជាដើម" ។

ពាក្យទាំង៤យ៉ាងគឺ **ព្យាធិ រោគ គិលាន អាពាធ** ទាំងនេះ មានន័យថា ការឈឺចាប់ចាក់ដោត ចំពោះកាយចិត្តរបស់មនុស្សសត្វ តែប៉ុណ្ណោះ ។ រាងកាយរបស់មនុស្សសត្វ ដែលមានធម៌ជាបច្ច័យតាក់តែងមកហើយ សុទ្ធតែជាប្រកត គឺជាកន្លែងនាំឲ្យកើតរោគាពាធ បានទាំងអស់ ដូចបាលីក្នុងគិរិមានន្ទសូត្រថា

**ពហុទុក្ខោ ខោ អយំ កាយោ ពហុអាទីនវោ**

ប្រែថា "រាងកាយនេះ នាំមកនូវទុក្ខច្រើនប្រការណាស់ មានទោសក៏ច្រើនប្រការណាស់" ។ ដូចសំណុំរាងកាយរបស់យើង ដែលមានភ្នែក ត្រចៀក ច្រមុះ អណ្តាត មាត់ ធ្មេញ ក្បាល បំពង់ក សាច់ ឈាម សួត ថ្លើម បេះដូង ក្រពះ ពោះវៀនធំ តូចជាដើម ។ សម្ភារៈនៃរាង

កាយ ដូចរៀបរាប់មកប៉ុណ្ណោះ សុទ្ធតែជាប្រភពនាំឲ្យកើតរោគាពាធបាន ទាំងអស់ ។

## សូមរៀបរាប់អំពីរោគដោយសង្ខេប ដូចតទៅនេះ

ចក្ខុរោគា រោគក្នុងភ្នែក, សោតរោគា រោគក្នុងត្រចៀក, ឃាន-រោគា រោគក្នុងច្រមុះ, ជិវ្ហារោគា រោគក្នុងអណ្តាត, មុខរោគា រោគក្នុងមាត់, ទន្តរោគា រោគក្នុងធ្មេញ, សីសរោគា រោគក្នុងក្បាល, កណ្ឋរោគា រោគក្នុងបំពង់ក, មំសរោគា រោគក្នុងសាច់, លោហិតំ រោគឈាម, បប្ផាសំ រោគសួត, យកនំ រោគថ្លើម, ហទយំ រោគបេះដូង, បិហកំ រោគក្រពះ, អន្តំ រោគពោះវៀនធំ, អន្តគុណំ រោគពោះវៀនតូច, មធុមេហោ រោគទឹកមូត្រផ្អែម, ខេសា រោគមហារីក ប៉ុណ្ណោះជាដើម ។

រោគក្នុងកាយរបស់យើង ដែលឃើញពិតប្រាកដ ក្នុងកាលសព្វថ្ងៃនេះ ដែលវេជ្ជបណ្ឌិតជំនាញៗ លំបាកព្យាបាល ជារោគដ៏គួរគាប់ឃោរឃៅ មាន៣យ៉ាងគឺ រោគឈាមដែលគេតែងហៅថា រោគឈាមឡើង រោគឈាមចុះ១ រោគទឹកមូត្រផ្អែម១ និងរោគមហារីក១ ។ រោគគ្រប់យ៉ាង សុទ្ធតែជាបច្ចាមិត្រ ជាសត្រូវចំពោះជីវិតទាំងអស់ ដូចសេចក្តីពណ៌នាមកដោយសង្ខេបប៉ុណ្ណោះ ។

ការពិចារណាព្យាធិធម៌រឿយៗ ដើម្បីបន្ទាបពិសស្រវឹងមួយហៅថា «អារោគ្យមទៈ» គឺស្រវឹងថា អាត្មាអញ ជាអ្នកមានតួជមិនដែលមានរោគណាមួយទេ ។

**៣- មរណៈ** ប្រែថា "សេចក្តីស្លាប់" ពាក្យនេះ មានវេវចនស័ព្ទជាច្រើនយ៉ាងគឺ មច្ចុ (ការបំផ្លាញជីវិត), កាលកិរិយា (ការវិនាសជីវិត), អន្តកៈ (ការផ្តាច់ជីវិត) ខន្ធភេទ (ការបែកធ្លាយខន្ធ) អនិច្ចកម្ម (អំពើនៃជីវិតមិនទៀង), ជីវិតក្ខយៈ (ការអស់ជីវិត), ប៉ុណ្ណេះជាដើម មានន័យថា "សេចក្តីស្លាប់" តែម្យ៉ាងប៉ុណ្ណោះ ។ ក្នុងអត្ថបទធម៌នេះ សូមចាប់យកពាក្យថា "មរណៈ" ដូចសេចក្តីអធិប្បាយដោយសង្ខេប តទៅនេះ

ក្នុងបាលី ច្រើនប្រើមរណធម៌ ដូចពុទ្ធភាសិតក្នុងអភិណ្ហបច្ចវេក្ខណសូត្រថា **មរណធម្មោម្ហិ មរណំ អនតីតោ** ប្រែថា "អាត្មាអញមានមរណធម៌ មិនអាចកន្លងមរណធម៌បានទេ" ។ មរណៈ (សេចក្តីស្លាប់) ជាភ័យធំមួយនៃជីវិតរបស់មនុស្សសត្វ ទុកថា ជាអនិដ្ឋារម្មណ៍គឺអារម្មណ៍មិនជាទីប្រាថ្នា មិនជាទីត្រូវការ នៃមនុស្សសត្វទេ ។

មនុស្សសត្វគ្រប់ជាតិ តែងភ័យ ញ័ររន្ធត់ តក់ស្លុត ចំពោះសេចក្តីស្លាប់នេះ ដ៏ក្រៃលែង ប៉ុន្តែ ព្រះសម្មាសម្ពុទ្ធ សព្វព្រះទ័យសម្តែងធម៌ទេសនាអំពីមរណធម៌នេះញឹកញយណាស់ ដូចក្នុងអត្ថបទសមថកម្មដ្ឋាន មានឈ្មោះថា "មរណានុស្សតិកម្មដ្ឋាន" ដែលព្រះអង្គទ្រង់លើកឡើងសម្តែងឲ្យពុទ្ធបរិស័ទពិចារណារឿយ ៗ ចំពោះសេចក្តីស្លាប់ ដើម្បីឲ្យពុទ្ធបរិស័ទពិចារណាជាក់ច្បាស់អំពីសេចក្តីស្លាប់ កុំឲ្យកិតភ័យ តក់ស្លុត រន្ធត់ចំពោះសេចក្តីស្លាប់ហួសហេតុពេក ព្រោះថា រូបកាយដែលកើតមកហើយក្នុង

បច្ចុប្បន្ន តែងតែជាប់ទាក់ទងនៅដោយជរា ព្យាធិ និងមរណៈមកហើយដែរ ព្រោះហេតុនោះ ឃើញថា រូបកាយនេះ មានមរណៈជាប់មកជាមួយស្រាប់ ហើយ យើងមិនគួរតក់ស្លុតភិតភ័យ ចំពោះមរណៈក្នុងបច្ចុប្បន្ននេះឡើយ យើងគួរតក់ស្លុតភិតភ័យចំពោះមរណធម៌នៅក្នុងអនាគតឯនោះវិញ ដោយហេតុថា បើរូបកាយយើង នឹងត្រូវកើតក្នុងអនាគតច្រើនជាតិទៀត យើងនឹងត្រូវជួបប្រទះមរណៈក៏ច្រើនដងដែរ ។

មនុស្សសត្វបុថុជ្ជន ដែលនាំគ្នារស់នៅក្នុងគ្រួសារនីមួយៗ សុទ្ធតែរស់នៅដោយផ្សងព្រេង ប្រថុយប្រថានទាំងអស់ ឥតមានអ្នកណាម្នាក់ដឹងកាលកំណត់នៃជីវិតរបស់ខ្លួន ថា «ជីវិតរបស់អាត្មាអញ ត្រូវកំណែនមរណសង្គ្រាមមកកែនយកទៅ ក្នុងថ្ងៃណាឬខែណា»ឡើយ ឬថា «ក្នុងគ្រួសាររបស់អាត្មាអញនេះ តើមរណសង្គ្រាម កែនយកជីវិតឈ្មោះណាទៅមុន ទុកជីវិតឈ្មោះណាចាំកែនទៅជាខាងក្រោយ?»។

មនុស្សសត្វទាំងអស់គ្រប់វណ្ណៈគ្រប់ត្រកូល សុទ្ធតែត្រូវកំណែនមរណសង្គ្រាម ឥតមានសល់អ្នកណាម្នាក់ឡើយ ។ មរណសង្គ្រាម លោកកប់ថា ជាសង្គ្រាមធំណាស់ មិនចេះមានសន្តិភាពក្នុងកាលណាទេ ចេះតែប្រកាសសង្គ្រាម ទៅលើមនុស្សសត្វទាំងអស់ រាល់ថ្ងៃ ខែ ឆ្នាំ ឥតចេះចប់ ឥតចេះផ្អាកឡើយ ។ មនុស្សទាំងអស់ ត្រូវព្រាត់ប្រាសនិរាសចាកចោលសត្វនិងសង្ខារ ជាទីស្រឡាញ់ ពេញចិត្តក្តី មិនជាទីស្រឡាញ់

ពេញចិត្តក្តី ដូចយើងឃើញពួមនុស្សសត្វព្រាត់ប្រាសយំយែក សម្រក់ទឹកភ្នែក ទឹកសំបោរ ហៀហូរសស្រោក់ គ្រប់វណ្ណៈ គ្រប់ត្រកូលទាំងអស់ ព្រោះហេតុកំណែនទូទៅនៃមរណសង្គ្រាមនេះឯង ។

ការពិចារណាចំពោះមរណធម៌រឿយ ៗ នេះ ដើម្បីលះបង់នូវជីវិតាល័យគឺសេចក្តីអាល័យក្នុងជីវិតផង ដើម្បីបន្សាបនូវពិស នៃសេចក្តីស្រវឹងក្នុងជីវិតដែលហៅថា **ជីវិតមទៈ** នោះផង ។

ឯកន្តបរមសុខ គឺសុខក្សេមក្សាន្ត ដ៏ក្រៃលែងដាច់ដោយឡែកនោះ មានតែព្រះនិព្វានទេ ទើបរួចជ្រះស្រឡះ ចាកកំណែននៃមរណសង្គ្រាម លុះតែអរិយសាវក អរិយសាវិកា បានប្រព្រឹត្តអប់រំកាយវាចាចិត្ត ឲ្យបរិសុទ្ធ ឲ្យកើតប្រាជ្ញាភ្លឺថ្លា ធ្វើខ្លួនឲ្យបានមគ្គបានផល ទើបអាចចូលទៅកាន់ទ្វារព្រះនិព្វានបាន ។ និព្វានធម៌ ទើបជាធម៌ផ្តល់នូវបរមសុខ ឥតមានចាក់ចង់ដោយទុក្ខទោសព្រាត់ប្រាសនិរាសទៀតឡើយ ។

ជរាព្យាធិកថា ចប់តែប៉ុណ្ណោះ ។

# ចតុរារិយសច្ច

(តមកពីលេខមុន)

ភិក្ខុ ប៉ាង-ខាត់ រៀបរៀង

មួយទៀត ក្នុងរដ្ឋបាលសូត្រ ព្រះសម្ពុទ្ធទ្រង់ត្រាស់ចំពោះរដ្ឋបាលភិក្ខុ(១)ថា "លោកនេះ ចេះតែហូរទៅជានិច្ច ជាធម៌មិនទៀងទាត់ទេ"= ឧបនីយតិ លោកោ អទ្ធុវោ ។ ដូច្នេះ លោកនេះ ជាលោកមិនទៀងទាត់ រលត់ទៅហើយផ្សំគ្នាកើតឡើងទៀត តពីមួយទៅមួយ ព្រោះជាធម៌ទាក់ទងដោយហេតុផល មិនមានអ្វីដែលមិនផ្លាស់ប្តូរនៅក្នុងរូបខ្លួនឯង មិនមានអ្វីនៅខាងក្រោយដែលគួរនឹងហៅថា "សត្វ", "បុគ្គល" ឬ "អាត្មាអញ-ឯង" ដែលទៀងទាត់បានឡើយ ដូចពុទ្ធភាសិតថា(២)

ជីវិតំ អត្តភាវោ ច  សុខទុក្ខា ច កេវលា
ឯកចិត្តសមាយុត្តា  លហុសោ វត្តតេ ខណោ ។
ចុល្លាសីតិ សហស្សានិ  កប្បំ តិដ្ឋន្តិ យេ មរូ
ន ត្វេវ តេបិ តិដ្ឋន្តិ  ទ្វីហិ ចិត្តេហិ សមាហិតា ។
អនិព្វត្តេន ន ជាតោ  បច្ចុប្បន្នេន ជីវតិ

---

១- មជ្ឈិមនិកាយ រដ្ឋបាលសូត្រ សៀវភៅទី ២៤ ទំព័រ ២៩៨ ។ ធម្មុទ្ទេស ៤ ប្រការគឺ: ១ ឧបនីយតិ លោកោ អទ្ធុវោ, ២ អតាណោ លោកោ អនភិស្សរោ, ៣ អស្សកោ លោកោ សព្វំ បហាយ គមនីយំ, ៤ ឩនោ លោកោ អតិត្តោ តណ្ហាទាសោ ។ ២ ទុ. មហា. ។

ចិត្តភង្គា មតោ លោកោ បញ្ញត្តិ បរមត្ថិយា ។
អទស្សនតោ អាយន្តិ ភគ្គា គច្ឆន្តុទស្សនំ
វិជ្ជុប្បាទោវ អាកាសេ ឧប្បជ្ជន្តិ វយន្តិ ច ។

សេចក្តីប្រែ ជីវិតក្តី អត្តភាពក្តី សុខទុក្ខក្តី ជាធម៌ប្រកបដោយចិត្តតែមួយ ខណៈ (នៃធម៌ទាំងឡាយមានជីវិតជាដើមនេះ) តែងប្រព្រឹត្តទៅរហ័សណាស់ ។

ទេវតាទាំងឡាយ សូម្បីឋិតនៅបានដល់ទៅ ៨៤.០០០ កប្ប ក៏ដោយ ក៏មិនមែនឋិតនៅ ដោយចិត្តពីរទេ ។

សត្វ ឈ្មោះថា "មិនទាន់កើតឡើង" ដោយចិត្តដែលមិនទាន់កើត (ចិត្តអនាគត), ឈ្មោះថា "រស់នៅ" ដោយចិត្តជាបច្ចុប្បន្ន, ឈ្មោះថា "ស្លាប់" ដោយចិត្តរលត់ហើយ, កាលបើដូច្នេះ ក៏គ្រាន់តែជាបញ្ញត្តិ ឬជាវោហារប្រចាំលោក ដោយបរមត្ថប៉ុណ្ណោះ ។

សង្ខារ តែងកើតឡើងពីទីដែលគេមិនឃើញ បែកធ្លាយទៅ ក៏ទៅបាត់កន្លែងទីដែលគេមើលមិនឃើញដូចគ្នាដែរ កើតឡើងក្តី វិនាសទៅក្តី គេមើលមិនឃើញផ្លូវទៅ ឬ ផ្លូវមកឡើយ ប្រៀបដូចផ្លេកបន្ទោរក្នុងអាកាស ដូច្នោះឯង" ។

សេចក្តីក្នុងគាថាទាំងនេះ ប្រាប់ច្បាស់ថា បើមិនមានរូប វេទនា សញ្ញា សង្ខារ ឬសកម្មភាពរបស់ចិត្ត ឬក៏វិញ្ញាណទេ ក៏មិនត្រូវនឹងកប់

ថា «សត្វ», «បុគ្គល» ឬ «អាត្មា-អញ-ឯង» បានទេ, លុះត្រាតែផ្សំគ្នា ដោយកាយនិងចិត្ត ទាក់ទងគ្នាទៅវិញទៅមករួមគ្នា ទើបបានកើតទៅជា «ម៉ាស៊ីនមួយ» ប្រកបដោយកាយនិងចិត្ត Machine psycho-physiologique ទើបយើងកើតគំនិតមួយឡើងហៅថា «សត្វ», «បុគ្គល» ឬ «អាត្មា-អញ-ឯង» បាន ។

សមដូចពុទ្ធភាសិតដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ថា (១)

យថា ហិ អង្គសម្ភារា    ហោតិ សទ្ទោ រថោ ឥតិ
ឯវំ ខន្ធេសុ សន្តេសុ    ហោតិ «សត្តោ»តិ សម្មុតិ ។

ប្រែថា: ពាក្យដែលសន្មតហៅថា «រថ» ព្រោះប្រកបដោយអង្គសម្ភារៈយ៉ាងណា, ខន្ធដែលកើតមានឡើង ទើបលោកសន្មតថា «សត្វ» យ៉ាងនោះឯង ។

សេចក្តីនេះ ព្រះពុទ្ធឃោសាចារ្យពោលទុកថា :

នាមញ្ច រូបញ្ច ឥធត្ថិ សច្ចតោ
ន ហេត្ថ សត្តោ មនុជោវ វិជ្ជតិ
សុញ្ញំ ឥទំ យន្តមិវាភិសង្ខតំ
ទុក្ខស្ស បុញ្ជោ តិណកដ្ឋសាទិសោ ។

---

១ សំ. ស. ។

Comme le dit Buddhaghosa :

Seule la souffrance existe, mais nonsouffrant Seules les actes sont, mais l'acteur n'existe pas,

As Buddhaghosa says :

Mere suffering exist., but no suffer is found. The deeds are, but no doer ie found,

ប្រែថា: កុនលោកនេះ នាមនិងរូប មានពិត ប៉ុន្តែ សត្វគឺមនុស្ស មិនមានទេ ។ នាមនិងរូបនេះ ជាធម្មជាតសោះសូន្យទេ ដូចយន្តដែលជាងធ្វើឡើង, សេចក្តីពិត គ្រាន់តែជាកញ្ចប់ញត្តសម្រាប់រងទុក្ខតែប៉ុណ្ណឹងទេតើ ដូចជាស្មៅឬអង្កត់ឧសឥតខ្លឹមសារ ។

ទុក្ខមេវ ហិ ន កោចិ ទុក្ខិតោ
ការកោ ន កិរិយា វ វិជ្ជតិ
អត្ថិ និព្វុតិ ន និព្វុតោ បុមា
មគ្គមត្ថិ គមកោ ន វិជ្ជតិ ។

ប្រែថា: សេចក្តីទុក្ខ មានពិត ឯបុគ្គលរងទុក្ខ មិនមានទេ អ្នកធ្វើ (កម្ម) មិនមានទេ ឯអំពើកម្ម មាន, ការរលត់មាន, ឯបុគ្គលរលត់ មិនមានទេ, ផ្លូវដើរ មាន ឯអ្នកដើរ មិនមានទេ ។

ទុក្ខមេវ ហិ សម្ភោតិ ទុក្ខំ តិដ្ឋតិ វេតិ ច
នាញ្ញត្រ ទុក្ខា សម្ភោតិ នាញ្ញត្រ ទុក្ខា និរុជ្ឈតិ(១) ។

ប្រែថា: មានតែទុក្ខទេដែលកើតឡើង មានតែទុក្ខទេដែលតាំងនៅ មានតែទុក្ខទេដែលប្រែប្រួលទៅ ក្រៅពីទុក្ខមិនមានអ្វីដទៃកើត ក្រៅពីទុក្ខ មិនមានអ្វីដទៃរលត់ ។

---

១ សំ. ស. ។

ការវិភាគខាងលើនេះ ពន្យល់ច្បាស់ថា ការយល់ឃើញថា "មនុស្ស" "សត្វ", "បុគ្គល" ឬ "អាត្មា អញ - ឯង" ជាសេចក្ដីយល់ឃើញខុសពិត ជាធម៌ដែលចិត្តគួចកាន់អ្វីមួយ ។ ហើយប្រតិស្ឋឲ្យកើតឡើងឯកឯង ដូចជាពាក្យដែលប្រតិស្ឋហៅថា "ស្នែងទន្សាយ, ពុកមាត់អណ្ដើក" ដូច្នោះឯង គឺយើងយកចេតសិកធម៌ ៥២ ប្រការរបស់ខន្ធបញ្ចកៈ មកផ្គុំជាពាក្យមួយ ហើយសំគាល់ទទេ ៗ ថា "មនុស្ស" "សត្វ", "បុគ្គល" ឬ "អាត្មា - អញ - ឯង" ដែលព្រះសម្ពុទ្ធហៅគំនិត ឬ មនោគតិនេះ ថា "សក្កាយទិដ្ឋិ" The idea of self ។ សេចក្ដីពិត ខន្ធបញ្ចកៈនេះ រួមជាមួយគ្នា ទើបលោកហៅថា "មនុស្ស" "សត្វ" "បុគ្គល" ឬ "អាត្មា - អញ ឯង" នេះឯងជាតួ "ទុក្ខ" ដែលហៅថា "សង្ខារទុក្ខ" មិនមាន "សត្វ", "បុគ្គល" ឬ "អាត្មា - អញ ឯង" ឯណាដទៃដែលនៅក្រៅខន្ធបញ្ចកៈ ហើយដឹងសុខ ឬ ដឹងទុក្ខ នោះឡើយ ។

ដូច្នេះ យើងគប្បីយល់ថា មិនមានអ្វីដែលមិនប្រែប្រួល នៅក្រៅការប្រែប្រួលនេះទេ មានតែការប្រែប្រួលប៉ុណ្ណោះ ដែលប្រព្រឹត្តទៅ ។ ការយល់ថា ជីវិត ជាធម្មជាតកំពុងប្រែប្រួលនោះ មិនមែនជាការត្រឹមត្រូវទេ, សេចក្ដីពិត ជីវិតនេះ ជាការប្រែប្រួលក្នុងខ្លួនឯងតែម្ដង ជីវិតនិងការប្រែប្រួលនោះ មិនមែនជាធម្មជាតពីរផ្សេងពីគ្នាទេ ។ យើងអាចនិយាយ

ត្រឹមតែមួយបែបទៀតបានថា « មិនមានអ្នកគិត ក្រៅពីគំនិតនោះទេ ពោលគឺគំនិតនោះឯងហើយគឺអ្នកគិត » ។

បើយើងចង់ប្រាស់ យើងរកនូវអ្នកគិតនៅក្នុងគំនិតថា តើអ្នកគិតនៅឯណា? យើងរកមិនឃើញទេ ។ សេចក្តីនេះ យើងមិនអាចនឹងគេចឲ្យផុតពីសំដីហេតុផលនៃក្រុម ការតេសៀន Cartésien ដែលពោលទុកថា Je pense, donc je suis = I think, therefore I am (Cogito Ergo Sum) ប្រែថា « ខ្ញុំគិត នេះគឺខ្ញុំ » នោះទេ ។ ពាក្យនេះ មិនផ្ទុយពីពុទ្ធសាសនាឡើយ ។

និយាយមកដល់ត្រង់នេះ មកដល់ប្រស្នាថា ជីវិត ឬ ចិត្ត នេះមានដើមកំណើតមកពីណា ? ក្នុងពុទ្ធសាសនា ព្រះសម្ពុទ្ធទ្រង់ត្រាស់ទុកថា ជីវិតដើម ឬ ចិត្តដើម មិនមានទីបំផុតខាងដើមទេ= អនមតគ្គ ។ អ្នកដែលមានគំនិតជឿថា ព្រះអាទិទេពជាអ្នកបង្កើតជីវិតឡើងនោះ គួរតែទញទាល់ខ្លួនឯង ក្នុងការឆ្លើយរបស់ខ្លួនដែរ ។ បើយើងសួរគេ "ដូចម្តេចទៅ ដើមកំណើតអាទិទេព ?" គេនឹងឆ្លើយឥតអៀនខ្មាសឲ្យទាន់ដៃស្រង់សំដីសំនួរយើងភ្លាមថា "អាទិទេព មិនមានកំណើតទេ" គេឆ្លើយព្រោះគេឥតមានគំនិតងឿងឆ្ងល់សូម្បីតែបន្តិច នៅក្នុងចម្លើយរបស់គេនោះសោះ ហាក់ដូចជាគេយល់ថា ចម្លើយរបស់គេនេះត្រឹមត្រូវ ។ ក្នុងពុទ្ធសាសនា ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា (១) សង្សារនេះ មិនមានទីបំផុត

១- សំយុត្តនិកាយ អនមតគ្គសំយុត្ត សៀវភៅទី ៣២ ទំព័រ ៣៩ ។

ដែលយើងមើលឃើញនោះទេ ដើមកំណើតរបស់សត្វខាងដើម អន្ទោលទៅមក វិលទៅមក នៅក្នុងស្រោមអវិជ្ជា អវិជ្ជាដឹកទៅដោយអំណាចតណ្ហា គេមិនអាចនឹងដឹងបានទេ ។ អវិជ្ជានេះហើយ ជាហេតុដើម ដែលចេះតែនាំឲ្យកើតត ៗ គ្នា ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា «ដើមកំណើតអវិជ្ជា គេមិនអាចនឹងដឹងបានទេ» ។

សេចក្ដីរៀបរាប់ទាំងអស់ ដូចបានពោលមកខាងលើដោយសង្ខេបនេះ ជាអត្ថន័យដែលមាននៅក្នុងបទថា «ទុក្ខអរិយសច្ច» ។ គួរកត់សំគាល់ថា ទុក្ខអរិយសច្ចនេះ ជាធម៌មានសេចក្ដីច្បាស់លាស់វិសេសបំផុត ដូចសេចក្ដីដែលអង្គព្រះសម្ពុទ្ធត្រាស់ទុកថា(១) «អ្នកណាបានឃើញទុក្ខ អ្នកនោះឃើញទុក្ខសមុទយៈ ឃើញទុក្ខនិរោធ ឃើញទុក្ខនិរោធគាមិនីបដិបទា» ឃើញគ្រប់បរិវដ្ដ ៣ គ្រប់ទាំង ៤ ប្រការ ដោយសេចក្ដីច្បាស់លាស់ ។ ពុទ្ធសាសនិកជន មិនទំទុក្ខចំពោះជីវិត ដែលពោរពេញដោយទុក្ខ ដូចអ្នកកាន់លទ្ធិសាសនាដទៃខ្លះនិយាយបរិហារថា ជីវិតពុទ្ធសាសនិកជន ពោរពេញៈដោយទុក្ខ ចេះតែទំទុក្ខគ្រប់ពេលវេលា ព្រោះព្រះសម្ពុទ្ធជាគ្រូរបស់គេទេសនាប្រដៅថា ជីវិតនេះ សុទ្ធតែទុក្ខ ដូច្នេះទេ ។ ពុទ្ធសាសនិកជនដែលបានយល់ធម៌ពិត មានក្ដីរីករាយបំផុត មិនខ្លាច មិនព្រួយបារម្ភ ជ្រះថ្លាជានិច្ច ហើយបិតទៅដោយសន្ដិ មិនតក់ស្លុតចំពោះហេតុការណ៍ ដែល

២- សំយុត្តនិកាយ មជ្ឈិមបណ្ណាសក ឧបាយវគ្គ សៀវភៅទី ៣៣ ទំព័រ ១៣៤ ។

ប្រែប្រួល ទៅតាមធម្មតាលោកនោះទេ ព្រោះបានយល់សេចក្ដីពិតទៅតាមពិតហើយ ។ អង្គព្រះសម្ពុទ្ធ ទ្រង់មិនដែលទំទុក្ខវេទនាទេ ទ្រង់តែងសម្រេចព្រះឥរិយាបថតាមប្រក្រតី មានព្រះភក្ត្រស្រស់ញញឹមប្រិមប្រិយជានិច្ច (មិហិតបុព្វង្គម) សូម្បីតែរូបចម្លាក់ រូបគំនូរ ក៏ជាងតែងតែធ្វើព្រះភក្ត្រញញឹមស្រស់ប្រកបដោយមេត្តា(១) ។ គម្ពីរដីកាពុទ្ធសាសនា ដូចថេរគាថាឬថេរីគាថា មាននិទានច្រើនណាស់ ដែលនិយាយពីពុទ្ធសាសនិកជនទោះជាបុរស ឬស្រី, ទោះជាភិក្ខុ ឬភិក្ខុនី, ទោះជាឧបាសក ឬឧបាសិកាតែងមានចិត្តតាំងនៅក្នុងក្ដីស្ងប់ក្សេមក្សាន្ត ពណ៌សម្បុរស្រស់បំព្រង ព្រោះបានឃើញធម៌ហើយ ។ នៅក្នុងក្ដីស្ងប់ក្សេមក្សាន្ត ពណ៌សម្បុរស្រស់បំព្រង ព្រោះបានឃើញធម៌ហើយ ។

ព្រះបាទបសេនទិកោសល ទ្រង់ស្ងើចព្រះរាជហឫទ័យបំផុតហើយលាន់ព្រះឱស្ឋត្រាស់ចំពោះព្រះភក្ត្រ ព្រះភគវាថា:

( នៅមានត )

---

១- មើលការរចនា ពុទ្ធសាសនាបែបគន្ធារៈ ចិន ជពុន ព្រះភក្ត្រអង្គរធំ Sourir d' Angkor -

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ - កន

ប្រែ ~ រៀបរៀង

## (ក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកភាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ
>
> យូ-អ៊ុន

អស់នាម៉ឺនមុខមន្ត្រីទាំងពួងឆ្លើយថា: លោកជាមហាឧបរាជសម្រេចរាជការ មានសតិបញ្ញាជ្រៅទូលាយណាស់ លោកបានត្រិះរិះយល់សមគួរយ៉ាងណា ហើយមកប្រឹក្សាតើនរណានឹងអាចទទឹងអធ្យាស្រ័យលោកបាន ព្រោះលោកបានប្រសាសន៍នេះគួរនឹងការរាជការផែនដី, សុម៉ាស៊ូក៏នាំនាម៉ឺនមុខមន្ត្រីទាំងនោះ ចូលទៅគាល់ព្រះនាង គួយថាយហៅទូលស្នើតាមសេចក្ដីដែលយល់ឃើញថ្វាយព្រះសណ្ដាប់គ្រប់ប្រការ, ព្រះនាងគួយថាយហៅ ក៏សួរថា: បើដូច្នោះអស់អ្នកនឹងលើកយកនរណាឡើយជាម្ចាស់ផែនដីវិញ? សុម៉ាស៊ូទូលថា ទូលព្រះបង្គំជាខ្ញុំពិគ្រោះមើលឃើញថាចូតីជាពូជព្រះរាជវង្ស សក្តូថៃ នៅធ្វើជាចៅហ្វាយស្រុកផៃសៀ, ឈ្មោះជាមនុស្សមានសតិបញ្ញាឆ្លៀវឆ្លាតមុតមាំណាស់ ឃើញគួរនឹងធ្វើជាអម្ចាស់ផែនដីបាន ។

ព្រះនាងគួយថាយហៅឆ្លើយថា: មិនគួរទេ, យើងពិគ្រោះមើលទៅឃើញថានឹងយកមាមកសោយរាជ្យជំនួសក្ស័យនោះ មិនត្រូវនឹងទំនៀមទម្លាប់សណ្ដាប់ប្រវេណី យើងឃើញថា: ពាប់ក្ស័យព្រះចៅចូក៏ជាចៅហ្វាយស្រុកង្គួនសៀ ឆ្លាតឆ្លៀវមានសតិបញ្ញាល្អនឹងរក្សាផែនដីបាន សុំឲ្យអ្នកទាំងពួងប្រឹក្សាគ្នាមើលចុះ សុម៉ាស៊ូទូលតបថា: ដែលទ្រង់មានព្រះសវនីយនោះប្រពៃណាស់ ដែលនឹងលើករាជសម្បត្តិឲ្យបូម៉ានោះឃើញសមគួរហើយ អស់នាម៉ឺនមុខមន្ត្រីក៏យល់ឃើញព្រមគ្នា, សុម៉ាស៊ូក៏ប្រើបរិវារកាន់សំបុត្រទៅអញ្ជើញចូម៉មក ហើយទូលព្រះនាងគួយថាយហៅថា: សុំអញ្ជើញព្រះអង្គយាងឡើងទៅលើសាលានិយាយរាជការ នឹងបានប្រឹក្សាទោសព្រះចៅចូហាន ។

ព្រះនាងគួយថាយហៅក៏ចូលទៅអញ្ជើញព្រះចៅចូហានចេញមកគង់លើសាលានិយាយរាជការ ហើយព្រះនាងត្រាស់ថា: ចៅបានសោយរាជសម្បត្តិ ប្រព្រឹត្តមិនត្រូវតាមគន្លងធម៌ នឹងទម្លាប់ទំនៀមក្សត្រិយ៍អំពីបូរាណ ប្រព្រឹត្តខ្លួនប្រាណ ជាមនុស្សអន្ធពាលស្រើបស្រាលដោយល្បែងស្រាល្បែងស្រី មានប្រក្រតីស្រវឹងជានិរន្តរ៍ មិនសមគួរជាម្ចាស់ផែនដី គឺគ្មានយកហឫទ័យទុកដាក់នឹងសេចក្ដីសុខទុក្ខអាណាប្រជានុរាស្ត្រសោះ ដែលធ្វើដូច្នោះនឹងតាំងនៅជាម្ចាស់ផែនដីតទៅទៀតពុំសមគួរ វេលានេះ អស់នាម៉ឺនមុខមន្ត្រីធំតូចពលនា គេបានប្រឹក្សាជុំនុំយល់ព្រម

ឃើញថា ខ្លួនទៅនឹងនៅជាម្ចាស់ផែនដីតទៅទៀតពុំបានទេ ត្រូវតែទៅនាំយកព្រះសែងគ្របី និងគ្រាសម្រាប់រាជ្យ មកប្រគល់ឲ្យនាម៉ឺនគេចុះ គេនឹងបានលើកយករូបមនុស្សដទៃ ដែលមានសតិបញ្ញាឲ្យឡើងសោយរាជសម្បត្តិជាម្ចាស់តទៅ ឯខ្លួនទៅត្រូវវិលទៅទទួលនាទីរាជការជាទីបើអង តាមលំនាំព្រះបិតាតាំងទុកពីដើមនោះចុះ បើមិនមានព្រះតម្រាស់ឲ្យហៅទេ មិនត្រូវចូលគាល់ឡើយ, ចូហាងក៏យកព្រះសែងគ្របី និងគ្រាសម្រាប់រាជ្យមកប្រគល់ហើយ ក៏ក្រាបបង្គំលាព្រះនាងគួយថាយហៅយំហើយដើរចេញទៅ, មាននាម៉ឺន ៤-៥ នាក់ នឹករលឹកដល់គុណចូហាងអត់ទប់ចិត្តពុំបានក៏នាំគ្នាយំហើយតាមជូនទៅ ចូហាងក៏នាំគ្រប់គ្រួចេញទៅនៅទីដំណាក់ដើមនៃខ្លួន ។

ឯចូម៉ចូលមកដល់ទិសខាងជើង, សុម៉ាស៊ីក៏ចាត់អស់នាម៉ឺនមុខមន្ត្រីធំតូចឲ្យចេញទៅទទួល អស់នាម៉ឺនទៅដល់ក៏ធ្វើគំនាប់, ចូម៉ចុះពីលើរទេះសេះហើយ ក៏ធ្វើគំនាប់អស់នាម៉ឺនទាំងពួង, អកសុខជានាម៉ឺនធំម្នាក់និយាយថា: ព្រះអង្គកុំធ្វើគំនាប់អស់យើងខ្ញុំម្ចាស់ឡើយ, ចូម៉តបថា: ខ្លួនខ្ញុំនេះក៏ជាខ្ញុំផែនដីនឹងមិនគំនាប់អស់លោកក៏មិនគួរ នោះអស់នាម៉ឺនក៏នាំគ្នាពចូម៉ដាក់លើរទេះបះចូល ទៅក្នុងព្រះរាជវាំង, ចូម៉នៅគោតក្រែងមិនព្រមជិះរទេះ នោះមានព្រះតម្រាស់ព្រះនាងគួយថាយហៅឲ្យចូម៉ចូលគាល់ ចូម៉ថា បើដូច្នោះនឹងជិះរទេះចូលគាល់ឃើញថាមិនសមគួរសោះ ថាហើយចូម៉ក៏ដើរទៅដល់ តែដល់ព្រះរាជវាំង, សុម៉ា

ស៊ូវឃើញដូច្នោះក៏ចេញទៅទទួលគំនាប់ ចូម៉ក៏ក្រាបចុះ ស៊ុម៉ាស៊ូទាញ
ដៃចូម៉ឲ្យក្រោកឡើងហើយទើបប្រស្រ័យថា ៉ លោកបានសេចក្ដីសុខ
សប្បាយទេឬ? ថាហើយក៏នាំចូលទៅគាល់ព្រះនាងគួយថាយហៅ ។
ត្រាស់ថា: កាលនៅពីតូច យើងបានពិគ្រោះមើលឃើញឫក ទាំងកិរិ-
យាមារយាទនិងលក្ខណៈកសីល្អណាស់ ឫកខុសពីក្មេងទាំងពួង យើង
ក៏នឹកតែក្នុងចិត្តថា ទៅថ្ងៃនឹងបានជាម្ចាស់ផែនដីប្រាកដឥឡូវឃើញពិត
ដូចគំនិតនឹកទុក, វេលានេះ អស់នាម៉ឺនមុខមន្ត្រីជំនុំយល់ព្រមគ្នា គួរ
ឲ្យទៅសោយរាជសម្បត្តិ តពូជព្រះរាជវង្ស បើទៅបានជាម្ចាស់ផែនដី
ហើយ ចូរតាំងនៅក្នុងសត្យសុចរិតឧស្សាហ៍យកចិត្តទុកដាក់ក្នុងកិច្ចរាជ-
ការទាំងពួង បើនឹងធ្វើការអ្វីគប្បីឲ្យពិគ្រោះឲ្យម៉ត់ចត់ល្អ ឲ្យដឹងច្បាស់
ក្នុងខុសត្រូវទោសគុណធ្ងន់ស្រាល កុំស្រវឹងពេលកលទៅដោយការ
លេងល្បែងពាលមានស្រានិងស្រីជាដើម ចូរប្រព្រឹត្តខ្លួនតាមទំនៀម
ទម្លាប់ច្បាប់បុរាណរាជប្រវេណី ដែលជាទីវង្សក្សត្រិយ៍សោយរាជសម្បត្តិ
តាំងមកពីដើម ។

ចូម៉ទូលតបថា: ទូលព្រះបង្គំជាខ្ញុំនេះ មានសតិបញ្ញាតិចណាស់
មិនគួរនឹងស្នងស្នះទទួលនូវរាជសម្បត្តិបានទេ? ព្រះនាងគួយថាយហៅ
នូវអស់មុខមន្ត្រីក៏មិនស្ដាប់ ចេះតែលួងលោមអញ្ជើញដល់បីគ្រា ទើប
ចូម៉ទទួល? ស៊ុម៉ាស៊ូនិងអស់នាម៉ឺនមុខមន្ត្រីទាំងពួង ក៏ព្រមគ្នាអញ្ជើញ

ប៉ូម៉ទៅគាល់ព្រះទីនាំងចុងព្រះរាជរោងរម្យ ទើបលើកថ្វាយនូវព្រះសែង គ្រប់ និងត្រាសម្រាប់រាជ្យឲ្យប៉ូម៉ៗ ក៏បានតាំងនៅក្នុងសម្បត្តិក្សត្រិយ៍ តាំងពីថ្ងៃនោះមក ទើបថ្វាយព្រះនាមថា ព្រះចៅចេងធួន(ព.ស.៧៩៧) ព្រះចៅប៉ូម៉ក៏ទ្រង់បើកលែងមនុស្សទោសទាំងអស់ ហើយលើកលែង យកពន្ធសួយសារអាករទាំងពួងតាមបុរាណរាជប្រវេណីក្សត្រិយ៍ ដែល សោយរាជសម្បត្តិបីរៀងមកនោះ ហើយតាំងសុម៉ាស៊ូជាមហាឧបរាជ កាលបើចូលគាល់ឲ្យមានមនុស្សកាន់គ្រឿងសាស្ត្រាវុធហែចូលទៅ លុះ ដល់ជិតទីស្តេច ហើយហាមមិនឲ្យថ្វាយបង្គំ គ្រាន់តែធ្វើគំនាប់ហើយ អង្គុយចុះ លុះទឹងពិតទូលពីការអ្វីក៏ហាមមិនឲ្យបញ្ចេញនាមខ្លួនដូចមន្ត្រីទាំង ពួង ហើយឲ្យនាម៉ឺនទាំងពួងធំតូចលើងទីតាមគុណបំណាច់ ៗ·

ព្រះចៅប៉ូម៉សោយរាជ្យបាន ២ ឆ្នាំ ។ លុះដល់ខែមាឃ ប៉ូយ៉ីរទៀម ពួកស្រុកហោឡាំទៅឈរធ្វើចៅហ្វាយស្រុកគេងជីវ បានស្រដីត្រូតលើ ខែគ្រហូយឡាំ, ខែគ្រឈើវល្លិផង; លុះដឹងថាសុម៉ាស៊ូ អហង្ការនិរទេសម្ចាស់ផែនដីចេញហើយ យកអ្នកឯទៀតមកតាំងឡើងតាមអំពើចិត្ត ឯង ក៏មានសេចក្តីខឹងខ្លាំងណាស់, នោះប៉ូយ៉ីរទៀនជាបុត្រនិយាយនឹង បិតាថា: លោកអាពុកបានជាចៅហ្វាយស្រុក មានយសស័ក្តិអាជ្ញាសិទ្ធិនៅក្នុងដៃ ដែលសុម៉ាស៊ូធ្វើដូច្នេះ យើងនឹងស្ងៀមមិនគួរទេ ៗ

ប៊ូយីរទៀមថា: ដែលទៅនិយាយដូច្នេះប្រពៃណាស់ ទើបឲ្យអញ្ជើញប៊ុនយឹម ដែលជាប័ក្ខពួករបស់ចូសង់ មកខាងក្រោយផ្ទះជាទីស្ងាត់ ផ្ទឹតនាប់គ្នាហើយក៏អង្គុយនៅមិនទាន់និងបរបាគ្នាក៏យំសោកាល័យ ប៊ូយិមសួរថា: ហេតុអ្វីបានជាយំ, ប៊ូយីរទៀមក៏ប្រាប្ពរឿងទាំងពួងឲ្យស្ដាប់ហើយថា ហេតុដូច្នេះបានជាខ្ញុំមានសេចក្ដីឈឺចិត្តណាស់,ប៊ុនយិមថា:លោកគិតធ្វើការបំរុងផែនដីដូច្នេះគួរណាស់ហើយ, ខ្ញុំបាទនឹងជួយឲ្យអស់ពីចិត្ត បុត្រខ្ញុំបាទម្នាក់ឈ្មោះប៊ុនសេកមានកំឡាំងច្រើនណាស់, គាបកស៊ូនឹងមនុស្ស ១០-០០០នាក់បាន រាក៏ខឹងក្ដៅណាស់ដែរ គិតតែនឹងកំចាត់សុម៉ាស៊ីចេញ ដើម្បីសងសឹកជួសចូសង់ ចេះយើងនឹងលើកទ័ពទៅ ត្រូវតាំងរាជាមេទ័ពមុខ ៗជានឹងមានជ័យជំនះសត្រូវជាប្រាកដ; ប៊ូយីរទៀមឮដូច្នោះក៏មានចិត្តអំណរណាស់, ទើបចាក់សុរាដាក់ពែងហើយលើកឡើងតាំងសត្យាធិដ្ឋានស្បថស្បាទគ្នា ហើយឲ្យទៅបញ្ចុះបញ្ចូលនាយទាហានស្រុកហ៊្លួយឡាំថា: នាងគួយតាយហៅមានព្រះតម្រាស់បង្គាប់ឲ្យទាហានទាំងពួង ទៅឲ្យព្រមគ្នាដល់ស្រុកឈើវឈុន, លុះទាហានទាំងអស់ចូលទៅព្រមគ្នាហើយ ក៏ឲ្យតាំងពេធីខាងទិសបស្ចិមឲ្យសម្លាប់សេះស ១ យកឈាមមកកូរលាយទឹកស្រាក៏ខូសបួឲ្យទាហានទាំងពួងផឹកហើយថា សុម៉ាស៊ីរាក្សត់ទឹងផែនដី, នាងគួយតាយហៅមានព្រះតម្រាស់បង្គាប់មកឲ្យយើង:លើកទ័ពទៅកំចាត់សុម៉ាស៊ីចេញ អស់ពល

ទាហានបានឮដូច្នោះក៏មានសេចក្ដីត្រេកអរណាស់ ព្រមចិត្តគ្នាដែលនឹងកំចាត់សុម៉ាស៊ូ, ប៊ូឃីវខៀមក៏នាំទាហាន ៥០.០០០ លើកទៅតាំងនៅស្រុកហាងសៀ, ប៊ុនយឹមនាំទាហាន ២០.០០០ ជាទ័ពណូន, ប៊ូឃីវខៀមមានសំបុត្រទៅដល់អាណាខែត្រឡើងឲ្យលើកទាហានមកជួយ ។

ឯសុម៉ាស៊ូឈឺភ្នែកជា (ខ្លាំង) ឲ្យពេទ្យទៅកាត់ហើយដាក់ថ្នាំរក្សាជាយូរថ្ងៃទទួលបំរើសេះទៅប្រាប់ថា: កងទ័ពស្រុកហ៊ួយឡាំលើកមក នោះសុម៉ាស៊ូក៏ឲ្យអញ្ជើញអងសុកជានាម៉ឺនធំចូលមកប្រឹក្សាថា: ដ្បិតកងទ័ពប៊ូឃីវខៀមលើកមក តើយើងនឹងរិះគិតប្រការម្ដេច, អងសុកថា: កាលគ្រាគួនអ៊ូជាទាហានឯក មានថ្វីដៃខ្លាំងពូកែប្រាកដខ្ទរទាំងផែនដី, លីបងរិះគិតបញ្ចុះបញ្ចូលគ្រប់គ្រួទាហាន ដែលនៅក្នុងស្រុកកេងជីវបានហើយក៏មានជ័យជំនះដល់គួនអ៊ូ គ្រានេះខ្ញុំគិតថានឹងឲ្យទៅបញ្ចុះបញ្ចូលគ្រប់គ្រួទាហានឯស្រុកហ៊ួយឡាំ ដែលនៅក្នុងដែនស្រុកវុយកុក · បើបានហើយយើងនឹងលើកកងទ័ពទៅតាំងស្កាត់ទុកនៅផ្លូវប៊ូឃីវខៀមគង់នឹងត្រឡប់ទៅឯង យើងគង់មានជ័យជំនះជាប្រាកដ ។

សុម៉ាស៊ូថា: អ្នកនិយាយនេះត្រូវណាស់, តែថាខ្ញុំនៅឈឺនឹងទៅឯងមិនបាន ដែលនឹងឲ្យមនុស្សដទៃទៅជំនួស ខ្ញុំក៏មិនទុកចិត្តជាបានការក្រែងធ្វើឲ្យខូចការទៅ, ចុងហោយនាយទាហានធំឆ្លើយថា: ទាហានស្រុកហ៊ួយឡាំខ្លាំងពូកែណាស់ ដែលនឹងឲ្យអ្នកដទៃទៅជំនួសក្រែងនឹង

តទល់មិនឈប់ ការគ្រានេះជាការធំបើខុសគ្នាត់ហើយនឹងខូចរាជការទៅ សុម៉ាស៊ីក៏មានះក្នុងចិត្តក្រោកឡើងឈរហើយថា ខ្ញុំឈឺប៉ុណ្ណេះមិនទាន់ជាអ្វីប៉ុន្មានទេ ត្រូវតែទៅខ្លួនឯងទើបបានការ ថាហើយក៏ឲ្យសុម៉ាចៀវនៅរក្សាស្រុក ទើបឲ្យជូកាត់ចុននាយទាហានជាមេទ័ពស្រុកអ៊ីជីវលើកទៅវាយស្រុកឈើរឈុន, ឲ្យគាវជុននាយទាហានជាមេទ័ពស្រុកសេងជីវលើកទៅស្កាត់នៅដំបន់ចៀវសេងជាផ្លូវសត្រូវនឹងត្រឡប់ទៅ, ឲ្យអេងទីនាយទាហានទៅវាយដំបន់ទិនទ្យាំ ឯខ្លួនសុម៉ាស៊ីជាមេទ័ពលួង ជិះរថលើកទ័ពទៅតាំងនៅក្នុងស្រុកសុងយ៉ុង, នាម៉ឺននឹងទាហានទាំងពួងអង្គុយព្រមគ្នារិះគិតការដែលនឹងឲ្យមានជ័យជំនះដល់សត្រូវ ។

គេងប៉ោទីប្រឹក្សាថា: ប៊ួយវិទៀមនោះ មានសតិបញ្ញាចេះរិះគិតណាស់តែថានឹងរិះគិតការអ្វីក៏មិនហ្វូតទៅបាន, ឯចុនឃឹមមានកំឡាំងច្រើន តែថាគ្មានប្រាជ្ញាទីងគំនិតសោះ, ឯទាហានស្រុកហ្វួយទ្យាំមានថ្វីដៃខ្លាំងពូកែក្លាហានណាស់ យើងនឹងធ្វើក្ដីក្ដៈមិលងាយនោះមិនបានទេ, សុំឲ្យរក្សាបន្ទាយគូទុកឲ្យមាំមួនបើយើងឃើញកំឡាំងសត្រូវថមថយហើយសឹមរិះគិតវាយឲ្យខ្ទេចខ្ទីកុំឲ្យដឹងខ្លួនទាន់ឡើយ ៕

អងគីវា: កងទ័ពក្បត់លើកមកគ្រានេះ មិនមែនទាហានទាំងពួងមានចិត្តរិះគិតមកឯងទេ, ជាហេតុព្រោះប៊ួយវិទៀមរិះគិត ទាហានទាំងពួងទទីងមិនក្លានក៏ហាំចិត្តគិតតែមក, បើយើងលើកទ័ពចេញទៅវាយ ក៏ឃើញថាទា

ហានតាំងពួនទឹងក្វួយកេខ្វាត់ខ្វាយទៅ, សុម៉ាស៊ីថា អ្នកនិយាយនេះត្រូវណាស់ក៏លើកកងទ័ពល្ហួងរំកិលចូលទៅបោះនៅទីស្ថានអ៊ុនស៊ុយ, អងគីថា: ស្រុកឡាំតេងនោះ ជាទីចំណាប់ខ្វាប់ខ្ជួនណាស់, យើងត្រូវស្រូតរូតលើកទៅតាំងនៅទីនោះសិន, បើចង្អុងឲ្យយួរទៅសត្រូវមកតាំងមាំជាមុនហើយ យើងនឹងតារទំលាយយកដោយកម្រ, សុម៉ាស៊ីយល់ឃើញត្រូវផង ក៏ឲ្យអងគីនាយទ័ពមុខលើកទៅតាំងបន្ទាយនៅដែនកំពែងស្រុកឡាំតេង ។

ប៊ូយ៉ីវៀមតាំងទ័ពនៅស្រុកអងសៀងដឹងថា សុម៉ាស៊ីលើកទ័ពមកទើបប្រឹក្សានឹងតាហានតាំងពួន នោះកាន់យ៉ុងនាយតាហានកងមុខថា ឯទីស្រុកឡាំតេងនោះ មានភ្នំនឹងទន្លេខ្ទប់ជុំជាទីមាំមួនណាស់, បើពួកសុម៉ាស៊ីតាំងនៅមុនហើយ មុខជាយើងធ្វើការបានដោយកម្រណាស់ សុំឲ្យលោកបន្ទំលើកកងទ័ពទៅតាំងនៅទីនោះឲ្យបានជាមុនទើបស្រួល ។

ប៊ូយ៉ីវៀមក៏ឲ្យលើកកងទ័ពទឹងទៅស្រុកឡាំតេង ទៅមួយស្របក់មានបំរើសេះមកប្រាប់ថា ស្រុកឡាំតេងនោះ តាហានសុម៉ាស៊ីទៅតាំងនៅទីនោះហើយ ប៊ូយ៉ីវៀមនៅមិនទាន់ជឿ ក៏លើកកងទ័ពទៅជិតដល់ឃើញមាន ន្ទាយមាំមួនណាស់ មានទង់ជ័យ:ជាតភាយជុំវិញ, ប៊ូយ៉ីវៀមឃើញដូច្នោះក៏ថយទ័ពត្រឡប់ទៅតាំងបន្ទាយនៅកណ្ដាលផ្លូវ បំរើសេះមកប្រាប់ថា ទ័ពស៊ុនជុនស្រុកកាំងតាំង លើកចូល[illegible]នអកទឹងភាយ

ស្រុកឈើឈុន, ប៊ូយីវៀមតិយណាស់ ថាបើស្រុកឈើឈុនជាអន្តរាយហើយ តើយើងនឹងត្រឡប់ទៅនៅទីឯណា ថាហើយក៏រំសាយទ័ពទៅក្នុងពេលកណ្តាលយប់នោះ លើកទៅតាំងនៅស្រុកហានសៀ ។

ស៊ុម៉ាស៊ូដឹងថា ប៊ូយីវៀមរំសាយទ័ពថយផុតទៅហើយ ក៏ឲ្យហៅនាម៉ឺនមុខមន្ត្រីចូលទៅប្រឹក្សា ម៉ៅតានដឹងថា ប៊ូយីវៀមរំសាយទ័ពទៅគ្រានេះ ព្រោះខ្លាចកងទ័ពស្រុកកាំងតាំងនឹងលើកធ្លាក់មកពីក្រោយទៅវាយស្រុកឈើឈុន ឃើញចំនួននឹងរំសាយទ័ពទៅនៅស្រុកហានសៀ ហើយនឹងបង្វិលកទាហានឲ្យទៅរក្សាស្រុកឈើឈុន, សុំឲ្យលោកចាត់ទាហានលើកទៅជាពួកទៅវាយ ស្រុកផាក់កៃសៀ, ស្រុកហានសៀ, ខ្ញុំបាទឃើញថាទាហានស្រុកហ៊ួយឡាំក៏នឹងថយទ័ពទៅឯង, លោកប៊ូធ្វើសំបុត្រទៅដល់គេងង៉ាយចៅហ្វាយស្រុកកុនជីវ ជាមនុស្សមានសតិបញ្ញាប៉េះប៉ះគិត ឲ្យលើកទៅជួយវាយស្រុកផាក់កៃសៀ បើបានហើយឃើញថានឹងប្រាប់ដោយងាយ ស៊ុម៉ាស៊ូយល់ឃើញត្រូវ ក៏ឲ្យសំបុត្រទៅដល់គេងង៉ាយថា ឲ្យលើកកងទ័ពទៅវាយស្រុកផាក់កៃសៀ យើងនឹងលើកតាមទៅផង ។

ឯប៊ូយីវៀមតាំងទ័ពនៅស្រុកហានសៀ ខ្លាចកងទ័ពស៊ុម៉ាស៊ូនឹងលើកទៅវាយ ក៏ឲ្យបំពេរសេះទៅស៊ើបល្បាតស្តាប់ដំណឹងរឿយៗ ហើយឲ្យអញ្ជើញប៊ុនប៉ែមមកក្នុងបន្ទាយហើយប្រឹក្សាថា ខ្ញុំក្រែងស៊ុម៉ាស៊ូនឹងលើក

ទៅវាយយកស្រុកឆាក់កែសៀ; ប៊ុនយើងថា ខ្ញុំបាទទឹងប៊ុនអេងសុំទាហាន ៥០០០ ទឹងលើកទៅតេក្បាស្រុកឆាក់កែសៀទុកឲ្យបាន លោកកុំព្រួយឡើយប៊ូយើរទៀមមានអំណរណាស់, ចៅពាក់ប្រើប៊ុនអេងអាពុកទឹងកូននាំទាហាន៥០០០ចេញទៅ លុះទៅដល់ជិតមានបំរើសេះមកប្រាប់ថា កងទ័ពស្រុកវៀកុកលើកមកមានទាហានប្រហែល១០០០០ប៉ាយ មកតាំងនៅទិសឯលិច មានទង់សជោតជាសំគាល់ ទឹងទង់ជ័យទាំងពួងនោះ ឃើញថាមិនមែនកងទ័ពនាយទាហាន ឃើញថាជាកងទ័ពស្ដេចលើកមក, តែថាទង់សំគាល់ជាឈ្មោះសុម៉ាស៊ូ ឥឡូវតាំងបន្ទាយនៅឡើយមិនទាន់ស្រេច; ប៊ុនអេងជិះសេះឈរនៅជិតនិយាយទឹងបិតាថា គេកំពង់តាំងបន្ទាយមិនទាន់ស្រេច បើយើងលើកទ័ពទៅជា២កងវាយប្រសព្វខ្ចប់មុខជាទឹងបែកបានដោយងាយ បិតាទើបសួរថា យើងទឹងលើកទ័ពទៅពេលណាល្អ; ប៊ុនអេងថា លើកទៅពេលយប់នេះទុំងបានចំណាប់ល្អ បិតានាំពលកណ្ដាលលើកទៅទិសខាងត្បូង ខ្ញុំបាទទឹងពលពាក់កណ្ដាលទៅវាយខាងទិសឯជើង បើដល់ពេលកណ្ដាលអធ្រាត្រឲ្យលើកចូលវាយឲ្យព្រមគ្នា លុះវេលាយប់ក៏លើកពលញែកទៅតាមដែលគិតគ្នានោះ ឯប៊ុនអេងនោះអាយុបាន១៨ឆ្នាំ កំពប់ ៦ ហត្ថ ពាក់ក្រិសសៀតដំបងដែក ជិះសេះយន្តចូលទៅជិតបន្ទាយសុម៉ាស៊ូ ។

( នៅមានត )

# កវីទស្សនៈ

ចំពោះ

បញ្ហាស្នេហារវាងបុរសនិងស្ត្រី

ផល ~ និត

- ពាក្យ ៧ -

បើគេទន្ទេញបញ្ចេញពាក្យថា    "ស្នេហា ស្នេហា!" នេះយ៉ាងខ្លី
អ្នកផងនឹកភ្លាំងជាំងឃើញអ្វី    គឺ "ស្នេហាស្ត្រីនិងបុរស" ។
លើកឡើងពលស្នេហានេះ    កម្រិតណាអេះ? ទើបនិទស្សន៍
បញ្ចេញជា "បញ្ហា" សារៈខ្ពស់    គួរជនទាំងអស់ពិគ្រោះក្រើ ។
គេថា មនុស្សមានចិត្តឥតស្នេហា    ដូចជាសុរិយាឥតរស្មី
គឺថា ស្នេហានាំប្រុសស្រី    ទុកជារស្មីនៃពួកមនុស្ស ។
គេថា មិនត្រូវលោកក្រឹត្យ    ឃ្លាងពានប្រព្រឹត្តស្នេហាខុស
គឺថា: តាមច្បាប់ធម្មជាតិមនុស្ស    ស្រីប្រុសត្រូវមានសិទ្ធិស្នេហា ។
គេថា ទោះមេឃរលំក្នុងរលាយ    ក៏យើងឥតណាយចិត្តពីគ្នា
គឺថា តម្លៃនៃស្នេហា    ធ្ងន់ប៉ុនគ្នានឹងជីវិត ។
គេថា រាល់ឥតសុខមង្គល    ប្រសិនខ្វះផលស្នេហាពិត
គឺថា ស្នេហាជាតុសិត    ព្រោះព្រំជិតឲ្យសុខសាន្ត ។
គេថា អ្នកកាត់ផ្តាច់ស្នេហា    ឈ្មោះថាជាអ្នកធ្វើបាបប្រាណ
គឺថា ស្នេហាជាល័ក្ខបាន    នាំមនុស្សឲ្យបានសេរីភាព ។

នេះជាទស្សនៈមនុស្សលោកយើ　ទាញញាក់កវីឲ្យលៃកាព្យ
ល្បងដោះបញ្ហាលោកសភាព　នាំមកជម្រាបមិត្រអ្នកអាន ៗ
ចុះអ្វីទៅហ៎! ជា «ស្នេហា»?　នេះជា «បញ្ហា» ឃ្លាប្រមាន
ដើម្បីនឹងឆ្លើយឲ្យត្រូវបាន　ទាល់តែញែកជាខលំអានធាតុ ៗ
ក្នុងលោក ធាតុពីរគឺញីឈ្មោល　ជាគោលគុំផ្សំពូជជាតិ
អ្នកវិទ្យាសាស្ត្រច្បាស់ខាងធាតុ　ចេញទ្រឹស្តីរាំទស្របគ្នាថា =
ធម្មជាតិផ្ទៃទៅនៅក្នុងលោក　ជាផលសំយោគរវៃផ្លា
គឺធាតុញីឈ្មោលមូលមិត្រគ្នា　ទើបកើតបានជាអាត្មាប្រាណ ៗ
បុប្ផជាតិ, រុក្ខជាតិ ឬវល្លិ៍ស្មៅ　សាយពូជទិត្យនៅនាសព្វឋាន
ក៏មានញីៈឈ្មោលយោលយោគប្រាណ　ទើបអាចកើតបានជាពូជថ្មី ៗ
ឯសត្វតិរច្ឆានទិងប្រាណមនុស្ស　ក៏មិនផ្សេងខុសពីឈ្មោលញី
តែមនុស្សគេហៅថា «ប្រុសស្រី»　គ្រាន់ជាសម្តីរៀវថ្លៃខ្ពស់ ៗ
ដូច្នេះ ធម្មជាតិរៀតបង្កើត　ជាដើមកំណើតអ្វីទាំងអស់
ឲ្យមានលក្ខណៈជាធាតុរស់　គូគូទាំងអស់គឺប្រុស-ស្រី ៗ
ចុះហេតុបង្កើតធាតុពីរនេះ　បើត្រិះរិះតើប្រយោជន៍អ្វី?
អាចឆ្លើយភ្លាមថា ធាតុប្រុសស្រី　បង្កើតដើម្បីផ្សំជាពូជ ៗ
[illegible]តិចតិចត្រៅថែមទៅទៀត　គេអាចយល់ស្មៀន[illegible]យោខ្ទប
នៃធម្មជាតិ[illegible]ជាពូជ　មានៈហេតុ[illegible] =

ធម្មជាតិជាអ្នកឲ្យកំណើត បង្កបង្កើតដើមពូជផៅ
នៃអស់អ្វីៗផងទូទៅ ដែលបិតទិត្យនៅនាគតលោក ។
លុះបង្កើតបានប្រាណអ្វីៗ ពាសពេញលោកិយថ្លៃសំយោគ
រួចហើយធម្មជាតិប្រើស្នៀតបោក ឲ្យប្រាណក្នុងលោកសានពូជ-គ ។
គឺហាក់ដូចជាប្រើកលល្បិច ពោលការកិច្ចជាអ្នក-ក
ហើយផ្ទេរវេរផ្ទុកកិច្ចកម្ម នេះតឲ្យទៅគ្រប់អ្វីៗ ។
ឲ្យអស់ទាំងអ្វីៗក្នុងលោក នោះធ្វើសំយោគតវេសី
បង្កើតពូជពារនាលោកិយ បន្តជាថ្មីដោយខ្លួនឯង ។
ប៉ុន្តែ ដើម្បីអ្វីទាំងនេះ អាចបេះសានពូជដូចថ្វាថ្លែង
ធម្មជាតិក៏ច្នៃលៃតាត់តែង តែកតែងជាជាតិធាតុពីរយ៉ាង ។
គឺធាតុញីមួយ , ធាតុឈ្មោលមួយ ឲ្យរួមគ្នាជួយកម្លាំងសាង
កាលធាតុពីរនេះប៉ះគ្នាភ្លាង ទើបកើតជាកងរូបគ្រប់មុខ ។
អស់ទាំងអ្វីៗដែលជាញី នាទីត្រូវតែធាតុញីទុក
អ្វីៗជាឈ្មោលក៏ទំនុក តែធាតុឈ្មោលទុកក្នុងអង្គប្រាណ ។
លុះធាតុទាំងពីររស់រៀនកប មានលទ្ធភាពកពូជបាន
អ្វីៗញីឈ្មោលទាំងប៉ុន្មាន ជាយានដឹកនាំទៅផ្សំគ្នា ។
ចំពោះសារពើឈើទាំងឡាយ កាលផុះត្រសាយហើយចេញផ្កា
ធាតុឈ្មោលក្នុងលំអងបុប្ផា ទៅផ្សំនិងផ្កាមានធាតុញី ។

ទើបផ្កាញីនោះក្លាយជាផ្លែ មានពូជហូរហែប្រពៃណី
បើគ្មានធាតុឈ្មោលចូលធាតុញី នាទីផ្កានោះអស់ផ្លែពិត ។
ឯសត្វតិរច្ឆាននិងប្រាណមនុស្ស មិនខុសពីគ្នាជាបរិត
ត្រូវផ្សំធាតុពីរជាកំហិត ទើបផ្តិតផ្តួចផ្តើមជារូបប្រាណ ។
ប្លែកតែវិស័យព្រៃព្រឹក្សា ឥតមានចលនាដេកដើរបាន
ត្រូវពឹងសត្វល្អិតឬខ្យល់ប្រាន ទើបប្រាណធាតុឈ្មោលចូលធាតុញី ។
ឯមនុស្សសត្វវិញមិនបែត្តិ មិនបាច់ពឹងសត្វឬខ្យល់អី
អាចពឹងសកម្មភាពឃាតខ្លី នៃប្រាណប្រុសស្រីផ្ទាល់តែម្តង ។
តើមនុស្សទាំងឡាយសប្បាយចិត្ត នឹងការប្រព្រឹត្តផិតស្នេហ៍ស្នង
ផ្សំធាតុពីរនេះពេកកន្លង ឬក៏អ្នកផងធុញទ្រាន់ក្រៃ ? ។
បើគិតពីរឿងទុក្ខសាំញ៉ាំ តាំងពីសកម្មភាពហៃ
រហូតស្រីស្រីទ្រាំពហ៍ផ្ទៃ ធ្ងន់ខ្លួនពល់ថ្ងៃក្រៃចម្បែង ។
ដល់ពេលកើតកូនស៊ូរសូទ្យជន្ម ឈឺចាប់ទូរទន់ឈប់លែង
ប្រុសប្រុសធ្វើការគិតស្វះស្វែង ប្រឹងប្រែងថែទាំចិញ្ចឹមគ្នា ។
ប៉ុណ្ណោះជាអាទ្យអាចលាតប្រាប់ មិនបាច់សារស័ព្ទក៏អាចថា
ទាំងស្រីទាំងប្រុសទោះមនុស្សណា ក៏ធុញចិន្តាទ្រាន់ក្រៃលែង ។
តើប្រឹងធ្វើអីឲ្យលំបាក ហត់នឿយគ្មានស្រាកស្រាលចម្បែង
[illegible] ទៅខំប្រឹងប្រែងប្រយោជន៍អ្វី ? ។

ធម្មជាតិហាក់យល់ដល់ទឹកចិត្ត　ថាមនុស្សសត្វពិតគិតដូចស្ដី
ទើបបិតជានុយត្រយបំណាំ　ឲ្យមនុស្សសត្វធំដោយស្រើបស្រាលៗ
គឺប្រើមធ្យោបាយបំភាន់　បង្កើត «រដ្ឋាន់» មួយគ្រាកាល
ឲ្យមនុស្សសត្វចប់ជ្រមុជក្បាល　ស្រើបស្រាលដែនគ្នាស្រក់ចាប់ ។
ទុក្ខវេទនាក្នុងភារកិច្ច　មិនតិចមិនតូចដូចរ៉ាយរ៉ាប់
ដូច្នេះ រដ្ឋាន់ដ៏គួរគាប់　នោះក៏ត្រូវកប់ឲ្យគ្រាន់បើ ។
រដ្ឋាន់នោះគឺក្ដីសុខឯក　ជាសុខថ្មែកឥតអ្វីស្មើ
ដែលកើតក្នុងក្ដីរម្យទំហើ　អំពីផ្សំធាតុញីនិងឈ្មោល ។
រដ្ឋាន់នេះពិតមានឫទ្ធិក្រៃ　ឲ្យមនុស្សស្រីមស្មុះកញ្ជ្រោល
គ្រាន់តែឃល់សព្ទជាប់ស្រមោល　ក៏ដោលដួងចិត្តគិតសប្បាយ ។
ឲ្យបុរសស្ត្រីវៃនៃគ្រា　គ្រាន់តែឃើញគ្នាញ័ររញាក់កាយ
ឲ្យគ្រាន់តែទឹកក្លឹកពីឆាយ　ក៏ស្រើបសប្បាយត្រឹមគ្នា ។
ទោះបីដង្ហក់ហាក់ទ្រមម្ដច　ក៏នៅតែក្លួចគ្មានទីកទា
ឲ្យក្លួចទឹកអស់គ្រោះកាចជា　ពីទុក្ខវេទនាដែលជាផល ។
ក្នុងពេលកើតកូនកេដូនតា　ក្នុងពេលស្រក់លែងទឹកដល់ .
នេះជារដ្ឋាន់ពាន់ឥទ្ធិពល　មនុស្សសត្វសាកលខ្វល់ប្រាថ្នា ។
កាលបើដូច្នេះ ពិតមនុស្សលោក　ក៏យោគកើតធម៌មួយភ្ជាំងគ្នា
គឺការជាប់ស្អិតជិតចិន្តា　ប្រាថ្នា «រដ្ឋាន់» ថ្លៃកនោះ ។

សេចក្ដីប៉ុនប៉ងចំណងចិត្ត ដែលជាប់ចងស្អិតមិនងាយដោះ
ប្រាថ្នារង្វាន់គ្រាកាលនោះ នេះឯងដែលឈ្មោះថា «ស្នេហា» ។
បើតាមន័យនេះ រិះគិតយល់ គឺកលធម្មជាតិទាក់ចិន្ដា
ទស្សនៈកវីស្រដីថា «ស្នេហាគឺជាការបាញ់បោក» ។
ព្រោះថា លទ្ធផលជាក់ស្ដាង ក៏គឺព្រមសាងពូជកុនលោក
ទោះទុក្ខវេទនាប៉ុន្មានដោក ក៏យោគមុជក្បាលព្រមទទួល ។
អ្នកផងបកស្រាយរាយតម្លៃ លើកថ្លៃស្នេហាហាក់ដូចស្រួល
លុះដល់រិះគិតឫទ្ធិកំស្លួល តើតម្លៃប្រួលប្រែម៉េចវិញ? ។
ប៉ុន្តែមនុស្សលោកដោកដោយកាម ដក់ចិត្តស្អិតញ៉ាមនៅតាមដេញ
ស្ទុះរករង្វាន់នោះឯងមិញ ទោះប្រានក្បាលពេញក៏មិនងាយ ។
ថែមទាំងចាត់ទុកថា «ស្នេហា» នេះជាវត្ថុសប្បាយ
ដូច្នេះ បានជាមនុស្សទាំងឡាយ ខ្វល់ខ្វាយប្រណាំងប្រជែងគ្នា ។
ណាបានដូចចិត្ត គិតថាឈ្នះ ខ្លះបន់ស្រន់ព្រះសុំស្នេហា
ខ្លះចាញ់ បន្ទោសព្រេងវាសនា ក្រៀមក្រំទុកទ្រូងហោយ ។
ខ្លះទៀត មិនបានដូចស្មានគិត ហិនបង់ជីវិតគិតថាសម
ខ្លះហិនក្សត់ផិតលេងចិត្តធំ ខ្លះហិនបន្ទំយ៉ាងព្រៃផ្សៃ ។
ប្រហូកប្រហល់វល់ចរិត បណ្ដាលភ្លើងចិត្តឆេះហឫទ័យ
ហេតុម៉ែឪកូនពីថ្ងៃ ប្រែទ័យទាស់ទែងខ្វែងចិត្តគ្នា ។

ករណីនេះឯងវៀងគួរខុស  ទើបគេតមាខមនុស្សធម៌មួយថា
**កាមេសុមិច្ឆាចារ**  ប្រែថា " ប្រព្រឹត្តខុសក្រិត្យស្នេហ៍ " ៗ
ជាមាត្រាហាមក្នុងសីលប្រាំ  ឲ្យមនុស្សបងចាំជាហូរហែ
ដើម្បីសុខសាន្តទាំងយើងគេ  ជាមេរបាំងកំងស្នេហា ៗ

បើតាមសភាពស្រីនិងប្រុស  ពីរនេះជាមនុស្សខុសផ្សេងគ្នា
ប៉ុន្តែ ករណីកិច្ចស្ថាបនា  គឺត្រូវរួមគ្នាទើបកើតពូជ ៗ
រួមហើយ ស្ត្រីណាមានផ្ទៃពោះ  ស្ត្រីនោះពោះមាំឬធំតូច
សុខភាពតែងតែប្រែខាតខូច  តាំងពីកពូជផ្ដួចឡើងប៉ុប ៗ
ប្រុសប្រុសត្រូវតែថែរក្សា  ជួយគ្រងស្ងួនក្ខាឲ្យជាទិច
ទើបឈ្មោះថា " រួមករណីយកិច្ច "  មិនត្រូវបំភ្លេចគេបន្ទួនឡើយ ៗ
ប៉ុន្តែ ប្រុសខ្លះអាងផ្ទាស់ប្រែក  បានស្រស់ស្រួបយករង្វើនហើយ
បោះខ្លួនបោលស្រីទៅព្រងើយ  នេះហើយជាទោសប្រុសលោកិយ ៗ
ស្រីខ្លះក៏ចេតកើតគំនិត  ទោមនស្សពាសចិត្តខ្លួនជាស្រី
ធម្មជាតិដាក់ទោសគ្មានប្រណី  ឲ្យស្រីពហ៍ពោះគ្រោះទុក្ខទល់ ៗ
ឯប្រុសគេស្រួលមិនទូលទុក្ខ  ក្រេបរសយកសុខរួចគ្មានខ្វល់
ដូច្នេះ ត្រូវតែកែកិច្ចកល  រកផលឲ្យស្មើភ្លើប្រុសវិញ ៗ
គឺប្រើវិធីគេសុំខ្ចប  កុំឲ្យមានពូជពន្លកចេញ
ក្រលកយកតែផលចំណេញ  ហាក់ដេញជើងប្រុសឲ្យប៉ុះម្ដង ៗ

ករណីនេះឯងដែលកើតជា    មានស្រីពេស្យាផ្កាមាសផង

ប្រុសប្រុសទៅលោមលេមទាក់ទង    បំពេញស្នេហ៍ស្នងតាមត្រូវការ ៗ

លុះដល់ជួបប្រុសច្រើនជាំជោគ    បណ្ដាលជារោគគ្មានពូជធារ

បង្កើតជាសិទ្ធិជម្រិតទារ    យកថ្លៃការងារបានថែមទៀត ៗ

នេះជាវិធានការម្យ៉ាង    អាចឲ្យជៀសវាងទុក្ខបង្អៀត

បង្រាមសីលធម៌ក៏រួបទៀត    ជាស្នៀតចំណេញមិនពាញ់ប្រុស ៗ

ធម្មជាតិបោកប្រាសដោយរង្វាន់ ឲ្យមនុស្សស្ម័គ្រស្នេហ៍ព្រមសាងមនុស្ស

រីឯមនុស្សវិញចេញផ្លូវខុស    ស្រីប្រុសរួមគ្នាបោកវិញទី ៗ

មធ្យោបាយនេះបែបសមរម    ជាទីនិយមមនុស្សលោកិយ

ហេតុនេះឯងហើយទើបផែនដី    មានស្រីពេស្យាកើតសុះសាយ ៗ

ពួកគេគិតតែស្រើបស្រាលល្ហុក    រួមគ្នាផញ្ចួកវីវក់កាយ

ក្រោយយករង្វាន់យ៉ាងសប្បាយ    ឯពូជទៅនាយរលាយផុត ៗ

ដល់គ្មានកូនចៅតពៅពូជ    ទុក្ខទោសធំតូចគួរតក់ស្លុត

ដូចការពពោះ ប្រសូតបុត្រ    ក៏គេជៀសផុតគ្មានអំពល់ ៗ

ប៉ុន្តែ ការប្រើវិធីនេះ    បើរិះឲ្យល្អិតគិតឲ្យដល់

មិនមែនចំណេញពេញដូចយល់    វានៅតែខ្វល់អំពល់ទុក្ខ ៗ

ព្រោះគេត្រូវខាតបង់ដើមទុន    ជាមុនច្រើនណាស់មិនមែនសុខ

ដូចជាចំណាយចាយសំបុក    ត្រូវប្រឹងដោយទុក្ខដង្ហក់កាយ ៗ

ត្រូវចាយកម្លាំងជីវជាតុ ត្រូវខាតពេលាគ្រាខ្វល់ខ្វាយ
ត្រូវប្តូរទីនេះ គរុកកូនកាយ ត្រូវរងអន្តរាយរឿងផ្សេងៗ ៗ
ដូច្នេះ វិធីភ្នែនផ្ទាន់ ដោយមិនឲ្យបន្តពូជឯង
ទោះគ្មានពហ៍ផ្លែ ចិញ្ចឹមក្មេង ឬលែងកើតកូនសណ្តានទុក ៗ
កិតង់បង់ខាតជាតុកម្លាំង អស់ចាំងដើមទុនជុនគ្រប់មុខ
មានរឿងកស្រូវពុំស្ងួតស្ងុខ រងទុក្ខវេទនាជាច្រើនដែរ ៗ
ធម្មជាតិហាក់ដូចយល់មិនខុស ថាពិតជាមនុស្សនឹងគេចវែរ
តាមប្រកបកទៅផ្លូវនេះដែរ ទើបបានជាគេរៀបថ្លៃគ្រោះ ៗ
រៀបចំអន្ទាក់ទុកវេទនា ភយក្តាជុំវិញផ្ទាន់នោះ
ឲ្យតែលួកក្រឹបពិតជាគ្រោះ ចង់ដោះផ្លូវណាក៏ស្អារស្អិត ៗ
ហេតុនេះ ទស្សន: ថា «ស្នេហា» តើមានអ្វីជាខ្លឹមសារពិត
គឺវាជាការបោកលួង់លួត នៃចិត្តមនុស្សលោកជាកកាមា ៗ
ព្រះពុទ្ធជិនច្បាស់ត្រាស់ពន្យល់ ថា «បើបុគ្គលប្រាសស្នេហា
**អញ្ញា មុត្តោច ចន្ទិមា** ដូចដួងចន្ទ្រាប្រាសពពក» ៗ
ពាក្យនេះ បញ្ជាក់គ្គដួយខុស ពីគំនិតមនុស្សដែលស្តីមក
គឺថា ស្នេហាជាពពក តែងមកបាំងបិទចិត្តសារពើ ៗ
**នត្ថិ បញ្ញា សមាភា** «ពន្លឺប្រាជ្ញាគ្មានគូស្មើ»
ដូច្នេះ បើគិតពិនិត្យមើល «ប្រាជ្ញា»ទេតើ ជាស្មើ ៗ

បើមានស្នេហាមកបាំងបិទ ប្រាជ្ញាតែងល្ងិតឥតរង្សី
ស្នេហាជាអ័ព្ទបាប់លោកិយ ប្រាជ្ញាជារស្មីនៃលោកា ។
“ឲ្យតែឃ្លានឆ្ងាញ់ស្រឡាញ់ល្អ” នេះពាក្យតំណពីដូនតា
រិតតែបញ្ជាក់វគ្គនេះថា ស្នេហាបាំងភ្នែកញែកឃើញសូន្យ ។
ករណីនេះឯង ទើបព្រេងព្រឹទ្ធ បានរក្សាសិទ្ធិពីតាដូន
ក្នុងរឿងជ្រើសគូគ្រួសារកូន កើតជាដំបូន្មានតគ្នា ។
ព្រោះគេឃើញថាក្មេងស្លូវ ៗ កំពុងឈាមការធាវស្នេហា
ឲ្យតែជួបគ្នាភ្លាមកាលណា ក៏កើតស្នេហាភ្លាមរំពេច ។
ដល់ចិត្តស្នេហាវាបាំងស្បែក ព្រិលភ្នែកគិតអ្វីក៏លែងលេច
ឃើញតែរន្ទាន់តាំងបើកភ្លេច ធ្វើម៉េចនឹងយល់ផលទៅមុខ ។
រីឯចាស់ទុំពុំស្នេហា ទើបមានប្រាជ្ញាវិចារទុក
តាំងពីឥឡូវទល់ទៅមុខ ស្ទាបហេតុផលសុខឲ្យកូនបាន ។
ព្រោះគ្មានពពកមកបាំងបិទ គឺចិត្តស្នេហារួបរឹតប្រាណ
ប្រាជ្ញាថ្លាស្អាតឥតខាតខាន អាចធ្លុះអាចស្មានច្រើនបានត្រូវ ។
ស្ទាបស្ទង់ទិសស្រយនៃគូស្នេហ៍ រួមគ្នាបានទេ ! ឬបែរផ្លូវ ?
អត្តិតមារយាទញាតិអាស្រូវ តាំងពីម៉ែឪផៅពង្សា ។
ស្ទង់មើល ចរិត ចិត្ត ទម្លាប់ មានច្បាប់ឥតច្បាប់ឬយ៉ាងណា
ផ្គុំផ្គូមើលផ្លូវចរិយា ទើបអាចរួមគ្នាជាសុខសាន្ត ។

ព្រោះរឿងផ្សំធាតុជាតិកាមា　　អ្នកណាក៏អាចរួមធ្វើបាន
វែងនិស្ស័យចិត្តសន្តាន　　ពុំងាយធ្វើបានចូលគ្នាទេ ។
សម័យឥឡូវផ្លូវបំបែក　　កូន ៗ កាត់បែកសិទ្ធិពីមេ
អាងថា រឿងផ្ទាល់ខ្លួនផងគេ　　ទោះមេក៏មិនត្រូវជ្រៀតជ្រែក ។
រឿងស្នេហ៍រឿងសិទ្ធចិត្តដោយខ្លួន　　មិនគួររុកកូនខ្លាំងពេក
អ្នកណាទទួលទុក្ខទៅស្អែក ?　　គឺរូបកូនឯកឯងទេតើ ។
ជានេះ ក៏សមបំមិនខុស　　កើតមកជាមនុស្សគ្រាន់បើ
ត្រូវតែស្គាល់គុណទោសសារពើ　　មិនត្រូវល្ងីល្ងើស្រេចគេដឹក ។
បើកូនកើតមកមានប្រាជ្ញា　　បេះពិចារណាភ្ញាក់រលឹក
ចាំបាច់ម៉ែឪត្រាយផ្លូវដឹក　　ឲ្យស្ទឹកខ្លួនក្បាលខ្លួនខាលអី ! ។
ប៉ុន្តែ ប្រុសស្រីនៅវ័យក្មេង　　កូនគេកូនឯងច្រើនយល់ខ្វី
ម៉ែឪអប់រំគ្រប់អ្វីអ្វី　　កើតឡើងដឹងក្តីវ័យតទៅ ។
ម៉ែឪដឹកនាំផ្សំគំនិត　　ព្រោះឃើញកូនល្ងិតនៅល្ងង់ខ្លៅ
ការជួយរិះគិតប្រៀនប្រដៅ　　នេះក៏បានទៅជាករណីយកិច្ច ។
គឺកិច្ចត្រូវធ្វើចំពោះកូន　　ជួយជូនយោបល់ប្រៀនកលល្បិច
តាំងពីកើតទល់មង្គលកិច្ច　　ទើបស្រេចបែកជាគ្រួសារផ្សេង ។
ទៅក្នុងរយៈកាលគ្រប់គ្រង　　ម៉ែឪត្រូវធ្វើកិច្ចចាត់ចែង
តាំងពីស៊ីបុកផ្ទះសម្បែង　　ស្ទះស្ទង់ចែងការឲ្យកូនធ្វើ ។

ជាមេគំនិតត្រិតបញ្ញា ជានាខុសត្រូវផ្សំអំពើ
អប់រំនិស្ស័យឲ្យគ្រាន់បើ ត្រួតលើមើលទល់ដល់មារយាទ ។
រីឯចិត្តចង់ចំណង់មនុស្ស តែងខុសពីគ្នា ជាធម្មជាតិ
តែបើកូនខុសបុះផ្លូវខាត ម៉ែឪត្រូវរកគលាតតម្រង់ ។
មិនត្រូវបណ្ដោយឲ្យតាមកម្ម កុំមើលបំណាំចាំឲ្យលង់
នេះជាទំនៀមខ្មែរសុទ្ធត្រង់ មិនចង់ឲ្យក្មេងលេងតាមចិត្ត ។
  មានពាក្យខ្លះថា បើម៉ែឪ ធ្វើបេះតែត្រូវផ្លូវគំនិត
ជ្រើសគូឲ្យកូនជាសុចរិត មិនបិតប៉ុន្មានប្រាណប្រាសគ្នា ។
តើមកពីអ្វីបានជាព្រាត់ ? ឬមកពីគាត់បាត់តម្រា ?
រៀបគូឲ្យកូនស្ងួនឲ្យទន្យា បានជាកូនគ្មានសុកមង្គល ? ។
  រឿងនេះពិតណាស់ចាស់មានក្នុក មិនហ៊ានប្រកែកថាមិនយល់
តែបើគិតស៊ិនមិនគួរធ្ងល់ រកមានចុសគល់ច្រើនប្រការ ។
ម៉ែឪរូបខ្លះចាស់តែខ្លួន ស្រឡាញ់កូនស្ងួនស្មើសង្ខារ
បង្ខំចិត្តកូនឲ្យរៀបការ គ្មានគិតពិចារមើលនិស្ស័យ ។
ខ្លះលោភលន់ពេកក្នុករឡប់ សំឡឹងឃើញទ្រព្យអ្នកដទៃ
ឃើញយសឃើញស័ក្ដិគេប្រពៃ វង្វេងហឫទ័យតែចង់បាន ។
ក្មេចទឹកវិនិច្ឆ័យនិស្ស័យចិត្ត ក្មេចស្នេហ៍ចរិតស្ដាប់សន្ដាន
ប្រាសប្រាល់ទឹកឃើញតែការបាន ទើបមានករណីគួរឲ្យស្ដាយ ។

ប្រសិនបើគិតឲ្យល្អិតល្អន់ កុំលន់លោកលន់ខុសគម្រាយ
កូនចៅនៅរួមសុខសប្បាយ ពិតពុំអន្តរាយដូច្នោះណា ។
រីឯកូនវិញដែលចេញមុខ រើសគូរួមសុខ ក៏ដូចគ្នា
ខ្វះទើបនឹងបានក៏ប្រេះឆា ខ្វះបែកបាក់គ្នាយ៉ាងដូចត់ ។
កើតទៅជារឿងកៀងកលកិច្ច នេះក៏មិនតិច មានប្រាកដ
ខ្វះប្រឹងសម្ងំដោយខំអត់ ទឹងតែព្រាត់ប្រាសទឹកខ្លាសខ្លោច ។
ព្រោះជ្រុលអំណួតអួតថាល្អ ទ្រាំនៅទុនកទាំងផ្សាខ្លោច
ដំណើរចម្រើនកើនប្រយោជន៍ ក៏ហើរហិនហោចខូចប្រក្រតី ។
«ធ្វើស្រែបើខុសខុសមួយឆ្នាំ រង់ចាំឆ្នាំក្រោយធ្វើសាថ្មី
រៀបគូស្រករកូនប្រុសស្រី ខុសហើយរៀបថ្មីខុសដដែល» ។
បើមិនត្រូវគ្នាត្រូវតែលះ លែងឲ្យស្រឡះឈប់ក្រវែល
បើនៅតែរួមមនុស្សដដែល ត្រូវខូចអស់ពេលមួយជីវិត ។
រឿងនេះបុពណញាណប្រត្យក្ស យកចិត្តទុកដាក់ដល់កម្រិត
មុននឹងរៀបកូនតែងរិះគិត ហៅញាតិឆ្ងាយជិតមកពីគ្រោះ ។
មិនមែនប្រថុយផុយទាំងនៅ ដូចជាម៉ែឪខ្លៅខ្វះនោះ
ព្រោះខ្លាចពាពោនមានហ្នឹងអោះ មិនឆាយស្រាយដោះដូចស្រែឡើយ ។
ដូច្នេះស្នេហាកំឲ្យសុខ តែដល់ទើសមុខទាស់ចិត្តហើយ
ស្នេហាពិតជាចុះអន់ស្បើយ លែងចង់កៀកកើយឲ្យជួបមុខ ។

កំណើតស្នេហាមាន ២ បែប    កវីសង្ខេបជាទំនុក

មួយកើតដោយគ្រាន់តែជួបមុខ    មួយដោយទំនុកបម្រុងគ្នា ៗ

«គឺខ្លះឃើញភ្លាមតាមមើលភ្លឹក    ដេកដើររឭករកស្នេហា»

ចង់បានភ្លាន់ទាន់ចិន្តា    មុនចិត្តមេបាយល់ថាព្រម

កាលនេះច្រើនណាស់មនុស្សលោកយេ    យុវប្រុសស្រីវ័យថ្នាក់ថ្នម

បណ្តាយបន្តិចលិចចុះល្មម    ប្រឈមរកគ្នាស្រកផ្លូវ ៗ

ខ្លះទ្រាំមិនបានហ៊ានលះឈាត់    លែងការស្ងាត់ក្បត់ម៉ែឪ

ខ្លះមិនហ៊ានលង់ចង់ការស្រូវ    ព្រោះខ្លាចម៉ែឪថាត្រូវក្បត់ ៗ

គ្រាន់តែថែទុកជាសង្សារ    ចង់ចិត្តរៀបការអនាគត

យកទេពអ្នកតាជាសម្បថ    យកព្រះគុណវត្តឲ្យឧបត្ថម្ភ ៗ

អ្នកខ្លះមិនស៊ូ ផ្លូវមេត្រី    រកគូស្នេហ៍ថ្មីគ្មានបារម្ភ

សង្សារមុនមោហ៍ទ្រហោយំ    ទុក្ខធំរងរែក្សយជន្មា ៗ

អ្នកខ្លះទៀតគ្រង់មិនបង់ស័ត្យ    សុខចិត្តគោរកាត់ចាំជួបគ្នា

ប៉ុន្តែពាស់ចិត្តមិត្រមេបា    កើតជាបញ្ហាខ្លាចផ្សាទ្វេ ៗ

ម៉ែឪថាខុស កូនថាត្រូវ    ម៉ែឪថាទៅ កូនថាទេ

កាយតាស់ទាស់ទែងលែងខ្មាសគេ    តើរម្តេចទៅផ្លូវសុខសាន្ត ៗ

កូនប្រុសស្រីខ្លះប្រាប់តាស់ថា    "គុណរឿងស្នេហា តាមមិនបាន

បើរឿងឯទៀតគោះប៉ុន្មាន    កូនអាចតាមបានគ្មានប្រកែក ៗ

មើលចុះប្រុសស្រីនៅវ័យក្មេង បើរឿងអ្វីផ្សេងតែងផ្លូវផ្ដេក
ពឹងពាក់ម៉ែឪជាបង្អែក ចម្លែកតែរឿងស្នេហានេះ ។
គឺវាពិតណាស់ច្បាស់ដូចច្បាប់ ស្នេហាជាអ័ព្ទបាំងតម្រិះ
បិទផ្លូវប្រាជ្ញាប្រែជាបេះ អាងនោះអាងនេះបេះតែមាន ។
កិច្ចការអ្វីអ្វីស្ដាប់ម៉ែឪ ថាល្អ ថាត្រូវ ថាតាមបាន
ដល់រឿងស្នេហាមកប្រៀបប្រាណ ប្រែហ៊ានឲ្យតាស់តាមខ្លួនវិញ ។

បរិយាយសេចក្ដីនៃបញ្ហា ពាក់ទងស្នេហាតាំងនេះមិញ
ឃើញថាស្នេហានេះពោរពេញ ដោយទុក្ខទោម្នញដ៏មហិមា ។
រឿងបង្កើតពូជរក្ខបសោះ ពីព្រោះនៅត្រង់ផ្សំជាគូគ្នា
ទោះបីគ្មានចិត្តជិតស្នេហា តែជាគូជួបគ្នា ត្រូវតែកើត ។
ប៉ុន្តែ ជាតិមនុស្សខុសពីសត្វ ក្រៅពីបង្កើតពូជកំណើត
នៅមានគំនិតប្រាជ្ញាឆើត បង្កើតបញ្ហាការរួមរស់ ។
បើនៅរួមគ្នាជាសប្បាយ ញញឹមក្អាកក្អាយមុខស្រាយស្រស់
ទើបថាជីវិតថ្លៃថ្លាខ្ពស់ ហៅរស់មានសុភមង្គល ។
បើរស់ជាទុក្ខមុខជួបហ្មញ ស្ទើរយំស្ទើរឡូញមិនគួរយល់
មួយជើង-មួយត្បូង តោងរំពល់ អពមង្គលមួយជីវិត ។
ដូច្នេះ បញ្ហាការរួមរស់ ទើបជាថ្នាក់ខ្ពស់គួររិះគិត
ឯរឿងស្នេហាការផ្គូផ្គង ត្រូវត្រិតខិតជាក់ថ្នាក់បន្ទាប់ ។

កុំយកស្នេហាថាជាធំ ហេតុប្រឡំខុបទម្ចាប់
ព្រោះស៊ីមិនបាត់អត់មិនស្លាប់ កុំអាលប្រញាប់ខ្ញុំមុនចាស់ ៗ
តើបានជាអ្វី? ស្ដីទៅមើល? កាលបើយើងព្រើលផ្អើលផ្ដេសផ្ដាស
ជ្រួលជ្រើមផើមព្រៃហើយព្រាត់ប្រាស វាបានតែខ្មាសគេប៉ុណ្ណឹង ៗ
ខ្លះទៀតពាក់ទងជាសង្សារ មិនព្រមរៀបការផ្អកណាផ្សឹង
ពាស់ចិត្តម៉ែឪទៅជាខឹង មានះប៉ះរឹងប្រឹងឡូឡា ៗ
បើចាំពិគ្រោះនឹងម៉ែឪ គ្រប់រូបគ្នាសិនសឹមស្នេហា
តើវាឥតកូនឬយ៉ាងណា? ចាំបាច់ធ្វេធ្វាចងការអើ ៗ
ការរឿងស្បថស្បែខ្មោស្មូតគ្រង់ ថាហើយមិនបង់បែរសំដី
នេះសូមសរសើរក្ដីប្រុសស្រី ព្រោះគេហ៊ានស្ដី គេហ៊ានធ្វើ ៗ
ប៉ុន្តែ ការស្បថកំណត់ចិត្ត បើធ្វើមិនគិតឥតអំពើ
នឹកក្លួតថាក្លាមចាំងពក្ដី ជ្រុលខុសរុះរើធ្វើម៉េចសម ៗ
បើកុំអាលជួញទំនួញស្បថ ដោយក្បត់មុនមេបារៀបចំ
តើមានបញ្ហាអ្វីជាធំ? ពិតជាសុខដុមដុំមេបា ៗ
ឯការរួមរស់ជាសុខសាន្ត មិនបាច់ចាំមានចិត្តស្នេហា
ដូចជាចាស់ចាស់គឺយាយតា អាចរស់រួមគ្នាស្មើជីវិត ៗ
ឬក៏ដូចជាម៉ែនិងកូន ឬដូចបងប្អូន ឬដូចមិត្រ
តើមានស្នេហាណាដាប់ចិត្ត ម្ដេចក៏អាចស្និទ្ធរួមរស់បាន ៗ

(នៅមានត)

# រាជពង្សាវតារ

តាមសាស្ត្រាស្លឹករឹតបានពីវត្តកោកកាក

លោក ឃួន-សែម ចម្លង

លោក លី-ធាម តេង ពិនិត្យផ្ទៀង

## សេចក្តីបញ្ជាក់

ការិយាល័យនិពន្ធនៃទស្សនាវដ្តី កម្ពុជសុរិយា សុំបញ្ជាក់ថា អត្ថបទ "រាជពង្សាវតារ" មានច្រើនប្រភេទ ដែលបុព្វបុរសយើងបានតែងហើយចារទុកក្នុងសាស្ត្រាស្លឹករឹត ។ វេលានេះ យើងសុំស្រង់យកមកចុះផ្សាយម្តងមួយ ដើម្បីទុកជូនជាឯកសារសិក្សា សម្រាប់អ្នកស្រាវជ្រាវ និង អ្នកចង់ដឹងគ្រប់ប្រភេទ ។ តែសុំអភ័យផងថា: យើងឥតមានកែពាក្យពេចន៍ទេ រក្សាទុកដូចដើម តែកែអក្ខរាវិរុទ្ធ, ដូច្នេះបើមានរឿងរ៉ាវក្តី ពាក្យសម្តីក្តី ទាក់ទងទៅខាងការគោរពរាជនិយមនោះ សូមអ្នកអានទុកថា ជាសម្តី ជារឿងរ៉ាវ របស់គេសម័យនោះ យើងគ្រាន់តែយកមកលាតត្រដាងមើលឲ្យច្បាស់ និងជាឯកសារប៉ុណ្ណោះ ។

**សុភមស្តុ** ស្វស្តិ សិរីសុខសុភមង្គលពហុលបេស្តា មហាតិរេក ឯកស័ក វិសុទ្ធិផុតិជយា ព្រះពុទ្ធសករាជព្រះសាសនាកន្លងទៅហើយបាន ២៤១២ព្រះវស្សា មហាសករាជឡើងជា ១៧៩១ ចុល្លសករាជ ១២៣១ ឆ្នាំមមែឯកស័កថ្ងៃសៅរ៍ ១៣ កេចខែពិសាខវេលាងាចព្រឹក ជាបុទ្ធក្សស្វស្តិ នៃព្រះបាទសម្តេចព្រះ-រកត្តមបរមទេពាវតារ គុណសាសនទាវិទ្ធមហិស្សរាធិបតី សិរីសុរិយោវង្សទកត្ថពង្ស គម្រង់ព្រ្គ បរមនាថមហាកម្ពុជា

ធិបតី នូវសព្វសីលប្រសិទ្ធិស្ថិតស្ថានព្រះព្រហ្ម អំណោយជ័យជាមហៃ ឝ្វរិយាធិបតី នៃប្រថពីដល់សកលកម្ពុជាណាចក្រ អគ្គមហាបុរស រាជវិ- វង្សនាតិរេកឯកឧត្តម បរមចក្រពត្រាធិរាជ បរមនាថ បរម.ពិត្រ ព្រះចៅ ក្រុងកម្ពុជាធិបតី ជាម្ចាស់ជីវិតលើត្បូង គង់នៅបរមរាជវាំងចតុម្មុខ ក្នុងពេញ ស្ដេចចេញគង់ព្រះទីនាំងទេវាវិនិច្ឆ័យ ជុំអស់ព្រះរាជវង្សានុវង្ស សមណ ព្រាហ្មណ៍ព្រឹទ្ធបុរោហិត លោកបារ្យសេនាបតីមុខមន្ត្រីផងទាំងពួង ទើប ទ្រង់ព្រះតំរិះយល់ថា ព្រះរាជពង្សាវតារព្រះមហាក្សត្រសោយរាជសម្បត្តិ ក្នុងក្រុងកម្ពុជាមហាឥន្ទបត្ត តួបជួនដំណើរតគ្នាជាលំដាប់ៗ ពីមុនមក នោះ ជាអន្លើនរាជ្យអន្លើនឆ្នាំ ខូចខាតបទខ្លះ គង់នៅខ្លះ ឯដែលគង់នៅ នោះគឺខាតខុសលើសលស់ជាច្រើនទើបមានព្រះរាជឧង្ការ នូវព្រះបន្ទូល បរមនាថ ក្រោមៈលើត្បូង ៗ ឲ្យផ្ទៀងឲ្យត្រូវ អក្ខរៈព្យញ្ជនៈជាថ្មី ឲ្យត្រូវ សករាជ ដែលមហាក្សត្រា សោយរាជសម្បត្តិជាលំដាប់រៀងមក ដល់ កាលបច្ចុប្បន្ននេះ ឯព្រះរាជពង្សាវតារព្រះមហាក្សត្រ ដែលតាំងគសាង ផែនដី ព្រះនគរខ្មែរពីដើមមកនោះបាត់អស់ ស៊ើបសួររកពុំទាន់ឃើញ ប្រាកដ នឹងពណ៌នាឲ្យវិត្ថារទៅពុំទាន់បាននឹងសំដែងជានិទាន តាមព្រះ បរមបុរាណកត្ថាជាកំណត់រាជប្រវេណី ដោយលំដាប់រៀងមកដូច្នោះ ចាប់ ដើមពីអគ្គសម្ដេចព្រះបរមត្រៃលោកនាថជាអម្ចាស់ ទ្រង់ចូលព្រះមហា នគរនិព្វាន ស្ដេចព្រះរាជដំណើរទ្រង់ក្យណោកោះជម្ពូរ៉ប តាមឆ្នោះលោ-

ណមហាសាគរ តែពីអេត្ត ទឹងព្រះមហាអានន្ទត្ថេរ មកដល់កោះមួយធំ មានដើមផ្ទុកផុះ កណ្ដាលកោះ ឯដើមផ្ទុកនោះ បែកមែកត្រសុំត្រសាយ សាខា មានប្រយោជន៍ជារូងហើយមានសត្វត្រគួតមួយ តែងពឹងពាក់ សំណាក់អាស្រ័យជាទីឋាន ឯដីនោះក៏សឹងតែកបស្មើប្រពៃដូចផ្ទៃស្គរ ស្ដេចនាគក៏នាំបរិវារ ឡើងមកលេងទឹកជាប្រក្រតី រីសម្ដេចព្រះសាស្ដា បរិយាវង្ស ទ្រង់យានព្រះបាទសីហនាទ នាំនៃព្រះមហាអានន្ទត្ថេរចូល ទៅឈប់ក្រោមម្លប់ដើមផ្ទុកនោះ ជួនជាព្រះសុរិយេន្ទអស្ដង្គត ព្រះបន្ទូរ ថែងត្រចាំស្ងាននកា រុក្ខទេវតារក្សាដើមផ្ទុកក៏និម្មិតអាសនៈ ក្រឡាបន្ទុំ មានខ្ញង់ព្រហ្មព្រាវស្បូវត្រូវព្រះសន្ធិយា ថ្វាយព្រះបន្ទំធ្វើសេយ្យាសន៍ បរិយា លុះព្រះឧត្តមយាមកន្លងទៅហើយ ស្ដេចនាគរាជនាំបរិវារឡើង មកលេងឃើញព្រះជិនស្រី ក៏ចូលទៅទូលសិរសា ក្រាបថ្វាយបង្គំ នមស្សការ អារាធនាទូលព្រះធម្មវិសេសទេសនា ដោយបញ្ចបីតិប្រា· មោទ្យ មនោរថា ឯសម្ដេចព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់សំដែងព្រះធម្មវិសេស ទេសនា ជាសន្ដាប់នៃស្ដេចនាគរាជនិងហ្វូងនាគទាំងពួង លុះអញ្ញត្តិក- សម័យ អស់ពួកទេពនិករគមរមេឃ មានសម្ដេចសហស្សន័យន៍ជាប្រធាន ចេញចរចាកទីវិមានៈហោះផ្ដោះចុះមកកាន់សំណាក់ នៃព្រះដ៏មានបុណ្យ សួរនូវបញ្ហាដោយទីទៃ ៗ លុះចូលជាបច្ឆិមយាម តាមពុទ្ធវិសេសក៏អស់ព ពួកទេវតា និងពួកនាគទាំងពួង ខ្លះបានស្រោតាសកទាមី ក្រាបថ្វាយបង្គំ

លាវិលទៅឋានលំនៅទីទៃៗវិញ ឯសម្តេចព្រះទសពលញាណ ក៏ប្រះប្រាណសម្រាន្តដោយសេយ្យាសន៍ចរិយា លុះពេលបច្ចូសសម័យព្រះអង្គតើនទេសនានូវនិស្ស័យនៃសត្វលោក ដោយពុទ្ធកិច្ចស្រេចហើយត្រាស់ផ្តាំព្រះមហាអានន្ទត្ថេរឲ្យគង់ចាំនៅដើមឈូក ស្តេចគ្រងនូវចីវរឃ្ញុំគ្រលុំស្អាតហើយ និមន្តទៅទ្រង់បិណ្ឌបាត ឯតាវតឹង្សាវិមាន លុះបានចង្ហាន់បិណ្ឌបាតស្រេច ស្តេចវិលមកឯដើមឈូកចែករំលែកចង្ហាន់ព្រះរាជទានឲ្យព្រះមហាអានន្ទត្ថេរ ហើយស្តេចសោយ ខណៈស្តេចសោយនោះ សត្វត្រកួតក៏ធុំក្លិន រសអាហារទិព្វឆ្ងាញ់ពិសារប្រាថ្នាចង់បរិភោគ តាំងទៅក្នុងរូងនោះពុំបាន ក៏វារចេញមកកាន់សំណាក់នៃព្រះដ៏មានបុណ្យ ដល់ហើយឱនសិរសា ក្រាបថ្វាយបង្គំដោយវិន័យសត្វ ទើបសម្តេចព្រះជិនវង្សទ្រង់ពូតចង្ហាន់មួយពំនូត ព្រះរាជទានឲ្យទៅសត្វត្រកួតៗក៏បរិភោគអស់ដោយជាតិរសអាហារទិព្វឆ្ងាញ់ពិសា ក៏លៀនជីហ្វាលិទ្ធមាត់ខ្លួនឯង ទើបទ្រង់ព្រះទស្សនាការ អណ្តាតសត្វត្រកួតបែកព្រែកជាពីរ ក៏ទ្រង់ញញឹមៗ ខណៈនោះ ព្រះមហាអានន្ទត្ថេរ លើកអញ្ជលីប្រណម្យបង្គំទូលសួរថា ទ្រង់ឃើញសត្វត្រកួតលិទ្ធមាត់ហើយ ទ្រង់ញញឹមនោះ មានហេតុប្រការដូចម្តេច ទើបសម្តេចព្រះជិនវង្ស ទ្រង់ត្រាស់ទំនាយ ប្រាប់ព្រះមហាអានន្ទត្ថេរថា នន្ទអើយ អំណើះតទៅ កោះគោកឈូកនេះនឹងដុះដីឡើងជាធំទូលាយកើតជានគរមួយ ឯសត្វត្រកួតដែលមានចិត្តជ្រះថ្លា មកក្រាបថ្វាយ

បន្ទិតជាគតនេះ ដោយអំណាចកុសលដែលសោតប្រសាទបានឮសម្ដែង ព្រះធម៌វិសេសទេសនានៃតថាគត កាលសំដែងជាសណ្ដាប់ស្ដេចនាគរាជ និងទេវតានោះ លុះអស់អាយុទៅនឹងបានទៅកើតជាបុត្រស្ដេចមួយអង្គ នៅក្រុងឥន្ទបត្តនគរ ហើយរាជបុត្រនោះឯងនឹងបានមកដល់ទីនេះ ឯស្ដេចនាគរាជដែលមកស្ដាប់ព្រះធម៌វិសេសទេសនានោះ នឹងមកសាងជាព្រះនគរឲ្យនៅ ឈ្មោះហៅក្រុងកម្ពុជាធិបតី ប្រទេសដទៃនឹងសន្មតមកហៅថា គាសាខេមរៈ ចំណែរទៅ សម្ដេចអម្រិន្ទ្រាធិរាជនឹងមកសាងប្រាសាទរាជវាំនឲ្យថែមទៀត នឹងបានឈ្មោះជាឥន្ទបត្តបុរីជាឈ្មោះ ២ ទើបឯមនុស្សក្នុងនគរនេះ ស្រដីពុំប្រាកដដោយសត្យា នោះហេតុពីព្រោះស្ដេចផែនដី ជាតិជាសត្វត្រកូលអណ្ដាតពីរនោះឯង លុះព្រះអង្គប្រោសទំនាយរួចហើយ ស្រេចតាំងនគរកត្តកិច្ច ក៏ស្ដេចនាំមហាអានន្ទត្ថេរ ព្រះរាជដំណើរទៅបន្តិច ដល់ព្រះនគរកុសិនរាក្នុងនៃព្រៃកំពង់តាំងគូ ស្ដេចនឹងចូលបរិនិព្វាន ក៏ប្រតិស្ឋានព្រះពុទ្ធសាសនា ៥០០០ ព្រះវស្សាទុកប្រោសសត្វផងទាំងឡាយ ឯព្រះជន្មបាន ៨០ ព្រះវស្សានៅថ្ងៃអង្គារ ពេញបូណ៌មីខែពិសាខឆ្នាំម្សាញ់ឯកស័ក ស្ដេចចូលព្រះមហានិព្វានទៅ ទើបអាចារ្យតាំងឆ្នាំម្សាញ់ជាឯកស័ក រាប់ថាព្រះពុទ្ធសករាជ ១ ព្រះវស្សា រៀងមកដល់កាលបច្ចុប្បន្ននេះ សំដែងព្រះពុទ្ធទំនាយ សម្ដេចតែប៉ុណ្ណេះ ។

ខណៈនេះ នឹងសំដែងព្រះរាជពង្សាវតារតាមបរម្បរា តាមឆ្នាំតៗ តាមក

ជាលំដាប់ក្សត្រខត្តិយរាជនោះ មានមហាក្សត្រា ១ អង្គទ្រង់ព្រះនាមឈ្មោះ អស្សច័យរាជ ព្រមមុខមន្ត្រីនិងរាស្ត្រ ចំណុះសំពៅ ៥០០ នាក់ បើកសំ-ពៅចេញមកពីនគរមកលេងសមុទ្រ លុះដល់កណ្ដាលប្រវាលសាគរត្រូវខ្យល់ព្យុះនាំមក សំពៅនោះមកជិតកំពង់វែក នឹងវិលទៅវិញពុំបានក៏ខាន តាំងស្រុកនៅឆ្នេរសមុទ្រ ជិតកោះគោកធ្លក ហើយសន្មតដើមធ្លកនោះជាលាក់ចារិក ហៅជានគរគោកធ្លកឯព្រះបាទអស្សរ័យរាជ បង្កើតព្រះរាជបុត្រ ១ អង្គព្រះនាមឈ្មោះក្រវាឡតិស្សរាជ ហើយអស្សច័យរាជសុគតទៅ នោះក្រវាលតិស្សរាជ បានសោយរាជសម្បត្តិ ទទួលព្រះរាជឱង្ការស្នងសម្ដេចព្រះវររាជបិតា នោះបង្កើតរាជបុត្រា បុត្រីរៀងមក ដំណើរនេះឈប់ទុកនៅ នឹងស្រដីទៅឯព្រះមហាក្សត្រ ១ ព្រះអង្គ ទ្រង់ព្រះនាមឈ្មោះអាទិច្ចវង្ស គង់នៅឥន្ទបត្តបុរីស្រីមហានគរជាឧត្តរទិសភាគ ស្ដេចមានព្រះរាជបុត្រា ៥ ព្រះអង្គ សឹងជាទ្រង់មហិទ្ធិឫទ្ធិតេជៈ ទូទៅគ្រប់ប្រទេស ទើបស្ដេចឲ្យព្រះរាជបុត្រាច្បងទៅគ្រងបច្ចន្តប្រទេស ទិសបូព៌ ឯព្រះរាជបុត្រាបន្ទាប់ គ្រងបច្ចន្តប្រទេសទិសឧត្តរ ឲ្យព្រះរាជបុត្រាកណ្ដាលទៅគ្រងបច្ចន្តប្រទេស ទិសបស្ចិម ឲ្យព្រះរាជបុត្រាបន្ទាប់កណ្ដាល ព្រះនាមហៅព្រះថោង ទៅគ្រងបច្ចន្តប្រទេស ទិសទក្សិណ ឯព្រះរាជបុត្រាពៅដោយនៅកុមារតូចណាស់ ស្ដេចឲ្យគង់នៅព្រះនគរធំ ជាមួយនឹងស្ដេច ឯព្រះរាជបុត្រា ដែលទៅគ្រងព្រះនគរទាំង ៤ សឹងបានជាសាមល-

រាជ តែរដូវទ្វាទសមាសកាលណា ក៏តែងចូលថ្វាយបង្គំគាល់សម្ដេចព្រះវររាជបិតាពុំដែលខាន លុះចំណេរទៅព្រះបាទអាទិច្ចវង្សក៏ទ្រង់ព្រះតម្រិះរិះគិតថា ព្រះរាជបុត្រាទាំង ៤ ព្រះអង្គបានឲ្យចេញទៅគ្រងស្រុកទីទៃ ៗ ស្រេចហើយ នៅតែព្រះរាជបុត្រពៅ គួរនឹងឲ្យសោយរាជសម្បត្តិនៅព្រះនគរកណ្ដាលនេះ នឹងឲ្យព្រះនគរទាំង ៤ ជាផ្លូវព្រះរាជមេត្រីសម្ពន្ធញាតិផងគ្នា ទ្រង់មានព្រះតម្រិះដូច្នោះហើយ ក៏ជំនុំនឹងអគ្គមហាសេនា នូវសេនាបតីមន្ត្រីមុខអមាត្យមេជាបុរោហិតា ទីប្រឹក្សាទាំងពួង ក៏យល់ព្រមផងព្រះរាជហឫទ័យ ហើយទើបតែងព្រះរាជសារត្រាស់ប្រើរាជទូតឲ្យនាំទៅឯព្រះរាជបុត្រា ទាំង ៤ ព្រះអង្គ ដែលគង់នៅព្រះនគរគ្រប់ទិសឯព្រះរាជបុត្រា ដែលគង់នៅព្រះនគរទិសបូព៌ា ឧត្តរ បស្ចិម ទាំង ៣ ព្រះអង្គបានទ្រង់ព្រះសណ្ដាប់ ស័ព្ទអក្សរបវរលេខាក៏ស្រុះស្រួល ទទួលតាមព្រះរាជអធ្យាស្រ័យហើយ ទើបចាត់ចែងតែងគ្រឿងបណ្ណាការ លើកព្យុហយាត្រាតាមក្បួនចូលកាន់ព្រះនគរព្រះវររាជបិតា ឯព្រះថោងព្រះរាជបុត្រាបន្ទាប់កណ្ដាលដែលគ្រងព្រះនគរទិសទក្សិណនោះ លុះបានជ្រាបសេចក្ដីសុភសារអក្សរហើយក៏ទាស់ទឹងអធ្យាស្រ័យ ត្រាស់ជំនុំនឹងអស់មុខមន្ត្រីទីប្រឹក្សាថា សម្ដេចព្រះវររាជបិតាទ្រង់ព្រះតម្រិះនឹងឲ្យព្រះរាជបុត្រាពៅសោយរាជសម្បត្តិក្នុងព្រះនគរកណ្ដាល ទៅជាព្រះនគរធំលើសអស់នគរយើងទាំងពួង ឯនឹងឲ្យយើងជាបងទាំង ៤ ព្រះនគរ ទៅថ្វាយផ្កាមាសផ្កា

ថ្វាក់ នេះឃើញថាពុំត្រូវតាមគន្លងប្រវេណីធម៌ សម្តេចព្រះវៀមទាំង៣ ព្រះនគរក៏យល់ថា ពុំព្រមផងយើងក៏ពុំគួរព្រមតាម ទ្រង់ព្រះតម្រិះការដូច្នោះហើយ អស់មុខមន្ត្រីទីប្រឹក្សាទាំងពួង ក៏ព្រមតាមផង ទើបព្រះថោងក៏តែងរាជសារ តបព្រះរាជសារសម្តេចព្រះវររាជបិតា ក្នុងមុសារាទ ថាពុំសប្បាយសព្វជំពូក ពុំបានចូលមកក្រាបបង្គំគាល់ឡើយ ឯរាជទូតក៏ទទួលរាជសារហើយ ក្រាបថ្វាយបង្គំលាត្រឡប់ទៅកាន់ព្រះនគរ ដល់ព្រមជាមួយនឹងក្សត្រទាំង៣ព្រះអង្គ ដែលមកពីទិសបូព៌ ឧត្តរ បស្ចិម ស្រេចក៏ចូលក្រាបបង្គំគាល់ព្រះមហាក្សត្រាធិរាជ ខណៈព្រះបាទអាទិច្ចវង្ស ទ្រង់ទតព្រះនេត្រឃើញ តែព្រះរាជបុត្រា ៣ អង្គ បាត់ ១ អង្គពុំឃើញត្រាស់ដណ្តឹងថា ដំណើរហេតុដូចម្តេច ក៏បានជាឲ្យព្រះថោងដែលគង់ព្រះនគរទិសទក្សិណពុំឃើញមក នោះរាជទូតក្រាបបង្គំថ្វាយរាជសារហើយ យកសេចក្តីក្រាបទូលតាមដំណើរ ដែលព្រះរាជបុត្រាត្រាស់អធ្យាស្រ័យត្រាស់ជំនុំនឹងអស់មុខមន្ត្រីសព្វសេចក្តី ឯព្រះបាទអាទិច្ចវង្សទ្រង់ជ្រាបសព្វប្រការហើយ ទ្រង់ព្រះក្រោធត្រាស់ថា ព្រះថោងរឹងទទឹងនឹងព្រះរាជនុញ្ញាដូច្នេះនោះដល់ស្លាប់ ចាំរៀបអភិសេកព្រះរាជបុត្រនៅរួចកាលណា នឹងឲ្យលើកទ័ពទៅចាប់យកមកសម្លាប់ចេញ ទើបនឹងពុំបានជាបម្រុងជម្រះតទៅ គ្រានោះស្តេចរៀបអភិសេកព្រះរាជបុត្រានៅឲ្យសោយរាជសម្បត្តិទទួលព្រះរាជនុញ្ញាស្នងស្តេច ហើយត្រាស់បង្គាប់ព្រះរាជបុត្រាទាំង៣

អង្គ ឲ្យលើកទ័ពសន្ធាប់គ្នាទៅចាប់ព្រះថោង ខណៈនោះអគ្គមហាសេនា សេនាបតីមុខមន្ត្រី និងទីប្រឹក្សាទាំងពួងយកសេចក្ដីក្រាបបង្គំទូលថាទោស ព្រះរាជបុត្រាដែលទទឹងទាស់នឹងអធ្យាស្រ័យនោះគួរទ្រង់ក្រោធ គួរប្រហារ ជីវិតបង់មែន ប៉ុន្តែដ្បិតព្រះថោងព្រះរាជបុត្រាមានព្រះទ័យអបអរអរិយ ក្សត្រាណាប្រជានុរាស្ត្រ ក្នុងព្រះនគរទិសទក្សិណនោះ យូរមកក៏សុខ សប្បាយ ពុំដែលកំហែងកំហោករាស្ត្រឲ្យបានសេចក្ដីក្ដៅក្រហាយ ហើយមកធ្វើឲ្យបានសេចក្ដីសុខសង្គមង សូមទ្រង់ព្រះមេត្តាប្រោស គួរតែ បំបរបង់ឲ្យចេញពីព្រះនគរទៅៗឯព្រះបាទអាទិច្ចវង្សទ្រង់ព្រះសណ្ដាប់ពាក្យ អគ្គមហាសេនា សេនាបតីមុខមន្ត្រី ទីប្រឹក្សាទាំងពួងទទួលទាស់ហើយ មានព្រះរាជឱង្ការតម្រាស់ ថាកូនចៅអញឯណាពុំប្រកបដោយសត្យកតញ្ញូ ពុំចង់ឃើញមុខមាត់ឡើយ ហើយបើទុកឲ្យនៅយូរៈឃើញថានឹងកើតហេតុ វិវាទទាំងគ្នាទៅមុខពុំខាន ដូច្នេះឲ្យលើកកងទ័ពទៅចាប់ឆាត់សក់ឲ្យសម្គាល់ ថាកាត់សាសន៍ទាំងស្នំគ្រួបក្សពួកក៏យកអង្កត់ឱសគ្រាសមាត់បីជង ហើយ ចេញទៅនៅផុតដែនព្រះរាជអាណាខេត្ត កុំឲ្យឮឈ្មោះបោះសម្លេងឡើយ ខណៈនោះព្រះរាជបុត្រាទាំង ៣ ព្រះអង្គ និងសេនារាជទាហាន ក្រាបបង្គំ លាលើកទ័ពចេញទៅតាមចាប់ព្រះថោង និងស្នំគ្រួបក្សពួក ក៏បានកាត់ សក់គ្រប់គ្នា គឺសម្គាល់ថា កាត់សាសន៍យកអង្កត់ឱសគ្រាសមាត់ ៣ ជង ក៏ដេញព្រះថោងនិងស្នំគ្រួបក្សពួក ឲ្យចេញពីព្រះនគរ ទៅដោយអរញ្ញ

ប្រទេសទិសទក្សិណ ផុតដែនព្រះរាជអាណាខេត្រ ហើយក្សត្រ ៤ ព្រះអង្គទ្រង់សោកក្រៃ អាល័យរលឹកនឹកអាណិតព្រះថោង ហើយសាក់ថយទ័ព ត្រឡប់វិលមកក្រាបបង្គំទូលព្រះវររាជបិតាតាមដោយនូវដំណើរសព្វគ្រប់ ហើយក៏ក្រាបបង្គំលាលើកព្យុហៈ ចាកត្រឡប់ទៅកាន់នគរទៅៗវិញ ទើបព្រះបាទអាទិច្ចវង្សទ្រង់ឲ្យព្រះរាជបុត្រាពៅបង្អស់ចេញទៅគ្រងព្រះនគរដែលដេញព្រះថោងចេញនោះ ៗនេះនឹងស្រដីឯព្រះថោងនិងស្នំគ្របក្សពួក កាលដើរចេញពីព្រះនគរក៏កើតធម្មសង្វេគរន្ធត់ស្លុតអង្គកាយចិត្តគិតច្រើនដំពូក ស្មើរទឹងបែកព្រះឧរ តឹងក្នុងថ្ងូមដង្ហើមប្រមាត់ ដើរចេញមកតាំងទុក្ខ ពុំសុខក្នុងកាយចំប្រចំញាប់ញ័រ លុះចេញផុតព្រះរាជអាណាខេត្រហើយចូលមកដល់នគរគោកធ្លកទៀបភូមិចាម ក៏នៅជាសុខជាមិត្រ ជាមេត្រីនឹងស្តេចចាម លុះនៅយូរទៅក៏ឲ្យអ្នកប្រាជ្ញបណ្ឌិត គិតក្លែងអក្សរសំស្ក្រឹតជាអក្សរខេមរៈ ថ្លែងភាសាដើម មិនឲ្យស្រដីភាសាដើមឲ្យស្រដីភាសាថ្មីប្រឡំភាសាខុតខ្លះ ភាសាសំស្ក្រឹតខ្លះ ប្រឡំភាសាចាមខ្លះ ហេតុដូច្នេះបានជាពួកចាមរាប់អក្ខរៈ ៣៣ តួ ថៈពាក្យខុតសំឡេងប្រហែលគ្នា ព្រះសមណថេរថេរីបរិញ្ញាជកបរិញ្ញាជិកា មានពីកាលនោះមកហើយក៏កើតវិវាទនឹងស្តេចចាម លើកទ័ពដេញស្តេចចាមរត់ឡើងទៅនៅចម្ប៉ាស័ក ជាដែនព្រះនគរឡូនាង មានកាលសម័យថ្ងៃមួយ ព្រះថោងបបួលអស់មហាតលិក ឡើងគង់ព្រះទីនាំងអស្សរត បរកាត់ផ្លូវខ្សាច់ទៅ

ក្រសាលនៅកោះគោកធ្លក វេលាថ្ងៃសៀលទឹកជោរឡើងនឹងវិលមកវិញ ក៏ពុំបានហើយខាននៅកណ្ដាលកោះគោកធ្លក លុះវេលាពត្រីនាងនាគកុមារី ជាព្រះរាជបុត្រីស្ដេចនាគរាជនាំបរិវារសឹងក្រឡាខ្លួនជារូបស្រីទេពអប្សរឡើងមកលេងនៅផ្ទួកកោះគោកធ្លក នោះព្រះថោងឃើញនាងនាគកុមារីរូបឆោមលោមពណ៌ល្អ ចាប់ចិត្តប្រតិព័ទ្ធ ទើបធ្វើជាទូតបាដិហារប្រស្នាសួរគ្នាទៅវិញទៅមកបាន ជ្រាបដំណើរទើទៃ ៗ ហើយព្រះថោងប្រលោមលោមមេត្រីនឹងនាងនាគ ក៏ព្រមតែចិត្តពុំទាន់ព្រមខ្លួន ទើបឲ្យសត្តសញ្ញាថា ៧ ថ្ងៃទៀត ឲ្យព្រះថោងរៀបសក្ការបណ្ណាការមកថ្វាយបង្គំសូមជណ្ដឹងដល់សម្ដេចព្រះវររាជបិតា មាតា នឹងសម្រេចដូចសេចក្ដីប្រាថ្នា ជាហើយនាងនាគ ក៏នាំបរិវារវិលទៅកាន់ពិភពនាគវិញ ឯព្រះថោងលុះទឹកនាចហើយ ឡើងគង់ព្រះទីនាំងអស្សតរ នាំពួកមហាតលិកវិលមកដល់ទីឋានលំនៅវិញ លុះគ្រប់ ៧ ថ្ងៃ ក៏រៀបអស់ព្រះរាជបណ្ណាការស្រេចហើយ តែងទ្រង់អង្គគ្រឿងអលង្ការ វិភូសិតវិសុទ្ធពិចិត្របនាហើយឡើងគង់លើអាជានេយ្យ នាំពួកមហាតលិកទៅកាន់កោះគោកធ្លក ខណៈនោះ នាងនាគកុមារី ព្រះរាជបុត្រីស្ដេចនាគរាជ លុះទៅដល់ស្ថានពិភពនាគវិញហើយ យកសេចក្ដីក្រាបបង្គំទូលសម្ដេចព្រះវររាជបិតាមាតាតាមដោយដំណើរ នឹងមានស្វាមី ឯស្ដេចនាគរាជជាសម្ដេចព្រះរាជបិតាមាតាបានទ្រង់ជ្រាបហើយ ក៏ទ្រង់ព្រមគ្នាប្រទានព្រះរាជបុត្រី ដោយនូវសេចក្ដី

ស្រឡាញ់ពេញចិត្ត លុះគ្រប់ ៧ ថ្ងៃ ស្ដេចនាគក៏នាំព្រះអគ្គមហេសីព្រះរាជបុត្រីបុត្រា នូវរាជវង្សានុវង្ស អង្គរក្សសេវកអគ្គមហាសេនាសេនាបតីមុខមន្ត្រីអាមាត្យយោធានាគទាំងពួង ឡើងមកកាន់កោះគោកធ្លក ស្ដេចនាគរាជបានជួបនឹងព្រះថោង ហើយក៏ធ្វើជាបាដិហារ្យប្រស្នាសាកសួរស្រួលទទួលដោយកិរិយាគារពស្មោះស ទ្រង់ផ្សំព្រះរាជបុត្រីនឹងព្រះថោង ទើបស្ដេចនាគរាជសម្ដែងឫទ្ធិ ស្រូបទឹកសមុទ្រសឹងកើតឡើងជានគរ វិចិត្រជាព្រះរាជវាំងកំផែងកែងសំអាតប្រាសាទរាជដ្ឋាន មានប្រាសាទ ៣ រដូវថ្វាយព្រះថោងនាងនាគឲ្យនៅរៀបការពិពាហមង្គលមានតូរ្យតន្ត្រី កើតឈ្មោះកេងព្រះថោងនាងនាគពីកាលនោះមក ហើយឲ្យព្រះថោងសោយរាជសម្បត្តិទ្រង់ព្រះនាមហៅថាព្រះបាទទេវង្សអស្ចារ្យ តាំងអភិសេកនាងនាគឡើងជាព្រះអគ្គមហេសីព្រះនាមនគរឲ្យហៅព្រះនគរក្រុងកម្ពុជាធិបតី ឲ្យមន្ត្រីនាគឡើងកាន់ជាប្រក្រតីជាមួយមនុស្ស កាលនោះមានសៀមចុះមកពីស្រុកលើមកនៅចឹងស្ពាធ្វើត្រីងៀតក៏ជូនទិស្សួយទឹកចឹង ចូលមកក្រាបទូលថ្វាយជាមួយពុំដែលខាន នោះស្ដេចចាមលើកទ័ពត្រឡប់មកដេញព្រះបាទទេវង្សអស្ចារ្យ ឯព្រះបាទទេវង្សអស្ចារ្យពុំដឹងខ្លួន ក៏រត់ឡើងទៅតាំងស្រុកនៅនគររាជសីមា ជាដែនក្រុងកម្ពុជាធិបតីគង់នៅនគររាជសីមានោះបាន ១ ឆ្នាំ ទើបព្រះបាទទេវង្សអស្ចារ្យលើកទ័ពត្រឡប់មកដេញស្ដេចចាមរត់ទៅតាំងស្រុកបយង់កោខ្វះ នៅភ្នំជីសូខ្វះ ឯព្រះបាទទេវង្សអស្ចារ្យ

ដោយរាជសម្បត្តិបរមសុខដុម ទឹកសមុទ្រក៏កាន់តែស្រក ដីក៏កាន់តែដុះចេញទៅធំ មនុស្សក៏កាន់តែច្រើន កាលព្រះអគ្គមហេសីទ្រង់គភ៌នោះ នាងទ្រង់ព្រះសុបិនឃើញសម្តេចអម្រិន្ទ្រាធិរាជ មកអង្អែលព្រះឧទរព្រះនាងមានកែវមណីរត្ន ១ មានរស្មីជាលប្រាក់ ៧ ពណ៌ ហើយព្រះអគ្គមហេសីក្រាបទូលសម្តេចព្រះស្វាមី ៗ ឲ្យហោរាទំនាយថា នឹងមានព្រះរាជឱរស្ស ១ ព្រះអង្គ ទ្រង់ឫទ្ធិតេជៈឈ្នះសត្រូវគ្រប់ទិស ក្រោយនោះព្រះអគ្គមហេសីទ្រង់គភ៌គ្រប់ខែ ១០ ក៏ប្រសូតព្រះរាជឱរស្ស មួយព្រះអង្គ ទ្រង់ព្រះនាមហៅព្រះកេតុមាលា លុះព្រះជន្មបាន ៦ ព្រះវស្សា ព្រះឥន្ទប្រើព្រះមាតុលីទេវបុត្រ ឲ្យនាំព្រះរាជរថចុះមកក្រាបទូលព្រះបាទទេវង្សអស្ចារ្យថា ព្រះកេតុមាលានេះ ជាព្រះរាជបុត្រព្រះឥន្ទដែរ ដ្បិតព្រះឥន្ទបាននិមន្តទេវបុត្រ ឲ្យច្យុតចុះមកបង្កើត ហើយក៏អញ្ជើញព្រះកេតុមាលា បញ្ជិះព្រះរាជរថនាំឡើងទៅទុកឯឋានតាវត្តិង្ស នៅ ៧ ថ្ងៃមនុស្សលោក ហើយសម្តេចព្រះឥន្ទ្រាធិរាជ ឲ្យព្រះមាតុលីទេវបុត្រ ជូនព្រះកេតុមាលាចុះមកឯមនុស្សលោកវិញ ទើបព្រះឥន្ទប្រើព្រះវេស្សកម្មទេវបុត្រ ឲ្យច្យុតចុះមកបង្កើតជាមនុស្សបេះការ ហើយបានសាងប្រាសាទតូច ១ ថ្វាយព្រះកេតុមាលាគង់ នោះទើបព្រះបាទទេវង្សអស្ចារ្យសុណ្ណគគៈទៅ ទើបព្រះវេស្សកម្មទេវបុត្រ ដែលកើតជាមនុស្សបេះការនោះ សាងប្រាសាទធំមួយទៀត [illegible] សព្វសារពើតែង

សព្វគ្រប់ថ្វាយព្រះកេតុមាលាឲ្យ សាយរាជសម្បត្តិ មានព្រះផ្លួលល្អ ក្រក់ទុកនៅបុរោហិតរក្សា ដរាបមកដល់បច្ចុប្បន្នឥឡូវនេះ ហើយរៀប អភិសេកព្រះកេតុមាលាឲ្យសោយរាជសម្បត្តិ គង់នៅព្រះរាជវាំង មហា នគរវត្ត ព្រះនគរក៏សុខសប្បាយក្សេមក្សាន្ត អស់ប្រទេសឯទៀតសន្មត ហៅថានគរខ្មែរ ប្រែនាមនគរហៅថាក្រុងកម្ពុជាធិបតី សិរីសន្ធរបវរឥន្ទ្របត្ត កុរុរដ្ឋរាជធានីបុរីរម្យឧត្តមមហាឋាន ហើយបានសាងព្រះផ្លួលព្រះនគរ សព្វដំបន់ច្រើនអនេក ទើបព្រះកេតុមាលា បង្កើតព្រះរាជបុត្រា ២ ព្រះអង្គ ព្រះនាមព្រះវិនោរាជ ១ ព្រះឧទ័យ ១ ឯព្រះកេតុមាលាស្តេចទ្រង់ព្រះ ឧម្តកាពាធមួយឆ្នាំ ព្រះឥន្ទឲ្យព្រះព្រហ្ម ១ អង្គ ចុះមករម្ងាប់ចង្រៃនោះ ក៏បានក្សាន្តដូចអំពីដើមរៀងមក លុះព្រះពុទ្ធសករាជបាន ៦៣៣ ព្រះ វស្សា ឆ្នាំថោះ ទើបព្រះអាចារ្យ តាំងឡើងជាមហាសករាជសក ១ រៀង មកនោះ រៀបអភិសេកព្រះកេតុមាលា សោយរាជសម្បត្តិម្តងទៀត ទ្រង់ ព្រះនាមហៅថាព្រះបាទអដ្ឋពលពាហុសោ ទើបព្រះឥន្ទតាំងទូងរដ្ឋ ៧ បុរោហិត ៧ អាសាឍហានរដ្ឋ ៧ ឲ្យនៅរក្សាព្រះបាទអដ្ឋពលពាហុសោ ហេតុស្តេចមានបុណ្យណាស់ ឯព្រះបាទអដ្ឋពលពាហុសោសោយរាជ សម្បត្តិបរមសុខអង្វែងទៅ ទ្រង់ជរាភាពក៏សោយវិលាល័យទៅ ខណៈ នោះមានក្មួយព្រះមហារាជ ត្រូវព្រះធម្មវង្ស ជាទីឥសីកត្ត ១ អង្គយកព្រះកាដិ នេយ្យា ស្តេចបានសោយរាជសម្បត្តិ ទ្រង់ព្រះនាមបទុមវង្សតាំងវិនោរាជា

សម្តេចឧបរាជ តាំងព្រះឧទ័យរាជាជាសម្តេចព្រះមហាឧបរាជ លុះអំណើះ ទិនព្រះបទុមវង្សសុគតទៅ ព្រះវិនោរាជដែលតាំងនៅឧបយោរាជសោយរាជសម្បត្តិ លុះឥតទិនសម្តេចព្រះវិនោរាជជាព្រះរៀមទៅទៀតព្រះឧទ័យរាជដែលតាំងនៅសម្តេចព្រះមហាឧបរាជ សោយរាជសម្បត្តិ ហើយស្តេចទៅក្រសាលនៅផ្ទុកខ្សាច់ខែត្របាសិលាមិ សមុទ្ររទិនទាំងនាគមួយក៏គិតសម្រាលពងពោលនៅទីផ្ទុកខ្សាច់ ៗ កាលនោះមានឈ្មួញនេះម្នាក់ឈ្មោះនាងគង់ ពុកចង្កាអមតាង រើសយកនាគនោះយកទៅស្រុកញាស់ កើតជាកូនមនុស្ស ឲ្យឈ្មោះហៅព្រះកេង ឯព្រះឧទ័យរាជសម្តេចមហាសោយរាជសម្បត្តិបរមសុខ បង្កើតបុត្រា ១ អង្គទ្រង់ព្រះនាមព្រះបទុមវង្សាសុរិយវង្ស ទើបព្រះឧទ័យរាជក៏សុវណ្ណគតទៅ នោះព្រះបទុមសុរិយវង្សបានសោយសោយរាជសម្បត្តិ ស្នងសម្តេចព្រះវររាជបិតា ឯនាយគង់អមតាងក៏បានជានាយសួយ តែងដងទឹកនាំចូលមកក្រាបទូលថ្វាយព្រះបទុមសុរិយវង្សពុំដែលខាន ទើបនាយ គង់ អមតាង ក៏អនិច្ចកម្មទៅ នៅព្រះកេងជាកូនចិញ្ចឹម នោះព្រះកេងក៏បានជានាយសួយទឹកតាងនាយគង់ ព្រះកេងមានបុណ្យប្ញទ្ធិអានុភាពណាស់ ទើបមានព្រះអាជ្ញាហ្វូងទៅនាំទឹកសួយ លុះបានដល់ទៅព្រះកេងបង្គាប់ឲ្យត្បាញជាលក្នែកគ្រួចនោះ២៥ ហើយព្រះកេងដងទឹកដាក់ក្នុងជាលផ្ទុកលើរទេះ ប្រគល់ឲ្យអាជ្ញាហ្វូងក៏ខ្វាចអំណាចព្រះកេង ហើយ ប នាំ ទេះផ្ទុះជាលទឹកនោះ ត្រឡប់ចូលមកក្រាបបង្គំទូលថ្វាយព្រះ

សុរិយវង្ស ស្ដេចទ្រង់ជ្រាបហើយព្រួយព្រះរាជហឫទ័យថាអ្នកមានបុណ្យ កើតមកហើយ ទ្រង់ត្រាស់ប្រើទៅពញាខ្ញុំគេជាជំឌិនឲ្យទៅចាប់ព្រះកេង១ ជីនខ្លួន រត់ឡើងទៅដល់មឿងពិជិត សុំបាយមេស្រុក ៗ ឲ្យបាយនឹងត្រីក្រាញ់ មកព្រះកេង ១ សុំបាយបូតយកតែសាច់ត្រីក្រាញ់ សល់នៅតែក្បាលនឹងឆ្អឹង បោះចោលទៅក្នុងទឹកស្រះ ហើយបន្ទាប់ថាសត្វត្រីរស់ទៅហែលទៅ ត្រីក៏រស់មានតែក្បាលនឹងឆ្អឹងនៅហែលសព្វថ្ងៃនេះ ហើយព្រះកេងនៅទីទ្វារ លុះរួចកាច់មែកឈើធ្វើជាកៀរ ដូតទៅនៅដីបន្ទាប់ថាឲ្យឈើដុះរស់លូតលាស់ឡើង ឈើក៏រស់នៅសព្វថ្ងៃឈ្មោះហៅថាឈើស្អុយ ឯពញាគេជាជាំឌិន តាមទៅដល់មឿងពិជិតព្រះកេងជីនខ្លួនក៏រត់ឡើងទៅដល់ស្រុកសុខោថៃ ហើយព្រះកេងបួសជាភិក្ខុនៅវត្តនោះ វេលាដែលភិក្ខុកេងបោសឋានអាកាមព្រះវិហារ ទើបពញាគេជាជាំឌិនមុជដើរក្នុងដីទៅផុសឡើងបានពាក់កណ្ដាលខ្លួន ក្នុងដីទីអាកាមជួបនឹងភិក្ខុកេង សួរថាព្រះកេងនៅឯណា នោះភិក្ខុកេងប្រាប់ថានៅហ្នឹងស័នចុះសឹមប្រាប់ទើបពញាគេជាជំឌិនក៏នែខ្លួន ជាថ្មនៅសព្វថ្ងៃ ហេតុព្រះកេងកាលពីជាតិមុន បានប្រគេនទឹកបានព្រះគោនាគមនោ បានជាមាត់ទិព្វ ឯសម្ដេចសុខោថៃ ក៏សុវណ្ណគតទៅ ទើបភិក្ខុកេងថយសិក្ខាបទចេញបានសោយរាជសម្បត្តិស្រុកសុខោថៃនោះ ប្រែព្រះនាមថាសម្ដេចស្រីចន្ទ្រាធិបតី ស្ដេចគង់ជាបរម

( នៅមានត )

៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE


ឆ្នាំទី ៤៤ ខែមេសា

ព.ស. ២៥១៦ គ.ស. ១៩៧២

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : អ៊ុក ~ សាម៉ន

និពន្ធនាយក - អ្នករៀបចំ លី ធាម តេង

គណៈកម្មការនិពន្ធ:

ព្រះពោធិវង្ស ស្នួន–ហាយ

លោក ផល–និក អ្នកស្រី ពេជ–សល់

# បញ្ជីរឿង

អត្ថបទ | ទំព័រ

## ១— ផ្នែកសាសនា :


១. វិបារណកថា មនុស្សលោក រៀបរៀងដោយ ព្រះញាណវង្ស អ៊ុម-ស៊ុម . ១៨៧

២. ចតុរារិយសច្ច (ត) រៀបរៀងដោយ ព្រះភិក្ខុ ប៉ាង-ខាត់ . . ២០៧


## ២— ផ្នែកអក្សរសាស្ត្រ :


៣- រឿងសាមកុក (ត) ឧកញ៉ា ទូ-កន ប្រែរៀបរៀង . . . . . ២១២

៤- តើគេគិតដូចម្តេចអំពីជនជាតិជប៉ុន? ប្រែសម្រួលដោយ
អ្នកស្រី ពេជ-សល់ . . . . ២២០

៥- កវីទស្សន: ចំពោះស្នេហាបុរស និង ស្ត្រី (ត) (ពាក្យកាព្យ) លោក
ឆល-ទិត រៀបរៀង . . . . ២៣៥

៦ ភពិទ្យាវិការ សកស្រ្តាវិត្តកោកកាក (ត) លោក យួន-សែប បម្លង
ចេញពីស្លឹករឹត . . . . . ២៥១


---

### តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ៛

អាណាព្យាបាលសូមផាក់ជា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

**ផ្នែកសាសនា**

# មនុស្សលោក

រៀបរៀងដោយ ព្រះញាណវង្ស អ៊ុម-ស៊ុម
ក្រុមជំនុំព្រះត្រៃបិដក

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តាមអត្ថន័យរបស់ព្រះពុទ្ធសាសនា ពាក្យនេះ ចែកជាពីរគឺ មនុស្ស ១ លោក ១ ។

**មនុស្ស** តាមសព្ទ គឺអ្នកដឹងនូវហេតុនិងមិនមែនហេតុ, អ្នកមានសន្តានចិត្តខ្ពង់ខ្ពស់, អ្នកមានគំនិតល្អិតល្អន់ ។ តាមសេចក្ដី បានដល់សត្វវិសេសមួយពួក ដែលមានចិត្តគំនិតអធ្យាស្រ័យ កិរិយាមារយាទនិងលក្ខណៈខ្ពង់ខ្ពស់ ប្លែកពីសត្វតិរច្ឆាន គឺចេះដឹងស្គាល់ហេតុល្អ និងហេតុអាក្រក់ ស្គាល់ខុសស្គាល់ត្រូវ ស្គាល់ថា ហេតុនេះ ឲ្យផលជាសុខ ហេតុនេះ ឲ្យផលជាទុក្ខ អំពើដែលកំពុងប្រព្រឹត្តធ្វើនេះ នាំឲ្យមានគ្រោះថ្នាក់ ឬនាំឲ្យមានសុភមង្គល កិច្ចការនេះ នាំឲ្យវិនាសហិនហោច កិច្ចការនេះនាំឲ្យបានចម្រុងចម្រើនរុងរឿង ចេះធ្វើច្បាប់-ចេះគោរពច្បាប់ ។ល។

**លោក** តាមសព្ទ គឺសភាវធម៌ដែលតែងតែវិនាសទៅ ឬរលាយទៅ ។ តាមសេចក្ដី បានដល់សភាវធម៌ដែលតែងតែកើតឡើងហើយវិនាសទៅវិញជារឿយ ៗ ជួនកាលបាត់ ១ ឃើញ ១ គឺកើតឡើងហើយ

បាត់ទៅ បាត់ទៅហើយកើតឡើងវិញ តាមកាលសម័យ ។ បើរាប់ជាប្រភេទគឺ ដី ទឹក ភ្លើង ខ្យល់ មេឃ អាកាស ព្រះអាទិត្យ ព្រះចន្ទ ផ្កាយ មនុស្ស សត្វតិរច្ឆានទូទៅទាំងអស់ ឋានមនុស្ស ឋានសួគ៌ ឋានព្រហ្ម ឋាននរក ប្រេត ។ល។ រួបរួមពាក្យទាំងពីរនេះមកគឺ មនុស្សដែលកើតដោយអំណាចលោកគឺ ដី ទឹក ភ្លើង ខ្យល់ និងអាកាសផ្សំផ្សំឡើង មិនយូរប៉ុន្មាន ក៏វិនាសឬរលាយក្លាយទៅជាដី ទឹក ភ្លើង ខ្យល់និងអាកាសវិញ ហៅថា មនុស្សលោក ។ មនុស្សលោក មានជាតិសាសន៍ មានឈ្មោះ មានចំនួន មានប្រភេទ មានលំនៅ មានអ. ធ្យាស្រ័យ មានមុខការ មានជំនឿ ។ល។ ច្រើនស្ទើររាប់មិនអស់ ដោយធម្មតាតាក់តែងមក ។

## មនុស្សលោកនិងវាសនា

មនុស្សលោកម្នាក់ ៗ សុទ្ធតែមានព្រេងវាសនា ដោយដៀសវាងពីរូប ។ វាសនានោះគឺជាលទ្ធផលរបស់កម្មចាស់ ដែលតាក់តែងរៀបចំកម្រិតក្របខណ្ឌ ឲ្យមនុស្សលោកទៅជាល្អ អាក្រក់ ខ្ពង់ខ្ពស់ ថោកទាប ក្រខ្សត់ សម្បូរសប្បាយ អាយុវែង អាយុខ្លី មានប្រាជ្ញា ឥតប្រាជ្ញា បេះដឹង ល្ងង់ខ្លៅ ។ល។ ប៉ុន្តែ គេមានទំនងអាចដណ្តើបយកជ័យជម្នះនឹងវាសនាអាក្រក់បានខ្លះ ៗ ឬខកខានបានទទួលជោគវាសនាល្អ ក្នុងពេលខ្លះ ៗ ដោយមាន :

១-**វីរិយៈ** សេចក្ដីព្យាយាម គឺខំប្រឹងប្រែងខ្នះខ្នែង រំលោភ សង្កាត់ លះបាបអកុសលលាមកអាក្រក់ចាស់ ដែលកើតមានហើយក្នុងអតីតកាល ឲ្យអស់ពីសន្ដានទៅ ព្យាយាមការពារបិទស្ទះបាបអកុសលថ្មី ក្នុងបច្ចុប្បន្ននិងអនាគតដែលមិនទាន់កើតមាន កុំឲ្យកើតមាន ព្យាយាមចម្រើនបុណ្យកុសលថ្មី ក្នុងបច្ចុប្បន្ននិងអនាគត ដែលបម្រុងនឹងកើតឬកំពុងកើតមាន ឲ្យកើតមានច្រាកដឡើង ព្យាយាមអប់រំបុណ្យកុសលចាស់ដែលមានស្រាប់ហើយ ឲ្យរឹងរឹតតែចម្រើនកើនឡើង កុំឲ្យសាបរលាបទៅវិញ ។

**វីរិយៈ**: សេចក្ដីព្យាយាមនេះ ព្រះពុទ្ធសាសនា បានចាត់ទុកថា ជាគុណធម៌មួយយ៉ាងប្រសើរបំផុត, មនុស្សលោកប្រព្រឹត្ត-ធ្វើអ្វី ១ បើខ្វះសេចក្ដីព្យាយាមហើយ ពុំអាចសម្រេចផលតាមប្រាថ្នាឡើយ ពីព្រោះធម៌នេះអាចធ្វើមនុស្សលោកដែលពុំធ្លាប់មានកេរ្តិ៍ឈ្មោះ ឲ្យទៅជាអ្នកមានកេរ្តិ៍ឈ្មោះយ៉ាងធំធេងក៏បាន ធ្វើមនុស្សលោក ឲ្យទៅជាទេវតា ជាព្រហ្ម ជាពោធិសត្វ ជាព្រះសម្ពុទ្ធក៏បាន ធ្វើមនុស្សលោកឲ្យរួចផុតអំពីទុក្ខទោសគ្រោះថ្នាក់ក៏បាន ។ ព្រោះហេតុនោះ ទើបក្នុងចំនួនពុទ្ធការកធម៌ ១០ គឺធម៌ដែលសាងឬធ្វើមនុស្សលោក ឲ្យទៅជាព្រះពុទ្ធ, មានវីរិយៈ នៅក្នុងនោះដែរ ដូចជាព្រះសម្ពុទ្ធបរមគ្រូ កាលមិនទាន់ត្រាស់ដឹង នៅជាព្រះពោធិសត្វព្រះនាម **ជនក** នៅឡើយ ទ្រង់កំពុងសាង វីរិយបារមី ព្រះអង្គខំព្យាយាមហែលឆ្លងមហាសមុទ្រយ៉ាងធំធេង ត្រាតែដល់ត្រើយ

រួចចាកគ្រោះថ្នាក់បាន, សង្ខេបរឿងដូចតទៅនេះ :

កាលកន្លងទៅយូរអង្វែងហើយ ព្រះបរមពោធិសត្វ ទ្រង់ច្យុតចាកទេវលោក មកចាប់បដិសន្ធិក្នុងផ្ទៃនៃអគ្គមហេសីព្រះបាទអរិដ្ឋជនក ក្នុងក្រុងមិថិលាមហានគរ ។ ក្រោយបន្តិចមក នគរកើតទេសង្គ្រាម ព្រះបាទអរិដ្ឋជនក ទ្រង់សោយទិវង្គតទៅ ព្រះនាងក៏កៀសខ្លួនរត់ចេញពីនគរទៅនៅឯក្រុងចម្បានគរ ។ កាលព្រះពោធិសត្វប្រសូតមកហើយ ព្រះនាងថ្វាយព្រះនាមថា មហាជនកកុមារ ។ លុះព្រះអង្គមានព្រះជន្មាយុ ១៦ វស្សា ក៏លាព្រះវរមាតាត្រឡប់ទៅនគរវិញ ធ្វើដំណើរដោយជិះសំពៅ ។ លុះទៅដល់កណ្ដាលសមុទ្រធំធេង មានខ្យល់ព្យុះយ៉ាងខ្លាំងបោកបក់បែកសំពៅ លិចលង់ក្នុងលំហ មហាសមុទ្រ, មនុស្សដែលនៅក្នុងសំពៅទាំងប៉ុន្មានស្លាប់អស់ នៅសល់តែព្រះពោធិសត្វមួយព្រះអង្គឯង ទ្រង់ខំតាំងសេចក្ដីព្យាយាមហែលទឹកអស់ ៧ ថ្ងៃ ទើបមណីមេខលាទេពតាដែលថែរក្សាសមុទ្រ មកស្រង់ព្រះអង្គ យកទៅដាក់ក្រោមដើមស្វាយ ក្នុងឧទ្យានក្បែរនគរមិថិលានោះ ។ នៅពេលនោះពួកមហាជនកំពុងតែដើរស្វែងរកអ្នកមានបុណ្យ ដើម្បីលើកឲ្យសោយរាជ្យក្នុងនគរមិថិលា ដោយព្រះអង្គមានបុណ្យស្រាប់ គេក៏លើកព្រះអង្គឲ្យសោយរាជ្យ អភិសេកជាមួយនឹងនាងសិម្ពិទី ឲ្យជាអគ្គមហេសី រួចហើយទើបព្រះអង្គទៅដង្ហែយកព្រះមាតាមកនៅក្នុងនគរមិថិលាវិញ ។

**វីរិយៈ** នេះ មិនត្រឹមតែធ្វើមនុស្សលោក ឲ្យទៅជាខ្ពង់ខ្ពស់ថ្លៃថ្នូរ ប៉ុណ្ណោះទេ គឺទុកដូចជារបងឬស្សស្រួស សម្រាប់បិទការពារមិនឲ្យវាសនា ថោកទាប ដែលបម្រុងនឹងកើតមាន មិនឲ្យកើតបានទៀតផង ។

**២- ហីនវីរិយៈ**: សេចក្តីព្យាយាមបន្ធូរបន្ថយ គឺលះបង់សេចក្តីព្យាយាម មិនប្រារព្ធផ្តើមកិច្ចការចាំបាច់ ដែលត្រូវធ្វើខានមិនបាន ។ ហីនវីរិយៈ នេះ ព្រះពុទ្ធសាសនា ចាត់ទុកថា ជាអកុសលធម៌មួយយ៉ាង ចង្រៃបំផុត ពីព្រោះអាចធ្វើមនុស្សលោកឲ្យទៅជា: អាក្រក់ ថោកទាប ក្រខ្សត់ អាយុខ្លី អប្បឥតប្រាជ្ញា ល្ងង់ខ្លៅ ។ល។ ក៏បាន អាចធ្វើមនុស្ស ឲ្យក្លាយជាតិកំណើត ទៅជាសត្វតិរច្ឆានក៏បាន ទៅជាអាទិសមានកាយ គឺ ប្រេត អសុរកាយក៏បាន រហូតដល់ទៅបំផ្លាញវាសនា របស់មនុស្សលោកដែលបម្រុងនឹងខ្ពង់ខ្ពស់ថ្លៃថ្នូរ ឲ្យទៅជាថោកទាបវិញក៏បាន ។

**៣- សម្បទា** ការដល់ព្រម គ្រប់គ្រាន់ បរិបូណ៌សមប្រកប មាន ៤ យ៉ាងគឺ

ក-ការក្រោកខ្មីឃ្មា ស៊ុះស្មា ស្រាក់ស្រាទេញ មិនតំអក់ទម្រន់ ក្រើនក្រតើន រៀសរៃ ប្រឹងប្រែង ស្វះស្វែងរកសិក្សាចំណេះវិជ្ជា សម្រាប់ផ្លូវធម៌និងផ្លូវលោក ទាន់ខ្លួនកំពុងពេញវ័យ ខំប្រឹងប្រែង ប្រកបការងារ ទាន់ពេលវេលា ឬកាលសម័យ មិនប្រកាន់ថាយប់ថ្ងៃ ក្តៅត្រជាក់

លំបាកស្រណុក ដើម្បីកាន់កាប់សម្បូរសប្បាយដោយភោគទ្រព្យ ហៅថា ឧដ្ឋានសម្បទា ។

ខ- ការថែរក្សា គឺបានភោគទ្រព្យមកហើយ ត្រូវចេះថែរក្សាការពារ រៀបចំទុកដាក់ ឲ្យបានគង់វង់ កុំឲ្យវិនាសអន្តរាយបាត់បង់ទៅវិញ ហៅថា អារក្ខសម្បទា ។

គ ភាពជាអ្នកមានមិត្រល្អ គឺមិត្រដែលមានចិត្តស្មោះត្រង់នឹងខ្លួន មិត្រដែលរួមសុខទុក្ខជាមួយគ្នា មិត្រហ៊ានប្រាប់ការណ៍អាថ៌កំបាំងហើយ ពិតផង មិត្រដឹកនាំឲ្យបានប្រយោជន៍ ចម្រុងចម្រើនវៀរចាកទោសពៃរ៍ ហៅថា កល្យាណមិត្តតា ។

ឃ ជាអ្នកចិញ្ចឹមជីវិតស្មើ គឺចិញ្ចឹមជីវិតស្មើនឹងផ្នែកទ្រព្យសម្បត្តិ ដែលខ្លួនរកបានមកហើយបែងចែកជា ៤ ផ្នែក ទុកមួយផ្នែកសម្រាប់ចាយវាយនិងប្រើប្រាស់ធម្មតា ហៅថា សមជីវិតា ។

សម្បទាទាំង ៤ យ៉ាងនេះ ទុកដូចជាឃ្លាំងសម្រាប់ផ្ទុកទ្រព្យសម្បត្តិផង អាចញុំាងមនុស្សអ្នកខ្សត់ខ្សោយភោគទ្រព្យ ឲ្យទៅជាអ្នកមានសម្បូរហូរហៀរផង ជាជំនួយដល់ឋានន្តរខ្ពង់ខ្ពស់របស់មនុស្សលោកផង ជារបង សម្រាប់ការពារភ័យអាក្រក់[illegible] របស់មនុស្សលោកដែលបម្រុងនឹងកើតមាន កុំឲ្យកើតមានផង ។

**៤- កោសជ្ជៈ:** អ្នកខ្ជិលច្រអូសកោកង៉ក់ ធ្ងន់ដៃធ្ងន់ជើង លើកឈាន

មិនរួច ៗ គោសដ្ឋៈនេះ ព្រះពុទ្ធសាសនាក៏ចាត់ទុកថា ជាអកុសលមួយយ៉ាងចង្រៃបំផុតដែរ ពីព្រោះវាអាចបំផ្លិចបំផ្លាញវាសនារបស់មនុស្សលោកដែលបម្រុងនឹងខ្ពង់ខ្ពស់ថ្លៃថ្នូរ ដោយមានទ្រព្យសម្បត្តិស្តុកស្តម្ភមាំមួនមានចំណេះវិជ្ជា ជាកវីបណ្ឌិតយ៉ាងជំនាញ ឲ្យទៅជាអ្នកទីទាល់ក្រ រហេមរហាមក៏បាន ឲ្យទៅជាអ្នកល្ងង់ខ្លៅ អប្បឥតប្រាជ្ញាក៏បាន ទុកដូចជាគម្របឬសម្រាស់ សម្រាប់បិទក្តិតវាសនាខ្ពង់ខ្ពស់ថ្លៃថ្នូរ របស់មនុស្សលោកមិនឲ្យមានពន្លឺរស្មីក៏បាន ៗ

ដើម្បីពិសោធន៍ឲ្យដឹងថា តើមនុស្សលោកម្នាក់ៗ ត្រូវមានវាសនាខ្ពង់ខ្ពស់ថ្លៃថ្នូរឬទេ គេត្រូវតែលះបង់ហីនវិរិយៈ និងគោសដ្ឋៈ ចេញជាដាច់ខាត ហើយប្រញាប់ប្រញាល់ចម្រើនវិរិយៈ និងសម្បទា ឲ្យកើតឡើងជំនួសវិញភ្លាមៗ ពីព្រោះវាសនាគឺបុណ្យព្រេង ពុំមែនលើកទ្រព្យសម្បត្តិនិងចំណេះវិជ្ជាតាមមកជូន ដោយមនុស្សលោក គ្មានព្យាយាមនិងប្រឹងប្រែងនោះបានឡើយ ស្ករមាននៅក្នុងផ្លែត្នោត និងដើមអំពៅពិតមែនប៉ុន្តែផ្លែត្នោតឬដើមអំពៅ ពុំមែនបញ្ចេញស្ករទាំងដុំ ទាំងគ្រាប់ទាំងនាឡិទាំងកញ្ចប់មកជូន ដោយមនុស្សលោកមិនគាបយកទៅរម្ងាស់បានឡើយ ៗ

## មនុស្សលោកនិងមិត្ត

អ្នកដែលរាប់អានគ្នាយ៉ាងជិតដិតស្និទ្ធស្នាល អស់ពីចិត្តថ្លើម ហៅថាមិត្ត ៗ មនុស្សលោកម្នាក់ៗ បើសង្កេតតាមដានសាច់ការពិតមួយ សុទ្ធតែ

ប្រាថ្នារកសុខទាំងអស់គ្នា, ដូច្នេះម្នាក់ ៗ ពុំអាចនៅទ្រមឹងត្រមោចតែម្នាក់ឯងបានទេ គឺគេត្រូវតែស្វែងរកការចងមិត្ត ដើម្បីរកពង្រីកសេចក្តីសុខដែលគេបានផ្ទាល់ខ្លួនមកខ្លះ ៗ ហើយ ឲ្យទូលំទូលាយ ៗ តាមគម្ពីរព្រះពុទ្ធសាសនា សម្តែងអំពីមិត្រមានពីរពួក :

១ មិត្រដែលមានចិត្តគំនិតនិងអធ្យាស្រ័យល្អ ហៅថា កល្យាណមិត្រ,

២ - មិត្រដែលមានចិត្តគំនិត និងអធ្យាស្រ័យលាមកអាក្រក់ ហៅថា បាបមិត្រ ។

### មិត្រល្អមាន ៤ ប្រភេទគឺ

ក - មិត្រជួយដឹកនាំទំនុកបម្រុងឲ្យមានដំណើរស្រួល ឆ្ពោះទៅរកសេចក្តីចម្រើន,

ខ - មិត្ររួមសុខទុក្ខជាមួយគ្នាមិនរត់ចោលគ្នាក្នុងគ្រាមានអាសន្នអន់ក្រ,

គ - មិត្រណែនាំ ប្រាប់ពន្យល់អំពីសេចក្តីចម្រើន,

ឃ - មិត្រមានសេចក្តីអនុគ្រោះ និងអាណិតអាសូរដល់គ្នា ៗ

### មិត្រអាក្រក់មាន ៤ ប្រភេទគឺ

ក - មិត្រគិតតែចង់បានរកប្រយោជន៍ពីមិត្រវិញ,

ខ - មិត្របានតែខាងសម្តី គឺល្អតែមាត់ក្រៅ,

គ - មិត្រប៉ុនខាងនិយាយអែបអបចាក់បណ្តោយតាម,

ឃ - មិត្រដឹកនាំឲ្យតែខាងវិនាសហិនហោច ៗ

មិត្តដែលមនុស្សលោកត្រូវចង គឺកល្យាណមិត្ត ។ កល្យាណមិត្តនេះ ទោះបីមានតែម្នាក់ក៏ដោយ មនុស្សលោកត្រូវតែចងភ្ជាប់ទុកជាការចាំបាច់ ពីព្រោះមិត្តនេះ អាចជួយផ្តល់សេចក្តីសុខចម្រុងចម្រើនដល់មនុស្សលោក បានដូចបំណង ដូចជាព្រះសម្មាសម្ពុទ្ធជាដើម ព្រះអង្គតែមួយព្រះអង្គឯងគត់ ប៉ុន្តែ អាចរកសេចក្តីសុខពិត មកជូនមនុស្សលោក បានយ៉ាងទូលំទូលាយ ។

មិត្តដែលមនុស្សលោកមិនត្រូវចង ឬមិនត្រូវសេពគប់ គឺបាបមិត្ត ។ បាបមិត្តនេះ ទោះបីមានច្រើនយ៉ាងណាក៏ដោយ ត្រូវតែចៀសវាងចេញឲ្យឆ្ងាយជាដាច់ខាត ពីព្រោះមិត្តនេះ ផ្តល់សុទ្ធតែទុក្ខទោសវិនាសអន្តរាយ ដល់មនុស្សលោកយ៉ាងពិតប្រាកដ ។ ដូចជាស្តេចអជាតសត្រូវ ទៅចងមិត្តនឹងភិក្ខុទេវទត្តដែលជាបាបមិត្ត គឺភិក្ខុទេវទត្តនេះជាជាតិក្សត្រ មានមានះខ្លាំងណាស់ បានប្រណែនឈ្នានីសនឹងព្រះសម្មាសម្ពុទ្ធ ដោយអាងលេសថា ព្រះសម្មាសម្ពុទ្ធជាជាតិក្សត្រ បំណែកខ្លួនក៏ជាជាតិក្សត្រដែរ ឥឡូវនេះ បើព្រះអង្គបានត្រាស់ជាព្រះពុទ្ធហើយ ខ្លួនអញក៏ត្រូវតែបានត្រាស់ជាព្រះពុទ្ធដែរ ទើបខំព្យាយាមធ្វើឃាតព្រះសម្មាសម្ពុទ្ធ លុះធ្វើមិនបានសម្រេចដូចបំណង ក៏ទៅនិយាយបញ្ចុះបញ្ចូលល្បួងលោមបោកបញ្ឆោតស្តេចអជាតសត្រូវ ដែលកំពុងមានវ័យនៅក្មេង ដើម្បីជាកម្លាំងជួយឲ្យបានសម្រេចដូចបំណង ដោយឧបាយកលផ្សេង ៗ ថា ព្រះអង្គ!

មនុស្សលោកឥឡូវនេះ អាយុខ្លីពេកាស់ ហើយព្រះអង្គកំពុងនៅក្មេង ក្រែង មិនបានសោយរាជ្យ ពីព្រោះរាជសម្បត្តិនោះ ត្រូវធ្លាក់មកលើព្រះអង្គ ហើយ ហេតុនេះ សូមព្រះអង្គសម្លាប់ព្រះវរបិតារបស់ព្រះអង្គពេលទៅ ទើបបានសោយរាជ្យឆាប់ ចំណែកអាត្មាភាពឯនេះ កំព្យាយាមធ្វើគត់ព្រះសម្មាសម្ពុទ្ធដែរ ដើម្បីបានត្រាស់ដឹងឆាប់ ៗ ស្ដេចអជាតសត្រូវ ហេតុតែខ្លួននៅក្មេង ខ្វះសេចក្ដីមិនទាន់ដឹងការណ៍ពក់ជ្រៅ កំជឿស្ដុង ព្យាយាមរករឿងសម្លាប់ព្រះបាទពិម្ពិសាល ជាព្រះវរបិតាពល់តែបាន ហើយក្រោយមក កំបានសោយរាជ្យមែន ៗ ចំណែកភិក្ខុទេវទត្ត ទោះបីទំព្យាយាមធ្វើគត់ព្រះសម្មាសម្ពុទ្ធ យ៉ាងណា កំមិនបានសម្រេចដូចបំណង ពល់តែបែកដើមទ្រូងស្លាប់ ព្រះធរណីស្រូប ទៅកើតក្នុងអវិចីនរក ទល់គ្មានទីងសព្វថ្ងៃនេះ ៗ

## មនុស្សលោក និង ច្បាប់

មនុស្សលោកមិនអាចនៅតោលតែម្នាក់ឯងបានឡើយ គឺត្រូវនៅរួមគ្នាជាសង្គម ៗ សង្គមមានច្រើនប្រភេទ :

- សង្គមតូចបំផុត មានត្រឹមតែប្ដី ប្រពន្ធ កូន ចៅ ហៅថា គ្រួសារ,
- សង្គមធំលើសនេះបន្ដិច មានញាតិសាច់សាលោហិតកប់ចញ្ចួលផង ហៅថា ត្រកូល,
- សង្គមធំទូលំទូលាយលើសនោះទៅទៀត ដែលគេប្រមូលផ្ដុំជា

បក្សសម្ព័ន្ធជាតិនិងរដ្ឋនីមួយ ៗ ឲ្យមានអង្គការបីជាមួយគ្នាគឺ អង្គការនីតិបញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងអង្គការតុលាការ ហៅថា បក្សសម្ព័ន្ធ ។

ដើម្បីឲ្យសង្គមទាំងនោះ មានសេចក្តីសុខសាន្តនិងរៀបរយងាយគ្រប់គ្រង គេត្រូវតែធ្វើច្បាប់សម្រាប់មនុស្សលោក ហើយមនុស្សលោក ត្រូវតែនៅក្រោមអំណាចច្បាប់ ។ ប៉ុន្តែ បើមនុស្សលោកណាមិនចេះច្បាប់ មិនស្គាល់ច្បាប់ គឺមិនគោរពសិទ្ធិសេរីភាព អធិបតេយ្យភាព បូរណភាពទឹកដី ទំនៀមទម្លាប់ បេតិកភណ្ឌនិងសម្បត្តិវប្បធម៌ របស់ប្រទេសជាតិគេ មនុស្សលោកនោះ គេហៅថា មនុស្សឥតច្បាប់ ឥតទម្លាប់ ជាមនុស្សព្រៃផ្សៃ ជាមនុស្សទមិឡអន្យតិរិយ មនុស្សលោកដទៃមិនត្រូវទៅសេពគប់សមគំនិតយកធ្វើជាមិត្រឡើយ ។

## មនុស្សលោកនិងសាសនា

ទោះជានៅក្នុងសម័យណាក៏ដោយ មនុស្សលោក តែងតែមានការភ័យតក់ស្លុតនេត់ សស្លន់សស្លោចំពោះសេចក្តីស្លាប់ ដែលបណ្តាលពីហេតុផ្សេង ៗ មកកំពៀញកំហែងគំរាមខ្លួនជានិច្ច ។ ដោយមានការភ័យតក់ស្លុត ជាមូលហេតុដូច្នេះហើយ ទើបជម្រុញមនុស្សលោកតាំងពីជំនាន់ណា ៗ មក ឲ្យស្វះស្វែងរកកន្លែងសម្រាប់ទីពឹងតែរៀង ៗ ខ្លួន ជាបន្ទាន់គឺអ្នកខ្លះយកភ្នំ អ្នកខ្លះយកព្រៃ ដើមឈើ ថ្ម ចេតិយ សមុទ្រជាដើម ជាទីពឹងពីព្រោះគេជឿដោយខ្វះវិចារណញ្ញាណថា ពំនឹងនៃ ទះនេះ ប្រហែលជានឹង

នាំឲ្យបានក្សេមក្សាន្ត រួចចាកគ្រោះថ្នាក់មរណភ័យដោយពិត ម៉្លោះហើយជំនឿនោះ ក៏ចេះតែមានជាប់តរៀងមក ។ លុះព្រះពុទ្ធជាបរមគ្រូ បានត្រាស់ដឹងឡើងកាលណា ទ្រង់បានត្រាស់បញ្ជាក់ក្នុងព្រះសូត្រ ចំពោះអគ្គិទត្តបុរោហិតថា «មនុស្សលោកភាគច្រើន កាលណាមានសេចក្ដីស្លាប់មកកំហែងគំរាមឲ្យភ័យតក់ស្លុតហើយ រមែងរត់រកភ្នំខ្លះ ព្រៃឈើខ្លះ ដើមឈើខ្លះ សួនច្បារខ្លះ ចេតិយខ្លះ យកមកជាទីពឹងពាក់, ពំនឹងរបៀបនេះពុំមែននាំឲ្យសុខក្សេមក្សាន្តប្រសើរឧដុង្គឧត្ដម នាំឲ្យរួចចាកសេចក្ដីទុក្ខគ្រប់យ៉ាងបានទេ (ផ្ទុយពីនេះវិញ) លុះណាតែយកព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹង ព្រមទាំងឃើញច្បាស់ នូវអរិយសច្ចបួន គឺ ទុក្ខ ហេតុដែលបណ្ដាលឲ្យកើតទុក្ខ (តណ្ហា) អរិយមគ្គមានអង្គ ៨ ជាផ្លូវត្រង់ ឆ្ពោះទៅកាន់ទីរំលត់ទុក្ខ និងព្រះនិព្វានជាកន្លែងរំលត់ទុក្ខ ដោយប្រាជ្ញាដែលពិចារណាហើយផង ទើបចាត់ទុកថា ជាទីពឹងដ៏ក្សេមក្សាន្ត ប្រសើរឧដុង្គឧត្ដម អាចរួចចាកទុក្ខទាំងពួងបានដោយពិត» ។ ព្រះពុទ្ធទ្រង់ជាអ្នកដឹកនាំពន្យល់ផ្លូវ ឲ្យសត្វដើរតាម ថាផ្លូវនេះត្រូវល្អ គឺមិនឆ្ងាយពេក មិនវាំងមិនរដិបរដុប មិនមានកក់ មិនរអិល មិនមានគ្រោះថ្នាក់ ផ្លូវនេះមានគ្រោះថ្នាក់ដោយរអិល មានកក់ល្បប់ មានដង្គត់ · ដីញួង មានបន្លាច្រើន មិនគួរដើរ គួរតែចៀសវាង, ព្រះធម៌សម្រាប់យឹតយោងស្រោចស្រង់សត្វអ្នកប្រតិបត្តិតាម, ព្រះសង្ឃជាស្រែបុណ្យ សម្រាប់ព្រួសសាបចណ្ដុះពូជកុសល ។

អាស្រ័យហេតុនេះ មនុស្សលោក ត្រូវតែមានសាសនាណាមួយ ដែលខ្លួនមានជំនឿ គួរប្រកាន់យកជាចាំបាច់ ពីព្រោះមានសាសនាខ្លះជួនកាលទុកដូចជាឃ្លាំងវប្បធម៌អក្សរសាស្ត្រ និងទំនៀមទម្លាប់ជាតិគេទៀតផងដូចជាព្រះពុទ្ធសាសនា ទុកដូចជាឃ្លាំងវប្បធម៌ និងអក្សរសាស្ត្រជាតិខ្មែរជាដើម ។ ផ្ទុយទៅវិញ បើជាតិសាសន៍ណាគ្មានសាសនា គឺគេមិនត្រូវការនឹងសាសនា អ្នកប្រាជ្ញលោកចាត់ទុកជាមនុស្សព្រៃផ្សៃ គ្មានវប្បធម៌ គ្មានសីលធម៌ គ្មានទំនៀមទម្លាប់ គឺជាមនុស្សដែលតែឈ្លានពានគេ ជិះជាន់ជិះជាន់លើសិទ្ធិសេរីភាព អធិបតេយ្យភាព បូរណភាពទឹកដី និងទ្រព្យសម្បត្តិវប្បធម៌របស់ជាតិគេ ដោយឥតភាតញញើត ឥតអៀនខ្មាសដូចសត្វតិរច្ឆាន ។

## មនុស្សលោកមាន ៤ ចំពូក:

១.មនុស្សដែលមានកាយវិកលវិការ ជាសំណល់ផលមកអំពីបាបកម្មចាស់ ប្រកបការងារដោយដៃជើងខ្លួនឯងមិនកើត ដើរតែសុំទានគេយកមកចិញ្ចឹមជីវិត បានព្រឹកខ្វះល្ងាច បានល្ងាចខ្វះព្រឹក អត់ៗ ឃ្លានៗ មានអាការដូចជាប្រេត ហៅថា មនុស្សប្រេត ;

២.មនុស្សអនាថា គ្មានទីពឹង ចិញ្ចឹមជីវិតអាស្រ័យដោយបុគ្គលដទៃ គ្មានគំនិតចំប្រឹងប្រែងខ្វះខ្វែងប្រកបការងារផ្សេងៗ តាមពេលវេលារស់នៅដោយត្រដាបត្រដួស រហេមរហាមមានអាការដូចជាសត្វតិរច្ឆាន

ហៅថា មនុស្សតិរច្ឆានោ ;

៣-មនុស្សដែលមានចិត្តអាក្រក់ កាចឃោរឃៅ ប្រព្រឹត្តតែអំពើលាមកអាក្រក់ផ្សេងៗ មានឃាតកម្មនិងចោរកម្មជាដើម ត្រូវអាជ្ញាធរចាប់ខ្លួនធ្វើទោសដាក់គុកតាមច្បាប់ រងទុក្ខវេទនាអស់សិទ្ធិសេរីភាព ដូចជាសត្វនរក ហៅថា មនុស្សនេរយិកោ ;

៤-មនុស្សដែលមានហិរិនិងឱត្តប្បៈ គឺចេះអៀនខ្មាសនិងអំពើបាបតក់ស្លុតនឹងអំពើបាបអកុសល ប្រព្រឹត្តតែកុសលកម្មបថ ១០ ខ្ជាប់ខ្ជួនតែក្នុងទាន សីល ភាវនា មិនមានធម៌ប្រមាទ មានអាការដូចជាទេវតា ហៅថា មនុស្សទេវោ ឬមនុស្សភូតោ ។

## មនុស្សលោកមាន ៥ ចំពូកទៀត

**១-ទុគ្គិតោ** មនុស្សដែលរងទុក្ខវេទនាជានិច្ចមិនដែលស្រាកស្រាន្ត

**២-ព្យាធិតោ** មនុស្សដែលទទួលរងតែនឹងជំងឺតម្កាត់ផ្សេងៗពុំដែលបានជាសះស្បើយឡើយ ;

**៣-មូឡ្ហោ** មនុស្សដែលឆ្កួតវង្វេងវង្វាន់ភាន់កាំងស្មារតី យកជាការមិនបាន ;

**៤ ឥណាទា** មនុស្សដែលជំពាក់បំណុលគេ គេតឹងទារពីមុខពីក្រោយដោះមិនរួច ;

**៥-និស្សយសេចកោ** សេវកៈ គឺខ្ញុំកំដរ រស់នៅដោយពឹង

ផ្អែកតែនឹងបុណ្យម្ចាស់ ឬចៅហ្វាយនាយ ។

មនុស្សលោកទាំង ៥ ពួកនេះ ទោះបីមានជីវិតរស់នៅ ក៏លោកទុកដូចជាស្លាប់បាត់ទៅហើយ ។

## មនុស្ស និង ធម៌

តាមន័យរបស់ព្រះពុទ្ធសាសនាថា សត្វដែលបានមកចាប់កំណើតកើតជាមនុស្ស ក្រៃក្រពេកណាស់ ពីព្រោះកំណើតមនុស្សនីមួយ ៗ សុទ្ធតែបានមកដោយមហាកុសលវិបាកជួយឧបត្ថម្ភទាំងអស់ ហើយលោកចាត់ទុកជាឧត្តមភេទ គឺភេទមានតម្លៃយ៉ាងខ្ពង់ខ្ពស់បំផុត លើសភេទនានាទាំងអស់ ពីព្រោះម្នាក់ ៗ គេចង់សាងខ្លួនគេឲ្យទៅទេវតាក៏បាន ទៅជាព្រះឥន្ទ្រក៏បាន ទៅជាព្រះព្រហ្មក៏បាន ឬ ទៅជាព្រះពុទ្ធអង្គក៏បាន ។ ដើម្បីរក្សាតម្លៃនិងសេចក្ដីសុខរបស់មនុស្សលោក ឲ្យបានរីកចំរើនលូតលាស់ជាងនេះទៅទៀត មនុស្សលោកត្រូវមានធម៌ ៤ យ៉ាងគឺ

១ - មានចិត្តអំណត់អត់ធន់ ចំពោះហេតុការណ៍ផ្សេង ៗ ដែលបណ្ដាលមកពីធម្មជាតិខ្លះ ពីផលវិបាករបស់អតីតកម្ម គឺកម្មចាស់ ដែលចៀសពុំរួចខ្លះ ពីអារម្មណ៍ដែលមនុស្សលោកជួបប្រទះ នាបច្ចុប្បន្នកាលនេះខ្លះ គឺអត់ធន់ចំពោះការខំប្រឹងលះបាបអកុសលគ្រប់បែបយ៉ាង អត់ធន់ចំពោះការខំប្រឹងចំរើនសន្សំបុណ្យកុសលទាំងតិចទាំងច្រើន ហៅថា ខន្តិ,

២ - មានគំនិតពិតត្រង់ ច្បាប់លាស់ ប្រាកដប្រជា គឺលះបាប

ពិតជាលះបាប ចម្រើនបុណ្យ ពិតជាចម្រើនបុណ្យ គិតអំពីអ្វី ធ្វើនូវអ្វី និយាយពីរឿងអ្វី ឲ្យច្បាស់លាស់ពិតប្រាកដ មិនកាយកប់ត្រឡប់ត្រឡិន ម្តងអីបេះ ម្តងអីចុះ បាតដៃជាខ្នងដៃ ហៅថា សច្ចៈ,

៣. ត្រូវមានចិត្តដាប់ក្តុកទឹកដល់គុណឧបការៈ របស់លោកអ្នកមានគុណទាំងអស់ មានមាតាបិតាជាដើម កុំបំភ្លេចចោល ហើយត្រូវធ្វៀតរកឱកាស នឹងធ្វើកិច្ចតបគុណ ដោយមធ្យោបាយណាមួយកុំបីខាន ហៅថា កតញ្ញុតា,

៤ - ត្រូវតាំងចិត្តឲ្យទូលំទូលាយ ស្រឡាញ់រាប់អាន អាណិតអាសូរ ចំពោះសព្វសត្វទាំងអស់ឥតរើសមុខ គ្រប់ទិសទាំង ១០ ទុកដូចជាបងប្អូន រួមឈាមជាមួយគ្នា ព្រមទាំងចែករំលែកសេចក្តីសុខដែលខ្លួនមាន ចែកផ្សាយដល់គ្នីគ្នា ដើម្បីឲ្យគេបានសុខដូចយើងផង ហើយកុំមានពៀរវេរានឹងគ្នា ចូរកេក្រខ្លួនឲ្យបានសុខរៀង ៗ ខ្លួន ហៅថា មេត្តា ។

## មនុស្សលោកជួយមនុស្សលោក

យើងជាមនុស្សលោក កើតនៅក្នុងចំណោមមនុស្សលោក ម្នាក់ ៗ សុទ្ធតែចង់បានសុខ សេចក្តីសុខនោះសោត ជួនកាលបានមកពីសំណល់បុណ្យចាស់ពីព្រេងនាយ ជួនកាលបានមកពីការធ្វើប្រព្រឹត្តផ្សេងផ្សំនាយអាយត្រូវទំនង ក្នុងបច្ចុប្បន្ន ។ ដើម្បីពង្រីកសេចក្តីសុខនោះឲ្យបានធំទូលំទូលាយគ្មានព្រំដែន ម្នាក់ ៗ ត្រូវចេះជួយគ្នា សង្គ្រោះគ្នា យឹតយោងគ្នាក្នុង

គ្រាមានអាសន្នអន់ក្រ ដូចជាក្នុងសម័យមានសង្គ្រាម ឬ ក៏ក្នុងការធម្មតា ទៅតាមមធ្យោបាយរៀងៗខ្លួន ដែលអាចជួយបាន ។ មនុស្សលោកតែម្នាក់មែន ប៉ុន្តែគេមានសេចក្តីសុខធំទូលំទូលាយ ហើយមានសន្តានចិត្តសប្បុរសផង ប្រាថ្នាចង់ឲ្យតែមនុស្សលោកបានសុខដូចគ្នា អាចជួយអ្នកដទៃកប់លានអ្នក ឲ្យបានសុខយ៉ាងគ្រប់គ្រាន់ ។ ព្រះសម្មាសម្ពុទ្ធតែមួយព្រះអង្គគត់ ទ្រង់មានចរិយាធម៌ គឺការប្រព្រឹត្ត ៣ យ៉ាង

គឺ ពុទ្ធត្ថចរិយា ការប្រព្រឹត្តដើម្បីនឹងបានត្រាស់ដឹង នូវអនុត្តរធម៌ ១

ញាតត្ថចរិយា ការប្រព្រឹត្តដើម្បីនឹងស្រោចស្រង់ពពួកញាតិរបស់ព្រះអង្គ១

លោកត្ថចរិយា ការប្រព្រឹត្តដើម្បីប្រយោជន៍នឹងស្រោចស្រង់សត្វលោក១

ទ្រង់បានត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គរកសេចក្តីសុខពិតឃើញមុនគេ ទ្រង់សម្តែងធម៌ឃើតយោងសត្វ គឺមនុស្សលោក ទេវលោក ព្រហ្មលោក ឲ្យបានឃើញពន្លឺសុខពិតស្មើរកប់មិនអស់ ៗ មយមាណព ក៏តែម្នាក់ឯងដែរ ជាមនុស្សសាមញ្ញធម្មតា ប៉ុន្តែជាអ្នកស្វែងរកសេចក្តីសុខតែម្យ៉ាង អាចជួយមិត្រភក្តិរបស់គាត់ ៣៣ នាក់ ឲ្យបានសុខយ៉ាងជាក់ស្តែង គឺរួចរស់រានមានជីវិត ដែលបណ្តាលមកពីស្តេចមួយព្រះអង្គមិនប្រកបដោយធម៌ ប្រើឲ្យយកទៅសម្លាប់ចោល ៗ ដំណើររឿងសង្ខេបដូចតទៅនេះ :

កន្លងអតីតកាលកន្លងទៅយូរហើយ នៅក្នុងមចល គ្រាម នាដែនមគធៈ កាលនោះ មានមាណពម្នាក់ឈ្មោះ មឃៈ ជាអ្នកមានចិត្តសប្បុរស សង្គ្រោះគេជានិច្ច បានធ្វើទីដីមួយកន្លែង បង្ហាប់ឲ្យរាបស្មើល្អ អ្នកផង ឃើញហើយគួរឲ្យជ្រះថ្លា ។ ស្រាប់តែមានមាណពដទៃទៀត មានចិត្តកាក្រក់មិនសួរយល់ការណ៍ ក៏មកបណ្តេញគាត់ចេញ មិនឲ្យធ្វើនៅទីនោះ មឃមាណព ឥតមានតូចចិត្តសោះ សុខចិត្តចេញពីទីនោះ ទៅធ្វើនៅកន្លែងផ្សេងទៀត គេក៏តាមមកព្យាបាទបណ្តេញគាត់ ដូចពេលមុនទៀតជាច្រើនលើក ។ ក្រោយមក គាត់កាន់ចបទៅជម្រះទីកន្លែងមួយទៀត ធ្វើឲ្យយ៉ាងរលីងស្អាត ហើយកន្លែងនោះ មហាជនទាំងឡាយ តែងទៅមកហូរហែជាប់ជានិច្ចផង ។ បើនៅរដូវរងា គាត់បង្កក់ភ្លើង នៅរដូវក្តៅ គាត់ដងទឹកតម្កល់ទុកក្នុងពាង ជូនសាធារណជនប្រើប្រាស់ជារៀងរាល់ថ្ងៃតាមត្រូវការ ហើយគាត់តែងតែចេញទៅធ្វើការពីព្រលឹម ៗ ដើម្បីធ្វើផ្លូវពង្រាបឲ្យរាបស្មើ ព្រមទាំងកាប់ឆ្ការមែកឈើព្រៃណាដែលប្រជែងផ្លូវយកចេញ ។ ជួនកាលមានមាណពដទៃទៀតមកសួរគាត់ថា អ្នកឯងធ្វើផ្លូវទៅណា ខ្ញុំធ្វើផ្លូវទៅស្ថានសួគ៌ ។ លុះយល់ឃើញថា មឃ-មាណព មានគំនិតល្អ គឺចេះសង្គ្រោះគេដូច្នេះហើយ ទើបមាណពដទៃ ៗ ទៀត មកសុំធ្វើជាមួយ ម្តងម្នាក់ ម្តងពីរនាក់យូរ ៗ បានកើនរហូតដល់ ៣៣ នាក់ ទាំងអស់គ្នាបាននាំគ្នាធ្វើផ្លូវ បានប្រវែងប្រហែល ២ យោជន៍ ។

និយាយពីគាមភោជក គឺចៅសង្កាត់ភូមិនោះ ឃើញមាណពទាំង ៣៤ នាក់ធ្វើដូច្នោះ គាត់មិនសប្បាយចិត្តសោះ ពីព្រោះគិតឃើញថា ពួកមាណពទាំងនេះ ធ្វើការឥតប្រយោជន៍ទទេ បើប្រសិនណាជានាំគ្នាទៅ សាច់ជាដើមមកស៊ី ផឹកសុរាវិញ ប្រហែលជាអញនឹងមានកម្រៃខ្លះ ក៏ទៅ ហៅមាណពទាំងអស់នោះមក ហើយហាមឃាត់ជាដាច់ខាតមិនឲ្យធ្វើ ៗ មាណពទាំងអស់ ប្រកែកមិនព្រមឈប់ ៗ ចៅសង្កាត់តូចចិត្តខ្លាំង ដោយ គេមិនព្រមស្ដាប់បង្គាប់ ក៏រត់ទៅក្រាបទូលស្ដេចមួលបង្កាច់ថា ខ្ញុំឃើញ ពួកចោរនៅក្នុងព្រៃទៅវិញ ៗ ចំណែកព្រះរាជាមិនបានពិចារណា ក៏ជឿ តាមពាក្យចៅសង្កាត់ដែលពិតទូលមួលបង្កាច់ ស្មានថាជាចោរមែន ក៏ទ្រង់ បញ្ជាឲ្យទៅចាប់មាណពទាំងអស់នោះមក ហើយត្រាស់បញ្ជាឲ្យដឹកដំរីមក បញ្ជាន់សម្លាប់ចោលឲ្យអស់ ៗ មឃមាណព ឥតមានភ័យតក់ស្លុត អ្វីបន្តិចបន្តួចសោះ បាននាំលើកដល់មាណពជាមិត្រសំឡាញ់ទាំងអស់ថា មិត្រទាំងអស់គ្នា ពេលនេះ យើងនឹងដល់ថ្នាក់ទីបំផុតនៃជីវិតហើយ ចូរ ប្រុងស្មារតី តាំងចិត្តឲ្យប្រកបដោយមេត្តា យើងគ្មានអ្វីទីពឹងក្រៅពីធម៌ មេត្តានេះទេ គឺកុំខឹង កុំតូចចិត្ត កុំអាក់អន់ចិត្តនឹងព្រះរាជា នឹងចៅសង្កាត់ ហើយនឹងដំរីឲ្យសោះ មាណពទាំងអស់ក៏ធ្វើតាម ដោយអានុភាពនៃចិត្ត ប្រកបដោយមេត្តា ដំរីក៏មិនហ៊ានទៅជិត ៗ ព្រះរាជាទ្រង់ឆ្ងល់យល់ថា ក្រែងដំរីឃើញមនុស្សច្រើន បានជាវាមិនហ៊ានជាន់ បើដូច្នេះត្រូវឲ្យគ្របគ្នា

យកកន្ទេលទៅគ្របមាណពទាំងអស់ឲ្យជិត រួចប្រើដំរីឲ្យមកបញ្ជាន់ម្ដងទៀត ធ្វើយ៉ាងនេះក៏ដោយ ដំរីតែងតែលែងហ៊ានមកជិតថែមទៀត ៗ ទើបព្រះរាជា ទ្រង់ឲ្យហៅមាណពទាំងអស់នោះមកសួរពត៌មាន តាំងពីដើមរៀងមក លុះទ្រង់ជ្រាបសេចក្ដីសព្វគ្រប់ហើយ ក៏មានព្រះទ័យសោមនស្សណាស់ថា អម្បាលសត្វតិរច្ឆាន ម្ដេចគង់ដឹងគុណ ចុះខ្លួនជាមនុស្សត្រឡាំង ម្ដេចក៏មិនដឹងគុណសោះ គេធ្វើការនេះជាជំនួយដល់ផែនដីទេតើ ៗ ទើបទ្រង់សូមឲ្យមាណពទាំងនោះអត់ទោសផងចុះ ហើយទ្រង់ប្រគល់ទៅសង្កាត់ព្រមទាំងប្រពន្ធកូនទៅ ឲ្យជាខ្ញុំបម្រើមាណពទាំង ៣៤ នាក់នោះ ទ្រង់ប្រទានដំរីទាំងអស់ សម្រាប់ជាយានជំនិះ ហើយស្រុកភូមិដែលទៅសង្កាត់ត្រួតត្រានោះទៀតសោត ក៏ទ្រង់ប្រគល់ឲ្យជាកម្មសិទ្ធិ សម្រាប់មាណពទាំងនោះ ប្រើប្រាស់ប្រកបមុខការងាររចិញ្ចឹមជីវិត នៅជាសុខសាន្តចុះ ៗ.

ចប់

# ចតុរារិយសច្ច

( តមកពីលេខមុន )

ភិក្ខុ ម៉ាខ ~ ខាត់ រៀបរៀង

សូមទ្រង់ព្រះមេត្តាប្រោស សាវ័កអញ្ញតិត្ថិយ៍ទាំងឡាយ មានមុខស្លេកស្លាំង ស្លឹតស្លក់ សម្បុរសោះក្រោះ ក្រៀមស្ងួត មុខគួរខ្ពើម ហាក់ដូចជាអស់សង្ឃឹមក្នុងចិត្ត មិនដូចសាវ័កព្រះអង្គទេ ៗ សាវ័កព្រះអង្គ មុខគួរឲ្យជ្រះថ្លាណាស់ កក្រូផូរផង់ ស្រស់បំព្រង (ហដ្ឋបហដ្ឋ) មានចិត្តខ្ពស់ (ឧទគ្គឧគ្គ) មានចិត្តរីករាយក្រៃលែង ក្នុងធម្មវិន័យ (អភិរតរូប) មានឥន្ទ្រិយស្រគត់ស្រគំ (បីណិន្ទ្រិយ) មានការខ្វល់ខ្វាយតិច (អប្បោ-សុក) ទឹកមុខថ្លាត្រយង់ (បន្នលោម) (sereine) ស្ងប់ស្ងៀម (បវុត្ត) មានចិត្តតាំងនៅដូចម្រឹគ (មិគ្គភូតេន ចេតសា) មានពន្លឺគួរឲ្យជ្រះថ្លា ៗ ទីបំផុត ទ្រង់មានបន្ទូលបន្ថែមថា « សាវ័កព្រះអង្គ បានជាមានអាការស្រស់ដូច្នេះ ព្រោះបានយល់ធម៌ព្រះអង្គពិត ទៅតាមពិតហើយ » ៗ

ដូច្នេះ ពុទ្ធសាសនិកជនដែលបានយល់ធម៌ពិត ទៅតាមពិតហើយ តែងមានអាការមុខគួរឲ្យជ្រះថ្លាក្រៃលែង មិនទំទុកដូចអ្នកទាំងផ្ដាសពោលបរិហានោះទេ ៗ សេចក្ដីដែលបានពណ៌នាមកនេះ ជាទុក្ខអរិយសច្ច ៗ

## ជំពូក ទី បី

### អរិយសច្ច ទីពីរ

**ខ- ទុក្ខសមុទយអរិយសច្ច** ការកើតឡើងនៃទុក្ខ (l'Apparition de Dukkha, Tne Arising of Dukkha) ។ អរិយសច្ចទីពីរនេះ គឺការកើតឡើង ឬកំណើតនៃទុក្ខ ជាសេចក្តីពិត -(ទុក្ខសមុទយអរិយសច្ច) ។ អត្ថន័យ ធម្មតាទូទៅនៃសច្ចៈទីពីរនេះ ពុទ្ធសាសនិកជនបានចេះដឹងគ្រប់គ្នាហើយ ជាអត្ថន័យដែលអង្គព្រះសម្ពុទ្ធបានពន្យល់ច្រើនអន្លើណាស់ នៅក្នុងគម្ពីរព្រះត្រៃបិដក ដែលជាគម្ពីរដើម ដូចសេចក្តីតទៅនេះ ។

ធម៌អ្វី ដែលនាំឲ្យកើតទុក្ខ ? តណ្ហា «ការស្រេកឃ្លានអន្ទះសា, សេចក្តីប្រាថ្នា ក្តៅក្រហាយ» ជាធម៌នាំឲ្យមានភពថ្មី ភពថ្មី ជាធម៌នាំឲ្យវិលមកកាន់ភពថ្មី ភពថ្មី (បោនោព្ភវិកា) ប្រកបដោយក្តីរីករាយ, តណ្ហានេះប្រកបដោយក្តីត្រេកត្រអាល ដោយការជាប់ចំពាក់ពាក់វិនខ្លាំងក្លា (នន្ទិរាគសហគតា) ហើយនាំឲ្យចេះតែស្វែងរកសេចក្តីរីករាយថ្មីៗ ឥតឈប់ឈរតទៅទៀត នៅត្រង់នេះនៅត្រង់នោះ ដរាបតទៅ=(តត្រតត្រាភិនន្ទិនី) បានដល់តណ្ហា ៣ ប្រការគឺ

**១- កាមតណ្ហា** សេចក្តីប្រាថ្នាក្នុងកាមភព

**២- ភវតណ្ហា** សេចក្តីប្រាថ្នាឲ្យកើតក្នុងរូបភព

**៣- វិភវតណ្ហា** សេចក្តីប្រាថ្នាឲ្យកើតក្នុងអរូបភព ។

ការស្រេកឃ្លានខ្លាំង សេចក្ដីប្រាថ្នាស្ងួតស្ងាញ ការជាប់ចំពាក់ពាក់នៃការលោភលន់ពន់ប្រមាណ ទាំងអស់នេះហើយ កើតប្រាកដឡើងដោយអាការផ្សេង ៗ ច្រើនអនេក ហើយនាំឲ្យកើតទុក្ខគ្រប់ប្រការ នាំឲ្យមានកំណើតតទៅទៀត ។ សេចក្ដីនេះ យើងមិនគួរគប្បីយល់ថា តណ្ហានេះជាដើមហេតុ តែមួយនេះទេ, តាមពុទ្ធសាសនា ហេតុដើម មិនមែនមានតែមួយទេ អ្វីទាំងអស់សុទ្ធតែមានការទាក់ទងគ្នាទៅវិញទៅមក, ឯតណ្ហាដែលទុកថា « ជាហេតុឬជាកំណើតនៃទុក្ខ » នេះ ក៏ព្រោះតែធម៌នេះនាំឲ្យកើត (សមុទយ) ធម៌អ្វីតទៅទៀត គឺតណ្ហា ជាហេតុនាំឲ្យកើតវេទនា (Sensation), ការកើតវេទនា ជាហេតុនាំឲ្យកើតផស្សៈ (Contact), ហើយចេះតែនាំឲ្យកើតអ្វី ៗ បន្តទៅទៀត វិលទៅវិលមកដូចកង់ ធុន ជាអង្គព្រះសម្ពុទ្ធទ្រង់ត្រាស់ឲ្យឈ្មោះថា "បដិច្ចសមុប្បាទ" (Production conditionné) ដែលយើងនឹងត្រូវនិយាយតទៅ ៖

មួយទៀត "តណ្ហា" នេះ មិនមែនជាដើម ឬ បុព្វហេតុតែមួយ ដែលនាំឲ្យកើតទុក្ខទេ គ្រាន់តែជាបុព្វហេតុចេញមុខមុនគេ រហ័សក្លាមមុនគេ គឺជាប្រធាន ជាធម៌នាំឲ្យកើតសព្វទាំងអស់ ។ អត្ថបទជាបាលី ដែលនិយាយពីសមុទយ ឬ កំណើតនៃទុក្ខ មិនមែនមានត្រឹមតែតណ្ហានេះទេ មានធម៌ដទៃទៀតច្រើន ដែលជាគ្រឿងសៅហ្មង (កិលេសា សាសវា ធម្មា) តែតណ្ហានេះ ជាមេក្លោង ។ ដើម្បីកុំឲ្យឃ្លាតចេញពីគោល

អត្ថាធិប្បាយរបស់យើងនៅពេក ក្នុងទីនេះ យើងគ្រាន់តែរំលឹកថា តណ្ហា នេះហើយ ដែលជាមណ្ឌលឧត្តមគតិខុស ដែលនាំឲ្យយល់ថាមាន « ខ្លួនឯង = Soi, Sell » កើតមកពីអវិជ្ជា (Ignorance) ។

សព្វថា «តណ្ហា» មិនមែនបានសេចក្ដីត្រឹមតែសេចក្ដីប្រាថ្នា, ឧបា-ទាន ការប្រកាន់ជាប់ចំពោះកាមគុណ ទ្រព្យសម្បត្តិ អានុភាព ប៉ុណ្ណឹងទេ បានសេចក្ដីរហូតទៅដល់ឧបាទានធម៌ ជាគ្រឿងប្រកាន់ខ្ជាប់ដទៃទៀត ដូចការប្រកាន់គំនិត ឧត្តមគតិ មតិ ទ្រឹស្ដី ទស្សនាទាន (Conception) និងជំនឿទៀតផង ព្រោះធម៌ទាំងនេះ សុទ្ធតែកើតពីតណ្ហា ដែលហៅថា «ធម្មតណ្ហា (២)» ។ តាមពុទ្ធវចនៈ ដែលមានអត្ថាធិប្បាយទុកមក ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា អពមង្គលគ្រប់យ៉ាង ការបោលបលទាស់ទែងខ្វែងគំនិតគ្នាគ្រប់ប្រការ ចាប់ពីការទាស់គ្នាតូចតាច ស្វាមីភរិយាទាស់គ្នារៀងរហូតទៅដល់មហាសង្គ្រាមរវាងប្រទេស, សេចក្ដីអន្តរាយទាំងអស់នេះ ឫសគល់របស់វានៅត្រង់ «តណ្ហា» នេះឯង ។ រដ្ឋបុរសក្នុងលោក ដែលព្យាយាមរកការដោះស្រាយការខ្វែងគំនិតជាអន្តរជាតិ ឬដែលនិយាយពីសង្គ្រាម ឬពីសន្តិភាព គ្រាន់តែជាផ្លូវនយោបាយ ឬ ជាផ្លូវសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺនិយាយត្រឹមតែសំបកក្រៅ មិនចូលទៅដល់

---

១ - អភិសមុច័យ, ទំព័រ ៤៣ : ប្រាធាន្យាថិ : សរិក្រកាថិ : ។

២ - មជ្ឈិមនិកាយ មូលបណ្ណាសក ។

កង៏បំណោទដែលជាចុងគល់ឡើយ ដូចសេចក្ដីដែលព្រះសម្ពុទ្ធត្រាស់ចំពោះវច្ឆគោត្តភិក្ខុថា "លោកនេះ បេះតែខ្ទះខាត មិនបេះឆ្អែតទេព្រោះជា "ខ្ញុំតណ្ហា" (តណ្ហាទាសោ)" ។

មនុស្សក្នុងលោកយល់គ្រប់គ្នាថា "សេចក្ដីទុក្ខគ្រប់ប្រការ សុទ្ធតែកើតចេញមកពីសេចក្ដីប្រាថ្នា" សេចក្ដីនេះមិនមែនជាធម៌ពិបាកយល់នោះទេ ស្ដាប់បានគ្រប់គ្នាហើយ ប៉ុន្តែសេចក្ដីដែលនិយាយថា "តណ្ហាជាហេតុដើមនាំឲ្យកើតកពច្ចឹកពច្ចឹ ឬថា នាំឲ្យមានកំណើតទៀត" នោះ ជាបំណោទមួយដែលគេដោះស្រាយបានដោយលំបាកបំផុត ។ ដើម្បីដោះស្រាយប្រស្នាលំបាកនេះ ត្រូវតែដោះស្រាយទៅតាមទស្សនវិជ្ជា នៃបួនអរិយសច្ច ទើបបានដើងលព្ធមួយដ៏ប្រសើរបំផុត ពោលគឺវែកញែកឲ្យល្អិតជ្រាលជ្រៅតាមទុក្ខសមុទយអរិយសច្ច ហើយឲ្យឆ្លើយស្របគ្នាត្រឹមត្រូវតាមអរិយសច្ចទីមួយគឺទុក្ខអរិយសច្ចទៀតផង ព្រោះថា ប្រស្នាលំបាកនេះ ជាប់ទាក់ទងគ្នាទៅដល់ទ្រឹស្ដីកម្មៈ និងកពច្ចឹទៀតដូចសេចក្ដីតទៅនេះ

(នៅមានត)

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ - កន

ប្រែ ~ រៀបរៀង

## (ត)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នកភិងវៃឆ្លាស់បើបានអាន |
| នឹងបេះឧបាយកលចំណាន | ទាំងមានសន្ដានស្នេហាជាតិ |

យូ-អ៊ុន

ឯស៊ុម៉ាស៊ីតាំងទ័ពនៅចាំកងទ័ពគេងចាយ នៅតែមិនទាន់ឃើញមក ក្អែកនោះក៏តែតែឈឺចាប់ជាខ្លាំងណាស់ បេះតែដេកសម្ងំនៅលើគ្រែ ប្រើទាហានប្រហែល ៣០០ នាក់ឲ្យព័ទ្ធរង់រក្សាខ្លួនលុះពេលកណ្ដាលអធ្រាត្រ បានឮសំឡេងទាហានក្នុងបន្ទាយ ផ្អើលជ្រួលច្រាល់ប្របល់គ្នាទាំងសេះនឹងមនុស្ស ទើបឲ្យបំរើចេញទៅពិនិត្យមើលក៏បានសេចក្ដីថា មានទាហានម្នាក់មានកំឡាំងខ្លាំងពូកែណាស់ មិនមាននរណាទប់ទល់បានៗដេញវាយបុករុកចំលាយបន្ទាយចូលមកពីទិសឯជើង, ស៊ុម៉ាស៊ីបានឮដូច្នោះក៏ភ័យខ្លាំងណាស់ ឲ្យក្ដៅកេលកលក្នុងដើមទ្រូងបីដូចជាភ្លើងឆេះ ព្រោះទោសៈបណ្ដាលឡើង, ឯភេគក្នុងក្អែកក៏តែតែកំរើបខ្លាំង កែវក្អែកនោះក៏ផ្ទុះចេញមក តែគិតក្រែងទាហានទាំងពួងដឹងទឹងប្រែចិត្ត, ស៊ុម៉ាស៊ីក៏យកសំពត់ក្ដួយទៅរុំព័ទ្ធហើយដេកខាំមាត់ទាល់តែសំពត់នោះដាច់ជា ២ កំណាត់ ។

វេលានោះ ប៊ុនអេងនាំទាហានហែកបន្ទាយចូលទៅបាន ក៏ដេញកាប់សម្លាប់ទាហានសុម៉ាស៊ូស្លាប់ច្រើនណាស់, ប៊ុនអេងបែរមុខទៅខាងណា ក៏វិនាសខាងនោះអស់គ្មាននរណាតទប់បាន, ប៊ុនអេងប្រហារតែខាងទិសឧត្តរមួយប៉ែក ដើម្បីចាំមើលបិតានឹងលើកមកវាយប្រសព្វពីម្ខាងក៏មិនឃើញ, លុះនឹងវាយតចូលទៅទៀតឲ្យដល់ទ័ពហ្លួង មានទាហានសុម៉ាស៊ូព្រួតគ្នាបាញ់ផ្លូស្នាក់ពីមុខបីដូចគ្រាប់ភ្លៀង បេះតែពារទន្ទ្រានទៅវិញទៅមកទាល់តែភ្លឺស្វាងក៏ហែកចូលទៅមិនបាន, លុះព្រឹកឡើងទើបបានឮសំឡេងត្រែ សំឡេងស្គរសម្រាប់គងទ័ពក៏ប្លែកចិត្តគិតថា ហេតុម្តេចបានជាបិតាទើបមិនលើកមកពីទិសឯត្បូង ក៏លើកមកពីទិសឯជើងវិញ ទើបបំផាយសេះទៅមើល ក៏ឃើញឯកងទ័ពគេង៉ាយ ៗ កាន់ជាវជិះសេះនាំមុខស្រែកថា អាក្បត់ផែនដី ឯងកុំតនឹងអញចូរស្រុតមកលេងគ្នា, ប៊ុនអេងបានឮដូច្នោះ ក៏កំលាំងចូលទៅប្រយុទ្ធគ្នាបានប្រហែល ៥០ ក្បួន មិនទាន់ចាញ់ឈ្នះ, កាលកំពុងតស៊ូគ្នានោះ ទាហានសុម៉ាស៊ូលើកជំនួយមកជួយវាយប្រសព្វពីម្ខាងមុខនឹងក្រោយ, ឯទាហានប៊ុនអេងគេចខ្លួនក៏គេចដោះយកតែរួចខ្លួន នៅតែប៊ុនអេងម្នាក់ឯង ក៏ផែងវែកចំណោមទាហានសុម៉ាស៊ូចេញបានទៅទិសឯត្បូង, ទាហានសេះសុម៉ាស៊ូប្រហែល ១០០ សុទ្ធតែមានថ្វីដៃ ក៏បំផាយសេះដេញតាមទៅដល់ស្ពានស្រុកង៉ាក់កៃសៀ ប៊ុនអេងឃើញទាហានដេញភ្ជាប់ក្រោយទៅជិតនឹងទាន់, ក៏ញាក់សេះ

ត្រឡប់កស្រែកគំហកស្ទុះសន្ធុញមកវិញ , ពាហានទាំងពួងក៏នាំគ្នាថយ , ប៊ុនអេងក៏ត្រឡប់សេះបរតិចៗទៅមុខទៅ , ពាហានសុម៉ាស៊ីនាំគ្នាទៅប្រជុំហើយប្រឹក្សាគ្នាថាៈ ពាហានម្នាក់នេះហានក្លាណាស់ យើងព្រមចិត្តគ្នាដេញចាប់ខ្លួនឲ្យត្រាតែបាន គិតហើយក៏បំផាយសេះដេញតាមទៅ ; ប៊ុនអេងត្រឡប់មុខសេះវិលមកតស៊ូ ហើយស្រែកគំហកថា អាពួកពាហានជ្រូកឯងមិនខ្លាចសេចក្ដីស្លាប់ទេឬ? ថាហើយក៏ចាប់ដំបងដែកដេញចូលទៅវាយស្លាប់ច្រើនណាស់ ត្រឹមតែពួកពាហានសុម៉ាស៊ីបែកហើយត្រឡប់លើកដេញហើយបែកត្រឡប់ក្រោយដល់ ៤ គ្រា ៥ គ្រា , ប៊ុនអេងក៏វាយស្លាប់គ្រប់គ្រា ពាហានសុម៉ាស៊ីក៏ត្រឡប់ទៅវិញ ។

ឯប៊ុនឃឹមជាបិតាប៊ុនអេងលើកពាហាន ចេញមកក្នុងពេលយប់នោះវង់ទៅខាងក្នុងវីវក់វង្វេងផ្លូវនឹងរកច្រកចេញមិនរួច ទាល់តែភ្លឺស្រាង , លុះព្រឹកឡើងទើបក្រឡេកឃើញច្បាស់ថាមិនមែនផ្លូវ មិនឃើញទ័ពប៊ុនអេងឃើញតែកងទ័ពសុម៉ាស៊ីមានជ័យជំនះរុកកន្ទ្រានដេញមកច្រើនណាស់បើសកំឡាំងក៏ថយទ័ពតទៅផ្លូវស្រុកឈើវលុន ។

មានពាហានសុម៉ាស៊ីម្នាក់ឈ្មោះអ៊ុនតាយបុក ពីដើមជាមនុស្សស្និទ្ធទំនុកទុកចិត្តប៊ូសេង , លុះសុម៉ាអ៊ីសម្លាប់ប៊ូសេងទៅហើយ អ៊ុនតាយបុកក៏ទៅនៅធ្វើការនឹងសុម៉ាស៊ី គិតតែចង់សម្លាប់សុម៉ាស៊ីសងសឹកតបគុណប៊ូសេង , កាលពីដើមប៊ុនឃឹមនឹងឈ្មោះនេះស្រឡាញ់រាប់អានគ្នាណាស់

លុះសុម៉ាស៊ូឈឺក្តៅកណាស់ នៅរិះគិតរកទំនងមិនទាន់បានការក៏ចូលទៅ និយាយថា ខ្ញុំបាទឃើញថា ប៊ុនឃីមនោះជាមនុស្សស័ត្យពិតត្រង់ ដែលនឹងគិតការជាក្បត់ផែនដីនោះមិនមែនទេ, ដែលមកធ្វើការទាំងនេះ ក៏ព្រោះនឹងរឹងទទឹងប៊ូយីវទៀតមិនបាន បើដូច្នោះ ខ្ញុំបាទសុំទៅនិយាយបញ្ចុះបញ្ចូលប៊ុនឃីមឲ្យស្ម័គ្រមកចូលខាងលោកមុខជាបាន សុម៉ាស៊ូយល់ឃើញត្រូវក៏បើកឲ្យទៅ ។

អ៊ុនតាយបុកពាក់គ្រឿងសឡើងជិះសេះ តាមទៅជិតប៊ុនឃីមហើយស្រែកដង្ហោយហៅប៊ុនឃីមថា: អ្នកឃើញយើងច្បាស់ឬទេ ? យើងឈ្មោះអ៊ុនតាយបុក, ប៊ុនឃីមក្រឡេកមក, អ៊ុនតាយបុកក៏បើកមួកបង្ហាញមុខពីលើខ្នងសេះ យកសែបង្អុលហើយស្រែកថា ប៊ុនឃីមហេតុម្តេចបានជាលើកទ័ពតតាំងដូច្នេះ ត្រូវបង្អង់នៅបន្តិចសិននឹងបានការ- អ៊ុនតាយបុកថាដូច្នោះ ព្រោះឃើញថាសុម៉ាស៊ូឈឺធ្ងន់នឹងជិតស្លាប់ហើយ ទើបបង្ខំប៊ុនឃីមទុក ។

ឯប៊ុនឃីមមិនជឿចិត្តអ៊ុនតាយបុក ក៏ស្រែកបង្កូតជេរហើយលើកធ្នូឡើងបាញ់, អ៊ុនតាយបុកឃើញដូច្នោះតូចចិត្តណាស់ ក៏យំហើយញាក់សេះត្រឡប់មកវិញ ប៊ុនឃីមក៏នាំទាហានរត់ទៅតាមផ្លូវស្រុកឈឺវលុន, លុះដឹងថា ដូកាត់អៀនទាហានសុម៉ាស៊ូបានស្រុកនោះហើយ ក៏ងាកមុខតម្រង់ទៅស្រុកហាងសៀ, លុះឃើញវ័ពកាវជុនទីងអងគី, គេងងាក

លើកមកស្កាត់នៅពីមុខជា ៣ ផ្លូវ, ប៊ុនឃីមយល់ថានឹងពារទំលាយទៅមិន បាន ក៏លើកត្រឡប់ទៅស្រុកកាំងតាំង ស្ទុះចូលទៅជាខ្ញុំស៊ុនជុនដែល ជាមហាឧបកជ ។

ឯប៊ូឃីវខៀម តាំងនៅស្រុកហានសៀ ដឹងថាស្រុកឈីវឈុនខូច ហើយ ទ័ពប៊ុនឃីមក៏បែកទៀត កងទ័ពសុម៉ាស៊ូក៏លើកមកជា ៣ ផ្លូវ តាំង នៅជិតស្រុកក៏លើកទាហានចេញច្បាំង, ក្រឡេកឃើញគេងាយលើក ចេញមក ក៏ឲ្យកាន់យ៉ុងចេញត- មិនទាន់បាន ១ ក្បួនគេងាយកាប់ទឹង ជាវត្រូវកាន់យ៉ុងស្លាប់ហើយក៏ពារទន្ទ្រានដេញចូលទៅ, អាវជុន, អងគី ក៏លើកទាហានចូលហោមព័ទ្ធតាំង ៤ ទិស, ប៊ូឃីវខៀមឃើញថានឹងតស៊ូ មិនបាន ក៏នាំទាហានស្និទ្ធប្រហែល ១០ នាក់រត់ទៅដល់ស្រុកស៊ុមកួន, សង់ប៉េកចៅហ្វាយស្រុកក៏បើកទ្វារទទួលចូលទៅ ហើយតែងគុសៀង,ប៊ូ ឃីវខៀមស្រវឹងស្រាមិនដឹងខ្លួន សង់ប៉េកក៏សម្លាប់កាត់យកក្បាលនាំទៅ ឲ្យសុម៉ាស៊ូ ។

លុះសុម៉ាស៊ូប្រាបប្រាមសត្រូវកបតាបហើយ ក៏តាំងជូកាត់គៀនជា នាយទាហានធំ បានទិយាយកដការស្រុកអេងជីវ, ស្រុកហ្វីយឡាំ តាំង ពួងនោះ ហើយក៏លើកត្រឡប់ទៅស្រុកហ្វូគោ, សុម៉ាស៊ូឈឺក្តែកជុំទន់ ណាស់ រែកតែតាប់ពេលជាខ្លាំង វេលាកណ្ដាលអធ្រាត្រ ជេកក៏មិនលក់ គ្រាន់តែលើវេបទ្ទិចៗ ក៏ក្រឡេកឃើញលីហានទិងខៀវអ៊ុំ ហើយទឹង

ហេហៅហៀនទាំង ៣ នាក់មកឈរនៅប្របរគ្រែដំណេក ក៏ដឹងថាខ្លួនមុខជាមិនរស់រួចហើយ ទើបប្រើមនុស្សឲ្យចូលទៅក្រុងឡុកអៀងរកសុម៉ាចៀវឲ្យទៅជួយ, សុម៉ាចៀវក៏ចូលទៅដល់ទីដំណេក ឃើញថាមុខជាមិនរស់ក៏គាំងតែយំសោកអាណោះអាល័យ, សុម៉ាស៊ូក៏ផ្តាំថា: បងបានធ្វើរាជការរៀងមក ក៏បានសេចក្តីចំរើនស័ក្តិយសពេញទីជាមហាឧបរាជ បងក៏អាចចេះរក្សាខ្លួនមិនមានសេចក្តីអន្តរាយ, ទៅត្រូវទទួលការធ្វើជំនួសបងតទៅ ត្រូវតែរាំងរក្សាខ្លួនឲ្យបានល្អ, បើមានកិច្ចរាជការធំៗ កុំត្រូវទុកចិត្តអ្នកដទៃឲ្យខ្ពបផ្លូវការរាជការ ការដែលខុសទាស់ហើយ ក៏នឹងវិនាសអស់ដល់ទាំងគោត្រ លុះផ្តាំសព្វគ្រប់ហើយ ក៏ប្រគល់ត្រាសម្រាប់ងារឲ្យសុម៉ាចៀវជាប្អូន ។

ឯសុម៉ាចៀវនៅរង់ឲ្យបងផ្តាំប្រដៅឲ្យបានសេចក្តីតទៅទៀត តែឃើញថាបងមានសេចក្តីទុក្ខវេទនា ក្នុងភ្នែកកំរើបធ្ងន់ណាស់, សុម៉ាស៊ូស្រែកឡើងដោយសំឡេងខ្លាំងហើយដាច់ខ្យល់ស្លាប់, កាលសុម៉ាស៊ូស្លាប់នោះ នៅក្នុងខែផល្គុន ព្រះចៅចោម៉ោសោយរាជ្យបាន ២ ឆ្នាំ, សុម៉ាចៀវក៏តែងការសពបងតាមប្រវេណី ហើយនាំសេចក្តីនោះទៅក្រាបទូលព្រះចៅចោម៉ោ ៗ ក៏មានត្រាស់ព្រះរាជតម្រាស់តាំងឲ្យសុម៉ាចៀវស្តីរាជការក្នុងស្រុកហ៊ូគោ ដើម្បីការពារទ័ពខ្មាំងខាងស្រុកកាំងតាំង, សុម៉ាចៀវក៏មិនពេញចិត្តនៅជាអល់ឯក, តែថាមិនប្រកែកគ្រាន់តែស្ងៀម ។

ចុងហោយនិយាយនឹងសុម៉ាចៀវថា: លោកមហាឧបរាជបងទើបតែនឹងអនិច្ចកម្ម, ចិត្តខ្ញុំរាជការទាំងពួងក៏នៅមិនទាន់រៀបរយ ដែលលោកនឹងតាំងនៅក្នុងស្រុកហ៊ូតោនេះ, បើមានមនុស្សអាក្រក់រកគិតប្រទូសរ៉ាយឲ្យកើតឡើងក្នុងរាំង ដែលនឹងទៅកំចាត់ចេញនោះឃើញថាមិនទាន់ការ, ឯសុម៉ាចៀវក៏យល់ឃើញត្រូវ ទើបលើកទាហានទៅឈប់នៅដំបន់ឡុកស៊ុយ, ព្រះចៅចោម៉ជ្រាបការដូច្នោះ ក៏មានព្រះទ័យភ័យណាស់ណា, មានទាហានម្នាក់ឈ្មោះអង់សុកក្រាបទូលស្តេចថា: សូមឲ្យព្រះអង្គតាំងសុម៉ាចៀវជាទីមហាឧបរាជ និយាយការរាជការជំនួសបងឲ្យមានទឹកចិត្តសប្បាយ, ព្រះចៅចោម៉ក៏យល់ត្រូវផង ទើបប្រើអង់សុកឲ្យកាន់ព្រះតម្រាស់ទៅដល់សុម៉ាចៀវឲ្យចូលទៅគាល់ នឹងបានតាំងជាមហាឧបរាជ, សុម៉ាចៀវក៏ចូលទៅគាល់ព្រះចៅចោម៉ ស្ដើតនាប់ទទួលទីនិយាយរាជការទូទាំងផែនដី ។

ខណៈនោះពួកល្បាតរាជការខាងស្រុកសែឈួន លុះដឹងដំណឹងថាសុម៉ាស៊ូស្លាប់ហើយ ក៏នាំសេចក្តីនោះទៅជូនដល់កៀងអ៊ុយៗ ក៏នាំពត៌-មាននោះចូលទៅក្រាបទូលព្រះចៅឡៅសៀនហើយថា សុម៉ាស៊ូទើបស្លាប់ សុម៉ាចៀវបានតាំងជាមហាឧបរាជជំនួសបង ទុកជាខឹងចោលស្រុកឡុកអៀងមិនបាន ព្រោះទើបនឹងតាំងទីនិយាយរាជការថ្មី ស្រុកខេសដែលជារាជអាណាខេត្រទាំងអស់នៅមិនទាន់រាបទាប ទូលព្រះបង្គំជាខ្ញុំ

សុំអាសាលើកទៅវាយស្រុកវុយកុកមុខជានឹងបាន , ព្រះចៅឡាសៀនក៏មិនដឹងនឹងទទឹងទាស់ ទ្រង់ព្រមបើកឲ្យកៀងអ៊ុយទៅ , កៀងអ៊ុយក៏ថ្វាយបង្គំលាចេញទៅស្រុកហានតុង រៀបចាត់ចែងលើកទ័ពចេញទៅ ។

ខណៈនោះ , ទៀវអេកជានាយទាហានធំហាមឃាត់ថា: ខបខណ្ឌសីមាដែលត្រូវឡើងស្រុកសែឈួនក៏តិច ស្បៀងអាហារក៏ស្តួចស្តើង ដែលនឹងលើកទ័ពទៅ ផ្លូវក៏ឆ្ងាយ ឃើញថាកម្រណាស់ , សុំឲ្យតែងកងទ័ពចេញទៅរក្សាអាណាខែត្ររបស់យើងទុក ឲ្យបណ្តាពស្ត្របាននៅជាសុខ ខ្ញុំបានគិតយ៉ាងនេះ ឃើញនឹងមានសេចក្តីចំរើនដល់ស្រុកទេសរបស់យើង កៀងអ៊ុយថា: អ្នកនិយាយនេះ ខ្ញុំមិនយល់ឃើញផងសោះ , ព្រោះកាលពីគ្រាមុនមហាឧបពជនៅមិនទាន់ចូលមកធ្វើខ្ញុំពជការនៅឡើយ បានកំណត់ទុកថា ផែនដីក្នុងមហាប្រទេសចិនតាំងឡាយនឹងបែកទៅជា ៣ ចែក លុះចូលមកធ្វើពជការហើយក៏លើកទ័ពទៅវាយស្រុកវុយកុក ទៅតាំងបន្ទាយនៅទីក្ខគីសានដល់ ៦ លើកហើយពជការក៏មិនសម្រេចរលត់សូន្យពាក់កណ្តាលផ្លូវ កាលនឹងរលត់សូន្យនោះ លោកក៏បានផ្តាំទុកនឹងយើងឲ្យធ្វើការតទៅ , គ្រានេះយើងបានចំណាប់ហើយត្រូវតែតាំងចិត្តគិតយកអាសាគម្ចាស់ផែនដី ទៅធ្វើការតបស្នងព្រះតេជៈព្រះគុណ តាមប្រវេណីជាតិទាហាន , ទោះនឹងបាត់ខ្លួនប្រាណក៏ពុំត្រូវសោកស្តាយអាល័យជីវិត ,

( នៅមានត )

# តើយើងគិតដូចម្ដេចអំពីជនជាតិជប៉ុន ?

ប្រែរៀបរៀងដោយអ្នកស្រី ពេជ-សល់

កាលពីឆ្នាំ ១៩៦៩ លោកការល់ និងលោកស្រីស្លេយម៉ីដាន (Carl et Shelley Mydans) បានសរសេរថា "សំនួរខាងលើនេះហើយ ដែលគេត្រូវចោទ នៅពេលដែលប្រជាជន ប្រកបដោយលក្ខណៈគួរឲ្យស្ញែងនេះ រៀបចំខ្លួន និងធ្វើសេចក្ដីសម្រេចចិត្ត ដែលជាទម្ងន់ទៅលើវាសនាទ្វីបអាស៊ីព្រមទាំងវាសនាពិភពលោកទាំងមូលផង ។

នៅឆ្នាំ ១៩៧០ ខាងមុខនេះ នឹងមានមហាអំណាចថ្មីមួយ បញ្ចេញខ្លួនធ្វើឲ្យគេឯងភ្ញាក់ផ្អើលមិនខានឡើយ ក្នុងពិភពលោកយើងនេះ ។ ប្រទេសជប៉ុនជាប្រទេសមួយ នៅដាច់ពីគេឯង ហើយជាប្រទេសដែលបានទទួលបរាជ័យក្នុងសង្គ្រាម កាលពី ២៥ ឆ្នាំមុននេះសោះ ស្រាប់តែឥឡូវនេះក្លាយទៅជាប្រទេសលូតលាស់មួយយ៉ាងសម្បើម ហើយមានដំហរមាំទាំជាងគេ ក្នុងចំណោមប្រទេសនានានៅទ្វីបអាស៊ី ថែមទាំងត្រូវបានគេចាត់ទុកជាមហាអំណាចទី ៣ ខាងផ្នែកសេដ្ឋកិច្ចផង ។ ទោះជាប្រទេសជប៉ុនមានការចម្រើនលូតលាស់ខ្ពស់ ដល់កម្រិតនេះហើយក៏ដោយ ក៏ប្រទេសនេះ ពុំទាន់បានចេញមុខប៉ុន្មានលើឆាកអន្តរជាតិនៅឡើយដែរ ។

នៅឆ្នាំ ១៩៧០ ខាងមុខនេះ ប្រទេសជប៉ុននឹងត្រូវធ្វើសេចក្ដីសម្រេចចិត្តយ៉ាងសំខាន់ ៗ ហើយ តើប្រទេសនេះ នឹងបំបាត់លក្ខខ័ណ្ឌ

ដែលសម្រេចថា ត្រូវបន្ថយដើមទុនបរទេស មិនឲ្យហូរចូលមកក្នុងប្រទេសខ្លួនឬដោះស្រាយចំណងសេដ្ឋកិច្ចដូចម្តេចទៅវិញ ដើម្បីឲ្យបានស្រុះស្រួលជាមួយនឹងសហរដ្ឋអាមេរិក? ចុះជាមួយនឹងប្រទេសចិន តើត្រូវដើរនយោបាយយ៉ាងណាទៅវិញ ក្នុងផ្ទៃអាស៊ីប៉ែកអាគ្នេយ៍ ? តើប្រទេសជប៉ុនមាននាទីជាអ្វី ក្នុងវិស័យរីកចម្រើន ? តើប្រទេសជប៉ុនអាចគេចរកគតិកាសញ្ញាសន្តិសុខ ស្តីអំពីការធានាការពារបរមាណូ ដែលខ្លួនបានចុះហត្ថលេខាជាមួយនឹងសហរដ្ឋអាមេរិក មិនឲ្យមានការកែប្រែបាន ដោយមិនឲ្យមានការចលាចល ផ្ទុះចេញអំពីមជ្ឈដ្ឋានយុវជននិស្សិតនិយមបានឬទេ ? បើតោះជាប្រទេសជប៉ុន ដោះស្រាយរបៀបណា ក៏នៅតែមានផលវិបាកយ៉ាងធំ ធ្លាក់ទៅលើពាណិជ្ជកម្មពិភពលោក និងលើអនាគតនៃទ្វីបអាស៊ីដែរ ។ ដូច្នេះហើយ ទើបក្រោយអំពីអ្នកប្រវត្តិសាស្ត្រជាច្រើនតំណមក យើងចោទសំនួរដ៏សំខាន់នេះម្តងទៀត ថា "តើយើងត្រូវគិតដូចម្តេចអំពីជនជាតិជប៉ុន ?

ជប៉ុន ជា "សត្វមាននិស្ស័យខាងសន្សំនិងសំចៃ"

ពិតមែនហើយតែជប៉ុនទាំងអស់មានចិត្តគំនិតមិនដូចគ្នា ប៉ុន្តែយើងត្រូវដឹងថា ប្រជាជាតិនេះ មានមនុស្សដល់ទៅជាង ១០០ លាននាក់ បើតោះជាមិនមានគំនិតប្លែក ៗ គ្នាពល់តែរូប ក៏នៅតែមានការប្លែក ៗ ច្រើនដែរ ។ ម្ល៉ោះហើយ គេអាចគ្រោងគំនូរមួយដោយប្រមាណ ឲ្យប្រហែលទៅនឹងភាពពិតរបស់ជប៉ុនបាន ដូចដែលគេតែងធ្វើចំពោះជាតិនានាដែរ ។

ជួនកាលគេនិយាយថា ប្រទេសជប៉ុនមានពីរផ្នែក គឺប្រទេសជប៉ុនផ្នែកអ្នករដ្ឋការ អ្នកនយោបាយ អ្នកជំនួញ និងប្រទេសជប៉ុនផ្នែកបញ្ញវន្ត ។ ផ្នែកទី ១ មានគណៈបក្សប្រជាធិបតេយ្យសេរីជាតិណាង ក្រុមនេះហើយដែលគ្រប់គ្រងរដ្ឋ តាំងពីពេលចប់ចម្បាំងមក ។ ឯផ្នែកអ្នកបញ្ញវន្ត ដែលមានភាគ ១ ធំ ចេញអំពីប្រភពសង្គមរដ្ឋ ចូលចិត្តធ្វើនយោបាយតាមបែបម៉ាក្សីសនិង ឡេនីន ជំនាន់ដើម ។ អ្នកទាំងនេះ ជាអ្នកនយោបាយបែបសំគិះហើយមិនដែលមានសមត្ថភាពនឹងទៅផ្លាស់ប្តូរនៃពួកផ្នែកទី ១ បានម្តងណាឡើយ ។

ដូចយ៉ាងរឿងសម្រេចចិត្តជាច្រើនដងរបស់ប្រទេសជប៉ុន ដែលគេនាំគ្នាធ្វើតាំង តាំងតែពីឆ្នាំ ១៩៧០ មក ក៏ត្រូវបានទៅពួកកាន់អំណាចសព្វថ្ងៃនេះ យកទៅអនុវត្តទៀត គឺអ្នកកាន់អំណាចនេះហើយ ដែលធ្វើមនុស្សឱ្យទៅជាពលរដ្ឋទាន់សម័យ ហើយពួកបញ្ញវន្តតែងដាក់ឆ្មារបែបចំអកថា « សត្វមានទិស្សយខាងសន្សំនិងសំចៃ » នោះ ។

នៅប្រទេសជប៉ុន រឿងនយោបាយ មិនមានរបៀបរៀបចំដូចនៅខាងបស្ចិមប្រទេសទេ ។ ក្នុងរឿងនេះ អ្នកជំនួញបរទេសម្នាក់ បាននិយាយថា :

នៅប្រទេសនេះ បើនិយាយឱ្យចំ គឺគេមិននិយមសម្រេចអ្វីៗ ឱ្យដាច់ណាត់ទេ ។ ការជ្រើសរើសនិងការចាត់ចែង ហាក់ដូចជាសាយភាយចេញ

ភ្លាម ៗ អំពីកិច្ចព្រមព្រៀងមួយ ជាឯកឆន្ទតែម្តង ហើយកិច្ចព្រមព្រៀងនេះទៀតសោត ក៏សឹងតែផុសចេញអំពីក្រុមនីមួយ ៗ នៃអង្គការរដ្ឋ តាមសន្ទាប់ តាំងតែពីបាតធំខាងក្រោម រហូតទៅដល់កំពូលស្រួចខាងលើ ព្រោះគម្រោងអង្គការរដ្ឋគេ មានខកងជាសាជី ៗ

នេះជាទម្លាប់របស់គេ ឬថា ជាការបម្រើនតាមសភាវគតិរបស់គេក៏បាន ៗ ការដែលគួរកត់សម្គាល់មួយ ចំពោះជនជាតិនេះ គឺ ជនជាតិនេះចូលចិត្តភាពមិនប្រាកដ និងមិនចំពោះ មិនផ្ទាល់ ជាជាងភាពច្បាស់លាស់ និងភាពប្រាកដ ៗ នេះហើយជាចរិតអថិត្រៃយនៃជនជាតិជប៉ុន ៗ សូម្បីតែក្នុងភាសានិយាយរបស់គេ ក៏មានសភាពដូច្នេះដែរ គឺគេប្តូរយោបល់គ្នាបែបតាំត្រណោត បែបអណ្តែតអណ្តូង ៗ ប៉ុន្តែភាសាគេនោះ អាចបង្ហាញឲ្យឃើញច្បាស់បាន នូវគំនិតដែលមានន័យល្អៀងគ្នាតែបន្តិចបន្តួច ហើយបើចង់និយាយអំពីការពាក់ទងរវាងមនុស្សវិញ គេបេះរកពាក្យប្រដូចមកពោល ឲ្យយល់បានដោយងាយ ហើយសមរម្យទៀតផង ៗ ប៉ុន្តែ បើយកភាសាជប៉ុន ទៅធ្វើជាមធ្យោបាយ ដើម្បីជជែកអំពីរឿងវិទ្យាសាស្ត្រ ឬកិច្ចការខាងជំនួញវិញ ពុំល្អអើយ ភាសានោះ ទៅជាឧបករណ៍មួយយ៉ាងគម្រក់ មិនគួរពេញចិត្តសោះ ៗ

តែ កុំឃើញប៉ុណ្ណឹងហើយ ប្រញាប់នាំគ្នាសន្និដ្ឋាន ថាជប៉ុនជាមនុស្សញ៉ាក់ ខ្ជិល ចូលចិត្តដេកបណ្តែតអារម្មណ៍នោះឲ្យសោះ ផ្ទុយទៅវិញទេ

ជនជាតិនេះ សម្បូរខាងកម្លាំងឋាមពល មានគំនិតចង់ចេះ ចង់ដឹង ចង់រៀន ប្រឹងខ្លួនទីងធ្វើការ ដុះជាប់ទីងក្បាលជាទិច្ច ហើយគេលើកតម្កើងជោគជ័យរបស់គេ ប៉ុន្តែគ្មានទីងវត្តសក្តិសិទ្ធិដែលគេគោរពបូជា ។ ជាពិសេសទៅទៀត គឺជប៉ុនពូកែខាងចេះសម្របខ្លួនតាមគេ ។ នេះហើយ ដែលជាករណីគ្មានពីរ ចំពោះប្រទេសថ្មី ហើយជឿនលឿន ។ ប្រទេសជប៉ុនមិនដែលបន្ទំខ្លួនឲ្យនៅក្នុងរបបណា ឬនៅក្នុងទ្រឹស្តីណាមួយ ដែលនិយាយថារបៀបនេះល្អ របៀបនេះអាក្រក់ឡើយ ព្រោះយោបល់តាំងនេះ នាំឲ្យតែអាក់ដំណើរជឿនលឿនរបស់គេទេ ។

## ខ្ញូរសមុទ្រ (Méduse Japonaise)

បើមើលពីខាងក្រៅ លទ្ធិប្រជាធិបតេយ្យជប៉ុន មានសភាពដូចបេះបិទ នឹងលទ្ធិប្រជាធិបតេយ្យអឺរ៉ុប ។ អ្នកតំណាងទិនសភា ត្រូវជ្រើសរើសតាមការបោះឆ្នោតជាសាកល ពួកគណៈបក្ស ផ្លាស់ប្តូរគ្នាកាន់អំណាច ដោយគ្មានការគម្រាមកំហែងអ្វីទេ គឺជាគ្រឿងយន្តមួយប្រភេទ ថែបជិតជិតណាស់ ខុសអំពីសភាពប្រជាធិបតេយ្យអឺរ៉ុបទើបគេអាចនិយាយអំពីរដ្ឋាភិបាលជប៉ុន ថាជារដ្ឋាភិបាលដែលកើតឡើង ដោយមានការយល់ព្រមជាឯកច្ឆន្ទ ។ អ្នកនយោបាយនិងគណៈបក្សមិនដឹកនាំប្រទេសទេ បើគិតតាមន័យនៃពាក្យនេះ គឺថា ជាតិនេះប្លែកអំពីការយល់របស់យើងដែលធ្លាប់តែថា អ្នកដែលមានភ័ព្វសនាបាន ធ្វើជាមេគេនោះ គឺត្រូវតែបញ្ជា

កិច្ចការផ្សេងៗតាមបំណងរបស់ខ្លួន ផ្ទុយទៅវិញ អ្នកនយោបាយទិសគណៈបក្សជប៉ុន ចាំបាច់តែមានការអនុម័តជាឯកច្ឆន្ទ លើបញ្ហាធំៗ ដែលចុះកុងរៀបការៈសិន ទើបចេញបញ្ជាជាក្រោយៗ ពុំនោះទេ ទាល់តែការអនុម័តជាឯកច្ឆន្ទនោះ ទាល់គំនិតគេច្រកចេញមិនរួច ទើបអ្នកនយោបាយហ៊ានសម្រេចជាយុទ្ធឯង ។

អាកប្បកិរិយាបែបនេះ ពួកយើង អ្នកបស្ចិមប្រទេសមិនយល់ទាល់តែសោះ ព្រោះជាអាកប្បកិរិយាដែលមានទិន្នាការអំពីទឹកដី ឬ ជាជាអាកប្បកិរិយា ដឹកនាំដោយអន្សរូសម្បជញ្ញៈ (Subconcient) ដែលធ្វើឲ្យប្រជាជនជប៉ុនចូលចិត្ត "ប្រមូលផ្តុំគ្នា" ។ អ្នកសង្កេតការមួយចំនួនបានពោលថា: អ្នកបច្ចេកទេសអាមេរិកកាំង បានសាកល្បងទំលាយរំលំសហគ្រាសធំៗ ដែលគោយកផ្សលើសេដ្ឋកិច្ចជប៉ុន តាំងពីមុនបរាជ័យមកដល់កងគ្រាបម្លាំងនេះ ប៉ុន្តែទៅជាទទួលញ៉ម ហើយសារភាពថា "ហាក់ដូចជាគេប្រយុទ្ធជាមួយទឹកខ្សែសមុទ្រ(១)" ។ តាមការពិត គឺមិនមែនជាការប្រឆាំងចំពោះជនណាម្នាក់ ឬចំពោះមនុស្សមួយក្រុមណាទេ គឺជាការប៉ះទង្គិចទៅលើទិន្នាការ ដែលមិនអាចទប់ទល់បាន ហើយថែមទាំងមានសភាពដូចជាប៉ះចំគ្រឿងសំខាន់នៃផ្ទៃកង ដែលជាហេតុបណ្តាលឲ្យមានការប្រែប្រួលរឹតតែខ្លាំងទៅទៀត ។

---

(១) ខ្សែសមុទ្រនេះ មានថែរគេវគោវច្រើន ប៉ុន្តែស្ងិតណាស់ ហើយតែកាលណាបើងចង់ហែកបណ្តាច់វា វាប្រឹងលួតចូលគ្នាមួយរំពេច ។

រឿងដែលធ្វើឲ្យអ្នកសង្កេតការបរទេស ចាប់ប្រាជ្ញាយ៉ាងធំ ប្រហែលជាមកអំពីជាតិនេះ មានអកប្បកិរិយាឃ្លងហែង ជាសភាពអ្នកធ្លាប់រស់នៅលើកោះផង ជាពលរដ្ឋមួយពួក ហើយមាននិស្ស័យយ៉ាងសំខាន់ខាងបេះផ្សែផ្សំយកលំនាំតាមគេផង ៗ ជប៉ុនម្នាក់ ដែលមានប្រាជ្ញាវៃឆ្លាតស្គាល់ចិត្តគំនិតរបស់ជនជាតិខ្លួន បានពោលថា «ភាពផ្ទុយនៃផ្នត់គំនិតរបស់ជាតិជប៉ុន ធៀបបានទៅនឹងទ្រឹស្តី នៃអ្នកលបមើលស្ថានការណ៍ខាងក្រៅ តាមប្រហោងតូច» ៗ

ប្រជាជនជប៉ុនដែលរស់នៅដាច់ឡែកអំពីគេ រាប់សតវត្សមកហើយ យល់ថា ខ្លួនគេ ប្រៀបបាននឹងមនុស្ស ដែលស្ថិតនៅក្នុងបន្ទប់ងងឹតមួយ ហើយលបមើលសង្កេតការព្រឹត្តិខាងក្រៅ ដែលមានរស្មីចញ្ចាំង តាមបន្ទោះមួយតូច ដោយគ្មានអ្នកណាមើលពីក្រៅមកឃើញឡើយ ហើយគ្មានចិត្តទុកស្មានថា ថ្ងៃណាមួយ ខ្លួននឹងអាចបញ្ចេញកាំរស្មីនៃគំនិតខ្លួននោះបង្ហាញគេបានផង ៗ ប៉ុន្តែ ជប៉ុនត្រូវប្តូរគំនិតនេះទៅវិញ នៅពេលដែលប្រទេសគេ បានរំកិលខ្លួនឆ្ពោះទៅកាន់ថ្នាក់ខ្ពស់ជាងគេ ក្នុងបណ្តាមហាអំណាចខាងឧស្សាហកម្មទាំងឡាយក្នុងលោក ៗ

កាលពីខែមិថុនា ឆ្នាំ ១៩៦៩ រដ្ឋាភិបាលជប៉ុនបានប្រកាសថា មានបំណងនឹងចាប់យកគោលនយោបាយថ្មី ក្នុងការបង្កើតផលិតផល ហើយនាអនាគត ប្រទេសជប៉ុនត្រូវឈប់ធ្វើតាមគេ ហើយត្រូវតែបង្កើតអ្វី ៗ ថ្មី

ដោយខ្លួនឯងទាំងអស់ ព្រោះតាំងពីដើមរៀងមកដល់ពេលនេះ ប្រទេសជប៉ុនគ្រាន់តែបានពិនិត្យ សិក្សា និងធ្វើអ្វី ៗ តាមប្រទេសគេតែប៉ុណ្ណោះ ។

និស្ស័យមហាស្ចារ្យខាងយកលំនាំផ្សេងៗតាមគេ

ជប៉ុនមានឧបសម្បទាថ្លៃកណាស់ ខាងបេះធ្វើខ្លួនឲ្យដូចគេ និងបេះយកគំនិតដែលខ្លួនបានសង្កេតរបស់គេ មកប្រើឲ្យបានជាប្រយោជន៍ផ្ទាល់ខ្លួនពិតៗ ។ ការសិក្សាមានអាទិ៍ជាឯកសិទ្ធិជកាប នៅប្រទេសនេះ ដូច្នេះហើយ ទើបនៅសម័យបច្ចុប្បន្ននេះ ប្រទេសជប៉ុនជាប្រទេសមួយ ដែលមានអនក្ខរៈជនតិចជាងគេបំផុតក្នុងលោកទាំងមូល ។ តាំងតែពីសតវត្សណាមក ជប៉ុនមានវរជនពូកែ ៗ អាចទទួលវិជ្ជាដែលពិបាកយល់ និងវិជ្ជាបច្ចេកទេសសាំញ៉ាំបំផុត ដែលនាំមកអំពីបរទេស ។

ហើយទើបតែអំពីក្រោយសង្គ្រាមនេះទេ ដែលក្រុមហ៊ុនជប៉ុនឈ្មោះ នីប៉ុង គោគ្ហាគូ បានចាប់ផ្ដើមសាងនាប្រដាប់ថតរូបមួយប្រភេទឈ្មោះ នីកុន ។ ប្រដាប់ថតរូបនេះ មានប្រិយភាពសម្បើម ហើយល្អលើសប្រដាប់ថតរូបនានាក្នុងពិភពលោកផង ។ លោក ហ័រ្ប៊ូស៊ី ស៊ីហ្កហាមា ដែលជាអតីតអគ្គនាយកចូលនិវត្តិ បានបញ្ជាក់លើសេចក្ដីខាងលើនេះ គួរឲ្យចាប់អារម្មណ៍ណាស់ ថា:

- តាំងពីយូរឆ្នាំមកហើយ យើងបានតាមសង្កេតការចម្រើនលូត

ណាស់ នៃជនជាតិអាឡឺម៉ង់ ក្នុងវិស័យនេះ ។ លុះមកដល់ឆ្នាំ ១៩៤៥ យើងបានសម្រេចចិត្តថា នឹងចាប់ធ្វើគ្រឿងថតរូបនិងកែវឆ្លុះថតនេះជាអា-ទិភាព រួចហើយយើងក៏តាំងចាប់សិក្សាយ៉ាងល្អិតល្អន់ អំពីគ្រឿងថតទាំងអស់របស់អាឡឺម៉ង់ ។ យើងចំយកលំនាំតាមគេបន្តិចម្តងបន្តិចម្តង ថែមថយគ្រឿងនេះខ្លះ-នោះខ្លះ ឲ្យមានសភាពល្អជាងគេបន្តិចឡើង ។ រួចយើងក៏បង្កើតបានជាប្រដាប់ថតរូបមួយបែប ។ តាមបច្ចេកទេសរបស់យើង ហើយមានភាពប្លែកអំពីរបស់គេ ។ ការដែលអាមេរិកាំងបានមកជួយ ដើម្បីឲ្យសហគ្រាសយើងមានរបៀបរៀបរយល្អ ជាគុណប្រយោជន៍មួយធំណាស់ចំពោះយើង ។ ប៉ុន្តែ មានកត្តាច្រើនផ្សេងទៀតដែលនាំឲ្យជប៉ុនយើងដើរមកដល់ជោគជ័យនេះ ។

លោកស្ហីកហាមា បានបន្ថែមទៀតថា :

ប្រទេសជប៉ុន ពុំសម្បូរដោយភោគទ្រព្យធម្មជាតិទេ សម្បូរតែខាងទឹកចិត្តតស៊ូ និងទឹកចិត្តក្លាហាន ប្រជាជនយើង មានសន្តានចិត្តចង់នឹងការងារខ្លាំងណាស់ ឯជនជាតិអាមេរិកាំង គេមាននិស្ស័យខាងរៀបចំនិងត្រួតត្រា ដុះពីកំណើតតែម្តង ។ ក្នុងនិស្ស័យនេះ គ្មានជនជាតិណាមួយ ធ្វើដូចគេបានទេ ។ យើងឈ្នះប្រជាជនទាំងឡាយ ដោយយើងប៉ុនប្រសប់ខាងការហត្ថកម្ម និងមានសន្តានចិត្តមាន.ក្នុងការងារ តែកាលណាយើងចាប់ធ្វើការអ្វីមួយហើយ យើងគ្មានគិតអ្វីក្រៅអំពីការនោះឡើយ ។ នេះហើយជាលក្ខណៈលេចជាងគេរបស់ជាតិយើង ។

ជាមពលសម្រាប់លក់

រឿងដែលប្រជាជនយើង មានសមត្ថភាពសម្បើមនឹងធ្វើការងារនេះ ហើយ ដែលធ្វើឲ្យអ្នកទស្សនាបរទេស ទៅជាស្រឡាំងកាំងៗ តួយ៉ាងដូចជានៅក្នុងរោងចក្រជាច្រើន ប្រដាប់ដោយគ្រឿងចក្រយ៉ាងទំនើបលើសលុប នៃក្រុមហ៊ុនម៉ាត់ស៊ុយស៊ីតា អេឡិចទ្រិច នៅក្រុងអូសាកា (La Compagnie Matsushita Electric d'Osaka) ដែលស្ថាបនាគ្រឿងវិទ្យុ គ្រឿងទូរទស្សន៍ គ្រឿងថតសំឡេង សញ្ញា «ណាសូណាល់» និង «ប៉ាណាសូនិច» មានចំនួនកម្មករទាំងស្រីទាំងប្រុសច្រើនស្ទើររាប់មិនបាន អង្គុយជាជួរ ឈ្ងោកសម្ងំតែផ្គុំធាតុនៃអេស្រាណូ (éléments électroniques) យ៉ាងល្អិតៗ ហើយពិបាកធ្វើក្រៃលែង ៗ តើកម្លាំងអ្វីមកបង្ខំចិត្តអ្នកទាំងនោះ ឲ្យខំធ្វើការឲ្យបានល្អ ឲ្យបានឆាប់រហ័ស ឲ្យបេះអត់ធន់នឹងការងារយ៉ាងនេះ? តើជាមពលអ្វី ដែលជម្រុញចិត្តកម្មករក្មេងៗ ក្នុងរោងចក្រទាំងពាស់ទាំងមូលនោះ ឲ្យយកចិត្តទុកដាក់នឹងការងារ បីដូចជាមនុស្សវក់ ហើយមិនដែលមកធ្វើការ ដោយយឺតពេលម្តងណាសោះ សូម្បីតែកម្មករធ្វើដី គឺខំជីកដីទាំងញញាក់ញញ័រ បីដូចជាទាហានដែលខំជីកលេណដ្ឋាន ដើម្បីជ្រកពួន នៅក្រោមសន្ទុះគ្រឿងគ្រាប់ នៃបច្ចាមិត្តដូច្នោះឯង ៗ

ក៏ប៉ុន្តែគ្មានកម្មករណាមួយ នឹករកពាក្យឆ្លើយតបនឹងសំនួរគេ ថាខ្លួនធ្វើការ ដើម្បីឲ្យសហគ្រាសបានចំរើនល្អណាស់ទេ ពីព្រោះគេទុកសហគ្រាសជាគេហសារទី ២ របស់ខ្លួន ៗ អ្នកខ្លះយល់ថា ការខ្វះខ្វែងរៀស

នៅក្នុងកិច្ចការបែបនេះ គឺជាការអប់រំរបស់ជាតិជប៉ុនឯងនោះតែម្តង ដែលចូលចិត្តប្រកួតក្នុងរឿងធ្វើការ គឺគេធ្វើរបៀបដូចជាកេណ្ឌមនុស្សឲ្យធ្វើការក្នុងសង្គមមួយ ដែលពោរពេញដោយទឹកចិត្តប្រយុទ្ធ ពីកំណើតតែម្តង ដូច្នេះហេតុការណ៍ដ៏ជ្រៅនៃចរិតបែបនេះ កុំថាឡើយតែជនបរទេស សូម្បីតែពួកជប៉ុនឯងហ្នឹង ក៏មិនយល់ខ្លួនឯងដែរ ៗ រឿងពិសេសទៅទៀត ដែលធ្វើឲ្យជនបរទេសទាំងនោះ រឹតតែភ្ញាក់ទឹកចិត្តខ្លាំងទៅទៀត គឺជប៉ុនមានសកម្មភាពដ៏អស្ចារ្យ ហើយមិនចេះហួតរីង ឯខាងថាមពលក៏មិនចេះហេវហាបដូចគ្នាដែរ ៗ

ជនជាតិជប៉ុនទាំងនោះ ក្រោយអំពីបានធ្វើការអស់កម្លាំងកាយហើយ ក៏គង់តែទៅធ្វៀតលេងសប្បាយ លុះតែហេវល្វើយទើបឈប់ ៗ ប្រជាជនជប៉ុន មានសម្បទាខាងធ្វើការដោយឥតសំចៃកម្លាំង ហើយថែមទាំងចេះរក្សាខ្លួន ឲ្យនៅក្នុងវង្វង់របៀបរៀបរយទៀតនោះ បានសេចក្តីថា គេត្រឹមត្រូវទាំងសព្វ សូម្បីតែរឿងខ្ចីបុល ជំពាក់បំណុលគេហើយ ក៏នៅតែទៀងទាត់ទៀត ៗ លក្ខណៈទាំងនេះហើយទេដឹង ដែលជាកូនសោរនៃការរីកចម្រើនរបស់គេនោះ ?

សូម្បីតែជេរប្រមាថគ្នា ក៏ធ្វើដោយគួរសមដែរ

តាំងពីប៉ុន្មានឆ្នាំមកនេះ ការនិយមរបៀបរៀបរយ របៀបសមរម្យដែលមានជាទម្លាប់មក តាំងពីយូរណាស់មកហើយនោះ ហាក់ដូចជាលុប

បាត់ខ្លះទៅហើយ ប៉ុន្តែនៅសល់ឫសក្នុងលក្ខណៈសង្គមជាតិគេ ហើយទោះជាត្រូវការប្រាស្រ័យគ្នាជាធម្មតាហ្នឹងក៏ដោយ ក៏ប្រសប់រកពាក្យប្រើឲ្យស្រទន់ពីរោះដែរ ៗ បើសិនជាគេចង់ជេរប្រមាថអ្នកណាម្នាក់ ក៏គេនៅតែប្រើពាក្យគួរសម ដែលសម្រាប់ប្រើចំពោះមនុស្សធម្មតាដែរ ពុំនោះទេ គេគ្រាន់តែយកពាក្យមិនសូវគួរសម ដែលជនសាមញ្ញមិនអាចប្រើបានចំពោះអ្នកមានបណ្ដាសក្ដិតែប៉ុណ្ណោះ ៗ

គេទុកជប៉ុនជាមនុស្សមានរបៀបរបប ស្អាតបាត និងចេះគួរសមណាស់ ហើយគេមានចរិតនេះ ពីកំណើតគេដូច្នេះមែន ក្នុងទំនាក់ទំនងនឹងមិត្តសំឡាញ់ក្ដី ក្នុងវិជ្ជាជីវៈក្ដី ៗ ប៉ុន្តែ នៅកន្លែងសាធារណៈឬនៅចំពោះតែអ្នកដែលគេមិនស្គាល់វិញ ជប៉ុនចេះបញ្ចេញឫកយោរយៅ ប្រឡេងខាម ដូចជាតិដទៃអ៊ីចឹងដែរ ៗ ចំណែកខាងផ្លូវថ្នល់ នៅទីក្រុងនៃប្រទេសនេះវិញ ក៏គ្មានទៅស្អាត ពិសេសឯណាជាងគេដែរ ៗ នៅក្នុងមជ្ឈដ្ឋានបរទេស ពេលមានបរិយាកាសមិនស្រួល ជប៉ុនអាចបញ្ចេញកាយវិការយ៉ាងប្លែក ដូនកាលគួរឲ្យខ្លាចផងក៏មាន ៗ ជប៉ុនមានទឹកមុខមាំមានសម្លឹងបែបព្រួយ ប្រុងជានិច្ច ហើយហាក់ដូចជាមានចិត្តគិតជាប់ថា តើខ្លួនអញត្រូវធ្វើអ្វី ឬថា តើគេប្រើអញឲ្យធ្វើអ្វីហ្ន៎ ?

ជនជាតិនេះ ចាប់អារម្មណ៍នឹងមតិអ្នកផងចំពោះខ្លួនណាស់ ម្ល៉ោះហើយ ក៏ខំតម្រែតម្រង់កិរិយាមារយាទខ្លួន ដើម្បីជៀសពាក្យគេនិន្ទានោះទៅ ៗ ឯពួកបស្ចិមប្រទេសវិញ គេគ្មានគិតដូច្នោះទេ គេយកតែអំពើល្អឬអាក្រក់ជាប្រមាណ ៖

ជប៉ុនគិតយកន័យ គ្រង់ខ្លាចគេថាជាប្រមាណ រួចទើបទប់ចិត្តខ្លួន តាមរបៀបនោះទៅ ។ នៅក្នុងក្រុមហ៊ុនមាត់ស៊ុយស្ហ៊ីតា អេឡេចទ្រិច គេមានធ្វើកន្លែងមួយពិសេស សម្រាប់អ្នកបម្រើការ ដែលក្តៅចិត្តខឹងរឿងអ្វីមួយ ទៅបន្ធូរបរិយាកាស ។ នៅកន្លែងពិសេសនោះ អ្នកបម្រើការចូលទៅពេលណាក៏បាន ។

រាល់ថ្ងៃ មានមនុស្សពី ១៥ ទៅ ២០ នាក់ ដើរចូលបន្ត ៗ គ្នា ទៅក្នុងបន្ទប់នោះ ។ ក្នុងបន្ទប់នោះ គេគ្មានឃើញរបស់អ្វីក្រៅអំពីរូបមនុស្សពីរ ធ្វើដោយចំបើង ពាសសំពត់ រូបមួយធំ រូបមួយតូច និងព្រនង់ជាច្រើន សម្រាប់សំពងរូប ។ ឯរូបទីងមោងមួយតូចជាងគេនោះ ត្រូវគេសំពងញឹកញាប់ពេកទៅ ទាល់តែលៀនចំបើងចេញពីក្បាល រីឯគ្រង់កន្លែងក្រពះ ក៏រហែកសំពត់ពាសចេញអស់រលីងដែរ ។

ប៉ុន្តែគួរកត់សម្គាល់ថា ការដែលគេនាំគ្នាទៅសំពងរូបបែបនេះ មិនមែនគេសំដែងកំហឹងចំពោះនាយចៅហ្វាយគេទេ គឺគេវាយមនុស្សទីងខ្លួនគេតែម្តង ។

តាមសេចក្តីអធិប្បាយខាងលើនេះ យើងយល់ឃើញថា ជប៉ុនជាមនុស្ស ទម្យម ហើយតឹងរឹងនឹងខ្លួនឯងណាស់ ប៉ុន្តែមិនដូច្នោះសោះ ៗ ជប៉ុននេះដែលតាំងចិត្តជាស្រេចទីងការពារឈ្មោះ ឬ ការផ្តេសផ្តាសឡើយ ថែមទាំងចូលចិត្តល្បែងគប់ឈើ គ្នា ខ្វះខាតនោះអ្វីផង ហើយជប៉ុនលែ

ពេលមួយផ្ទែកធំ ក្នុងជីវិតរបស់គេ សម្រាប់លំហែនឹងល្បែងទាំងនោះ ។ គេបានបញ្ជាក់ថែមទៀតថា នៅទីក្រុងតូក្យូសព្វថ្ងៃនេះ គេមានរោងភាពយន្ត ១ ល្ខោនយន្ត ១ និងភោជនីយដ្ឋាន ១ សម្រាប់មនុស្សតែ ១១០ នាក់ប៉ុណ្ណោះ (រាប់ទាំងស្រី ទាំងប្រុស ទាំងក្មេង) ។ ពួកអ្នកមានធនធានភាគច្រើន ចូលចិត្តបញ្ចេញសំភ្លៀងភាពប្រណីត ភាពចេតនាយ ស្ទើរតែហួសហៀរចេញមកក្រៅផ្ទះ ។ ចំណែកឯគ្រឿងឧបភោគបរិភោគវិញក៏សម្បូរណាស់ទៅទៀត ។ មួយថ្ងៃ ១ គ្រាន់តែសម្រាមដែលផ្ទះនីមួយ ១ បោះចោល ដូចជាសំបកកំប៉ុង ប្រអប់ទំ ១ល១ ច្រើនហួសប្រមាណ ហើយបើធៀបទៅនឹងកាលពី ១៩៤៥ វិញ ស្ទើរតែបាយ ១ គ្រាប់ចំណែកតាមតម្លៃមាស ។

សម្លេងជាតិ

អំណើះតទៅ ប្រទេសជប៉ុននឹងមានភាពស្ទើរនឹងប្រទេសអាមេរិកគ្មានខុស ។ សហគ្រាសនីមួយ ១ ធំដង្គ្រាំង ១ កំពុងតែធ្វើការបង្កើតផលយ៉ាងសកម្ម បណ្តាលឲ្យអាកាសធាតុនៅទីក្រុង ព្រមទាំងស្រែចម្ការ ឡើងអួរអ័ព្ទ ។ មានយុវជនច្រើនដូចស្រមោច កាន់តំណែងត្រង់ប៉ុស្តិ៍បញ្ជាការធំ ១ ក្នុងសហគ្រាស ដែលកំពុងតែរីកចម្រើននោះ ។ ក្នុងវិស័យកសិកម្មវិញក៏គេនាំគ្នាប្រើគ្រឿងចក្រ កាន់តែច្រើនណាស់ទៅហើយដែរ ។ នៅតាមជនបទក្នុងទីក្រុង ឃើញតែរថយន្តយ៉ាងល្អ ១ ណែនណាន់តាន់តាប់ ។

ប៉ុន្តែ ពោះជាយ៉ាងនេះហើយក៏ដោយ របៀបសម័យក៏ពុំទាន់មានអានុភាព ដល់ទៅកម្ចាត់ភាពបុរាណបានអស់ដែរ ព្រោះគេនៅឃើញសល់ភាពនេះ ស្ទើរតែគ្រប់កន្លែងនៅឡើយ ។ មិនមែនដូចកាលពី ៤០ ឆ្នាំមុននោះទេ ជប៉ុនឥឡូវ ជាមនុស្សមានសុខភាពល្អប្លែក ហើយមានមាឌមាំ ៗ ទៀត ហេតុនេះហើយបានជាក្រោយពេលចម្បាំង គេត្រូវបង្កើនខ្នាតកៅអីនិងតុ សាលារៀន ឲ្យបានធំទូលាយជាងមុន ។

គួរឲ្យឆ្ងល់ណាស់ ភាពចាស់លាយនឹងភាពថ្មី ភាពល្អលាយនឹងភាព អាក្រក់ ហើយបានទៅជាកត្តាមួយដែលបែរជាធ្វើឲ្យប្រទេសជប៉ុនសម័យ ថ្មីនេះ មានគេចូលចិត្តស្រឡាញ់ច្រើនទៅវិញ ។ បើនិយាយឲ្យខ្លីទៅ គឺ ជាលក្ខណៈចម្លែកទាំងអស់នេះហើយ ដែលជាសម្ផស្សជប៉ុនទាក់ចិត្តយើង ព្រោះថា នៅឯខាងបស្ចិមប្រទេសឯណោះ ច្រើនតែមានមនុស្សម្នាក់ ៗ ឈ្លើយខុសពីចំណោមអ្នកដទៃ ឯនៅប្រទេសជប៉ុនវិញ គឺទៅជាចំណោម មនុស្សឈ្លើយច្រើនលេចចេញហួសអំពីមនុស្សម្នាក់ ៗ ទៅវិញ ។

សព្វថ្ងៃនេះ ប្រទេសជប៉ុនកំពុងតែប្រឹងប្រែងខ្លួន ទឹងឈានចាប់ យកនយោបាយ ល្បងយកទឹកដីក្នុងពិភពលោក ដោយសន្តិវិធី ហើយ ដែលជាវិធីលើកដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រ ។ ឯនយោបាយនេះទៀត សោត ក៏ពុំមែនជាឆន្ទៈនៃក្រុមណា ឬពួកណាក្នុងជនជាតិនោះទេ គឺជា កម្លាំងជំរុលចិត្តនៃប្រជាជាតិទាំងមូលតែម្ដង ។

ប្រែរៀបរៀងដោយអ្នកស្រី ពេជ - សល់

# កវីទស្សនៈ (ក)

ដូច្នេះ ការរស់អាចរួមគ្នា　　នៅត្រង់បរិយាចិត្តសន្តាន
នៅត្រង់ទស្ស័យស្មើលៃស្មាន　　ស្តីស្តាប់គ្នាបានគ្មានប្រកាន់　　ៗ
មិនឈ្លោះប្រកែកស្រែកក្តែងៗ　　យកត្រូវតែឯងល្បែងដុកដាន
នៅត្រង់ស្របគ្នាជាឯកច្ឆន្ទ　　ជាការសំខាន់កាន់សុខា　　ៗ

បកស្រាយប៉ុណ្ណោះអាចរិះយល់　　នូវឥទ្ធិពលនៃស្នេហា
តើយើងត្រូវដោះរបៀបណា　　ទើបអស់ «បញ្ហាស្នេហា» នេះ　　ៗ
បើតាមទ្រឹស្តីលៃសម្រួល　　ឃើញជាក់ស្រួលទឹងគេបរេះ
តែតាមសភាពមិនដូច្នេះ　　អ្នកទាំងល្ងង់ចេះជាប់ដូចគ្នា　　ៗ
ទោះបីឃើញទោសទុក្ខពិតពិត　　ប៉ុន្តែឯចិត្តមនុស្សលោកា
ក៏នៅតែស្អិតជាប់ស្នេហា　　កម្រជនណាលះកាត់បាន　　ៗ

ព្រះពុទ្ធទ្រង់ដឹងរឿងហ្នឹងច្បាស់　　បានជាប្រកាសគ្រាស់ទូន្មាន
ប្រាប់ផ្លូវត្រូវដើរដើក្សេមក្សាន្ត　　ឆ្ពោះទៅនិព្វានឋានរលត់　　ៗ
ជាទីដែលខ្សោះអស់តណ្ហា　　កាត់ផ្តាច់ស្នេហាគ្រឿងរន្ធត់
អ្នកដែលដើរតាមព្រះសុគត　　ច្រើនចូលកាន់ព្រតជាបព្វជិត　　ៗ
អ្នកបួសក៏ជាមនុស្សដូចយើង　　សុទ្ធតែត្រូវភ្លើងស្នេហ៍ដុតចិត្ត
តែលោកដើរត្រូវផ្លូវប្រព្រឹត្ត　　ហាត់លះកាត់ចិត្តពីស្នេហ៍ស្នង　　ៗ
លះលែងចាញ់បោកលោកធម្មជាតិ　　ប្រាសចោលពូជធាតុជាតិចំណង
ដូច្នេះទើបក្ស័យក្តីសៅហ្មង　　ដាច់ខ្សែចំណងចង-គអស់　　ៗ

ផ្កាទន់ទុនហ្នឹងស្រវឹងពុល មានពិសកាចជ្រុលជាងពិសពស់
សុខតិច, ឯទុក្ខកប់មិនអស់ មានសេចក្ដីផ្សាចេញជាផល ។
តើលះបែបនេះផុតឬទេ? បើកាត់ផ្ដាច់ស្នេហ៍មេឬសគល់
លះលែងផ្សំធាតុជាតិកង្វល់ ដូច្នេះតើផលទៅយ៉ាងណា? ។
មិនបាច់ព្រោកប្រាជ្ញកំសាចដីង បើលះអំពីង លែងបញ្ហា
រឿងទុក្ខផ្សេងៗព្រោះស្នេហា គរីពោលថា «បញ្ហាចប់» ។
ប៉ុន្តែចិត្តមនុស្សទាំងប្រុសស្រី មិនដូច្នេះអី ច្រើនបរច្ប់
បរជ្រែករកស្នេហ៍មិនព្រមឈប់ លះហើយត្រឡប់ជាប់ជាថ្មី ។
មានជនតិចណាស់ឈ្នះតណ្ហា ឈ្នះចិត្តស្នេហា ឈ្នះលោកិយ
លែងពាញ់ធម្មជាតិបោកសាវ្ដ រស់ក្នុងលោកិយជាសុខសាន្ត ។
ឯជនភាគច្រើនបម្រើលោក នៅតែពាញ់បោកយោគយល់ស្មាន
ថាផលស្នេហាឲ្យសុខសាន្ត ទើបស្អិតជិតប្រាណមិនហ៊ានលះ ។
ទោះបីឃើញទោសទុក្ខនោះដែរ ក៏នៅតែបែរទប់មិនឈ្នះ
បានត្រឹមតែពោលសរសើរព្រះ ថា «លោកអ្នកឈ្នះលះលោកិយ» ។
ដូច្នេះ «បញ្ហាស្នេហា» លោក ពានៅតែបោចជនប្រុសស្រី
ឥឡូវទស្សនៈអ្នកគរី ប្រែស្មៀតជាថ្មីមកលៃ ប្លាច់ ។
សូមឲ្យស្រីប្រុសលុះតណ្ហា បើខ្វះប្រាជ្ញាចូរចាំស្ដាប់
ទីមួយ-ត្រូវតែគោរពច្បាប់ ទីពីរ-ត្រូវគ្រាប់ខ្ជាប់ជាតិ ។

ផ្លូវច្បាប់គឺហាមប្រាមប្រព្រឹត្តិ រំលោភដោយចិត្តគិតប្រមាថ
ដោយចាប់បង្ខំផ្សំគាឃាត ដោយលួចព្យាបាទអ្នកលង់លក់ ។
ដោយប្រើថ្នាំកាមគាមទំនើប ឲ្យគេស្រៀវស្រើបស្រួលឆាបឆក់
ដោយការបំភ័យក្ដីអាក្រក់ ឲ្យគេផ្ដួលលេកលស់វិបត្តិ ។
ដោយប្រើអំណាចកាចឃោរឃៅ ឆា ឆៅតាមចង់ដូចអង្គក្សត្រ
នេះសុទ្ធតែត្រូវផ្លូវបញ្ញត្តិ ដែលរដ្ឋបានចាត់ថា « ខុសច្បាប់ » ។
ច្បាប់ធម៌គឺសីលក៏បានហាម ព្រោះត្រូវផ្ទុះកាមមិនគួរគាប់
ដោយភាគីម្ខាងនេះអត់ឲ្យ ដូចស្លាប់សិទ្ធិសេរីភាព ។
រីឯទំនៀមទម្លាប់ជាតិ ដែលហាមមារយាទដ៏ថោកទាប
ទាំងការលួចលាក់ស្ម័គ្រស្នេហភាព រួមគ្នាសាងបាបទាំងពីរនាក់ ។
គឺទាំងស្រីប្រុសចុះស្នេហា ស្រើបស្រាលរកគ្នាប្រាថ្នាស្ម័គ្រ
ស្រុះស្រួលបបួលគ្នារួមរ័ក្ស តាមផ្លូវលួចលាក់អ្នកអភិបាល ។
ការណ៍នេះពិតមែនតែសុខចិត្ត ព្រមគ្នាប្រព្រឹត្តត្រេកត្រអាល
តែក៏ជាទុក្ខទោសបណ្ដាល ឲ្យអ្នកអភិបាលកើតថ្នាំងថ្នាក់ ។
ព្រោះធម្មតាមនុស្សមើលខុសត្រូវ ទោះម៉ែឪឬណាម្នាក់
ចង់ឲ្យតែជនក្រោមភិភក្តិ បានស័ក្តិថ្នាក់យសកេរ្តិ៍ឈ្មោះល្អ ។
បើឃើញកូនចៅទៅប្រាស នោះគាត់សែនខ្មាសជាងវិលក្រ
នាមឈ្មោះម៉ែឪស្លាប់នៅល្អ ឲ្យខូចតំណាគេគ្រប់ ។

ភាសពាក្យគេថា ពូជនេះផិត    ពូជនេះបរិតចិត្តបំផុប
ពូជនេះប្រើនតែវៀចវេរខូច    ពូជនេះកំហូចកំហិលចៅ ។
យ៉ាងហ្នឹង តើជនជាមេបា    សុខស្រួលចិត្តបានម្ដេចទៅ ?
អីចឹងបានជាផ្ទុះភ្លើងក្ដៅ    ចង្រាំងទឹងកូនចៅដូចជាខ្មាំង ។
ដូច្នេះ ការពានពារទម្លាប់    ប្រពៃណីគាប់អក័ត្យខ្លាំង
ព្រោះអ្នកទាំងពីររួមប្រឆាំង    បង្កចម្បាំងទឹងមេបា ។
បើម្ខាងបង្ខំពុំសន្តោស    នោះវាជាទោសមនុស្សឯកា
ដល់ព្រមស្ម័គ្រស្មោះទាំងអស់គ្នា    នោះវាជាទោសទាំងពីរប្រាណ ។
    រឿងការរួមរសេរកេរន្ទាន់    នេះគ្រាន់តែបែកជាពីរស្ថាន
តម្លៃទាបខ្ពស់ខុសប្រមាណ    តើគួរចង់បាននូវស្ថានណា ? ។
គំមួយ រួមគ្នាជាគូគាប់    ខុសផ្លូវទម្លាប់ច្បាប់មេបា
មួយទៀតដោយបានរៀបអាពាហ៍    ជួបជុំមេបាឲ្យតាវជ័យ ។
ការរួមផ្ដើមផ្ដួចដោយលួចលាក់    ដឹងតែពីរនាក់នេះហៅ “ព្រៃ”
បុរាណចាត់ទុកថា “ចង្រៃ”    តម្លៃទាបតុះចុះដល់សូន្យ ។
ហើយគេព្រួសទោសខុសទម្លាប់    នេះជាប់ជាសែហែដល់កូន
រហូតដល់ចៅចៅជីដូន    ក៏សូន្យតម្លៃវិស័យសក្ក ។
គេប្រកាន់ថា ការខិលខូច    នេះវាមានពូជមិនងាយបាត់
ពូជណាផ្ដាច់ខូចលួចលាក់លាត់    កូនចៅត្រូវកាត់តាមពុំខាន ។

ឯការរួមរស់ជាយមេធា　　រៀបចំសាពាហ៍ពិពាហ៍ប្រាណ
នេះជាមង្គលដ៏ថ្កើនថ្កាន　　បុកណាឲ្យថ្លៃតម្លៃណាស់ ៗ
មើលចុះខុសគ្នាតែបន្តិច　　មួយដូចជាពេជ្រជាំលើមាស
មួយទៀតដូចជាលាមកពាស　　រងគាស្រូវកាសវិនាសថ្លៃ ៗ
គូរពោលសន្ទួចមួយបែបទៀត　　ជាស្នៀតយកគ្នារួមនិស្ស័យ
មួយយកជោយគេឲ្យពរជ័យ　　មួយព្រៃគឺគេជេរបន្ទា ៗ
ឯការបានជាប្រពន្ធប្តី　　ជ័យក្តី ជេរក្តី ដូចដូចគ្នា
តែជ័យថ្លៃជោគលោកជ្រះថ្លា　　ឯជេរគេថាជោគពាបវិន្ស ៗ
ដូច្នេះ ទម្លាប់បវេណី　　បុរសនារីខ្មែរស្លូតត្រង់
ត្រូវកុំកម្ចាត់ឲ្យបាត់បង់　　ទើបមិនលិចលង់កង់ស្នេហា ៗ
ការប្រព្រឹត្តច្បាប់ទំនៀមទម្លាប់　　នេះបើបានជាប់គ្រប់មាត្រា
ទស្សនៈកវីស្រដីថា　　"បញ្ហាស្នេហា" នឹងដូរស្រាល ៗ
ព្រោះចាស់បង្ហូនសួនទម្លាប់　　ប្រៀនប្រាប់ច្បាប់ក្រមអំឡុងកាល
បំណងកំនែកការស្រើបស្រាល　　កុំឲ្យកលជាលដូចតិរច្ឆាន ៗ
ធម្មតាពួកសត្វពាក់ឈ្មោលញី　　មានប្រពៃណីតាមសន្តាន
ប៉ុន្តែស្នេហាការរួមប្រាណ　　វាគ្មានរៀនខ្មាសចាស់កូនវ័យ ៗ
ដូចជាឆ្កែឆ្មាមាន់ទាប　　រស់នៅក្បែរសំយាបផ្ទះសព្វថ្ងៃ
បើគេឃើញចចកស៊ីពែកព្រៃ　　វាមាននិស្ស័យឥតសារៈធា ៗ

តែទឹកត្រអាលស្រាលស្រើបកាម ក៏ប្រព្រឹត្តភ្លាមតាមចិន្តា
ទោះបីបើកមុខកណ្ដាលថ្លា ក៏វាគ្មានចិត្តគិតអៀនខ្មាស ។
មិនបាច់មេបារៀបការទេ មិនរើសឈ្មោលមេប្ដូរក្មេងចាស់
ចេះតែពាក់ព័ន្ធជាន់តែពាស ប្ដូរផ្លាស់ប្រែប្រួលវល់តាមចង់ ។
ឯមនុស្សវិញមិនដូចសត្វ ស្គាល់គុណវិបត្តិកេរ្តិ៍ពូជពង្ស
ចេះអៀនចេះខ្មាសប្រាសក្ដីល្ងង់ មានច្បាប់តម្រង់កម្រិតកាត់ ។
ប្រសិនជនណាប្រាជ្ញាល្ងិត ហ៊ានពានប្រព្រឹត្តព្រើលដូចសត្វ
ជននោះមនុស្សពិត បណ្ឌិតបាត់ ទុកថាជា « សត្វ » ឥតសង្ស័យ ។
ព្រោះរូបតិរច្ឆានទិនប្រាណមនុស្ស មិនខុសផ្សេងគ្នាជាទៃ
មានភ្នែកច្រមុះសាច់សរសៃ ចេះគិតចេះភ័យក្ស័យជន្មា ។
ចេះផឹកចេះធីចំណីថ្ងៃ ចេះដើរចេះដេកស្រែកឡូឡា
ចេះសេពមេថុនដូចដូចគ្នា ផ្សេងតែ « ធម្មា » ជាប្រភេទ ។
គឺសត្វតិរច្ឆានឥតមានច្បាប់ ព្រោះអាប់ប្រាជ្ញាការសង្កេត
មិនចេះពិនិត្យគិតរះលល់ហេតុ ស៊ីឆ្អែតរួចដេកជាធម្មតា ។
មិនចេះរិះគិតផលិតថ្មី បង្កើតអ្វីអ្វីឲ្យថ្លៃថ្លា
មកពីឥត « ធម៌ » គឺ « ប្រាជ្ញា » រស់តាមកសនាលុះត្រាស្លាប់ ។
ប្លែកគ្នាប៉ុណ្ណោះ បើមនុស្សជាតិ ណាខានមារយាទពុំគួរគាប់
រស់នៅតាមចិត្តឥតទម្លាប់ មិនគោរពច្បាប់របស់មនុស្ស ។

អ្នកនោះមនុស្សដែរតែរូបប្រាណ ព្រោះមានសណ្ឋានជាស្រីប្រុស
តែចិត្តពិតជាពុំមែនមនុស្ស ព្រោះឃើញមិនខុសពីតិរច្ឆាន ៗ
ដូច្នេះមនុស្សជាតិត្រូវមានច្បាប់ ត្រូវមានទម្លាប់ ខានពុំបាន
កុំឲ្យមនុស្សក្លាយជាតិរច្ឆាន នេះជាដើមដាននៃទម្លាប់ ៗ
ស្នេហានៃមនុស្សខុសពីសត្វ នៅត្រង់ប្រតិបត្តិតាមក្រមច្បាប់
ចេះស្គាល់អៀនខ្មាសគាប់ពុំគាប់ រក្សាទម្លាប់គាប់ប្រសើរ ៗ
មិនព្រើលប្រសាចឥតខ្លាចក្រែង បំពេញចិត្តឯងស្វែងហោះហើរ
ទៅតាមចំណង់ខ្លួនដំណើរ ទើបលោកសរសើរជា «មនុស្ស» ពិតៗ

ហេតុនេះ យុវជនទាំងឡាយ ចូរឃើញឲ្យឆ្ងាយដោយគំនិត
កុំវល់យល់ដក់រក់តែជិត រឿងពិតអំពីង ល្មមដឹងបាន ៗ
កុំឆ្ងាញ់ចាញ់បោកលោកធម្មជាតិ យករឿងផ្សំធាតុជាប្រធាន
កុំយកចំណង់ចង់សន្តាន ឲ្យទុក្ខព្រួយប្រាណឥតអំពើ ៗ
មុននឹងផ្ដើមចិត្តផ្ដិតសង្សារ ត្រូវមានវិចារការសួរស្ទើ
ព្រមព្រៀងម៉ែឪសព្វអ្នកទើ រួចសិនសឹមធ្វើការបដ្ឋា ៗ
កុំអាងស្គាល់រឿងផ្ទាល់ខ្លួន ឃើញល្អសមសួនតែឯកា
ហើយហ៊ានប្រព្រឹត្តក្បត់មេបា ប្ដូហ៊ានសច្ចាឲ្យជាប់គុន ៗ
ព្រោះរឿងផ្ដើមផ្ដួចលួចស្នេហា តាំងចិត្តសន្យាទុកជាមុន
ឃើញច្រើនតែងរងទុក្ខករុណា កើតគុណវិបត្តិតែគ្រប់គ្នា ៗ

យ៉ាងហោចក៏ព្រួយដោយបារម្ភ ក្រែងពុំត្រូវចំដូចប្រាថ្នា
ឬក្រែងគូខ្វាងប្រែចិន្តា ឬក្រែងមេបាពុំប្រណី ៗ
បើខុសបំណងដួងពីគិត រឹងរៃឈឺចិត្តត្បិតមេត្រី
កើតជាវិបត្តិក្តាត់ស្តារ ហានធ្វើអ្វីអ្វីពុំគួរជា ៗ
ប្រសិនចិត្តស្អាតជាតិបរិសុទ្ធ គ្មានជាប់ពិរុទ្ធបទសង្ស័យ
កើតទុក្ខទាំងនេះមានពីណា ចិន្តាសុខស្រួលឥតក្តួលក្តៅ ៗ
ចំណែកខាងអ្នកអភិបាល គង់កាលជ្រើសគូឲ្យកូនទៅ
គួរមើលឲ្យល្អិតគិតឲ្យជ្រៅ កុំនៅឲ្យលង់ក្នុងវិបត្តិ ៗ
ពិសេសត្រូវស្ទាបស្ទង់គំនិត សួរចិត្តកូនសិនសឹមការកាត់
ទាល់តែកូនគិតចិត្តមូលម៉ត់ ទើបគ្មានវិបត្តិវិបាកក្រោយ ៗ
ទោះបីឃើញក្រ ល្អ ឬមាន និស្ស័យសន្តានមេត្តាក៏ដោយ
កូនពៅពេញចិត្តសឹមរៀបឲ្យ ប្រយ័ត្នស្តាយក្រោយព្រោយផ្ទុសការណ៍ ៗ
ត្រូវគិតចិត្តឯងក្រែងប្រមាណ កាលខ្លួនបង់បានគូសង្សារ
ទាល់តែគំនិតចិត្តទ្វេហារ ពេញចិត្តរៀបការទើបសុខសាន្ត ៗ
ប៉ុន្តែជាតិមនុស្សខ្វះស្រទន់ហ្នឹង គឺមិនព្រមចុងដឹងប្រមាណ
ធ្វើអ្វីបង់ឈ្នះភានៈប្រាណ តើក្តីសុខសាន្តមានយ៉ាងម៉េច ? ៗ
ពួកកូនជ្រើសគូប្តូរស្នេហា លួចលក់មេបាជាមុនស្រេច
ប្រសិនមេបាព្រមសម្រេច គេសេចក្តី «ស្រេចលើម៉ែ» ៗ

ប្រយ័ត្នតែប៉ះប្រាសពីហ្នឹង    សរសៃ គគីងប្រកែក "ទេ!"
ប្រកួតយកឈ្នះមានះកែ    ទាល់តែម៉ែឪក្តៅឆេះឆួល ។
រីឯមេបាក៏ជូរបោះ    មិនព្រមពិគ្រោះកូនឲ្យស្រួល
មានគេទាក់ទងក៏ទទួល    ផ្តេកផ្តួលយកជំមករិទ្ធិជ័យ ។
រៀបនេះឯងទើបវិនាសផ្លាយ    កូនខុតកម្មាយក្លាយទិសស្ស័យ
មានរឿងកាស្រូវនៅសព្វថ្ងៃ    នរជនឈ្មោះវៃប្តូរថ្លៃគិត ។

បញ្ហាស្នេហាដែលបកស្រាយ    បរិយាយក្លាយក្បោះអស់រឿងពិត
ឃើញថា សាំញាំចាំជីវិត    ព្រោះហេតុពីចិត្តឥតជម្ង ។
ច្បាប់លោកច្បាប់ធម៌មានសព្វគ្រប់    សម្រាប់កទប់ទោសស្នេហា
មានស្រេចឥតខ្វះចន្លោះណា    បើមិននាំគ្នាប្រតិបត្តិ ។
ច្បាប់ធម៌ប្រាប់ថា កុំប្រព្រឹត្ត    កាមេស្នេហ៍ស៊ូខ្ជូចជាសត្វ
គឺការប្រព្រឹត្តរួមប្រតិព័ទ្ធ    កុំភ្លាត់ឲ្យប៉ះសិទ្ធិគេ ។
មនុស្សដែលសិទ្ធិគេគ្រប់គ្រង    ផ្ទុំធម៌ចែកចងជាហូរហែ
គឺ ប្តី ប្រពន្ធ និងកូនគេ    នៅក្នុងកិច្ចថែអភិបាល ។
ផ្លូវលោកលក់ខ្ទៃលៃជាច្បាប់    ហាមប្រាប់ប្រព្រឹត្តចិត្តគ្រោល
មិនឲ្យអាងជនក្នុងអភិបាល    វិសាលដូចជាច្បាប់ធម៌ដែរ ។
ក្រៅពីប្រព្រឹត្តតាមក្រឹត្យច្បាប់    នៅមានទម្លាប់របស់ខ្មែរ
ជាកិច្ចការពារស្នេហាដែរ    ថែមទាំងកំណត់ឲ្យប្រពៃ ។

គឺកូនត្រូវនៅក្រោមមេបា | គ្រប់គ្រងរក្សាគ្រប់វិស័យ
តាំងពីកកើតចេញពីផ្ទៃ | រហូតពេញវ័យជាហូរហែ ។
រៀនផ្សំផ្គុំគប្បីប្រពន្ធ | នេះជាទម្ងន់កិច្ចឪម៉ែ
បើនៅមិនទាន់រៀបការទេ | កូនទៅត្រូវតែនៅគត់ព្រាំ ។
កុំលេងល្បែងថន់សន្យាល្បួង | សច្ចាកំណត់សន្មតចាំ
កុំអាលប្រព្រឹត្តអសទ្ធម្ម | រួមកម្មផ្សំធាតុមារយាទបើក ។
ចូរនៅចិន្តាអព្យាក្រិត | ជាចិត្តកណ្ដាលមិនស្រាលស្កើក
កុំរវើរតាមមេអណ្ដើក | កុំបើកបរិសុទ្ធមុនរៀបការ ។
រីឯម៉ែឪក៏ត្រូវស្ទាប | ស្ទង់មើលសភាពកូនសង្សារ
ទាល់តែចិត្តគេទាំងទ្វេភារ | ព្រមព្រៀងរៀបការសឹមចាត់ចែង ។
កុំប្រើកំហិតក្រិតបង្ខំ | កំហាល់ផ្សំផ្គុំទាំងកំហែង
ទើបកើតមង្គលដ៏ក្រៃលែង | នេះឯង ជាផ្លូវត្រូវដោះស្រាយ ។
**អទី** ខ្ញុំបាទ ជាតិខ្មែរ: | បញ្ចេញទស្សនៈន័យបរិយាយ
«បញ្ហាស្នេហា» ជាការស្រាយ | បញ្ចប់អធិប្បាយប៉ុណ្ណេះហាង ។

.................... ចប់ ....................

## អ្នកលង់ទឹក

អ្នកលង់ទឹក

កំពុងវារែក ជិតទីងជាប់ខ្យល់ បើមានកសិនា
ស្រក់ជះគល់ ក៏គោងទៅដល់ កំពង់ត្រើយហោង ។

ពុះបើគ្មានគល់

បែរទៅឆាកយល់ ខ្មោចមួយ ហីមពៅង គួរខ្ពើមគួរខ្លាច
កូនសាចស្អុយឆ្អាង តើគួរឲ្យឈោង តោងចាប់ឬទេ ? ។

បើមិនហ៊ានចាប់

ត្រូវតែលង់ស្លាប់ កណ្ដាលទន្លេ បើតោងអសោច
ខ្លាចខ្មោចកើម៉ែ តើគួរគិតកែ ជ្រើសទៅផ្លូវណា ? ។

បើស្ដាយជីវិត

ត្រូវតែកាត់ចិត្ត ប្រវេប្រវា ចាប់តោងខ្មោចនោះ
បណ្ដោះអាត្មា ដល់ត្រើយកាលណា សឹមដោះដៃចេញ ។

---

## លោកថា

លោកថា ប្រសិនមានដំបៅ ដំបៅកើតនៅទីដ៏ខ្លួនប្រាណ
ត្រូវលះទ្រព្យទិញថ្នាំចំណាន ព្យាបាលឲ្យបានជាប់សះជា ។
លោកថា ប្រសិនដំបៅនោះ មើលមិនជាសះអស់ចិន្ដា
ត្រូវវះកាត់ចេញទុកក ក្រែងចាំវេទនាដល់ស្លាប់ប្រាណ ។

លោកថា ធម្មតាការកាត់វះ ត្រូវដាយសាច់ខ្លះល្អពុំខាន
បើចៀសសាច់ល្អ វះម្តេចបាន នេះជាលំអានធម្មតាលោក ។

---

## អ្នកជិះនាវា

អ្នកជិះនាវា

ជួបព្យុះសង្ក្រាក កណ្តាលជលស័យ ទូកផ្ទុកមាសពេជ្រ
ហៀបលិចគួរភ័យ តើគួរឲ្យលៃ ដោះស្រាយយ៉ាងណា ។

បើទុកមាសពេជ្រ

ទូកត្រូវតែលិច កណ្តាលជលសា អ្នកជិះនឹងលង់
បាត់បង់ជីវា បើដាច់ចិន្តា ស្រក់ស្រទេញ ។

បើបោលមាសពេជ្រ

ទើបទូកលែងលិច ព្រោះស្រាលឡើងវិញ តែត្រូវខាតទ្រព្យ
តាប់ចិត្តនោះមិញ តើឲ្យចំណេញ ជ្រើសរើសផ្លូវណា ? ។

---

## ប្លន់ និង បោក

អ្នកត្រូវគេប្លន់គ្រាន់តែអស់ នូវទ្រព្យរបស់ធនធានពិត
ប៉ុន្តែខួរក្បាលផ្លូវគំនិត មិនទាន់វិបរិតបាញ់គេទេ ។
រីឯអ្នកដែលត្រូវគេបោក នោះទើបទាបថោកគ្មានអ្វីកែ
ទ្រព្យធនក៏រង់លេចទេ គំនិតក៏រេតាមគេញាក់ ។

គឺខាតចាំងទ្រព្យឆាប់ចាំងខ្លួ        ដេកស្លុកជួបស្នូរស្រេបគេដាក់
សូមខ្មែរគ្រប់ប្រាណមានការក្សាក់   ត្រូវខឹងទឹងអ្នកដែលបោកជាន់ ៗ

## មិនត្រូវជាមនុស្សចាញ់

មនុស្សកើតមួយជាតិជាតួមួយបាន   ដៃជើងខ្លួនប្រាណមានដូចគ្នា
មិនត្រូវខ្លាចគេដូចយក្សា        ទុកដាក់អាត្មាជាមនុស្សចាញ់ ៗ
អ្នកដែលចាញ់មុនធុនកំសាក       ព្រោះខ្លាចលំបាកចង់តែឆ្ងាញ់
សង្ឃឹមស្ងួនជាអាត្មាអញ        ឱនក្បាលចុះចាញ់ទើបបានសុខ ៗ
ខ្លាចខ្លា តោះក្រាបក្បែដល់ដី     ក៏ខ្លាក្រញីមិនរើសមុខ
បើចង់ឲ្យក្សាន្តបានក្តីសុខ      ចាល់តែកុំទុកឲ្យខ្លានៅ ៗ
តោះបើខ្លាច្រើនហើយហោរកាច     ក៏មិនគួរខ្លាចតាមចិត្តខ្លៅ
បើយើងបេះគិតគំនិតជ្រៅ        នោះខ្លាហោរយៅត្រូវតែស្លាប់ ៗ

## គតិពេចន៍

ពាសៈ កើតមក ពីសង្គ្រាម   គោត្រនាម កើតមក ពីប្រកាន់
ឧត្តម កើតមក ពីជះជាន់       ផ្គរលាន់ កើតមក ពីរន្ទះ ៗ
អ្នកពោល ច្រើនពោលតែពាក្យសម អ្នកធំ ច្រើនធំទាំងមាឌ
អ្នកគិត ច្រើនគិតតែផ្នួះ       អ្នកលះ ច្រើនលះតែទ្រព្យកាយ ៗ
ងាយណាស់ ប្រដៅឲ្យគេធ្វើ      ងាយណាស់ នុះកើឲ្យគន្ធកាយ
ងាយណាស់ តើមាត់ហានិយាយ ងាយណាស់ចាយឲ្យអស់ទ្រព្យ ៗ

អំណាច ពុំស្មើនឹងប្រាជ្ញា | អំណាច ពុំស្មើនឹងមានគំព្យ
ចំណេះ ពុំស្មើនឹងប្រសប់ | គោរព ពុំស្មើនឹងធ្វើតាម ។
ផ្គាប់ចិត្តទារក ដោយចំណី | ផ្គាប់ចិត្តស្រីស្រី ដោយផ្តល់កាម
ផ្គាប់ចិត្តអ្នកធំ ដោយលើកនាម | ផ្គាប់ចិត្តឧត្តម ដោយចំណេក ។
កំណាច ព្រួយព្រោះចង់បង្កើន | ចម្រើន ព្រួយព្រោះពិបាករក
អាក្រក់ ព្រួយព្រោះរាំទើសភ្នែក | ល្អពេក ព្រួយព្រោះខំការពារ ។
ចង់រស់ ព្រោះមានហេតុសប្បាយ | ចង់រស់ ព្រោះស្តាយសល់កិច្ចការ
ចង់រស់ ព្រោះចិត្តគិតគ្រួសារ | ចង់រស់ ព្រោះការកសាងខ្លួន ។

---

## កូនខ្មែរនិងវត្ត

គេថា កូនខ្មែរដែលក្រខ្សត់ | ច្រើនរស់ក្នុងវត្តពុទ្ធសាសនា
ខ្លះបួសហើយរៀនសិល្បវិជ្ជា | ខ្លះនៅសិក្សាជាយុវជន ។
ក្នុងវត្តមួយៗរាប់ពាន់នាក់ | ជឿគ្នានៅស្នាក់ច្រើនលើសលន់
បង្កើតទៅជាបញ្ហាធ្ងន់ | គាំងពីចង្ហាន់ - កុដិ - សាលា ។
ព្រះសង្ឃអង្គុយទៅអាភាស | តែងយល់ខ្វល់ណាស់នឹងបញ្ហា
ប្រឹងនាំឧបាសក - ឧបាសិកា | ឲ្យព្រមព្រៀងគ្នាជួយកសាង ។
ធ្វើកុដិ សាលា ធ្វើចង្ក្រាន | កើតគរុកណ្ឌផុះប្រជ្រាង
ទោះបីមិនគ្រប់មានសព្វយ៉ាង | ក៏ជាសំណង់គ្រាន់ជាងអត់ ។
បើធៀបស្ថិតិនៃយុវជន | ពីគ្រប់តំបន់ សុំនៅវត្ត
នៅសល់ច្រើនណាស់ដែលគ្មានអត់ | ព្រោះវត្តតិចពេកក្នុងជាទី ។

រឿងនេះប្ដូរជាតិហាប់គារម្មណ៍ គួរជួយឧបត្ថម្ភកេរ្ដិ៍
ករត្តឲ្យប្រេចក្នុងជាទី គ្រប់ទីតំបន់សង្កាត់ខណ្ឌ ៗ
ទើបពិតជាមានមធ្យោបាយ ជួយស្រាយបញ្ហាខ្សែយុវជន
កុំឲ្យអ្នកក្របេះតែទន់ អ្នកមានទ្រព្យធនបេះតែខ្ពស់ ៗ
ត្រូវយល់តម្លៃវត្តខ្មែរ ជាកេរ្ដិ៍សង្គមផ្ដុំគ្នារស់
ប្រសិនជាលុបបោលវត្តអស់ កូនខ្មែរញាប់រស់រងគ្រោះធំ ៗ
ព្រោះគ្មានទីនៅស្នាក់សិក្សា តើរូបអ្នកណាជួយឧបត្ថម្ភ
មានតែទៅផ្ទះពួនបម្ង ដេករុំអាវជ្រាក់ព្រាប្រាណ ៗ
បើមានវត្តច្រើនកើនចំណោះ កេងខ្មែរបង់បេះតាំងប៉ុន្មាន
គ្មានមធ្យោបាយស្រាយទីបាំង ចូលវត្តផ្ញើប្រាណបាននៅស្នាក់ ៗ
ឥតអស់តាំងឈ្នួលស្រួលតាំងគ្រប់ អាស្រ័យថ្ងៃយប់ឥតឧបសគ្គ
រៀនចេះ ចយចេញឈប់ពឹងពាក់ ទុកឲ្យគេស្នាក់នៅបន្ត ៗ

មធ្យោបាយនេះពេញជាត្រូវ គុណម៉ែកេរ្ដិ៍ឪពិតជាល្អ
អាចជួយសង្គ្រោះខ្មែរអ្នកក្រ បានច្រើនកំណាមកយូរហើយ ៗ
ថែមតាំងទាំងរដ្ឋឥតបង់ខាត គ្មានចាយប្រាក់ជាតិបន្តិចឡើយ
ផ្លូវស្រាយងាយពិតជិតបង្កើយ ប៉ុន្តែម៉ែអើយ! កូនឲ្យឈឺង ៗ

# ភ្លើងក្រៅនិងភ្លើងក្នុង

ភ្លើងក្រៅ ពុំអាចនឹងផុតកំ ឲ្យឆេះរលំបូររលាយ
ឯភ្លើងក្នុងវិញ ចេញពីកាយ កុំភ្លើងរលាយជាទឹកថ្លា ៗ
ភ្លើងក្រៅឆេះរាលរាលចំមក ត្រូវយកភ្លើងផុតរាលតប·ត
បំណែកភ្លើងក្នុងឆេះបង្ក ត្រូវយកធម៌ល្អមកទប់ទាន ៗ
ភ្លើងក្រៅទោះបីក្តៅពន្លឹក ប៉ុន្តែមានទឹករំលត់បាន
រីឯភ្លើងក្នុងនាំអង្គប្រាណ ពុំអាចរលត់បាននឹងទឹកឡើយ ៗ

✕ ✕
✕

# រាជពង្សាវតារ

## តាមសាស្ត្រាស្លឹករឹតបានពីវត្តកោកកាក

លោក ឃួន-សែម ចម្លង

លោក លី-ធាម តេង ពិនិត្យផ្ទៀង

( ក )

សុះតោ កាលនោះមានព្រះមហាក្សត្រមួយព្រះអង្គ គង់ព្រះនគរឡូនធាង ទ្រង់ព្រះនាមព្រះអនុរុទ្ធរាជ ស្តេចមានមហិទ្ធិរិទ្ធិតេជៈ អានុភាពតែងគោរពប្រណិប័តន៍ទំនុកបំរុងព្រះពុទ្ធសាសនា ស្តេចហោះដោយអាកាសវេហាស៍បាន ហើយត្រាស់ដោយសំពៅ ២ បើកចេញទៅស្រុកលង្កាទ្វីប ស្តេចគង់ព្រះទីនាំងអស្សតរកាន់ខែហោះដោយអាកាសទៅដល់លង្កាទ្វីបសូមចម្លងបិដកកម្មបាន ហើយសូមព្រះកែវមរកតពីស្តេចលង្កាទ្វីប ក៏ព្រមឲ្យតម្កល់ដាក់ក្នុងសំពៅ ២ ស្រេចហើយបើកសំពៅនោះវិលមកវិញ ឯព្រះបាទអនុរុទ្ធរាជឡើងគង់លើព្រះទីនាំងអស្សតរកែវហោះមកដល់ព្រះនគរមុន ទើបសំពៅដែលតម្កល់ព្រះបិដកកម្ម ពួកអ្នកលង្កាទ្វីបជួយតារសោរសោរនោះបានចូលទៅដល់ព្រះនគរឡូនធាង ឯសំពៅមួយដែលតម្កល់ព្រះកែវមរកត និងបិដកកម្ម ពួកអ្នកឡូនធាងតារសោរសោរខ្យល់ផាត់រសាត់ចូលមកដល់ឥន្ទបត្តមហានគរ ទើបព្រះបទុមសុរិយោវង្សបានទទួលយកធ្វើសក្ការបូជា

ឲ្យបាបេម្ទនទីនស្ទឹកមាសស្ទឹកប្រាក់ស្រេច   កាលគ្រានោះមហាសករាជ ៥៦១ ឆ្នាំកុរឯកស័ក ទើបព្រះគោបាញ្ញតាំងឡើងជាចុល្លសករាជ ១ រៀនមក នោះព្រះបទុមសុរិយវង្សទ្រង់បង្វែរប្រាសាទតូចថ្វាយជាវត្ត និមន្តព្រះកែវមរកតនិងព្រះបិដកកម្ម ឡើងប្រតិស្ឋានតម្កល់ជាក់ក្នុងប្រាសាទនោះ ហៅជាប្រាសាទនគរវត្ត ឯព្រះអនុរុទ្ធរាជ ដែលគង់ក្នុងព្រះនគរឡានឆាងឃើញតែសំពៅមួយទៅដល់ បាត់សំពៅមួយក៏ព្រួយព្រះរាជហឫទ័យណាស់លុះយូរទៅក៏ដឹងថា សំពៅដែលតម្កល់ព្រះកែវមរកតនិងព្រះបិដកកម្មនោះគាត់បោះចូលទៅដល់ឥន្ទបត្តមហានគរ ហើយស្តេចឡើងគង់ទីនាំងអស្សតែកែវមកឥន្ទបត្តមហានគរ ចុះសំណាក់ប្រាស្រ័យនៅលើផែនថ្ម ហើយទ្រង់បស្សាវៈហូរទឹកមូត្រទៅបែកថ្ម មានភិក្ខុមួយអង្គទៅជួបឃើញទឹកមូត្រហូរបែកថ្មជាអស្ចារ្យ ក៏សួរថាឧបាសកមកពីឯណា នាមករតើឈ្មោះអ្វី បាទជាមកនៅទីនេះ ឯព្រះបាទអនុរុទ្ធរាជបង់សេចក្តីសត្យពុំប្រាប់ដោយត្រង់ ស្រដីបន្លំថា ជាបំរើព្រះអនុរុទ្ធរាជ ឲ្យមកតាមយកសំពៅព្រះកែវមរកត និងបិដកកម្មដែលគាត់ចូលមក ក្នុងឥន្ទបត្តមហានគរនាំយកទៅព្រះនគរឡានឆាង ឯភិក្ខុនោះបានឮហើយវិលទៅទូលព្រះមហាសង្ឃរាជ ឯព្រះមហាសង្ឃរាជនាំសេចក្តីទៅថ្វាយព្រះពរ ដល់ព្រះបទុមសុរិយវង្សទ្រង់ជ្រាប ហើយថាព្រះកែវមរកតនិងព្រះកែវបិដកកម្ម សំពៅចូលមកដល់ស្រុកយើងនេះជាបុណ្យរបស់យើង យើងមិនឲ្យទេ សេចក្តីនេះខ្ចរខ្ចាយឮទៅដល់ព្រះ

បាទអនុរុទ្ធរាជ  ក៏ទ្រង់ព្រះក្រោធគិតថានឹងច្បាំងយកសំពៅនិងព្រះកែវមរកតព្រះបិដកកម្ពុបាទប៉ុន្តែជាតិនេះកើតមកជាធម្មិករាជហើយ តាំងដោយសត្យានុធម៌គួរតែសំដែងឫទ្ធិឲ្យឃើញ  ជាក់នឹងភ្នែកទើបបានជាឆាយលុះទ្រង់ព្រះតម្រិះស្រេច ស្ដេចយកឈើធ្វើជាដាវហើយលាយទឹកនិងផង់ធូលីថ្នាលបមុខដាវឈើ ហើយឡើងគង់លើអស្សតរកែវ ហោះប្រទក្សិណលើកំពែងកែវពញ ដ៏ពុំឲ្យអស់មនុស្សផងឃើញ ហើយស្ដេចបំបាំងកាយហោះទៅក្នុងមហាប្រាសាទនៃនគរជម្ពូ យកដាវឈើចិតព្រះសិរព្រះមហាក្សត្រ និងព្រះអគ្គមហេសីខ្ញូមុខមន្ត្រីទាំងពួង ស្រេចហើយហោះទៅលើអាកាសស្រុកហោសនានោះដោយព្រះសូរសៀងសីហនាទថានែ អ្នកទាំងឡាយបើមិនឲ្យសំពៅព្រះបិដកកម្ពុ នូវព្រះកែវមរកតទៅដល់យើងជាមហាក្សត្រទេ យើងនឹងកាត់សិរសាលោព្រឹកស្អែកទាំងអស់ បើពុំជឿចូរមើលក្បាលគ្នាចុះ ឯព្រះបរមសុរិយាវង្ស និងព្រះអគ្គមហេសីមុខមន្ត្រីទាំងពួងភ្ញាក់ហើយយកដៃស្ទាបក្បាលខ្លួន មើលឃើញផង់ធូលីថ្នាំទឹក ពល់គ្នាក៏កើតភ័យខ្លាចសេចក្ដីស្លាប់ទើបស្ដេចត្រាស់ប្រើអង្គមាត្យពីរនាក់ឲ្យទៅទូលថា ឯសំពៅព្រះបិដកកម្ពុជព្រះកែវមរកត ក្រោកដេជាបេសស្ដេចមែនហើយ  អញ្ជើញស្ដេចវិលទៅព្រះនគរវិញនានសិញចុះ  សឹមយាតបំរើឲ្យជូនសំពៅព្រះបិដកកម្ពុជទៅជាក្រោយ ដោយខ្លួនស្ទួមជាព្រះរាជមាត្រ  ឯព្រះបាទអនុរុទ្ធរាជបាន...

ហើយស្តេចហោះវិលទៅនន្ទពននគរឡានឆាងវិញ ទើបព្រះបទុមសុរិយវង្ស ត្រាស់ប្រើកងទូត ជូនតែសំពៅនិងព្រះបដកកម្មដែលពួកអ្នកនគរឡានឆាង ចារសរសេរនោះ ទៅដល់ព្រះបាទអនុរុទ្ធរាជឯព្រះកែវមរកត ស្តេចសូម ទុកប្រណិប័តន៍រក្សា នៅមហានគរវត្តព្រះមហានគរក៏ចំរើនរុងរឿងសុខ ក្សេមក្សាន្ត ស្តេចមានព្រះរាជបុត្រានោះ ៤ ព្រះអង្គ ព្រះនាមព្រះបាទ ធនញ្ជ័យ នោះពោកជ ១ ព្រះនាមព្រះបាទ ស្រីជេដ្ឋា ១ ព្រះបាទជេដ្ឋជ័យ ១ ព្រះបាទសន្ធុចក្រ ១ ស្តេចសោយរាជសមសុខ ជាអង្វែងទៅ ទ្រង់ព្រះ មរណភាពក៏សោយទិវង្គតទៅ ឯព្រះរាជបុត្រាទាំង ៤ ព្រះអង្គ បានសោយ រាជសម្បត្តិស្នងព្រះវររាជបិតា គ ៗ មកដល់រាជសម្បត្តិព្រះបាទសន្ធុចក្រ ជាសម្តេចព្រះរាជបុត្រាពៅបង្អស់ ស្តេចមានព្រះរាជបុត្រា១ព្រះអង្គព្រះនាម ព្រះបាទបក្រតត្រាធិរាជឯព្រះបាទសន្ធុចក្រស្តេចបេញគង់ឲ្យមុខមន្ត្រីគាល់ ទ្រង់ទតព្រះនេត្រទៅឃើញ មន្ត្រីមកឡើងគាល់ពុំសូវមកក្រាបក៏ទ្រង់ព្រះ ក្រោធ ទ្រង់ព្រះខ័ន កាត់កនាគព្រួសពិស បង្កើតឡើងជាយង់ភ្លើងទើប សន្មតហៅថាស្តេចគំលង់ លុះដល់ឥឡូវនេះ ។

(នៅមានត)

៥

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ


ឆ្នាំទី ៤៤ ខែឧសភា

ព.ស. ២៥១៦ គ.ស. ១៩៧២

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : អ៊ុក-សាម៉ន

និពន្ធនាយក-អ្នករៀបចំ លី ធាម តេង

គណៈកម្មការនិពន្ធៈ

ព្រះពោធិវង្ស ស្វរ-ហាយ

លោក ផល-និក អ្នកស្រី ពេជ-សល់

# បញ្ជីរឿង

**អត្ថបទ** | **ទំព័រ**


## ១— ផ្នែកសាសនា :

១ - ចតុរារិយសច្ច (ត) រៀបរៀងដោយ ព្រះភិក្ខុ ប៉ាង-ខាត់ . . . . ២៥៥

២- បុណ្យនៅលើគោកងាយធ្វើសោះ លោក ភិន-ឌីន រៀបរៀង, . . . ២៦១

## ២— ផ្នែកអក្សរសាស្ត្រ :

៣- រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . . ២៦៥

៤- វាណិជ្ជាវិចារ សាស្ត្រាវត្តគោកកាក (ត) លោក ឃួន-សែប ចម្លង
ចេញពីសៀវភៅរឹត . . . . . ២៨១


---

## តម្លៃខាង :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០៛០០ ។

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

# ចតុរារិយសច្ច

(តមកពីលេខមុន)

ភិក្ខុ ឆាំង-ខាត់ រៀបរៀង

លោកពោលថា អាហារមាន ៤ ប្រការ (១) ។ អាហារនេះ លោកទុកជាបុព្វហេតុមួយដែលឲ្យមានភពថ្មី ហើយឲ្យកើតជាសត្វឡើង គឺ

១- កវលិង្ការាហារ បានដល់អាហារគ្រោតគ្រាត ឬ ល្អិត,

២- ផស្សាហារ អាហារគឺវេទនា ៣ ប្រការ ដែលកើតពីការប៉ះពាល់ឥន្ទ្រិយទាំង ៦ ប្រការ,

៣ មនោសញ្ចេតនាហារ បានដល់ចេតនាកម្ម ៣ ប្រការ ដែលនាំឲ្យមានបដិសន្ធិក្នុងត្រៃភព,

៤- វិញ្ញាណាហារ បានដល់ចិត្តណាមួយ ដែលនាំទៅក្នុងខណៈបដិសន្ធិចិត្តក្នុងត្រៃភព (២) ។

---

១ មជ្ឈិមនិកាយ មូលបណ្ណាសក សម្មាទិដ្ឋិសូត្រ សៀវភៅទី ២០ ទំព័រ ១៥៣ ។

២ កវលិង្ការាហារ = La nourriture matérielle ordinaire. ផស្សាហារ = Le contact des organes des sens (y compris l' organe mentale). មនោសញ្ចេតនាហារ = la volition mentale ou volonté. វិញ្ញាណាហារ = La conscience ។

បណ្ដាអាហារទាំង ៤ ប្រការនេះ មនោសញ្ចេតនាហារនេះ ជាធម៌ប្រមូលយកចេតនាចង់រស់នៅ ចង់កើត ចង់កើតថ្មីទៀត ចង់បន្តកើតទៅទៀត ចង់ត្រឡប់មកកើតជាថ្មីទៀត (១) ។ ចេតនានេះឯង ជាឫសគល់នៃការកើត និងជាធម៌បន្តឲ្យមានការកើតតទៅទៀតមិនឈប់, ឯការកើតនេះ ត្រូវប្រព្រឹត្តទៅតាមច្បាប់ធម្មជាតិ គឺ កម្មល្អ ឬ អាក្រក់ (កុសលាកុសលកម្ម) ។

ចេតនានេះ ជាតួ "កម្ម" សមដូចពុទ្ធភាសិតថា "កាលបើបុគ្គលយល់ច្បាស់នូវមនោសញ្ចេតនាហារហើយ ក៏អាចយល់ដល់តណ្ហា ៣ ប្រការ(២) បានដោយប្រពៃ" ។ ដូច្នេះ ពាក្យថា "តណ្ហា, ចេតនា, មនោសញ្ចេតនាហារ" និង "កម្ម" នេះ ជាពាក្យមានអត្ថន័យតែមួយដូចគ្នា, បានសេចក្ដីថា សេចក្ដីប្រាថ្នា ចេតនា ចង់នៅជាមនុស្ស ចង់កើត ចង់កើតទៀត ចង់វិលមកកើតទៀត ចង់ចម្រុងចម្រើនឲ្យរឹងរឹតតែច្រើនតទៅទៀត ចង់សន្សំឲ្យកើតមានឡើងឥតឈប់ឈរ ។

នេះហើយ ជាបុព្វហេតុដែលនាំឲ្យកើតទុក្ខ ( ទុក្ខសមុទយៈ ) ។ ធម៌នេះហើយ ដែលយើងបានឃើញនៅក្នុងសង្ខារក្ខន្ធ ជាខន្ធមួយនៅក្នុងខន្ធបញ្ចកៈ ដែលនាំឲ្យកើតបានហៅថា "មនុស្ស" ឬ "សត្វ" ឡើង ។ ធម៌នេះ ជាធម៌សំខាន់ក្រៃលែង ជាចំណុចសារវន្តនៅក្នុង

---

១ មនោសញ្ចេតនាហារ បើនឹងប្រៀបធៀបដូចសញ្ញាណ (Libido) ក្នុង psycho logie moderne. ២- សំយុត្តនិកាយ: = កាមតណ្ហា, ភវតណ្ហា, វិភវតណ្ហា ។

ពុទ្ធសាសនា ។ យើង គប្បីគត់ចំណាំទុកឲ្យច្បាស់លាស់ដោយប្រពៃ បន្តិចឲ្យម៉ត់ចត់ថា បុព្វហេតុនេះហើយ មេនេះហើយ នាំឲ្យកើតទុក្ខទៅក្នុងទុក្ខ មិនមែននៅឯណាក្រៅពីបុព្វហេតុនេះឡើយ, ហើយគួរគត់ចំណាំទុកតទៅទៀតថា បុព្វហេតុ ឬមេនៃការរំលត់ទុក្ខ ក៏នៅក្នុងការរំលត់ទុក្ខនោះឯង មិនមែននៅឯណាក្រៅពីបុព្វហេតុនេះឡើយ សមដូចពុទ្ធភាសិតថា (១) យំ កិញ្ចិ សមុទយធម្មំ សព្វំ តំ និរោធធម្មំ "អ្វីមួយជាធម៌នាំឲ្យកើតអ្វីទាំងអស់នោះ ជាធម៌នាំឲ្យរលត់ទៅវិញ" ។

អ្វីនីមួយ ជាសត្វ ជាវត្ថុ ឬជាវិធី បើនៅក្នុងខ្លួនឯង មានធម៌ជាហេតុនាំឲ្យកើតឡើង ជាធម៌នាំឲ្យមកកើតជាមនុស្សវិញ ក៏តែងមានធម៌ ឬមានមេការរលត់ ឬក៏ការអន្តរាយ នៅក្នុងខ្លួនឯងវិញដែរ, ដូចជាខន្ធបញ្ចកៈ ជាធម៌ដែលមានបុព្វហេតុនាំឲ្យកើតក្នុងខ្លួនឯង ក៏ត្រូវមានធម៌ជាបុព្វហេតុនាំឲ្យរលត់ទៅវិញ ក្នុងខ្លួនឯងដែរ ។ ធម៌នេះ មានបរិយាយនៅក្នុងអរិយសច្ចទីបី ដែលហៅថា "និរោធសច្ច" ទៀត ។

មួយទៀត "កម្ម" ជាបាលី "កម៌" ជាសំស្ក្រឹត មកពីរូបធាតុតែមួយថា "ករ" ប្រែថា "ធ្វើ, ការធ្វើ" ។ ប៉ុន្តែ ក្នុងទ្រឹស្តីពុទ្ធសាសនា ពាក្យថា "កម្ម" ឬ "កម៌" មានអត្ថន័យពិសេស គឺមានអត្ថន័យថា "អំពើប្រកបដោយចេតនា" មិនមែនមានន័យត្រឹមតែ "អំពើ" ត្រង់ៗប៉ុណ្ណោះ

១- វិន័យ មហាវគ្គ បឋមភាគ សៀវភៅទី ៦ ទំព័រ ៣៥, Traduction tout ce qui a la nature de l'apparition, tout cela a la nature de la cessation whatever is of the nature of arising, all that is of the nature of cessation.

ទេ ។ ពាក្យថា «អំពើ»ត្រង់តាមធម្មតា មិនមែនមានន័យថា «ល្អ» ឬ «អា-ក្រក់» ទេ ឬមានន័យថា ជា «លទ្ធផល» (Résultat) នៃកម្ម ដូចអ្នកទាំងផ្ដាសពោលនោះ ក៏ឥតអគ្គិមានដែរ ។ បើតាមបរិភាសា (Terminologie) ពាក្យថា «កម្ម» ឬ «កម៌» នេះ ក្នុងព្រះសាសនា មិនមែនមានន័យថា ជា «ផល» (Effet) របស់ខ្លួនទេ, ឯផលរបស់កម្មនោះទើបលោកហៅថា «ផល» Fruit ឬ Résultat របស់កម្ម គឺ «កម្មផល» ឬ «កម្មវិបាក» ។

ចំណែកពាក្យថា «ចេតនា» ទើបអាចហៅជា «ល្អ» ឬ «អាក្រក់» បាន ដូចជា «តណ្ហា» នេះហៅជា «ល្អ» ឬ «អាក្រក់» បាន ។ ឯ «កម្ម» ឬ «កម៌» ដែលហៅជា «ល្អ» ឬ «អាក្រក់» ក៏ដោយអាស្រ័យចេតនានេះឯង, បើថា គ្រាន់តែជា «កម្ម» ឬ «កម៌» ត្រង់ៗនោះ មិនហៅជា «ល្អ» ឬ «អាក្រក់» បានទេ ។ ដូច្នេះ «កម្ម» ឬ «កម៌» ប្រកបដោយចេតនា ទើបហៅថា «ល្អ» ឬ «អាក្រក់» បាន ដូច កុសលកម្ម ផលិតផលល្អ, អកុសលកម្ម ផលិតផលអាក្រក់ ។ ធម៌គឺ តណ្ហា ចេតនា កម្ម ទាំង ៣ នេះមានកម្លាំងឲ្យហៅជា «ល្អ» ឬ «អាក្រក់» ព្រោះធម៌ទាំងនេះមានពលៈ ឬ ថាមពលនៅក្នុងខ្លួនឯង, «ពលៈ» ឬ «ថាមពល» នេះរុញច្រានឲ្យហៅជា «ល្អ» ឬ «អាក្រក់» តាមភាពរបស់ខ្លួន ។ ល្អ ឬអាក្រក់, កុសល អកុសល ជាសាបេក្ខៈ (Relatif) ហើយបិតនៅក្នុងវដ្ដកំណត់សង្សារ (ការអន្ទោលទៅមក) ។ ព្រះអរហន្ត លោកធ្វើអំពើដែរ

តែអំពើរបស់លោកមិនកើតទៅជា «កម្ម» ឬ «កម៌» ទេ គឺគ្រាន់តែជា «កិរិយា» ព្រោះចិត្តលោករួចស្រឡះហើយពីទ្រឹស្តីឬអន្ទាក់ ពោលគឺការយល់ឃើញខុស រួចស្រឡះហើយពីតណ្ហា ដែលបន្តកំណើត ឬវិលមកកាន់កំណើតវិញ ព្រមទាំងរួចស្រឡះពីធម៌ជាគ្រឿងសៅហ្មង ពោលគឺ កិលេស អាសវៈ គ្រឿងត្រាំ ទាំងអស់ហើយ ៗ ដូច្នេះ ព្រះអរហន្តមិនមានពូជកំណើតទៀតទេ (ខីណា ពីជា) ។

ទ្រឹស្តី «កម្ម» ឬ «កម៌» នេះ មិនគួរយើងកន្តច្រឡំថាដូចជាច្បាប់ដែលគេហៅថា «ច្បាប់យុត្តិធម៌ កាត់ទោសតាមចរិយា» និងសញ្ញាណថា «ប្រទានរង្វាន់» ឬ «ពិន័យទោស» នោះទេ ។ គំនិតដែលឃើញថា «ច្បាប់យុត្តិធម៌ កាត់ទោសតាមចរិយា, ច្បាប់ប្រទានរង្វាន់, ច្បាប់ពិន័យទោស" នេះ ជាគំនិតដែលកើតចេញពីទស្សនាទាននៃអាទិទេព នៃព្រះយមរាជ ដែលជាអ្នកតែងច្បាប់ សម្រេចថា «នេះល្អ, នេះអាក្រក់» ។ ពាក្យថា «ច្បាប់យុត្តិធម៌» (Justice) ក្នុងនាមខ្លួនឯង មានន័យមិនច្បាស់លាស់ទេ ហើយប្រកបដោយគ្រោះថ្នាក់ច្រើន ព្រមទាំងប្រគល់អំពើអាក្រក់ច្រើនជាងអំពើល្អ ដល់មនុស្សជាតិទៀតផង ។

ឯ «កម្ម» ឬ «កម៌» ដែលប្រើក្នុងពុទ្ធសាសនា ជាទ្រឹស្តី «ហេតុនិងផល» (Causes et effets) «កម្មនិងប្រតិកម្ម» (Action et réaction) ជាទ្រឹស្តីស្តីពីច្បាប់ធម្មជាតិ (Loi naturelle) សុទ្ធសាធ ឥតមានសេចក្តីជប

ច្បាប់តុលាការ ដែលមានសេចក្ដីជាច្បាប់ពិន័យទោសនោះទេ ។ ច្បាប់ "កម្ម" ឬ "កម៌" បើប្រកបដោយចេតនា សុទ្ធតែផលិតឬធ្វើឲ្យមាន "ហេតុនិងផល" ឬ "លទ្ធផល" ជាដរាបគឺកម្មជាកុសល ឲ្យផលល្អ, កម្មជាអកុសល ឲ្យផលអាក្រក់, មិនមែនដូចច្បាប់តុលាការ ឬ ច្បាប់ប្រធានធ្នាប់ ឬគឺច្បាប់ពិន័យទោសនោះឡើយ, កម្មឬកម៌ ផលិតចេញពីធម្មជាតិរបស់ខ្លួនសុទ្ធសាធ ពោលគឺពីច្បាប់កម្មសុទ្ធសាធ ។ ទ្រឹស្ដីកម្មឬកម៌នេះ មិនមានអ្វីទីងនាំឲ្យលំបាកចូលចិត្តពេកទេ ការដែលនាំឲ្យលំបាកយល់ក្នុងគំនិតនោះ គឺផលរបស់កម្ម ដែលប្រកបដោយចេតនានោះ អាចបន្តឲ្យផលរហូតទៅដល់អនាគតជាតិតទៅទៀត ។

សេចក្ដីត្រង់នេះ ត្រូវតែមានសេចក្ដីពន្យល់ដោយឡែកថា សេចក្ដីស្លាប់តាមទ្រឹស្ដីពុទ្ធសាសនានោះ តើដូចម្ដេច ?

អ្នកសិក្សាបានដឹងហើយថា "បុគ្គល, សត្វ" មិនមានទេ មានតែការផ្សំគ្នានៃពល: ឬថាមពល ដែលជារបស់កាយនិងចិត្ត ។ ការដែលយើងនិយាយថា "ស្លាប់" បានសេចក្ដីថា "ការមិនកម្រើក មិនដើរទាំងអស់នៃគ្រឿងចក្រគឺសរីរាង្គកាយ (organismcphyoiguc)" ។ ចុះ "ពល:" ឬ "ថាមពល" នេះ ផុតលេត់ឈឹងទាំងអស់តទៅ ព្រមមួយអន្លើដោយការឈប់ងឹកនៃការកម្រើក ឬការដើរនៃគ្រឿងចក្រគឺសរីរាង្គកាយដូច្នេះឬ ?

ទេ ! ទេ ! ពុទ្ធសាសនាមិនឆ្លើយដូច្នោះទេ ។ ពុទ្ធសាសនានិយាយថា មានធម៌ផ្សេងទៀត គឺ ឆន្ទ: ចេតនា តណ្ហា តណ្ហាចង់កើត ចង់បន្តកើត ចង់វិលបកកើតតទៅទៀត, ធម៌ទាំងនេះជាកម្លាំងខ្លាំងសម្បើម

អស្ចារ្យ ធ្វើឲ្យមានចលនា ធ្វើឲ្យជីវិតទាំងពួង.កតទាំងពួង ធ្វើឲ្យលោកទាំងមូលបេះតែប្រព្រឹត្តទៅមិនមានទីបំផុត ។ ពលៈ នេះ ធំណាស់, ជាមពលខ្លាំងណាស់ នៅក្នុងលោកយើងនេះ ។ តាមទ្រឹស្តីពុទ្ធសាសនា កម្លាំងទាំងអស់នេះ មិនមែនឈប់ដើរ ព្រមជាមួយនឹងការមិនដើរនៃគ្រឿងបក្រសពាង្គកាយ ពោល គឺ សេចក្តីស្លាប់ទេ, កម្លាំងទាំងអស់ បេះតែដើរតទៅជានិច្ច បន្តការដើររបស់ខ្លួនទៅក្នុងរូបដទៃទៀត បង្កើតជាភពថ្មី ៗ ដែលយើងហៅថា «ជាតិ» (កំណើត) ។

ឆ្លើយរួចប្រស្នាមួយហើយ មានប្រស្នាមួយទៀតកើតឡើងទៀតគឺប្រស្នាថា បើមិនមានអ្វីទៀងទាត់ មិនមានអត្តភាព (Entité) ដែលមិនប្រែប្រួល មិនមានសារជាតិ (substance) ដូចជាខ្លួនឯងឬព្រលឹងទេ, ចុះអ្វីទៅដែលអាចទៅកើតទៀត ឬឲ្យមានកំណើតទៀត ក្រោយពីការបែកធ្លាយសពាង្គកាយទៅ? មុនយើងនិយាយពីជីវិត(ការរស់នៅ) បន្ទាប់ពីមរណ-កាលទៅ យើងសន្មតទុកថា មានជីវិតរស់នៅសិនទៅចុះ, ចុះជីវិត(ការរស់នៅ) វាបន្តការរស់នៅរបស់វាបានដូចម្តេច ? អ្វីដែលយើងហៅថា "ជីវិត (ការរស់នៅ= vie, life)" ? ជីវិត(ការរស់នៅ)នេះ ដូចជាយើងនិយាយដដែល ៗ ថែបប្រែដែល ៗ មិនមែនអ្វីដទៃទេ គឺការផ្សំខន្ធបញ្ចកៈនេះឯង, ការផ្សំពលៈឬថាមពលនៃកាយនិងចិត្តនេះឯង ។ ធម្មជាតិដែលផ្សំគ្នានេះ ជាធម្មជាតិប្រែប្រួលជានិច្ចតទៅ មិនមែននៅថ

ដែល ។ទេ, សូម្បីតែក្នុងខណៈចិត្តពីរ ដែលតៗគ្នាក៏ដោយ គ្រប់តែខណៈចិត្ត សុទ្ធតែកើតឡើង តាំងទៅ ហើយរលត់ទៅវិញ ជាធម្មតា ។ កាលបើខន្ធបញ្ចកៈកំពុងកើតឡើង, សត្វ ឈ្មោះថាកំពុងទ្រុឌទ្រោមទៅផង ឈ្មោះថាកំពុងស្លាប់ទៅផង ដូចពុទ្ធភាសិតថា "ម្នាលភិក្ខុ គ្រប់ខណៈចិត្ត អ្នក ឈ្មោះថាកំពុងកើតឡើងផង ឈ្មោះថាកំពុងទ្រុឌទ្រោមទៅផង ឈ្មោះថាកំពុងស្លាប់ទៅផង (១) ។ ក្នុងចិរវេលា ដែលយើងមានជីវិតរស់នៅ យើងកើតផង យើងរស់ផង យើងស្លាប់ផង គ្រប់តែខណៈចិត្ត ប៉ុន្តែ យើងចេះតែបន្តការរស់ទៅបាន ក៏ព្រោះគ្រឿងចក្រ គឺសព៌ាង្គកាយឋិតនៅល្អ, បើគ្រឿងចក្រគឺ សព៌ាង្គកាយបែកធ្លាយហើយ ធម៌ទាំងឡាយគឺ ឆន្ទៈ ចេតនា តណ្ហា ។ល។ ជាពលៈឬថាមពលទនុញប្រាណទៅឲ្យយើងកើតទៀត ។ សេចក្ដីនេះ យើងចេះយល់ថា ជីវិត(ការរស់នៅ) របស់យើងនេះ ចេះតែបន្តគ្នាទៅបានដោយមិនមានធម្មជាតិអ្វីមួយទៀតទាក់ មិនចេះប្រែប្រួល ដូចជា "ខ្លួនឯង" ឬ "អាត្មា-ព្រលឹង" នេះ ម្ដេចក៏យើងមិនចេះយល់ថា ពលៈឬថាមពលដែលជារបស់កាយនិងចិត្តនោះ វាអាចបន្តការប្រព្រឹត្តទៅបានរបស់វា ដោយមិនមាន "ខ្លួនឯង" ឬ "អាត្មា ព្រលឹង" នៅខាងក្រៅខ្លួនវា បន្ទាប់ពីការឈប់ងក់នៃការដើរគ្រឿងចក្រគឺសព៌ាង្គកាយនោះផង ?

---

១ ខន្ធេសុ ជាយមានេសុ ជីយមានេសុ មីយមានេសុ ច ខណេ ខណេ ត្វំ ភិក្ខុ ជាយសេ ច ជីយសេ ច មីយសេ ច (បរមត្ថជោតិកា របស់ព្រះពុទ្ធឃោសាចារ្យ) ។

យើងគប្បីយល់ថា បើកាយបែកធ្លាយគឺស្លាប់ទៅហើយ ខន្ធដទៃទៀតដែលរួមគ្នាជាខន្ធបញ្ចកៈក៏រលត់ទៅដែរ តែធម៌ទាំងឡាយជាកម្លាំងដូចពលៈឬថាមពល គឺ ឆន្ទៈ ចេតនា តណ្ហា មិនរលត់ទៅជាមួយគ្រឿងបគ្រឹសពាង្គិកាយទេ វាបន្តការដើររបស់វា ទៅកាន់យករូបកាយមួយដទៃទៀត ដែលលោកហៅថា "ជីវិតថ្មី" ឬ "ភពថ្មីមួយទៀត" ។ កាលយើងបិតនៅក្នុងកុមារភាព រូបកាយចិត្តទាំងអស់នេះ នៅទន់ខ្សោយ នៅខ្ចី ប៉ុន្តែ វាមានអ្វីមួយនៅក្នុងខ្លួនវាជាពលានុភាព (potentialité), ធម៌នេះ វាផលិតនូវការចម្រើនធ្វើឲ្យមានវឌ្ឍនាការឡើងទៅជាមនុស្សធំ ៗ ពលៈឬថាមពលនៃកាយនិងចិត្តនេះហើយ រួមផ្សំគ្នាកើតបានទៅជាសពាង្គិកាយមួយ ដែលយើងហៅថាតួ "បុគ្គល" "សត្វ" ឬ "អាត្មា-អញ-ឯង" ហើយវាចេះតែបន្តនៅក្នុងខ្លួនវា នូវពលានុភាព ឲ្យកើតជាជីវិតថ្មី គឺ ភពថ្មីៗ ហើយមានវឌ្ឍនាការចម្រើនធំឡើង មានកម្លាំងពេញបរិបូណ៌ទៀតតទៅ ៗ

ធម៌ទាំងនេះ នោះយោបីវាមិនមានសារជាតិ ( substance ) ទៀងទាត់ មិនចេះប្រែប្រួលក៏ដោយ ក៏មិនមានអ្វីឆ្លងពីខណៈចិត្តមួយទៅខណៈចិត្តមួយទៀតទេ សូម្បីមើលទៅឃើញរូបជ្រះឆោ ក៏មិនមានអ្វីទៀងទាត់ ក៏មិនមានអ្វីមិនចេះប្រែប្រួល ហើយវាមិនអាចនឹងឆ្លង ឬ ធ្វើវដ្តប្រវេសន៍ (Transmigration) ពីជីវិតមួយទៅជីវិតមួយទៀតបានទេ បើចង់និយាយ

ការនេះ គឺ ជាគ្រឿងបន្តមួយជាប់គ្នាដឹក បន្តពីមួយទៅមួយដឹកទៅ ដែលលោកហៅថា «សន្តតិ» (ការតគ្រឿងបន្ត) ហើយវាចេះតែប្រែប្រួលទៅក្នុងខ្លួនវាគ្រប់ខណៈចិត្ត ៗ សន្តតិ (គ្រឿងតន្ត) នេះ បើនិយាយឲ្យសមរម្យ មិនគឺអ្វីដដែលទេ គឺជាធម្មជាតិទទេ តែវាមានចលនា ៗ បើនឹងប្រៀប គួរប្រៀបដូចអណ្តាតភ្លើងដែលឆេះរហូតពេញមួយយប់ អណ្តាតភ្លើងនេះមិនមែនជាអណ្តាតភ្លើងដដែល ៗ ទេ ឬនឹងថាអណ្តាតភ្លើងមួយផ្សេងទៀតក៏មិនមែនដែរ តែអ្នកកាន់ផ្លាស់ដែលមិនមានការសិក្សា មិនយល់សេចក្តីពិត ពោលថាមិនគឺភ្លើងដដែលទេ គឺភ្លើងដដែលនោះឯងឆេះរហូតទៅ ៗ សេចក្តីនេះ យើងគួរយល់ដូចម្តេច? ដូចកុមារម្នាក់ តទៅចម្រើនធំឡើងបានជាមនុស្សម្នាក់អាយុ៥០ឆ្នាំ យើងយល់ថាជាមនុស្សដដែល មិនត្រូវទេ, កុមារដែលចម្រើនធំឡើងបានដល់អាយុ ៥០ ឆ្នាំនេះ ដោយពិត មិនមែនកុមារដដែលទេ តែនឹងថាមនុស្សដទៃទៀត ក៏មិនមែនដែរ, ឯមនុស្សដែលស្លាប់ក្នុងភពនេះ ហើយទៅកើតក្នុងភពមួយទៀត នឹងថាមនុស្សដដែល ក៏មិនមែន ឬនឹងថាមនុស្សដទៃទៀតក៏មិនមែនដែរ (ន ច សោ, ន ច អញ្ញោ) ។ នេះជាសន្តតិ = គ្រឿងបន្តគ្នាដឹក នៃអនុក្រមតែមួយនេះឯង ។

ចំណែកការផ្សេងគ្នារវាងការស្លាប់និងការកើតនោះ គួរយល់ថា ក្នុងខណៈចិត្តដែលកើតតែមួយនោះប៉ុណ្ណោះ គឺ ចុងខណៈចិត្តដែលកើតនៃអត្តភាពនេះ ជាដើមខណៈចិត្តដែលកើតនៃអត្តភាពមួយទៀត ដែលយើងហៅថា "ជីវិត

(កំណើត) តទៅ ” ។ ក្នុងកត្តានេះក៏មិនគឺអ្វី គឺសន្តតិ (គ្រឿងបន្តគ្នាដើរ ក្នុងអនុក្រមដែល)នេះឯង ។ ក្នុងថិរវេលានៃការរស់នៅយើងសព្វថ្ងៃនេះ ខណៈចិត្តមួយបន្តទៅខណៈចិត្តមួយទៀត ហើយវាចេះតែបន្តគ្នាដើរតទៅ ជាធម្មតា ។ តាមទស្សនៈពុទ្ធសាសនា ប្រស្នាជីវិត (ការរស់នៅ) បន្ទាប់ពីការបែកធ្លាយរាងកាយទៅ មិនមែនមានការអាថ៌កំបាំងអ្វីជ្រៅពេកទេ ហើយយើងជាពុទ្ធសាសនិកជន មិនសូវកង្វល់ខ្វល់ចំពោះប្រស្នានេះប៉ុន្មានដែរ ព្រោះយើងបានយល់សភាវធម៌នេះតាមពុទ្ធវចនៈហើយ ។

## ជំពូកទីបួន

### អរិយសច្ចទីបី

គ. អរិយសច្ចទីបីនេះ គឺការជួយឲ្យបានសម្រេចឥស្សរភាព ការរួចស្រឡះ ការរួចចាកទុក្ខ សេរីភាពចេញពីទុក្ខ ចេញពីសន្តតិ (គ្រឿងបន្តនៃទុក្ខ)ជាសេចក្តីពិត ។ ការរួចស្រឡះទាំងអស់នេះ លោកហៅថា "ការរលត់ទុក្ខ (និរោធសច្ច)" ជាឈ្មោះព្រះនិព្វាន (សំ. និវ៌ន) ហើយជាធម៌ដែលគេបានឮទៅ តែគេមិនយល់ថាដូចម្តេច ។

ដើម្បីបំបាត់ "ទុក្ខ" ឲ្យអស់រលីង ត្រូវតែបំបាត់ឫសគល់ទុក្ខមែនទែន គោលគឺ "តណ្ហា" ដែលជាធម៌នាំឲ្យមានកំណើត នាំឲ្យមានភពថ្មី ៗ (បុនព្ភព) ដែលយើងបានសិក្សាខាងដើមរួចមកហើយ ។ ដូច្នេះ និរោធសច្ច ឬ និព្វាននេះមានឈ្មោះដទៃទៀតថា តណ្ហក្ខយ ឬ តណ្ហាក្ស័យ (ការរលត់តណ្ហាអស់ដើង) ។ ល ។

សព្វថ្ងៃនេះ គេតែងតែសួរថា ដូចម្តេចហៅថា "និព្វាន"? ជាសំនួរឆ្ងាយ ៗ តែមិនបានទទួលចម្លើយគួរជាទីពេញចិត្តសោះ ។ មានគម្ពីរដីកាច្រើនណាស់ ដែលលោកសរសេរ អធិប្បាយពន្យល់ ឆ្លើយតបប្រស្នាល្អិតសុខុមនេះ ។ ចម្លើយទាំងអស់នេះពេញដោយខ្លឹមសារ ត្រឹមត្រូវទៅតាមគន្លងធម៌អស់ដើងតែធ្វើឲ្យស្តាប់បានដោយលំបាកពេក ឬស្ទើរតែស្តាប់ពុំបាននោះ ។ ការស្តាប់មិនបាននេះ មិនមែនមកពីចម្លើយមិនក្បោះក្បាយ

អស់ដើមឬមកពីអ្វីនោះទេ ដោយពិត គឺមកពីភាសាមនុស្សលោកនេះក្រត់ពេក ក្រត់ណាស់ទាល់តែរកពាក្យចំមួយម៉ាត់មកថ្លែងបញ្ជាក់ធម្មជាតិពិតគឺអរិយសច្ច ឬសេចក្ដីពិតអវសានបំផុត ដែលហៅថា "និព្វាន" នេះពុំបានៗ ភាសាមនុស្ស ដោយពិតគេបង្កើតឡើង សម្រាប់ឲ្យតែសាធារណជនប្រើតាមន័យធម្មតាប្រក្រតី ឲ្យគ្រប់គ្រាន់ល្មមតែឲ្យស្ដាប់គ្នីគ្នា នៅលោកមនុស្សនេះ និយាយទៅកាន់គ្នីគ្នា ស្ដាប់បានយល់បាន ដឹងសេចក្ដីបាន ថាតើគេចង់ថាដូចម្ដេចៗ ឯពាក្យដែលគេសម្រាប់ស្ដាប់ឲ្យយល់សេចក្ដីពិត ធម្មជាតិពិត ធម៌ពិតអវសានបំផុត ដូចសេចក្ដីពិតបែបអរិយសច្ច ព្រះនិព្វានដែលខ្ពស់ហួសផុតការពិសោធមនុស្សលោក នោះមិនមានទាល់តែសោះៗ ដូច្នេះ ក្នុងលោកកិលេសនេះ មិនមានពាក្យមួយម៉ាត់សម្រាប់ពន្យល់ការពិសោធ សម្រាប់ធ្វើនិទស្សន៍ សេចក្ដីពិត ពិតបែបអរិយសច្ចព្រះនិព្វានឲ្យបានជាក់ស្ដែង ឲ្យប្រត្យក្សពិតប្រាកដទេ បើទុកជាអស់លោកអ្នកណា ចំពន្យល់ ចំធ្វើនិទស្សន៍ ចំធ្វើឲ្យអស់ដើមដូចម្ដេចក៏ដោយ ក៏នៅតែគេស្ដាប់មិនយល់ ស្ដាប់មិនបានឮតែសំឡេងពាក្យថា និរោធៗ និព្វានៗ ដដែលៗ ដូចត្រីដែលមិនមានពាក្យមួយម៉ាត់និយាយពីធម្មជាតិគោក ដីគោកនោះឡើយៗ សេចក្ដីនេះ មានរឿងដំណាលទុកថា ថ្ងៃមួយ បងត្រីនិងបងអណ្ដើកហែលទៅជួបគ្នា នៅកណ្ដាលសមុទ្រ ជួបគ្នាហើយ បងអណ្ដើកនិយាយទៅកាន់បងត្រីថា

- ខ្ញុំទើបតែនឹងមកពីទីដីគោក! បងត្រីអើយ !

- ចុះកាលបងនៅឯដីគោកនោះ បងហែលលេងសប្បាយឬទេ ?

(បងត្រីសួរ) ។

- ទេ ទេបងត្រី! នៅដីគោក គេមិនហែលទេ! បងអណ្តើកឆ្លើយប្រាប់ ។ បងអណ្តើកខំព្យាយាមនិយាយប្រាប់ឲ្យបងត្រីស្តាប់ ពីការដែលនៅលើគោក គេហែលមិនកើត គេត្រូវដើរលើដី គេត្រូវរត់លើដី គេមិនហែលដូចសត្វទឹកដែលហែលក្នុងទឹកសមុទ្រនោះទេ ព្រោះដីនោះ ជាធាតុរឹងមិនរាវដូចទឹក ។ លុះត្រាតែដើរលើ ឬរត់លើ ទើបទៅកាន់ទីផ្សេងៗបាន ទឹងមុជជ្រែកកាត់ក្នុងដីពុំបានទេ ។ ស្តាប់បងអណ្តើកនិយាយប្រាប់ពន្យល់ឲ្យរាក់ឲ្យឆាយ ស្តាប់យ៉ាងណា បងត្រីតែតែងឿងឆ្ងល់ រឹតតែស្តាប់មិនបាន រឹតតែកើតក្តីសង្ស័យខ្លាំងឡើងៗ ពាល់តែការ៉ាន់មាត់និយាយតវ៉ាខ្លាំងៗ ។

- អេ! បងអណ្តើក! ដូចជាខុសទំនងណាស់! បងត្រីនិយាយតប បងនិយាយនេះវាផ្សេងពីយើងធ្លាប់ដឹងណាស់ ដែលនៅមានគេដើរហ៎ ? វាមិនដែលធ្លាប់គេដើរ គេរត់ដូចជាបងថានោះទេ កុំថាឡើយដល់ទៅស្តាប់មិនបានពាក្យថា ដីគោក គ្រាន់តែពាក្យថា ដើរ រត់ ក៏ស្តាប់មិនបានផង គេធ្លាប់តែហែល ទៅណាមកណាគេហែល មានដែលអ្នកណាដើរឬរត់ ? ព្រោះមានតែធាតុរាវដូចទឹក! ដែលទៅមានធាតុរឹងដូចគោកឯណា ? បងនិយាយនេះវាខុសទំនងណាស់ វាមិនមែនដូចបងអណ្តើកនិយាយនេះទេ។

បងអណ្តើកចាល់គំនិត ស្រុញនៅទីងថ្កល់ រកពាក្យនិយាយប្រាប់បងត្រីឲ្យស្តាប់មិនបាន បងត្រីក៏នៅតែមិនមានសទ្ធាជឿថាមានដីគោក ឯបងអណ្តើក ក៏នៅតែរកពាក្យមួយម៉ាត់ប្រាប់ពន្យល់ ថាមានដីគោក ថាគោកនោះដូចម្តេច ។ សេចក្តីពិត ដីគោក "មាន" មិនមែនថា មិនមាននោះទេ គេនៅលើដីគោក គេដើរលើដីគោក សត្វរកលើដីគោក ដូចបងអណ្តើកនិយាយពិតមែន ។ នៅក្នុងលោកមនុស្សនេះ ពាក្យជាសម្មតិនាមសម្រាប់ហៅវត្ថុគំនិតឧត្តមគតិដែលមនុស្សលោកមាន តែសម្មតិនាមនេះមិនអាចយកទៅប្រើហៅសេចក្តីពិតឬបរតិធម៌ បែបអរិយសច្ចនេះបានទេ ព្រោះភាសាដែលជាសម្មតិនាមនេះជាឧបក្កិលេស ។ ពិតណាស់ ភាសាជាឧបក្កិលេស ជាក្ដក់រាំងបាំង ឬបំភន្តគំនិតមិនឲ្យយល់សេចក្តីពិតបែបអរិយសច្ចបាន បើនឹងយល់អរិយសច្ចធម៌បាន លុះត្រាតែដោះពាក្យជាឧបក្កិលេសចោលឲ្យស្រឡះ (វិមុត្តិ) ឲ្យអស់ពីសន្តានចិត្តចេញ ។ សេចក្តីនេះ គួរនឹកដល់ពាក្យដែលលោកប្រើក្នុងគម្ពីរលង្កាវតារសូត្រថា គម្ពីរមហាយានលោកថា មនុស្សលោកនេះ ជាសត្វល្ងង់ ជាប់ស្អិតតែនឹងពាក្យដែលខ្លួនឯងសន្មតប្រើ ដូចដំរីធ្លាក់ជាប់ផុងនៅក្នុងភក់" ។ ពាក្យនេះ មានសេចក្តីពិតមួយរយភាគរយ ។

តែឥឡូវនេះ យើងនឹងធ្វើអ្វីក៏មិនកើត បើយើងមិនមានភាសា ព្រោះភាសា វាការកំណត់បង្ហាញវត្ថុ គំនិត ឧត្តមគតិ ឬអ្វីៗ ដែលយើងត្រូវការនឹង

ប្រើ ជាការចាំបាច់ ត្រូវប្រើភាសា ដូចជាសេចក្ដីត្រូវការនិយាយពី និរោធ និព្វាន វិរាគ តណ្ហក្ខយ ។ល។ សេចក្ដីពិត ធម៌ទាំងអស់ មានពិតមិនមែនជា មិនមាននោះទេ បើនិព្វានជាធម៌ដែលគេអាចថ្លែងឬពន្យល់បាន ដោយវិជ្ជមានសព្ទ (Terme positif) ទៅក៏ចុះ យើងអាចនិយាយឲ្យគេស្ដាប់បាន ឲ្យគេយល់បានភ្លាម ដូចជាកិច្ចការធម្មតា ព្រោះវាមិនប្លែកពីធម្មតា វាមិនផ្សេងពីការដែលយើងដឹង ចុះបើនិព្វាននេះ ដោយខ្លួនវាជាធម៌ដែលលោកប្រើអវិជ្ជមានសព្ទ (Terme négatif) ជួយនឹងពាក្យធម្មតាប្រក្រតីទៅវិញ (១) ធ្វើដូចម្ដេចឡើយ ទើបឲ្យស្ដាប់បានងាយកើត ? ។

( នៅមានត )

---

១ ពាក្យសម្រាប់ហៅ “ និព្វាន ,, ជាវិជ្ជមានសព្ទក៏មាន ដូចពាក្យថា “ សិវក្ខេត្ត ប្រសើរ ” ” ខេម ក្សេម ,, សុទ្ធិ បរិសុទ្ធ ” “ទីបៈ កោះ” “សរណៈ ទីពឹង,, “ តាណ ការទីពឹង ,, បារ ត្រើយ ត្រើយឆ្ងាយ ” “ សន្តិ សេចក្ដីស្ងប់ ” ពាក្យទាំងអស់នេះ សុទ្ធតែជាពាក្យប្រើសម្រាប់ហៅ “ និព្វាន ” ។ ពាក្យខ្លះទៀតចំនួន ៣២ ពាក្យ ជាសទិសសព្ទប្រើសម្រាប់ហៅ “ និព្វាន ,, ដែរ នៅក្នុងអសង្ខតសំយុត្ត គម្ពីរសំយុត្តនិកាយ ពាក្យទាំងនេះសុទ្ធគេប្រើផ្លាស់ប្ដូរគ្នាបាន (Métaphcrique) សៀវភៅទំព័រ ៣៦ ទំព័រ ៣៤៩ ។

# បុណ្យនៅលើគោក ខាយធ្វើសោះ

លោក រ៉ាំង - ធីន រៀបរៀង

អ្នកដែលមានសទ្ធាជ្រះថ្លា ក្នុងការឲ្យទានចំពោះព្រះសង្ឃ តែងតែធ្វើទៅតាមធនធានរបស់ខ្លួន ៗ ទេយ្យវត្ថុ ដែលត្រូវធ្វើទានព្រះសង្ឃនោះ គឺបង្អែម និង ចម្អាប ដែលជាប្រធាននៃទេយ្យវត្ថុទាំងអស់ ។

ក្នុងរឿងបង្អែម និង ចម្អាបនេះ អ្នកធ្វើទាន មិនសូវពោលទេ យាគុទាន គឺទានបបរនេះឯង ព្រោះបបរមានគុណភាពល្អ ហើយជាវត្ថុការងាយហុត ងាយទុជាវេស បើបានហុតហើយអាចនឹងជ្រួតជ្រាបហើសសព្វសពាង្គកាយ ធ្វើឲ្យមានកម្លាំងមួយរំពេច អាចកម្ចាត់បង់សេចក្តីក្រវល់ក្រវាយ ខាងផ្លូវកាយនិងផ្លូវចិត្តបាន ៗ ព្រះមានព្រះភាគ ទ្រង់សរសើរបបរ ថាជាអាហារមួយដ៏ប្រណីត ៗ សូម្បីតែអ្នកជំងឺ ដែលបរិភោគអាហារមិនកើតក៏ត្រូវការបបរដែលគេរំលាស់ឲ្យល្វយហុតយកទុជារស ដើម្បីជួយឲ្យមានកម្លាំងកំហែងខ្លះ ៗ ទៅដែរ ។ ដូច្នេះ អ្នកឲ្យទានបបរឈ្មោះថាឲ្យអានិសង្ស ១០ យ៉ាង ៗ

ឯអានិសង្សដែលប្រែថា ផល ហូរមកមិនដាច់ មាន ១០ យ៉ាងនោះគឺ

១ - **អាយុ**: ការរស់នៅបានយូរ

២ - **វណ្ណៈ**: ពណ៌សម្បុរកាយភ្លឺថ្លា ស្រស់បំព្រង

៣ . **សុខ**: ការស្រួលខ្លួន និង ការសប្បាយចិត្ត

៤ . **ពលៈ** មានកម្លាំងពលំ គឺមានកម្លាំងរឹងប៉ឹង មាំមួន

៥ . **បដិភាណៈ** ប្រាជ្ញាឈ្លាសវៃ ការដឹងទាន់ភ្លាម ៗ

៦ . អាចកម្ចាត់បង់សេចក្តីឃ្លាន

៧ . អាចកម្ចាត់បង់សេចក្តីស្រេក

៨ ញុំាងខ្យល់ឲ្យបានដើរស្រួល

៩ . ញុំាងសរសៃឲ្យបានស្អាត

១០ . ញុំាងភត្តាហារឲ្យឆាប់រលួយ ។

កាលបើយាគុទាន ( ទានបបរ ) មានផលានិសង្សយ៉ាងនេះ អ្នកដែលមានសេចក្តីត្រូវការចង់បានសេចក្តីសុខក្នុងមនុស្សក្តី សេចក្តីសុខជាទិព្យក្តី សេចក្តីចំរើនជារបស់មនុស្សក្តី គួរឲ្យទានបបរនេះ ដូចមានរឿងតទៅនេះ :

## យាគុទាយកត្ថេរាបទាន

កាលនោះ ខ្ញុំនាំគៀររបស់ខ្ញុំមកកាន់ស្រុកតូច បានឃើញស្ទឹងមានទឹកពេញព្រៀប ហើយចូលទៅកាន់អាវាសរបស់សង្ឃ ។ ភិក្ខុទាំងនោះជាអ្នកនៅក្នុងព្រៃ ទ្រទ្រង់នូវធុតង្គ មានឈាន មានចីវរដ៏សៅហ្មង ត្រេកអរក្នុងទីស្ងាត់ ជាអ្នកប្រាជ្ញ នៅក្នុងអាវាសរបស់សង្ឃ ។ ភិក្ខុទាំងនោះ លោកជាអ្នករួចស្រឡះល្អហើយ ប្រកបដោយគារវគុណ មានដំណើរដោ ហើយ ភិក្ខុទាំងនោះមានស្ទឹងស្ទះផ្លូវ ក៏ខាននិមន្តបិណ្ឌបាត ។

ខ្ញុំមានចិត្តជ្រះថ្លាមានចិត្តរីករាយ មានចិត្តត្រេកអរ ហើយធ្វើអញ្ជលី យកអង្ករធ្វើបបរ ប្រគេនយាគុទាន ។ ខ្ញុំមានចិត្តជ្រះថ្លា ប្រគេនបបរ ដែលចំអិនហើយ ដោយដៃរបស់ខ្លួន ព្រោះពួកម្ចាស់របស់ខ្ញុំ បានទៅកើតឯឋានតាវត្តិង្ស ៗ វិមានជាវិការៈនៃកែវមណី កើតសម្រាប់ខ្ញុំ ក្នុងពួកទេវតាឋានតាវត្តិង្ស ខ្ញុំប្រកបដោយពួកនារី ត្រេកអរក្នុងវិមានដ៏ប្រសើរ ។ ខ្ញុំបានឋានៈជាព្រះឥន្ទ្រ សោយរាជ្យជាស្តេចនៃទេវតា អស់ ៣៣ ដង បានសោយរាជ្យដ៏ធំ ជាស្តេចចក្រពត្តិ អស់ ៣០ ដង បានសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់មិនអស់ ខ្ញុំសោយនូវយស ក្នុងទេវលោកនិងមនុស្សលោក ។ ក្នុងកាលដែលដល់នូវភពជាទីបំផុត ខ្ញុំបានលះបង់សម្បត្តិទាំងអស់ ព្រមទាំងសក់ដែលគេកោរកាត់ រួចហើយចូលទៅកាន់ផ្នួស ។ ម្យ៉ាងទៀតកាលខ្ញុំពិចារណា នូវសាកសពដោយការអស់ទៅនិងការសូន្យទៅ ក៏បានសម្រេចព្រះអរហត្ត ដោយការបំពេញនូវសិក្ខា ក្នុងកាលមុន ៗ ទានដ៏ប្រសើរ ខ្ញុំបានឲ្យហើយដោយប្រពៃ ទានកើតឡើងដោយដៃខ្ញុំបានប្រកបប្រពៃហើយ ខ្ញុំជាបុគ្គលបានដល់នូវអចលបទ គឺនិព្វាន ដោយយាគុទាននោះឯង ។ ខ្ញុំមិនដែលស្គាល់សេចក្តីសោក សេចក្តីខ្សឹកខ្សួល ការឈឺចាប់ ក្រវល់ក្រវាយនិងសេចក្តីក្តៅក្រហាយចិត្ត ដែលកើតឡើយ ៗ នេះជាផលនៃយាគុទាន ។ ខ្ញុំបានប្រគេនបបរដល់ព្រះភិក្ខុសង្ឃ ជាបុញ្ញខេត្តដ៏ប្រសើរ ក្នុងលោក ក៏បាននូវអានិសង្ស ៥ ប្រការ នុ៎ះ គុណនៃបបរ

ខ្ញុំបានបូជាស្រួលហើយ ។ អានិសង្ស ៥ ប្រការនោះគឺ ភាពជាអ្នកមិនមានជំងឺដម្កាត់ ១ ភាពជាអ្នកមានរូបភងល្អ ១ ភាពជាអ្នកត្រាស់ដឹងនូវធម៌ឆាប់មួយ ១ ភាពជាអ្នកមានបាយទឹកជាប្រក្រតី ១ ខ្ញុំមានអាយុវែងជាគម្រប់ ៥ នេះ ១ ។ បុគ្គលណាមួយ កាលធ្វើសេចក្ដីត្រេកអរឲ្យកើត គព្វីប្រគេនបបរចំពោះព្រះសង្ឃ បុគ្គលនោះឈ្មោះថា បណ្ឌិតតែងទទួលបាន: ៥ ប្រការនេះឯង ។ ករណីយកិច្ចទាំងអស់នេះ ខ្ញុំបានធ្វើរួចហើយ ភពទាំងឡាយ ខ្ញុំបានគាស់រំលើងចោលហើយ អាសវៈទាំងពួងរបស់ខ្ញុំអស់រលីងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានទេ ។ ខ្ញុំនោះតែងដើរទៅកាន់ស្រុកតូច - ធំ តែងថ្វាយបង្គំនូវព្រះសម្ពុទ្ធ និង ព្រះធម៌ជាសភាវៈដ៏ល្អ ។ ក្នុងកប្បទី ៣០ ពាន់ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃយាគុទាន ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរកាត់ផ្ដាច់នូវទន្លីង ។ ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើរួចស្រេចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះយាគុទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

( ចប់ ភាណៈ ៩ )

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ - កន

ប្រែ ~ រៀបរៀង

## (ក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកភាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ
>
> យូ-អ៊ុន

ឯស្រុកវុយកុកសោត ក៏ជាសត្រូវនឹងយើងមកពីដើម ត្រូវតែលើកទៅវាយឲ្យបាន ក្នុងពេលនេះ ។

ហៃហ៊្វូប៉ាឆ្លើយថា: លោកមានប្រសាសន៍នេះត្រូវណាស់, សុំឲ្យលើកកងទ័ពទៅតាមផ្លូវបៀស៊ីវ, យើងទៅវាយយកស្រុកថៅសេងនិងស្រុកឡាំអានដែលជាស្រុកសំខាន់បានហើយ ក៏នឹងបានខែត្រតាំងក្វន ដោយស្រួល, ទៀវអេកឆ្លើយថា លោកលើកទៅធ្វើការគ្រានេះ ដើរទ័ពយូរណាស់ទើបមិនបានជ័យជំនះ លើកត្រឡប់មកវិញ, ឯក្នុងគម្ពីរពិជ័យសង្គ្រាមមាននិយាយទុកថា មេទ័ពមេកងអ្នកដែលចេញទៅធ្វើការណាធ្វើសង្គ្រាម នឹងលើកទៅវាយគេត្រូវកុំឲ្យគេដឹងខ្លួនទាន់ ទើបនឹងមានជ័យជំនះ បើគេដឹងខ្លួនហើយ គេនឹងត្រៀមការយុទ្ធនាសង្គ្រាមទុកព្រម, នរណាមានឫទ្ធិខ្លាំងពូកែយ៉ាងណា ក៏គង់ធ្វើការមិនសមគេ,

ហេតុនេះសូមឲ្យលោកទំស្រូតរូតលើកៈទៅជាប្រញាប់ កុំឲ្យសត្រូវដឹងខ្លួនទាន់ឡើយ មុខជានឹងបានជ័យជំនះតែម្តង, គៀនអ៊ុយយល់ឃើញត្រូវ ក៏ឲ្យគេណ្ហប្រមូលទាហានទាល់តែអស់ បានចំនួនមនុស្ស ៦១ម៉ឺន ហើយលើកទៅតាមផ្លូវបៀស៊ីវ ។

លុះទៅដល់ដំបន់ខនេះទៅ ស៊ុយ កងល្បាតទៅប្រាប់គៀនអ៊ុយថា អ៊ុនគេង ទៅហ្វាយស្រុកយង់ជីវ ទឹងតាន់ថាយនាយទាហានវង់នាំពល ៧០.០០០ លើកតម្រង់មក, គៀនអ៊ុយទើបរិះគិតបទឧបាយឲ្យទាហានធំលើកទៅជា ២ កង, ឲ្យទៅវាយត្រឡប់ពីក្រោយ, ទៀវអេគខិង វែហហ៊្វាំ ក៏លើកចេញទៅ, គៀនអ៊ុយក៏លើកកងទ័ពចូលខនេះទៅស៊ុយ ទៅតាំងនៅឆ្នេរប្រាំងក្រើយខាងលិច, ឯអ៊ុនគេងក៏នាំពលចូលទៅទឹងប្រយុទ្ធគា, លុះលើកកងទ័ពទៅដល់ជិតហើយក៏ស្រែកសួរថា ស្រុកវុយកុក, ស្រុកគាំងតាំង, ស្រុកសៃឈួន ទាំងពីរប្រទេសនេះតាំងនៅស្រួល បើទាំងអស់គ្នានៅឲ្យស្ងៀមក៏មានតែសេចក្តីសុខ, ហេតុអ្វីបានជាអ្នកឯងលើកកងទ័ពមកវាយស្រុកយើង ។

គៀនអ៊ុយស្រែកថា ព្រះចៅចូហង់ខុសត្រូវប្រការម្តេច បានថា [illegible] ស្តេចឲ្យចេញពីរាជសម្បត្តិ ហើយយកអ្នកជាខែមក [illegible] ជា [illegible] វិញ ។ អស់នាម៉ឺនមន្ត្រីទាំងពួងខ្លាចអំណាចហើយក៏យល់ព្រមតាមទៅ យើងនៅផ្សេងប្រទេស, តែឃើញថាទៅហ្វាយ

នាយឯងធ្វើខុស ប្រវេណីអំពីបុរាណពេកណាស់ បានជាលើកទ័ពមក ធ្វើទោស ប្រាថ្នានឹងមិនឲ្យខ្ញុំផែនដីយកយៀងយ៉ាងតទៅខាងមុខ ។

អងតេងបានឮដូច្នោះ ក៏ទាញ់ទាល់តាមិនដឹងឆ្លើយថាប្រការម្ដេច ក៏ក្រឡេកមើលមុខ នាយទាហាន ៤ នាក់ ឈ្មោះទោបេង ១, ហ៊ុយគេង ១, ឡេវគាត់ ១, ជួហង ១ ហើយឆ្លើយថា គងទ័ពស្រុកសៃឈួនធ្វង មកតាំងបន្ទាយនៅត្រើយខាងណេះ, បើចាញ់ពួកយើងមុខជាទាហាន នឹងស្លាប់ជាច្រើនណាស់ កៀងអ៊ុយនេះមានថ្វីដៃខ្លាំងពូកែច្រើន តែ យើងមើលមិនឃើញមុខទេណា នឹងចេញទៅតទល់បាន, យើងឃើញ តែពួកអ្នកឯងទាំង ៤ នាក់ ចូរជួយគ្នាតើល្មមនឹងតក៏បានទេ ? បើគេ ចាញ់ប្រៀបថយនឹងយើងទៅហើយ ត្រូវអស់អ្នកនាំទាហានដេញទន្ទ្រាន ឲ្យមួនមាំ ជាហើយក៏ដេញទាហាននោះចូលតស៊ូ, កៀងអ៊ុយក៏បាន ចេញតទល់បានមួយស្របក់ ក៏ញាក់សេះនាំទាហានចូលបន្ទាយ អង តេងបង្គំស្រួតឲ្យទាហានដេញតាម, កៀងអ៊ុយថយទៅដល់ក្បែរមាត់ទឹក ហើយក៏នាំទាហានគេចឆ្លងទៅត្រើយខាងលិច ហើយស្រែកប្រកាស ដល់ទាហានទាំងពួងថា សត្រូវដេញមកជិតណាស់ហើយ, ពួកយើង សុទ្ធតែជាជាតិទាហានដៃជា ៗ ពូកែបំណាន បានជាប់ធ្វើការសង្គ្រាមមក ពីដើម ហេតុម្ដេចបានជាគ្រានេះមកនាំគ្នាញញើតខ្លាចដូច្នេះ, ទាហាន អងតេងនៅខាង... ក៏ត ។

ទៀវអេកនឹងហៃហ្វូចា ដែលលើកពលទៅលួចបង្កប់ លុះដឹងថាទ័ពទាំងសងខាងកំពុងច្បាំងគ្នា ក៏វាយត្រឡប់ពីក្រោយចូលទៅ១កង, វាយប្រសព្វចូលពីខាងមុខ ១ កង, កៀនអ៊ុយក៏តាំងសំដែងចុកពោះធ្វើមាំមួនបរពលចូលទន្ទ្រានត្រឡប់ចូលទៅវិញព្រមគ្នាទាំង ៣ កង, ពួកទាហានអង់គេងចុះទៅមាត់ទន្លេ, ឯទាហានអង់គេងដែលចុះទៅមុនពាល់ទឹងទឹកខ្លាចពុំអាចចុះទៅចេះតែកង់នៅ, ប៉ែកដែលរត់ចុះទៅខាងក្រោយ ទាំងមនុស្សនិងសេះក៏ជាន់គ្នារបួសពិការស្លាប់ប្រហែល ២ ភាគ, ប៉ែកដែលរត់ចុះទឹកក៏ស្លាប់ជាច្រើន, ទាហានកៀនអ៊ុយ ក៏កាត់យកក្បាលបាន ១០·០០០ប្លាយ ។

អង់គេងនាំពល ១០០ប្លាយវាយទំលាយគេចចេញទៅបាន, ហើយរត់ទៅតាមផ្លូវគេកគោសៀ ចូលទៅក្នុងកំពែងស្រុកហើយបិទទ្វារខ្ជាប់ខ្ជួនឲ្យពួកទាហានរក្សាត្រួតត្រា, កៀនអ៊ុយមានជ័យជំនះហើយ ក៏រៀបបាយទឹកជប់លៀងទាហានទាំងឲ្យបំណាច់រង្វាន់ហើយប្រឹក្សាថា ៗយើងនឹងលើកតាមទៅវាយយកស្រុកគេកគោសៀទៀត តើអស់អ្នកពលគ្នាទាំងយល់ឃើញប្រការម្ដេច ? ទៀវអេកឆ្លើយឃាត់ហាមថា លោកធ្វើការគ្រានេះមានជ័យប្រាកដជាកិត្តិយសណាស់ហើយ សុំឲ្យឈប់តែត្រឹមនេះចុះ, បើនឹងធ្វើការតទៅទៀតក្រែងភ្លាំងនឹងមិនរួចការទេឬ ? ដូចគេវាយ [illegible] ហើយវាយជើងផង គឺឲ្យឃើញជើងពស់ ។

កៀនអ៊ុយតបថា អ្នកនិយាយនោះមិនត្រូវទេ, ពីដើមយើងលើកទ័ពមកធ្វើការច្បាស់ការផងគេជាច្រើនគ្រា ៗ នេះយើងឧស្សាហ៍មកធ្វើការទៀតក៏បានជ័យជំនះ, ទាហានស្រុកវៀតកុកបែកគ្រានេះខ្ទេចខ្ទីច្រើនណាស់, មើលទៅឃើញញញើតខ្លាំងហើយ បើយើងលើកទៅវាយថែមទៀត ពលយើងក៏មានទឹកចិត្តចិត្តទុំមុខជានឹងបានស្រុកកេកកោសៀដោយងាយប្រហែលមួយដំណាស់ដៃ ទៅកុំបីកោតញញើតក្នុងចិត្តឡើយ។ ទៀវអេងឃាត់ហាមដល់៣សា កៀនអ៊ុយមិនស្តាប់ ក៏លើកទ័ពទៅស្រុកគេកកោសៀ ។

ឯតាន់ថាយខូចកងទ័ពនឹងកៀនអ៊ុយហើយ ក៏ទៅបញ្ចុះបញ្ចូលប្រមូលពលទាហាននឹងមកជួយអងគេង, លុះឃើញគេងងាយទៅហ្វាយស្រុកក្នុងដីវៀតទាហានជួនមក មានសេចក្តីត្រេកអរណាស់ ចេញទៅទទួលចូលមក, គេងងាយនិយាយថា លោកមហាឧបរាជឲ្យលើកកងទ័ពមកជួយ, តាន់ថាយឆ្លើយតបថា លោកនឹងរិះគិតជាប្រការម្តេចទើបនឹងឲ្យមានជ័យជំនះ ។

គេងងាយថា កៀនអ៊ុយមានជ័យជំនះដល់យើងនៅវ៉ងម៉ោរទាត់ទេទៅស៊ុយហើយ បើតាំងចញ្ចុះបញ្ចូលទាហាន៤ ការណាខែត្រូវនៃក្នុងនេះបានហើយធ្វើការតចូលមក, ខ្ញុំបានឃើញថាទាំងយើងនឹងលំបាកជាប្រាកដ នេះកៀនអ៊ុយមិនទាន់គិតធ្វើដោះគេ [illegible]

ត្រង់ចូលមកព័ទ្ធស្រុកគោកគោសៀតែម្តងដូច្នេះ, យើងនឹងខ្លាចអ្វី ដោយស្រុកគោកគោសៀនេះមាំមួនណាស់, ទោះបីនឹងវាយយ៉ាងណាក៏មិនបែក បើយើងនឹងលើកកងទ័ពទៅបង្កប់នៅក្ដាហានទៀ ចាំមើលបើឃើញកងទ័ពគៀងអ៊ុយលើកមក ត្រូវបញ្ចេញដោយកលឧបាយគង់នឹងចាញ់គេទៅជាប្រាកដ មុខជាមិនបង្អង់ឈប់ច្បាំងទេ ។

គាន់ថាយយល់ឃើញត្រូវ ក៏ឲ្យកេណ្ឌប្រមូលទាហានជា ២០កង, កង ១ កង ៥០នាក់ ហើយឲ្យត្រៀមកំភ្លោះទឹងផាវពេលទៅ ហើយឲ្យស្រែកហោឲ្យគឹកកងរំពង ។

ឯគៀងអ៊ុយឲ្យគាំងបន្ទាយ ៨អន្ទើ ព័ទ្ធស្រុកគោកគោសៀ ឲ្យទាហានតោរកំពែងទំលាយប៉មដល់ ៩ថ្ងៃ ១០ថ្ងៃ ហើយក៏ហែកចូលទៅមិនបាន ទាល់គំនិតណាស់មិនដឹងនឹងគិតយ៉ាងម្តេច ក៏ឲ្យរំខានក្នុងចិត្តពេកណាស់, លុះវេលាយប់ពួកកងល្បាតឲ្យបំពេរសេះមកប្រាប់ថា កងទ័ពលើកមកជា ២កង, ទង់ជ័យមួយមានអក្សរសម្គាល់ថា „ គាន់ថាយ, បៀនអាយ, ចុងគុន „ ទង់ជ័យមួយមានអក្សរសំគាល់ថា „ កេងសាយ ទៅហ្វាយស្រុកកុនជីវ „ គៀងអ៊ុយភ័យណាស់ឲ្យប្រមូលមុខមន្ត្រីចូលមកប្រឹក្សា ។

ហៃហ៊ុយប៉ាឆ្លើយថា កេងសាយនេះ មានថ្វីដៃច្បាំងខ្លាំងពូកែណាស់ ទាំងសតិបញ្ញាក៏ឆ្លៀវឆ្លាតក្នុងការណាដែរសង្គ្រាម, គៀងអ៊ុយថា កង

ទ័ពគេលើកមកពីចម្ងាយ ទាហានហេវពលរសាំរសាយទេ, បើយើងត្រូវបន្ទំ
ស្រួតស្រគេលើកចូលទៅក្រោយ ឃើញថានឹងបានដោយងាយ កុំឲ្យតែជំនួន
តាំងបន្ទាយទាន់ ថាហើយក៏ចាត់ទៀវអេកឲ្យនាំពលចូលទំលាយក្រោយ
ស្រុក, ចាត់ហៃហ៊ូប៉ាឲ្យទៅក្រយបុងគយ, ឯកៀងអ៊ុយក៏លើកទៅក្រោយ
ទ័ពតេងងាយ, លុះលើកទៅបានប្រមាណ៥០សិន ស្រាប់តែឮស្គរគំ-
គ្រោះផាវ និងសំឡេងមនុស្សស្រែកហោ សំឡេងស្គរទ័ពសន្ធាប់សន្ធឹក
ខ្លាំងណាស់, ក្រឡេកទៅឃើញទង់ជ័យដោតកាយជុំវិញដាសដាក់ក័យ
ណាស់ គិតថាមុខជាត្រូវកលរបស់តេងងាយជាប្រាកដ នឹងថូស់ការ
របស់គេហើយក៏ថយទ័ព, ទើបឲ្យបំរើសេះទៅតាមកងទ័ពទៀវអេង ឲ្យ
លើកថយត្រឡប់ទៅស្រុកហាន់តុង, ឯកៀងអ៊ុយនៅរាំងពីក្រោយ លុះ
ថយទៅដល់គយកៀមកុកទើបដឹងថា កងទ័ពដែលតំខ្លួននោះផាស់ច្រើន
ស្រពាប់ណាស់ គឺជាកងសឹករបស់តេងងាយធ្វើបញ្ឆោតឲ្យថូស់ការ ក៏
នាំនាយទ័ពនាយកងតាំងតួងចូលទៅ គាល់ព្រះចៅឡៅសៀនឯក្រុងសែ
ល្ហួន ហើយទូលរឿងរ៉ាវដែលទៅបានធ្វើការនោះសព្វគ្រប់ប្រការ ។

ព្រះចៅឡៅសៀន ឃើញកៀងអ៊ុយមានជ័យជំនះ បានសេចក្ដី
គាប់ប្រសើរមក ក៏ទ្រង់តាំងឲ្យលៀនទំជាតៃបុងគុន, កៀងអ៊ុយក៏ថ្វាយ
បង្គំលាទៅដល់ស្រុកហើយ ក៏មានចិត្តរឹងនឹងតេងងាយពេកណាស់ ឲ្យ
ទាហានត្រៀមគ្រឿងសស្ត្រាវុធ និងសេះជំនិះទូរស់គ្រឿងសព្វយុទ្ធ

ព្រមហើយ ឲ្យមានសំបុត្រចូលទៅក្រាបទូលព្រះចៅឡៅសៀនថាទឹង
សុំលាលើកទ័ពទៅវាយស្រុកវុយក្នុង១លើកទៀត ។

ឯអង់គែងដឹងថា កៀងអ៊ុយរំសាយទ័ពលើករត់ទៅហើយ ដោយសារគែងឆាយមកជួយទើបឲ្យទៅ អញ្ជើញគែងឆាយមកបរិភោគអាហារក្នុងស្រុក, ហើយក៏ឲ្យតែងសំបុត្របកសេចក្ដីគាប់ប្រសើររបស់គែងឆាយទៅទូលព្រះចៅហេម៉ ៗ ក៏ត្រាស់ឲ្យតាំងគែងឆាយជា អានសៃបុងកុន នាំទាហាននៅរក្សាស្រុកអេងដីវជាមួយខឹងគាន់ថាយ, គែងឆាយចេញទៅទទួលគំនាប់ត្រាតាំងតាមទម្លាប់ទំនៀម, គាន់ថាយក៏ឲ្យអញ្ជើញគែងឆាយទៅបរិភោគអាហារគុលៀង ហើយនិយាយថា ទាហានស្រុកសៃឈួនចាញ់គំនិតរិះគិតរបស់លោកគ្រានេះ ឃើញថាមុខជាមិនលើកមកទៀតឡើយ, គែងឆាយថា ខ្ញុំឃើញថាទាហានស្រុកសៃឈួនខឹងលើកទៀតដោយហេតុដល់៥ប្រការ, គាន់ថាយសួរថា ហេតុ៥ប្រ-ការនោះគឺអ្វីខ្លះ ? សុំលោកអធិប្បាយឲ្យស្ដាប់មើល, គែងឆាយថា ហេតុជាបឋមនោះ គឺទាហានស្រុកសៃឈួនរត់ទៅក៏មែន តែថាមិនចាញ់ដោយកំឡាំងរេហ៍ពលទឹងមានជ័យជំនះទុកមុន បានសេះទឹងសា-ស្ត្រាវុធរបស់យើងទៅជាច្រើន, ឯខាងយើងមានជ័យឲ្យគេរត់ទៅក៏មែន តែថាយើងក៏ខូចរេហ៍ពលច្រើនណាស់, ហេតុជាគំរប់ ២នោះ គឺទាហានស្រុកសៃឈួន បានបែបយ៉ាងពីចុងបេងបញ្ជាក់បង្រៀនទុកស្ទាត់ស្ទាត់

ព្រមព្រៀងជំនះជំនាញក្នុងការសង្គ្រាមណាស់, ទាហានខាងយើងគ្មាន
ចំណានស្ទាត់ដូចគេសោះ, ហេតុជាគំរប់៣នោះ គឺទាហានស្រុកសៃ-
ឈួនលើកមកខាងផ្លូវគោក ផ្លូវទឹកបន្ទុកស្បៀងប្រចាំជួន មិនលំបាក
ដោយកំឡាំងទាហានសោះ, ទាហានខាងយើងលើកមកបានតែផ្លូវគោក
ម្យ៉ាង, លំបាកដោយស្បៀងអាហារណាស់; ហេតុជាគំរប់៤នោះ
គឺទីក្រុងគេងគោសៀ និងស្រុកឡុងសេនេះ ហើយនិងស្រុកឡាំគាខ្ញី
គឺសាគទាំងអម្បាលនេះធំទូលាយណាស់, ទាហានស្រុកសៃឈួនបាន
មកញៀយ ៗ ដឹងស្គាល់គ្រប់អន្លើដីបទទៃញកសោយកយគ្នាមកគ្រប់ផ្លូវ,
ទាហានយើងត្រូវគ្រាក្យាបានដោយកម្រ, ហេតុជារប់៥នោះ គឺទា-
ហានស្រុកសៃឈួននឹងលើកមកធ្វើការគ្រាណាវៃមិនមកអាស្រ័យស្បៀង
អាហារក្នុងស្រុកកៀងជាកំឡាំងគ្រប់គ្រា, ខ្ញុំឃើញហេតុ៥ប្រការដូច្នេះ
ទើបថាកងទ័ពស្រុកសៃឈួននឹងលើកមកទៀតជាប្រាកដ; តាន់ថាយ
ស្តាប់ហើយក៏សរសើរតម្រិះប្រាជ្ញាគេងង៉ាយថា លោកមានសតិបញ្ញាធ្ងន់ក្តី
យល់ន័យកន្លងដឹងសេចក្តីដូច្នេះ នឹងខ្លាចអ្នកដល់ពួកសត្រូវទាំងនោះ ថា
ហើយ តាន់ថាយនិងគេងង៉ាយក៏តាំងសត្យស្បថស្បាន ជាបងប្អូននឹងគ្នា
ដរាបទាល់អស់ជីវិត ហើយក៏ឲ្យទាហានទាំងពួងហាត់រៀនគុណអាវុធយុទ្ធ
នាសង្គ្រាមឲ្យជំនាញស្ទាញស្ទាត់គ្រប់ប្រការ ហើយឲ្យទាហានទៅតាំង
បន្ទាយពយគ្រោះយប្រកល្ប៉ក ដែលជាទ័ពបរណ្ណតូសីមាឲ្យមាំមួន
គ្រប់ទីទៅ ។

ឯកៀនអ៊ុយនោះ លុះប្រមូលពលទាហានបានច្រើនហើយ ក៏តាំងជប់លៀងអាហារហើយប្រឹក្សាថា យើងនឹងលើកកងទ័ពទៅច្បាំងនឹងស្រុកវុយកុកគ្រានេះ តែអស់អ្នកនឹងយល់ឃើញជាប្រការម្តេច ? មានបោកម្នាក់ឈ្មោះហួនកៀនឆ្លើយថា លោកលើកទ័ពទៅគ្រាមុន បានជ័យជំនះមានកិត្តិយសទុកជាប្រាកដហើយ ទាហានស្រុកវុយកុកគោតក្រែងកែងខ្លាច បានជាគបៈគេជៈដល់ស្រុកសែឈួនហើយលោកនឹងលើកទ័ពទៅទៀតគ្រានេះ, បើថ្វាស់ព្រោយភ្លាំងភ្លាត់ ក៏នឹងក្ខយឲ្យខូចកិត្តិយសពីគ្រាមុននោះអសារឥតប្រយោជន៍, កៀនអ៊ុយថា អ្នកនិយាយនេះ ព្រោះឃើញថាដែនស្រុកវុយកុកនោះធំទូលាយ ហើយមានពលទាហានច្រើន បានជានាំឲ្យញញើតខ្លាច, ឯខ្ញុំឃើញថាកងទ័ពយើងបានប្រៀបជាងស្រុកវុយកុកច្រើនណាស់ ដោយហេតុ ៥ ប្រការទើបមិនឲ្យក្រែងខ្លាច ។

បណ្តាអស់នាយទាហានទើបសួរគេថា ប្រសាសន៍ថាហេតុ៥ប្រការនោះ គឺម្តេចខ្លះ ? កៀនអ៊ុយឆ្លើយថា ហេតុទាំង ៥ ប្រការនោះយើងនឹងពណ៌នាឲ្យស្តាប់ ហើយក៏និយាយត្រូវដូចពាក្យគេងស៊ាយដែលអធិប្បាយប្រាប់តាំងថ្ងៃ ដែលយើងប្រារព្ធមកហើយខាងលើនេះ គ្រប់ប្រការ, ហើយកៀនអ៊ុយថា យើងឃើញបានប្រៀបយ៉ាងនេះឯង, ទើបពេញចិត្តដែលនឹងគិតទៅវាយស្រុកវុយកុក, បើដូច្នេះហើយមិនទៅទ

តើទីងទៅកាលណាវិញឲ្យជាជាងកាលនេះ, ហៃហ៊ូញ៉ាថា តេងឆាយនោះនៅក្មេងសេចក្ដីក៏មែន តែគេមានសតិបញ្ញាស្រួចស្រស់ណាស់, ហើយគ្រានេះក៏បានជាទី « អាទសែបុងគុន » ផង មុខជាទីងបាត់បង់ពលទាហានឲ្យគេក្បស្រុកនឹងគយប្រកល្អកតាមទីខែត្រ ខណ្ឌមាំមួនជាងពីដើម យើងកុំអាលមើលឆាយក្រែងថូស់ការ ។

គៀងអ៊ុយឮដូច្នោះក៏ខឹងណាស់ ស្រែងគំហកថា ទីងធ្វើការធំហើយមកនាំនិយាយយ៉ាងនេះ ឲ្យពលទាហានមានចិត្តរញ្ញក នរណាក៏ដោយកុំហាមឃាត់យើងទៀត យើងមិនស្ដាប់ទេ, ថាហើយក៏បង្គាប់ឲ្យលើកកងទ័ពចេញទៅ, ឯខ្លួនគៀងអ៊ុយក៏នាំទាហានជាកងមុខលើកទៅ, អស់ទាំងរេហ៍ពលក៏លើកតាមទៅដល់ជំបន់ភ្នំគីសាន នោះមានកងល្បាតបាត់បរ៉េសេះមកប្រាប់ថា ទ័ពស្រុកវុយកុកលើកមកតាំងបន្ទាយស្កាត់ផ្លូវ មានបន្ទាយ៩អន្ទើ, គៀងអ៊ុយក៏មិនជឿស្ដាប់, ទើបជិះសេះនាំទាហានឡើងទៅលើភ្នំ ក្រឡេកទៅឃើញបន្ទាយកយហៃគ្នាទៅជាមាំមួនណាស់ មើលដូចអាសិរពិសមានក្បាលនិងកន្ទុយពេនព័ទ្ធតែគ្នា, គៀងអ៊ុយក៏និយាយនឹងហៃហ៊ូញ៉ាថា អ្នកនិយាយមកនេះត្រូវណាស់, តេងឆាយនោះមានតម្រិះរិះគិតមុតមាំមែន, ពីព្រោះមើលទៅឃើញរបៀបការប្រហែលនឹងលោកគយហាឧបកជកាចារ្យនៃយើង, ដែលយើងវាកពាក់ចំណាយចូលទៅឃើញជាមិនបាន ក្រែងមានថូស់ការប្រហែល តង-

ឆាយនៅក្នុងបន្ទាយនេះទេដឹងឬ ។ ចាហ៊ុយក៏នាំទាហានត្រឡប់មកវិញ ហើយឲ្យតាំងបន្ទាយនៅក្បែរមាត់ផ្លូវជាមាំមួន, ហើយបង្គាប់ទាហានឲ្យចេញទៅយាមល្បាតលាតត្រវែលជា ៥ ពួក, ក្នុង១ពួក ៥០០, ឲ្យកែងខ្លួនប្លែកៗពីគ្នា កាន់ទង់ជ័យ៥ពណ៌ ខៀវ, លឿង, ស, ក្រហម, ខ្មៅ មិនឲ្យដូចគ្នា ហើយតាំងបៀវនៅឆាយទាហានឲ្យនៅក្បែបន្ទាយ ទើបក៏-ដាប់ចា អ្នកឯងរក្សាបន្ទាយឲ្យល្អ ដ្បិតខ្លួនយើងនឹងលើកទ័ពទៅវាយស្រុកឡាំអាន់ ។

ឯគេងឆាយដឹងថា គងម៉ិងទ័ពស្រុកសៃឈួនលើកមកតាំងបន្ទាយនៅមាត់ផ្លូវប្រហែល ច្រើនថ្ងៃហើយមិនបានលើកមកវាយ, មានតែទាហានមកដើរយាមល្បាតមើលផ្លូវ ១០០ ឬ ១៥០ ហើយត្រឡប់ទៅ, ផ្លាស់ប្តូរគ្នា ១ថ្ងៃ៥ពួក, កែងខ្លួនប្លែកៗពីគ្នា, កាន់ទង់ក៏ពណ៌ផ្សេងគ្នា; ទើបគេង-ឆាយជិះសេះនាំទាហានឡើងទៅមើលលើកំពូលភ្នំ ក្រឡេកឃើញបន្ទាយ ហើយត្រឡប់ចុះទៅប្រាប់ឆាន់ថាយថា ខ្ញុំគួរយល់ថាកៀងអ៊ុយមិននៅក្នុងបន្ទាយនេះទេ ប្រហែលនឹងលើកទៅវាយស្រុកឡាំអាន់ជាប្រាកដ, ឯទាហានដែលលើកមកយាមល្បាតនោះឃើញស្លូតស្តើងទេ, សុំឲ្យលោកលើកទៅវាយយកបន្ទាយនោះឲ្យបាន ហើយតាំងស្កាត់នៅដើមផ្លូវ ខ្ញុំនឹងលើកទៅជួយស្រុកឡាំអាន់, បើកៀងអ៊ុយចាញ់ហើយ ខ្ញុំនឹងស្រួតទៅតាំងនៅក្បែរសៀងភាន់ ហើយនឹងបង្គាប់ទាហានទុកសន្សាផ្លូវដែល

ជាទីប្រហាបបើគៀនអ៊ុយលើកមកទីនោះ នឹងលើកយកខ្លួនឲ្យបាន មុខជានឹងចួសការផងយើងមិនខាន ។

គាត់ថាយថា ខ្ញុំមកនៅក្នុងស្រុកនេះយូរប្រមាណ ២០-៣០ឆ្នាំ ហើយ មិនទាន់ដឹងច្បាស់ផែនទីស្រុកនេះសោះ, លោកនៅស្រុកឯទៀតទេ ហេតុម្ដេចបានជាដឹងច្បាស់គ្រប់ច្រកល្ហកគ្រប់ដំបន់ដូចទេពតា ? ដែលលោកថានេះត្រូវណាស់, បូស្រួតរូតលើកទៅបុះ, ខ្ញុំនឹងចូលកាប់យកបន្ទាយនេះឲ្យបាន, គេនឹងរាយលើកទ័ពទៅតាមផ្លូវគាត់, ទ័ពស្រួតរូតទៅដល់ក្ដបូសៀនសាន់មុនគៀនអ៊ុយទៅដល់ ក៏តាំងបន្ទាយយ៉ាងមួនម៉ាំនៅលើក្ដនោះ, គេនឹងរាយបាត់ប្រើអេងគងជាកូននឹងស៊ុមៅនាយទាហានឲ្យនាំទាហានម្នាក់៥០០០ បង្គាប់ឲ្យលើកទៅតាំងនៅទីច្រកដំបន់ខ្លួននោះ, នាយទាហានទាំង ២ នាក់ក៏លើកទៅតួនបង្កប់ ឯកងបន្ទាយគេនឹងរាយនោះ ហាមប្រាមមិនឲ្យនិយាយគ្នាឲ្យឮមាត់កសោះ, ធ្វើហាក់ដូចជាមនុស្សនៅ ទង់ក៏មិនដោតសោះ ។

គៀនអ៊ុយលើកទៅដល់ទីនោះ ចូលទៅខាងមុខក្ដបូសៀនសាន់ ផ្លូវនឹងចូលទៅស្រុកឡាំគាន់ ក៏និយាយនឹងហៃហ៊្វូប៉ាថា ក្ដនេះជាទីស្រួល មួលម៉ាំមួនណាស់, បើយើងចូលទៅតាំងបន្ទាយនៅបាននឹងបានស្រុកឡាំគាន់ងាយនឹងរាយ, តែខ្ញុំឃើញថា គេនឹងរាយមានគំនិតរ៉ះគិត ប្រើហាប [illegible] ? [illegible]

ផុតពាក្យ ស្រាប់តែឮសូរផាវទឹងសូរស្គរ ស្រែកហោចុះមកពីលើភ្នំ ត្រ-ឡេកទៅឃើញទង់មានចារឹកអក្សរសំគាល់ថា «គេងសាយ» កងមុខភ័យណាស់, គៀងអ៊ុយក៏លើកទ័ពជំនួនជួនឡើងទៅ, ទាហានគេង-សាយក៏ថយត្រឡប់ទៅ, គៀងអ៊ុយក៏ដេញដឹតតាមទៅដល់មុខបន្ទាយ ឲ្យទាហានស្រែកជេរជាពាក្យខ្ញោះ ដើម្បីឲ្យគេងសាយចេញមកច្បាំង គេងសាយក៏តាំងនៅមិនចេញសោះ, គៀងអ៊ុយនឹងហែកចំណាយចូលទៅក៏មិនបាន, ទើបឲ្យទាហានទៅកាត់ឈើ ជញ្ជូនសិលាមកតាំងបន្ទាយភ្ជាប់, ទាហានគេងសាយលើកចេញមកដេញវាយចាក់កាប់សម្លាប់ទា-ហានគៀងអ៊ុយរីករវេលាពលនឹងតាំងបន្ទាយក៏មិនបាន ក៏ថយទ័ពត្រឡប់ទៅបន្ទាយដើមវិញ លុះវេលាព្រឹកឡើង, គៀងអ៊ុយក៏លើកទាហានទៅតាំងបន្ទាយនៅក្បែរសៀងសាន់ បន្ទាយនៅធ្វើមិនទាន់ភ្ជាប់, លុះពេលយាមមួយយប់ គេងសាយក៏ឲ្យទាហាន ៥០០ យកឈ្នួនភ្លើងទៅដុតបន្ទាយនេះឡើងបាន ក៏ចូលវាយប្រកាប់ជ្រួលច្របល់ឡើង តាំងបន្ទាយក៏មិនបាន, ឯគៀងអ៊ុយក៏លើកទ័ពទៅ ហើយប្រឹក្សានឹងហៃហ្វ៊ីប៉ាថា យើងនឹងលើកទៅវាយស្រុកឡាំអាន់ឃើញនឹងមិនបានហើយ, យើងច្បាំងយកស្រុកសៀងបេងចុះ, ដើម្បីរកជាស្បៀងអាហារ វាយបានហើយនឹងបានជាកំឡាំង ស្រុកឡាំអាន់ក៏នឹងក្ខយបានដោយងាយ, នឹងលើកទៅវាយស្រុក សង់ថេង, ស្រុកនុះនុសព្រៃហើតាំងបន្ទាយនៅឲ្យម៉ាពី

បម្វាយ ឲ្យគេងងាយរកំងរវល់ក្រោយ, ថាហើយកៀងអ៊ុយក៏លើកទា-
ហានទៅទាំងពេលកណ្ដាលអធ្រាត្រនោះ, លុះព្រឹកក៏ស្រាងក្រឡេកឃើញ
ក្នុងជាប្រហាបទៀបគ្នាឆ្ងាយស្រយាលណាស់ ទើបសួរអ្នកនាំផ្លូវថា ក្នុងនោះ
ឈ្មោះអ្វី ? អ្នកនាំផ្លូវប្រាប់ថា ឈ្មោះក្នុងទនកោះ, កៀងអ៊ុយឮដូច្នោះក៏
ភ័យណាស់ ទើបនិយាយថា ក្នុងនេះជាទីបំណាប់ម៉ាំមួន ឈ្មោះសាំឡេង
កាកាចមិនល្អ; បើសត្រូវមកស្លាប់នៅផ្លូវដែលទឹងត្រឡប់ទៅ ឃើងទឹងមិន
លំបាកទេឬ ? ថាហើយក៏អស់អែកនៅទីនោះ, មានពួកកងល្បាតមក
ប្រាប់ថា ឃើញដូលីហ៊ុយគុយឡើងខាងក្រោយក្នុង ប្រហែលទឹងមាន
កងទ័ពលើកមក, កៀងអ៊ុយបានឮដូច្នោះក៏ថយទ័ពមកវិញ, ឯស៊ុនខេ
ទឹងគេងតងលើកទាហានចេញកាយខួចប្រសព្វមក, កៀងអ៊ុយក៏ច្បាំង
ក្មាងតេចយក្មាងបង្អង់ថយទៅ, ឯគេងងាយក៏លើកទ័ពកាយស្កាត់ទុក កង
ទ័ពទាំងពាក់យចម្រុះចូលមកព្រមគ្នា, ទាហានកៀងអ៊ុយក៏បែកខ្ញែក
ស្លាប់ជាច្រើន ទទួលហៃហ៊ូប៉ាលើកទ័ពមកកាយខួប់ពង្វាង ទ័ពគេង-
ងាយក៏ថយទៅ, កៀងអ៊ុយក៏ចេញទៅរកហៃហ៊ូប៉ានិយាយថា គាន់-
ថាយលើកទ័ពមកកាយបន្ទាយក្នុងគិសានថែកទៅហើយ ហ៊ុំនៅខាយទា-
ហានខាងឃើងក៏ស្លាប់; កងទ័ពក៏ត្រឡប់ថែករត់ទៅស្រុកហានតុងអស់
ហើយ, កៀងអ៊ុយឮដូច្នោះក៏ខាល់គិតមិនដឹងបើទឹងគិតការតទៅយ៉ាង
ណា ក៏ឲ្យបយទ័ពត្រឡប់ទៅតាមផ្លូវតូចក្បែរជើងភ្នំ, គេងងាយក៏លើក

ទ័ពដេញជិតតាម, គៀនអ៊ុយឲ្យកងទ័ពរាំងអស់ដើរទៅមុន, ខ្លួនឯង
នៅកាន់ពីក្រោយ, លុះលើកថយទៅដល់ក្បែរភ្នំ; គាត់ថាយបង្កប់
ទាហាននៅទីនោះ លុះឃើញកងទ័ពគៀនអ៊ុយលើកមក ក៏នាំទាហាន
ចេញវាយស្កាត់មុខ, ទាហានគេងរ៉ាយ, គាត់ថាយ ព័ទ្ធទ័ពគៀនអ៊ុយ
លើកមកនោះទុក សម្លាប់ទាហានគៀនអ៊ុយស្លាប់ជាច្រើន; ឯគៀនអ៊ុយ
ទិនងហែកចំលាយចេញទៅខាងច្រកណាក៏មិនបាន, ទៀវងីទាហាន
គៀនអ៊ុយលើកមកដល់បានឃើញដូច្នោះ ក៏នាំពលប្រហែល ៣០០ចូល
ចោមវាយជួយគៀនអ៊ុយ ៗ ក៏ចំលាយចេញទៅបាន; ទៀវងីត្រូវព្រួញ
ស្លាប់ក្នុងទីចម្បាំង គៀនអ៊ុយក៏នាំទាហានដែលសល់ពីស្លាប់នោះរត់ទៅ
ស្រុកហាន់តុង ហើយរឭកដល់គុណទៀវងីណាស់ ថាជាមនុស្សស័ក្តិ
ទៀនគ្រន់មានចិត្តស្វាមីភក្តិធ្វើការគោរពតែស្លាប់ខ្លួនក្នុងសង្គ្រាម ទើបឲ្យ
ផ្ទាទបំណាច់ដល់បុត្រភរិយាគេចៅចៅសន្តាន ហើយចាត់ចែងឈ្មោះ
អ្នកដែលធ្វើការបាន មកតាំងធ្វើជានាយទាហានជំនួសទៀវងី ។

( នៅមានត )

# រាជពង្សាវតារ

## តាមសាស្ត្រាស្លឹករឹតបានពីវត្តកោកកាក

លោក ឃួន-សែម ចម្លង

លោក លី-ធាម តេង ពិនិត្យផ្ទៀង

( ក )

ព្រះបាទចក្រពត្រាធិរាជ សោយរាជសម្បត្តិស្នងព្រះវររាជបិតា ស្ដេចមានអ្នកម្នាង ២ នាក់មានគភ៌ អ្នកម្នាង ម្នាក់តែទៅនៅបន្ទប់ប្រទេស ១ ខណៈនោះមានកស្ត្រីម្នាក់ ឈ្មោះ ដំបងគ្រញូង ក្បត់ដណ្ដើមរាជសម្បត្តិបានក៏ឲ្យហោរាទាយ ហោរាទាយថា ទិសមានអ្នកដ៏មានបុណ្យ នៅក្នុងផ្ទៃគ្រប់មួយខែ កើតឡើងដណ្ដើមរាជសម្បត្តិ ទើបពញាដំបងគ្រញូងឲ្យចាប់យកតែឈ្មោះស្រីផើមទៅកាប់សម្លាប់ទាំងអស់ នៅសល់តែអ្នកម្នាង ១ នាក់ ក្រោយនោះហោរាទាយថា អ្នកមានបុណ្យកើតឡើងហើយ ពញាដំបងគ្រញូងឲ្យចាប់ក្មេងក្នុងព្រះនគរ យកទៅដុតក្នុងភ្លើង ឯកូនក្មេងម្នាក់នោះ ដោយសារមានបុណ្យ ភ្លើងពេលលោកអស់ទាំងខ្លួនក៏ពុំស្លាប់ លុះព្រះសង្ឃនិមន្តទៅទ្រង់បិណ្ឌបាតឃើញ រើសយកទៅចិញ្ចឹមរក្សាទុកឲ្យ ឈ្មោះហៅថា ចៅកិល ដ្បិតភ្លើងពេលញ្ញៀដៃញ្ញោះជើង លុះបានដល់អាយុ ១៧ ឆ្នាំឡើង ទើបហោរាទាយថា អ្នកមានបុណ្យនឹងមកដល់ថ្ងៃនេះហើយ អស់រាស្ត្រប្រជាក្នុងនគរ ក៏ឮហោរាទាយថាដូច្នោះ ទើបនាំគ្នាមើលនោះ [illegible]

អ្នកមានបុណ្យ ឯពញាដំបងក្រញូង ថាបើអ្នកមានបុណ្យដើរចូលមក ទឹងតយុទ្ធា សេះហោះលើអាកាសមកទឹងចេញទៅ ឯទៅកិលក្មេងនៅ ក្នុងវត្ត ដែលក្មេងកេលញ្ញដើងស្នាមផ្លែអស់ទាំងខ្លួននោះ លុះពួកអ្នកនគរ ផ្អើលទឹងអ្នកមានបុណ្យក៏កិលហួសចេញពីវត្ត ទៅរកមើលអ្នកមាន បុណ្យទឹងគេ ទើបសម្តេចព្រះឥន្ទ្រាធិរាជ ស្តេចហោះចុះមកក្លែងកាយជា តាចាស់ មានអាហារគ្រឿងប្រដាប់សំពាយ ស្ពាយហើយដឹកសេះតាមផ្លូវ មក ជួបទឹងក្មេងនោះកំពុងតែកិល ព្រះឥន្ទសួរថា ក្មេងនេះកិលទៅបាន ឯណា ក្មេងក៏ឆ្លើយប្រាប់ថាទៅមើលអ្នកមានបុណ្យ ព្រះឥន្ទថាទៅកាល ណាទឹងបានជល់បានឃើញ នៅទីនេះចុះតាទឹងផ្ញើសេះទឹងសម្ពាយក្បា ទុកឲ្យតាផង បើឃ្លានបាយយកបាយក្នុងសម្ពាយស៊ីចុះសឹមតាទៅមើល អ្នកមានបុណ្យហើយវិលមកវិញតានិយាយប្រាប់ឲ្យដឹង ក្មេងនោះក៏ទទួល សេះទឹងសម្ពាយទុកក្បា ព្រះឥន្ទក៏ទុកាសចេញទៅ ក្មេងនោះក៏យក បង្ហៀរសេះ មកចាក់នៅដៃសេះពាញស៊ីស្មៅក៏បានលា ដៃលាដើងរួចល្អ ហើយបង្អង់ ចាំមើលយល់តាចាស់បាត់យូរ ក៏ស្រាយសម្ពាយឃើញបាយ ស៊ីក៏មាននុជារស់អាហារទិព្វក៏មានកម្លាំង ឃើញខ្លួចប្រេងយកមកស្រឡាប លាបសព្វខ្លួនទៅក៏លោយរលុបស្នាមបាត់អស់ ខ្លួនល្អដូចមាស គិតថា អញនេះអ្នកមានបុណ្យពិតក៏ផ្លាស់សំពត់ចាស់ចោលចេញ ស្លៀកសំពត់ ទិព្វពាក់គ្រឿងទិព្វរួចស្រេច ក៏មានរូប នោះល្អដូចទេវតា ក៏ ឡើងជិះសេះ

ហោះទៅលើអាកាសចុះមកដល់ដំណាក់ដំបងគ្រញូង ចាប់ដំបងគ្រញូង
ក្រវែងពោលទៅខុសដំបងក៏ហួសទៅបាត់ ឯដំបងគ្រញូងក៏ភ័យខ្លាច
ខ្លួន រត់ចេញទៅនៅស្រុកឈារ ក៏អទិច្ចកម្មទៅ ទើបក្មេងដែលល្អជិះសេះ
ហោះមកនោះ នាមព្រះបាទព្រហ្មកិល ដែលហៅថាពញាក្រែកមកដល់
ត់ឡូវនេះស្តេចបានសោយរាជសម្បត្តិ ចុកេហ៍កតាំងឡាយថ្វាយព្រះនាម
ថាសម្តេចព្រះសទ្ធតអម្រិទ្ធ ពីកាលពញាដំបងគ្រញូងក្បត់ដណ្តើមរាជ
សម្បត្តិបាននោះ អ្នកម្នាងព្រះបាទចក្រពត្រារាជ ១ មានគភ៌រត់ទៅនៅ
បន្ទួប្រទេស សម្តពព្រះរាជបុត្រាមួយព្រះនាមពុំប្រាកដ លុះចម្រើនធំ
ឡើង មានម្នាង ១ មានគភ៌គ្រប់ខែដប់ក្នុងរាជសម្បត្តិ សម្តេចសទ្ធតអម្រិទ្ធ
ហើយព្រះរាជបុត្រាព្រះនាមពុំប្រាកដនោះសុគតទៅ ខណៈនោះសម្តេច
សម្ឋតអម្រិទ្ធ ឲ្យហោរាទំនាយតាយថា ទីនមានអ្នកមានបុណ្យពូជពង្ស
ក្សត្រក្នុងផ្ទៃគ្រប់ខែដប់ហើយ បើកើតឡើងនឹងដណ្តើមរាជសម្បត្តិ ស្តេច
ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់ប្រើឲ្យចាប់ស្រីផើមយកទៅកាប់សម្លាប់បង់
ទើបពេជ្ឈឃាដចាប់ស្រីផើមកាប់ចេញតាំងអ្នកម្នាង ដែលនៅបន្ទួប្រទេស
នោះ មានគភ៌គ្រប់ខែដប់យកមកកាប់សម្លាប់ កាប់កម្លួងកំណាត់ កាប់
ពោះមួយកំណាត់ ហើយពោលគណ្តាលកល កាលកាប់ពោះបុត្រនោះ
ប្រាវចេកទៅដើមទ្រូង លុះពេជ្ឈឃាដទៅហើយបុត្រក៏ធ្លាក់ចុះមកដល់នា
ផណើ មានបក្សីតាគមួយមកពបាំងក្លាកនោះក្រៀកក ដៃផ្លូវទៀប

ខណៈនោះមានអ្នកគង្វាលម្នាក់ឈ្មោះ តាគៈហ ដើរទៅឃើញ រើសយក
ចិញ្ចឹមជាបុត្រ តែងតែដឹកដៃចញ្ចិះកយកទៅឃ្វាលគោផង នាកាលមួយថ្ងៃ
តាគហេ ដេញគោទៅធ្លាក់ដំបងរកពុំឃើញ លុះថ្ងៃឯក្រោយ ដែលមាន
ហេតុនៅទីនោះក្តី ដើរដល់ទីនោះក្តីក៏ហៅថាបាត់ដំបង សព្វថ្ងៃហៅស្រុក
បាត់ដំបង ឯកុមារនោះប្រកបដោយបញ្ញាទិការបារមី ស្រដីថាអ្វី ១- ក៏ប្រ
កបដោយផ្លូវបោះបាន បាតដៃបាតជើងទាំងសងខាង មានហេតុជាលាយ
លក្ខណ៍កងចក្រ អស់មនុស្សស្រឡាញ់ចុះចូលទៅផង សន្មតហៅថា
បក្សីចាំក្រុង អាយុបាន ១៧ ឆ្នាំ ឡើងហើយ កាលនោះសម្តេចសន្តព
អម្រិនទ្រង់ជ្រាបហើយ ហោរាទាយថាអ្នកមានបុណ្យកើតឡើងហើយ
អាយុបាន ១៦ ឆ្នាំ មានហេតុជាលាយលក្ខណ៍កងចក្រ នៅបាតដៃបាតជើង
នៅរស់នៅ ស្តេចគិតកែងនឹងចាប់សម្លាប់ ឲ្យយកម្សៅទៅរោយបង្អួរហើយ
ឲ្យមកក្មួនក្មេងក្នុងផែនព្រះនគរទាំងអស់ ឲ្យលាបាតដៃព្រាបម្សៅនោះ
គ្រានោះព្រះពជា តម្រាស់គ្រាស់ឲ្យទៅហៅបក្សីចាំក្រុងទាំងតាគហេមក
ផង លុះបក្សីចាំក្រុងទៅព្រាបម្សៅ ឃើញស្នាមលាយលក្ខណ៍ជាកងចក្រ
ប្រាកដ ទើបអ្នកទាំងពួងកំពុងតែធោះឡា មើលស្នាមនៅម្សៅនោះ
តាគហេធក់ពបក្សីចាំក្រុង នាំរត់រួចចេញទៅ ឯសម្តេចសន្ធរ អម្រិនទ្រង់
ជ្រាបហើយ ក៏លើកទ័ពតាមចាប់តាគហេនាំបក្សីចាំក្រុងរត់មកដល់ស្រុក
បាត់ដំបង ហួសទន្លេមកដល់ខែត្រដើងព្រៃឈប់ដេក ១ យប់ផ្សងបុណ្យពុំ

ឲ្យមានមូសក៏គ្មានមូស បានជាហៅថា តាគហៅនៅទីនោះ មកដល់បច្ចុប្បន្ន នេះ ក៏គ្មានមូសនៅទីនោះឡើយ វេលាព្រឹកឡើង ក៏ហួសទៅដល់មាត់ ទន្លេធំ រកខូកនឹងខ្លួនគ្នា ឃើញដើមរកាមួយនៅច្រាំងទន្លេខាងកាយ ដើមល្ហុងមួយនៅខាងនាយ បក្សីតាំក្រុងបង្គាប់ថាដើមរកាកោងទៅ ដើមល្ហុងទេរមកឯដើមឈើទាំងពីរនៅត្រើយទន្លេទាំងសងខាង ក៏កោងទេរមកបាន ដើរឆ្លងរួចទៅ បានជាហៅថា រកាកោងល្ហុងទេរ ដល់មកសព្វថ្ងៃនេះ លុះ ដើរទៅដល់ប្រឡប់ឆ្នេរបឹងមួយ តាគហៅកាប់មែកជ្រៃមកដោតធ្វើជាម្លប់ឈប់ ប្រាស្រ័យ បក្សីតាំក្រុងក៏និទ្រាលក់ កាលនោះមានហ្វូងសត្វច្រើនបុះមក ស៊ីអាហារនៅស្លឹកត្រពាំងនោះ ផ្អើលហើរឡើងសន្ធឹកជាខ្លាំង ឯតាគហៅ ឮស័ព្ទក្ដុកផ្លូវទោះហើយក៏ស្មានថាជាកងទ័ពគេលើកមកតាម ក៏ដាស់បក្សីតាំ ក្រុងក្រោកឡើងភ័យណាស់សួរតាគហៅ ហើយរកពុំឃើញកងទ័ព ក៏ទឹង ថាបើបានសោយរាជសម្បត្តិកាលណា ទឹងសម្លាប់តារួចហើយ សឹមធ្វើ បុណ្យ ឯទីទួលនោះហៅថា ព្រះវិហារសួរ ដោយបក្សីតាំក្រុងសួរតាគហៅ ឯមែកជ្រៃដែលដោតជាម្លប់ស្របឈប់ប្រាស្រ័យនោះ ក៏រស់កើតជាដើម ជ្រៃ មានប្រផ្លូលមកដល់បច្ចុប្បន្ននេះសព្វថ្ងៃ ឯកងទ័ពលើកតាមទៅទាន់ តាគហៅក៏នាំបក្សីតាំក្រុងមកដល់ទីគោក មានស្រះដុះដើមឈូកជាច្រើន ចូលពួនក្នុងស្រះ យកស្លឹកឈូកគ្របសិរសា ទើបកងទ័ពលើកទៅដល់ទី គោកនោះក៏រកពុំឃើញ ហោកក្តុះទៅថានៅពួនក្នុងស្រះ កងទ័ពក៏បរដុះ

បញ្ញាន់ ដំរីដើរទៅជិតឈូកដែលពួន ក៏ជៀសចេញ គង់ទ័ពគេពុំឃើញ បានឈ្មោះហៅថា គោកបញ្ញាន់ សព្វថ្ងៃនេះ   គាត់ហែនាំគេទៅទៀត ដល់ទៅទួលមួយប្រទះឃើញស្រីក្រមុំម្នាក់ចេញដងទឹក បក្សីចាំក្រុង ចាប់ចិត្តប្រតិព័ទ្ធ ទើបស្រីក្រមុំនោះ បានឈ្មោះហៅថាភូមិប្រទះនាង គាត់ហែនាំគេឡើង ទៅដល់ព្រៃទួល ១ ឃ្លានបាយដេះផ្ទុំដើមចារគោគ ព្រៃហៅថា ព្រៃទុំដើមសព្វថ្ងៃនេះ   ហើយគាត់ហែនាំគេទៅបាត់នៅវាល ១ នោះអស់ពួកគង់ទ័ព ធ្វើនាស់កស់រកពុំឃើញ បានជាឈ្មោះហៅថាវាល ចង្រាស់ ហើយគេទៅពួនក្នុងគុហា ១ នៅភូមិប្រសិទ្ធិ ខណៈសម្ដេចសន្ធពអម្រិនអផ្សុក ក៏សុគតទៅ ពុំមានក្សត្រទីណាសោយរាជសម្បត្តិឡើយ ទើបអស់មុខមន្ត្រី ឲ្យមកតាមអញ្ជើញបក្សីចាំក្រុងយកទៅសោយរាជសម្បត្តិ ថ្វាយព្រះនាមថាព្រះបាទសម្ដេចបក្សីចាំក្រុង   ហើយស្ដេចវិលមកសាងគុហានៅភូមិប្រសិទ្ធិនោះ សរសេរស្លាកទីងំទុកថា ឈ្មោះអញបណ្ដាញសម្ដេចរាជបក្សីចាំក្រុង   ឯគាត់ហែស្ដេចឲ្យសម្លាប់ហើយធ្វើបុណ្យជាឧទ្ទិក ប្រេចស្ដេចទៅសាងវត្តព្រះវិហារសួគ៌ ១ វាលគោកបញ្ញាន់ ១ ឯស្រីក្រមុំដែលសម្ដេចបក្សីចាំក្រុងមានចិត្តប្រតិព័ទ្ធកាលគេនោះ ទ្រង់ឲ្យយកទៅ ធ្វើជាម្ចាស់ស្ដេច កើតព្រះរាជបុត្រនោះ ៣ ព្រះអង្គ ព្រះនាមព្រះវត្តិរាជ ១ ព្រះអង្សសរាជ ១ ព្រះសេណក្ខ ១ លុះគេគទីងព្រះបាទបក្សីចាំក្រុង សុវណ្ណគតៈទៅ ព្រះរាជបុត្រទាំង ៣ ព្រះអង្គ បានសោយរាជសម្បត្តិ មកដល់រាជ

សម្បត្តិព្រះសេណកុករាជជាអនុរាជទៅ ស្ដេចមានព្រះរាជបុត្រ ១ ព្រះអង្គព្រះនាមសីហរាជកុមារ ចិញ្ចឹមសត្វរុយខៀវ ១ ដាក់ក្នុងប្រអប់កែវទើបមានកូនបុរោហិតចិញ្ចឹមពីងពាង ទៀត ៩ តែងកាន់លេងជាមួយនឹងព្រះសីហរាជកុមារជាប្រក្រតី នាកាល ១ ថ្ងៃរាជកុមារបើកសត្វរុយខៀវលេង ពីងពាងកូនបុរោហិតនាំរុយខៀវស្លាប់ ឯព្រះបាទសីហរាជកុមារឃើញហើយ គិតនឹងស្ដាយរុយខៀវក៏សោកាខ្លាំងក្រៃ លុះជ្រាបដល់ព្រះបាទ សេណកុករាជជាព្រះរាជបិតា ក៏ទ្រង់ព្រះក្រោធមហិមាពុំពិចារណាក្នុងធម៌ដោយស្នេហាចំពោះ ព្រះរាជបុត្រ ក៏ឲ្យចាប់កូនបុរោហិតនោះយកទៅដាក់ទ្រមុចទឹកស្រះសម្លាប់បង់ ឯបុរោហិតជាឪពុកនោះខឹងហើយក៏នាំបុត្រភរិយា រត់ចេញទៅនៅពីងប្រទេសឯទៀត កាលនោះជ្រាបដល់ស្ដេចនាគរាជទ្រង់ខ្ញាល់ ថាស្ដេចចិត្តអាក្រក់ ឥតពិចារណា កាលពីមុនអញឲ្យមន្ត្រីឡើងមកគាល់ផ្សិតជាកូនចៅព្រះបាទនាងនាគជាកូនចៅគញ ក៏សម្លាប់មន្ត្រីអញ អញមិនយកទោសឥឡូវពីព្រោះតែរុយខៀវ ១ ឲ្យសម្លាប់មនុស្សម្នាក់ ស្ដេចនាគសំដែងឫទ្ធិបារមី ឲ្យទឹកផុសឡើងសាយពាសពេញក្នុងព្រះរាជវាំង អស់មនុស្សម្នាប្រជាជនផងលិចលង់ទឹកស្លាប់ក៏ច្រើន ព្រះបាទសេណកុករាជ ក៏សុគតទៅ សល់នៅតែអ្នកដែននៅលើផ្ទះ លើទូក មហាថេរ ១ អង្គ នឹងពួកអ្នករក្សាព្រះកែវមរកត ក៏ចប្ចូលគ្នាលើកយកព្រះកែវមរកតនឹងព្រះបដកចម្ដាក់ក្នុងសំពៅ នាំយកទៅស្រុកលើ ១ណា : នោះ

មានមហាក្សត្រមួយអង្គ សោយរាជសម្បត្តិ នៅក្រុងស្រីអយុធ្យាព្រះនាម ព្រះបាទភាទិកត្យជ ទ្រង់ជ្រាបថាក្រុងកម្ពុជាឥន្ទបត្តនគរ ទឹកឌុសឡើង លិចក្រុងខូចខាតបង់ ព្រះកែវមរកត និងព្រះបដិកធម្ម ទើបស្ដេចលើក ពលសកលយោធា ជាព្យុហៈ ចូលមកដល់ដែនក្រុងកម្ពុជាធិបតី ឥន្ទបត្ត នគរ ទើបសួរគេព្រះកែវមរកត និងព្រះបដកកម្មឃើញ ស្ដេចឲ្យបាច់តាំង ស្រ័គ្របក្បួនអ្នកកេក្យាព្រះកែវមរកតនិងព្រះបដកធម្ម វិលត្រឡប់ចូលទៅ ក្រុងស្រីអយុធ្យាអញ្ជើញព្រះកែវមរកត និងព្រះបដកកម្មឡើងប្រតិស្ឋានទុក ដោយវិសមគ្គ ហើយធ្វើសក្ការៈបូជា គេក្យាប្រណិតគ័ន៍ជាប្រក្រតីទៅ កុង ក្រុងស្រីអយុធ្យា កំសុខសប្បាយ គេរួមក្សាន្ត ថ្កើងរុងរឿង ពីព្រះសា សនាពីនោះរៀងមក ឯទឹកដែលឡើងលិចក្រុងកម្ពុជា ឥន្ទបត្តនគរ ក៏ ស្រកអស់ទៅ ឯព្រះបាទសីហរាជស្ដេចបានសោយរាជសម្បត្តិ ស្នងព្រះវរ រាជបិតា ស្ដេចមានព្រះរាជបុត្រី ១ អង្គនាមពុំប្រាកដ ។ ខណៈនោះមាន បុរសម្នាក់ធ្វើចំការដាំត្រសក់ផ្អែម កែងបេះផ្លែត្រសក់នាំក្រាបទូលថ្វាយ ព្រះបាទសីហរាជទ្រង់សព្វព្រះរាជហឫទ័យណាស់ ទើបស្ដេចព្រះរាជតាន លំពងជ័យ ១ ហៅថានាយត្រសក់ផ្អែម ហើយទ្រង់ព្រះរាជតានអំណាច ផង ថាបើនរណាទៅលួចបេះផ្លែត្រសក់នោះសម្លាប់ចុះ ឯនាយត្រសក់ផ្អែម ពុំបានដេក តែងដើររាំងមើល ទៅឃើញស្នាមជាជាហោ តាំងផ្ដាសក៏ចាប់ លំពែងចាក់ទៅត្រូវត្រង់ព្រះជន្មស្ដេច ទើបអគ្គមហាសេនា សេនាបតីមុខ

មន្ត្រីផងទាំងពួងជំនុំគ្នាថា គ្មានក្សត្រទីនសោយរាជសម្បត្តិ ឃើញតែនាយ
ត្រសក់ផ្អែមមានបុណ្យអស្ចារ្យ ក៏ព្រមគ្នាអញ្ជើញនាយត្រសក់ផ្អែមមកផ្សំ
នឹងព្រះរាជបុត្រីព្រះបាទរាជសីហរាជ នោះឲ្យសោយរាជសម្បត្តិថ្វាយព្រះ
នាមជាព្រះបាទ មហាបពិត្រធម្មិករាជាធិរាជជាម្ចាស់ផែនដីក្រុងកម្ពុជាធិបតី
អភិសេកព្រះរាជបុត្រីនោះឡើងជាព្រះអគ្គមហេសី ស្ដេចបង្កើតបុត្រាបុត្រី
ព្រះរាជនេត្តា ព្រះរាជនត្តា បានសោយរាជសម្បត្តិតព្រះរាជវង្ស ត្រកូលព្រះ
នគរកំសុខសប្បាយអាណាប្រជាជន ធ្វើស្រែចំការកើត មកដល់ព្រះបរម
និព្វាន បុត្រជាព្រះរៀមព្រះសិទ្ធានរាជា ជាព្រះអនុជ ១ មហាសករាជ
១៣១៦ ឆ្នាំ ជូតឆស័កនោះ ចុល្លសករាជ ៧៤៦ ព្រះបរមនិព្វានបុត្រ
កាលប្រសូតឆ្នាំរកាចត្វាស័ក លុះព្រះជន្ម ៥៣ វស្សាឡើងសោយរាជ
សម្បត្តិ ទទួលព្រះរាជឧក្កាតព្រះរាជវង្សមកតីកាលព្រះជន្ម ៣៨ វស្សា
ពុំទាន់សោយរាជ្យនោះ ឆ្នាំឆ្លូវបញ្ចស័កស្ដេចមានព្រះរាជបុត្រា ១ ព្រះអង្គ
ព្រះនាមព្រះស្រីសុរិយោទ័យ ឯបរមនិព្វានបុត្រ ស្ដេចសោយរាជសម្បត្តិ
បាន ៤ ព្រះវស្សា ព្រះជន្ម ៥៧ វស្សា ក៏សុវណ្ណគតទៅ មហាសករាជ
១៣២១ ឆ្នាំម្សាញ់ឯកស័ក ព្រះសិទ្ធានរាជា កាលសម្ពតឆ្នាំខាលសំរិទ្ធិ.
ស័ក ព្រះជន្មបាន ៥២ ព្រះវស្សា ឡើងសោយរាជសម្បត្តិទទួលព្រះរាជ
ឧក្កាស្នងព្រះរៀម ពីកាលព្រះជន្ម ២៦ ព្រះវស្សាពុំទាន់សោយរាជ
សម្បត្តិនោះ ឆ្នាំថោះបញ្ចស័ក ស្ដេចមានព្រះរាជបុត្រា ១ ព្រះអង្គព្រះនាម

ព្រះលំពង់រាជា ឯព្រះសត្ថានរាជា ស្ដេចសោយរាជសម្បត្តិបាន ៣ ខែ ក៏សុវណ្ណគតទៅ ទើបព្រះលំពង់រាជាព្រះជន្មបាន ៦៧ វស្សាឡើងសោយរាជសម្បត្តិទទួលព្រះរាជឱង្ការស្នងព្រះវររាជបិតា ពីកាលព្រះជន្ម ២២ ព្រះវស្សានោះឆ្នាំជូតអដ្ឋស័ក ស្ដេចបានព្រះរាជបុត្រា ១ ព្រះអង្គ ព្រះនាមព្រះបរមរាមានៅឆ្នាំថោះនពស័ក ស្ដេចមានព្រះរាជបុត្រា ១ ទៀត ព្រះនាមព្រះធម្មសោករាជ ឯព្រះលំពង់រាជាសោយរាជ្យបាន ៣ ព្រះវស្សា ព្រះជន្ម ២៨ព្រះវស្សាក៏សុវណ្ណគតទៅ មហាសករាជ ១៣១៤ ឆ្នាំរកចត្វាស័កព្រះស្រីសុរិយោទ័យ ព្រះជន្មបាន ២០ ព្រះវស្សា ឡើងគ្រងរាជសម្បត្តិស្នងសម្ដេចព្រះរៀមព្រះអយ្យកោ នៅពុំទាន់អភិសេក ខណៈនោះព្រះចៅឧថោងរាមាធិបតី ក្រុងស្រីអយុធ្យាទើបលើកទ័ពមកវាយបែកព្រះរាជវាំងមហានគរវត្ត នោះព្រះស្រីសុរិយោទ័យ នាំគ្រប់គ្រួចូលទៅពឹងក្រុងស៊ីសតនាគនហុត ឯព្រះបរមរាមាទៅ ប្រាស្រ័យនៅខេត្របាសាក់ ព្រះធម្មសោករាជនៅប្រាស្រ័យនៅស្រុកត្រាំង ទើបព្រះចៅអូថោង តាំងព្រះរាជបុត្រាព្រះនាមព្រះចៅបាសាក់ ឲ្យសោយរាជសម្បត្តិ នៅបរមរាជវាំងមហានគរវត្តបានតែ ៣ ព្រះវស្សាក៏សុវណ្ណគតទៅ នោះព្រះចៅអ៊ូខបង្អស់ឡើងសោយរាជសម្បត្តិ ស្នងសម្ដេចព្រះរៀមបាន ៣ ខែ ក៏សុវណ្ណគត់ទៅទៀត ព្រះចៅកំបង់ពិសីឡើងសោយរាជសម្បត្តិ ស្នងព្រះវររាជបិតាបាន ១ ខែ ខណៈនោះព្រះបរមរាជនឹងព្រះធម្មសោករាជលើកទ័ពវិលមក

បង្គាំង ទីនដណ្ដើមរាជសម្បត្តិវិញ ឯព្រះចៅអូរថោងនៅក្រុងស្រីអយុធ្យា ទ្រង់ជ្រាបថាខ្មែរប្រែគំនិត គិតថាទីងទ្រាំឲ្យរាជត្រកូលសៀមនៅក្រុងព្រះរាជវាំង មហានគរវត្តពុំបាន ក៏លើកទ័ពមកទទួលព្រះចៅកំបង់ពិសីជាព្រះរាជនត្តា ដាក់គេកៀរគ្រួ ៩ ម៉ឺនយកទៅផង ទើបព្រះស្រីសុរិយោទ័យ ចេញពីក្រុងស្រីសតនាគនហុត យកប្រាលប្រាបបានខេត្រនគររាជសីមា ហើយទើបលើកទ័ពតាមទៅច្បាំងដណ្ដើមយកបានគ្រួ ៩០ ម៉ឺនមកវិញ នោះ ស្ដេចឲ្យទៅទទួលយកគ្រប់គ្រួ ពីស្រីសតនាគនហុតមកនៅបរមរាជវាំងមហានគរវត្តវិញ មហាសករាជ ១៣១៨ ឆ្នាំជូតអដ្ឋស័ក ព្រះស្រីសុរិ-យោទ័យព្រះជន្មបាន ២៤ ព្រះវស្សា ស្ដេចប្រាប្ដាភិសេកសោយរាជសម្បត្តិ ក៏ទទួលព្រះរាជនុក្ការក្នុងឆ្នាំជូតអដ្ឋស័កនោះ ស្ដេចមានព្រះរាជបុត្រា ១ ព្រះអង្គ ព្រះនាមហៅព្រះស្រីសុរិយោវង្ស ឯព្រះស្រីសុរិយោទ័យស្ដេចសោយរាជសម្បត្តិបាន ៨ ព្រះវស្សា ព្រះជន្មបាន ៣២ ក៏សុវណ្ណគតទៅ មហាសករាជ ១៣២៦ ឆ្នាំរោងឆស័ក ព្រះបរមរាមាព្រះជន្មបាន ២១ ព្រះវស្សា ឡើងសោយរាជសម្បត្តិស្នងព្រះបិតុលាបាន ១០ ព្រះវស្សា ព្រះជន្មបាន ៣០ ព្រះវស្សា ក៏សុវណ្ណគតទៅ មហាសករាជ ១៣៣៦ ឆ្នាំមមីឆស័ក ព្រះធម្មសោករាជព្រះជន្មបាន ២៨ ព្រះវស្សា ឡើងសោយរាជសម្បត្តិ ទទួលព្រះរាជនុក្ការ ស្នងសម្ដេចព្រះរៀមហើយ លើកកងទ័ពទៅវាយស្រុកចំប៉ា ស្រុកជាប៉ុរី បានគ្រួ ៨ ពាន់ វិលមកព្រះរាជវាំង

មហានគរវិញ ស្ដេចមានព្រះរាជបុត្រា ១ ព្រះអង្គ ព្រះនាមព្រះបរមសោករាជ ១ ខណៈនោះចៅថាងឡួន ក្រុងស្រីអយុធ្យា លើកទ័ពមកច្បាំងក៏បរាជ័យចាញ់ កៀរយកតែគ្រួស្រុកចន្ទបុរី ស្រុកជលបុរីវិលទៅក្រុងស្រុកអយុធ្យាវិញ ឯព្រះធម្មាសោករាជស្ដេចសោយរាជសម្បត្តិបាន ២៨ ព្រះវស្សា ព្រះជន្មបាន ៥៥ ព្រះវស្សា ក៏សុរណ្ណគតទៅ ទើបព្រះស្រីសុរិយោវង្ស ព្រះជន្ម ៤៧ វស្សាឡើងសោយរាជសម្បត្តិ ទទួលព្រះរាជនុក្ការស្នងព្រះរៀមព្រះអយ្យកោខ្លួននោះ ពីកាលព្រះជន្ម ៤២ វស្សា នៅឆ្នាំមមីសំរិទ្ធិស័ក ស្ដេចមានព្រះរាជបុត្រា ១ ព្រះអង្គ ព្រះនាមចៅចៅពញាយក់ ឯសម្ដេចព្រះស្រីសុរិយោវង្ស ស្ដេចសោយរាជសម្បត្តិបាន ១៣ វស្សាព្រះជន្មបាន ៥៩ វស្សា ក៏សុរណ្ណគតទៅ មហាសករាជ ១៣៧៧ ឆ្នាំកុរសប្តស័ក ព្រះបរមសោករាជព្រះជន្មបាន ២៩ វស្សាឡើងសោយរាជសម្បត្តិ ទទួលព្រះរាជនុក្ការស្នង ព្រះបិតុលាខ្លួន ឯសម្ដេចព្រះសោករាជ សោយរាជសម្បត្តិបាន ៣ ព្រះវស្សា ព្រះជន្មបាន ៣១ ព្រះវស្សា គ្រានោះព្រះចៅបរមរាជាក្រុងស្រីអយុធ្យា លើកទ័ពមកព័យព្រះបរមសោករាជ នៅក្នុងមហានគរវត្តតាំងអស់ ៧ ខែ នោះពញាកែវនឹងពញាទ័យជាមន្ត្រីចូលនាំគំនិតនឹងសៀម លុះក៏សម្ដេចព្រះបរមសោករាជក្ស័យព្រះជន្មទៅ ឯពញាយក់ស្ដេចដោះរួចទៅនៅក្នុងដែនលាវ ទើបព្រះចៅបរមរាជា អភិសេកពញាកែវជាព្រះរាជបុត្រា តាំងព្រះនាមចៅជា

ព្រះចៅឥន្ទរាជាឲ្យសោយរាជសម្បត្តិ នៅបរមរាជវាំងមហានគរវត្ត ហើយ
ព្រះចៅបរមរាជា យកទាំងរូបព្រះគោ រូបសិង្ហ រូបសត្វទាំងពួង ពីមហានគរ
វត្តចូលទៅក្រុងស្រីអយុធ្យា ឯព្រះចៅឥន្ទរាជាសោយរាជសម្បត្តិ នៅព្រះ
បរមរាជវាំងមហានគរវត្ត បាន ៥ ខែ នោះចៅពញាយក់សម្ដេចឲ្យមហា
ត ២ នាក់លុកព្រះចៅឥន្ទរាជា ក្ស័យព្រះជន្មទៅហើយ ចៅពញាយក់វិល
មកគង់នៅបរមរាជវាំងមហានគរវត្តវិញ ចៅពញាយក់ព្រះជន្មបាន ២១ ព្រះ
វស្សា ស្ដេចបានខត្តមណ្ឌលសីមាក្រុងរាជសម្បត្តិ នៅពុំទាន់អភិសេក
បាន ១០ វស្សា ព្រះជន្មបាន ៣០ ព្រះវស្សា មហាសករាជឆ្នាំជូតសំរិទ្ធិ
ស័ក ចៅពញាយក់ស្ដេចប្រាប្ដាភិសេកសោយរាជសម្បត្តិទទួលព្រះរាជ
ទង្គារ ទ្រង់នាមហៅព្រះបាទសម្ដេចព្រះបរមរាជាធិរាជាធិបតី សិរីសុរិយោ
ពណ៌ធម្មិករាជាធិរាជបរមបពិត្រ ជាបរមរាជវាំងមហានគរវត្ត ស្ដេចមាន
ម្នាងម្នាក់ឈ្មោះអ្នកម្នាងស្រីសៀម ជាកូនឃុនសុងព្រះឥន្ទ កុងឆ្នាំថោះត្រី
ស័ក អ្នកម្នាងស្រីសៀម សម្ភពព្រះរាជបុត្រា ១ ព្រះអង្គ ព្រះនាមហៅ
ព្រះនា យណ៍រាមា ហើយស្ដេចព្រះតម្រាស់ នោះនាម៉ឺនមុខមន្ត្រីធំតូចជា
បរមរាជវាំងមហានគរវត្តនោះខេត្តសៀម ៗ គឺតែងយាយីជាទុក្ខបំបាក
អស់ការណាប្រជានុរាស្ត្រទស្សនាការ ទើបលើកគ្រប់គ្រួទៅសាងព្រះរាជវាំង
គង់ឯប្រាសាទកុងខែត្រស្រីសន្ធរ កាលនោះមហាសករាជ ១៣៩៣ ឆ្នាំ
ថោះត្រីស័ក សម្ដេចព្រះបរមរាជាធិរាជាធិបតី ស្ដេចលើកអស់គ្រួ

គ្រួ ព្រះរាជដំណើរ ចេញពោលទីព្រះបរមរាជវាំងមហានគរវត្ត មកសាង ព្រះរាជវាំង នៅភូមិបាសាណក្នុងខេត្តស្រីសន្ធរ គង់បាន ៩ ព្រះវស្សា មក ដល់ឆ្នាំជូតទោស័ក ស្ដេចលើកអស់គ្រប់គ្រូព្រះរាជដំណើរចេញចាកទីព្រះ រាជវាំងបាសាណមកសាងព្រះរាជវាំង ប្របមាត់ទន្លេចតុមុខក្រុងពេញគង់នៅ បរមសុខស្ដេចមានម្នាងម្នាក់ទៀត ឈ្មោះអ្នកម្នាងចន្ទ មកដល់ឆ្នាំចទោស័ក អ្នកម្នាងចន្ទសម្ពព្រះរាជបុត្រា ១ អង្គ ព្រះនាមហៅព្រះស្រីរាជាមកដល់ ឆ្នាំកុរត្រីស័ក អ្នកម្នាងស្រីសៀមសម្ពព្រះរាជបុត្រា ១ អង្គទៀត ព្រះនាម ហៅពញាធម្មរាជា ឯសម្ដេចព្រះបរមរាជាធិរាជរាមាធិបតី ស្ដេចមក គង់ព្រះរាជវាំងក្រុងពេញ បាន ៣៨ ព្រះវស្សាទៀត សិរីទាំងគ្រងទាំងសោយរាជ សម្បត្តិបាន ៦០ ព្រះវស្សា ស្ដេចបន្ទូររាជសម្បត្តិ ឲ្យទៅព្រះនាកយណ៌ កមាជាព្រះរាជបុត្រច្បង ព្រះនាកយណ៌កមាព្រះជន្មបាន ២៧ ព្រះវស្សា សោយរាជសម្បត្តិទទួលព្រះរាជនាម ទ្រង់ព្រះនាមហៅព្រះបាទសម្ដេច ព្រះនាកយណ៌កមាធិបតីសុរិយោពណ៌ ធម្មិកមហារាជាបរមបពិត្រគង់ ក្នុងព្រះរាជវាំងចតុមុខក្រុងពេញ ស្ដេចមានម្នាងម្នាក់ឈ្មោះអ្នកម្នាងកែវតីកាល ពុំទាន់សោយរាជសម្បត្តិព្រះជន្ម ២៧ ឆ្នាំ ម្សាញ់ឯកស័កនោះ អ្នកម្នាងកែវ សម្ពព្រះរាជបុត្រា ១ ព្រះអង្គព្រះនាមហៅ ព្រះស្រីសុរិយោទ័យ ឯសម្ដេច ព្រះបរមរាជាធិរាជស្ដេចព្រះរាជបិតា ស្ដេចគង់នៅជាព្រះឧភយោរាជ បាន ៤ ព្រះវស្សាទៀតព្រះជន្មបាន ៩៦ ព្រះវស្សាក៏សោយសុគតិវាល័យទៅ ឯ

សម្តេចព្រះនារាយណ៍រាមាធិបតី សោយរាជសម្បត្តិបាន៥ព្រះវស្សាព្រះជន្មបាន៤១វស្សា ក៏សុវណ្ណគតទៅ មហាសករាជ១៤៤៣ឆ្នាំម្សាញ់ត្រីស័កព្រះស្រីរាជាព្រះជន្មបាន៣២ព្រះវស្សាឡើងសោយរាជសម្បត្តិទទួលព្រះរាជទុក្ខាស្នេហ៍សម្តេចព្រះរាម ទ្រង់ព្រះនាមហៅសម្តេចព្រះរាជាធិរាជរាមាធិបតីបរមបពិត្រ ស្តេចមានម្នាងម្នាក់ឈ្មោះម្នាងកេសរ ពីកាលពុំទាន់សោយរាជសម្បត្តិនោះ នៅឆ្នាំថោះឯកស័កអ្នកម្នាងកេសរសម្រាលព្រះរាជបុត្រា១ព្រះអង្គព្រះនាមចៅពញាអុង ហើយស្តេចឲ្យចៅពញាធម្មរាជាអនុជពៅបញ្ចោលឈរគ្រងខេត្តមហានគរវត្តឯព្រះស្រីសុរិយោទ័យជាអគ្គនេយ្យាគិតផ្តួលរាជសម្បត្តិ សម្តេចព្រះស្រីរាជាធិរាជ ជាព្រះបិតុលាកើតច្បាំងនឹងគ្នា១ខណៈនោះ ព្រះចៅក្រុងស្រីអយុធ្យាលើកទ័ពមកវាយបានខែត្រចន្ទបុរីខែត្រមហានគរវត្ត នគរសីមា ហើយហួសមកចាប់សម្តេចព្រះស្រីរាជា និងព្រះសុរិយោទ័យទាំងគ្រប់គ្រួនាំចូលទៅក្រុងស្រីអយុធ្យាទុកតែនាយគង់នាយទ័ពសៀមឲ្យនៅរក្សាស្រុកកំពេញ ឯចៅពញាធម្ម-ជាថយពីខែត្រនគរវត្តទៅតាំងទ័ពនៅខេត្តបាភ្នំ ហើយលើកទ័ពមកច្បាំងដេញនាយគង់ទ័ពសៀមពីស្រុកកំពេញ រត់វិលចូលក្រុងស្រីអយុធ្យាវិញហើយ. ឬចគង់នៅព្រះរាជវាំងកំពេញ មហាសករាជ១៤៤៦ឆ្នាំវកនស័កចៅពញាធម្មរាជា ព្រះជន្មបាន៣៤ ព្រះវស្សាស្តេចឡើងសោយរាជសម្បត្តិ ទទួលព្រះរាជនុក្កាទ្រង់ព្រះនាមហៅព្រះបាទសម្តេចស្តេចព្រះរាជ

ឧត្ការព្រះមហាធម្មរាជាធិបតិន្ទ នរន្ទ្រនាថបរមបពិត្រ ហើយស្តេចយកព្រះវង្សធំជាព្រះរាជទេពី លើកឡើងជាអគ្គមហេសី ព្រះនាមហៅសម្តេចព្រះភគវតីស្រីទេពធីតា ពីកាលពុំទាន់សោយរាជសម្បត្តិនោះនៅឆ្នាំជូតអដ្ឋ-ស័កសម្តេចភគវតីស្រីទេពធីតាប្រសូតព្រះរាជបុត្រាមួយព្រះអង្គ ព្រះនាមហៅចៅពញាទាត់ លុះមកដល់ឆ្នាំខាលសំរឹទ្ធិស័ក សម្តេចព្រះភគវតីស្រីទេពធីតាប្រសូតព្រះរាជបុត្រា ១ អង្គទៀត ព្រះនាមហៅពញាចន្ទរាជា ឯសម្តេចព្រះស្រីរាជានិងព្រះស្រីសុរិយោទ័យ ដែលគង់នៅក្នុងក្រុងស្រីអ-យុធ្យានោះ នៅឆ្នាំខាលទោស័ក ព្រះស្រីសុរិយោទ័យដែលគង់នៅក្នុងក្រុងស្រីអយុធ្យានោះ នៅឆ្នាំខាលទោស័កព្រះស្រីសុរិយោទ័យ ព្រះជន្មបាន ៣៤ វស្សាក៏សុវណ្ណគតទៅ មកដល់ឆ្នាំរោងចត្វាស័កសម្តេចព្រះស្រីរាជាព្រះជន្មបាន ៤៤ វស្សាក៏សុវណ្ណគតទៅ នៅក្នុងស្រីអយុធ្យា ទើបសម្តេចព្រះមហាធម្មរាជាធិរាជ ក្នុងឆ្នាំរោងចត្វាស័កនោះស្តេចឲ្យទៅជាព្រះរាជមេត្រីនឹងព្រះចៅក្រុងស្រីអយុធ្យា សុំអស់គ្រប់គ្រឿងនិងព្រះសពសម្តេចព្រះរៀម ព្រះសពសម្តេចព្រះភគិនេយ្យា មកប្រជាប់ការបុណ្យថ្វាយព្រះភ្លើង ឯក្រុងកម្ពុជាធិបតី ឯចៅពញាអ៊ុងនោះព្រះចៅក្រុងស្រីអយុធ្យាទ្រង់ស្នេហាទុកជាព្រះរាជបុត្រ បើកឲ្យចេញមកតែពេលថ្វាយព្រះភ្លើង ហើយអញ្ជើញចៅពញាអ៊ុង ចូលទៅក្រុងស្រីអយុធ្យាវិញ ១ ខណៈនោះមានហ្វូងចោរនៅខេត្តសំរោងទង នាំសេណាល ១ គំពង់ ៣ ពាក្យមកក្រាបទូល

( នៅមានត )

៦

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤៤ ខែ មិថុនា

ព.ស. ២៥១៦ គ.ស. ១៩៧២

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : អ៊ុក - សាម៉ន

និពន្ធនាយក - អ្នករៀបចំ    លី ធាម តេង

គណៈកម្មការនិពន្ធ:

ព្រះពោធិវង្ស   ស្វូន–ហាយ

លោក ជល–ឆិក    អ្នកស្រី ពេជ–សល់

# បញ្ជីរឿង

អត្ថបទ　　　　　　　　　　　　　　　　　　　　ទំព័រ

## ១— ផ្នែកសាសនា :


១- ព្រះវិន័យជាបន្ទាត់ លោក ភ៉ន់-ជីន រៀបរៀង. . . . . . . ៣០៧

២ - ចតុរារិយសច្ច (ត) រៀបរៀងដោយ ព្រះភិក្ខុ ប៉ង-ខាត់ . . . . . ៣១៣


## ២— ផ្នែកអក្សរសាស្ត្រ :


៣- រឿងសាមកុក ( ត ) ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . . . ៣២២

៤- ពិធីបួងសួងសុំទឹកភ្លៀង លោក ជយ-ស៊ីជាត រៀបរៀង . . . . ៣៣៨

៥- វាពិច្ឆេទវិតារ សាស្ត្រាវត្តពោកកាក ( ត ) លោក ឃួន-សែប ចម្លង

ចេញពីស្លឹករឹត . . . . . . ៣៤២


---

## តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០៛០០ ។

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

# ព្រះវិន័យជាបន្ទាត់

## សូមធ្វើតាមវិន័យ កុំធ្វើតាមទម្លាប់

លោក វ៉ាន់ ឌីន រៀបរៀង

ពុទ្ធសាសនិកជនជាតិខ្មែរយើង មានការចេះ ដឹងច្រើន នូវធម៌វិន័យ ហើយប្រតិបត្តិរៀងរាល់ថ្ងៃ ។ ប៉ុន្តែនៅមានកន្លែងខ្លះ មិនបាន ពិនិត្យឲ្យបានដិតដល់ ដូចជារឿងប្រគេនបង្អែម និង បង្អាប និងរូបិយវត្ថុ ចំពោះបព្វជិតពុទ្ធសាសនា ។

រឿងទីមួយប្រគេនបង្អែមនិងបង្អាបនេះ ជារឿងដែលយើងគ្រប់រូប ធ្លាប់ដឹងមកហើយ ។ តែនៅខ្វះចន្លោះត្រង់រឿងប្រគេនភិក្ខុសង្ឃរួច ហើយ បើមាននរណាម្នាក់ចាប់ កាន់បង្អែមនិងបង្អាបនោះរៀបចំឲ្យស្រួល ដើម្បីប្រយោជន៍ភិក្ខុសង្ឃដដែល ៗ អ្នកដទៃទៀតដែលឃើញគេធ្វើយ៉ាង នោះតែងស្រែកប្រាប់ថា ប្រគេនសាថ្មីទៀតទៅ ។

រឿងទីពីរ រូបិយវត្ថុ « លុយ-កាក់ » ។ ចំពោះរឿងនេះ ភិក្ខុសង្ឃ គ្រប់វត្តអារាមមានការស្មុគស្មាញណាស់ក្នុងផ្លូវប្រតិបត្តិ ។ តែជាការ ងាយស្រួលនឹងប្រតិបត្តិណាស់ ចំពោះភិក្ខុសង្ឃដែលចេះចាំព្រះវិន័យ ត្រង់រូបិយសិក្ខាបទនេះ មិនមានការណ៍នាំឲ្យស្មុគស្មាញទេ ។

សូមពិនិត្យនូវរឿងទាំងពីរនេះឲ្យបានហ្មត់ចត់ តាមអត្ថាធិប្បាយបំភ្លឺដោយព្រះមហា គីម ប៊ុល ជាវិនយកោវិទ ដូចតទៅនេះ

## គួរប្រគេនទៀតឬទេ ?

ទេយ្យវត្ថុដែលភិក្ខុទទួលប្រគេនត្រឹមត្រូវ ប្រកបព្រមដោយអង្គ ៥ រួចហើយ បើអនុបសម្បន្ន(១) ចាប់ កាន់-ពាល់-ប៉ះ ទន្ទិច ឬ រៀបចំ ទុកដាក់ ដើម្បីប្រយោជន៍ដល់ភិក្ខុ មិនកាន់យកដើម្បីប្រយោជន៍ដល់ខ្លួនទេ ទេយ្យ-វត្ថុនោះមិនដាច់ពីការប្រគេនទេ គឺថា មិនបាច់ប្រគេនទៀត, ភិក្ខុឆាន់បានមិនខុសនឹងវិនយបញ្ញត្តិត្រង់ទន្តពោណសិក្ខាបទឡើយ ។ បើវត្ថុនោះអនុបសម្បន្នកាន់យកដើម្បីប្រយោជន៍ដល់ខ្លួន ទើបដាច់ប្រគេន ។

ការដាច់ពីការប្រគេននោះ ប្រកបដោយហេតុ ៧ យ៉ាង

១- **លិង្គបរិវត្តនេន** ក្លាយភេទ គឺភិក្ខុក្លាយខ្លួនទៅជាស្ត្រី ។

២- **កាលកិរិយាយ** ភិក្ខុម្ចាស់របស់ធ្វើមរណកាល ។

៣- **សិក្ខំ បច្ចក្ខានេន** ភិក្ខុពោលលាសិក្ខា (សឹក) ។

៤- **ហីនាយាវត្តនេន** ភិក្ខុប្រែរូបទៅកាន់ភេទគ្រហស្ថ គឺទៅចូលពួកតិរ្ថិយ ។

៥- **អនុបសម្បន្នស្ស ទានេន** ភិក្ខុឲ្យអនុបសម្បន្ន ។

៦- **អនបេក្ខវិស្សជ្ជនេន** ភិក្ខុលះបង់ឥតអាល័យ គឺភិក្ខុមិនប្រាថ្នា នឹងឆាន់លេបចូលទៅក្នុងពោះ ។

---

១ អនុបសម្បន្ន: [illegible]

**៧- អច្ឆិន្ទិត្វា គហណេន** - *អនុបសម្បន្នៈជាដើមយកទៅ ។ (បឋមសាមន្តបាសាទិកា អដ្ឋកថាវិន័យ ភាគ ១ នៃត្រង់បឋមបារាជិក វិនីត-វត្ថុកថា) ។*

### អំពីរូបិយវត្ថុនានា

*មាសក្តី-ប្រាក់ក្តី កហាបណៈក្តី-មាសកៈដែលគេធ្វើដោយលោហៈ ឈើ-ជ័រឈើ និងវត្ថុណាមួយ ដែលគេសន្មតសម្រាប់ចាយវាយបានក្នុងប្រទេសនោះៗក្តី ហៅថារូបិយវត្ថុ ។*

*ភិក្ខុសាមណេរ ទទួលទុកដាក់ដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទទួលទុកដាក់ក្តី នូវរូបិយវត្ថុនោះ ឬក៏ត្រេកអរចំពោះរូបិយវត្ថុនោះ ដែលគេទុកដាក់ឲ្យដោយអកប្បិយវោហារថាៈ រូបិយវត្ថុនេះចូរជារបស់លោកម្ចាស់ចុះ ខ្ញុំព្រះករុណាសូមប្រគេនរូបិយវត្ថុនេះដល់លោកម្ចាស់ ដូចនេះជាដើមក្តី មិនគួរ ។ ភិក្ខុត្រូវនិស្សគ្គិយបាចិត្តិយៈ តាមរូបិយសិក្ខាបទទី ៨ នៃកោសិយវគ្គ ។ សាមណេរ ត្រូវទណ្ឌកម្មតាមសិក្ខាបទទី ១០ នៃសាមណេរ ។*

*បើទាយក-ទាយិកា បានទុកដាក់នូវរូបិយវត្ថុក្នុងដៃនៃកប្បិយការកៈ ហើយបង្គាប់ដោយកប្បិយវោហារថាៈ រូបិយ មានចំនួនប៉ុណ្ណេះមាននៅក្នុងដៃនៃកប្បិយការកៈឈ្មោះៈនេះ សូមលោកម្ចាស់ប្រើប្រាស់បច្ច័យ ៤ ចុះ ដូចនេះគួរ ។ បើឧបាសកណា តាំងត្រូវយ៉ាងនេះ ហើយ ទុកដាក់ភិក្ខុសាមណេរ ត្រេកអរលោភចិត្ត មិនមែនអាបត្តិឡើយ ព្រោះថាអាបត្តិមិន*

ត្រូវកង្វល់ចិត្តទេ ។ បើភិក្ខុសាមណេរ ទុកដាក់រូបិយវត្ថុដោយខ្លួនឯង ទុកជាតាំងចិត្តត្រេកអរចំពោះបច្ច័យ ៤ ក៏ដោយ ក៏មិនរួចអំពីទោសព្រោះការទទួលទុកដាក់ដែរ ។

រូបិយវត្ថុ ដែលគេបូជាចំពោះព្រះពុទ្ធរូប . បដិមាករ . ព្រះសារីរិកធាតុ និងពោធិព្រឹក្ស ហៅថាពុទ្ធបូជា ។ បើយករូបិយវត្ថុជាពុទ្ធបូជានោះទៅប្រគេនលោកជាពហុស្សុត្រ ឬព្រះសង្ឃ មិនគួរ ។

រូបិយវត្ថុ ដែលគេបូជាចំពោះលោកជាពហុស្សុត្រ ដោយកប្បិយវោហារ ហៅថាធម្មបូជា ។ បើបង្វែរទៅដើម្បីព្រះពុទ្ធ ឬព្រះសង្ឃ មិនគួរ ។ រូបិយវត្ថុដែលគេបូជាចំពោះព្រះសង្ឃ ដោយកប្បិយវោហារដើម្បីបច្ច័យ ៤ ហៅថាសង្ឃបូជា ។ បើបង្វែរទៅដើម្បីព្រះពុទ្ធ ឬព្រះធម៌វិញ មិនគួរ ។

ប្រសិនបើឧបាសក . ឧបាសិកា វេរផ្កាប្រាក់ចំពោះសង្ឃ ដោយអកប្បិយវោហារថា ខ្ញុំព្រះករុណាសូមវេរប្រគេនផ្កាដ្បូង ១ ដែលវិចិត្រដោយរូបិយៈនេះដល់សង្ឃ សូមសង្ឃកសាងសេនាសនៈ មានកុដិជាដើមនេះចុះ ដូច្នេះមិនគួរ ។ ព្រោះថាបើភិក្ខុទទួលរូបិយវត្ថុដោយចិត្តដើម្បីអ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ បើទទួលដើម្បីខ្លួន ត្រូវនិស្សគ្គិយបាចិត្តិយ ។

ភិម - មិស ឥតិនាមកោ ឥមំ បញ្ញាំ និស្សជ្ជមិ ។

សេចក្ដីបញ្ជាក់ត្រង់ឃ្លាថា វេយ្យវត្ថុដែលភិក្ខុទទួលប្រគេនត្រឹមត្រូវ ប្រកបព្រមដោយអង្គ ៥ ។ សេចក្ដីថាទទួលប្រគេនប្រកបដោយអង្គ ៥ នោះគឺ

## បដិគ្គហណំ បញ្ចហង្គេហិ រូហតិ

ការទទួលប្រគេនឡើង ដោយអង្គ ៥ គឺៈ

១ ថាមមជ្ឈិមស្ស បុរិសស្ស ឧច្ចារណាមត្តំ ហោតិ វត្ថុមានទម្ងន់ល្មមបុរសមានកម្លាំងយ៉ាងកណ្ដាលលើកម្នាក់ឯងរួច ។

២ ហត្ថបាសោ បញ្ញាយតិ ហត្ថបាសប្រាកដ គឺទាយកស្ថិតនៅក្នុងហត្ថបាស ២ ហត្ថ ១ចំអាមនៃអ្នកទទួល ។

៣ អភិហារោ បញ្ញាយតិ ការបង្អោនចូលមកប្រាកដ គឺទាយកបន្ទន់ខ្លួនបង្អោនវត្ថុចូលមកដោយកាយ ។

៤ ទេវោ វា មនុស្សោ វា តិរច្ឆានគតោ វា កាយេន វា កាយប្បដិពទ្ធេន វា និស្សគ្គិយេន វា ទេតិ ទេវតាឬមនុស្សឬកំសត្វតិរច្ឆាន ប្រគេនដោយកាយក្ដី ដោយវត្ថុដែលជាប់នឹងកាយក្ដី ដោយការបោះឲ្យក្ដី ។

៥ តំ បន ភិក្ខុ កាយេន វា កាយប្បដិពទ្ធេន វា បដិគ្គណ្ហាតិ ភិក្ខុទទួលវត្ថុនោះដោយកាយក្ដី ដោយវត្ថុដែលជាប់នឹងកាយក្ដី ។

ត្រង់អង្គទី ១ ពាក្យទង់ដោយវត្ថុដែលត្រូវប្រគេន ។

គ្រប់អង្គទី ២ ទាក់ទងដោយទាយកនិងបដិគ្គាហកៈ ។

គ្រប់អង្គទី ៣.៤ ទាក់ទងដោយទាយកតែម្យ៉ាង ។

គ្រប់អង្គទី ៥ ទាក់ទងដោយបដិគ្គាហកៈតែម្យ៉ាង ។

ការទទួលប្រគេន ទាក់ទងដោយវត្ថុផង ដោយទាយកផង ដោយបដិគ្គាហកៈផង លុះតែប្រកបព្រមដោយអង្គទាំង ៥ នេះ ទើបឈ្មោះថាទទួលប្រគេន, បើខ្វះអង្គណាមួយ មិនឈ្មោះថាទទួលប្រគេនឡើយ ។

បើចង់ដឹងសេចក្ដីពិស្ដារ ចូរមើលក្នុងគម្ពីរទុតិយសមន្តបាសាទិកា អដ្ឋកថាវិន័យភាគ ២ កែត្រង់ទន្តបោណសិក្ខាបទ ។

# ចតុរារិយសច្ច

(តមកពីលេខមុន)

ភិក្ខុ ប៉ាង-ខាត់ រៀបរៀង

ការនិយាយធម៌ ដែលត្រូវប្រើអវិជ្ជមានសព្ទនេះ ងាយស្រួលគ្រាន់បើ ព្រោះមិនសូវមានបារម្ភកេក ។ តាមធម្មតា លោកនិយមប្រើពាក្យអវិជ្ជមានសព្ទ ដូចពាក្យថា តណ្ហក្ខយ = ការអស់តណ្ហា (Extinction de la soif, Extinction of thirst), អសង្ខត = ការមិនផ្សំគ្នា (Non composé ou non conditionné, Uncompound or Unconditionned); វិរាគ = ការប្រាសចាករាគៈ (Absence de désir, Absence of desir), និរោធ = ការរលត់ (Cessation), និព្វាន = ការអស់តណ្ហា (Extinction or blowing out), ការគាស់រំលើងតណ្ហាចេញ ។

សេចក្ដីតទៅនេះ ជាអត្ថន័យ ឬ សេចក្ដីអធិប្បាយពាក្យ " និព្វាន " ដែលមាននៅក្នុងគម្ពីរដើម គឺព្រះត្រៃបិដកជាបាលី:

- ការរលត់តណ្ហាអស់ដើម, ការបោះបង់តណ្ហា, ការលះបង់តណ្ហា, ការរលាស់តណ្ហាចេញ, ការផ្ដាច់តណ្ហាចេញ (១),

- ការបំបាត់ធម៌ដែលជាគ្រឿងផ្សំ, ការបោះបង់ចោលនូវអាសវៈ,

---

១ ពាក្យនេះ ជាសេចក្ដីអធិប្បាយពាក្យ "និរោធ" ដែលព្រះសម្ពុទ្ធត្រាស់ទេសនាទុកក្នុងធម្មចក្កប្បវត្តនសូត្រ ទ្រង់មិនប្រើពាក្យ "និព្វាន" ទេ ទ្រង់ប្រើសទិសសព្ទ ប្រើជំនួសពាក្យ "និព្វាន" ។

ការអស់តណ្ហា, ការរួចស្រឡះ, និព្វាន (១) ។

-ភិក្ខុទាំងឡាយ! ដូចម្តេចហៅថា អសង្ខតធម៌ ( Inconditionné )?

ភិក្ខុទាំងឡាយ! ការអស់រាគៈ (រាគក្ខយ) ការអស់ទោសៈ ទោសក្ខយ ការអស់មោហៈ (មោហក្ខយ), នេះហៅថា អសង្ខតធម៌ និព្វាន (២) ។

រាគៈ ការអស់តណ្ហា (តណ្ហក្ខយ) នេះហៅថា (និព្វាន) (៣) ។

បើនិយាយពីធម៌ ២ ប្រការ គឺ សង្ខតធម៌និងអសង្ខតធម៌ ការប្រាសចាករាគៈ (វិរាគធម៌) ជាធម៌ប្រសើរលើស ។ សេចក្តីនេះ បានដល់ពាក្យថា សេរីភាព ឬ ការរួចស្រឡះពីមានះ, ការបំបាត់សេចក្តីស្រេកឃ្លាន (បិបាសា តណ្ហា ) ការរំលើងឫសគល់ឧបាទាន, ការកាត់ផ្តាច់សន្តតិធម៌ (គ្រឿងបន្តការដើរ), ការអស់តណ្ហា, ការរួចស្រឡះ, ការរលត់ (និព្វាន) ដូចពុទ្ធភាសិតតទៅនេះ

ភិក្ខុទាំងឡាយ! បណ្តាធម៌ ២ ប្រការ គឺ សង្ខតធម៌និងអសង្ខតធម៌នេះ វិរាគធម៌ (ការប្រាសចាករាគៈ) ជាធម៌ប្រសើរលើស ព្រោះថា វិរាគៈ (ការប្រាសចាករាគៈ) ជាធម៌ញាំញីសេចក្តីស្រវឹង ធម៌បន្ទោបង់សេចក្តីស្រេកឃ្លាន ធម៌រំលើងសេចក្តីអាល័យ ធម៌ផ្តាច់បង់វដ្តៈ អស់តណ្ហា ប្រាសចាករាគៈ រលត់ និព្វាន (៤) ។

សេចក្តីដូចពោលខាងលើនេះ មានបរិព្វាជកម្នាក់បានក្រាបទូលសួរ

១-២ អសង្ខតសំយុត្ត សំយុត្តនិកាយ ។ ៣ អសង្ខតសំយុត្ត សំយុត្តនិកាយ ។ ៤ អង្គុត្តរនិកាយ ចតុក្កនិបាត បក្កវគ្គ សៀវភៅទី ៤២ ទំព័រ ៨៩ ។

ព្រះសារីបុត្តត្ថេរ ។ កាលនោះ ព្រះសារីបុត្តត្ថេរបានឆ្លើយតបបរិព្វាជកនោះវិញ មានសេចក្តីដូចអង្គព្រះសម្ពុទ្ធបានត្រាស់ខាងលើនេះដែរ, មានសេចក្តីថា ការរលត់រាគៈ រលត់ទោសៈ រលត់មោហៈ នេះហៅថា « និព្វាន » ។

ក្នុងគម្ពីរមជ្ឈិមនិកាយ ព្រះសារីបុត្តត្ថេរបានទេសនាទុកថា ការបោះបង់តណ្ហា ការកម្ចាត់បង់តណ្ហា ឬ ការបោះបង់-កម្ចាត់បង់ឆន្ទរាគចំពោះខន្ធបញ្ចកៈ នេះហៅថា ការរលត់ទុក្ខ (ទុក្ខនិរោធ) ។

មួយទៀត ព្រះមុសីលត្ថេរក៏បានទេសនាទុកក្នុងគម្ពីរសំយុត្តនិកាយថា ការរលត់ភព នេះហៅថា « និព្វាន » ទៀត ។

ដទៃពីសេចក្តីខាងលើនេះ ព្រះសម្ពុទ្ធ បានត្រាស់ពីរឿងនិព្វានជាអនេកបរិយាយ ដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា (១)

ភិក្ខុទាំងឡាយ! ទីណា មិនមានបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ, ឯសញ្ញាណថា អាកាស វិញ្ញាណ សុខុម គ្រោតគ្រាត ល្អ អាក្រក់ នាមនិងរូប ក៏មិនមាន ទីងថា លោកនេះក៏មិនមែន បរលោកក៏មិនមែន ទីងថា មានព្រះចន្ទព្រះអាទិត្យ ក៏ទេដែរ ។

ភិក្ខុទាំងឡាយ! តថាគតមិនពោលអ្វីទាំងនោះថា ទៅ-មក-ឋិតនៅ ចុតិ-កើតឡើង ទេ អ្វីទាំងនោះ មិនស្លាប់ មិនកើត មិនមានឧកាមារម្មណ៍

១ ខុទ្ទកនិកាយ ឧទានអដ្ឋមោ បាដលិគាមិវគ្គ សៀវភៅទី ៥២ ទំព័រ ៣២០ ។

នេះហើយ ជាទីបំផុតនៃទុក្ខ (និព្វាន) ។

សេចក្តីតទៅទៀត ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា

ភិក្ខុទាំងឡាយ! មានធម៌ មិនកើត (អជាត) មិនដុះ (អភូត) មិនផ្សំ (អកតំ) មិនតាក់តែង (អសង្ខតំ) ។

ភិក្ខុទាំងឡាយ! បើមិនមានធម៌ទាំងនេះៗ កើត ដុះ ផ្សំ តាក់តែង ហួសទៅ ក៏មិនមានប្រាកដ តែ បើមានធម៌ មិនកើត មិនដុះ មិនផ្សំ មិនតាក់តែង ហើយ ធម៌ កើត ដុះ ផ្សំ តាក់តែង ក៏មានប្រាកដដែរ ។ នេះ ក៏ជាទីបំផុតនៃទុក្ខ (និព្វាន) ។

ពុទ្ធភាសិតនេះ មានសេចក្តីច្បាស់លាស់អស់ដើម តែអ្នកឥតរៀន (Profane) ស្តាប់មិនបានទេ, បើចំប្រឹងស្តាប់ នឹងត្រូវដូចគេបីស្តាប់ខ្យល់ ។

ដោយហេតុតែនិព្វាន ជាធម៌ដែលលោកប្រើអវិជ្ជមានស័ព្ទ ដូចបានពោលខាងលើនេះ បានជាមានមនុស្សច្រើននាក់ មានសញ្ញាណយល់ខុស ទៅជាយល់ថា ជា «ធម៌អវិជ្ជមាន (Négatif)» បានសេចក្តីថា «និព្វាន សូន្យខ្លួនឯង (Annihiladu soi, Self annihilation)» ទៅវិញ ។

សេចក្តីពិត និព្វាន មិនមែនជា សូន្យខ្លួនឯង ទេព្រោះថា និព្វាន មិនមាន «ខ្លួនឯង» ដែលនឹងត្រូវធ្វើឲ្យសូន្យឡើយ ។ ថាបើមានការធ្វើឲ្យសូន្យនោះ គឺធ្វើឲ្យសូន្យមោហៈ (Illusion) គឺគំនិតយល់ខុសថាមាន «ខ្លួនឯង (Fausse idée b' un soi, False idea of self)» នោះវិញទេ ។

មួយទៀត មិនមានហេតុផលត្រឹមត្រូវសោះ ដែលបបួលគ្នានិយាយថា "និព្វាន" ជា "អវិជ្ជមាន (Négatif)" ឬជា វិជ្ជមាន (Positif )" នោះឡើយ ។ សញ្ញាណថា "អវិជ្ជមាន" ឬ "វិជ្ជមាន" នេះ ជាធម៌សាពេក្ខ (Relatif) ហើយនៅក្នុងវិស័យនៃទ្វិភាព (Dualité) ។ សព្ទទាំងនេះនឹងយកទៅប្រើសម្រាប់ឲ្យយល់អត្ថន័យថា "និព្វាន" ឬឲ្យយល់អត្ថន័យថា "អរិយសច្ច (សេចក្ដីពិតដ៏ប្រសើរ)" ពុំបានទេ ព្រោះ "និព្វាន" ឬ "អរិយសច្ច" នេះ ជាលោកុត្តរធម៌ ខ្ពស់ហួសផុតពីធម៌ទ្វិភាព (Dualité) និង សាពេក្ខភាព (Relativité) នោះទៅទៀត ។

គួឲ្យយល់សេចក្ដីពិតដែរ ពាក្យថា "អវិជ្ជមាន (Négatif)" ក៏មិនគួរនឹងយល់សេចក្ដីថាជា "សភាពអវិជ្ជមាន (Etat négatif)" នោះទេ ។ ពាក្យបាលី ឬសំស្រ្កឹត ដែលលោកយកទៅប្រើក្នុងន័យថា "សុខភាព = Santè" នោះលោកប្រើពាក្យថា "អារោគ្យ" ជាពាក្យអវិជ្ជមានសព្ទ, បើប្រែតាមរូបពាក្យ បានសេចក្ដីថា "ការមិនមានរោគ = Absence de maladie" ។ ដូច្នេះ ពាក្យថា "អារោគ្យ, សុខភាព" នេះ មិនមែនបានសេចក្ដីថា ជា "សភាពអវិជ្ជមាន = Etat négatif" នោះទេ ។

ពាក្យថា អម្រឹត ជាសំស្រ្កឹត អមតៈ ជាបាលី (Immortel), ពាក្យនេះជាសទិសសព្ទនឹងពាក្យថា "និព្វាន" ហើយជាពាក្យ "អវិជ្ជមាន Négatif" ដែរ ប៉ុន្តែ ក៏មិនមែនជាពាក្យមានអត្ថន័យថាជា "សភាពអវិជ្ជមាន" ទេ ។

អវិជ្ជមានភាព (Négation) នេះ មានរូបជា អវិជ្ជមាន ប៉ុន្តែ មិនមែនថ្លែងសេចក្ដីថាជា អវិជ្ជមាន ទេ ។ មានពាក្យមួយទៀត ជាសទិសសព្ទ ជាធម្មតារបស់ពាក្យថា និព្វាន គឺពាក្យថា មុត្តិ ជាបាលី, មុក្តិ ជាសំស្ក្រឹត, ប្រែថា «ការរួច, សេរីភាព (Liberté , Freedom)» ។ ពាក្យថា មុត្តិ នេះ មិនមានអ្នកណា ហ៊ាននិយាយថាមានអត្ថន័យជា «អវិជ្ជមាន = Négatif» ប៉ុន្តែពាក្យនេះ គឺជា «អវិជ្ជមាន» ដែរ ពោលគឺ «មុត្តិ, មុក្តិ = ការរួច, សេរីភាព (Liberté, Freedom) នេះ ជាការរួច ឬសេរីភាព ចេញពីអ្វីមួយដែលជាឧបសគ្គៈកាំង ដូចជាអកុសលធម៌ទាំងឡាយ មានលោភៈជាដើម ដែលជាអវិជ្ជមាន (Négatif) ទេ ។ ឯ និព្វាន, វិមុត្តិ, មោក្ខ ជាបាលី, «និព៌ាណ, វិមុក្តិ, មោក្ស» ជាសំស្ក្រឹត, ប្រែថា «ការរួចស្រឡះ, ការរួចអស់រលីង (La liberté absolue, Absolute freedom)» ជាធម៌រួចស្រឡះពីអកុសលធម៌ទាំងអស់ រួចស្រឡះអស់ជើងចេញពីតណ្ហា - អវិជ្ជា - ទោស រួចស្រឡះចេញពីអ្វីទាំងអស់ ដែលជាធម៌ទ្វិកភាព (Dualitè) ធម៌សាបេក្ខ (Relativité) ព្រមទាំងកាលវេលា (Temps) និងអវកាស (Espace) ទៀតផង ។

តទៅនេះ គួរលើកយកសេចក្ដីខ្លះ ក្នុងធាតុវិភង្គសូត្រ នៃគម្ពីរមជ្ឈិមនិកាយ មកពោលទៀត ព្រោះសូត្រនេះ ព្រះសម្ពុទ្ធទ្រង់បានត្រាស់បញ្ជាក់ច្បាស់លាស់ពីនិព្វាន ចំពោះបុក្កុសាតិព្រាហ្មណ៍ ជាព្រាហ្មណ៍អ្នក

ប្រាជ្ញវិសេស ក្នុងសម័យព្រះអង្គ នៅគេហដ្ឋាន នៃស្មូនឆ្នាំងម្នាក់ឈ្មោះ ភគ្គវៈ ដូចព្រះតម្រាស់ថា (១) ។

ភិក្ខុទាំងឡាយ! កាយមនុស្សប្រកបដោយធាតុ ៦ ប្រការគឺ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ វិញ្ញាណធាតុ និងអាកាសធាតុ ។ បើបែកវែកធាតុទាំងអស់ឲ្យល្អិតទៅ មិនឃើញមានអ្វីនៅសល់ មានតែវិញ្ញាណអាស្រ័យនៅ ។ បុគ្គលគួរពិចារណាមើលឲ្យឃើញពិតទៅតាមពិត ដោយបញ្ញាដ៏ប្រសើរ បើបានពិចារណាដោយបញ្ញាដ៏ប្រសើរហើយ នឹងឃើញពិតតាមពិតថា នុ៎ះមិនមែនជារបស់អាត្មាអញទេ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញទេ (នេតំ មម, នេសោហមស្មិ, ន មេ សោ អត្តា) ។ ដទៃពីនេះ មានតែវិញ្ញាណ ដែលទទួលដឹងថា សុខ្ខៈ ទុក្ខៈ មិនមែនជាសុខ ឬ ជាទុក្ខៈ ដោយវិញ្ញាណនោះឯង ។

ភិក្ខុទាំងឡាយ! ដូចកម្ដៅ បើកម្ដៅមាន ភ្លើងក៏មាន ដោយការពួតឈើអរណី, បើកម្ដៅដែលកើតពីការពួតនេះ រលត់ទៅវិញ ស្ងប់ទៅវិញ ដោយមិនមានការពួតឈើអរណីនេះ មានឧបមាយ៉ាងណា ។

ភិក្ខុទាំងឡាយ! សុខវេទនាកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាហេតុនៃសុខវេទនា បុគ្គលបានដឹងសុខវេទនា ដឹងថា អាត្មាអញមានសុខវេទនា សុខវេទនានោះរលត់ទៅវិញ ព្រោះរលត់នៃផស្សៈ ដែលជា

១ មជ្ឈិមនិកាយ ឧបរិបណ្ណាសក សៀវភៅ ទី ២៨ ទំព័រ ១៨៥ ។

ហេតុនៃសុខវេទនានោះឯង មានឧបមេយ្យយ៉ាងនោះឯង ។

ភិក្ខុទាំងឡាយ ដូចជាងមាសដែលជាអ្នកប្រសប់ដុតមាស លុះដុតមាសនោះបានការល្អហើយ យកមាសនោះទៅធ្វើជាគ្រឿងអលង្ការ តាមសេចក្តីត្រូវការ មានឧបមាយ៉ាងណា ។

ភិក្ខុទាំងឡាយ! ឧបេក្ខាចិត្ត កើតឡើងបរិសុទ្ធ ផូរផង់ ជាធម្មជាតទន់គួរដល់ការងារ បុគ្គលបង្អោនឧបេក្ខាចិត្តទៅកាន់អាកាសានញ្ចាយតនជ្ឈាន, វិញ្ញាណញ្ចាយតនជ្ឈាន, នេវសញ្ញានាសញ្ញាយតនជ្ឈាន, កាលបុគ្គលបានអរូបជ្ឈានទាំង ៤ នេះហើយ ឈាននោះ ក៏នៅជាសង្ខតជ្ឈាន, បុគ្គលនោះ ដែលតាក់តែង ដែលត្រិះរិះ ដើម្បីបម្រើន ឬ វិនាសទៀតហើយ ដែលប្រកាន់របស់អ្វីមួយក្នុងលោកនេះហើយ មិនតក់ស្លុត រំលត់កិលេសបានដោយពិតប្រាកដ ហើយដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បានធ្វើហើយ សោឡសកិច្ចបានធ្វើស្រេចហើយ ។ បើបុគ្គលនោះ ទទួលសុខវេទនា ទុក្ខវេទនា អសុខមទុក្ខវេទនា ក៏ដឹងច្បាស់ថា វេទនាទាំងនេះ មិនទៀងទាត់ មិនគួរទីងជាប់ចិត្ត ឡើយ មិនគួរទីងត្រេកអរឡើយ, ម្យ៉ាងហើយចិត្តក៏ស្ងៀមណាស់ ។ កាលបើបុគ្គលទទួលវេទនាត្រឹមតែកាយ ក៏ដឹងថា អាត្មាអញបានទទួលវេទនាត្រឹមតែដោយកាយ បើទទួលវេទនាត្រឹមតែជីវិត ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនាត្រឹមតែដោយជីវិត (១) ។ ដឹងច្បាស់ថា កាលបើកាយបែកធ្លាយ ...

១. មជ្ឈិមនិកាយ [illegible]

ហើយបន្ទាប់ពីការអស់ទៅនៃជីវិត វេទនាទាំងពួង ដែលអាត្មាអញមិនគួរត្រេកអរក្នុងលោកនេះ នឹងរលត់អស់ទៅមិនមានសេសសល់ឡើយ ។

ភិក្ខុទាំងឡាយ! ដូចប្រទីប ដែលឆេះ អាស្រ័យដោយប្រេងផង ដោយប្រឆេះផង ។ បើអណ្ដាតភ្លើងមិនមានអាហារ តែងរលត់ទៅ ព្រោះអស់ប្រេងផង អស់ប្រឆេះផង ហើយគេក៏មិនបន្ថែមប្រេងនិងប្រឆេះទៀត មានឧបមាយ៉ាងណា ។

ភិក្ខុទាំងឡាយ! កាលបើបុគ្គលទទួលវេទនា ត្រឹមតែដោយកាយ ត្រឹមតែដោយជីវិត ដឹងច្បាស់ថា លុះកាយបែកធ្លាយទៅហើយ បន្ទាប់ពីការអស់ទៅនៃជីវិត ឯវេទនាទាំងពួង ដែលអាត្មាអញមិនគួរត្រេកអរក្នុងលោកនេះ នឹងរលត់អស់ទៅមិនមានសេសសល់ឡើយ មានឧបមេយ្យយ៉ាងនោះ ។

ភិក្ខុទាំងឡាយ! បុគ្គលដែលប្រកបដោយគុណធម៌យ៉ាងនេះ ឈ្មោះថាប្រកប ដោយបញ្ញាធិដ្ឋានដ៏ឧត្តម ។

ភិក្ខុទាំងឡាយ! ដោយការដឹងក្នុងធម៌ (អរហត្តផល) ជាទីអស់ទៅនៃទុក្ខទាំងពួងណា ការដឹងនោះ ហៅថា បញ្ញាដ៏ប្រសើរក្រៃលែង ។ វិមុត្តិនោះ របស់បុគ្គលនោះ ឋិតនៅក្នុងសច្ចៈ ជាវិមុត្តិមិនកម្រើក ៖

ភិក្ខុទាំងឡាយ! បុគ្គលនោះ ព្រោះតែសង្កេតឃើញហើយនូវឧបធិ គឺ ខន្ធូបធិ, កិលេសូបធិ, អភិសង្ខារូបធិ, កាមគុណូបធិ ៤ ។ (នៅមាន)

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ - កន

ប្រែ ~ រៀបរៀង

(ក)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នកភាងវៃឆ្លាសបើបានអាន |
| នឹងបេះឧបាយកលចំណាន | ទាំងមានសន្ដានស្នេហាជាតិ |

យូ-អ៊ុន

កៀនអ៊ុយក៏ប្រឹក្សាទោសខ្លួនឯងថា យើងលើកទ័ពទៅធ្វើការគ្រានេះ ខ្វះខាតអាហារនិងសេះ គ្រឿងសស្ត្រាវុធច្រើនណាស់ ទោសទាំងនេះក៏ជាទម្ងន់មហិមា យើងត្រូវតែផ្តន្ទាធ្វើទោសខ្លួនឲ្យដូចយ៉ាងមបាទុបាពជកាលខ្ញុំកែតេងទីងផៃស៊ុម៉ាអ៊ីនោះទើបសមគួរ ថាហើយក៏តែងឧរឿងរ៉ាវកាត់សេចក្ដីធ្វើទោសខ្លួនឯង ដកហូតងាររេចញពីដំណែងយស-សក្ដិ តែឲ្យនៅធ្វើពជការត្រឹមតែទីនាយទាហានវិញ ហើយឲ្យបំរើនាំទៅថ្វាយព្រះចៅឡៅសៀន ។

ឯតេងង៉ាយទីងគាន់ថាយ លុះកងទ័ពស្រុកសៃឈួនបែករត់ទៅហើយ ក៏ឲ្យតែងតុលៀងនាយទ័ពនាយកង ហើយឲ្យចំណាប់ផ្ទាន់ដល់ទាហានទាំងពួងតាមសមគួរ គាន់ថាយទើបធ្វើជាសំបុត្រចងបើកសេចក្ដីគាប់ប្រសើរនៃតេងង៉ាយទៅដល់ស៊ុម៉ាចៀវ ។ ក៏ឲ្យអានត្រាទៅតាំង

គេនឹងងាយលឿនចិតទៅ បុត្រគេនឹងងាយកំតាំងឲ្យជាមន្ត្រីធំ គ្រានោះ ព្រះចៅពោម៉ាសោយរាជ្យបាន ៣ ឆ្នាំ (ព.ស. ៧៩៩) ឈ្មោះស្រុកពីដើមនោះ ឈ្មោះថា « កៃចេង » ក្នុងសម័យនោះប្រែឈ្មោះប្ដូរជាថ្មី ឲ្យហៅថាស្រុក « កាំឡ » វិញ ។

ចប់ ខ្សែ ៨២ នឹងតទៅ ៨៣ ទៀត

# សាមកុកខ្សែ ៨៣

តាំងពីសុម៉ាចៀវតម្កើងអំណាចមិនខ្លាចព្រះចៅហោម៉ គិតតែដណ្ដើមយករាជសម្បត្តិ ឆ្កាត់អៀនបះគិតកំចាត់សុម៉ាចៀវ ៗ ទូលឲ្យស្ដេចចេញរាំងដោយកល្បឧបាយ ទំព សុម៉ាចៀវក៏សម្លាប់ឆ្កាត់អៀនស្លាប់ សម្លាប់ទាំងបុត្រភរិយាអស់ ៣ ជួរពោត្រ និង បក្ខពួក ៣០១ នាក់ មានមនុស្សស្ម័គ្រនៅនឹងសុម៉ាចៀវជាច្រើន ។

ឯសុម៉ាចៀវបាននិយាយរាជការក្នុងស្រុកវុយកុកទាំងផែនដី កិច្ចការអ្វី ៗ ក៏សម្រេចលើខ្លួនតែម្នាក់ឯង មិនបាច់នឹងក្រាបពិតទូលព្រះចៅហោម៉ឡើយ ទោះបីនឹងចូលចេញក្នុងព្រះរាជវាំងក៏ឲ្យមានទាហាន ៣.០០០ កាន់សស្ត្រាវុធហែមុខហែក្រោយ សម្រាប់ការពារកាយខ្លួន, លុះឃើញថាគ្មាននរណាស្មើជាគូហើយ ក៏គេតែស្រវឹងនឹងយសផ្លាបណ្ដាស័ក្ដិជាខ្លាំង តាំងចិត្តគិតតែនឹងដណ្ដើមយករាជសម្បត្តិ មានមនុស្សស្និទ្ធម្នាក់ឈ្មោះកែច្រុង ជាកូនកែក្លួយជាទីទុកចិត្តសុម៉ាចៀវ ឈ្មោះនេះក៏ទៅនិយាយនឹងសុម៉ាចៀវក្នុងទីស្ងាត់ថា ប្រសាសន៍មានយសផ្លាបណ្ដាស័ក្ដិខ្ពស់ពេញទៅក្នុងទិសទាំង ៤ ហើយ ម្ដេចឡើយមិនគិតរាជសម្បត្តិនេះ ឃើញថានៅក្នុងកណ្ដាប់ដៃប្រសាសន៍ទាំងអស់ បើនឹងធ្វើការវេលានេះ ក្រែងមនុស្សទាំងពួងនឹងមិនស្ម័គ្រព្រមចិត្តគ្នា ទាំងនឹងស្ដាប់ដំណឹងពត៌មានមើលចិត្តថ្មើមមនុស្សទាំងពួងសិន ទើបនឹងបានគិតការធំតទៅ ៗ

សុម៉ាចៀវថា ខ្ញុំបានគិតទុកយូរហើយ តែថាម៉ះជំនឹងផែលទីនរកនរណាពឹងបកមាត់ប្រាប់គ្នាន ចើថាស្រឡាញ់យើងជួយរិះគិតផ្ចេះបាន

ជាសេចក្ដីគាប់ប្រសើរណាស់ណា   បើដូច្នោះត្រូវទៅជួយដើរទៅស្រុកហ៊្លួយឡាំ  ហើយនិយាយមើលទឹកចិត្តពួកចៅហ្វាយស្រុក  តែថាធ្វើជាថាខ្ញុំប្រើឲ្យហៅទៅទទួលរង្វាន់មកចែកពួកទាហានមានឈ្មោះ  ក្នុងការធ្វើសង្គ្រាមមានសេចក្ដីគាប់ប្រសើរហើយស្ដាប់មើលបែបលែបខាយ  តើគេនឹងចូលចិត្តនឹងយើងឬទេ ? តែធុងទទួលពាក្យស៊ុម៉ាចៀវហើយ  ក៏ចេញទៅស្រុកហ៊្លួយឡាំ ។

ឯជូកាត់គៀនចៅហ្វាយស្រុកហ៊្លួយឡាំ ពីដើមនៅស្រុកឡាំគៀងក្នុងខែត្រឡុងសេ ជាកូនបងកូនប្អូននឹងខុងបេង បានធ្វើកការនៅស្រុកវុយកុក កាលខុងបេងរស់នៅជាមហាឧបរាជក្នុងស្រុកសែឈុន  ឈ្មោះនេះក៏មិនបានសក្ដិយសជាអ្វី  ព្រោះមនុស្សទាំងពួងក្រែងថានឹងទៅចូលនឹងបងប្អូន លុះខុងបេងស្លាប់ទៅ  ទើបបានយសសក្ដិជានាម៉ឺនធំ  បានស្ដីកការជាចៅហ្វាយស្រុកហ៊្លួយឡាំនឹងហ្លួយខេតាំង ២ មណ្ឌល  ជាធំលើទាហានទាំងពួង  លុះតែធុងទៅរក  ក៏អញ្ជើញឲ្យស៊ីលៀងតាំងតុសេពសុរា តែ-ធុងឃើញជូកាត់គៀនស្រវឹងសុរាជោកក្នុងខ្លួនហើយ  ក៏ក្លែងនិយាយល្បងមើលទឹកចិត្តថា សព្វថ្ងៃនេះប្រជាករស្ដីតិះដៀលអម្ចាស់ផែនដីថាជាមនុស្សល្ងង់ខ្លៅមិនដឹងសេចក្ដីអ្វីសោះ  មិនសមគួរធ្វើជាម្ចាស់ផែនដីនេះ ស៊ុម៉ាចៀវបានជាមហាឧបរាជបំរុងផែនដីមក ៣ ភពហើយ  បានរក្សាស្ដ្រឲ្យនៅជាសុខស្រណុកសប្បាយមិនមានគន្ធាយអ្វីនោះ  ឃើញថាជាសេចក្ដីគាប់

ប្រសើរយ៉ាងធំ   គួរនឹងជំនួសម្ចាស់ស្រុកវៃយកុកបាន   តើលោកយល់ឃើញប្រការម្ដេច   ?

ដូកាត់អៀនបានឮដូច្នោះក៏ខឹងខ្លាំងណាស់ ថាចៅជាកូនកែគុយបានស៊ីបៀវត្សរ៍នាំកងរាជការស្រុកវៃយកុកជកបមក   គួរហើយនឹងមានចិត្តស័ក្យទៀងនឹងផែនដី   ម្ដេចក៏ទៅមកបរបាមិនគួរដូច្នេះ មិនគួរសោះ កែជុំងបានឮដូច្នេះក៏ភ័យណាស់ ទើបកែថា ខ្ញុំបាទបានឮអ្នកជកែគេនិយាយឲ្យតាស់ចិត្តណាស់   បានជានាំមកជំណាលឲ្យលោកប្រាប់ផង ៗ

ដូកាត់អៀនថា បើអន្តរាយមកដល់ម្ចាស់ផែនដី យើងជាខ្ញុំរាជការគួរនឹងសាសងព្រះតេជៈព្រះគុណត្រាតែអស់ជីវិត   កែជុំងបានឮដូច្នោះក៏នៅស្ងៀម ឈប់ដេកនឹងដូកាត់អៀន ១ យប់   លុះព្រឹកឡើងក៏លាចេញទៅ   លុះទៅដល់ទីក្រុងហើយ   ក៏សាស្រាយរឿងរ៉ាវដែលបរបានឹងដូកាត់អៀននោះឲ្យស៊ុមម៉ាបៀវស្ដាប់គ្រប់ប្រការ   ស៊ុមម៉ាបៀវបានឮដូច្នោះក៏ខឹងខ្លាំងណាស់ថាគួរប្ដូរមកបង្អាចបរបាយ៉ាងនេះ   កែជុំងឆ្លើយថា   ដូកាត់អៀននោះជានាម៉ឺនធំ   បេះដូងអយេកចិត្តទាហានទាំងពួង   អំហានក៏ស្រឡាញ់   យូរទៅមុខជានឹងមានភ័យជាប្រាកដ   កុំបណ្ដោយឲ្យយូរឡើយចូរលោកស្រួតរូតគិតរំលាងជីវិតដូកាត់អៀនចេញឲ្យបាន   ស៊ុមម៉ាបៀវយល់ឃើញត្រូវ   ក៏ឲ្យមានសំបុត្រស្ងាត់ទៅដល់ឆាក់លីមចៅហ្វាយស្រុកពេនជីវ   ហើយទើបឲ្យមានត្រាព្រះតម្រាស់ទៅដកឆ្លាដូកាត់អៀនចេញ

ចាកទ័ពទៅវាយស្រុកហ៊ួយឡាំ នឹងយកមកតាំងជាតាម៉ឺនធំគាល់បំរើធ្វើរាជការខាងក្នុងស្រុកហ្វួង ។

ឯបំរើកាន់ព្រះតម្រាស់លុះទៅដល់ហើយ ជូកាត់អៀនដឹងក្នុងព្រះតម្រាស់ហើយ ដឹងថាកែគុងនាំយករឿងការដែលនិយាយគ្នានោះទៅប្រាប់ដល់សុម៉ាចៀវទើ-រិះគិតធ្វើដូច្នេះ ដើម្បីនឹងធ្វើអន្តរាយដល់យើង ទើបឲ្យយកបំរើដែលកាន់ព្រះតម្រាប់នោះទៅសាកសួរយកសេចក្តី បំរើកាន់ព្រះតម្រាស់ឲ្យការថា សេចក្តីដូច្នោះខ្ញុំបាទមិនដឹងទេ ឆាក់លីមទៅ-វាយស្រុកនោះឯងឃើញថាមុខជាមិនដឹង ជូកាត់អៀនសួរថា គេនឹងដឹងដោយហេតុអ្វី ? បំរើកាន់ព្រះតម្រាស់ប្រាប់ថាឆាក់លីមនោះគាបជិងតាំងអស់ ព្រោះសុម៉ាចៀវឲ្យសំបុត្រស្ងាត់ទៅដល់ ១ ច្បាប់ ជូកាត់អៀនក៏ឲ្យយកបំរើកាន់ព្រះតម្រាស់នោះទៅសម្លាប់ចេញ ហើយលើកទាហាន ១០០០ ទៅវាយស្រុកអេងដីវ លុះទៅដល់ទ្វារខាងទិសឯត្បូង ឃើញមាត់ទ្វារកំពែងបើក ជូកាត់អៀនចូលទៅដល់ជើងកំពែង ក៏ស្រែកឲ្យបើកទ្វារទទួល តែគ្មាននរណាបើក ជូកាត់អៀនខឹងណាស់ ស្រែកជេរថា គាឆាក់លីមនេះ ជាមនុស្សឆោតខ្លៅបង្កាច់មកគិតប្រទូសរ៉ាយអញ ។ ទាហានល្អមានថ្វីដៃប្រមាណ ១០ នាក់លោតចុះពីលើខ្នងសេះ ហែលឆ្លងគូឡើងកំពែងទៅបាន ហើយដេញកាប់សម្លាប់ទាហានលើសើនបន្ទាយតែអស់ ហើយក៏បើកទ្វារស្រុកចេញមក ។

ជូកាត់អៀនក៏នាំទាហានចូលទៅក្នុងស្រុក ហើយឲ្យទាហានយកភ្លើងដុតផ្ទះឆាក់លឹម ៗ ក៏យំណាស់ ស្ទុះរត់ឡើង ទៅនៅក្នុងបន្ទប់ថ្នាក់ជាន់លើ ជូកាត់អៀនកាន់គ្រប់រពលដេញស្រាវជ្រាវរកខ្លួនជួបប្រទះក៏ស្រែកគំហកថាបិតារបស់អ្នកឯងពីដើមមកក៏ជាខ្ញុំផែនដីស្រុកវ៉ុយកុក លុះដល់មកខ្លួនឯងទៀតក៏ជាខ្ញុំរាជការគេមក គួរឃើញឧបការគុណច្រើនណាស់ ព្រោះម្ចាស់ផែនដីបានទំនុកបំរុងក្នុងផ្លូវសង្គ្រោះ ខ្លួនជាមនុស្សត្រូវតែកតញ្ញូស្គាល់គុណម្ចាស់ គួរហើយឬមកប្រែក្រឡាស់ជាក្បត់ចូលគំនិតនឹងសុ-ម៉ាចៀវដែលជាមនុស្សទុរយស ឆាក់លឹមនៅមិនទាន់នឹងឆ្លើយតបនោះ ជូកាត់អៀនក៏កាប់នឹងគ្រប់ត្រូវឆាក់លឹមដាច់កស្លាប់ ។

ជូកាត់អៀនមានសំបុត្រពោលទោសសុម៉ាចៀវ ឲ្យនាំចូលទៅក្រាបទូលព្រះចៅចោម៉ឺងក្រុងឡកអៀង, ហើយក៏កេណ្ឌរេហ៍ពលក្នុងស្រុកហ៊្វៃយឡាំ ស្រុកហ៊្វៃយខបានពល ១០ ម៉ឺនប្រាយ, ហើយឲ្យប្រមូលទៅត្រៀមព្រមទាំងសេះនឹងគ្រឿងសស្ត្រាវុធ ស្រូវអង្ករស្បៀងអាហារ ហើយតាំងង៉ីកុងជាទីប្រឹក្សាធំ ឲ្យនាំជូកាត់ចេងជាបុត្រទៅស្រុកតាំងតាំង ដើម្បីប្រគល់ទុកជារបស់បញ្ចាំចិត្ត សុំឲ្យជួយកងទ័ពលើកទៅព្រួតវាយកំចាត់សុម៉ាចៀវដែលជាសត្រូវរាជសម្បត្តិ ។

គ្រានោះស៊ុនជុនដែលជាមហាឧបរាជស្រុកតាំងតាំងស្លាប់ហើយ បានស៊ុនលឹមជាប្អូនទទួលស្តីទីជាមហាឧបរាជជំនួសបង, ស៊ុនលឹម

សម្លាប់តេងអ៊ុនជានាម៉ឺនធំនឹងពួកទាហានឈ្មោះលីគី អេងចុនស្លាប់, ទើប តាំងខ្លួនបានជាធំជាងមន្ត្រីទាំងពួង, ឯព្រះចៅស៊ុនលៀងក៏មានសតិ- បញ្ញា តែជាមិនដឹងនឹងថាដូចម្ដេច ព្រោះរាជការផែនដីស្រេចជាប់ទាត លើឈ្មោះស៊ុនលីមតែម្នាក់ឯង, ឌីកុងបានទៅដល់ស្រុកបោះចៅសៀ ក៏ចូលទៅគំនាប់ស៊ុនលីម ។ សួរថា អ្នកមកនេះមានកិច្ចធុរៈការអ្វី ? ឌីកុង ជំរាបថា ជូកាត់អៀនជាបងប្អូនខ្ញុំបេង ធ្វើរាជការខាងស្រុកវុយកុក ឃើញស៊ូម៉ាចៀវលើកយកម្ចាស់ផែនដីចេញ ដោយគិតនឹងចង់ដណ្ដើម យករាជសម្បត្តិខ្លួនឯង បានជាជូកាត់អៀនឈឺចិត្តគិតកំចាត់សត្រូវផែនដី ចេញ ឃើញថាកំឡាំងរេហ៍ពលរបស់ខ្លួនតិចមិនចួនការ ទើបប្រើខ្ញុំ បាទឲ្យនាំបុត្រមកប្រណាំបគន់លោក, ដើម្បីសុំកងទ័ពលោកទៅជួយ ក្រែងជាលោកនៅមិនជឿចិត្ត ក្រែងពុំពិតដូចសញ្ញា សូមទុកបុត្រ ឈ្មោះជូកាត់ចេងឲ្យនៅនឹងលោកជារូបបញ្ចាំ, សូមឲ្យតែលោកលើក ទាហានទៅជួយ, ស៊ុនលីមក៏ជឿ ទើបចាត់នាយទាហានឈ្មោះ ជួនគេក ជួនខួនទាំង ២ នាក់នេះជារបស់ហ្លួង អ៊ុនជួនជាមេទ័ពដូខ, ដូអ៊ុ, គងអ៊ី ២ នាក់នេះជានាយកងមុខ ឲ្យប៊ុនឃឹមនាំផ្លូវទាហានទាំង ៣ កងនោះ រេហ៍ ពលបាន ៧០.០០០ លើកទៅជួយជូកាត់អៀន, ឯឌីកុងក៏លាស៊ុនលីមមក

ស្រុកហ្លួយឡាំវិញ, ហើយចូលទៅជំរាបដូកាត់អៀនថា បាទ ក្រុងទេព ស្រុកកាំងកាំងមកហើយ ដូកាត់អៀនមានសេចក្តីអំណរណាស់ក៏ចាត់បែងក្រុងទេពហើយលើកទៅ ៗ

ឯសុម៉ាប៉ៀវបានដឹងដំណឹងតាមសំបុត្រដែលដូកាត់អៀនឲ្យនាំទៅទូលព្រះចៅចោម៉នោះ ក៏មានសេចក្តីខឹងណាស់; តាំងតែរិះគិតនឹងលើកទ័ពទៅវាយដូកាត់អៀន តែ ធ្មុងនិយាយថា វង្សរបស់លោកបានឧបត្ថម្ភទំនុកបំរុងផែនដីមកពីបិតា ទឹងបងតមកដល់លោកទៀត, គុណនេះជាធម្ងន់ណាស់ណាទៅហើយ តែជានៅឡើយព្រោះមិនទាន់ទូទៅក្នុងទិសទាំងពួង, បានជានៅមានមនុស្សនាំបះបោរជាក្បត់យ៉ាងនេះ ដែលលោកនឹងចេញទៅបង្ក្រាបសត្រូវដោយខ្លួនឯងនោះ ខ្ញុំបាទយល់ឃើញថាមិនត្រូវសោះ, ព្រោះក្រែងសត្រូវនឹងនាំបលាបលច្របូលច្របល់ឡើងក្នុងស្រុកក្រុង ដែលជាទីព្រះរាជសាន្ត បើកាលណាគេតវើកហើយលោកនឹងវិលត្រឡប់មក ប្រាបប្រាមជាក្រោយក៏នឹងបានសេចក្តីលំបាក; បើលោកអញ្ជើញព្រះនាងគួយថាយហៅ នឹងព្រះចៅចោម៉ចេញទៅប្រាបប្រាមសត្រូវវិញមុខជាស្ងប់ដោយងាយ, សុម៉ាប៉ៀវបានឮដូច្នោះក៏មានសេចក្តីត្រេកអរណាស់ ទើបឆ្លើយឡើងថា អ្នកនិយាយនេះត្រូវនឹងគំនិតគិតរបស់យើង, ថាហើយក៏ចូលទៅទូលព្រះនាងគួយថាយហៅថា ដូកាត់អៀនគិតក្បត់ទូលព្រះបង្គំនូវអស់នាម៉ឺនមុខមន្ត្រីទាំងពួង បានប្រឹក្សា

យល់ព្រមគ្នា សូមអញ្ជើញព្រះអង្គនឹងព្រះចៅពោម៉ចេញទៅផង នឹងបានបង្ក្រាបសត្រូវឲ្យរាបទាបរក្សាផែនដីទុកកុំបីឲ្យជាអន្តរាយ ដូចព្រះបន្ទូលព្រះចៅពោយ៉យដែលទ្រង់បណ្តាំទុកនោះ, ព្រះនាងគួយថាយហៅខ្លាចអំណាចមិនអាចនឹងទទឹងបាន ក៏ទទួលថានឹងទៅ, លុះព្រឹកឡើងថ្ងៃមួយ ស៊ុម៉ាចៀវក៏ចូលទៅទូលព្រះចៅពោម៉ថា « សូមអញ្ជើញព្រះអង្គស្តេចទៅទ័ព »។

ព្រះចៅពោម៉ឆ្លើយថា អ្នកជាមហាឧបរាជបានស្តីរាជការទាំងផែនដីជាសិទ្ធិដាច់ស្រេចលើអ្នកហើយ, ពោះបើនឹងបង្គាប់បញ្ជា នរណាក៏មិនអាចហ៊ានរើងទទឹងបាន, គួរតែអ្នកទៅវិញទើបស្រួល, ដែលនឹងឲ្យខ្ញុំឯងទៅនោះតើជាប្រការម្តេច ? ស៊ុម៉ាចៀវថា បើព្រះអង្គនឹងមិនព្រមស្តេចទៅវិញមិនគួរទេ, កាលគ្រាព្រះចៅពោធោស្តេចក៏បានគ្រប់ផ្គាត់ទៅប្រាបប្រាមរាជសត្រូវទាល់តែដល់ផ្លូវមហាសមុទ្រ, លុះមកផែនដីព្រះចៅពោគី ព្រះចៅពោយ៉យក៏គិតបង់ឲ្យផែនដីរាបទាប, បើរាជសត្រូវបង្កើតនៅទីណា ក៏ទ្រង់ព្រះឧស្សាហ៍ស្តេចទៅបង្ក្រាបនៅទីនោះ, ហេតុនេះសូមឲ្យព្រះអង្គស្តេចចេញទៅ ដេញរំលាងសត្រូវតាមបែបយ៉ាងព្រះបរមាវង្សត្រមកនោះចុះ, ដែលព្រះអង្គមកញញើតខ្លាចនោះមិនគួរទេ, ព្រះចៅពោម៉ទទឹងមិនបាន ក៏ទទួលថានឹងទៅ ទើបមានគ្រាព្រះតម្រាស់ឲ្យកេណ្ឌរេហ៍ពលក្នុងព្រះនគរទាំង ៤ អាទ្រី ក៏បានពល ២៦ ម៉ឺនតាំង

អង្គជីជាមេទ័ពមុខ តាំងទៀនជាបាលដ្ឋទ័ពមុខ ហោប៉ាជាប៉ែកស្ដាំ, ដីរ-ជាយទៅហ្វាយស្រុកគុនដីជាប៉ែកឆ្វេង, ព្រះចៅហោម៉ក៏ទ្រង់ព្រះទ័នាំងពលរថលើកទ័ពទៅតាមផ្លូវស្រុកហ្លួយឡាំ ក៏ទៅដល់ប្រទល់នឹងកងទ័ពស្រុកកាំងតាំងដែលជាកងទ័ពមុខមកជួយជូកាត់គៀននោះ, ជូអ៊ីដែលជាមេទ័ពស្រុកកាំងតាំងក៏លើកទាហានចេញក, អង្គជីជិះសេះនាំទាហានចេញច្បាំង, ជូអ៊ីច្បាំងនឹងអង្គជីមិនទាន់បាន ១ ភ្លែង ក៏ទន់កំឡាំងប្រុងនឹងឃ្លាត់ជូអ៊ីក៏រត់, កងអ៊ូជិះសេះចេញមកតជំនួសទៀង មិនទាន់បានញភ្លែងក៏ប្រះរត់ទៅទៀត, អង្គជីនាំទាហានដេញទ្រួនតាម, ទ័ពស្រុកកាំងតាំងចាញ់ប្រៀបក៏រំសាយពលរត់ថយទៅ តាមផ្លូវចម្ងាយប្រហែល ៨០០ សិន (២០ គី) ក៏តាំងបោះបន្ទាយនៅទីនោះ ទើបឲ្យបំរើសេះកាន់សំបុត្រប្ដឹងចូលទៅដល់ជូកាត់គៀនដែលទៅតាំងនៅស្រុកឈីវល្យុន ជូកាត់គៀនក៏លើកទ័ពមកជាមួយនឹងប៊ិនឃីម, ឯប៊ិនអេងជាបុត្រច្បង ប៊ិនហៅបុត្របន្ទាប់ទាំង ២ នាក់ក៏មកជាមួយនឹងបិតា ។

សុម៉ាចៀវដឹងថា ទ័ពជូកាត់គៀនលើកទៅបញ្ចូលគ្នានឹងទ័ពស្រុកកាំងតាំងហើយ, ទើបឲ្យប្រមូលមន្ត្រីធំតូច ២ នាក់ ឈ្មោះហ៊ោស៊ីវ ១ ចុងហោយ ១ មកប្រឹក្សាពីការសង្គ្រាម, ចុងហោយថា កងទ័ពស្រុកកាំងតាំងលើកមកជួយគេគ្រានេះព្រោះលោកដោយលោកសក្ការ បើជួបប្រទះត្រូវយើងយករបស់ទ្រព្យទៅបោះកយពាល ជាការបញ្ឆោតឲ្យបរាជ័យ

ដល់យើង សុម៉ាចៀវយល់ឃើញត្រូវផង ទើបបង្គាប់ចៅពៅ, ជីវហាយ ឲ្យនាំទាហានជា ២ កងទៅបង្កប់នៅដើមផ្លូវស្រុកចៅថាវសៀ ឲ្យអង់គី ទឹងតាំងខៀននាំទាហានទៅបង្កប់នៅចុងផ្លូវនោះ, ហើយប្រើឲ្យសេង ជុយទៅល្បួងបញ្ឆោតឲ្យចេញមកច្បាំង ហើយបង្គាប់ថា បើគេមកក៏យ ហើយឲ្យធ្វើជារត់ទៅតាមផ្លូវចៅថាវសៀ, ឲ្យតាន់ជុននាំហ្វូងសេះទឹង គោរទេះផ្ទុករបស់ទ្រព្យទៅទំលាក់ចោលនៅផ្លូវនោះ ហើយបង្គាប់ថា បើ សត្រូវលើកមកឲ្យបាចសាចចោលរបស់ទ្រព្យទាំងនោះ ហើយឲ្យរត់ចេញ

ឯជូកាត់ឿនប្រើជូអ៊ីទាហានស្រុកកាំងតាំងជាមេកស្ដាំ, ប៊ុនឃីមជា មេកឆ្វេងលើកចេញ, លុះឃើញគង់ចំពស្រុកវុយកុកមិនបានប្រុងប្រៀប រៀបរយ មានមនុស្សទឹងសេះចោលកាយផ្ដេសផ្ដាសក៏បពេលចូលក៏យ; ស៊ុនជុនក៏នាំទាហានរត់ទៅ, តាន់ជុនផែលនាំរបស់មកនោះ, លុះឃើញ ជូកាត់ឿនលើកចំពមកហើយ ចោលរបស់ទ្រព្យកត់ក៏យនាំគ្នារត់ នោះ ពួកទាហានជូកាត់ឿនឃើញរបស់ជ្រុះចោលដោយផ្លូវច្រើនណាស់, ទាំង អស់គ្នាក៏នាំគ្នាឈប់រើសដណ្ដើមយករបស់ទ្រព្យ ទឹងគោសេះមិនបានជា ប្រុងប្រយ័ត្នរក្សាខ្លួន, នោះស្រាប់តែឮស្គរគំគ្រោះទឹងជាវឡើង ត្រឡប់ ទៅឃើញចៅប៉ាវទិងជីវហាយនាំទាហាន ២ កងក៏យសន្ធឹងចូលមក, ជូ-កាត់ឿនភ័យខ្លាចពេកណាស់ក៏បង្ខំត ឃើញអង់គីទឹងតាំងខៀនចាំ ក៏យខ្ទប់ប្រសព្វចូលមក, ឯប៊ុមម៉ាចៀវក៏លើកទាហានជុនថែមមកទៀត,

ផ្កាត់គៀនឃើញលើសកំឡាំងដែលទ័ពតស៊ូច្បាំងពុំបាន ក៏ថយទ័ពរត់ទៅដល់ស្រុកឈើរឈុន ហើយឲ្យទាហានឡើងរក្សានាទីសើនបន្ទាយ, ឯសុម៉ាចៀវក៏ឲ្យចូលចោមព័ទ្ធវាយប្រសព្វទាំង៤ទិស, នោះទាហានក្នុងកងទ័ពស្រុកកាំងតាំងក៏ថយទៅនៅឯជំបន់តាខ់ធង, ព្រះចៅចោម៉ក៏ទៅតាំងទ័ពប្រថាប់នៅស្រុកហាងសៀ ។

វេលានោះ ចុងហោយនិងសុម៉ាចៀវថា ក្នុងស្រុកឈើរពុននោះស្រូវអង្ករស្បៀងអាហារគឺនៅមានបរិបូណ៌, បើយើងនឹងព័ទ្ធទុកយូរក៏គង់មិនដាច់ខ្វះឲ្យលំបាក, ក្រែងតែទាហានស្រុកកាំងតាំងនឹងលើកមកវាយទ័ពពីក្រោយ យើងនឹងវរវីកលំបាក, ដែលយើងព័ទ្ធទុកទាំង៤ទិសដូច្នេះនេះនឹងនាំឲ្យថ្វស់ការ នឹងសុំឲ្យព័ទ្ធទុកតែ៣ទិស បើចំហទិសខាងត្បូង បើរត់ចេញពីស្រុកហើយ សឹមយើងឲ្យទាហានយើងលើកដេញប្រហារពីក្រោយទៅឲ្យយ៉ាងមាំ មុខជានឹងបានជ័យជំនះតែម្តង, ឯកងទ័ពកាំងតាំងនោះ គឺលើកពីផ្លូវឆ្ងាយ, ពោះនឹងនាំស្បៀងអាហារជាប់មកក៏តិចតួច ដែលនឹងបញ្ជូនមកទៀតក៏មិនទាន់ សូមឲ្យលើកកងទ័ពទៅស្កាត់ពីខាងក្រោយ នៅមិនទាន់ចូលវាយក៏នឹងផ្អើលក្តាក់រត់ទៅឯង ។

ឯសុម៉ាចៀវបានឮដូច្នោះក៏លើកដៃឡើងស្ទាបអង្អែលខ្នងចុងហោយ ហើយសរសើរថា អ្នកឯងមានគំនិតបេះរ៉ះគិតច្រើនណាស់ វិស័យដូចបញ្ញានិងគំនិតរបស់ទៀវលៀង ក្នុងគ្រាព្រះចៅហាន់កោចោ, ថាហើយ

ក៏ឲ្យអងគីលើកបន្ថយទាហានដែលព័ទ្ធខាងទិសឯត្បូងនោះចេញ ។

ឯស៊ុនលឹមស្រុកកាំងតាំង ក៏ឲ្យយកខ្លួនជូអ៊ីនាយទ័ពមុខទៅកាត់ផ្តន្ទាទោសថា គ្រាន់តែឲ្យទៅសង្កត់ជំណួបប៉ុនស្រុកឈើវល្ហុនប៉ុណ្ណោះ នៅធ្វើមិនបានពជការ បំណាច់បើនឹងទៅគិតវាយយកស្រុកវ៉ុយកុកទាំងមូល តើធ្វើម្តេចនឹងបាន ? បើធ្វើការគ្រានេះមិនឈ្នះដល់សត្រូវទេ យើងនឹងត្រូវប្រហារជីវិតបង់, ជូអ៊ីក៏គំនាប់លាត្រឡប់ទៅបន្ទាយហើយ ប្រឹក្សានឹងនាយទ័ពទាំងពួង; អ៊ីជួននាយកងទ័ពជូនថា ទិសខាងត្បូងសត្រូវមិនបានព័ទ្ធទេ, ខ្ញុំបាទសុំលើកកងទ័ពចូលទៅជួយកាត់កៀន ដើម្បីនឹងរក្សាស្រុកទុក លោកត្រូវលើកទាហានចូលវាយ កងទ័ពស្រុកវ៉ុយកុកចុះ, ខ្ញុំបាទនឹងលើកទាហានពីក្នុងចេញមកវាយប្រសព្វទៀត មុខជាកងទ័ពវ៉ុយកុកនឹងបែកជាប្រាកដ, ជូអ៊ីយល់ឃើញត្រូវទើបចាត់អ៊ុចជូនគេក, ជួនទួន, ប៊ុនយ៉ឹម នាយទាហាន ៤ នាក់នេះនាំពល ១០.០០០ លើកចូលទៅតាមផ្លូវទិសឯត្បូង ។

ឯទាហានស្រុកវ៉ុយកុកមិនមានបង្គាប់ឲ្យវាយស្កាត់ទុក ក៏បណ្តោយឲ្យកងទ័ពស្រុកកាំងតាំងលើកចូលទៅក្នុងស្រុក, ទើបយកសេចក្តីទៅជំរាបដល់ស៊ុម៉ាចៀវៗដឹងហើយទើបថា កងទ័ពស្រុកកាំងតាំងបែកគ្នាចូលទៅជួយរក្សាស្រុកទុក, ជូអ៊ីក៏លើកចូលវាយយើង សមគ្នះដែលយើងគិតទុកហើយ; ទើបឲ្យរកគង់គីទឹងកាន់កៀន នាយទាហាន ៤ នាក់បង្គាប់

ថា អ្នកឯងត្រូវលើកទាហានទៅបង្កប់នៅក្បែរផ្លូវ ដែលកងទ័ពជូអ៊ីទឹង លើកមក, បើគេបណ្ដោយចូលមកបន្តិចហើយត្រូវឲ្យទាហានស្រែក ហោដេញកាប់សម្លាប់តាមក្រោយចូលទៅ, អង្គី, គាន់កៀនក៏នាំទា-ហានទៅបង្កប់តាមបង្គាប់, លុះកងទ័ពជូអ៊ីលើកគ្នាបណ្ដោយចូលទៅ ស្រុកហើយ ក៏លើកពលចេញវាយពីក្រោយតាមទៅ កងទ័ពស្រុក កាំងតាំងក៏បែក, ខ្លួនជូអ៊ីក៏បែកទៅកេស៊ុនលឹម ១ ទឹង ណាស់ ថាឯងជា មេទ័ពបែកទឹងយកខ្លួនមិនបាន ក៏បង្គាប់ឲ្យទាហាននាំទៅសម្លាប់, ទើប ឲ្យហៅជួនហ៊ុយជាបុត្រជួនខ្លួនមកបង្គាប់ថា អ្នកឯងត្រូវស្រូតលើកទ័ព ទៅវាយស្រុកវ៉ុយកុកឲ្យថយទៅឲ្យបាន បើមិនបានទេ តាំងអាពុកតាំង កូនកុំវិលមកឃើញមុខយើងឡើយ, ស៊ុនលឹមបង្គាប់ហើយក៏លើកទៅ ដំបន់កៀនងៀប ។

ចុងហោយដំកបស៊ុម៉ាចៀវថា កងទ័ពដែលមកជួយនោះបែកទៅ ហើយ, យើងត្រូវលើកទាហានទៅព័ទ្ធឲ្យជុំវិញទាំង ៤ ទិសចុះ, ស៊ុម៉ា-ចៀវយល់ឃើញត្រូវ ក៏ឲ្យទាហានចេញទៅវាយទាំង ៤ ទិស, ឯជួន-ហ៊ុយលើកទាហានមក ឃើញទាហានស្រុកវ៉ុយកុកច្រើនណាស់ ទឹង ទំលាយចូលទៅមិនបាន ទឹងថយក្រោយទៅក៏ខ្លាចស៊ុនលឹម, ក៏ស្ម័គ្រ ចូលទៅនៅទឹងស៊ុម៉ាចៀវ ។ ក៏តាំងឲ្យជួនហ៊ុយជាទាហានទេ, ជួនហ៊ុយ មានសេចក្ដីត្រេកអរណាស់ រំពឹកកតញ្ញូតបគុណស៊ុម៉ាចៀវ ទើបសរ-

សេសំបុត្រជាសេចក្ដីថា ឲ្យជូនខ្លួនជាបិតា និងជូតេកជាមាសត្រូវចូលទៅ នៅនឹងសុម៉ាបៀវចុះ, ស៊ុនលឹមនោះមនុស្សកាចក្រក់ គ្មានសេចក្ដីមេត្តាករុណាសោះ, ខ្ញុំបាទក៏បានចូលទៅនៅនឹងសុម៉ាបៀវហើយ លុះសរសេរហើយ ក៏បង់សំបុត្រនោះនឹងព្រួញធ្នូហើយបាញ់ទំលាក់ទៅក្នុងស្រុក, ជូតេកបានសំបុត្រហើយក៏នាំទៅបង្ហាញជូនខ្លួន, ហើយក៏លបនាំបក្ខពួករបស់ខ្លួនបើកទ្វារចេញទៅនៅនឹងសុម៉ាបៀវ ។

ឯជូកាត់អៀនជាទុក្ខណាស់ គិតរកឧបាយដែលនឹងកែខ្លួនឲ្យរួច បៀវប៉ាំង និងបៀវអ៊ីជាទីប្រឹក្សាទើបនិយាយនឹងជូកាត់អៀនថា ស្បៀងអាហារក្នុងស្រុកនេះក៏ស្តើងស្ដួចណាស់ហើយ ពលទាហានក៏ច្រើន, ដែលនឹងសុំយូរទៅក៏ប្រហែលមិនគ្រប់គ្រាន់, នឹងឲ្យគេតទល់យូរណាស់មុខជាមិនស្រួល, ខ្ញុំបាទគិតថានឹងឲ្យលើកទាហានយើងនឹងទាហានស្រុកកាំងតាំងពារទំលាយចេញទៅឲ្យបាន ក៏ត្រូវតែប្រថុយច្បាំងឲ្យអស់ថ្វីដៃគ្រាតែស្លាប់ទាំងអស់គ្នាទៅចុះ, ជូកាត់អៀនបានឮដូច្នោះក៏ខឹងណាស់ ថាខ្ញុំឃើញល្មមនឹងរក្សាទុកនៅបាន, ដែលអ្នកមកគិតយ៉ាងនេះ ឃើញថា ស្រួលហើយឬ ? ថាយ៉ាងនេះគឺកែងឲ្យបាញ់សត្រូវ បើតទៅមុខ បើយអ្នកឯងមកនិយាយយ៉ាងនេះទៀត យើងនឹងឲ្យយកខ្លួនទៅប្រហារជីវិត ។

( នៅមានត )

# ពិធីបួងសួងសុំភ្លៀង

លោក ឆយ ស៊ីផាត រៀបរៀង

តាមបវេណីពីបូរាណកាលមក នៅប្រទេសកម្ពុជាយើងនេះបុព្វបុរស របស់យើងលោកតែងបានរៀបតាក់តែងធ្វើពិធីបួងសួងសុំភ្លៀង ឬ ហៅថា ពិធីវរុណសាស្ត្រ នៅក្នុងឆ្នាំណាដែលរាំងភ្លៀង ។ ក៏ប៉ុន្តែតាមប្រក្រតីធម្មតានោះច្រើនតែក្នុងខែជេស្ឋ ព្រោះតាមរដូវកាលនៅប្រទេសយើង រដូវភ្លៀងធ្លាក់ចាប់តាំងពីខែពិសាខមក តែបើខែពិសាខផុតទៅហើយក៏នៅតែគ្មានភ្លៀង គេក៏រៀបចំធ្វើពិធីវរុណសាស្ត្រ បួងសួងសុំទឹកភ្លៀងឲ្យធ្លាក់ចុះដើម្បីជាប្រយោជន៍ដល់កសិករ បានប្រកបការងារចិញ្ចឹមជីវិត ។

ពិធីបួងសួងសុំភ្លៀងនេះ អ្នកប្រាជ្ញពីបូរាណបានប្រតិដ្ឋឡើងស្រប ទៅតាមលក្ខណៈគតិពុទ្ធសាសនា ដោយសំអាងយកគុណានុភាពនៃព្រះរតនត្រ័យ អាស្រ័យទៅអានុភាពនិងវត្ថុស័ក្តិសិទ្ធិក្នុងលោកដើម្បីជាផ្លូវចិត្តប្រព្រឹត្តទៅតាមបំណង ។

**ពិធីការ** - តាមទំនៀមបូរាណ អ្នករៀបចំពិធីត្រូវជីកដីជម្រៅមួយហត្ថជាកងបួនជ្រុងស្មើប្រវែងមួយជ្រុង ១២ ហត្ថ ១ចំអាម រួចព័ទ្ធព័ទ្ធដោយរាជវតិ ដោយឥត្រូវគេលំអដោយទង់ជ្រុង ធ្វើរូបព្រះឥន្ទមួយព្រះហស្តស្តាំចង្អុលទៅមេឃ ព្រះហស្តឆ្វេងសំយុងចុះ រូបព្រះសុភូតិត្រូវគង់តែន តែនព្រះហស្តស្តាំចង្អុលទៅមេឃ ព្រះហស្តឆ្វេងដាក់លើភ្លៅ និងរូប

ព្រះគន្ធារតំរូបព្រះពុទ្ធជាតំណាងព្រះអង្គកាលទ្រង់ចុះស្រង់ទឹក មានសាការៈ សណ្ឋិតឈរព្រះហស្តស្ដាំបក់ហៅភ្លៀង ព្រះហស្តឆ្វេងទទួលទឹក ។ រូបសំណាកតាំងនេះត្រូវយកទៅដាក់នៅមាត់រណ្ដៅ ។ រួចយកត្រីរ៉ស់ ១ ទៅដាក់ក្នុងរណ្ដៅហើយចាក់ទឹកបន្តិចល្មមកុំឲ្យវាងាប់ ទើបនិមន្តព្រះសង្ឃ ៤ អង្គមកសូត្រធម៌សុភូតិសូត្រ ។ ចំពោះព្រះសង្ឃដែលនិមន្តការពិធីនេះត្រូវជម្រះអាបត្តិឲ្យបានបរិសុទ្ធសិន ។ ចំណែកពេលវេលាគឺគេប្រារព្ធនៅវេលាថ្ងៃត្រង់ ហើយហាមដាច់ខាតមិនឲ្យអ្នកដែលមករួមពិធី ទាំងព្រះសង្ឃទាំងឧបាសក មិនឲ្យបាំងឆ័ត្រឬទទួរម្លប់ការពារកំដៅឡើយ ។

នៅពេលចាប់ផ្ដើមពិធីអាចារ្យត្រូវសូត្រ **នោរន្ថោ** អញ្ជើញទេវតាខ្មោចព្រាយ បិសាច អារក្ស អ្នកតា ក្នុងស្រុកព្រៃភ្នំក្រមថ្ម សាគរ គិរីបព្វតា ស្រែចំការ ទូទាំងសកលមណ្ឌលព្រហ្មលោក ឲ្យចុះមកកំចាត់បង់អពមង្គលគោលាហល សឹកសាមសង្គ្រាមជ័យទុរ្ភិក្សអត់បាយ និងជម្ងឺតម្កាត់វិបត្តិផលស្រុក ជាទុក្ខក្នុងនគររួចហើយទើបនិមន្តលោកសូត្រធម៌តទៅ ។

ទៅតាមស្រុកខ្លះគេនិយម ចាប់ឆ្មាស្រោចទឹក ឬហែអ្នកតាយកទៅទំលាក់ទឹកឧបកិច្ចជាអ្នកតាក្រៅស្រុះ នេះជាតម្រាប់ប្រពៃណីនិយម ។

និទានទាក់ទងនឹងពិធីសុំភ្លៀង

ពិធីបុណ្យសាស្ត្រនេះ ជាទំនៀមប្រពៃណីបុរាណប្រមាណជាគតិពុទ្ធនិយមដែលបុរាណាចារ្យ ប្រាកដឡើងដោយមេឃស្រាយរឿងពីក្នុងគម្ពីរពុទ្ធនិយមជាគោលដែលជាប់ទាក់ទងនឹងហេតុដែលពំនឹងភ្លៀងដូចជារឿងនិទាន

ខ្ទះខាងក្រោមនេះ ។

**១-រឿងនឡបជាតក:** និទាននេះមានសេចក្ដីដំណាលថា គ្រាមួយនោះ នៅដែនកោសល គ្មានភ្លៀងធ្លាក់សោះ ម្ល៉ោះហើយបឹងបួគ្រពាំង រីងហួតស្ងួតអស់ ស្រះបោក្ខរណីមុខវត្តជេតពនមានតែភក់ ត្រីនៅក្នុងស្រះ ស្លាប់ជាច្រើន ហើយត្រូវហ្វូងក្អែកចឹកស៊ីរាល់ថ្ងៃ ។ ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ទតឃើញដូច្នោះ ទ្រង់ក៏មានព្រះមហាករុណាចំពោះត្រី ទើបទ្រង់ចុះទៅកាន់ស្រះ ហើយឲ្យអានន្ទពុទ្ធោបដ្ឋាកៈ យកសាដកមកផ្លាស់ស្រង់ ក៏ក្ដៅដល់អាសនាព្រះឥន្ទ្រាធិបតី ស្ដេចក៏ប្រើវស្សវលាហក បណ្ដាលឲ្យភ្លៀងធ្លាក់ចុះមក ។ ភិក្ខុទាំងឡាយឃើញហេតុដូច្នោះ ក៏សរសើរថាអស្ចារ្យណាស់ ទើបព្រះដ៏មានព្រះភាគត្រាស់ថាអស្ចារ្យអំពីពេលនេះ ដែលតថាគតបានត្រាស់ហើយ កាលពីតថាគតកើតជាស្ដេចត្រីរ៉ស់ឈ្មោះនឡបៈ នៅវស្សបូរ៍ក៏បានធ្វើឲ្យកើតអស្ចារ្យដូច្នេះដែរ ដោយសច្ចកិរិយាដើម្បីអនុគ្រោះដល់ពួកត្រីទាំងឡាយជាញាតិ ។ ឯសច្ចកិរិយានោះ គឺតថាគតបានពោលថា តាំងពីតថាគតកើតជាត្រីវេលាណា តថាគតមិនដែលក្លែងបៀតបៀនសម្បសត្វតូចមួយដោយខ្លួនឯងម្ដងសោះឡើយ ។ ដោយសច្ចកិរិយានេះហើយ ភ្លៀងក៏ធ្លាក់ចុះមកដោយប្រពៃ ។

**២-សុត្តជាតកធានានិសង្ស -** និទានមានដំណាលមានព្រះអរហន្តមួយព្រះអង្គព្រះនាម សុក្ខុតិត្ថេរ គង់នៅក្នុងព្រៃ ។ មានពេលមួយ លោកក៏ខិតខំចូលទៅសាច់ក្នុងរាជគ្រឹះ ពេលនោះ ព្រះពុទ្ធតម្ពិសាល

ប្រជានឹងធ្វើកុដិប្រគេន តែព្រះអង្គទ្រង់ភ្លេចទៅ ព្រះសុភូតិត្ថេរក៏គង់នៅ កណ្ដាលវាល គឺបណ្ដាលឲ្យរាំងភ្លៀង ទើបព្រះបាទពិម្ពិសារទ្រង់ព្រះតម្រិះរកហេតុបណ្ដាលឲ្យរាំង ក៏ទ្រង់ជ្រាបថាព្រះអង្គភ្លេចពាក្យប្រជាក៏បាត់ឲ្យរាជវល្លភ៍ធ្វើកុដិប្រគេនលោកភ្លាម លុះសង់កុដិរួចហើយភ្លៀងក៏បង្អុរចុះ មកមួយរំពេច ។

**៣ - សុភូតិសូត្រ** - សូត្រនេះមាននៅក្នុងកាណាវ៉ៈដែលមានដំណាលថា សម័យមួយព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ដែនមគធៈ ជាមួយភិក្ខុ ៥០០រូប លុះស្ដេចទៅដល់អង្គុត្តរនិគម ទ្រង់ក៏ចៀងចូលទៅ ។ ពេលនោះជារដូវភ្លៀង ក៏ប៉ុន្តែឥតមានភ្លៀងធ្លាក់សោះ បណ្ដាលឲ្យអ្នកនិគមនោះលំបាកវេទនាជាខ្លាំង ទើបព្រះដ៏មានបុណ្យទ្រង់ត្រាស់ហៅសុភូតិត្ថេរឲ្យចំរើនអាបោកសិណគឺប្រារព្ធយកទឹកជាអារម្មណ៍ ។ ព្រះសុភូតិត្ថេរក៏ទទួលតាមពុទ្ធដម្រាស់ ក៏សំឡឹងមើលអាកាសចូលកាន់អាបោកសិណ ហើយបន្លឺឧទានបំពោះព្រះឥន្ទព្រះព្រហ្មយមយក្ខនាគកុម្ភណ្ឌក្រុត អារក្សចតុលោកបាល ឲ្យរឭកនូវធម៌របស់ព្រះសម្មាសម្ពុទ្ធមានសច្ចៈ បួនប្រការជាដើម ដែលព្រះអង្គសំដែងហើយ ដោយអំណាចចេតោវិមុត្តប្រកបដោយមេត្តាកើតឡើងអំពីអាបោកសិណ សូមឲ្យសត្វទាំងឡាយកុំមានពៀរនឹងគ្នា កុំមានទុក្ខភ័យ ហើយចូរឲ្យវស្សាវលាហកបង្អុរភ្លៀងឲ្យធ្លាក់ចុះមកដោយស្រួលតាមរដូវកាល ។

ដោយមានរឿងរ៉ាវដូចពណ៌នាមកនេះ ក៏កើតទៅជាមូលហេតុដើមនៃពិធីវរុណសាស្ត្រ ឬពិធីបួងសួងសុំភ្លៀងរហូតមកដល់សព្វថ្ងៃនេះ ។

# រាជពង្សាវតារ

តាមសាស្ត្រាស្លឹករឹតបានពីវត្តកោកកាក

លោក ឃួន-សែម ចម្លង

លោក លី-ធាម តេង ពិនិត្យផ្ទៀង

( ក )

ថ្វាយសម្តេចព្រះមហាធម្មរាជាធិរាជ នៅបរមរាជវាំងចតុមុខភ្នំពេញ ស្តេចឲ្យនាមហៅពួករណ៍គជេន្ទ្រ ហើយស្តេចព្រះរាជដំណើរទៅស្ថាបនាព្រះចេតិយដំកល់ព្រះអដ្ឋិសម្តេចព្រះរៀមនិងសម្តេចព្រះភគនេយ្យានៅភ្នំសន្ទុក ហើយស្តេចព្រះរាជដំណើរវិលមកបរមរាជវាំងចតុមុខវិញ ឯសម្តេចព្រះមហាធម្មរាជា ស្តេចសោយរាជសម្បត្តិបាន ១៧ ព្រះវស្សា ព្រះជន្មបាន ៥០ វស្សាក៏សុវណ្ណគតទៅ ។ មហាសករាជ ១៤៦២ ឆ្នាំជូតទោស័ក ចៅពញាទាត់ព្រះជន្មបាន ២៥ ព្រះវស្សា ឡើងសោយរាជសម្បត្តិ ទទួលព្រះរាជឱការស្នងសម្តេចព្រះវររាជបិតា ទ្រង់ព្រះនាមហៅព្រះបាទសម្តេចព្រះស្រីសុគន្ធបទ ស្តេចទៅសាងព្រះរាជវាំងគង់ឯស្រុកបាសាន ក្នុងខេត្តស្រីសន្ធរ ស្តេចមានម្នាងម្នាក់ឈ្មោះអ្នកម្នាងពៅ កាលពុំទាន់សោយរាជសម្បត្តិនោះ អ្នកម្នាងពៅសម្ភពព្រះរាជបុត្រាមួយព្រះអង្គ ព្រះនាមហៅចៅពញាយសរ-ជា ឯចៅពញាចន្ទរាជា ជាព្រះអនុជពៅ គង់នៅព្រះរាជវាំងចតុមុខភ្នំពេញ ដល់ឆ្នាំរកសំរិទ្ធិស័កហ្លួងព្រះនាមឈ្មោះ កន ក្បត់ ដេញសម្តេចព្រះស្រីសុ-

គន្ធបទ ស្តេចនាំគស់គ្រប់គ្រួ ចេញពីព្រះរាជវាំងបាសានទៅប្រាស្រ័យនៅ ស្ទឹងក្នុងខេត្តកំពង់ស្វាយ ឯចៅពញាចន្ទរាជាស្តេចនាំគ្រប់គ្រួចេញព្រះរាជ វាំងកំពេញទៅប្រាស្រ័យនៅក្នុងខែត្រពោធិសាត់ ឯស្តេចព្រះស្រីសុគន្ធ បទស្តេចសោយរាជសម្បត្តិ ចៅនរេសរត់ចូលទៅនៅក្រុងស្រីអយុធ្យា វិញចាប់បានសៀមជាឈ្លើយក៏ច្រើន ហើយស្តេចព្រះរាជដំណើរត្រឡប់ មកគង់នៅព្រះរាជវាំងលង្វែកវិញ ឯចៅពញាយសរាជាព្រះភគិនេយ្យ ស្តេចមានព្រះរាជបុត្រី ១ ព្រះនាមហៅព្រះសុជាតិស្ត្រី ហើយចៅពញា យសរាជាក៏សុគតទៅ មហាសករាជ ១៥១០ ឆ្នាំជូតសំរឹទ្ធិស័ក សម្តេចចៅ ពញាចន្ទរាជាគ្រងរាជសម្បត្តិព្រះជន្មបាន ៣៧ ព្រះវស្សា ស្តេចឡើង សោយរាជសម្បត្តិទទួលព្រះរាជឱង្ការព្រះនាមហៅ ព្រះបាទសម្តេចព្រះ រាជឱង្ការព្រះវររាជាធិរាជរាមាធិបតីព្រះស្រីសុរិយោពណ៌ធម្មិករាជាស្តេច យកព្រះវង្សធំជាព្រះរាជទេពី លើកឡើងជាព្រះអគ្គមហេសីព្រះនាមហៅ សម្តេចព្រះភគវតីស្រីទេវធីតា ពីកាលឆ្នាំរោងអដ្ឋស័កនោះសម្តេចព្រះភគវ តីស្រីទេវធីតាទ្រង់ប្រសូតព្រះរាជបុត្រា ១ ព្រះអង្គព្រះនាមបរមរាជា ក្រោយ នោះស្តេចមានព្រះរាជបុត្រី ១ ទៀត ប្រទុំសុរិស្ត្រី លុះដល់ឆ្នាំថោះត្រី ស័កនោះព្រះចៅធម្មរាជាធិរាជឲ្យនៅក្រុងស្រីអយុធ្យា ឲ្យចៅពញាអុនជា ព្រះរាជបុត្រា សម្តេចព្រះស្រីរាជាត្រូវជាព្រះរៀមព្រះអយ្យកោ ១ នាំពល សៀម ៩ ម៉ឺនលើកទ័ពចេញពីក្រុងស្រីអយុធ្យាមកច្បាំង ចូលដល់ក្នុង

ខេត្រពោធិសាត់ទើបសម្តេចព្រះបរមរាជារាមាធិរាជធិបតី ព្រះរាជដំណើរ
លើកទ័ពចេញពីព្រះរាជវាំងលង្វែក ទៅទទួលចម្បាំងដល់ខេត្រពោធិសាត់
ស្តេចមាននិមិត្តឃើញ ដើមពោធិស្ងួតយូរហើយ រស់ឡើងវិញ នោះ
ស្តេចយកផ្កាស្លាម្លូទៀនធូបបូជានមស្ការ ថ្វាយព្រះពោធិនោះហើយ
ស្តេចចេញតតាំងចម្បាំងឈ្នះចៅពញាអុង ឯចៅពញាអុងព្រះជន្ម ៦១ព្រះ
វស្សាក្ស័យព្រះជន្មលើកព្រះទីនាំងគជេន្ទ្រក្នុងការសង្គ្រាម ចាប់បានកង
ទ័ពសៀមជាឈ្លើយក៏ច្រើន កងទ័ពសៀមដែលសល់ខ្លះ ក៏រត់វិលចូល
ទៅក្រុងស្រីអយុធ្យាវិញ ទើបស្តេចលើកព្រះសពចៅពញាអុងរួចហើយ
ស្តេចសាងព្រះវិហារមួយ នៅខាងដើមពោធិនោះ ហើយស្តេចយកពាន
ព្រះស្រីរបស់ស្តេចមួយ របស់ចៅពញាអុង១ សាងជាព្រះពុទ្ធរូប ២ព្រះ
អង្គបញ្ចុះព្រះអដ្ឋិចៅពញាអុងនៅទីវិហារនោះឯដើមព្រះពោធិនោះស្តេចឲ្យ
ហៅព្រះពោធិមានបុណ្យ ហើយស្តេចព្រះរាជដំណើរត្រឡប់មកគង់នៅ
ព្រះរាជវាំងលង្វែកវិញ ក្នុងរាជសម្បត្តិនូវស្តេចទ្រង់ព្រះពស្ត្រប្រវែង ៨ ហត្ថ
អស់នាម៉ឺនមុខមន្ត្រី ដណ្តប់ស្សប្រវែង ៨ ហត្ថជិះត្រែប៉ាងត្រែកែកានផ្លិត
ស្លឹកត្នោតចូលគាល់ទូលក្តីឆ្លើយក្តី ថាព្រះបាទអម្ចាស់ ស្តេចសោយរាជ
សម្បត្តិបាន ១៦ ព្រះវស្សាទៀត សិរីទាំងគ្រងទាំងសោយរាជសម្បត្តិបាន
៥១ ព្រះវស្សាព្រះជន្មបាន ៨៥ ព្រះវស្សា ឡើងសោយរាជសម្បត្តិទទួលព្រះ
រាជទុការស្នងព្រះវររាជបិតាទ្រង់ព្រះនាមហៅ ព្រះសម្តេចព្រះបរមរាជា

ធិរាជរាមាធិបតីស្តេចយកព្រះសុជាតិស្ត្រីព្រះអនុជព្រះអយ្យកោ ១ ជាព្រះអគ្គមហេសី លើកព្រះនាមហៅសម្តេចព្រះភគវតីស្រីចក្រពត្តិរាជ ហើយកាលពីពុំទាន់សោយរាជសម្បត្តិ នៅព្រះជន្ម ២២ ព្រះវស្សា ឆ្នាំឆ្លូវនព្វស័ក នោះសម្តេចព្រះភគវតីស្រីចក្រពត្តិរាជ ប្រសូតព្រះរាជបុត្របុរស ១ អង្គព្រះនាមព្រះសត្ថាដល់ព្រះជន្មបាន ៣៧ ព្រះវស្សា ឆ្នាំរោងចត្វាស័ក នោះអ្នកម្នាងកេសរសម្ភពព្រះរាជបុត្រា ១ អង្គ ព្រះនាមព្រះស្រីសុពណ៌ ដល់ព្រះជន្ម ៤៦ វស្សា ឆ្នាំឆ្លូវត្រីស័ក នោះអ្នកម្នាងវង្សសម្ភពព្រះរាជបុត្រា ១ ព្រះអង្គព្រះនាមហៅពញាអន លុះដល់ឆ្នាំមមីអដ្ឋស័ក សម្តេចព្រះបរមរាជាធិរាជរាមាធិបតី លើកទ័ពព្រះរាជដំណើរចេញពីព្រះរាជវាំងលង្វែកទៅគង់នៅកំពង់ក្រសាំង ហើយស្តេចឲ្យកេណ្ឌកងទ័ព ទៅចាំស្រុកនគររាជសីមា បាននសៀមជាឈ្លើយជាច្រើន ហើយស្តេចព្រះរាជដំណើរវិលមកគង់នៅព្រះរាជវាំងលង្វែកវិញ ខណៈនោះស្តេចលាវឲ្យនាម៉ឺន ២ នឹងពល ១ ពាន់ នាំដំរីកំពស់ ៤ ហត្ថ ភ្នាល់នឹងដំរីស្តេចព្រះបរមរាជាធិរាជរាមាធិបតី ថាបើដំរីស្តេចព្រះបរមរាជាធិរាជរាមាធិបតីឈ្នះ នឹងឲ្យស្រុកលាវមកជាចំណុះ បើដំរីស្តេចលាវឈ្នះនឹងឲ្យស្រុក ខ្មែរជាចំណុះស្រុកលាវ នោះដំរីសម្តេចព្រះបរមរាជាធិរាជរាមាធិបតីកំពស់តែ ៧ ហត្ថ ដល់ឈ្នះដំរីស្តេចលាវ ហើយស្តេចឲ្យគួសពលលាវទាំង ១ ពាន់នោះ ទុកនៅព្រះរាជវាំងលង្វែកវិញទាំងអស់ បើកតែនាម៉ឺនលាវតោះឲ្យនាំដំរីចុះទៅស្រុកលាវវិញ ត្រា

នោះស្ដេចលាវទ្រង់ព្រះក្រោធកេណ្ឌពលជាច្រើន ក្នុងឆ្នាំមមែនព្វស័ក លើកទ័ពជាពីរផ្លូវ ស្ដេចលាវលើកទ័ពដើរគោក មហាឧបរាជលាវលើកទ័ពដើរទឹក ចូលមកដល់ក្នុងខែត្រសទុក នោះសម្ដេចព្រះបរមរាជាធិរាជរាមាធិបតី ស្ដេចលើកទ័ពចេញពីព្រះរាជវាំងលង្វែកទៅដល់ខែត្រសទុក ទទួលច្បាំងឈ្នះស្ដេចលាវ ចាប់បានលាវជាឈ្លើយក៏ច្រើន ឯស្ដេចលាវនិងមហាឧបរាជលាវរត់រួចត្រឡប់ចូលទៅស្រុកលាវវិញ នោះស្ដេចព្រះដំណើរត្រឡប់មកគង់នៅព្រះរាជវាំងលង្វែកវិញ ដល់មកឆ្នាំវកសំរិទ្ធិស័កនោះ មហាឧបរាជលាវទ័ពដើរទឹកចូលមកច្បាំង ដល់កោះចៅរ៉ាមម្ដងទៀតទើបសម្ដេចព្រះបរមរាជាធិរាជរាមាធិបតីលើកព្យុហៈ ចេញចតុរង្គដើរទឹក គង់ព្រះទីនាំងនាវាទូវអស់ទាំងទ័ពជាច្រើន ស្ដេចព្រះរាជដំណើរចេញទៅដល់កោះចៅរ៉ាម ទទួលច្បាំងឈ្នះមហាឧបរាជលាវ ចាប់បានពលលាវជាឈ្លើយក៏ច្រើន ឯមហាឧបរាជលាវរត់រួចត្រឡប់ចូលទៅស្រុកលាវវិញ ឯលាវដែលចាប់បានមកនោះ ស្ដេចឲ្យហៅលាវបាក់ទូក ហើយស្ដេចព្រះរាជដំណើរត្រឡប់មកគង់នៅព្រះរាជវាំងលង្វែកវិញ ឯសម្ដេចព្រះបរមរាជាធិរាជរាមាធិបតី សោយរាជសម្បត្តិបាន ១១ ព្រះវស្សាព្រះជន្មបាន ៥៧ វស្សាក៏សុវណ្ណគតទៅ មហាសករាជ ១៥៣៤ ឆ្នាំជូតចត្វាស័ក ព្រះសត្ថៈ ព្រះជន្មបាន ២៤ ព្រះវស្សាឡើងសោយរាជសម្បត្តិទទួលព្រះរាជធុរស្នង ព្រះជនកនាថទ្រង់ព្រះនាមហៅ ព្រះបាទសម្ដេចព្រះបរមរាជាធិរាជរាមាធិ

ធិបតី ស្ដេចយកព្រះវង្សធំជាព្រះរាជទេពី លើកឡើងជាព្រះអគ្គមហេសី ព្រះនាមថាសម្ដេចព្រះភគវតីចក្រពត្តិរាជ ហើយពីកាលពុំទាន់សោយរាជ្យសម្បត្តិ ព្រះជន្មបាន ២២ ព្រះវស្សា ឆ្នាំចទោស័កនោះសម្ដេចព្រះភគវតីស្រីចក្រពត្តិរាជប្រសូតព្រះរាជបុត្រា ១ អង្គព្រះនាម ព្រះជ័យជេស្ឋា ស្ដេចសោយរាជសម្បត្តិបាន ៤ វស្សា ឆ្នាំថោះនព្វស័កនោះ សម្ដេចភគវតីស្រីចក្រពត្តិរាជ ប្រសូតព្រះរាជបុត្រា ១ អង្គទៀត ព្រះនាមហៅពញាតន់ហើយស្ដេចមានម្នាងលាវមួយទៀតឈ្មោះអ្នកម្នាងពេជ្រមៃសាវ ដល់ឆ្នាំរោងអដ្ឋស័កនោះ អ្នកម្នាងពេជ្រលាវមៃសាវសម្ភពព្រះរាជបុត្រា ១ អង្គ ព្រះនាមហៅពញាញោម ទើបសម្ដេចព្រះរាជដំណើរលើកទ័ពចូលទៅច្បាំងនឹងស្រុកក្រុងស្រីអយុធ្យា ប្រទះទ័ពព្រះរាជរាំងច្បាំង ចាប់បានសៀមជាឈ្លើយក៏ច្រើន ហើយស្ដេចព្រះរាជដំណើរត្រឡប់វិលមកព្រះរាជវាំងលង្វែកវិញ ឯព្រះស្រីសុភាវណៈ ជាព្រះអនុជកណ្ដាលមានព្រះរាជបុត្រា ២ អង្គព្រះនាមព្រះជេស្ឋា ១ អង្គ ព្រះនាមឧទ័យ ១ អង្គ មហាសករាជ ១៥៤៤ ឆ្នាំវកទោស័ក នោះព្រះបាទសម្ដេចព្រះបរមរាជាអគ្គរាជាធិបតី ស្ដេចសោយរាជសម្បត្តិបាន ៩ វស្សា ព្រះជន្ម ៣២ វស្សា ឯព្រះជ័យជេស្ឋា ជាព្រះរាជបុត្រាច្បង ព្រះជន្មបាន ១១ វស្សា ហៅពញាតន់ជាព្រះរាជបុត្រាកណ្ដាល ព្រះជន្មបាន ៦ វស្សា នោះស្ដេចទ្រង់តាំងលើកព្រះរាជបុត្រាទាំងពីរឡើងសោយរាជសម្បត្តិ ព្រះរាជបុត្រច្បងព្រះនាមហៅព្រះបាទសម្ដេច

ស្តេចព្រះរាជឱង្ការជ័យជេស្ឋាធិរាជរាមាធិបតី ឯព្រះរាជបុត្រកណ្តាលព្រះនាមហៅព្រះបាទសម្តេចព្រះរាជឱង្ការព្រះបរមរាជាធិរាជរាមាធិបតី ខណៈនោះព្រះចៅនរេសូរក្រុងស្រីអយុធ្យា លើកកងទ័ពពល ៥ ម៉ឺន ចូលមកដល់ព្រះរាជវាំងលង្វែក ច្បាំងនឹងសម្តេចព្រះសត្ថាបរមរាជាមហាធិបតីច្បាំងគ្នាជាយូរខែបាញ់បែកព្រះរាជវាំងលង្វែក ហើយស្តេចព្រះអគ្គមហេសីនិងចៅពញាមនជាព្រះអនុជរៅ និងព្រះទេវីក្សត្រី ត្រូវជាព្រះមាតុច្ឆានិងព្រះរាជបុត្រព្រះនាមសម្តេចព្រះ ជ័យជេស្ឋាធិរាជ ១ សម្តេចចៅពញាតន់ជរមរាជា ១ សោយរាជសម្បត្តិ និងចៅពញាញោមជាព្រះរាជបុត្រពៅ ១ ដល់ចេញពីព្រះរាជវាំងលង្វែកទៅគង់ឯស្រុកស្រីសឈរ កាលនោះព្រះចៅនរេនចាប់បានព្រះស្រីសុពារណោ : និងព្រះរាជបុត្រព្រះស្រីសុពារណ: ព្រះនាមជ័យជេស្ឋា ១ អង្គព្រះឧទ័យ ១ អង្គ ទាំង ៣ អង្គ នាំយកចូលទៅក្រុងស្រីអយុធ្យា ឯព្រះចៅនរេនទុកតែមហាមន្ត្រីសៀម ឲ្យមកឈរនៅស្រុកឧត្តុង្គមានជ័យ ដល់ឆ្នាំមមីទោស័ក ព្រះវង្សឈ្មោះអ្នកព្រះរាមជើងព្រៃ មកសុំព្រះរាជទេពីសម្តេចព្រះសត្ថាបរមរាជាធិរាជរាមាធិបតីនៅស្រុកស្រីរឈរ នោះស្តេចមិនព្រមឲ្យ ក៏ព្រះរាជដំណើរនាំព្រះរាជទេពីនិងព្រះ វបុត្រព្រះនាមសម្តេចព្រះជ័យជេស្ឋាធិរាជ ១ អង្គ សម្តេចព្រះចៅពញាតន់រាមរាជា ១ អង្គដែលឲ្យសោយរាជសម្បត្តិ នោះចេញពីស្រុកស្រីសឈរ ទៅនៅស្រុកលាវដល់ឆ្នាំមមែត្រីស័កសម្តេចព្រះសត្ថាបរះរាជាសុគតទៅ ដល់ឆ្នាំរក

ចត្វាស័ក សម្តេចព្រះជ័យជេស្ឋាធិរាជសុគតទៅទៀត នៅតែសម្តេចពញា តន់បរមរាជា គង់នៅស្រុកលាវតែមួយអង្គ ឯចៅពញាអននាំព្រះអនុជ ទៅ ១ អង្គ ចៅពញាញោម ១ អង្គ ស្តេចគង់នៅព្រះរាជវាំងស្រុកស្រីស ឈរ អ្នកព្រះរាមជើងព្រៃឡើងគ្រងរាជសម្បត្តិនៅស្រុកស្រីសឈរ ហើយ អ្នកព្រះរាមជើងព្រៃលើកទ័ពមកដល់ឧត្តុង្គមានជ័យ ច្បាំងដេញមន្ត្រី សៀមរត់ចូលទៅក្រុងស្រីអយុធ្យាវិញ ឆ្នាំរកា ចត្វាស័ក ចាប់ងឈ្មោះរូបវិស្ស វេទ្យាជាបុត្រធម៌សម្តេចព្រះសត្ថាបរមរាជានោះ វិលពីស្រុកលាវមកដល់ ស្រុកស្រីសឈរ ឯអ្នកព្រះរាមជើងព្រៃគ្រងរាជសម្បត្តិបាន ៣ វស្សា ហើយអ្នកព្រះរាមជើងព្រៃ គិតល្បិចនឹងសម្លាប់ចាប់ង ចាប់ងដឹងខ្លួនលុះ អ្នកព្រះរាមជើងព្រៃស្លាប់ ហើយចាប់ងរូបវិស្សវេទ្យាវិលចូលទៅ គាល់អញ្ជើញសម្តេចចៅពញាតន់បរមរាជា អំពីស្រុកស្រីសឈរឲ្យសោយរាជ សម្បត្តិ មហាសករាជ ១៤៩៤ ឆ្នាំរការ បញ្ចស័ក សម្តេចចៅពញាតន់ បរមរាជាព្រះជន្មបាន ១៩ ព្រះវស្សា ឡើងសោយរាជសម្បត្តិទទួលព្រះរាជ ទុក្ការ គង់នៅព្រះរាជវាំងស្រីសឈរ ដល់ឆ្នាំកុរ សប្តស័ក សម្តេចចៅពញា តន់បរមរាជាព្រះជន្មបាន ២១ វស្សា ស្តេចព្រះរាជដំណើរលើកទ័ពចេញទៅ ចាប់បាមស្រុកត្បូងឃ្មុំ នោះមានរាមរឈ្មោះចៅពិត ១ ផ្កា ឈ្មោះសក្យណា ១ [illegible] ស្តេចក្បួនព្រះជន្ម [illegible] សករាជ [illegible] ឆ្នាំកុរ សប្តស័ក ចៅពញា អនជាព្រះអនុជ [illegible] ជាព្រះជន្មបាន [illegible] ៩ វស្សា ឡើងសោយ

រាជសម្បត្តិស្នងសម្ដេចព្រះកតនេយ្យា ទ្រង់ព្រះនាមសម្ដេចព្រះបរមរាជា ស្ដេចគង់នៅព្រះរាជវាំងស្រុកស្រីសឈរ ហើយស្ដេចឲ្យទៅយកនាងពៅ ឯពញាសេដ្ឋីជាប្ដីរត់ចូលទៅកែវព្រះភ្លើង ហើយកែវព្រះភ្លើងមកលុកព្រះឬាទព្រះបរមរាជាក្សយព្រះជន្ម នៅព្រះរាជវាំងស្រីសឈរ មហាសករាជ ១៤៥៨ ឆ្នាំជូតអដ្ឋស័ក ចៅពញាញោមព្រះរាជបុត្រពៅ ព្រះសត្ថាបរមរាជាព្រះជន្ម ២១ ព្រះវស្សា ឡើងគ្រងរាជសម្បត្តិស្នងសម្ដេចព្រះបិតុលា ទ្រង់ព្រះនាមសម្ដេចព្រះកែវហ្វា គង់នៅព្រះរាជវាំងស្រុកស្រីសឈរស្ដេចពុំរិះគិតរាជការផ្ទៃក្រោមឡើយ ពុំគង់ដោយទូវក្រិត្យព្រះមហាក្សត្រ ប្រព្រឹត្តខាងតែសេចក្ដីខុស ធ្វើបាណាតិបាតកាមេសុមិច្ឆាសុរាមេរ័យ ដើរតែតែបាញ់សត្វ ចាប់កូនក្រមុំគេ ទើបសម្ដេចព្រះទេវីក្សត្រីត្រូវជាសម្ដេចព្រះអយ្យកាសម្ដេចព្រះកែវហ្វា ពុំរិះគិតរាជការប្រព្រឹត្តខុសដូច្នោះ ឲ្យសារទៅក្រុងស្រីអយុធ្យា ក្រាបទូលព្រះចៅឯកាទសរដ្ឋ សូមសម្ដេចព្រះសុរិយោពណ៌ជាព្រះកតនេយ្យានោះមកឲ្យសោយរាជសម្បត្តិ នោះព្រះចៅឯកាទសរដ្ឋ បើកសម្ដេចព្រះស្រីសុរិយោពណ៌ឲ្យចេញមកក្រុងកម្ពុជាធិបតី ដល់មកគង់នៅកោះស្លាកែត ឯសម្ដេចព្រះទេវីក្សត្រី នឹងសម្ដេចព្រះកែវហ្វា នូវព្រះរាជវង្សានុវង្ស ចូលមកគង់មូលនៅកោះស្លាកែតទើបសម្ដេចព្រះរាជឧត្ដរ ព្រះស្រីសុរិយោពណ៌បរមរាជា ស្ដេចឲ្យកម្រោះបគស់ស្រុកក្លួចធិប្បុះខ្ទះទៅទះ ក៏ស្ដេចឲ្យនាំសារទៅក្រុងស្រីអយុធ្យាក្រាបទូល

ព្រះចៅឯកាទសរដ្ឋ សូមព្រះជ័យជេដ្ឋា ១ ព្រះឧទ័យរាជ ១ ជាព្រះរាជបុត្រទាំងពីរអង្គ មកគ្រងកម្ពុជាធិបតី ឯព្រះចៅឯកាទសរដ្ឋ ព្រមបើកព្រះរាជបុត្រទាំង ២ អង្គ ទើបសម្តេចព្រះរាជឱង្ការ ព្រះស្រីសុរិយោពណ៌បរមរាជាឲ្យព្រះរាជបុត្រទាំង ២ ព្រះអង្គ ចេញច្រាមច្រាបអស់ស្រុកតូចធំរាបអស់ហើយ ស្តេចនាំរាជវង្សានុវង្ស ចេញអំពីព្រះរាជវាំងកោះស្លាកេតុ ស្តេចព្រះរាជដំណើរមកសាងព្រះរាជវាំងគង់នៅត្រើយល្វាឯម ហើយស្តេចលើកព្រះសុជាតិស្រី ឡើងជាព្រះអគ្គមហេសី ព្រះនាមហៅសម្តេចកេតកីស្រីសុជាតា ដល់ឆ្នាំខាល សំរឹទ្ធិស័ក នោះសម្តេចព្រះកែវហ្វាដែលស្តេចទៅរិក្យត្រីបទួយចេញពីគ្រងរាជសម្បត្តិនោះ ចេញទៅជាសត្រូវគិតលុកសម្តេចព្រះរាជឱង្ការ ព្រះស្រីសុរិយោពណ៌បរមរាជាធិរាជជាព្រះបិតុលា នោះសម្តេចព្រះរាជឱង្ការ ព្រះស្រីសុរិយោពណ៌បរមរាជាធិរាជទ្រង់ប្រោស ឲ្យចាប់យកសម្តេចព្រះកែវហ្វាសម្លាប់តាមទោសប្រវេណីក្សត្រក្នុងរាជសម្បត្តិ សម្តេចព្រះរាជឱង្ការព្រះស្រីសុរិយោពណ៌បរមរាជាធិរាជនោះស្តេចអាវផាយ អស់នាម៉ឺនមុខមន្ត្រីតូចធំ នាយមហាត នាយពលឲ្យពាក់អាវផាយ ឡើងគាល់ ទូលក្តីថ្វាយក្តី ថាព្រះស្រីសារពេជ្ញសម្តេចនរនាថ ឯខុនណាងស្រីឲ្យថ្វាយថាពារ ថ្វាយព្រះអគ្គមហេសីថាវែម ថ្វាយស្តេចគ្រប់ព្រះអង្គថាព្រះបាទម្ចាស់ ស្តេចសោយរាជសម្បត្តិបាន ១៨ ព្រះវស្សា ចំនួនរាជសម្បត្តិឲ្យព្រះជ័យជេដ្ឋាជាព្រះរាជបុត្រច្បង មហាសក

រាជ ១៥៩៤ ឆ្នាំមមីពត្វាស័ក ឯព្រះឧទ័យ ព្រះជន្មបាន ៣៨ វស្សា ព្រះ
ជ័យជេស្ឋា ព្រះជន្មបាន ៤០ វស្សា ឡើងសោយរាជសម្បត្តិទទួលព្រះរាជ
ឧង្ការ ទ្រង់ព្រះនាម សម្តេច ស្តេចព្រះរាជឧង្ការ ព្រះជ័យជេស្ឋាធិរាជរាមា
ធិបតី ស្តេចគង់នៅព្រះរាជវាំងត្រើយល្វាឯម ហើយស្តេចឲ្យនាមព្រះឧទ័យ
រាជាជាព្រះអនុជ ហៅសម្តេចព្រះឧទ័យបរមរាជា ជាព្រះវររាជបិតា ស្តេច
គង់នៅឧបយោរាជ ដល់ឆ្នាំមមែបញ្ចស័ក ព្រះជន្មវស្សាបាន ៦៤ វស្សា
ក៏សុវណ្ណគតទៅនៅព្រះរាជវាំងត្រើយល្វាឯម ហើយស្តេចប្រជាប់ការធ្វើ
បុណ្យថ្វាយព្រះភ្លើង ព្រះបរមសព រួចហើយសម្តេចព្រះរាជឧង្ការព្រះជ័យ
ជេស្ឋាធិរាជរាមាធិបតី ស្តេចនាំសម្តេចព្រះរាជឧទ័យបរមរាជា ជាព្រះ
អនុជនិងអស់ព្រះរាជវង្សានុវង្ស ចេញពីព្រះរាជវាំងត្រើយល្វាឯម ព្រះរាជ
ដំណើរទៅសាងព្រះរាជវាំងគង់នៅឧត្តុង្គមានជ័យ ឯអ្នកអង្គបូរព្រះរាជ
បុត្រីស្តេចយួន នោះស្តេចជាព្រះរាជទេពី លើកឡើងជាព្រះអគ្គមហេសី
ហៅសម្តេចព្រះភគវតីព្រះស្រីក្សត្រ កាលសម្តេចព្រះរាជឧង្ការព្រះជ័យ
ជេស្ឋាធិរាជរាមាធិបតី ពុំទាន់សោយរាជសម្បត្តិ ព្រះជន្មបាន ២៦ ព្រះ
វស្សាក្នុងឆ្នាំរោងសំរិទ្ធិស័ក នោះអ្នកម្នាងសុខ សម្ភពព្រះរាជបុត្រា ១ ព្រះ
នាមហៅចៅពញាតូ អ្នកម្នាងសម្ភពព្រះរាជបុត្រា ១ ព្រះនាមហៅចៅពញា
នូ ស្តេចសោយរាជសម្បត្តិបាន ៦ វស្សា នៅឆ្នាំរកាសំរ អ្នកម្នាងលាវ
មួយឈ្មោះអ្នកម្នាងប៉ុស សម្ភពព្រះរាជបុត្រា ១ ព្រះនាមហៅចៅពញាចន្ទ

ខណៈនោះព្រះចៅប្រាសាទថោងក្រុងស្រីអយុធ្យា លើកទ័ពដើរគោក ចូលមកជិតដល់កំពង់ឆ្នាំងទើបសម្តេចព្រះរាជ ព្រះជ័យជេស្ឋាធិរាជរាមាធិបតី ស្តេចលើកទ័ពចេញពីព្រះរាជវាំងឧត្តុងមានជ័យ ទៅទទួលច្បាំងគ្នានៅកំពង់ឆ្នាំងឈ្នះព្រះចៅប្រាសាទថោង ចាប់បានជាឈ្លើយក៏ច្រើន នោះព្រះចៅប្រាសាទថោង រត់ចូលទៅក្រុងស្រីអយុធ្យាវិញ ឯពលសៀមដែលចាប់បានមកជាឈ្លើយនោះ ស្តេចឲ្យហៅសៀមចុះគង់ ដល់ឆ្នាំចអដ្ឋស័កព្រះចៅស្រីធម្មរាជាមហាឧបរាជ លើកទ័ពដើរទឹក ចូលមកដល់ស្រុកពាមព្រាំងម្តងទៀត នោះស្តេចលើកទ័ពចេញពីព្រះរាជវាំងឧត្តុងមានជ័យទៅទទួលច្បាំងឈ្នះព្រះស្រីធម្មរាជា រត់វិលចូលទៅក្រុងស្រីអយុធ្យាវិញ ហើយស្តេចព្រះរាជដំណើរ វិលចូលមកគង់ព្រះរាជវាំងឧត្តុងមានជ័យវិញនោះស្តេចស្អាងព្រះចេតិយ៍ធំ១ នៅលើភ្នំព្រះរាជទ្រព្យ ហៅព្រះចេតិយត្រៃត្រឹង្ស បញ្ចុះព្រះអដ្ឋិព្រះស្រីសុរិយោពណ៌ ជាសម្តេចព្រះបរមជនកនាថ ស្តេចសោយរាជ្យបាន១០វស្សា ព្រះជន្មបាន៤៩វស្សានៅថ្ងៃព្រហស្បតិ៍ ៣កើតខែមិគសិរ ឆ្នាំថោះត្រីស័ក ស្តេចក៏សុវណ្ណគតទៅ មហាសករាជ ១៥៧៣ ឆ្នាំថោះត្រីស័ក ចៅពញាតូព្រះរាជបុត្រច្បងសម្តេចព្រះរាជឱង្ការ ព្រះជ័យជេស្ឋាធិរាជនោះ ព្រះជន្មបាន២៤វស្សាឡើងសោយរាជសម្បត្តិ ទទួលព្រះរាជឱង្ការព្រះស្រីធម្មរាជាធិបតី ហើយស្តេចព្រះរាជដំណើរទៅស្អាងព្រះរាជវាំង គង់ឯកោះឃ្លោក ឯសម្តេច

ឧទ័យបរមរាជាធិរាជ ព្រះជន្មបាន ៤៧ វស្សា ឡើងជាឧបយោរាជនៅ
ព្រះកំពង់ឧត្ដុង្គមានជ័យ ស្ដេចមានម្នាង ៣ នាក់ ពីកាលឆ្នាំរកាអដ្ឋស័កអ្នក
ម្នាងសនសម្ដេចព្រះរាជបុត្រា ១ ព្រះនាមអ្នកអង្គនន់ នៅឆ្នាំចសំរឹទ្ធិស័កអ្នក
ម្នាងសួសសម្ដេចព្រះរាជបុត្រា ១ អង្គព្រះនាមអ្នកអង្គស្ងួរ ឆ្នាំជូតត្រីស័ក
សម្ដេចព្រះរាជបុត្រាមួយទៀត ព្រះនាមអ្នកអង្គនន់ នៅឆ្នាំខាលបញ្ចស័ក
អ្នកម្នាងអិន សម្ដេចព្រះរាជបុត្រា ១ អង្គព្រះនាមអ្នកអង្គអុម ឯព្រះបាទ
សម្ដេចស្ដេចព្រះរាជឧង្ការព្រះស្រីធម្មរាជាធិរាជរាមាធិបតី គង់ឯព្រះរាជវាំង
គោះឃ្លោកនោះស្ដេចឲ្យលើកទ័ព ទៅចាប់ស្រុកសុកណានគររាជសីមា
បានគ្រួនាំមកខ្លះ ស្ដេចសោយរាជសម្បត្តិបាន ៨ វស្សា ព្រះជន្មបាន ៣១
វស្សាឆ្នាំចពោស័កនោះ ស្ដេចពុំជាប់ព្រះទ័យ កើតប្រាំងនឹងសម្ដេចព្រះ
បរមរាជាធិរាជឧបយោរាជជាសម្ដេចព្រះបិតុច្ឆានោះ ឯសម្ដេចព្រះឧទ័យ
បរមរាជាធិរាជប្រាំងឈ្នះ សម្ដេចព្រះរាជឧង្ការ ព្រះស្រីធម្មរាជាក្ស័យ
ព្រះជន្មក្នុងការសង្គ្រាម នៅខែត្រកញ្ជរបរិបូណ៌ ចប់ហោង ។

## ខ្សែទី ២

មហាសករាជ ១៤៨១ ឆ្នាំកុរឯកស័ក ហៅពញាទូរព្រះនាមព្រះអង្គ
ទង ជាព្រះរាជបុត្រព្រះជ័យជេស្ឋា ព្រះជន្មបាន ២៣ វស្សាឡើងសោយ
រាជសម្បត្តិ ទទួលព្រះរាជឧង្ការស្នងសម្ដេចព្រះរៀម ទ្រង់ព្រះនាមហៅ
ព្រះបាទសម្ដេចព្រះរាជឧង្ការ ព្រះអង្គទងរាជាធិរាជរាមាធិបតី ស្ដេចគង់
នៅព្រះរាជវាំងឧត្ដុង្គមានជ័យ ស្ដេចទ្រង់បញ្ញត្តិឲ្យអស់នាម៉ឺនមន្ត្រីធំតូច

ទូលក្តីថ្វាយក្តីជាព្រះករុណាវិសេស   កាលណាមានកើងនៅស្រុករលាំងគ្រើល   បះក្បត់ស្តេចៗឲ្យប្រាលប្រាបកបទៅ   ដល់ឆ្នាំថោះបញ្ចស័ក ស្តេចសោយរាជសម្បត្តិបាន៥វស្សា ព្រះជន្មបាន ៤៧ វស្សាក៏សុគតទៅ   ដល់ឆ្នាំរោងឆស័ក   នោះអ្នកអង្គនន់ជាព្រះរាជបុត្រច្បង   សម្តេចព្រះឧទ័យបរមរាជាព្រះជន្មបាន ២១ វស្សា   ឡើងសោយរាជសម្បត្តិ ទទួលព្រះរាជទ្ធាសេងព្រះវៀម   ព្រះអយ្យកោ ១ ទ្រង់ហៅព្រះបាទសម្តេចព្រះរាជទ្ធារ ព្រះបទុមរាជាធិរាជរាមាធិបតី   ស្តេចយកព្រះរាជបុត្រីសម្តេចព្រះជ័យជេដ្ឋាធិរាជគ្រូវជាព្រះអយ្យកោ ១ ជាព្រះអគ្គមហេសី លើកព្រះនាមហៅសម្តេចព្រះភគវតី   ស្រីវរក្សត្រ   ក្នុងឆ្នាំរោងឆស័ក សម្តេចភគវតីព្រះស្រីវរក្សត្រ   ប្រសូតព្រះរាជបុត្រាមួយព្រះអង្គ   ព្រះនាមព្រះជេដ្ឋា ដល់ឆ្នាំម្សាញ់សប្តស័ក   សម្តេចព្រះឧទ័យព្រះបរមរាជ.ជាឧប. យោរាជ ព្រះជន្មបាន ១៦ វស្សា សម្តេចព្រះរាជទ្កាបទុមរាជព្រះជន្មបាន ៤៤ វស្សា ទើបទៅពញាបទជាព្រះរាជបុត្រ:ពៅ សម្តេចព្រះជ័យជេដ្ឋាធិរាជបេញក្សត់ជាសត្រូវ   លុកសម្តេចព្រះឧទ័យបរមរាជា ជាសម្តេចព្រះបិតុច្ឆាខិងសម្តេចព្រះបទុមរាជា   ជាព្រះវៀមព្រះអយ្យកោ ១ ក្សយព្រះជន្មទៅឆ្នាំមមីអដ្ឋស័ក   ទៅពញាបទូព្រះជន្មបាន ២៣ វស្សា   ឡើងសោយរាជសម្បត្តិ   ទទួលព្រះរាជទ្កាសេងសម្តេចព្រះវៀម   ព្រះអយ្យកោ ១ ព្រះនាមហៅព្រះបាទសម្តេចព្រះរាមរាជាមាធិបតី   គង់នៅព្រះរាជវាំងឧដុង្គ

ឰជ័យ ឯអ្នកអង្គអុំមជាព្រះអនុជព្រះអយ្យកោ ១ ជាព្រះរាជបុត្រព្រះឧទ័យបរមរាជាឧបយោរាជ ស្តេចឲ្យជាសម្តេចព្រះកែវហ្វា ឯសម្តេចព្រះកែវហ្វា មានម្ចាស់លាវម្នាក់ឈ្មោះអ្នកម្នាងចន្ទ សម្ពព្រះរាជបុត្រា ១ ព្រះនាមអ្នកអង្គនន់ លុះមកដល់ឆ្នាំចកោស័ក ព្រះបាទសម្តេចព្រះរាមរាជាបរមបពិត្រ ស្តេចសោយរាជសម្បត្តិបាន ១៨ វស្សា នោះអ្នកអង្គអុំមសម្តេចព្រះកែវហ្វា ១ អ្នកអង្គសូរ ១ អ្នកអង្គតន់ ១ តាំង ៣ ព្រះអង្គនេះ ជាព្រះរាជបុត្រសម្តេចព្រះឧទ័យបរមរាជា ឧបយោរាជ ចេញទៅជាសត្រូវនឹងសម្តេច ព្រះរាមាធិបតីនោះ អ្នកអង្គសូរសម្តេចកតវតី ព្រះស្រីវរក្សត្រត្រូវជាសម្តេចព្រះមាតុលា ឲ្យទៅសុំកងទ័ពយួន មកច្បាំងនឹងសម្តេចព្រះរាមាធិបតី នោះកងទ័ពយួនលើកមកជួយច្បាំង ចាប់បានសម្តេចព្រះរាមាធិបតីដាក់ទ្រុងនាំទៅសុគតឯស្រុកយួន ឯអ្នកអង្គអុំមជាសម្តេចព្រះកែវហ្វា កាលដែលទ័ពយួនច្បាំងនោះ ស្តេចក្ស័យព្រះជន្មក្នុងសង្គ្រាមជ័យនោះទៅ ទើបយួនប្រែច្បាំងនឹងអ្នកអង្គសូរ និងអ្នកអង្គតន់ ស្តេចតាំង២ព្រះអង្គស៊ូច្បាំងឈ្នះ ដេញទ័ពយួនតក់ប៉ុះវិលទៅស្រុកយួនវិញ ។ មហាសករាជ ១៥៩៣ ឆ្នាំកុរត្រីស័ក អ្នកអង្គសូរជាព្រះរាជបុត្រព្រះឧទ័យបរមរាជាបយោរាជព្រះជន្មបាន ៣៨ វស្សា ឡើងសោយរាជសម្បត្តិទទួលព្រះរាជឱង្ការស្នងសម្តេចព្រះរៀម ព្រះអយ្យកោព្រះនាមហៅសម្តេចព្រះរាជឱង្ការព្រះបរមរាជាធិរាជរាមាធិបតីបរមបពិត្រ ស្តេចយក

អ្នកអង្គឡើងត្រូវជាព្រះអនុជព្រះវរបិតា ១ ជាព្រះរាជទេពី លើកឡើងជា
អគ្គមហេសី ព្រះនាមហៅសម្តេចព្រះភគវតីព្រះវរក្សត្រី ហើយស្តេច
មានម្ចាស់ ២ ទៀត គឺអ្នកម្ចាស់ពៅសម្តេចព្រះរាជបុត្រា ១ អង្គ ព្រះនាមអ្នក
អង្គជី ។ ដល់ឆ្នាំជូតបញ្ចស័ក អ្នកម្ចាស់ទៃសម្តេចព្រះរាជបុត្រ ១ អង្គព្រះ
នាមពៅពញាសួរ នោះបានទទេនុក្បត់ស្តេច ៗ ឲ្យចាប់សម្លាប់ទៅ ក្នុង
សម្បត្តិនោះមានដំរីញោយ ១ ជាមង្គលគជេន្ទ្រ ដល់ឆ្នាំរោងអដ្ឋស័ក អ្នក
អង្គតន់ជាព្រះអនុជព្រះជន្មបាន ២៨ វស្សា ស្តេចឲ្យព្រះនាមហៅសម្តេច
ព្រះរាមាធិបតីឧបរាជ ឯសម្តេចព្រះបរមរាជា ដល់ឆ្នាំកុរបញ្ចស័ក
នោះ ស្តេចសោយរាជសម្បត្តិបាន ១៣ វស្សា ព្រះជន្មបាន ៥០ វស្សា
នោះព្រះស្រីជ័យជេដ្ឋាជាព្រះភាគិនេយ្យា ចេញជាសត្រូវ លុះសម្តេច
ក្ស័យព្រះជន្មទៅ ឯសម្តេចរាមាធិបតី ជាឧបរាជនឹងអ្នកអង្គនន់ ជា
ព្រះភាគិនេយ្យា ចាញ់ទ័ពរត់ចុះទៅពឹងយួន ឯព្រះស្រីជ័យជេដ្ឋព្រះជន្ម
បាន ៣៣ វស្សា ឡើងសោយរាជសម្បត្តិ ទទួលព្រះរាជឧក្ការស្នង
សម្តេចព្រះបិតុច្ឆាទ្រង់ព្រះនាមហៅព្រះបាទសម្តេចព្រះបទុមរាជាធិរាជរាមា
ធិ_បតី ស្តេចយកអ្នកម្ចាស់ឡ ព្រះនាមសម្តេចព្រះភគវតីត្រូវជាព្រះមាតុ·
ច្ឆា ជាព្រះអគ្គមហេសី ស្តេចសោយរាជសម្បត្តិបាន ៥ ខែ នោះសម្តេច
ព្រះភគវតីព្រះវរក្សត្រីឲ្យរាល់លុកក្ស័យព្រះជន្មទៅ មហាសករាជ ១៦០៧
ឆ្នាំរកាសប្តស័ក នោះអ្នកអង្គធីជាព្រះរាជបុត្រអ្នកអង្គសួរ ព្រះនាមជាស·

ម្តេចព្រះបរមរាជាព្រះជន្មបាន ៣២ វស្សា ឡើងគ្រងរាជសម្បត្តិ ស្នងព្រះរៀមព្រះអយ្យកោ ១ ទ្រង់ព្រះនាមហៅសម្តេចព្រះកែវហ្វា ស្តេចមានម្នាង ១ នាក់ ឈ្មោះអ្នកអង្គពៅ ពីកាលពុំទាន់សោយរាជសម្បត្តិនោះអ្នកម្នាងពៅសម្ភពព្រះរាជបុត្រា ១ ព្រះអង្គ ទ្រង់ព្រះនាមហៅពញាយ៉ង់ ខណៈនោះសម្តេចព្រះរាមាធិបតី ជាឧបយោរាជនិងអ្នកអង្គនន់ ដែលរត់ទៅនៅពឹងយួននោះនាំទ័ពយួនឡើងមកច្បាំងនឹង អ្នកអង្គជីសម្តេចព្រះកែវហ្វាច្បាំងគ្នាពីឆ្នាំជូតសប្តស័ក ដល់ឆ្នាំខាលអដ្ឋស័ក នោះសម្តេចព្រះរាមាធិប-តីឧបយោរាជ នោះនាំទ័ពយួនមកច្បាំង ព្រះជន្មបាន ៥១ វស្សា ទ្រង់អ-ពាធសុវណ្ណគតកំពុងច្បាំង ឯអ្នកអង្គជី សម្តេចព្រះកែវហ្វាទទួលគ្រងរាជ្យបាន ២ វស្សា ព្រះជន្មបាន ៣៣ វស្សា ចាញ់ទ័ពយួនទៅសុគតនៅស្រុកច្រាំងជម្ពីង ក្នុងខេត្តសំរោងទង ឯអ្នកអង្គនន់ដែលនាំកងទ័ពយួនឡើងមកច្បាំងនោះ ស្តេចមកគង់នៅជាមេត្រីនឹងព្រះវង្សានុវង្ស នៅព្រះរាជវាំងឧត្តុង្គឫជ័យ ក្នុងឆ្នាំថោះឯកស័ក ទៅពញាសូរដែលទ្រង់ព្រះនាមហៅព្រះស្រីធម្មរាជានោះ ព្រះជន្មបាន ៤៦ វស្សា ឡើងសោយរាជ្យទទួលព្រះរាជឱង្ការស្នងសម្តេចព្រះរៀម គឺព្រះជ័យជេដ្ឋាបរមសុរិន្ទ ឯអ្នកអង្គនន់ដែលឡើងមកពីស្រុកយួននោះ ព្រះជន្មបាន ៤៧ វស្សា ឡើងឧបយោរាជ ព្រះនាមជាព្រះបរមសុរិន្ទរាជា ត្រូវជាព្រះរៀមព្រះអយ្យកោ ១ និងសម្តេចព្រះជ័យជេដ្ឋាបរមសុរិន្ទ កើតច្បាំងនឹងគ្នា ដល់ឆ្នាំមមែត្រី

ស័ក អ្នកអង្គនន់ជាឧបយោរាជ និងសម្ដេចព្រះជ័យជេដ្ឋា បរមសុរិន្ទ កើតច្បាំងនឹងគ្នា ទើបសម្ដេចព្រះជ័យជេដ្ឋាបរមសុរិន្ទឲ្យនាំសារទៅទូលព្រះធម្មរាជាក្រុងស្រីអយុធ្យា សុំទ័ពសៀមមកច្បាំង នោះអ្នកអង្គនន់ឧប-យោរាជច្បាំងចាញ់រត់ចុះទៅពឹងយួន ៗ កាលនៅស្រុកយួននោះអ្នកអង្គនន់ឧបយោរាជ ស្ដេចមានម្នាង១នាក់ឈ្មោះអ្នកម្នាងឯម ជាកូនចិនចុងគុន ដល់ឆ្នាំរកា ញ្ចស័ក អ្នកម្នាងឯមសម្ភពព្រះរាជបុត្រា ១ អង្គ ឲ្យព្រះនាមហៅអ្នកអង្គអ៊ឹម ឯសម្ដេចព្រះជ័យជេដ្ឋាបរមសុរិន្ទ នាំព្រះរាជវង្សានុវង្ស ចេញពីព្រះរាជវាំងឧត្ដុង្គឫជ័យ ព្រះរាជដំណើរមកសាងព្រះរាជវាំង គង់នៅស្រុកទ្រាំងជើង ខែត្រសំរោងទង ខណៈនោះអ្នកអង្គនន់ឧបយោរាជ ដែលនៅស្រុកយួនរត់ទៅពឹងចិនចុងគុន នាំពលចិនលើកទ័ពមកច្បាំងបានស្រុកក្រោមនាយកាយដល់ស្រុកឧត្ដុង្គឫជ័យទើបសម្ដេចព្រះជ័យជេដ្ឋាបរមសុរិន្ទលើកទ័ពចេញមកទទួលច្បាំង ឈ្នះទ័ពអ្នកអង្គនន់ឧបយោរាជ ៗ រត់ ទៅស្រុកយួនវិញ ហើយសម្ដេចព្រះជ័យជេដ្ឋាបរមសុរិន្ទ ស្ដេចនាំព្រះរាជវង្សានុវង្ស ព្រះរាជដំណើរមកនៅព្រះរាជវាំងឧត្ដុង្គឫជ័យគង់វិញ លុះដល់ឆ្នាំជូតអដ្ឋស័ក នោះអ្នកអង្គនន់ឧបយោរាជ ដែលនៅស្រុកយួន នាំទ័ពចិនពីស្រុកយួនឡើងមក បញ្ចុះបញ្ចូលបានស្រុកស្រីសឈរ ហើយសាងព្រះរាជវាំងគង់នៅស្រុកស្រីសឈរ ហើយឲ្យលើកទ័ពមកច្បាំងនឹងសម្ដេចព្រះជ័យជេដ្ឋាបរមសុរិន្ទ ច្បាំងនឹងគ្នាពីឆ្នាំជូតដល់ឆ្នាំម្សាញ់

ពុំបាញ់ពុំឈ្នះថយទ័ពទៅដោយខ្លួន ឯសម្តេចព្រះជ័យជេដ្ឋាបរមសុរិន្ទ ព្រះជន្មបាន ២៧ វស្សា កើតព្រះរាជកណ្តាំពេក នោះស្តេចព្រះបរិន្ទរាជសម្បត្តិថ្វាយសម្តេចព្រះវររាជជននីនាថគ្រង លុះគណ្ឋិពេកសះជាស្បើយហើយ ស្តេចទ្រង់ព្រះផ្នួសបាន ៧ ថ្ងៃ ដាក់ព្រះផ្នួសចេញ លុះដល់ឆ្នាំកេងតោស័ក លើកទ័ពធ្វើថយមកបោះនៅបន្ទាយជ្រោយចង្វារ នោះសម្តេចនៅពញាកាន់ជានាម៉ឺន ១ ចិនតាន់ចុងអៀម ក្បត់ស្តេចក្នុងព្រះរាជមន្ទីរ ១ ចេញជាសត្រូវនឹងសម្តេចព្រះជ័យជេដ្ឋាបរមសុរិន្ទ ហើយនៅពញាកាន់និងចិនតាន់ចុងអៀម រត់ចូលទៅពឹងអ្នកអង្គនន់ឧបយោរាជ ឯព្រះរាជវាំងស្រុកស្រីសឈរ នោះអ្នកអង្គនន់ឧបយោរាជ ប្រើឲ្យសម្តេចនៅពញាកាន់និងចិនតាន់ចុងអៀម ឲ្យនាំពលខ្មែរចិនលើកទ័ពមកច្បាំង នឹងសម្តេចព្រះជ័យជេដ្ឋាបរមសុរិន្ទ ច្បាំងឈ្នះបានសំពៅ ២ ផង ហើយសម្តេចព្រះជ័យជេដ្ឋាបរមសុរិន្ទ យកអ្នកអង្គអុំជាព្រះរាជបុត្រាសម្តេចព្រះបទុមរាជា ជាព្រះគងនេយ្យា ដែលជាប់មកនឹងសំពៅជាព្រះរាជទេពី លុះដល់ឆ្នាំម្សាញ់ត្រីស័ក អ្នកអង្គនន់ឧបយោរាជឲ្យទៅសុំទ័ពយួន លើកមកច្បាំងនឹងសម្តេចព្រះជ័យជេដ្ឋាបរមសុរិន្ទទៀត ឯសម្តេចព្រះជ័យជេដ្ឋាបរមសុរិន្ទច្បាំងឈ្នះទៀត ដេញទ័ពយួនរត់ទៅចុះនៅស្រុកយួនវិញ ទើបសម្តេចព្រះជ័យជេដ្ឋាបរមសុរិន្ទ ស្តេចទទួលយកព្រះរាជសម្បត្តិ គឺពីព្រះវររាជជននីនាថមកវិញ ទ្រង់ព្រះនាមជាព្រះបាទសម្តេចព្រះរាជឱង្ការ ព្រះជ័យជេ-

ហ្ម បរមសុរិន្ទ្រាធិរាជរាមាថ ស្សួរ ស្ដេចលើកអ្នកអ៊ុំឡើងជាអគ្គមហេសី
ហៅសម្ដេចព្រះកត្តតីស្រីបរមចក្រពត្តិរាជក្សត្រី លុះដល់ឆ្នាំរកាសប្ដស័ក
សម្ដេចព្រះនាងទ្រង់គភ៌ប្រសូតព្រះរាជបុត្រា ១ អង្គ ព្រះនាមពុំប្រាកដ
ដល់ឆ្នាំមមែបញ្ចស័ក ប្រសូតព្រះឱរសមួយអង្គ ព្រះនាមជាស្រីធម្មរាជា
សម្ដេចព្រះបទុម គឺអ្នកអង្គនន់ ឧបយោរាជព្រះជន្មបាន ៥៧ វស្សា ទ្រង់
ព្រះពាធសុគតទៅ នៅព្រះរាជវាំងស្រីសឈរ នោះព្រះវង្សាចាមនាំពល
វាច្រើនមកនៅជាចំណុះ សម្ដេចព្រះជ័យជេស្ឋា បរមសុរិន្ទ្រាធិរាជឥស្សូរ
ទីបស្ដេចបង្វែររាជសម្បត្តិឲ្យទៅនៅពញាយន់ ជាព្រះរាជបុត្រអ្នកអង្គធីជា
សម្ដេចព្រះកែវហ្វា ឯចៅពញាយន់ព្រះជន្មបាន ២៣ វស្សា ឡើងសោយ
រាជសម្បត្តិ ស្ដេចយកព្រះជាតក្សត្រីជាព្រះរាជបុត្រី សម្ដេចព្រះបទុមរា-
ជាធិរាជ ត្រូវជាមាតុច្ឆា ជាព្រះជាយា ពីកាលឆ្នាំកុរឆស័ក សម្ដេចព្រះ
ជាតក្សត្រីប្រសូតព្រះរាជបុត្រ ១ អង្គ ព្រះនាមអ្នកអង្គតន់ ឯសម្ដេចព្រះ
ជេស្ឋាបរមសុរិន្ទ្រាធិរាជ បង្វែររាជសម្បត្តិចេញហើយ ស្ដេចទ្រង់ព្រះ
ផ្នួសបាន ៥ ថ្ងៃដាក់ព្រះផ្នួសមកវិញ ដល់ឆ្នាំជូតអដ្ឋស័កសម្ដេចព្រះរាជ
ឱង្ការរាមាធិបតីសោយរាជសម្បត្តិបាន ២ វស្សាសុវណ្ណគតទៅ ។ មហា
សករាជ ១៦១៩ ឆ្នាំជូតនព្វស័ក នោះសម្ដេចព្រះជ័យជេស្ឋាបរមសុរិន្ទ្រាធិ-
រាជទទួលរាជសម្បត្តិមកវិញ ក្នុងរាជសម្បត្តិនោះមានដំរី ១ ជាមង្គល
ហាក៏ទើបស្ដេច ឲ្យទៅវាលបាក់អ្នកអង្គអ៊ុំ ជាព្រះរាជបុត្រអ្នកអង្គនន់ទប

យោរាជ អំពីស្រុកយួនឡើងមកនៅជាមួយផង ហើយស្តេចឲ្យសម្តេចព្រះមហាក្សត្រីជាព្រះរាជបុត្រីស្តេច ១ ឲ្យជាព្រះអគ្គជាយាអ្នកអង្គអិម ឯអ្នកអង្គអិមព្រះជន្មបាន ១៦ វស្សា ស្តេចឲ្យឡើងជាសម្តេចព្រះកែវហ្វា ដល់ឆ្នាំថោះឯកស័ក កែនេនអិមជាកូនៗកញ្ញាមហាសេនាមុញចេញជាសត្រូវក្បត់ស្តេចរត់ទៅពឹងយួនសុំទ័ពលើកមកច្បាំង ឯសម្តេចព្រះជ័យជេស្ឋាបរមសុរិន្ទ្រាធិរាជនាំព្រះរាជវង្សានុវង្សព្រះរាជដំណើរចេញ ពីព្រះរាជវាំងទុគ្គពុជ័យទៅគង់ឯខែត្រពោធិសាត់ ឯកែនេនអិមនាំទ័ពយួនលើកតាមទៅច្បាំងដល់ខែត្រពោធិសាត់ នោះសម្តេចព្រះជ័យជេស្ឋាបរមសុរិន្ទ្រាធិរាជស្តេចចេញទទួលច្បាំងឈ្នះចាប់បានកែនេនអិមប្រហារជីវិតស្លាប់ទៅ ពួកកងទ័ពយួនក៏រត់ចុះទៅស្រុកយួនវិញ លុះដល់ឆ្នាំរោងទោស័កសម្តេចព្រះជ័យជេស្ឋាបរមសុរិន្ទ្រាធិរាជ ស្តេចបន្ទូររាជសម្បត្តិឲ្យអ្នកអង្គអិមសម្តេចព្រះកែវហ្វាគ្រងដល់ឆ្នាំម្សាញ់ត្រីស័ក នោះសម្តេចព្រះជេស្ឋាបរមសុរិន្ទ្រាធិរាជចេញទ្រង់ព្រះផ្នួសនៅវត្តពោធិមានបុណ្យបាន ៣ ថ្ងៃ ដាក់ព្រះផ្នួសចេញវិញ នោះសម្តេចព្រះកែវហ្វាថ្វាយរាជសម្បត្តិមកវិញ ហើយស្តេចបន្ទូររាជសម្បត្តិឲ្យសម្តេចព្រះស្រីធម្មរាជាគ្រងវិញ កាលណាមានសម្រែនៅប្រុកកុឡាបះក្បត់ស្តេច ១ ក្រាលព្រះរាជទៅ ដល់ឆ្នាំមមែបញ្ចស័ក នោះស្តេចព្រះជ័យជេស្ឋាបរមសុរិន្ទ្រាធិរាជ ព្រះរាជឿនព្រះរាជបុត្រលើកគ្រប់គ្រងព្រះរាជដំណើរ ចេញពីព្រះរាជវាំងខេត្តពោធិសាត់មករៀប

( [illegible] )